របាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សប្រចាំតំបន់ ឆ្នាំ ២០០៦

# ពាណិជ្ជកម្មផ្អែកលើកត្តាមនុស្ស

## ការបំប្លែងពាណិជ្ជកម្មដើម្បីការអភិវឌ្ឍមនុស្សនៅអាស៊ីនិងប៉ាស៊ីហ្វិក

UNDP

J-MOI-KT0041





ខ្លឹមសារនៃពាណិជ្ជកម្មដែលជាសកម្មភាពជំនួញ ត្រូវបានឆ្លាក់ជាម៉ូតនៅលើកាក់លោហៈធាតុ និង ជាស្នូលនៃលក្ខខណ្ឌរបស់មនុស្ស ដែលបង្កើតឡើងដោយដៃមនុស្ស ។ ទំនាក់ទំនងទៅមកដ៏សាំញ៉ាំ និង ឌីណាមិក កើតមានរវាងពាណិជ្ជកម្ម និងការអភិវឌ្ឍមនុស្ស ពោលគឺ តើអ្នកទាំងនោះគឺជានរណា និងតើពួកគេអាចក្លាយទៅជាអ្វី ។ ប្រការចាំបាច់ គឺត្រូវធ្វើឱ្យមានតុល្យភាពរវាងពាណិជ្ជកម្មដែលបំពេញតួនាទីរបស់ខ្លួនជាសកម្មភាពជំនួញ និងសក្តានុពលរបស់វាសម្រាប់លើកកម្ពស់កំណើន ដើម្បីកាត់បន្ថយភាពក្រីក្រ កាត់បន្ថយវិសមភាព និងពង្រឹងការអភិវឌ្ឍធនធានមនុស្ស ។

# របាយការណ៍ ស្ដីពី ការអភិវឌ្ឍមនុស្សនៅអាស៊ី-ប៉ាស៊ីហ្វិក ឆ្នាំ ២០០៦

## ពាណិជ្ជកម្មផ្អែកលើកត្តាមនុស្ស

ការបំប្លែងពាណិជ្ជកម្ម ដើម្បីអភិវឌ្ឍមនុស្ស

នៅអាស៊ី និង ប៉ាស៊ីហ្វិក

UNDP

បោះពុម្ពផ្សាយសម្រាប់
កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

MACMILLAN

315.96
HDR 2006
sh: statistics

library.ncdd.gov.kh
014652

រក្សាសិទ្ធិ ២០០៦

ដោយ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ
មជ្ឈមណ្ឌលប្រចាំតំបន់នៅទីក្រុងកូឡុំបូ ផ្នែកអភិវឌ្ឍន៍មនុស្ស
២៣ រុក្ខវិថី ឯករាជ្យ ទីក្រុង កូឡុំបូ ៧ ប្រទេសស្រីលង្កា

រក្សាសិទ្ធិគ្រប់យ៉ាង។ គ្មានផ្នែកណាមួយនៃឯកសារនេះអាចត្រូវផលិតឡើងវិញ ឬបញ្ជូនបន្ត តាមទម្រង់ណាមួយ ឬតាមមធ្យោបាយណាមួយ ដោយគ្មានការអនុញ្ញាតជាមុននោះឡើយ។
បុគ្គលណាក៏ដោយ ដែលធ្វើសកម្មភាពដោយពុំមានការអនុញ្ញាត ទាក់ទងនឹងការបោះពុម្ពឯកសារនេះ អាចត្រូវផ្តន្ទាទោសក្រោមច្បាប់ព្រហ្មទណ្ឌ និងសងការខូចខាត។

បោះពុម្ពផ្សាយលើកទីមួយ ឆ្នាំ ២០០៦

បោះពុម្ពផ្សាយសម្រាប់ UNDP ដោយ Macmillan India Ltd.
សៀវភៅនេះមិនមែនសម្រាប់លក់ក្រោមរូបភាពជាជំនួញនោះទេ។

**MACMILLAN INDIA LTD.**
Delhi Chennai Jaiput Mumbai Tatna Bangalore
Bhopal Chandigarh Coimbatore Cuttack Guwahati
Hubli Hyderabad Lucknow Madurai Nagpur Pune
Raipur Thiruvananthapuram Visakhapatnam

ISBN CORP-000036

Published by Rajiv Beri for Macmillan India Ltd.
2/10 Ansari Road, Daryagam, New Delhi 110 002

Printed at Sanat Printers
312 EPIP, Kundli 131 028

## ក្រុមការងាររៀបចំ
## របាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សនៅអាស៊ី-ប៉ាស៊ីហ្វិក ឆ្នាំ ២០០៦

### ប្រធានក្រុម

អានូវ៉ាដា រ៉ាជ្ជីវ៉ាជ្ជីវ៉ន

ក្រុមស្នូលៈចាន់ដ្រាសិការ, រ៉ាម៉េសប្រ្កាំផាត, អាជីឡា អ៊ុមជិន និងជូន ឡុងលំ

អ្នកពិនិត្យផ្ទៀងផ្ទាត់ : ភីធី ស្តុកឃី

ទីប្រឹក្សាផ្នែកស្ថិតិ : អាមីតា គុនដូ

ក្រុមការងារផ្នែកស្ថិតិ : រស្មី បង់កា កាល់ប៉ាណា ជូដារី និក នីរ៉ាន់ចាន់សារ៉ាន់ជី

រចនាក្រប : រ៉ូស វ៉ានៀ

ពិនិត្យផ្ទៀងផ្ទាត់ផ្នែកបច្ចេកទេស និងផលិតៈ Macmillan India Ltd.

**ផ្នែកអភិវឌ្ឍន៍មនុស្សនៅអាស៊ីប៉ាស៊ីហ្វិក (HDU)**

**មជ្ឈមណ្ឌលប្រចាំតំបន់នៅក្រុងកូឡុំបូ (RCC)**

របាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សនៅអាស៊ី-ប៉ាស៊ីហ្វិក ឆ្នាំ ២០០៦ គឺជាលទ្ធផលនៃកិច្ចប្រឹងប្រែងប្រកបដោយការសហការ។ សមាជិកផ្សេងទៀតនៃ HDU ដែលបានចូលរួមក្នុងការរៀបចំរបាយការណ៍នេះរួមមានៈ ស៊ូសាន ហ៊ូ និង រ៉េណាតា រ៉ូបៀន ។ ក្រុមចាត់ចែងការងាររដ្ឋបាលនៃ HDU ដែលបានផ្តល់ការគាំទ្រក្នុងការរៀបចំរបាយការណ៍នេះរួមមាន រ៉ូវ៉ាន់ជី សេណារ៉ាដ និង រ៉េហាណា ខាត់ទីឡាន់។ ខេយ ឃីបី ដរជី បានជួយក្នុងការងារអប់រំ និងផ្សព្វផ្សាយ។

# បុព្វកថា

ពាណិជ្ជកម្មអន្តរជាតិបានក្លាយជាគ្រឿងយន្តសម្រាប់កំណើនសេដ្ឋកិច្ចនៃប្រទេសជាច្រើននៅអាស៊ីនិងប៉ាស៊ីហ្វិក។ "ភាពអស្ចារ្យខាងសេដ្ឋកិច្ច" នៃ "ខ្លា" អាស៊ីបូព៌ាបានកើតឡើងភាគច្រើនដោយសារសមត្ថភាពនៃតំបន់នេះ ក្នុងការនាំចេញទៅកាន់ទីផ្សារនានាលើពិភពលោក និងការបង្កើនផលិតកម្មទ្រង់ទ្រាយធំ ដោយមានបច្ចេកវិទ្យា ដែលនាំឱ្យមានប្រាក់ចំណូលខ្ពស់។ ភាពក្រីក្របានថយចុះជាទូទៅនៅក្នុងតំបន់នេះ ហើយប្រជាពលរដ្ឋជាច្រើនរយលាននាក់ បានលើកកម្ពស់គុណភាពនៃការរស់នៅរបស់ខ្លួនយ៉ាងច្រើន។

ប៉ុន្តែ ប្រជាពលរដ្ឋខ្លះមិនបានទទួលកំណែលំអការកែប្រែជីវភាពរស់នៅដូចខាងលើនេះទេ។ ប្រទេសតូចៗមួយចំនួននៅក្នុងតំបន់នេះ ជាពិសេសបណ្តាប្រទេសដែលអភិវឌ្ឍន៍តិចតួច (LDCs) ពុំបានទទួលផលចំណូលច្រើនពីពាណិជ្ជកម្មនៅឡើយទេ។ ប្រជាពលរដ្ឋក្រីក្រនៅក្នុងតំបន់នេះ បានទទួលរងគ្រោះដោយសារភាពមិនរីកចម្រើនខាងផ្នែកកសិកម្មនៅពេលដែលភាពសំបូរស្តុកស្តម្ភថ្មីនៃទីផ្សារនៅលើពិភពលោកខកខានមិនមានឥទ្ធិពលដល់ទីជនបទដែលជាកន្លែងប្រជាពលរដ្ឋក្រីក្រភាគច្រើនរស់នៅ។ សូម្បីតែ នៅក្នុងបណ្តាប្រទេសដែលមានកំណើនសេដ្ឋកិច្ចឆាប់រហ័សក្តី ពាណិជ្ជកម្មបានពង្រីកគម្លាតរវាងគ្នានៅក្នុងតំបន់ វិស័យ និង គ្រួសារនានា។ សេដ្ឋកិច្ចនៃប្រទេសជាច្រើន ជាពិសេសនៅតំបន់អាស៊ីបូព៌ា ពុំមានសមត្ថភាពក្នុងការបង្កើតការងារឱ្យបានគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន ដែលមានចំនួនកាន់តែកើនឡើងនោះឡើយ ជាពិសេសសម្រាប់ពួកមនុស្សក្មេងៗ និង ស្ត្រី។

ការប្រកាសរបាយការណ៍អភិវឌ្ឍន៍មនុស្សនៅអាស៊ី-ប៉ាស៊ីហ្វិក ឆ្នាំ២០០៦ ដែលមានចំណងជើងថា **ពាណិជ្ជកម្មផ្អែកលើកត្តាមនុស្ស** បានធ្វើឡើងនៅក្នុងពេលសំខាន់មួយដែលនៅសល់តែប៉ុន្មានខែទៀតតែប៉ុណ្ណោះ មុនពេលដល់ឱសានវាទទាពេលចុងឆ្នាំ ដើម្បីបញ្ចប់របៀបវារៈនៃកិច្ចចរចានៅទីក្រុងដូហា ស្តីពីការអភិវឌ្ឍ។ យើងកំពុងស្ថិតនៅចំណុចកណ្តាលនៃកម្មវិធីសកម្មភាពទីក្រុងប្រ៊ុចសែលរយៈពេល ១០ឆ្នាំ សម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួចជាងគេ និងនៅសល់ពេលត្រឹមតិចជាងមួយទសវត្សរ៍ប៉ុណ្ណោះ ដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

ដូចដែលយើងអាចឃើញក្នុងរបាយការណ៍នេះ ការលំបាកជាច្រើននៅតែត្រូវប្រឈមនៅឡើយ។ ចំណងទាក់ទងរវាងពាណិជ្ជកម្ម ការអភិវឌ្ឍមនុស្ស និងការកាត់បន្ថយភាពក្រីក្រ មានភាពទន់ខ្សោយនៅឡើយ។ នាពេលនេះ សមាជិកភាពនៃអង្គការធនាគារពិភពលោក WTO បានបង្កការលំបាកសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការចែករំលែកផលចំណេញពីសកលភាវូបនីយកម្ម។ កំណើនយ៉ាងខ្លាំងនៃសេដ្ឋកិច្ចក្នុងប្រទេសចិន ដែលជាក្តីសង្ឃឹមសម្រាប់បណ្តាប្រទេសជិតខាងនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក មិនបានផ្តល់ផលចំណេញទៅវិញទៅមកដល់ដៃគូពាណិជ្ជកម្ម នៅក្នុងតំបន់របស់ខ្លួននោះឡើយ ហើយក្នុងករណីខ្លះ បានបង្កការលំបាកសម្រាប់ប្រទេសទាំងនោះថែមទៀតផង។ សារគន្លឹះមួយក្នុងចំណោមសារជាច្រើននៅក្នុងរបាយការណ៍នេះចង់បង្ហាញថា ជោគជ័យនៅលើទីផ្សារពិភពលោកបាននាំមកជាមួយនូវកាលានុវត្តភាពថ្មី និងការទទួល

ខុសត្រូវផងដែរ ជាពិសេស សម្រាប់ប្រជាជាតិដែលមានការអភិវឌ្ឍតិចតួច។

ដោយផ្អែកលើទស្សនៈវិស័យរបស់តំបន់អាស៊ី-ប៉ាស៊ីហ្វិក របាយការណ៍នេះពិនិត្យមើលភាពចាំបាច់ដែលត្រូវផ្លាស់ប្តូរនៅក្នុងប្រព័ន្ធពាណិជ្ជកម្មពិភពលោក ដូចដែលបានប្រមើលឃើញនៅក្នុងភាពជាដៃគូសម្រាប់ការអភិវឌ្ឍ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ របាយការណ៍នេះផ្អែកលើបទពិសោធខុសៗគ្នានៅក្នុងតំបន់នេះ ដើម្បីស្នើឱ្យមានយុទ្ធសាស្ត្រអភិវឌ្ឍន៍ទូលំទូលាយ ដែលរួមបញ្ចូលយ៉ាងមានប្រសិទ្ធិភាពនូវសេរីភាវូបនីយកម្មពាណិជ្ជកម្ម ជាមួយការលើកកម្ពស់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍមនុស្ស។

ពាណិជ្ជកម្មផ្អែកលើកត្តាមនុស្ស ក៏ធ្វើអត្តសញ្ញាណផងដែរ នូវចំពូកគោលនយោបាយដែលចាំបាច់សម្រាប់ធានាថាប្រជាពលរដ្ឋទាំងអស់បានទទួលអត្ថប្រយោជន៍ដែលពាណិជ្ជកម្មផ្តល់ឱ្យ។ អនុសាសន៍គោលនយោបាយបែបនេះរួមមាន ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ការអប់រំជាន់ខ្ពស់ និងការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) ដើម្បីធ្វើការប្រកួតប្រជែង ការប្រកាន់យកគោលនយោបាយជាយុទ្ធសាស្ត្រសម្រាប់ពាណិជ្ជកម្ម និងឧស្សាហកម្ម ការយកចិត្តទុកដាក់ឡើងវិញលើផ្នែកកសិកម្ម និងការអភិវឌ្ឍជនបទ និងវិធានការនានាដើម្បីប្រឆាំង "កំណើនភាពគ្មានការធ្វើ"។ គំនិតនានា នៅក្នុងរបាយការណ៍នេះ អាចរួមចំណែកទៅក្នុងការធ្វើឱ្យសកលភាវូបនីយកម្មកាន់តែប្រសើរឡើង ពោលគឺសកលភាវូបនីយកម្មដែលផលអត្ថប្រយោជន៍សម្រាប់ទាំងអស់គ្នា ទាំងនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងនៅក្នុងពិភពលោកទាំងមូល។

ការប្រកាសអំពីពាណិជ្ជកម្មផ្អែកលើកត្តាមនុស្ស កត់សម្គាល់នូវរបត់មួយសម្រាប់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិផងដែរ ពោលគឺការវិវត្តនៃរបាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សនៅអាស៊ីប៉ាស៊ីហ្វិក ទៅជារបាយការណ៍ប្រចាំឆ្នាំ។ យើងរំពឹងថារបាយការណ៍ប្រចាំឆ្នាំថ្នាក់តំបន់នេះ នឹងផ្តល់ការវិភាគជាបន្តទៀត អំពីបញ្ហាសំខាន់ៗនៃការអភិវឌ្ឍដែលបង្ហាញថាមានការពាក់ព័ន្ធយ៉ាងខ្លាំង ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ។

**ភាម៉ាល់ ឌេវីស**

ប្រធាន កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

ការវិភាគ និងអនុសាសន៍អំពីគោលនយោបាយនៅក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ក្រុមប្រឹក្សាប្រតិបត្តិនៃកម្មវិធីនេះ ឬបណ្តារដ្ឋជាសមាជិកនៃកម្មវិធីនេះឡើយ។ របាយការណ៍នេះ គឺជាការបោះពុម្ពផ្សាយដោយឯករាជ្យ ដែលចាត់ចែងឡើងដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។ នេះជាលទ្ធផលបានពីកិច្ចប្រឹងប្រែងប្រកបដោយការសហការគ្នា រវាងក្រុមអ្នកជំនាញការល្បីៗ អ្នកពាក់ព័ន្ធនានា និងក្រុមការងារនៃផ្នែកអភិវឌ្ឍន៍មនុស្សរបស់មជ្ឈមណ្ឌលប្រចាំតំបន់នៅទីក្រុងកូឡុំបូ។

# អារម្ភកថា

នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ពាណិជ្ជកម្មត្រូវបានគេបង្ហាញឱ្យឃើញថាអាចផ្តល់នូវការងារ និងប្រាក់ចំណូលខ្ពស់សម្រាប់មនុស្សជាច្រើនលាននាក់។ ទន្ទឹមនឹងនេះ ប្រជាពលរដ្ឋជាច្រើននៅពុំទាន់បានទទួលប្រយោជន៍នៅឡើយទេ រួមទាំងកសិករក្រីក្រដែលពុំមានលទ្ធភាព ដោយសាររបាំងពាណិជ្ជកម្ម និងថ្លៃកសិផលដែលស្ថិតនៅក្រោមការគៀបសង្កត់ កម្មករដែលបាត់បង់ការងារពីឧស្សាហកម្មក្នុងស្រុកដោយសារការកាត់បន្ថយអត្រាពន្ធលើផលិតផលដែលមានភាពប្រកួតប្រជែងក្នុងការនាំចូល ស្ត្រីដែលគួរតែទទួលប្រាក់កម្រៃខ្ពស់ និងធ្វើការក្នុងលក្ខខណ្ឌប្រសើរជាងមុន ប៉ុន្តែដែលប្រឈមនឹងហានិភ័យនៃការបង្ខំឱ្យប្តូរទីកន្លែង ដោយសារការលុបចោលកូតាលើវាយនភណ្ឌ និងកម្មករឯនាយសមុទ្រដែលចាកចោលគ្រួសារនឹងប្រឈមជាមួយការរើសអើង និងការកេងប្រវ័ញ្ច ដើម្បីទៅស្វែងរកការងារក្រៅប្រទេស ដែលអាចលើកកម្ពស់ជីវភាពរស់នៅក្នុងប្រទេស។

របាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សនៅអាស៊ី-ប៉ាស៊ីហ្វិក ឆ្នាំ ២០០៦ ត្រូវបានរៀបចំឡើងដោយប្រជាពលរដ្ឋ និងសម្រាប់ប្រជាពលរដ្ឋនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ របាយការណ៍នេះព្យាយាមបង្ហាញឱ្យឃើញច្បាស់អំពីបញ្ហាទាក់ទងនឹងពាណិជ្ជកម្ម ដែលធ្វើឱ្យប្រជាពលរដ្ឋទូទៅគ្រប់លំដាប់ថ្នាក់ បានយល់កាន់តែច្រើនឡើងអំពីពាណិជ្ជកម្ម ដែលអាចសម្រួលឱ្យមានការជជែកវែកញែក និងការតស៊ូមតិប្រកបដោយការយល់ដឹងកាន់តែច្រើនអំពីបញ្ហានេះ។ ក្នុងន័យនេះ យើងសង្ឃឹមថា របាយការណ៍នេះនឹងជួយលើកកម្ពស់ការអភិវឌ្ឍមនុស្សនៅក្នុងតំបន់នេះ ដោយផ្តោតជាពិសេសលើការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

ខ្ញុំជឿជាក់យ៉ាងមោះមុតថា របាយការណ៍នេះគឺជាផលិតផលដែលបានពីការគិតគូរតាមបែបធម្មជាតិរបស់មនុស្សជាច្រើនរយនាក់នៅក្នុងតំបន់នេះ ដែលមានអ្នកជំនាញការ អ្នកវិភាគ មន្ត្រីរដ្ឋាភិបាល តំណាងនៃអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងផ្នែកឯកជន ព្រមទាំងប្រជាពលរដ្ឋជាច្រើនដែលមានវប្បធម៌ខុសៗគ្នា។

របាយការណ៍នេះមិនត្រឹមតែបានផ្អែកលើការសិក្សាអំពីបញ្ហា និងស្ថានភាពទៅតាមប្រទេស ព្រមទាំងឯកសារដែលចាត់ចែងរៀបចំឡើងដោយ UNDP ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្អែកលើយោបល់ទាក់ទងនឹងវិធាន និងខ្លឹមសារដែលទទួលបាននៅក្នុងសិក្ខាសាលាមួយចំនួននៅថ្នាក់តំបន់ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងកិច្ចប្រជុំបច្ចេកទេសនានា។ ហេតុនេះ ដំណើរការនៃការប្រមូលយោបល់ និង គំនិតពីប្រភពខុសៗគ្នា ដែលមានការយល់ដឹងនៅក្នុងតំបន់នេះ មានលក្ខណៈពេញលេញនិងសំបូរបែប។

សំណួរនានាដូចតទៅនេះ បានផ្តល់ការលើកទឹកចិត្តសម្រាប់របាយការណ៍នេះ មាន តើសេរីភាវូបនីយកម្មខាងពាណិជ្ជកម្មមានឥទ្ធិពលបែបណាចំពោះលក្ខខណ្ឌរបស់ស្រទាប់សង្គមមនុស្សដែលក្រីក្រជាងគេ? តើការពង្រីកពាណិជ្ជកម្មរួមវិភាគទានចំពោះកំណើនយ៉ាងខ្ពស់នៃភាពមានការងារធ្វើ និងការកាត់បន្ថយភាពក្រីក្រដែរឬទេ? សេចក្តីសន្និដ្ឋានបង្ហាញថាចំណងទាក់ទងទាំងនេះមិនកើតឡើងដោយស្វ័យប្រវត្តិនោះទេ

និងទាមទារឱ្យមានការច្នៃប្រឌិត តាមរយៈការផ្លាស់ប្តូរទៅរកផ្លូវល្អ នៅក្នុងរបបពាណិជ្ជកម្មអន្តរជាតិ និងគោលនយោបាយក្នុងស្រុកឱ្យបានសមស្រប។

មេដឹកនាំនានានៅក្នុងកិច្ចប្រជុំកំពូលថ្មីៗនេះ របស់សហប្រជាជាតិបានសម្រេចថា នឹងប្រឹងប្រែងឱ្យអស់លទ្ធភាព ដើម្បីរំដោះមនុស្សជាតិពីស្ថានភាពអស់សង្ឃឹម និងអមនុស្សធម៌នៃភាពក្រីក្រធ្ងន់ធ្ងរ។ យើងអាចផ្តល់វិភាគទានយ៉ាងច្រើនដើម្បីបំពេញតាមការសន្យានេះ និងផ្តល់នូវប្រយោជន៍ដល់កសិករ ស្ត្រី កម្មករតាមរោងចក្រ កម្មករនៅក្រៅប្រទេស និងអ្នកដទៃទៀត ដែលរហូតមកដល់ពេលនេះ នៅពុំទាន់បានទទួលការយកចិត្តទុកដាក់នៅឡើយ ដោយការធានាថា ពាណិជ្ជកម្មមានន័យសម្រាប់មនុស្ស និង លើកកម្ពស់ការរស់នៅសម្រាប់មនុស្សទាំងអស់គ្នា។

**ហាហ៊ីស ប៉ាស្ហា**

នាយក

ការិយាល័យប្រចាំតំបន់សម្រាប់អាស៊ី និង ប៉ាស៊ីហ្វិក

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះគឺជាលទ្ធផលបានពីកិច្ចសហប្រតិបត្តិការពិតប្រាកដ។ មានមនុស្សជាច្រើនដែលសមនឹងបានទទួលការកោតសរសើរ និងដែលបានរួមវិភាគទានតាមវិធីខុសៗគ្នាជាច្រើន ហើយពុំមានការប្រឹងប្រែងណាមួយដើម្បីទទួលស្គាល់ឱ្យបានពេញលេញនូវវិភាគទានទាំងនោះ អាចផ្តល់នូវភាពយុត្តិធម៌បានឡើយ។ ទោះជាយ៉ាងនេះក្តី យើងចាំបាច់ត្រូវទទួលស្គាល់ឱ្យបានច្រើនតាមតែអាចធ្វើទៅបាននូវការរួមវិភាគទានទាំងនោះ។ Hafiz Pasha បានលើកទឹកចិត្ត និងតម្រង់ទិសការងារនេះ ថែមទាំងបានផ្តល់យោបល់ល្អៗជាច្រើន។ របាយការណ៍នេះក៏បានទទួលយោបល់ជាក់លាក់ពី Kemal Dervis ប្រធាន UNDP ផងដែរ។ សហសេវិកនៅក្នុង RCC បានផ្តល់យោបល់និងការគាំទ្រជាបន្តបន្ទាប់ចំពោះដំណើរការនេះ។

## អ្នករួមវិភាគទាន

ការសិក្សាជាច្រើនអំពីទិដ្ឋភាពនានា ឯកសារសំណេរសេចក្តីព្រាង កំណត់ហេតុនានាអំពីបញ្ហាជាច្រើន បានផ្តល់ជាចំណែកនៃរបាយការណ៍នេះ។ អ្នករួមវិភាគទានចម្បងៗគឺ Ratnakar Adhikari, Homi S. Aibara, Anu Bhasin, Rupa Chanda, c.P. Chandrasekhar, Uttam Deb, Biswajit Dhar, Ramesh Gampat, Jayati Ghosh, Murray Gibbs, Komal Gopalani, Vu Quoc Huy, Sanath Jayanetti, Mumtaz Keklik, Mohan Kumar, Kamal Malhotra, Sebastian Mathew, Manuel Montes, Syed Nawab Haider Naqvi, Omar Noman, Pedro Ortega, Thangavel Palanivel, Hafiz Pasha, Minh Pham, Abdul Aziz Rahman, Mustafizur Rahman, Anuradha Rajivan, Miho Shirotori, Ruangrai Tokrisna, Lam Quoc Tuan, Tereso S. Tullao, Nguyen Viet Vinh nig Swarnim Wagle ។

## ការពិគ្រោះយោបល់បច្ចេកទេស

របាយការណ៍នេះក៏ផ្អែកលើយោបល់ និង គំនិត ដែលបានលើកឡើងនៅក្នុងការពិគ្រោះយោបល់បច្ចេកទេសជាច្រើននៅថ្នាក់តំបន់ ដែលមានការផ្តល់យោបល់ពីសំណាក់អ្នកជំនាញការនៅក្នុង និងមកពីក្រៅ UNDP ផងដែរ។ អ្នកចូលរួមនៅក្នុងការពិគ្រោះយោបល់ទាំងនោះរួមមាន : Rashmi Banga, Anuradha Bhasin, Elena Borsatti, Javed Burki, Jolita Butkeviciene, Rupa Chanda, c.P. Chandrasekhar, Kay Kirby Dorji, Ramesh Gampat, Jayati Ghosh, Murray Gibbs, Cherie Hart, Cristina Hernandez, Susan Howes, Achila Imchen, T. Indrani, Mumtaz Keklik, Aileen K wa, Marie Laberge, David Luke, Kamal Malhotra, Sebastian Mathew, Manuel Montes, B. Murali, Napoleon Navarro, Omar Noman, Pedro Ortega, Thangavel Palanivel, Hafiz Pasha, Minh Pham, Syed Ayub Qutub, Anuradha Rajivan, K.V. Ramani, Deepali

Sharma, Margarita Songco, Arusha Stanislaus, Trudy Tan, Thiyaga¬rajan Velumail, Swarnim Wagle, Yumiko Yamamoto nig Uchita de Zoysa ។

## ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

របាយការណ៍នេះរួមបញ្ចូលផងដែរនូវទស្សនៈដែលបានលើកឡើងដោយអ្នកពាក់ព័ន្ធជាច្រើននៅក្នុងការពិគ្រោះយោបល់ជាបន្តបន្ទាប់ ។ អ្នកពាក់ព័ន្ធទាំងនោះ ត្រូវបានជ្រើសរើសពីក្នុងចំណោមគ្រឹះស្ថានអប់រំ រដ្ឋាភិបាល ឯកជន CSOs អ្នកវិភាគអង្គភាពរបស់ UN តំណាងនានានៃកម្មករ និងអ្នកប្រើប្រាស់ផលិតផល ។ អ្នកចូលរួមទាំងនោះរួមមាន : Shirin Akhter, Primo Amparo, M.C. Arora, Maria Fides Bagasao, T. Balan, Rashmi Banga, Anuradha Bhasin, Libran Cabactulan, Ricardo Casco, Rupa Chanda, c.P. Chandrasekhar, Bipul Chatterjee, Wallace Shuaihua Cheng, Xie Cheng, Hla Phyu Chit, Srey Chanthy, Kalpana Choudhary, Verona Collantes, Michael Angelo Cortez, Rodolfo de la Cruz, Pramod Dev, Maurice Dewulf, K. Dharmarajan, Ramesh Gampat, Jayati Ghosh, Nguyen Thanh Giang, Murray Gibbs, K.M. Gopakumar, R. Gopalan, Komal Gopalani, Gopinath, Ganesh Gurung, Kanupriya Gupta, Tahir Hasnain, Minh Chien, Ho, Susan Howes, Vu Quoc Huy, Achila Imchen, T. Indrani, Sanath Jayanetti, Markus Jelitto, Sitanon Jesdapipat, Kamol Kamoltrakul, Mumtaz Keklik, Makmur Keliat, Parashar Kulkarni, Nagesh Kumar, Udaya Kumar, Nguyen Thi Phuong Lan, Leeber Leebouapao, Zhongzhou Li, S.H. Mahatre, Abdul Halim bin Mansor, Rajan Mohapatra, Manuel Montes, Monwer Mostafa, Samsen Neak, Shrawan Nigam, Ernesto Ordonez, Pedro Ortega, Thangavel Palanivel, Balaji Pandey, K. Seeta Prabhu, Purnima Purohit, Atiur Rahman, Ananya Raihan, Anuradha Rajivan, Sripriya Ranganathan, N.P. Samy, Husein Sawit, Deepali Sharma, Pradeep Sharma, Stanley Simpson, Photong Sliphong, Bounthone Soukavong, Farhana Faruqi Stocker, Indah Suksmanigsigh, Supanee Taneewut, Dikshya Thapa, Riza Tjahjadi, Samar Verma, Gautam Vohra, Swarnim Wagle, Dushni Weerakoon, Ng Lip Yong, Uchita de Zoysa nig B.K. Zutshi ។

ក្រុមការងារក៏សូមសំដែងអំណរគុណផងដែរ ចំពោះការចូលរួមយ៉ាងសកម្មរបស់សហព័ន្ធអ្នកប្រើប្រាស់ផលិតផល និងទំនុកចិត្តសង្គម (CUTS) តាមរយៈមជ្ឈមណ្ឌលពាណិជ្ជកម្ម សេដ្ឋកិច្ច និងបរិស្ថានអន្តរជាតិ (CITEE) រួមទាំងការសម្របសម្រួលដែលបានធ្វើឡើងដោយសហព័ន្ធនេះ ។

## ការងារស្ថិតិ

ព័ត៌មានស្ថិតិត្រូវបានប្រមូលផ្តុំដោយ Rashmi Banga និង Niranjan Sarangi ដោយមានការជួយជ្រោមជ្រែងពី Kalpa-na Choudhary, Iori Kato និង Chune Loong Lum ។

## អ្នកពិនិត្យ

របាយការណ៍ RHDR បានទទួលការពិនិត្យដោយក្រុមអ្នកជំនាញការនៅក្នុង និងមកពីក្រៅ UNDP ។ អ្នកពិនិត្យបានផ្តល់យោបល់ទូទៅ និងយោបល់ដោយឡែក ។ ឯកសារសិក្សានានា និងសេចក្តីព្រាងជំពូកនានា ត្រូវបានដាក់ឱ្យពិនិត្យតាមរយៈដំណើរការពិនិត្យជាក្រុម (Peer Review) ។ ក្រុមការងារសូមថ្លែងអំណរគុណចំពោះ Anuradha Bhasin, Jolita Butkeviciene, C.P. Chandrasekhar, Carolyn Deere, Cristina Hernandez, Mumtaz Keklik, Aileen Kwa, Richard Leete, David Luke, Victor Ognivtsev, V.R. Panchamukhi, Dwijen Rangnekar, Miho Shirotori, Jan Vandemoortele and Josef Yap. Amitabh Kundu, S.K. Nath, R. Ramachandran និង Suranjana Vidyaratne ដែលបានពិនិត្យការងារខាងផ្នែកស្ថិតិ ។

## ការរៀបចំ

ការិយាល័យ UNDP ប្រចាំនៅប្រទេសឥណ្ឌា បានផ្តល់សេវាគាំទ្រនៅក្នុងអំឡុងពេលនៃការរៀបចំរបាយការណ៍នេះ ។

ការបង្ហាញជូន និងការផ្សព្វផ្សាយរបាយការណ៍នេះ បានធ្វើឡើងដោយមានការជួយជ្រោមជ្រែងរបស់ផ្នែកអប់រំនិងផ្សព្វផ្សាយព័ត៌មាននៃកម្មវិធីរបស់ UNDP-RCC ជាពិសេស Kay Kirby Dorji ។

សូមថ្លែងអំណរគុណចំពោះ Suwansawan Baran, Dora Blessich, Barbara Lemoine nig Siamak Moghaddam មកពីការិយាល័យ UNOPS ប្រចាំនៅអាស៊ី ដែលកាលពីមុនមានស្នាក់ការនៅទីក្រុងកូឡាឡាំពួ និងបច្ចុប្បន្នប្តូរមកទីក្រុងបាងកក ដែលបានផ្តល់សេវាគាំទ្រខាងផ្នែករដ្ឋបាល ។ ផ្នែកសេវាជំនួយរបស់ UNDP-RCC ក៏បានផ្តល់ការគាំទ្រដែរ ជាពិសេសគឺ Lushantha Arsecularatne, Manoj Basnyat និង Vishwa Khanna ។

របាយការណ៍នេះគឺជាលទ្ធផលបានពីការដឹកនាំ និងការប្តេជ្ញារបស់ Anuradha Rajivan ដែលអាចតម្រង់ទិសការងារនេះ តាមរយៈការជម្រុញនានា ហើយប្រសិនបើពុំមានគាត់ទេនោះ ការងារនេះនឹងមិនអាចបញ្ចប់ទៅបានឡើយ ។

**ម៉ឺញ តែម**

នាយកថ្នាក់តំបន់

មជ្ឈមណ្ឌល UNDP ប្រចាំតំបន់នៅទីក្រុងកូឡុំបូ

# មាតិកា


បុព្វកថា v

អារម្ភកថា vii

សេចក្តីថ្លែងអំណរគុណ ix

ពាក្យបំព្រួញ xxi

## ទិដ្ឋភាពរួម

យុគសម័យនៃកំណើនសេដ្ឋកិច្ចលឿន និងសេរីភាវូបនីយកម្មពាណិជ្ជកម្ម ៣

ការធ្វើឱ្យពាណិជ្ជកម្មកសិផលជួយដល់ជនក្រីក្រ ៦

កែតម្រូវទៅតាមកាលសម័យថ្មីសម្រាប់វិស័យវាយនភណ្ឌ និងសម្លៀកបំពាក់ ៨

ការលក់សេវាឆ្លងកាត់ព្រំដែន ៨

ឱកាសធ្វើពាណិជ្ជកម្មសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច ១០

របៀបវារៈប្រាំបីចំណុច ១១

ទៅដល់ព្រំដែនផ្សេងៗគ្នា ១៦

## ជំពូក ១ : ការប្រើប្រាស់ពាណិជ្ជកម្មអន្តរជាតិដើម្បីលើកកម្ពស់ការអភិវឌ្ឍមនុស្ស

ធ្វើឱ្យមានតុល្យភាពរវាងកំណើន និងការអភិវឌ្ឍមនុស្ស ២២

ប្រកាន់យកកំណើនសេដ្ឋកិច្ចតាមរយៈពាណិជ្ជកម្ម ២៤

សក្តានុពលសម្រាប់ចំណាត់ការរបស់រដ្ឋ ២៥

ចំណាត់ការកម្រិតពហុភាគី កម្រិតតំបន់ និងទ្វេភាគី ៣៣

ភាពចាំបាច់នៃការអភិវឌ្ឍមនុស្ស ៣៦

ទម្រង់នៃរបាយការណ៍នេះ ៣៧

## ជំពូក ២ : ពាណិជ្ជកម្ម និងការអភិវឌ្ឍមនុស្ស : បទពិសោធនៅអាស៊ី-ប៉ាស៊ីហ្វិក

និន្នាការនៃពាណិជ្ជកម្មអន្តរជាតិ ៤១

ឥទ្ធិពលនៃបញ្ហាថាមពល ៥២
ឥទ្ធិពលទៅលើការអភិវឌ្ឍមនុស្ស ៥៣
ច្រកការងារ ៦០

## ជំពូក ៣ : ការធ្វើឱ្យពាណិជ្ជកម្មកសិផលជួយដល់ជនក្រីក្រ

ទម្រង់នៃពាណិជ្ជកម្មកសិផលពិភពលោក ៧៣
ការនិយមនយោបាយការពារនៅភាគខាងជើង ៧៧
ការគាបសង្កត់លើពាណិជ្ជកម្ម និងការអភិវឌ្ឍមនុស្ស ៨១
ការធ្វើឱ្យពាណិជ្ជកម្មកសិផលជួយដល់ជនក្រីក្រ ៨៤
គោលនយោបាយពាណិជ្ជកម្មកសិផលនៃប្រទេសកំពុងអភិវឌ្ឍន៍ ៨៦
កម្មសិទ្ធិបញ្ហា ៨៨
ការកំណត់ភូមិសាស្ត្រ ៩១
ជលផល និងការអភិវឌ្ឍមនុស្ស ៩៤
ទិសដៅគោលនយោបាយសម្រាប់ពាណិជ្ជកម្មកសិផល ១០២
គោលនយោបាយជាអាទិភាព ១០៦

## ជំពូក ៤ : ការកែតម្រូវឱ្យស្របនឹងយុគ្គសម័យថ្មីសម្រាប់វាយនភណ្ឌ និងសម្លៀកបំពាក់

និន្នាការពាណិជ្ជកម្មពិភពលោកលើវាយនភណ្ឌ និងសម្លៀកបំពាក់ ១១២
ការផ្លាស់ប្តូររបបពាណិជ្ជកម្ម ១១៩
ទិសដៅនៃគោលនយោបាយជាតិ ១២៩
វិធានការអន្តរជាតិដើម្បីបង្កើនការប្រើប្រាស់ទីផ្សារ ១៣៣
ការផ្លាស់ប្តូរចម្បងនៅខាងមុខ ១៣៥

## ជំពូក ៥ : ការលក់សេវាឆ្លងដែន

ចំណាកស្រុករយៈពេលខ្លី ១៤០
លទ្ធកម្មដំណើរការជំនួញ ១៥០
ទេសចរណ៍អន្តរជាតិ ១៦៥
ពាណិជ្ជកម្មថ្មីខាងសេវាសេដ្ឋកិច្ច ១៧៣

## ជំពូក ៦ : កាលានុវត្តភាពពាណិជ្ជកម្មសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច


ហេតុអ្វីប្រទេសអភិវឌ្ឍន៍តិចតួចមិនបានទទួលប្រយោជន៍គ្រប់គ្រាន់ពីពាណិជ្ជកម្ម? ១៨០

បទពិសោធន៍អំពីសមាហរណកម្មពាណិជ្ជកម្ម ១៨១

ឥទ្ធិពលនៃសមាហរណកម្មពាណិជ្ជកម្មទៅលើការអភិវឌ្ឍមនុស្ស ១៨៧

កិច្ចផ្តួចផ្តើមដើម្បីដោះស្រាយភាពងាយរងគ្រោះរបស់ LDCs ១៨៩

មាគ៌ាទៅមុខ ១៩៥


## ជំពូក ៧ : ពាណិជ្ជកម្មដើម្បីការអភិវឌ្ឍមនុស្ស : របៀបវារៈប្រាំបីចំណុច


វិនិយោគដើម្បីភាពប្រកួតប្រជែង ២០៤

អនុម័តយកគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្ម ២០៥

ស្តារការយកចិត្តទុកដាក់លើកសិកម្ម ២០៦

ប្រយុទ្ធនឹងកំណើននៃភាពគ្មានការងារធ្វើ ២០៧

រៀបចំរបបពន្ធដារថ្មី ២០៨

ធ្វើឱ្យអត្រាប្តូរប្រាក់មានស្ថិរភាព ២០៩

ស៊ូទ្រាំជាមួយពហុភាពនិយម ២១០

ធ្វើសហប្រតិបត្តិការជាមួយប្រទេសជិតខាង ២១០

ទៅដល់ព្រំដែនផ្សេងគ្នា ២១១

## កំណត់សម្គាល់ ២១៣

## បណ្ណាល័យសាស្ត្រ ២២១


## ប្រអប់


១.១ ចំណាត់ថ្នាក់ប្រទេសនានាដែលមានប្រើប្រាស់ក្នុងរបាយការណ៍នេះ ២២

១.២ ស្តារការបាត់បង់ប្រាក់ចំណូលពីសេរីភាវូបនីយកម្មនៅបង់ក្លាដេស ២៦

១.៣ អន្តរាគមន៍របស់រដ្ឋទៅលើពាណិជ្ជកម្ម - បាតុភូតដែលមានជាយូរលង់មកហើយ ២៨

១.៤ សមាហរណកម្មជាយុទ្ធសាស្ត្ររបស់អន្តរជាតិ នៅក្នុងសកលភាវូបនីយកម្មពិភពលោក ២៩

១.៥ តំបន់កែច្នៃសម្រាប់ការនាំចេញ ៣០

១.៦ អត្រាប្តូរប្រាក់ជាក់ស្តែង : បទពិសោធន៍នានាប្រចាំតំបន់ ៣២

| | | |
|---|---|---|
| ១.៧ | ភាពប្លែកៗគ្នានៃកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ | ៣៤ |
| ១.៨ | កិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ដែលបានបង្កើតឡើង និងដែលទាក់ទងជាមួយប្រទេសនៅអាស៊ី-ប៉ាស៊ីហ្វិក | ៣៥ |
| ២.១ | អាស៊ី - រោងចក្រថ្មីនៃពិភពលោក | ៤៣ |
| ២.២ | ផ្តើមចេញពីបរិមាណស្បៀងលើស ទៅឱនភាពស្បៀង | ៤៩ |
| ២.៣ | ការប៉ះទង្គិចទាក់ទងនឹងការផ្គត់ផ្គង់ប្រេង | ៥០ |
| ២.៤ | ពាណិជ្ជកម្ម និងកំណើននៅក្នុងការធ្លាក់ចុះដ៏អស្ចារ្យនៃភាពក្រីក្រក្នុងប្រទេសម៉ាឡេស៊ី | ៥៥ |
| ២.៥ | ការរួមបញ្ចូលស្ត្រីទៅក្នុងសកលភាវូបនីយកម្ម | ៥៩ |
| ៣.១ | សេរីភាវូបនីយកម្មពាណិជ្ជកម្មកសិផលនៅឥណ្ឌូណេស៊ី | ៨៣ |
| ៣.២ | និមិត្តរូបប្រចាំភូមិសាស្ត្រនៅអាស៊ី | ៩៣ |
| ៣.៣ | ស្តង់ដារសុវត្ថិភាពចំណីអាហារ និងការនេសាទទ្រង់ទ្រាយតូច | ៩៨ |
| ៣.៤ | CITES: ជម្លោះអំពីបង្គារ-អណ្តើក និងកម្មករនេសាទនៅឥណ្ឌា | ១០១ |
| ៤.១ | ស្ត្រីក្នុងការងារនៅក្នុងឧស្សាហកម្មកាត់ដេរនៃប្រទេសបង់ក្លាដេស | ១១៧ |
| ៤.២ | លក្ខខណ្ឌការងារដ៏លំបាកនៅក្នុងឧស្សាហកម្មកាត់ដេរក្នុងក្រុងដេលី | ១១៨ |
| ៤.៣ | LDCs : អ្នកទទួលផលចម្បងនៃកិច្ចព្រមព្រៀងវាយនភណ្ឌចម្រុះ | ១១៨ |
| ៥.១ | ការផ្លាស់ទីនៃពលករគ្មានជំនាញនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក | ១៤១ |
| ៥.២ | ការប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះនៅប្រទេសបង់ក្លាដេស | ១៤២ |
| ៥.៣ | ភាពរើសអើងលើការផ្តល់ទិដ្ឋាការធ្វើការងារ | ១៤៣ |
| ៥.៤ | លទ្ធផលនៃការអភិវឌ្ឍមនុស្សបណ្តាលពីចំណាកស្រុក | ១៤៦ |
| ៥.៥ | ការជម្រុញរបស់រដ្ឋាភិបាលលើចំណាកស្រុកបណ្តោះអាសន្នពីប្រទេសវៀតណាម | ១៤៧ |
| ៥.៦ | ជម្រើសនៃចំណាកស្រុកក្នុងកិច្ចព្រមព្រៀងទូទៅលើពាណិជ្ជកម្មខាងសេវាកម្ម | ១៥១ |
| ៥.៧ | ការធ្វើលទ្ធកម្មដំណើរការជំនួញ - ឥទ្ធិពលលើការពង្រីកចំនួនការងារ | ១៥២ |
| ៥.៨ | សេវាលទ្ធកម្មនៅតាមខ្សែចង្វាក់នៃតម្លៃ | ១៥៣ |
| ៥.៩ | កត្តាមានឥទ្ធិពលលើភាពប្រកួតប្រជែងនៅក្នុងលទ្ធកម្មសកល | ១៥៥ |
| ៥.១០ | លទ្ធផលនៃការអភិវឌ្ឍមនុស្សបណ្តាលពីការធ្វើលទ្ធកម្ម | ១៦០ |
| ៥.១១ | វិធានការក្នុងស្រុកដើម្បីលើកកម្ពស់ការធ្វើលទ្ធកម្ម | ១៦១ |
| ៥.១២ | ការបង្កើតឧត្តមភាពសម្រាប់ការធ្វើលទ្ធកម្មនៅម៉ាឡេស៊ី | ១៦៣ |
| ៥.១៣ | សារៈសំខាន់នៃទេសចរណ៍ក្នុងស្រុក | ១៦៥ |
| ៥.១៤ | បង្កើនការធ្វើដំណើរកំសាន្តនៅម៉ាល់ឌីវ | ១៧០ |

៥.១៥ ការអភិវឌ្ឍទេសចរយ៉ាងឆាប់រហ័សនៅទីដាច់ស្រយាលអង្គរនៅកម្ពុជា ១៧២
៦.១ ការប្រុងប្រយ័ត្នរបស់ណេប៉ាល់ក្នុងការធ្វើសេរីភាវូបនីយកម្មសេវាកម្ម ១៨៣
៦.២ មាត្រាចែងពីការយកចិត្តទុកដាក់ពិសេស និងខុសគ្នានៅក្នុង WTO ១៨៤
៦.៣ TRIPS និងវិបត្តិសុខភាពសាធារណៈនៅក្នុងប្រទេសកម្ពុជា ១៨៦
៦.៤ ពាណិជ្ជកម្មរវាង LDCs នៅអាស៊ី-ប៉ាស៊ីហ្វិក និង ចិន ១៩០
៦.៥ ជំនួយសម្រាប់ពាណិជ្ជ : មាគ៌ាទៅមុខ ១៩៣
៦.៦ ផលិតផលដោយឡែក : កាលានុវត្តភាពសម្រាប់ LDCs ១៩៦

## តារាង

២.១ ស្ថានភាពនៃកំណើនប្រចាំតំបន់ ៤១
២.២ ពន្ធជាក់ស្តែងលើការនាំចូលសម្រាប់ប្រទេសខ្លះៗ ឆ្នាំ ១៩៩០ និង ២០០០ (%) ៤៤
២.៣ អត្រាកំណើននៃការនាំចេញ ទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ (%) ៤៥
២.៤ អត្រាកំណើននៃការនាំចូល ទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ (%) ៤៦
២.៥ សមាសភាពនៃទំនិញនាំចេញ និងនាំចូលសម្រាប់លក់ ៤៨
២.៦ អត្រាកំណើនតាមវិស័យ និងអត្រាកំណើន GDP ៥២
២.៧ និន្នាការនៃមេគុណ Gini ទសវត្សរ៍ឆ្នាំ ១៩៦០ ដល់ ១៩៩០ ៥៤
២.៨ កំណើនចំនួនការងារ និងផលិតផល ព្រមទាំងភាពយឺតនៃចំនួនការងារតាមវិស័យ ៦២
២.៩ កត្តានានាដែលរួមចំណែកធ្វើឱ្យប្រែប្រួលអត្រាកំណើនចំនួនការងារ ៦២
២.១០ សមាសភាពនៃតម្លៃបន្ថែមលើផលិតផលកម្មន្តសាលក្នុងប្រទេសចិន និងម៉ាឡេស៊ី (%) ៦៣
២.១១ កំណើននៃលទ្ធផល និងចំនួនការងារនៅក្នុងវិស័យសេវាកម្ម ៦៤
២.១២ កំណើនទូទៅនៃចំនួនការងារ និង GDP ព្រមទាំងភាពយឺតនៃចំនួនការងារនៅក្នុងប្រទេសមួយចំនួន ៦៥
២.១៣ សមាសភាពនៃតម្លៃបន្ថែមនៅក្នុងផលិតផលកម្មន្តសាលនៅប្រទេសឥណ្ឌា (%) ៦៥
២.១៤ កំណើននៃផលិតភាពកត្តាសរុបនៅក្នុងប្រទេសមួយចំនួន ៦៦
៣.១ តម្លៃបន្ថែមនៅក្នុងវិស័យកសិកម្ម គិតជាភាគរយនៃ GDP ៧១
៣.២ ភាគរយនៃចំនួនការងារនៅក្នុងវិស័យកសិកម្ម ៧២
៣.៣ ភាគចំណែកនៃកសិផលមួយចំនួនដែលបានធ្វើពាណិជ្ជកម្មឆ្លងដែនលើពិភពលោក ឆ្នាំ ២០០៥ ៧៣
៣.៤ ប្រទេសនាំមុខក្នុងការនាំចេញកសិផលនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្នាំ ២០០៣ ៧៦
៣.៥ សហភាពអឺរ៉ុប - ការប៉ាន់ប្រមាណអំពីការគាំទ្រចំពោះវិស័យកសិកម្ម (លានដុល្លារ) ៧៨
៣.៦ ស.រ.អា - ការប៉ាន់ប្រមាណអំពីការគាំទ្រចំពោះវិស័យកសិកម្ម (លានដុល្លារ) ៧៩

| | | |
|---|---|---|
| ៣.៧ | ការឧបត្ថម្ភធនរបស់ ស.រ.អា ចំពោះកសិផលមួយចំនួន (លានដុល្លារ) | ៧៩ |
| ៤.១ | ការនាំចេញវាយនភណ្ឌ និងសម្លៀកបំពាក់លើពិភពលោក (លានដុល្លារ) | ១១៣ |
| ៤.២ | ប្រទេសនាំចេញវាយនភណ្ឌឈានមុខគេ ឆ្នាំ ២០០៤ | ១១៤ |
| ៤.៣ | ប្រទេសនាំចេញសម្លៀកបំពាក់ឈានមុខគេ ឆ្នាំ ២០០៤ | ១១៥ |
| ៤.៤ | ចំនួនការងារនៅក្នុងផ្នែកវាយនភណ្ឌ និងកាត់ដេរ ក្នុងប្រទេសមួយចំនួននៅអាស៊ី | ១១៦ |
| ៤.៥ | វាយនភណ្ឌ និងសម្លៀកបំពាក់នាំចូលដោយ ស.រ.អា និងសហភាពអឺរ៉ុប នៅឆ្នាំ ២០០៤ និង ២០០៥ | ១២១ |
| ៤.៦ | ភាគចំណែកនៃតម្លៃលើវាយនភណ្ឌ និងសម្លៀកបំពាក់ (%) | ១២២ |
| ៥.១ | ចំនួនទេសចរមកទស្សនាប្រទេសនានានៅអាស៊ី-ប៉ាស៊ីហ្វិក ឆ្នាំ ២០០៥ | ១៦៦ |
| ៥.២ | ចំនួនការងារនៅក្នុងឧស្សាហកម្មទេសចរណ៍ | ១៦៨ |
| ៦.១ | សូចនាករគន្លឹះនៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួចនៅអាស៊ី-ប៉ាស៊ីហ្វិក | ១៧៨ |


## រូប


| | | |
|---|---|---|
| ១.១ | ដ្យាក្រាមអំពីទំនាក់ទំនងពាណិជ្ជកម្ម និងការអភិវឌ្ឍមនុស្ស | ២៣ |
| ២.១ | អត្រាពន្ធលើទំនិញនាំចូល ឆ្នាំ ១៩៨០-២០០០ | ៤២ |
| ២.២ | ភាគចំណែកពីអាស៊ី-ប៉ាស៊ីហ្វិក នៅក្នុងពាណិជ្ជកម្មពិភពលោក ឆ្នាំ ១៩៧៣-២០០០ (%) | ៤៤ |
| ២.៣ | តុល្យភាពជញ្ជីងពាណិជ្ជកម្ម អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក និងអាស៊ីខាងត្បូង ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ | ៤៧ |
| ២.៤ | សមាសភាពនៃការនាំចូល និងការនាំចេញទំនិញសម្រាប់លក់ | ៤៨ |
| ២.៥ | សមាសភាពនៃផលិតផលកម្មន្តសាលដែលនាំចេញ ឆ្នាំ ១៩៨០-២០០០ | ៥០ |
| ២.៦ | កំណើនការនាំចេញទំនិញ និងសេវា និង GDP នៅក្នុងបណ្តាប្រទេសក្នុងអាស៊ី-ប៉ាស៊ីហ្វិក | ៥១ |
| ២.៧ | ភាពក្រីក្រខាងប្រាក់ចំណូល ឆ្នាំ ១៩៨១-២០០១ % នៃប្រជាជនរស់នៅពឹងផ្អែកលើចំណូលតិចជាង ១ដុល្លារ ក្នុងមួយថ្ងៃ | ៥៦ |
| ២.៨ | LDCs និងប្រទេសកំពុងអភិវឌ្ឍន៍ ពាណិជ្ជកម្មគិតជា % នៃ GDP ឆ្នាំ ១៩៧០-២០០២ | ៥៦ |
| ២.៩ | អត្រាកំណើនជាមធ្យមប្រចាំឆ្នាំរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និង LDCs ឆ្នាំ ១៩៧០-២០០០ | ៥៧ |
| ២.១០ | អត្រាគ្មានការងារធ្វើប្រចាំតំបន់ ឆ្នាំ ១៩៩៣ និង ២០០៣ | ៦១ |
| ២.១១ | កម្រិតអប់រំនៃអ្នកឥតការងារធ្វើ | ៦៦ |
| ២.១២ | អត្រាអ្នកមានការងារធ្វើ តាមភេទ ទសវត្សរ៍ឆ្នាំ ១៩៩០ | ៦៧ |
| ៣.១ | ថ្លៃចំណាយលើការនាំចូលស្បៀងជាលក្ខណៈជំនួញ | ៧៣ |
| ៣.២ | លំដាប់នៃប្រទេសនាំចេញ : ការប្រៀបធៀបរវាងទំនិញសម្រាប់លក់ និងកសិផល | ៧៦ |
| ៣.៣ | អត្រាពន្ធកំណត់ដោយប្រទេសជឿនលឿនលើទំនិញនាំចូលពីតំបន់នីមួយៗ (%) | ៨០ |

៤.១ ការផ្លាស់ប្តូរទម្រង់នៃការនាំចេញលើពិភពលោក ឆ្នាំ ១៩៩០-២០០២ ១១៣
៤.២ ភាគចំណែកនៃការនាំចេញវាយនភណ្ឌនិងសម្លៀកបំពាក់នៅក្នុងប្រទេសមួយចំនួននៅអាស៊ី ឆ្នាំ ២០០៤ ១១៤
៤.៣ ភាគរយនៃស្ត្រីនៅក្នុងការងារដែលមានប្រាក់កម្រៃក្នុងផ្នែកវាយនភណ្ឌ និងសម្លៀកបំពាក់ ១១៦
៤.៤ កំណើនតម្លៃផលនាំចេញវាយនភណ្ឌ និងសម្លៀកបំពាក់ទៅសហភាពអឺរ៉ុប និងស.រ.អា ឆ្នាំ ២០០៤-០៥ ១២៣
៥.១ លំហូរនៃការផ្ញើប្រាក់មកផ្ទះទៅក្នុងប្រទេសមួយចំនួននៅអាស៊ី ឆ្នាំ ១៩៨៣-២០០៣ គិតជាពាន់លានដុល្លារ ១៤១
៥.២ ចំណាកស្រុកនៃបុរស និងស្ត្រី ពីប្រទេសស្រីលង្កា ១៤៣
៥.៣ ចំនួនទេសចរ ធៀបនឹងចំនួនប្រជាជន ១០០ នាក់ ឆ្នាំ ២០០២ ១៦៧


## ឧបសម្ព័ន្ធស្ថិតិ

អំពីទិន្នន័យ


តារាង ១. សូចនាករមូលដ្ឋាន ២៣៨
តារាង ២. សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស - និន្នាការ ២៣៩
តារាង ៣. សូចនាករភាពក្រីក្រ វិសមភាពប្រាក់ចំណូល និងកង្វះអាហារូបត្ថម្ភ ២៤០
តារាង ៤. សូចនាករលទ្ធភាពប្រើប្រាស់ទឹកស្អាតសម្រាប់ផឹក និងបរិក្ខារសម្រាប់អនាម័យ ២៤១
តារាង ៥. សូចនាករសុខភាពមាតា និងកុមារ ២៤២
តារាង ៦. សូចនាករសេវាសុខភាព ២៤៣
តារាង ៧. សូចនាករអក្ខរភាព និងការចុះឈ្មោះចូលរៀន ២៤៤
តារាង ៨. សូចនាករការអភិវឌ្ឍយេនឌ័រ ២៤៥
តារាង ៩. សូចនាកររបាយបច្ចេកវិទ្យា ២៤៦
តារាង ១០. សូចនាករនិរន្តរភាពថាមពល និងបរិស្ថាន ២៤៧
តារាង ១១. អត្រាពន្ធ កម្រិតកំពូលក្នុងស្រុក និងកម្រិតកំពូលអន្តរជាតិ ២៤៨
តារាង ១២. អត្រាពន្ធ MFN ទាក់ទងនឹងកសិកម្ម ២៤៩
តារាង ១៣. ប្រាក់ចំណូលពន្ធគយ និងពន្ធផ្សេងៗទៀត ២៥០
តារាង ១៤. និន្នាការអត្រាប្តូរប្រាក់ជាក់ស្តែង (REER, គោល ២០០០=១០០) ២៥១
តារាង ១៥. និន្នាការអត្រាការប្រាក់ជាក់ស្តែង ឆ្នាំ ១៩៩០-២០០៣ ២៥២
តារាង ១៦. ពាណិជ្ជកម្ម និងកំណើន ២៥៣
តារាង ១៧. ការនាំចេញ និង ការនាំចូលទំនិញសម្រាប់លក់ ២៥៤
តារាង ១៨. ភាគចំណែកនៃកសិផលនៅក្នុងការនាំចេញ និងតម្លៃបន្ថែម ២៥៥
តារាង ១៩. ភាគចំណែកនៃផលិតផលកម្មន្តសាលនៅក្នុងការនាំចេញ និងតម្លៃបន្ថែម ២៥៦

តារាង ២០. ភាគចំណែកនៃកសិផលនៅក្នុងការនាំចេញ និង តម្លៃបន្ថែម ២៥៧
តារាង ២១. ការនាំចេញសេវាកម្មតាមវិស័យ ២៥៨
តារាង ២២. ការនាំចូលសេវាកម្មតាមវិស័យ ២៥៩
តារាង ២៣. កំណើនការនាំចេញ ការនាំចូល និង GDP ២៦០
តារាង ២៤. កម្លាំងពលកម្ម និងអត្រាគ្មានការងារធ្វើ ២៦១
តារាង ២៥. វចនាសម្ព័ន្ធនៃការងារ ២៦២
តារាង ២៦. ប្រាក់ផ្ញើត្រលប់មកផ្ទះរបស់កម្មករ និងប្រាក់ទទួលបានពីប្រភពផ្សេងទៀត ២៦៣
តារាង ២៧. ការនាំចូលនូវមុខទំនិញចាំបាច់ ២៦៤
តារាង ២៨. លក្ខខណ្ឌផ្លាស់ប្តូរសុទ្ធនៅក្នុងពាណិជ្ជកម្ម ២៦៥
តារាង ២៩. សន្ទស្សន៍កំហាប់ និងភាពចម្រុះនៃការនាំចេញ និងនាំចូល ទៅតាមប្រទេស និងក្រុមនៃប្រទេសនានា ២៦៦
តារាង ៣០. សន្និធិរូបិយប័ណ្ណបរទេសសរុប ( មិនរាប់បញ្ចូលមាស) ២៦៨
តារាង ៣១. និន្នាការនៃតុល្យភាពគណនីចរន្ត (%GDP) ២៧០
តារាង ៣២. និន្នាការនៃតុល្យភាពគណនីមូលធន (%GDP) ២៧១
តារាង ៣៣. ការវិនិយោគដោយផ្ទាល់ពីបរទេស ២៧២
តារាង ៣៤. ជំនួយអភិវឌ្ឍន៍ផ្លូវការ ២៧៣
តារាង ៣៥. ការនាំចេញតាមតំបន់ចម្បងៗដែលជាប្រភពដើម និងជាគោលដៅចុងក្រោយ ២៧៤
តារាង ៣៦. ការនាំចូលតាមតំបន់សំខាន់ៗដែលជាប្រភពដើម និងជាគោលដៅចុងក្រោយ ២៧៥
តារាង ៣៧. កិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ និងទ្វេភាគី និងសមាជិកភាពអង្គការ WTO ២៧៦

និយមន័យនៃបច្ចេកសព្ទ ២៧៧

# ពាក្យបំព្រួញ

| | |
|---|---|
| ACCEC | ASEAN-China Comprehensive Economic Cooperation<br>កិច្ចសហប្រតិបត្តិការទូលំទូលាយខាងសេដ្ឋកិច្ចអាស៊ាន-ចិន |
| ADB | Asian Development Bank<br>ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFTA | ASEAN Free Trade Area<br>តំបន់ពាណិជ្ជកម្មសេរីអាស៊ាន |
| AFTA-CER CEP | AFTA-CER Closer Economic Partnership<br>ភាពជាដៃគូសេដ្ឋកិច្ចជិតស្និទ្ធ AFTA-CER |
| AGOA | African Growth and Opportunity Act<br>ច្បាប់ស្តីពីកំណើននិងកាលានុវត្តភាពសម្រាប់អាហ្វ្រិក |
| AICEP | ASEAN-India Comprehensive Economic Partnership<br>ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ឥណ្ឌា |
| AJCEC | ASEAN-Japan Comprehensive Economic Cooperation<br>កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ជប៉ុន |
| AKCCP | ASEAN-Korea Comprehensive Cooperation Partnership<br>ភាពជាដៃគូសហប្រតិបត្តិការទូលំទូលាយអាស៊ាន-កូរ៉េ |
| AMS | Aggregate Measure of Support<br>វិធានការសរុបនៃការគាំទ្រ |
| AO | Appellation of Origin<br>លក្ខខណ្ឌនៃប្រភពដើម |
| APEC | Asia Pacific Economic Cooperation<br>កិច្ចសហប្រតិបត្តិការតំបន់អាស៊ី-ប៉ាស៊ីហ្វិក |
| ARF | ASEAN Regional Forum<br>វេទិកាថ្នាក់តំបន់របស់អាស៊ាន |
| ARV | Anti-retroviral<br>ប្រឆាំងវីរុស (ថ្នាំ) |
| ASCM | Agreement on Subsidies and Countervailing Measures<br>កិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធន និងវិធានការទូទាត់សំណង |
| ASEAN | Association of Southeast Asian Nations<br>សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| ASEAN+3 | ASEAN -China-Japan-Korea<br>អាស៊ាន-ចិន-ជប៉ុន-កូរ៉េ |
| ATC | Agreement on Textiles and Clothing<br>កិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌ និងសម្លៀកបំពាក់ |

| | |
|---|---|
| AMTI | American Textile Manufacturers Institute វិទ្យាស្ថានអាមេរិកកាំងនៃផលិតករវាយនភណ្ឌ |
| BIMSTEC-FTA | Bay of Bengal Initiative for Multi-Sectoral Technical and Economic Cooperation Free Trade Area<br>កិច្ចផ្តួចផ្តើមឈូងសមុទ្របេងហ្គាល់សម្រាប់តំបន់ពាណិជ្ជកម្មសេរី នៃកិច្ចសហប្រតិបត្តិការបច្ចេកទេស និងសេដ្ឋកិច្ចពហុវិស័យ |
| BIS | Bank of International Settlement<br>ធនាគារនៃដំណោះស្រាយអន្តរជាតិ |
| BPO | Business process outsourcing<br>ការធ្វើលទ្ធកម្មដំណើរការជំនួញ |
| BTA | Bilateral Trade Agreement<br>កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី |
| CAFTA | Central American Free Trade Agreement<br>កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅតំបន់អាមេរិកកណ្តាល |
| CARP | Comprehensive Agrarian Reform Programme<br>កម្មវិធីកំណែទម្រង់កសិកម្មទូលំទូលាយ |
| CBI | Caribbean Basin Initiative<br>កិច្ចផ្តួចផ្តើមនៅកម្រិតអាងទន្លេនៃតំបន់ការ៉ាអ៊ីប |
| CEPT | Agreement on the Common Effective Preferential Tariff<br>កិច្ចព្រមព្រៀងស្តីពីតារាងអនុគ្រោះពន្ធ |
| CER | Closer Economic Relations<br>ទំនាក់ទំនងសេដ្ឋកិច្ចជិតស្និទ្ធជាងមុន |
| CET | Common External Tariff<br>តារាងពន្ធទូទៅក្រៅប្រទេស |
| CITES | Convention on International Trade in Endangered Species of Wild Flora and Fauna<br>អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិនៃប្រភេទសត្វ និងរុក្ខជាតិ ជិតផុតពូជ |
| CU | Customs Union<br>សហភាពរួចពន្ធគយ |
| DTIS | Diagnostic Trade Integration Study<br>ការសិក្សាវិភាគសមាហរណកម្មពាណិជ្ជកម្ម |
| DAFEL | Department of Administration of Foreign Employment Labour Force<br>នាយកដ្ឋានរដ្ឋបាលពលករបរទេស |
| DFID | UK Department for International Department<br>នាយកដ្ឋានរបស់ចក្រភពអង់គ្លេសសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| EAEC | East Asian Economic Council<br>ក្រុមប្រឹក្សាសេដ្ឋកិច្ចអាស៊ីបូព៌ា |
| EAI | Enterprise for ASEAN Initiative<br>សហគ្រាសសម្រាប់កិច្ចផ្តួចផ្តើមអាស៊ាន |
| EBA | Everything But Arms Agreement<br>អ្វីៗទាំងអស់លើកលែងតែកិច្ចព្រមព្រៀងសព្វាវុធ |
| ECO | Economic Cooperation Organization |

| | |
|---|---|
| | អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច |
| EPZ | Export Processing Zones<br>តំបន់កែច្នៃសម្រាប់ការនាំចេញ |
| EU | European Union<br>សហភាពអឺរ៉ុប |
| FAO | Food and Agriculture Organiza-tion of the United Nations<br>អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ |
| FAO-FISHSTAT | FAO Fishery Statistics<br>ស្ថិតិជលផលនៃអង្គការ FAO |
| FAS/USDA | Foreign Agricultural Service/United States Department of Agriculture<br>សេវាកសិកម្មបរទេស/ក្រសួងកសិកម្មសហរដ្ឋអាមេរិក |
| FDI | Foreign Direct Investment<br>ការវិនិយោគដោយផ្ទាល់ពីបរទេស |
| FTA | Free Trade Agreement<br>កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី |
| FTAA | Free Trade Area of the Americas<br>តំបន់សេដ្ឋកិច្ចសេរីនៃទ្វីបអាមេរិក |
| G-77 | Group of 77<br>ក្រុម ៧៧ |
| GATS | General Agreement on Trade in Services<br>កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម |
| GATT | General Agreement on Trade and Tariffs<br>កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្ម និងអត្រាពន្ធ |
| GCI | Growth Competitiveness Index<br>សន្ទស្សន៍ភាពប្រកួតប្រជែងនៃកំណើន |
| GDP | Gross Domestic Product<br>ផលទុនក្នុងស្រុកសរុប |
| GI | Geographical Indications<br>ការកំណត់ទីតាំងភូមិសាស្ត្រ |
| GSP | Generalized System of Preferences<br>ប្រព័ន្ធអនុគ្រោះទូទៅ |
| GSTP | Agreement on Global System of Trade Preferences Among Developing Countries<br>កិច្ចព្រមព្រៀងស្តីពីប្រព័ន្ធសកលនៃការអនុគ្រោះខាងពាណិជ្ជកម្មក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ |
| HACPP | Hazard Analysis and Critical Control Point<br>ការវិភាគគ្រោះថ្នាក់ និងចំណុចសំខាន់ដើម្បីត្រួតពិនិត្យ |
| HIV/AIDS | Human Immunodeficiency Virus/ Acquired Immunodeficiency Syndrome<br>មេរោគអេដស៍/ជម្ងឺអេដស៍ |
| HPLC | High Performance Liquid Chromatography<br>ការវិភាគតាមបែបក្រូម៉ាតូក្រាហ្វី |
| IATP | Institute for Agriculture and Trade Policy |

| | |
|---|---|
| | វិទ្យាស្ថានសម្រាប់គោលនយោបាយកសិកម្មនិងពាណិជ្ជកម្ម |
| ICFTU | International Confederation of Free Trade Unions |
| | សហព័ន្ធអន្តរជាតិនៃសហភាពពាណិជ្ជកម្មសេរី |
| ICSF | International Collective in Support of Fishworkers |
| | សមាគមន៍អន្តរជាតិគាំទ្រកម្មករនេសាទ |
| ICTSD | International Centre for Trade and Sustainable Development |
| | មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ពាណិជ្ជកម្មនិងអភិវឌ្ឍន៍ដោយចីរភាព |
| IF | Integrated Framework |
| | ក្របខ័ណ្ឌសមាហរណកម្ម |
| IGG | Inter-Governmental Group |
| | ក្រុមអន្តររដ្ឋាភិបាល |
| ILO | International Labour Organization |
| | អង្គការពលកម្មអន្តរជាតិ |
| IMF | International Monetary Fund |
| | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| IOM | International Organization for Migration |
| | អង្គការអន្តរជាតិសម្រាប់ជនចំណាកស្រុក |
| IP | Intellectual Property |
| | កម្មសិទ្ធិបញ្ញា |
| IPA | Integrated Programme of Action |
| | កម្មវិធីសកម្មភាពចម្រុះ |
| IPN | Integrated production networks |
| | បណ្តាញផលិតកម្មចម្រុះ |
| IPR | Intellectual Property Rights |
| | សិទ្ធិខាងកម្មសិទ្ធិបញ្ញា |
| IS | Indication of Source |
| | សញ្ញាសំគាល់ប្រភព |
| ISO | International Standards Organization |
| | អង្គការស្តង់ដារអន្តរជាតិ |
| IT | Information Technology |
| | បច្ចេកវិទ្យាព័ត៌មាន |
| ITCB | International Textiles and Clothing Bureau |
| | ការិយាល័យវាយនភណ្ឌនិងសម្លៀកបំពាក់អន្តរជាតិ |
| LBD | Learning by doing |
| | រៀនផងធ្វើផង |
| LDC | Least Developed Countries |
| | បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច |
| LICs | Low Income Countries |
| | បណ្តាប្រទេសមានប្រាក់ចំណូលទាប |
| MBA | Master in Business Administration |

| | |
|---|---|
| | អនុបណ្ឌិតផ្នែករដ្ឋបាលធុរកិច្ច |
| MDG | Millennium Development Goals<br>គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MEA | Multilateral Environmental Agreements<br>កិច្ចព្រមព្រៀងបរិស្ថានពហុភាគី |
| MFA | Multi-fibre Arrangement<br>កិច្ចព្រមព្រៀងពហុសរសៃអំបោះ |
| MNC | Multinational corporations<br>សាជីវកម្មពហុជាតិ |
| MOU | Memorandum of Understanding<br>អនុស្សារណៈនៃការយោគយល់ |
| MRA | Mutual Recognition Agreements<br>កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក |
| NAFTA | North American Free Trade Agreement<br>កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង |
| NAMA | Non-agricultural market access<br>សិទ្ធិប្រើប្រាស់ទីផ្សារសម្រាប់ផលិតផលក្រៅពីកសិផល |
| NASSCOM | National Association of Software and Service Companies<br>សមាគមន៍ជាតិនៃក្រុមហ៊ុនកម្មវិធីកុំព្យូទ័រ និងសេវាកម្ម |
| NET | Natural Economic Territories<br>តំបន់សេដ្ឋកិច្ចធម្មជាតិ |
| NFIDC | Net food importing developing countries<br>បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ដែលនាំចូលសុទ្ធនូវស្បៀងអាហារ ( ការនាំចូលច្រើនជាងការនាំចេញ) |
| NGO | Non-governmental organisations<br>អង្គការមិនមែនរដ្ឋាភិបាល |
| NIC | Newly Industrialised Countries<br>បណ្ដាប្រទេសឧស្សាហកម្មថ្មី |
| NIE | Newly Industrializing Economies<br>បណ្ដាសេដ្ឋកិច្ចឧស្សាហកម្មថ្មី |
| ODC | Other duties and charges<br>ពន្ធ និងកម្រៃសេវាដទៃទៀត |
| OECD | Organisation for Economic Co-operation and Development<br>អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ |
| OPEC | Organization of the Petroleum Exporting Countries<br>អង្គការនៃបណ្ដាប្រទេសនាំចេញប្រេងកាត |
| PACER | Pacific Agreement on Closer Economic Partnership<br>កិច្ចព្រមព្រៀងតំបន់ប៉ាស៊ីហ្វិកស្ដីពីភាពជាដៃគូសេដ្ឋកិច្ចជិតស្និទ្ធ |
| PIC | Pacific Island Countries<br>បណ្ដាប្រទេសជាកោះនៅមហាសមុទ្រប៉ាស៊ីហ្វិក |
| PICTA | Pacific Island Countries Trade Agreement |

កិច្ចព្រមព្រៀងពាណិជ្ជកម្មនៃបណ្តាប្រទេសជាកោះនៅ មហាសមុទ្រប៉ាស៊ីហ្វិក

| | |
|---|---|
| PPB | Parts per billion<br>មួយភាគពាន់លាន |
| PPM | Parts per million<br>មួយភាគលាន |
| PPT | Parts per trillion<br>មួយភាគលាន-លាន |
| PTA | Preferential Trade Agreement<br>កិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្ម |
| PVP | Plant Variety Protection<br>កិច្ចការពារពូជរុក្ខជាតិ |
| QR | Quantitative restrictions<br>ការដាក់កំហិតលើបរិមាណ |
| R&D | Research and Development<br>ការស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| RCD | Regional Cooperation for Development<br>កិច្ចព្រមព្រៀងតំបន់សម្រាប់ការអភិវឌ្ឍ |
| REER | Real Effective Exchange Rate<br>អត្រាប្តូរប្រាក់ជាក់ស្តែងកំពុងប្រើប្រាស់ |
| ROO | Rules of origin<br>គោលការណ៍ទាក់ទងនឹងប្រភពដើម |
| RTA | Regional Trade Agreement<br>កិច្ចព្រមព្រៀងពាណិជ្ជកម្មប្រចាំតំបន់ |
| SAARC | South Asian Association for Regional Cooperation<br>សមាគមន៍ប្រទេសនៅអាស៊ីខាងត្បូងសម្រាប់សហប្រតិបត្តិការ ប្រចាំតំបន់ |
| SAC | South Asian Countries<br>បណ្តាប្រទេសនៅអាស៊ីខាងត្បូង |
| SAFTA | South Asian Free Trade Agreement<br>កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅអាស៊ីខាងត្បូង |
| SAPTA | South Asian Preferential Trading Agreement<br>កិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មនៅតំបន់អាស៊ីខាងត្បូង |
| SARC | Declaration on South Asian Regional Cooperation<br>សេចក្តីថ្លែងការណ៍កិច្ចសហប្រតិបត្តិការប្រចាំតំបន់អាស៊ីខាងត្បូង |
| SARS | Severe Acute Respiratory Syndrome<br>ប្រជុំរោគសញ្ញានៃប្រព័ន្ធផ្លូវដង្ហើមធ្ងន់ធ្ងរ |
| SDT | Special and Differential Treatment<br>ការអនុគ្រោះពិសេស និងដោយឡែក |
| SIDS | Small Island Developing States<br>រដ្ឋកំពុងអភិវឌ្ឍន៍នានានៃកោះតូចៗ |
| SISs | Small Island States |

| | |
|---|---|
| | រដ្ឋនានានៃកោះតូចៗ |
| STD | Short-term debt |
| | បំណុលរយៈពេលខ្លី |
| T&C | Textiles and Clothing |
| | វាយនភណ្ឌ និងសម្លៀកបំពាក់ |
| TBT | Technical Barriers to Trade |
| | របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម |
| TED | Turtle Excluder Device |
| | បរិក្ខាររំដោះចេញសត្វអណ្តើក |
| TFP | Total Factor Productivity |
| | ផលិតភាពនៃកត្តាសរុប |
| TIFA | Trade and Investment Framework Agreements |
| | កិច្ចព្រមព្រៀងក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគ |
| TNC | Transnational corporations |
| | កិច្ចសហប្រតិបត្តិការឆ្លងកាត់ប្រទេស |
| TPSEPA | Trans-Pacific Strategic Economic Partnership Agreement |
| | កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចយុទ្ធសាស្ត្រឆ្លងកាត់តំបន់ប៉ាស៊ីហ្វិក |
| TRIMs | Agreement on Trade Related Investment Measures |
| | កិច្ចព្រមព្រៀងស្តីពីវិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម |
| TRIPS | Trade-Related Aspects of Intellectual Property Rights |
| | ទិដ្ឋភាពទាក់ទងនឹងពាណិជ្ជកម្មនៃសិទ្ធិលើទ្រព្យសម្បត្តិខាងបញ្ញា |
| TSE | Total Support Estimate |
| | ការប៉ាន់ប្រមាណអំពីការគាំទ្រសរុប |
| UN | United Nations |
| | អង្គការសហប្រជាជាតិ |
| UNCTAD | United Nations Conference on Trade and Development |
| | សន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ |
| UNDP | United Nations Development Programme |
| | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNDP-RCC | UNDP Regional Centre in Colombo |
| | មជ្ឈមណ្ឌលកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ប្រចាំតំបន់នៅទីក្រុងកូឡំបូ |
| UNESCAP | United Nations Economic and Social Commission for Asia and the Pacific |
| | គណៈកម្មការសហប្រជាជាតិទទួលបន្ទុកសេដ្ឋកិច្ចនិងសង្គមសម្រាប់ តំបន់អាស៊ី និងប៉ាស៊ីហ្វិក |
| UNIDO | United Nations Industrial Development Organization |
| | អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ |
| UPOV | Union for the Protection of New Varieties of Plants |
| | សហភាពដើម្បីការពារប្រភេទពូជរុក្ខជាតិថ្មី |
| USITC | United States International Trade Commission |
| | គណៈកម្មការពាណិជ្ជកម្មអន្តរជាតិរបស់សហរដ្ឋអាមេរិក |
| USSR | Union of Soviet Socialist Republics |

| | |
|---|---|
| | សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត |
| USTR | United States Trade Representative<br>តំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិក |
| VAT | Value Added Tax<br>ពន្ធលើតម្លៃបន្ថែម |
| WDI | World Development Indicators<br>សញ្ញាសម្គាល់ការអភិវឌ្ឍពិភពលោក |
| WTO | World Tourism Organization<br>អង្គការទេសចរណ៍ពិភពលោក |
| WTO | World Trade Organization<br>អង្គការពាណិជ្ជកម្មពិភពលោក |
| WTTC | World Travel and Tourism Council<br>ក្រុមប្រឹក្សាទស្សនាចរ និងទេសចរណ៍ពិភពលោក |
| $ | refers to US dollars, unless otherwise specified<br>សំដៅលើដុល្លារអាមេរិក លើកលែងតែមានការបញ្ជាក់ |
| € | refers to the Euro, unless otherwise specified<br>សំដៅលើអឺរ៉ូ លើកលែងតែមានការបញ្ជាក់ |

# ពាណិជ្ជកម្មផ្អែកលើកត្តាមនុស្ស
# ទិដ្ឋភាពទូទៅ

តំបន់អាស៊ី-ប៉ាស៊ីហ្វិកបានក្រសោបយកពាណិជ្ជកម្មសេរី ប៉ុន្តែពាណិជ្ជកម្មសេរីនឹងមិនជ្រួតជ្រាបដល់ជនក្រីក្រទេ លុះត្រាតែប្រទេសទាំងនោះអនុវត្តកម្មវិធីនយោបាយថ្មីៗដ៏ក្លាហាន ដែលបង្កើនកំណើនសេដ្ឋកិច្ច ដើម្បីលើកកម្ពស់ការអភិវឌ្ឍមនុស្ស។

តំបន់អាស៊ី-ប៉ាស៊ីហ្វិកកំពុងស្ថិតនៅជួរមុខនៃសាកលភាវូបនីយកម្ម ដែលមានអត្រាកំណើនសេដ្ឋកិច្ចឆាប់រហ័សបំផុតក្នុងពាណិជ្ជកម្មអន្តរជាតិ។ អាស៊ីបូព៌ាធ្លាប់តែឈានមុខគេ ប៉ុន្តែឥឡូវនេះអាស៊ីខាងត្បូងក៏បានបង្ហាញវត្តមានដ៏រឹងមាំផងដែរ។ មានទំនិញជាច្រើនអនេកដែលចាប់ពីអាវយឺតរហូតដល់ស្បែកជើង កំព្យូទ័រ កំពុងតែចរាចរប្រទាក់ខ្វាត់ខ្វែងក្នុងតំបន់ ជាពិសេសនៅក្នុងប្រព័ន្ធផលិតកម្មសមាហរណកម្មអន្តរជាតិ មុនពេលត្រូវបានបញ្ជូនទៅកាន់ទីផ្សារសកលលោក។ ការរីកចម្រើននេះកើតឡើងមិនត្រឹមតែចំពោះទំនិញប៉ុណ្ណោះទេ រីឯផ្នែកសេវាកម្មក៏បានរីកចម្រើនផងដែរ ពោលគឺចាប់ពីក្រុងបាងកាល័រ រហូតដល់ក្រុងម៉ានីល មានបុគ្គលិករាប់សែននាក់កំពុងតែជួយអតិថិជន និងភ្ញៀវនៅអឺរ៉ុប សហរដ្ឋអាមេរិក ឬជប៉ុន ហាក់បីដូចជាពួកគេកំពុងអង្គុយក្នុងការិយាល័យមួយនៅជិតអតិថិជនទាំងនោះអញ្ចឹង។ ហើយកាលណាសេវាកម្មមិនអាចបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិក បានបុគ្គលិកផ្តល់សេវាធ្វើដំណើរតាមអាកាសយានឆ្លងកាត់តំបន់ និងមហាសមុទ្រ ដើម្បីបម្រើការងារជាអ្នកបម្រើតាមគេហដ្ឋាន ឬគិលានុបដ្ឋាយិកា កម្មករសំណង់ ឬវិស្វករសំណង់ កម្មកររោងចក្រ ឬគណនេយ្យករ។ ដូច្នេះ តំបន់អាស៊ី-ប៉ាស៊ីហ្វិក មិនត្រឹមតែកំពុងក្លាយទៅជាថ្នាលបណ្តុះធនធានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសេនាធិការគាំទ្រនៃពិភពលោកទៀតផង។

ពិភពលោកកំពុងតែសម្លឹងមើលដំណើរការនេះដោយការភ្ញាក់ផ្អើលនិងមិនមានការព្រួយបារម្ភច្រើនទេ។ នៅក្នុងប្រទេសអ្នកមាននៅបស្ចិមប្រទេស បដិវត្តន៍ឧស្សាហកម្មក្នុងសតវត្សរ៍ទី ១៩ បានបង្កើតមជ្ឈមណ្ឌលថ្មីដ៏ធំដែលជាចំណុចប្រមូលផ្តុំសេដ្ឋកិច្ចសកលលោក៖ ក្នុងសតវត្សរ៍ទី ២១ នេះ តុល្យភាពអំណាចមិនបានផ្លាស់ប្តូរច្រើនទេ ប៉ុន្តែមានលក្ខណៈរាយប៉ាយច្រើន។ បញ្ហានេះបង្កើតឡើងនូវសំណួរជាច្រើន ដូចជា៖ តើអ្នកណាផលិតអ្វី ផលិតនៅកន្លែងណា និងដោយរបៀបណា? និងជាពិសេស តើបញ្ហាទាំងនេះមានផលប៉ះពាល់អ្វីលើជីវិតមនុស្ស លើប្រាក់ចំណូល លើសុខភាព កម្រិតការអប់រំ និងអនាគតរបស់ពួកគេ លើប្រការដែលថាតើពួកគេជាអ្នកណា និងថាតើពួកគេនឹងក្លាយទៅជាអ្វី? និយាយដោយសង្ខេប តើបញ្ហានេះមានន័យដូចម្តេចចំពោះការអភិវឌ្ឍមនុស្ស? ហើយដោយពិនិត្យមើលបញ្ហានេះតាមទស្សនៈវិស័យផ្សេង តើការអភិវឌ្ឍមនុស្សតាមស្តង់ដារកម្រិតខ្ពស់ អាចរួមវិភាគទានអ្វីខ្លះដល់ការពង្រីកពាណិជ្ជកម្ម និង កំណើនសេដ្ឋកិច្ច?

របាយការណ៍នេះឆ្លើយតបទៅនឹងសំណួរទាំងនេះ ដោយចេញពីផ្ទៃក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ ដំណើរការពិគ្រោះយោបល់ដ៏ពេញលេញមួយរវាងអ្នកធ្វើគោលនយោបាយ បញ្ញវន្ត សង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត បានពិនិត្យការអភិវឌ្ឍថ្មីៗបំផុតលើកំណើនសេដ្ឋកិច្ចនិង

*តំបន់អាស៊ី-ប៉ាស៊ីហ្វិក មិនត្រឹមតែកំពុងក្លាយទៅជាថ្នាលបណ្តុះធនធានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសេនាធិការគាំទ្រនៃពិភពលោកទៀតផង។*

> *មានឧទាហរណ៍ជាច្រើនពីប្រវត្តិសាស្ត្រ ដែលបង្ហាញអំពីអ្វីដែលអាចកើតឡើងនៅពេលដែលផលប្រយោជន៍ពាណិជ្ជកម្មមានអាទិភាពខ្ពស់ជាងសុខុមាលភាពរបស់មនុស្ស ។ ពាណិជ្ជកម្មមិនមែនជាបញ្ហាចំពោះឧស្សាហកម្មឯកជនតែមួយនោះទេ ជានិច្ចកាល វាទទួលអន្តរាគមន៍យ៉ាងសកម្មពីរដ្ឋ ។*

ពាណិជ្ជកម្ម និងបានព្យាយាមវាយតម្លៃផលប៉ះពាល់លើការអភិវឌ្ឍមនុស្ស និងជាពិសេស ផលប៉ះពាល់លើប្រទេសក្រីក្របំផុតនៅក្នុងតំបន់ និងប្រជាពលរដ្ឋក្រីក្របំផុតរបស់ប្រទេសទាំងនោះ ។

បញ្ហានេះមិនមែនជាការងារងាយស្រួលឡើយ ។ ជាក់ស្តែង តំបន់នេះគឺជាតំបន់ដ៏ធំមួយដែលមានប្រជាជនជាង ៦០ ភាគរយនៃប្រជាជនទូទាំងសកលលោក ។ លើសពីនេះទៀត ប្រទេសទាំងឡាយនៅអាស៊ី-ប៉ាស៊ីហ្វិកមានលក្ខណៈខុសគ្នាខ្លាំងដែលមានចំណាត់ថ្នាក់ទី ៣ រហូតដល់ទី ១៤០ ក្នុងចំណោមប្រទេសចំនួន ១៧៧ ដែលត្រូវបានធ្វើចំណាត់ថ្នាក់ខាងសន្ទស្សន៍អភិវឌ្ឍន៍មនុស្សក្នុងឆ្នាំ ២០០៣ ។ ទន្ទឹមនឹងនេះ ដោយសារចរន្តនៃការផ្លាស់ប្តូរសង្គមនិងសេដ្ឋកិច្ចមានល្បឿនលឿនពេក ហើយដំណើរការផ្លាស់ប្តូរមានភាពស្មុគស្មាញពេកនៅក្នុងតំបន់មួយដែលមានថាមភាពជាងគេនៅក្នុងពិភពលោក គេមានការលំបាកក្នុងការពិនិត្យបញ្ហាទាំងអស់នេះឱ្យបានស៊ីជម្រៅ ។

ហេតុនេះ របាយការណ៍ផ្តោតលើការយកចិត្តទុកដាក់មួយចំនួន ប៉ុន្តែ ទោះបីជារបាយការណ៍នេះពិតជាបានពិចារណាអំពីគំរូកំណើនសេដ្ឋកិច្ច និងពាណិជ្ជកម្មក្តី ក៏របាយការណ៍នេះយកចិត្តទុកដាក់ជាចម្បងលើផលប៉ះពាល់ទាំងឡាយដែលមានអានុភាពលើការអភិវឌ្ឍមនុស្សនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់នេះ ។ ប៉ុន្តែ របាយការណ៍នេះបានបញ្ជាក់ជ្រៅជាងនេះទៅទៀត ដោយសង្កត់ធ្ងន់ថា ទាំងពាណិជ្ជកម្ម ទាំងកំណើនសេដ្ឋកិច្ចមិនមែនជាគោលដៅចុងក្រោយឡើយ ផ្ទុយទៅវិញ វាគាន់តែជាមធ្យោបាយឆ្ពោះទៅកាន់គោលដៅធំជាងការពង្រីកកិច្ចអភិវឌ្ឍមនុស្ស និង ការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងការបាត់បង់សិទ្ធិ ។

ពាណិជ្ជកម្មពិតជាអាចលើកកម្ពស់ការអភិវឌ្ឍមនុស្ស ប៉ុន្តែ វាក៏អាចរារាំងការអភិវឌ្ឍមនុស្សផងដែរ ។ តាមពិតពាណិជ្ជកម្មគឺជាសកម្មភាពស្វែងរកចំណេញ ហើយគេឃើញមានឧទាហរណ៍ជាច្រើនពីប្រវត្តិសាស្ត្រដែលបង្ហាញអំពីអ្វីដែលអាចកើតឡើងនៅពេលដែលផលប្រយោជន៍ពាណិជ្ជកម្មមានអាទិភាពខ្ពស់ជាងសុខុមាលភាពរបស់មនុស្ស: របបសក្តិភូមិទាសភាព អាណានិគមនិយម និងរបបប្រកាន់ពូជសាសន៍បែបអាប៉ាថេត (apartheid) គឺជាទម្រង់ហួសហេតុខ្លះៗ ។ បច្ចុប្បន្នក៏ដូចគ្នាដែរ ការខិតខំនាំចេញនិងនាំចូលទំនិញនិងសេវាបន្ថែមជាទូទៅនាំឱ្យមានដំណើរការដ៏ស្មុគស្មាញ និងប្រកបដោយថាមភាពមួយ ដែលធ្វើឱ្យមានអ្នកឈ្នះនិងអ្នកចាញ់ ។ សេរីភាវូបនីយកម្ម អាចបង្កើនកាលានុវត្តភាពសម្រាប់ការនាំចេញ ប៉ុន្តែវាក៏ធ្វើឱ្យអ្នកផលិតក្នុងស្រុកប្រឈមមុខនឹងការប្រកួតប្រជែងពីបរទេសផងដែរ ជាពិសេសនៅក្នុងប្រទេសក្រីក្រ ពួកគេអាចគ្មានលទ្ធភាពទប់ទល់បាន ។ ដូច្នេះ ទន្ទឹមគ្នានឹងការបង្កើតកាលានុវត្តភាពថ្មី ជាពិសេសនៅក្នុងវិស័យទំនើប វាក៏អាចបំផ្លាញជីវភាពរស់នៅរបស់ប្រជាជនដែលធ្វើការងារនៅក្នុងវិស័យកម្មន្តសាលសាមញ្ញ ឬនៅក្នុងវិស័យកសិកម្ម ។

ដោយប្រឈមមុខជាមួយនឹងលទ្ធភាពបំផ្លាញនេះ អ្នកជាតិនិយមខាងសេដ្ឋកិច្ចអាចអះអាងការពារប្រការអ្វីមួយដែលមានលក្ខណៈប្រហាក់ប្រហែលនឹងស្វ័យធនភាព ដោយដាក់ឧបសគ្គពាណិជ្ជកម្មកាន់តែខ្ពស់ និងដោយសំដៅឆ្ពោះទៅរកភាពខ្លួនទីពឹងខ្លួនកម្រិតជាតិ ពោលគឺថា តើហេតុអ្វីបានជាចាំបាច់ត្រូវពឹងផ្អែកលើការនាំចូល ខណៈដែលអ្នកអាចផលិតវត្ថុដូចគ្នាដោយខ្លួនឯងបាន? ចំណុចនេះមានលក្ខណៈទាក់ទាញខាងផ្លូវចិត្ត ប៉ុន្តែ នឹងជួបប្រទះការលំបាកជាក់ស្តែងជាមិនខាន ។ មនុស្សនៅក្នុងសតវត្សរ៍ទី ២១ មានសិទ្ធិខាងសង្គមនិងសេដ្ឋកិច្ច ដែលអាចបំពេញបានតែតាមរយៈពាណិជ្ជកម្មអន្តរជាតិ គេតែងតែត្រូវការការនាំចេញខ្លះ ដើម្បីរករូបិយប័ណ្ណបរទេសសម្រាប់ការនាំចូលសំខាន់ៗ ចាប់តាំងពីថ្នាំពេទ្យ រហូតដល់ស្បៀងអាហារ

រហូតដល់ប្រេងកាត។

នៅខាងចុងម្ខាងទៀត គឺក្រុមអ្នកគាំទ្រពាណិជ្ជកម្មសេរី ដែលមិនចង់ឱ្យមានឧបសគ្គអ្វីទាំងអស់ ពោលគឺទុកឱ្យទីផ្សារគ្រប់គ្រងទីកន្លែងផលិតកម្មដែលមានលក្ខណៈសមស្របបំផុតខាងសេដ្ឋកិច្ច។ ចំណុចនេះ អាចទំនងជាមានលក្ខណៈគួរឱ្យទាក់ទាញ និងទុកចិត្តជាង ប៉ុន្តែចំណុចនេះក៏ជាជំនឿខុសឆ្គងផងដែរ ដោយសារវាពាក់ព័ន្ធនឹងពាណិជ្ជកម្មរវាងដៃគូមិនស្មើភាពគ្នា ដែលអនុញ្ញាតឱ្យប្រទេសនិងក្រុមហ៊ុនដែលមានបំផុត និងមានអំណាចបំផុត កំណត់ល័ក្ខខ័ណ្ឌ ហើយទុកឱ្យអ្នកចូលរួមក្រីក្រនិងទន់ខ្សោយជាងទទួលយកនូវអ្វីដែលគេផ្តល់ឱ្យ។ ប្រការនេះនឹងនាំឱ្យមានហានិភ័យ ខាងផ្នែកវិសមធម៌បន្ថែមទៀតរវាងក្រុមប្រទេសទាំងពីរប្រភេទ និងទាំងនៅក្នុងប្រទេសផ្ទាល់ខ្លួនផង។

## រដ្ឋសកម្ម

គេអាចគិតថាដំណោះស្រាយប្រសើរបំផុតគឺការបែងចែកដ៏សាមញ្ញនៃការទទួលខុសត្រូវ ពោលគឺអនុញ្ញាតឱ្យទីផ្សារសេរី និងចំហាចាត់ចែងកំណើនសេដ្ឋកិច្ច ខណៈពេលដែលតម្រូវឱ្យរដ្ឋាភិបាលដោះស្រាយបរាជ័យទីផ្សារ និងទទួលខុសត្រូវលើផលវិបាកនៃកំណើនវិសមភាពក្នុងផ្នែកការយកចិត្តទុកដាក់ខាងសង្គម និងអាទិភាពអភិវឌ្ឍន៍មនុស្ស។

ប៉ុន្តែ ការបែងចែកនេះមិនបានគិតដល់ប្រការដែលពាណិជ្ជកម្ម កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍមនុស្សមានទំនាក់ទំនងពឹងផ្អែកគ្នាទៅវិញទៅមក។ ចំណុចនីមួយៗត្រូវការចំណុចដទៃទៀត។ ទំនាក់ទំនងផ្ទាល់មួយគឺតាមរយៈប្រាក់ចំណូលពន្ធ។ ការលុបពន្ធ ឬការបន្ថយពន្ធអាចមានផលប៉ះពាល់ខូចខាតលើការអភិវឌ្ឍមនុស្សដោយសារប្រទេសជាច្រើនពឹងផ្អែកលើពន្ធគយ និងពន្ធដទៃទៀតសម្រាប់ចំណូលរដ្ឋាភិបាលក្នុងសមាមាត្រដ៏ខ្ពស់មួយៈ នៅក្នុងប្រទេសកោះប៉ាស៊ីហ្វិកខ្លះមានរហូតដល់ទៅ ៧០ភាគរយ។ ហេតុនេះ សេរីភាវូបនីយកម្មពាណិជ្ជកម្មអាចតម្រូវឱ្យមានការកាត់បន្ថយសេវាសាធារណៈច្រើននៅពេលដែលប្រាក់ចំណូលធ្លាក់ចុះ។

ទំនាក់ទំនងទីពីរ គឺការកំណត់លំដាប់លំដោយ។ ប្រទេសទាំងឡាយអាចចាំបាច់ត្រូវសម្រេចបាននូវការអភិវឌ្ឍមនុស្សក្នុងកម្រិតណាមួយដើម្បីរៀបចំមូលដ្ឋានគ្រឹះសម្រាប់សេរីភាវូបនីយកម្ម។ ការបង្កើនពាណិជ្ជកម្មអន្តរជាតិ តម្រូវឱ្យមានមិនត្រឹមតែទុននិងបច្ចេកវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកម្លាំងពលកម្មប្រកបដោយសមត្ថភាពផងដែរ។ ចំពោះចំណុចនេះ រដ្ឋចាំបាច់ត្រូវទទួលបន្ទុកធានាឱ្យបានថាមានសមត្ថភាពសំខាន់ៗ ដើម្បីអនុញ្ញាតឱ្យវិស័យឯកជនអាចទាញយកផលពេញលេញពីសេរីភាវូបនីយកម្ម។

ពាណិជ្ជកម្មមិនមែនជាបញ្ហាចំពោះឧស្សាហកម្មឯកជនតែមួយនោះទេ ជានិច្ចកាល វាទទួលអន្តរាគមន៍យ៉ាងសកម្មពីរដ្ឋ។ រដ្ឋាភិបាលតែងតែទទួលស្គាល់តម្លៃវិស័យឯកជនថាជាក្បាលម៉ាស៊ីនចម្បងនៃកំណើនសេដ្ឋកិច្ច ប៉ុន្តែ រដ្ឋាភិបាលក៏ដឹងដែរថា វិស័យឯកជនចាំបាច់ត្រូវមានការគ្រប់គ្រង ឬការដឹកនាំក្នុងកម្រិតមួយសមស្របប្រសិនបើវិស័យនេះត្រូវបម្រើដល់ការអភិវឌ្ឍមនុស្សយ៉ាងពិតប្រាកដ។

## យុគសម័យនៃកំណើនសេដ្ឋកិច្ចលឿន និងសេរីភាវូបនីយកម្មពាណិជ្ជកម្ម

ការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ច និងពាណិជ្ជកម្មឱ្យដើរត្រង់ផ្លូវគឺជាការងារដ៏លំបាកមួយ។ ជារឿយៗ គេសង្កេតឃើញមានដំណើរការវិវឌ្ឍទៅមុខឆាប់រហ័ស ហើយអាស៊ី-ប៉ាស៊ីហ្វិកគឺជាតំបន់រីកចម្រើនឆាប់រហ័សបំផុតនៅក្នុងពិភពលោក។ នៅក្នុងអំឡុងឆ្នាំ ១៩៩០ និង ២០០៣ ផលិតផល

ជាតិសរុបបានកើនជាបន្តបន្ទាប់ក្នុងអត្រាមធ្យមលើស ៧% ។ រដ្ឋាភិបាលជាច្រើនអាចទទួលបានការកោតសរសើរចំពោះការងារនេះ ដោយសារកំណើនសេដ្ឋកិច្ចដ៏លឿននេះភាគច្រើនបានកើតឡើងនៅក្នុងអំឡុងពេលនៃសេរីភាវូបនីយកម្មពាណិជ្ជកម្មដ៏រឹងប៉ឹង ។ នៅអាស៊ីបូព៌ានិងប៉ាស៊ីហ្វិក សេរីភាវូប-នីយកម្ម បានចាប់ផ្តើមនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និងមកដល់ឆ្នាំ ២០០០ អត្រាពន្ធមធ្យមបានធ្លាក់ចុះមកត្រឹម ៨% ។ អាស៊ីខាងត្បូងមានការយឺតយ៉ាវជាងក្នុងការចាប់ផ្តើមសេរីភាវូបនីយកម្ម ប៉ុន្តែបានធ្វើសេរីភាវូបនីយកម្មយ៉ាងលឿន ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ហើយមកដល់ឆ្នាំ ២០០០ អត្រាពន្ធមធ្យមបានធ្លាក់ចុះមកត្រឹម ១៨% ។

ការបញ្ចុះអត្រាពន្ធគឺជាវិភាគទានដ៏សំខាន់ដល់កំណើនពាណិជ្ជកម្ម ។ ពីពេលមុនកំណើននាំចេញបានកើនឆាប់រហ័សក្នុងអាស៊ីបូព៌ានិងប៉ាស៊ីហ្វិកច្រើនជាងនៅអាស៊ីខាងត្បូង ប៉ុន្តែនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ វាបានរីកសាយនៅទូទាំងតំបន់ ។ ដូច្នេះ នៅក្នុងចន្លោះឆ្នាំ ១៩៩០ និង ២០០៣ ក្នុងពេលដែលអាស៊ីបូព៌ានិងប៉ាស៊ីហ្វិក កំពុងតែមានថាមពលខ្លាំងដើរទៅមុខ ហើយពាណិជ្ជកម្មដែលជាភាគរយនៃផលិតផលជាតិសរុបបានកើនពី ៤៥% ដល់ ៨១% នោះសមាមាត្រ នៅអាស៊ីខាងត្បូងក៏បានកើនឡើងពី ២០% ទៅ ៣៤% ដែរ ។ ជាលទ្ធផលសេដ្ឋកិច្ចរបស់ប្រទេសទាំងអស់នៅអាស៊ី "កាន់តែបើកចំហខ្លាំងឡើង" ។

ទន្ទឹមគ្នានឹងការកើនឡើងនៃទំហំពាណិជ្ជកម្ម គេក៏ឃើញមានការផ្លាស់ប្តូរដ៏គំហុកផងដែរនៅក្នុងរចនាសម្ព័ន្ធពាណិជ្ជកម្ម ។ ប្រទេសខ្លះបានបន្តពីការនាំចេញទំនិញ ហើយក៏លក់សេវាកម្មកាន់តែច្រើនផងដែរ ។ ការនាំចេញផលិតផលសំខាន់ៗទាំងនេះកំពុងតែប្រែក្លាយទៅជាទំនិញកម្មន្តសាលកាន់តែច្រើន ហើយក្នុងវិស័យកម្មន្តសាលនេះ មានសហគ្រាសជាច្រើនកំពុង តែឡើងកាំជណ្តើរបច្ចេកវិទ្យាឆ្ពោះទៅកាន់ការផលិតទំនិញកាន់តែទំនើប ថ្វីបើប្រការនេះគឺជាបាតុភូតឃើញច្បាស់នៅក្នុងអាស៊ីបូព៌ាជាងនៅអាស៊ីខាងត្បូង ។

តើកំណើនពាណិជ្ជកម្មលឿននេះមានផលប៉ះពាល់អ្វីលើការអភិវឌ្ឍមនុស្ស? លទ្ធផលមួយដែលបង្កការរំខានជាងគេគឺថាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើននៅក្នុងតំបន់ការចូលរួមកាន់តែច្រើននៅក្នុងទីផ្សារអន្តរជាតិ បាននាំមកជាមួយនូវកំណើននៃវិសមភាពប្រាក់ចំណូល ។ ប៉ុន្តែ តាមការកត់សម្គាល់វិជ្ជមានជាងនេះ គេឃើញមានការធ្លាក់ចុះច្រើននៃភាពក្រីក្រ: ពីឆ្នាំ ១៩៩០ ដល់ ឆ្នាំ ២០០១ ចំនួនមនុស្សដែលរស់នៅអាស្រ័យលើប្រាក់តិចជាង ១ ដុល្លារ ក្នុងមួយថ្ងៃ បានធ្លាក់ចុះជិត ២៥០ លាននាក់ ។

ការរីកចម្រើនយឺតជាងគេបំផុតកើតមាននៅក្នុងប្រទេសអភិវឌ្ឍន៍ទាបជាងគេបំផុត ។ ថ្វីបើមានកំណើនពាណិជ្ជកម្មក្តី ក៏ប្រទេសអភិវឌ្ឍន៍ទាបជាងគេបំផុតជាច្រើនទទួលបានជោគជ័យតិចតួចប៉ុណ្ណោះ ក្នុងការកាត់បន្ថយភាពក្រីក្រ ។ ខណៈដែលនៅប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងតំបន់សមាមាត្រនៃប្រជាពលរដ្ឋដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ១ ដុល្លារ ក្នុងមួយថ្ងៃ គឺមាន ២២% ប្រទេសអភិវឌ្ឍន៍ទាបជាងគេបំផុត មានអត្រា ៣៨% ។

តាមពិតនៅក្នុងទូទាំងតំបន់ គេនៅតែឃើញមានភស្តុតាងនៃភាពក្រខ្សត់ធ្ងន់ធ្ងរនៅឡើយ ។ បញ្ហានេះបង្ហាញច្បាស់នៅក្នុងទិន្នន័យស្តីពីការប្រើប្រាស់ចំណីអាហារ ។ ការធ្វើសេរីភាវូបនីយកម្មទីផ្សារកសិផល អាចបានជួយកាត់បន្ថយតម្លៃចំណីអាហារ ជាពិសេស តម្លៃកសិផលដែលត្រូវបានផលិតតាមការគាំទ្រឧបត្ថម្ភធនកសិកម្មនៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ។ ប៉ុន្តែបញ្ហានេះទំនងជាមិនបាននាំឱ្យសន្តិសុខស្បៀង មានការរីកចម្រើនទៀតទាត់ឡើយ ។ បច្ចុប្បន្ន មានប្រទេសកាន់តែ

ច្រើនប្រឈមមុខនឹងកង្វះខាតស្បៀងអាហារ ហើយទ្វីបអាស៊ីនៅមានអ្នកអត់ឃ្លានច្រើនជាងតំបន់ផ្សេងទៀតនៃពិភពលោក ពោលគឺមានចំនួនជាង ៥១០ លាននាក់។

ចំពោះបញ្ហាសុខភាពវិញ រូបភាពបានបង្ហាញពីសញ្ញាវិជ្ជមានជាទូទៅ។ សម័យកាលកំណើនសេដ្ឋកិច្ច ដែលនាំមុខដោយពាណិជ្ជកម្មត្រូវបានគួបផ្សំជាមួយការកែលម្អសុខភាព ប៉ុន្តែ វិស័យនេះទំនងជាមានការយឺតយ៉ាវក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប៉ុន្តែ បញ្ហាមួយដែលនឹងកើតឡើងក្នុងពេលឆាប់ៗនេះ គឺកិច្ចព្រមព្រៀងដែលជម្រុញដោយអង្គការពាណិជ្ជកម្មពិភពលោកស្តីពីកម្មសិទ្ធិបញ្ញា អាចចាប់ផ្តើមរារាំងដល់ការផ្គត់ផ្គង់ថ្នាំពេទ្យទូទៅសំខាន់ៗមួយចំនួន។

គេអាចរំពឹងថាពាណិជ្ជកម្មនឹងបង្កើននិយាមអប់រំតាមរយៈការផ្តល់ការលើកទឹកចិត្តកាន់តែច្រើនដល់ប្រជាពលរដ្ឋដើម្បីពង្រីកជំនាញរបស់គេ។ ប៉ុន្តែ នៅទីនេះក៏អញ្ចឹងដែរ ការរីកចម្រើនគឺមានលក្ខណៈមិនគ្រប់គ្រាន់ឡើយ។ បញ្ហាធំជាងគេបំផុតគឺមាននៅអាស៊ីខាងត្បូងដែលនៅទីនោះក្នុង ចំណោមកុមារប្រាំនាក់ មានកុមារម្នាក់មិនបានចូលរៀននៅកម្រិតបឋមសិក្សា។

ពាណិជ្ជកម្មក៏មានឥទ្ធិពលខ្លាំងទៅលើទំនាក់ទំនងយេនឌ័រផងដែរ។ ចរន្តនាំចេញនៅអាស៊ីបូព៌ាក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០ គឺពឹងផ្អែកយ៉ាងខ្លាំងលើការគៀងគរកម្មការិនី។ ដោយអាចទទួលប្រាក់ចំណូលឯករាជ្យ ស្ត្រីជាច្រើនបានទទួលសេរីភាពផ្ទាល់ខ្លួនកាន់តែច្រើនតាមនោះដែរ ប៉ុន្តែបានត្រឹមតែក្នុងកម្រិតមួយប៉ុណ្ណោះ។ ស្ត្រីដែលមានការងារធ្វើទូទាំងពិភពលោក សុទ្ធតែជាអ្នកមានបន្ទុកការងារត្រួតទៅឯផ្ទះ និងការងារដែលទទួលបានប្រាក់បំណាច់នៅក្រៅផ្ទះ។ ហើយនៅកន្លែងធ្វើការ ពួកគេច្រើនតែជាពលរដ្ឋវណ្ណៈទីពីរ កាលណានិយាយដល់ការគ្រប់គ្រង និងការចាត់ចែងការងារ ហើយអាចធ្លាក់ខ្លួនទៅក្នុងការបៀតបៀនផ្លូវភេទផង។

## ការពង្រីកច្រកការងារ

តាមពិត ចំពោះស្ត្រីនិងបុរស ច្រកចម្បងដែលនាំឱ្យមានផលប៉ះពាល់ពាណិជ្ជកម្មទាំងអស់នេះទៅលើការអភិវឌ្ឍមនុស្ស ដើម្បីឱ្យបានកាន់តែប្រសើរ ឬកាន់តែអាក្រក់ គឺកើតឡើងតាមរយៈការងារ។ ប្រការល្អបំផុតគឺ ពាណិជ្ជកម្មកាន់តែច្រើនមានន័យថា មានការងារកាន់តែច្រើន និងភាពគ្មានការងារធ្វើកាន់តែតិច។ ជាអកុសល ប៉ុន្មានឆ្នាំកន្លងមកនេះ សេចក្តីសន្និដ្ឋាននេះមិនបានកើតឡើងញឹកញាប់ឡើយ។

ទោះបីជាប្រទេសនានានៅអាស៊ី បានបង្កើតការងារយ៉ាងឆាប់រហ័សក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ដែលមានចំនួនសរុប ៣៣៧ លាននាក់ក៏ដោយ ក៏ពាណិជ្ជកម្មបានបង្កើតការងារកាន់តែតិចគឺបានតែ ១៧៦ លាននាក់ប៉ុណ្ណោះ ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ ចំនួននេះមិនបានផ្តល់ការងារគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋដែលកើនឡើងទេ ពោលគឺក្នុងចន្លោះឆ្នាំ ១៩៩៣ និង ២០០៣ អត្រានិកម្មភាពនៅអាស៊ីអាគ្នេយ៍ បានកើនពី ៣.៩% ដល់ ៦.៣%។ ហើយប្រការគួរឱ្យព្រួយបារម្ភ គឺថាស្ថានភាពច្រើនតែធ្លាក់ដុនដាប នៅក្នុងប្រទេសខ្លះដែលមានពាណិជ្ជកម្មច្រើនជាងគេ ឧទាហរណ៍ដូចជាប្រទេសចិន និងសិង្ហបុរី ដែលត្រូវបានពិនិត្យឃើញមានអត្រានិកម្មភាពកើនខ្លាំងជាងគេ។ បន្ទុកនេះភាគច្រើនត្រូវធ្លាក់ទៅលើក្រុមមនុស្សក្មេងៗ ពោលគឺក្នុងឆ្នាំ ២០០៤ ជាពេលដែលយុវជនដែលមានអាយុ ១៥ឆ្នាំ ឈានដល់អាយុ ២៤ឆ្នាំ បង្កើតបានកម្លាំងពលកម្ម ១/៥ ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ចំនួននេះស្ទើរតែស្មើពាក់កណ្តាលនៃចំនួនអ្នកគ្មានការងារធ្វើ។ ដូចគ្នានេះដែរ ស្ត្រីក៏ត្រូវគេបំភ្លេចចោល ជាពិសេស ក្នុងប្រទេសជាច្រើនអត្រានិកម្មភាពស្ត្រី គឺខ្ពស់ជាងបុរស។

*ច្រកចម្បងដែលនាំឱ្យមានផលប៉ះពាល់ពាណិជ្ជកម្មទាំងអស់នេះទៅលើការអភិវឌ្ឍមនុស្សដើម្បីឱ្យបានកាន់តែប្រសើរ ឬកាន់តែអាក្រក់ គឺកើតឡើងតាមរយៈការងារ។*

ហេតុអ្វីបានជាតំបន់នេះជួបប្រទះ "កំណើនបាត់បង់ការងារ"? បញ្ហាភាគច្រើនគឺកើតឡើងនៅអាស៊ីបូព៌ា និងជាពិសេសក្នុងវិស័យផលិតកម្ម ដោយសារទោះបីជាលទ្ធផលនៃផលិតកម្មបានកើនឡើងជិត ១៨០% ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ក្តី ក៏កំណើនការងារពាក់ព័ន្ធមានអត្រាត្រឹមតែ ៣% ប៉ុណ្ណោះ។ បញ្ហាចម្បង គឺដោយសារវិស័យផលិតកម្មបានប្តូរចេញពីឧស្សាហកម្មបច្ចេកវិទ្យាទាបដែលប្រើពលករច្រើន ដូចជាវិស័យកាត់ដេរជាដើម ទៅជាឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់ដែលប្រើទុនច្រើន ដូចជា វិស័យអេឡិចត្រូនិក ហើយសូម្បីតែនៅក្នុងវិស័យផលិតកម្មដែលប្រើពលករច្រើនក្តី ក៏ក្រុមហ៊ុនទាំងឡាយបានបន្តវិនិយោគលើឧបករណ៍សន្សំសំចៃពលករដែរ។

ស្ថានភាពការងារមានលក្ខណៈខុសៗគ្នានៅអាស៊ី។ ក្នុងតំបន់នេះ ក្រៅពីការបន្ថយល្បឿនបន្តិចនៃអត្រាកំណើនសេដ្ឋកិច្ច ការងារបានបន្តកើនឡើង ប៉ុន្តែក្នុងចំនួនមានកម្រិត។ បញ្ហានេះបណ្តាលមកពីតំបន់អាស៊ីខាងត្បូងមិនទាន់មានបទពិសោធខាងការកែប្រែរចនាសម្ព័ន្ធទាំងស្រុង ពោលគឺការបន្តពឹងផ្អែកលើឧស្សាហកម្មប្រើពលករច្រើន និងឧស្សាហកម្មពឹងផ្អែកលើធនធានធម្មជាតិ។ ការពឹងផ្អែកបែបនេះ អាចនាំឱ្យកំណើនសេដ្ឋកិច្ចយឺតយ៉ាវ ប៉ុន្តែ យ៉ាងហោចណាស់ក៏វាបានបែងចែកផលប្រយោជន៍កាន់តែមានសមភាព ដែរ។

បទពិសោធនៅអាស៊ី-ប៉ាស៊ីហ្វិកបានបង្ហាញច្បាស់ថាពាណិជ្ជកម្មតែមួយមុខមិនអាចដោះស្រាយបញ្ហាវិសមភាពបានទេ ផ្ទុយទៅវិញវាធ្វើឱ្យបញ្ហានេះកាន់តែធ្ងន់ធ្ងរឡើង។ រដ្ឋាភិបាលជាច្រើនបានទទួលស្គាល់ថាខ្លួនត្រូវតែកំណត់គោលនយោបាយបំពេញបន្ថែម ដើម្បីធានាឱ្យមានការចូលរួមកាន់តែច្រើនក្នុងទីផ្សារអន្តរជាតិ ព្រមជាមួយនឹងការបង្កើតការងារ និងការលើកកម្ពស់ការអភិវឌ្ឍមនុស្ស។

## ការធ្វើឱ្យពាណិជ្ជកម្មកសិផលជួយដល់ជនក្រីក្រ

ការងារទាំងនេះមិនអាចមានសម្រាប់តែវិស័យឧស្សាហកម្ម ឬសេវាកម្មទំនើបតាមតំបន់ជាយក្រុងប៉ុណ្ណោះទេ ប៉ុន្តែត្រូវបង្កើននៅតាមតំបន់ជនបទ និងក្នុងវិស័យកសិកម្មផងដែរ។ ក្នុងខណៈពេលកំណត់ទស្សនៈវិស័យរបស់ខ្លួនលើពាណិជ្ជកម្មអន្តរជាតិ រដ្ឋាភិបាលជាច្រើននៅក្នុងតំបន់បានបំភ្លេចចោលវិស័យកសិកម្ម ហើយវិនិយោគកាន់តែតិចនៅតំបន់ជនបទ។ តាមពិត សេរីភាវូបនីយកម្មច្រើនតែមើលរំលងផលិតកម្មស្បៀងអាហារក្នុងស្រុក ដោយអនុញ្ញាតឱ្យមានការនាំចូលចំណីអាហារដែលមានតម្លៃថោក។ ទំនិញទាំងនេះផ្តល់ផលប្រយោជន៍ដល់អ្នកប្រើប្រាស់ដែលមានចំណូលទាប ប៉ុន្តែវាអាចគម្រាមកំហែងដល់ជីវភាពរស់នៅរបស់កសិករក្រីក្រ និងសហគមន៍អ្នកនេសាទដែលមានផលវិបាកធ្ងន់ធ្ងរលើគោលការណ៍សមធម៌។

*ការងារទាំងនេះមិនអាចមានសម្រាប់តែវិស័យឧស្សាហកម្ម ឬសេវាកម្មទំនើបតាមតំបន់ជាយក្រុងប៉ុណ្ណោះទេ ប៉ុន្តែត្រូវបង្កើននៅតាមតំបន់ជនបទ និងក្នុងវិស័យកសិកម្មផងដែរ។*

ភស្តុតាងដែលច្បាស់បំផុតនៃការមិនអើពើដល់ជនបទ គឺការអន្តរាយធ្ងន់ធ្ងរចំពោះជញ្ជីងពាណិជ្ជកម្មកសិផល។ នៅដើមទសវត្សរ៍ឆ្នាំ ១៩៦០ ប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយមានអតិរេកពាណិជ្ជកម្មកសិផលប្រចាំឆ្នាំសរុបប្រហែល ៧ ពាន់លានដុល្លារ ប៉ុន្តែ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០មក ជាទូទៅពួកគេបានក្លាយទៅជាអ្នកនាំចូលផលិតផលកសិកម្ម ឧទាហរណ៍ ជាមួយនឹងឱនភាព ចំនួន ១១ ពាន់លានដុល្លារ នៅឆ្នាំ ២០០១។

ប្រទេសទាំងឡាយនៅតំបន់អាស៊ីប៉ាស៊ីហ្វិក បានចូលរួមចំណែកក្នុងការបង្កើនអតុល្យភាពនេះ។ តាមការពិត ពួកគេមិនដែលក្លាយជាការីចម្បងក្នុងទីផ្សារសកលលោកទេ។ តាមពិត ក្នុងចំណោមអ្នកនាំចេញជោគជ័យនៅអាស៊ី មានតែ

ប្រទេសចិនទេដែលទទួលបានជោគជ័យ ដែលមួយផ្នែកគឺបានមកពីការនាំចេញកសិផល ប៉ុន្តែប្រទេសមួយចំនួនទៀត ដូចជាសាធារណរដ្ឋកូរ៉េ និងម៉ាឡេស៊ី បានប្រើអតិរេកដែលទទួលបានពីវិស័យកម្មដើម្បីវិនិយោគក្នុងវិស័យនាំចេញរបស់គេ។ ហើយសូម្បីតែក្នុងពេលបច្ចុប្បន្ន ប្រទេសវៀតណាមបានប្រើការនាំចេញកសិផលជាប្រភពសំខាន់សម្រាប់ការប្តូររូបិយប័ណ្ណបរទេស។

ប៉ុន្តែ ប្រការដែលគួរព្រួយបារម្ភខ្លាំង គឺថាប្រទេសមួយចំនួនមិនត្រឹមតែនាំចេញតិចប៉ុណ្ណោះទេពួកគេទំនងជានឹងក្លាយទៅជាអ្នកនាំចូលដ៏ធំផងដែរ ជាពិសេសប្រទេសចិន។ ហេតុនេះការផ្គត់ផ្គង់ស្បៀងអាហារអាចមានលក្ខណៈកាន់តែចង្អៀតខ្លាំង។ ប្រការនេះចោទជាសំណួរអំពីសន្តិសុខស្បៀង។ ស្បៀងអាហារមិនដូចទំនិញដែលអាចជួញដូរបានផ្សេងទៀតទេ ហើយប្រទេសជាច្រើនចូលចិត្តអ្វីៗដែលបំពេញតម្រូវការប្រទេសខ្លួនឯង។ ដូច្នេះ វានឹងមានន័យថាការយកចិត្តដាក់កាន់តែខ្លាំងទៅលើផលិតកម្មក្នុងស្រុក និងផ្តល់ការការពារកាន់តែច្រើនដល់កសិករដែលមានការពិបាកក្នុងការប្រកួតប្រជែងតាមតម្លៃពិភពលោក ជាពិសេសនៅពេលដែលតម្លៃទាំងនេះមិនមានលក្ខណៈពិតដោយសារការឧបត្ថម្ភធននៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបដែលផ្តល់លទ្ធភាពឱ្យគេនាំចេញក្នុងតម្លៃទាបជាងថ្លៃផលិត។

តំបន់អាស៊ី-ប៉ាស៊ីហ្វិកមានចំណុចទទួលផលចំណេញជាច្រើនដោយការជម្រុញពាណិជ្ជកម្មកសិផលដែលមានសមធម៌ជាទូទៅ ប៉ុន្តែវាគឺជាការពិត ជាពិសេសចំពោះវិស័យនេសាទ។ ប្រទេសទាំងឡាយក្នុងតំបន់នាំចេញ ១/៣ នៃការនាំចេញត្រី និងផលិតផលនេសាទ។ បច្ចុប្បន្ននេះ ប្រទេសចិនគឺជាប្រទេសនាំចេញត្រីធំបំផុតក្នុងពិភពលោក ខណៈដែលប្រទេសជប៉ុនគឺជាប្រទេសនាំចូលត្រីធំជាងគេបំផុត ប៉ុន្តែ ពាណិជ្ជកម្មត្រីមានសារៈសំខាន់នៅក្នុងទូទាំងតំបន់។ តាមពិត តំបន់អាស៊ី-ប៉ាស៊ីហ្វិក គឺជាតំបន់រស់នៅសម្រាប់អ្នកនេសាទ ៩៨% ក្នុងពិភពលោក និង ៩៥% នៃកសិករចិញ្ចឹមត្រីទូទាំងពិភពលោក។

ក្នុងករណីខ្លះ អ្នកនេសាទមានជំហររឹងមាំជាងកសិករ ដោយសារគេលក់ផលិតផលមួយផ្នែកធំបានទៀងទាត់ និងមានស្ថេរភាព។ ប៉ុន្តែ ចំពោះករណីផ្សេងទៀត ពួកគេអាចងាយរងគ្រោះដែលបណ្តាលមកពីកត្តាធម្មជាតិ ដូចជាការប្រែប្រួលផលនេសាទ ដោយសារអាកាសធាតុ ហើយប្រថុយជីវិតនិងព្យុះសង្ឃរា ឬបណ្តាលមកពីកត្តាសេដ្ឋកិច្ចទាំងឡាយ ដូចជា ការប្រែប្រួលតម្លៃ និងការប្រែប្រួលលទ្ធភាពចូលទីផ្សារជាដើម។

សហគមន៍អ្នកនេសាទជាច្រើនបានទទួលចំណូលទាបស្រាប់ហើយ ប៉ុន្តែស្ថានភាពរបស់គេអាចកាន់តែធ្ងន់ធ្ងរកាលណាធនធានត្រីត្រូវហិនហោចអស់។ ការប្រកួតប្រជែងដ៏តានតឹងក្នុងវិស័យនេសាទបើកចំហកំពុងតែនាំទៅរកការនេសាទហួសកម្រិតនៅក្នុងតំបន់ពាណិជ្ជកម្មសំខាន់ៗជាច្រើន។ វិស័យនេសាទអាស៊ីក៏ប្រឈមមុខផងដែរនឹងបញ្ហាចូលដល់ទីផ្សារនៅក្នុងប្រទេសអភិវឌ្ឍន៍ដែលតម្រូវឱ្យមានស្តង់ដារសុវត្ថិភាពចំណីអាហារកាន់តែខ្ពស់។

ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវប្រឈមនឹងជម្រើសគោលនយោបាយដ៏ស្មុគស្មាញមួយចំនួនអំពីពាណិជ្ជកម្មកសិផល ពោលគឺត្រូវសម្រេចថាតើខ្លួនអាចពឹងផ្អែកលើការនាំចូលត្រឹមកម្រិតណា។ ប្រទេសខ្លះបានសម្រេចវិនិយោគក្រៅវិស័យកសិកម្ម ឬក្នុងវិស័យកសិកម្ម ប៉ុន្តែបានសង្កត់ធ្ងន់លើមុខទំនិញដែលអាចនាំចេញបាន។ ការធ្វើបែបនេះអាចមានមូលហេតុសមស្របតាមទស្សនៈវិស័យប្រសិទ្ធិភាពសេដ្ឋកិច្ច ប៉ុន្តែគ្មានមូលហេតុចំពោះទស្សនវិស័យអភិវឌ្ឍន៍មនុស្សឡើយ។ ក្នុងរយៈពេលមួយ ការបង្កើនពាណិជ្ជកម្មកសិផលអាចជម្រុញ

កំណើនសេដ្ឋកិច្ចបាន និងមានផលចំណេញដល់អ្នកប្រើប្រាស់ក្រីក្រ ហើយក៏ទំនងជានឹងដាក់សម្ពាធទៅលើតម្លៃក្នុងស្រុក និងធ្វើឱ្យខូចខាតដល់ជីវភាពរស់នៅរបស់កសិករក្រីក្រផងដែរ ។

## ការកែតម្រូវតាមសម័យកាលថ្មី សម្រាប់វិស័យវាយនភណ្ឌ និង សំលៀកបំពាក់

វិស័យមួយផ្សេងទៀតដែលមានសារៈសំខាន់ខ្លាំងចំពោះគ្រួសារក្រីក្រជាច្រើនដែរនោះ គឺវិស័យវាយនភណ្ឌ និងឧស្សាហកម្មកាត់ដេរ ដែលនៅក្នុងប្រទេសជាច្រើនវិស័យនេះមានតួនាទីជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម ។ ក្នុងករណីនេះ តំបន់អាស៊ី-ប៉ាស៊ីហ្វិកកំពុងស្ថិតនៅក្នុងភាពចលាចលដែលអាចកើតឡើងនៅពេលដែលថាប្រទេសអភិវឌ្ឍន៍ បានបោះបង់ចោលប្រព័ន្ធកូតាក្រោមកិច្ចព្រមព្រៀងវាយនភណ្ឌចម្រុះ ។ កិច្ចព្រមព្រៀងនេះហាមឃាត់ការនាំចូលពីផលិតករធំៗក្នុងតំបន់ ជាពិសេស គឺចិន និងឥណ្ឌា ប៉ុន្តែបានផ្តល់កូតាទៅឱ្យប្រទេសជាច្រើន ដូចជា បង់ក្លាដេស និងណេប៉ាល់ ដែលបានប្រើកូតាទាំងនោះជាមូលដ្ឋានទាក់ទាញឧស្សាហកម្មថ្មីៗ ។ លទ្ធផលដែលទទួលបានគឺមានឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរជាច្រើនកើតឡើងពាសពេញតំបន់ដោយបង្កើតការងាររាប់សែនសម្រាប់កម្មករដែលមានជំនាញតិចនិងក្រីក្រ ហើយភាគច្រើនជាស្ត្រី ដែលមានអត្រា ៩០% នៅបង់ក្លាដេស និង ៨៧% នៅស្រីលង្កា ។

ចាប់តាំងពីយុគសម័យនោះបានបញ្ចប់នៅឆ្នាំ ២០០៤ ភាគច្រើននៃផលិតករទាំងនោះ បានពុះពារកែតម្រូវតាមការប្រកួតប្រជែងផ្ទាល់ ជាពិសេសជាមួយប្រទេសចិន ។ ដូច្នេះហើយ លទ្ធផលរបស់ប្រទេសមួយចំនួនមិនបានធ្លាក់ក្នុងស្ថានភាពធ្ងន់ធ្ងរដូចដែលគេបានបារម្ភឡើយ ។ តាមពិត ជារួម ផលិតករនៅទ្វីបអាស៊ីបានមានស្នាដៃប្រសើរច្រើនជាងផលិតករនៅក្នុងតំបន់ផ្សេងទៀតហើយថែមទាំងបានបង្កើនចំណែកនៃការនាំចេញទៅសហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុបទៀតផង ។ ប៉ុន្តែផលចំណេញមិនត្រូវបានចែករំលែកប្រកបដោយសមធម៌ដូចបានរំពឹងទុកឡើយ ។ អ្នកឈ្នះធំជាងគេ មានចិន និង ឥណ្ឌា ហើយអ្នកចាញ់ធំជាងគេមានណេប៉ាល់ ហ្វីលីពីន និង ថៃ ។ ទោះជាយ៉ាងនេះក្តី គេគួរកត់សម្គាល់ថាមានប្រទេសមួយចំនួនដែលបានពឹងផ្អែកលើកូតា អាចមានលទ្ធភាពរក្សាឬបង្កើនចំណែកក្នុងទីផ្សារបានដែរ ពោលគឺប្រទេសកម្ពុជា វៀតណាម ឥណ្ឌូណេស៊ី ស្រីលង្កា និង បង់ក្លាដេស ។

*មធ្យោបាយតែមួយគត់ដើម្បីរស់រានបានក្នុងទីផ្សារប្រកួតប្រជែងសកលលោក គឺត្រូវបង្កើនគុណភាពឧស្សាហកម្ម និងបង្កើនទាំងគុណភាព និងបរិមាណ ផលិតផល ។*

ប៉ុន្តែសូម្បីក្នុងបច្ចុប្បន្នក្តីក៏យើងពិបាកនឹងប្រមើលវាសនាអនាគតនៃពាណិជ្ជកម្មវាយនភណ្ឌនិងសំលៀកបំពាក់ ពីព្រោះប្រទេសអភិវឌ្ឍន៍បានការពារខ្លួនគេទល់នឹងកំណើនទំនិញនាំចូលដោយប្រើការហាមប្រាមបណ្តោះអាសន្ន ។ ប៉ុន្តែអ្វីដែលច្បាស់គឺមានមធ្យោបាយតែមួយគត់ដើម្បីរស់រានបានក្នុងទីផ្សារប្រកួតប្រជែងសកលលោកគឺត្រូវបង្កើនគុណភាពឧស្សាហកម្ម និងបង្កើនទាំងគុណភាព និងបរិមាណផលិតផល ។ ចំណុចនេះក៏នឹងមានន័យផងដែរថាជាការកែលម្អល័ក្ខខ័ណ្ឌការងារ ដោយសារអ្នកនាំចេញស្ថិតក្រោមសម្ពាធពីអង្គការពាណិជ្ជកម្មឱ្យធានាថាទំនិញរបស់គេ មិនត្រូវបានផលិតក្រោមល័ក្ខខ័ណ្ឌកេងប្រវ័ញ្ចឡើយ ។ ពាណិជ្ជកម្មវាយនភណ្ឌ និងសំលៀកបំពាក់ដែលមានកម្រិតខ្ពស់អាចលើកកម្ពស់ការអភិវឌ្ឍមនុស្សបាន ប៉ុន្តែអាចទៅរួចបានតែក្នុងករណីដែលរដ្ឋាភិបាល និងនិយោជក ចាត់វិធានការចាំបាច់តែប៉ុណ្ណោះ ។

## ការលក់សេវាឆ្លងកាត់ព្រំដែន

ប្រទេសនៅតំបន់អាស៊ីនៅបន្តពឹងពាក់លើពាណិជ្ជកម្មទំនិញអន្តរជាតិ ។ ក៏ប៉ុន្តែ នៅក្នុងបីទសវត្សរ៍កន្លងមកនេះ ប្រទេសទាំងនេះបានទាញយកអត្ថប្រយោជន៍ពីឱកាសពង្រីក

ពាណិជ្ជកម្មសេវា ហើយជាផលវិបាក ពាណិជ្ជកម្មអន្តរជាតិបានក្លាយទៅជាមានភាពស្មុគស្មាញកាន់តែខ្លាំង។ រឿងនេះទាក់ទិននឹងចលនាឆ្លងកាត់ព្រំដែនបីប្រភេទ: មួយគឺអ្នកលក់ធ្វើចលនា ដូចជានៅក្នុងពលកម្មចំណាកស្រុក មួយទៀតគឺការងារធ្វើចលនា ដូចជានៅក្នុងការជួលអាជីវកម្មពីក្រៅ និងមួយទៀតគឺអ្នកទិញធ្វើចលនា ដូចជានៅក្នុងវិស័យទេសចរណ៍អន្តរជាតិ។

ចលនាទាំងបីប្រភេទនេះបានកើនឡើងជាដុំកំភួន។ ចំពោះពលកម្មចំណាកស្រុក កម្មករដែលមានជំនាញកម្រិតទាបជាច្រើនលាននាក់បន្តធ្វើដំណើរទៅបរទេសដោយអាស្រ័យលើកិច្ចសន្យារយៈពេលខ្លី: ប្រហែល ១០% នៃកម្លាំងពលកម្មហ្វីលីពីន និង ១២% នៃកម្លាំងពលកម្មស្រីលង្កា បច្ចុប្បន្ននេះកំពុងធ្វើការនៅឯនាយសមុទ្រ។ ពលករចំណាកស្រុកជាច្រើនបានធ្វើឱ្យគុណភាពនៃជីវភាពរស់នៅរបស់ពួកគេមានភាពប្រសើរឡើងនិងសូម្បីតែពលករដែលក្របំផុតនោះក៏អាចបានទទួលប្រាក់កម្រៃគ្រប់គ្រាន់សម្រាប់លើកស្ទួយជីវភាពគ្រួសាររបស់ពួកគេចេញពីភាពក្រខ្សត់បានដែរ។ ក៏ប៉ុន្តែ ពលករទាំងនេះអាចធ្វើការនៅក្រោមស្ថានភាពត្រូវគេកេងប្រវ័ញ្ចផងដែរ និងត្រូវបានកាត់ផ្តាច់ទាំងស្រុងពីជីវភាពរស់នៅនៅឯស្រុកកំណើតរបស់ខ្លួន។ ទាំងប្រទេសដែលជាដើមកំណើតនិងប្រទេសដែលជាទិសដៅអាចធ្វើឱ្យពលកម្មចំណាកស្រុកបានទទួលផលច្រើននិងត្រូវតាមបទពិសោធដោយប្រទេសដែលជាដើមកំណើត អាចធានាថាពលករចំណាកស្រុកបានទទួលព័ត៌មានគ្រប់គ្រាន់ មានការគាំទ្រជាប្រាក់កាស និងបានទទួលការបណ្តុះបណ្តាលមុននឹងពួកគេចេញដំណើរ ហើយប្រទេសដែលជាទិសដៅអាចធ្វើឱ្យដំណើរការពលកម្មចំណាកស្រុកមានភាពងាយស្រួលនិងមានតម្លាភាពយ៉ាងច្រើន។

តំបន់អាស៊ីក៏ជាអ្នកត្រួសត្រាយផងដែរក្នុងការធ្វើវិនិយោគផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសេវាដំណើរការអាជីវកម្មនៅឯនាយសមុទ្រ: នៅក្នុងករណីខ្លះ កម្មករបច្ចេកវិទ្យាព័ត៌មានបន្តធ្វើដំណើរទៅបរទេស ដើម្បីធ្វើការងាររយៈពេលខ្លីនៅក្នុងប្រទេសជឿនលឿន ប៉ុន្តែការរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ និងការថយចុះនៃចំណាយនៅក្នុងការតភ្ជាប់តាមប្រព័ន្ធអ៊ិនធឺណិត អាចអនុញ្ញាតឱ្យសេវាទាំងនេះត្រូវបានផ្តល់កាន់តែច្រើនឡើងពីចម្ងាយដោយផ្តល់ការងារដល់យុវជនដែលបានរៀនសូត្រយ៉ាងជ្រៅជ្រះក៏ដូចជាទាក់ទាញឱ្យចូលក្នុងកម្លាំងពលកម្មនូវបណ្តាក្រុមផ្សេងទៀត ដូចជាអ្នកចូលនិវត្តន៍ជាដើម។ ទោះជាយ៉ាងណាក្តីក៏ប្រការនេះមានផលប៉ះពាល់លើមនុស្សផងដែរ: ឧទាហរណ៍ វេនការងារយប់វែងអាចបង្កឱ្យមានផលអាក្រក់ដល់សុខភាពនិងរារាំងមិនឱ្យមានជីវភាពសង្គមធម្មតា ដោយបំបែកកម្មករពីសហគមន៍របស់ពួកគេ។ ម្យ៉ាងទៀត កំណើនដ៏លឿននៃឧស្សាហកម្មជួលពីខាងក្រៅក៏ធ្វើឱ្យមានភាពខុសគ្នាកាន់តែខ្លាំងឡើងនៅក្នុងតំបន់ផងដែរ។ រដ្ឋាភិបាលបារម្ភផងដែរថាពួកគេមិនបានបង្កើតឱ្យមានកម្មករជំនាញគ្រប់គ្រាន់សម្រាប់ពង្រីកឧស្សាហកម្មនោះ។ ប៉ុន្តែរដ្ឋាភិបាលទាំងនេះមានជម្រើសគោលនយោបាយច្រើនដែលអាចធានាបានថាការជួលពីក្រៅអាចបង្កើតបានជាវិភាគទានយ៉ាងខ្លាំងក្លាចំពោះការអភិវឌ្ឍធនធានមនុស្ស រួមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធ ការបណ្តុះបណ្តាលកម្លាំងពលកម្ម និងធានាឱ្យមានបរិស្ថាន និយ័តកម្ម និងសារពើពន្ធល្អប្រសើរ។

នៅក្នុងវិស័យទេសចរណ៍ក៏ដូច្នេះដែរ តំបន់អាស៊ី-ប៉ាស៊ីហ្វិកគឺជាអ្នកនាំមុខពិភពលោកដោយបានបង្កើនចំណែករបស់ខ្លួននៅក្នុងចរាចរពិភពលោកពីកម្រិតតិចជាង ១០% នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ដល់ ៤០% នៅក្នុងឆ្នាំ២០០៤។ ទេសចរណ៍អាចផ្តល់ឱ្យមានប្រភពការងារថ្មី សូម្បីតែនៅក្នុងតំបន់ឆ្ងាយដាច់ស្រយាលក៏ដោយ។ ក៏ប៉ុន្តែ វិស័យនេះក៏អាចបង្កឱ្យមានផលប៉ះពាល់ផងដែរ ឧទាហរណ៍ ដូចជាការប្តូរទី

*តំបន់អាស៊ីក៏ជាអ្នកត្រួសត្រាយផងដែរក្នុងការធ្វើវិនិយោគផ្នែកបច្ចេកវិទ្យាព័ត៌មាន និង សេវាដំណើរការអាជីវកម្មនៅឯនាយសមុទ្រ*

កន្លែងវប្បធម៌ និងការបំផ្លិចបំផ្លាញបរិស្ថាន។ គេអាចដោះស្រាយបញ្ហាជាច្រើនបានឬធ្វើឱ្យមានផលប៉ះពាល់តិចបំផុតតាមរយៈការធ្វើផែនការ និងការគ្រប់គ្រងសមស្រប ឧទាហរណ៍ដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធសមស្រប ការផ្តល់ការបណ្តុះបណ្តាលដល់កម្មករដែលធ្វើការនៅក្នុងសហគ្រាសតូចតាច និងដោយធានាឱ្យមានសម្ព័ន្ធភាពសេដ្ឋកិច្ចល្អប្រសើររវាងការីទេសចរណ៍ធំៗនិងបណ្តាសហគមន៍ក្រខ្សត់។

## ឱកាសធ្វើពាណិជ្ជកម្មសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច

បញ្ហាពាណិជ្ជកម្មទាំងអស់នេះមានសារៈសំខាន់ពិសេសនៅក្នុងប្រទេសអភិវឌ្ឍន៍ទាបជាងគេបំផុត។ ចំពោះប្រទេសអភិវឌ្ឍន៍ទាបជាងគេបំផុតជាច្រើន ពាណិជ្ជកម្មតំណាងឱ្យសមាមាត្រដ៏ធំនៃសកម្មភាពសេដ្ឋកិច្ច។ ហេតុដូច្នេះហើយ អនុបាតពាណិជ្ជកម្ម-ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសទាំងនោះច្រើន តែមានកម្រិតខ្ពស់ជាងអនុបាតពាណិជ្ជកម្ម-ផលិតផល ក្នុងស្រុកសរុបរបស់ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនឬរហូតដល់នៅក្នុងប្រទេសអភិវឌ្ឍន៍ទៀតផង។ ប្រទេសទាំងនេះហាក់ដូចជាមានរបបពាណិជ្ជកម្មទូលំទូលាយ ជាមួយនឹងប្រទេសទាំងឡាយណាដែលមានអត្រាពន្ធទាបឬដែលគ្មានរបាំងពន្ធដារ។

ជាអកុសល ការធ្វើសមាហរណកម្មនៅក្នុងពាណិជ្ជកម្មអន្តរជាតិ ហាក់ដូចជាមិនបាននាំឱ្យមានការកាត់បន្ថយភាពក្រខ្សត់ក្នុងកម្រិតប្រហាក់ប្រហែលគ្នាឡើយ។ នៅពេលដែលត្រូវធ្វើសមាហរណកម្មនៅក្នុងពាណិជ្ជកម្មអន្តរជាតិ ប្រទេសអភិវឌ្ឍន៍ទាបជាងគេបំផុតស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះមែនទែន ដោយសារជាទូទៅ ប្រទេសទាំងនេះមានសេដ្ឋកិច្ចតូចតាច ទីតាំងមិនអំណោយផល និងស្ថិតនៅឆ្ងាយពីទីផ្សារអន្តរជាតិ ដែលនៅក្នុងនោះ ប្រទេសទាំងនេះគឺជាការីតូចតាច ឬអន់ខ្សោយ។

នៅក្នុងកាលៈទេសៈទាំងនេះ ហេតុអ្វីបានជាប្រទេសអភិវឌ្ឍន៍ទាបជាងគេបំផុតចង់ចូលជាសមាជិកនៃអង្គកាពាណិជ្ជកម្មពិភពលោក និងការធ្វើសេរីភាវូបនីយកម្មបន្ថែមទៀត? ដោយសារជម្រើសផ្សេងទៀតនោះមានភាពអាក្រក់ជាង ដូចជាការដាក់ឱ្យនៅដាច់តែឯងឬការត្រួតត្រាទ្វេភាគីដោយមហាអំណាចមួយឬច្រើន។ ទោះបីជានៅមានកម្រិតក្តី ក៏អង្គការពាណិជ្ជកម្មពិភពលោកដែលជាអង្គការពហុភាគីនេះនៅតែជាជម្រើសល្អប្រសើរជាង ប្រសិនបើអង្គការនេះផ្តល់ឱ្យមានវិធានគ្រឹះជាមូលដ្ឋាន និងទៀងទាត់មួយចំនួន។

ប៉ុន្តែ ប្រទេសអភិវឌ្ឍន៍ទាបជាងគេបំផុតបានជួបប្រទះនឹងការលំបាកខ្លាំងក្នុងដំណើរការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ ប្រទេសទាំងនេះខ្វះធនធានមនុស្សជំនាញដែលគេត្រូវការ ដើម្បីយល់ដឹងពីផលប៉ះពាល់ដែលអាចកើតចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្ម។ ហើយដោយសារវិធាន ស្តីពីការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកមានភាពមិនច្បាស់លាស់ សមាជិកចាស់នៃអង្គការនេះអាចកេងយកអត្ថប្រយោជន៍ពីសមាជិកចូលថ្មីដោយដាក់ឱ្យមានល័ក្ខខ័ណ្ឌខុសឆ្គង ដែលជាទូទៅ កាត់បន្ថយសេរីភាពរបស់ពួកគេក្នុងការចាត់វិធានការលើបញ្ហានានា មិនគ្រាន់តែលើតារាងអត្រាពន្ធប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងលើកម្មសិទ្ធិបញ្ញាផងដែរ និងរហូតដល់ទៅលើវិធីដែលប្រទេសទាំងនេះចាត់ចែងសេដ្ឋកិច្ចរបស់ខ្លួនថែមទៀត ឧទាហរណ៍ ដូចជាលើល្បឿន និងកម្រិតនៃឯកជនភាវូបនីយកម្មរបស់ប្រទេសទាំងនោះជាដើម។

ប្រទេសអភិវឌ្ឍន៍ទាបជាងគេបំផុតនៅក្នុងតំបន់អាចចូលរួមក្នុងលក្ខណៈកាន់តែទទួលបានផ្លែផ្កាច្រើននៅក្នុងប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ ក៏ប៉ុន្តែប្រការនេះនឹងចាំបាច់ត្រូវ

កំណត់សកម្មភាពជាមុនឱ្យបានច្រើនទាំងនៅកម្រិតជាតិនិង អន្តរជាតិ។ ឧទាហរណ៍ ប្រការនេះនឹងមានន័យថាផ្តល់អាទិភាព យ៉ាងខ្ពស់ទៅលើបញ្ហាពាណិជ្ជកម្ម បង្កើនវិនិយោគ កសាង សម្ព័ន្ធភាពកាន់តែរឹងមាំ។ ប៉ុន្តែ ប្រទេសអភិវឌ្ឍន៍ទាបជាងគេ បំផុត និងប្រទេសជឿនលឿនគប្បីធានាឱ្យបានថា គំនិតផ្តួចផ្តើម ពាណិជ្ជកម្មនិងការចរចារមិនត្រូវផ្អែកលើការតបស្នងគ្នាទៅវិញ ទៅមកឡើយប៉ុន្តែផ្អែកយ៉ាងច្រើនលើទស្សនៈនៃការអភិវឌ្ឍ ធនធានមនុស្សដោយទាញយកអត្ថប្រយោជន៍ពីកាលានុវត្តភាព នៃ"ជំនួយសម្រាប់ ពាណិជ្ជកម្ម"។

## របៀបវារៈប្រាំបីចំណុច

តើប្រទេសក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ឆ្លើយតបទៅ នឹងការទាមទារឱ្យមានបរិយាកាសថ្មីសម្រាប់ពាណិជម្មអន្តរជាតិ តាមវិធីណា? ច្បាស់ណាស់ហើយគេមិនអាចមានផែនការជា ស្តង់ដារណាមួយនោះទេ ជាពិសេសចំពោះតំបន់ដ៏ធំធេង និង មានភាពចម្រុះគ្នាបែបនេះ។ ប៉ុន្តែ គេមានមធ្យោបាយសម្រាប់ បង្រួបបង្រួមភាពចម្រុះគ្នានេះ ដោយពិនិត្យមើលបញ្ហា ពាណិជ្ជកម្មតាមរយៈទស្សនៈអភិវឌ្ឍន៍ធនធានមនុស្ស។ ការវិភាគនៅក្នុងរបាយការណ៍នេះ ស្នើឡើងនូវអាទិភាពចំនួន ប្រាំបីដែលអាចអនុវត្តបានជាទូទៅ ក្នុងកម្រិតមួយ។

### ១- វិនិយោគដើម្បីភាពប្រកួតប្រជែង

នៅក្នុងពិភពសកលភាវូបនីយកម្ម វិនិយោគ សាធារណៈត្រូវគិតពីការពិចារណាទាំងនៅក្នុងកម្រិតជាតិ និង អន្តរជាតិ។ ជាទូទៅ ប្រភេទនៃវិនិយោគភាគច្រើន គឺស្ថិតនៅ ដដែល ក៏ប៉ុន្តែអាចធ្វើការកែតម្រូវដោយគិតគូរដល់ការប្រកួត ប្រជែងជាអន្តរជាតិ។ ដូច្នេះ នៅពេលដែលពិនិត្យមើលពី ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន រដ្ឋាភិបាលទាំងឡាយចាំបាច់ធានា ឱ្យបានថា ពួកគេមានផ្លូវថ្នល់ ផ្លូវដែក ស្ពាន និងប្រព័ន្ធ ទូរគមនាគមន៍ ដែលបំពេញតាមសេចក្តីត្រូវការក្នុងស្រុក និង ត្រូវតាមតម្រូវការអន្តរជាតិ ក្នុងការបញ្ជូនទំនិញ និងសេវាទៅ កាន់ទីផ្សារអន្តរជាតិឱ្យបានឆាប់រហ័សនិងចុះសោហ៊ុយតិចផង។

ប៉ុន្តែ ធនធានមនុស្សក៏មានសារៈសំខាន់ដូចហេដ្ឋា រចនាសម្ព័ន្ធរូបវន្តអញ្ចឹងដែរ។ ប្រទេសពាណិជ្ជកម្មដែល ជោគជ័យបំផុត បានធ្វើវិនិយោគយ៉ាងច្រើនលើមូលដ្ឋានគ្រឹះនៃ ការអភិវឌ្ឍធនធានមនុស្សដែលបង្កើតបានជាកម្លាំងពលកម្ម ដែលមានសុខភាពរឹងមាំ និងមានចំណេះដឹងជ្រៅជ្រះ ដែលមាន ការអត់ធ្មត់ ជំនាញ និងភាពបត់បែន ដើម្បីទប់ទល់នឹង បរិយាកាសពាណិជ្ជកម្មដែលប្រែប្រួល។ ការអប់រំត្រូវចាប់ផ្តើម ពីការសិក្សារឹងមាំជាសកលនៅកម្រិតបឋមសិក្សា ក៏ប៉ុន្តែ សព្វថ្ងៃនេះ គ្រប់ប្រទេសទាំងអស់ចាំបាច់ត្រូវធានាឱ្យបានថា ខ្លួនមានមនុស្សគ្រប់គ្រាន់ដែលមានជំនាញផ្នែកបច្ចេកទេស និង ការគ្រប់គ្រង។ មនុស្សដែលបានទទួលការអប់រំល្អប្រសើរនៅ បឋមសិក្សាឬមធ្យមសិក្សាអាចប្រើប្រាស់សក្តានុពលរបស់ខ្លួន បានសម្រាប់ពាណិជ្ជកម្មអន្តរជាតិ ប្រសិនបើអ្នកទាំងនេះបាន ទទួលការគាំទ្រពីអ្នកដទៃ ដែលមានកម្រិតសិក្សាជ្រៅជ្រះ ឧទាហរណ៍ ផ្នែកវិស្វកម្ម ទូរគមនាគមន៍ ឬគណនេយ្យ។

ទន្ទឹមគ្នានេះដែរ ប្រទេសជាច្រើនចាំបាច់ត្រូវធ្វើ វិនិយោគយ៉ាងច្រើននៅក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍដែល លើកកម្ពស់ផលិតភាព និងជាពិសេស ដែលឆ្លើយតបទៅនឹង សេចក្តីត្រូវការរបស់ជនក្រីក្រ ដោយវាយតម្លៃជាបន្តបន្ទាប់លើ បច្ចេកវិទ្យាសមស្របបំផុតដែលអាចពឹងផ្អែកលើចំណុចខ្លាំង របស់ប្រទេសជាតិ។ ការវិនិយោគបែបនេះអាចធ្វើឱ្យសម្រេចបាន តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និង ឯកជន ថ្វីបើ ការស្រាវជ្រាវភាគច្រើនអំពីកាលានុវត្តជាក់ស្តែងសម្រាប់ជន ក្រីក្រ ទំនងជាកើតឡើងនៅក្នុងវិស័យសាធារណៈក្តី។

*ប្រទេសពាណិជ្ជកម្ម ដែលជោគជ័យបំផុត បានធ្វើវិនិយោគយ៉ាង ច្រើនលើមូលដ្ឋានគ្រឹះ នៃការអភិវឌ្ឍ ធនធានមនុស្ស*

> *រដ្ឋត្រូវកំណត់អត្តសញ្ញាណបណ្តាផ្នែក និងឧស្សាហកម្មខ្លះៗ ដែលមានសក្តានុពលក្នុងរយៈពេលខ្លី និងរយៈពេលវែង នៅក្នុងទីផ្សារអន្តរជាតិ និងដឹកនាំសហគ្រាសឆ្ពោះទៅរកសក្តានុពលទាំងនោះ។*

## ២- អនុម័តយកគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្ម

នៅក្នុងពិភពនៃការីសកលធំៗ និងការប្រកួតប្រជែងយ៉ាងសាហាវ បច្ចុប្បន្ននេះ គ្មានប្រទេសកំពុងអភិវឌ្ឍន៍ណាមួយមានប្រណិតភាពក្នុងការចូលទៅកាន់ទីផ្សារពិភពលោក និងសង្ឃឹមថានឹងបានទទួលផលប្រសើរបំផុតនោះទេ។ ហេតុនេះ រដ្ឋត្រូវកំណត់អត្តសញ្ញាណបណ្តាផ្នែក និងឧស្សាហកម្មខ្លះៗ ដែលមានសក្តានុពលក្នុងរយៈពេលខ្លី និងរយៈពេលវែងនៅក្នុងទីផ្សារអន្តរជាតិ និងដឹកនាំសហគ្រាសឆ្ពោះទៅរកសក្តានុពលទាំងនោះ។ ឧស្សាហកម្មជម្រើសនេះមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ក៏ប៉ុន្តែគប្បីជាឧស្សាហកម្មទាំងឡាយណាដែលមានលទ្ធភាពផ្សារភ្ជាប់ធំបំផុតជាមួយនឹងបណ្តាឧស្សាហកម្មផ្សេងទៀតដែលអាចឱ្យពួកគេបណ្តុះបណ្តាលមនុស្សបាន ជាច្រើននៅក្នុងជំនាញជាសារវន្ត ហើយដូច្នេះអាចផ្តល់ឱ្យមានប្រយោជន៍ហូរហៀរដល់ផ្នែកសេដ្ឋកិច្ចផ្សេងទៀត។

ពិតមែនហើយ ការជ្រើសរើសអ្នកឈ្នះមិនមែនជាការងាយនោះទេ។ គោលដៅនោះគឺត្រូវធ្វើឱ្យបានសម្រេចនូវគោលនយោបាយសមស្របមួយរវាងរដ្ឋាភិបាល និងផ្នែកឯកជនដែលប្រើអភិក្រមវិន័យ និងរង្វាន់។ រង្វាន់នឹងរួមមានឱកាសសម្រាប់ប្រតិបត្តិការនៅក្រោយរបាំងតារាងអត្រាពន្ធ រហូតទាល់តែក្រុមហ៊ុនមានកម្លាំងគ្រប់គ្រាន់ក្នុងការប្រកួតប្រជែងជាអន្តរជាតិ។ វិន័យគឺថាឧស្សាហកម្មទាំងនេះត្រូវបានពិនិត្យពិច័យយ៉ាងដិតដល់ដើម្បីធានាឱ្យបានថា ក្រុមហ៊ុនទាំងនេះអាចមានជីវិតរហូតដល់ពេលដែលមានការចរចាគ្នានឹងត្រូវផលិតដោយមិនប្រែប្រួលនូវផលិតផលនិងសេវា ដែលអាចប្រកួតប្រជែងបានយ៉ាងជោគជ័យសម្រាប់ការនាំចេញ។ សហគ្រាសត្រូវស្ថិតនៅក្រោមគោលនយោបាយស្តីពីការប្រកួតប្រជែងក្នុងស្រុកផងដែរ ដែលត្រូវបានតាក់តែងឡើងដើម្បីទប់ស្កាត់សហគ្រាសទាំងនោះមិនឱ្យបំពានលើភាពផ្តាច់មុខ។

ប៉ុន្តែ តម្រូវការជាសារវន្តសម្រាប់ការចូលរួមនៅក្នុងពាណិជ្ជកម្មអន្តរជាតិគឺថាត្រូវធ្វើផែនការតាមយុទ្ធសាស្ត្រ និងឱ្យតាមលំដាប់លំដោយយ៉ាងយកចិត្តទុកដាក់បំផុត។ ដូច្នេះ តារាងអត្រាពន្ធខ្ពស់ត្រូវប្រតិបត្តិតាមពេលវេលាយ៉ាងតឹងតែងបំផុត ដើម្បីជៀសវាងការបង្កើតភាពផ្តាច់មុខដែលមិនដែលបង្កើតបានជាសហគ្រាសនាំចេញយ៉ាងខ្លាំងក្លានោះទេ តារាងអត្រាពន្ធត្រូវតែបន្ថយចុះជាស្វ័យប្រវត្តិក្រោយពីរយៈពេលណាមួយដែលបានកំណត់ជាមុន។

## ៣- ស្តារឡើងវិញនូវការយកចិត្តទុកដាក់លើវិស័យកសិកម្ម

យុទ្ធសាស្ត្រពាណិជ្ជកម្មដែលអាស្រ័យលើការអភិវឌ្ឍធនធានមនុស្សត្រូវតែមានកសិកម្មជាស្នូលរបស់វា។ ប្រការនេះមិនមែនដោយហេតុថាកសិកម្មផ្តល់ឱ្យមានកាលានុវត្តភាពសម្រាប់នាំចេញនោះទេ ក៏ប៉ុន្តែ ដោយហេតុថានៅក្នុងប្រទេសជាច្រើន កសិកម្មនៅតែជាប្រភពប្រាក់ចំណូលចម្បងសម្រាប់ជនក្រីក្រ ហេតុដូច្នេះហើយគ្មានយុទ្ធសាស្ត្រពាណិជ្ជកម្មណាមួយដែលធ្វើឱ្យអន្តរាយដល់ជីវភាពរស់នៅទីជនបទអាចអះអាងថាបានលើកស្ទួយការអភិវឌ្ឍមនុស្សនោះទេ។ ជាពិសេសចំពោះប្រទេសដែលនាំចូលចំណីអាហារ គេឃើញមានសារៈសំខាន់ក្នុងការរក្សាឱ្យមានតារាងអត្រាពន្ធលើការនាំចូលចំណីអាហារដើម្បីការពារផលិតករក្រីក្រ។ ប្រសិនបើរឿងនេះបណ្តាលឱ្យមានតម្លៃខ្ពស់ដែលបង្កឱ្យមានការពិបាកយ៉ាងខ្លាំងដល់អ្នកប្រើប្រាស់ក្រីក្រ រដ្ឋាភិបាលត្រូវរៀបចំឱ្យមានប្រព័ន្ធសុវត្ថិភាពសង្គមសមស្រប។ ប្រការនេះមានអត្ថប្រយោជន៍ជាយុទ្ធសាស្ត្រផងដែរក្នុងការរក្សាឱ្យមានសន្តិសុខស្បៀងអាហារជាតិនៅក្នុងពិភពមួយដែលក្នុងរយៈពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះអាចមានតម្លៃចំណីអាហារយ៉ាងខ្ពស់។ ក៏ដូចជាការការពារដែរ កសិករក៏ចាំបាច់ត្រូវមានការរីកចម្រើនផងដែរ។ នៅក្នុងប្រទេសជាច្រើន

ការអភិវឌ្ឍទីជនបទបានថយចុះយ៉ាងខ្លាំង។ គេចាំបាច់ត្រូវតែកែប្រែនិន្នាការនេះឡើងវិញ ជាពិសេសតាមរយៈការធ្វើវិនិយោគ ឧទាហរណ៍ដូចជាការកសាងប្រព័ន្ធស្រោចស្រពទឹក ការផ្គត់ផ្គង់អគ្គិសនីដល់ភូមិ និងការកសាងផ្លូវថ្នល់ពីស្រែចំការទៅកាន់ទីផ្សារ។

## ៤- ប្រយុទ្ធនឹងកំណើននៃភាពអត់ការងារធ្វើ

ជាទូទៅ ប្រទេសជាច្រើនដែលធ្វើឧស្សាហូបនីយកម្ម បានធ្វើឧស្សាហូបនីយកម្មដោយអាស្រ័យលើផលិតកម្មដែលប្រើពលកម្មច្រើននៅក្នុងឧស្សាហកម្មនានា ដូចជាឧស្សាហកម្មសំលៀកបំពាក់ វាយនភណ្ឌ ស្បែកជើងជាដើម ដែលទាញយកអត្ថប្រយោជន៍ពីការផ្គត់ផ្គង់ពលកម្មយ៉ាងធំធេងដែលមានប្រាក់កំរៃទាប។ ក៏ប៉ុន្តែ នៅពេលដែលឧស្សាហូបនីយកម្មដំណើរការទៅមុខប្រទេសទាំងនេះច្រើនតែមានទំនោរទៅកាន់ខ្សែសង្វាក់ផលិតកម្មកម្រិតខ្ពស់ ដែលប្រើមូលធនយ៉ាង ច្រើន។ ជាលទ្ធផល ប្រទេសពាណិជ្ជកម្មដែលបានទទួលជោគជ័យបំផុត ភាគច្រើននៅតំបន់អាស៊ីបូព៌ា បានបង្កើតការងារដោយមានភាពយឺតយ៉ាវមែនទែន ដែលជាបាតុភូតនៃកំណើនភាពអត់ការងារធ្វើ។

គេអាចយល់បានពីដំណើរការនេះនៅក្នុងកម្រិតមួយ។ ប៉ុន្តែ ប្រការដែលមិនសូវអាចយល់បានគឺថា តើហេតុអ្វីបានជារដ្ឋាភិបាលធ្វើឱ្យនិន្នាការនេះកាន់តែមានភាពធ្ងន់ធ្ងរឡើងដោយរក្សាទុកឱ្យមានអត្រាការប្រាក់ទាប ដែលជាចុងក្រោយផ្តល់ឱ្យមានចំណូលចិត្តលើមូលធនជាងពលកម្ម។ ចំណុចនេះអាចជាយុទ្ធសាស្ត្រមួយយ៉ាងប្រសើរចំពោះកំណើនយ៉ាងលឿន ក៏ប៉ុន្តែវាបង្កឱ្យមានបញ្ហាច្រើនណាស់នៅពេលខាងមុខ។ គេគប្បីអនុញ្ញាតឱ្យសហគ្រាសជ្រើសរើសយកសោហ៊ុយតិចបំផុតសម្រាប់ផលិតកម្ម ក៏ប៉ុន្តែ ការជ្រើសរើសនេះមិនត្រូវលំអៀងប្រាសចាកពីពលកម្មនោះទេ ហេតុដូច្នេះហើយ អត្រាការប្រាក់គប្បីឆ្លុះបញ្ចាំងពីតម្លៃពិតប្រាកដនៃមូលធនតែមិនមែនជាអត្រាការប្រាក់ ដែលឧស្សាហករចូលចិត្តនោះទេ។ នៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នានេះដែរ រដ្ឋគប្បីឈប់ប្រើការលើកទឹកចិត្តផ្នែកពន្ធដារដល់សហគ្រាស ដោយហេតុថា រឿងនេះអាចបង្កើនចំណូលលើមូលធននិងជាថ្មីម្តងទៀតជម្រុញឱ្យមានការធ្វើវិនិយោគដោយប្រើមូលធន ច្រើន។

ហេតុផលមួយទៀតថាតើហេតុអ្វីបានជាសហគ្រាសអាចរារែកក្នុងការទទួលយកកម្មករថ្មី គឺថាកិច្ចសន្យាការងារអាចមានភាពតឹងរ៉ឹងមែនទែន។ ប្រការនេះបង្កើតបានជាទ្វិកភាពមួយដែលឋិតថេរនៅយូររវាងក្រុមអ្នកផ្ទៃក្នុង និងអ្នកដែលត្រូវបានការពារដោយមានការធានារ៉ាប់រងអំពីការងារដែលស្ថិតនៅក្រោមនិយ័តកម្មជាតិ និងកម្លាំងពលកម្មដ៏ធំធេងដែលជាញឹកញាប់ត្រូវបានកេងប្រវ័ញ្ចក្នុងការងារតាមអត្រាផលិត។ ផ្ទុយទៅវិញ កម្មករជាច្រើនត្រូវបានបញ្ចូលបន្តិចម្តងៗឱ្យបំពេញការងារជាផ្លូវការ ក៏ប៉ុន្តែ ដោយអាស្រ័យលើកិច្ចសន្យាការងារដែលមានភាពបត់បែនយ៉ាងគ្រប់គ្រាន់ដែលអាចឱ្យពួកគេត្រៀមខ្លួនទៅបំពេញការងារនៅក្នុងផ្នែកឬក្រុមហ៊ុនផ្សេងទៀតបាននៅពេលដែលស្ថានភាពពាណិជ្ជកម្មប្រែប្រួល។ រដ្ឋាភិបាលអាចជួយបាននៅក្នុងដំណើរការនេះដោយផ្តល់ឱ្យមានការគាំទ្រដល់កម្មករតាមរយៈការធានារ៉ាប់រងសុខភាព និងរបបសន្តិសុខសង្គម និងតាមរយៈគោលនយោបាយដ៏សកម្ម ស្តីពីទីផ្សារពលកម្ម ដើម្បីលើកទឹកចិត្តដល់ការបណ្តុះបណ្តាលឡើងវិញ និងការដាក់ពង្រាយសាជាថ្មី។

## ៥- រៀបចំរបបពន្ធដារថ្មី

ការធ្វើសេរីភាវូបនីយកម្ម គឺជាបញ្ញត្តិទូទៅសម្រាប់ជោគជ័យសេដ្ឋកិច្ច ក៏ប៉ុន្តែ វាមានផលប៉ះពាល់ដែលគេមិនចង់បាន ពោលគឺវាមានន័យថាបំភ្លេចចោលប្រភពប្រាក់ចំណូល

រដ្ឋាភិបាល ដែលអាចព្យាករណ៍បាន និងជាប្រភពងាយស្រួលប្រមូលផង។ ដូច្នេះ រដ្ឋាភិបាលត្រូវមានរបបពន្ធដារសម្រាប់ជំនួសរួចជាស្រេចមុននឹងចាប់ធ្វើសេរីភាវូបនីយកម្ម។

ប៉ុន្តែ គេត្រូវយកចិត្តទុកដាក់ក្នុងការធានាឱ្យបានថា ពន្ធដារថ្មីទាំងនេះកើនឡើងជាលំដាប់ដោយមានសមាមាត្រទៅនឹងប្រាក់ចំណូលនិងមិនធ្វើឱ្យប៉ះពាល់ដល់ជនក្រីក្រនោះទេ។ ឧទាហរណ៍ ពន្ធគយជាញឹកញាប់គឺមានលក្ខណៈកើនឡើងជាលំដាប់ ដោយហេតុថាវាមានអត្រាយ៉ាងខ្ពស់លើវត្ថុប្រណិតដែលជាការចាប់អារម្មណ៍ច្រើនរបស់អ្នកមានទ្រព្យធន។ ពន្ធសាជីវកម្ម ក៏កើនឡើងជាលំដាប់ដែរថ្វីបើមនុស្សជាច្រើនអាចគេចវេសមិនបង់ពន្ធតាមចំនួនទូទាត់ស្រេចក៏ដោយ ដោយហេតុថាមេធាវីនៅក្នុងសាជីវកម្មធំៗ មានជំនាញបច្ចេកទេសនៅក្នុងការធ្វើផែនការពន្ធដារ រីឯសហគ្រាសភាគច្រើននៅក្រៅប្រព័ន្ធអាចបន្លំអ្នកទារពន្ធបានយ៉ាងងាយ។ ការពិតគឺដូចគ្នានេះដែរចំពោះពន្ធលើប្រាក់ចំណូលដែលជាទូទៅនិយោជិតដែលធ្វើការនៅក្នុងរដ្ឋាភិបាលឬនៅក្នុងប្រព័ន្ធនិងដែលមានប្រាក់ចំណូលមធ្យមទំនងជាត្រូវបង់យ៉ាងច្រើន។

ការបានប្រាក់ចំណូលយ៉ាងច្រើនពីពន្ធសាជីវកម្ម ឬពន្ធលើប្រាក់ចំណូលមានន័យថាទាមទាឱ្យមានការពិនិត្យមើលច្បាប់ពន្ធដារយ៉ាងយកចិត្តទុកដាក់ ដើម្បីលុបបំបាត់ល្បិចគេចពន្ធស្របច្បាប់ និងត្រូវពិចារណាលើជម្រើសផ្សេងទៀតផងដែរ ដូចជាពន្ធកាត់យកមុន។ បន្ថែមលើនេះ រដ្ឋាភិបាលអាចពិចារណាលើការយកពន្ធលើដីធ្លីនិងពន្ធតម្លៃបន្ថែមនៃមូលធនផងដែរ។ ហើយប្រការដែលជឿនលឿនបំផុតនោះគឺអាចអនុម័តយកពន្ធលើតម្លៃបន្ថែម ថ្វីបើការងារនេះតម្រូវឱ្យមានការប្រមូលផ្ដុំឯកសារសេដ្ឋកិច្ចយ៉ាងហ្មត់ចត់ និងត្រូវការបង្កើតឯកសារទាំងនោះដោយយកចិត្តទុកដាក់ក្ដី។ ទោះជាយ៉ាងណាក្ដី គេមិនត្រូវយកពន្ធលើចំណីអាហារ និងរបស់របរចាំបាច់សម្រាប់ជនក្រីក្រទេ។

ចំណុចជាគន្លឹះគឺថាប្រភពប្រាក់ចំណូលថ្មីទាំងនេះចាំបាច់ត្រូវរៀបចំឱ្យបានស្រេចបាច់ និងដាក់ឱ្យដំណើរការមុននឹងចាប់ផ្ដើមធ្វើសេរីភាវូបនីយកម្ម ឬបើមិនដូច្នោះទេ ប្រទេសនឹងត្រូវប្រឈមមុខជាមួយនឹងហានិភ័យនៃការកាត់បន្ថយសេវាសាធារណៈយ៉ាងច្រើន ដែលនឹងបង្កឱ្យមានផលអាក្រក់ដល់ការអភិវឌ្ឍធនធានមនុស្ស។

## ៦- ធ្វើឱ្យអត្រាប្ដូរប្រាក់មានស្ថិរភាព

រឿងមួយដែលបន្ទុចបង្អាក់ពាណិជ្ជកម្មអន្តរជាតិ និងធ្វើឱ្យខូចទឹកចិត្តដល់ការធ្វើវិនិយោគ គឺអត្រាប្ដូរប្រាក់ ដែលអាចប្រែប្រួលយ៉ាងឆាប់រហ័សដែលធ្វើឱ្យមានការពិបាកដល់រដ្ឋ ឬសហគ្រាសក្នុងការធ្វើផែនការនៅពេលខាងមុខ។ ក៏ប៉ុន្តែ វាក៏គឺជាប្រការសំខាន់ផងដែរដែលថាអត្រាប្ដូរប្រាក់ត្រូវតែមានភាពប្រាកដនិយម៖ អត្រាប្ដូរប្រាក់ខ្ពស់ពេកនឹងអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សេចក្ដីសង្ឃឹមក្នុងការស្វែងរកការងារធ្វើចំពោះជនក្រីក្រ ដោយដាក់ទណ្ឌកម្មដល់អ្នកនាំចូល ក៏ដូចជាកសិករ និងផលិតករក្នុងស្រុកផ្សេងទៀតដែលត្រូវប្រឈមមុខជាមួយនឹងការប្រកួតប្រជែងដែលកាន់តែកើនឡើងពីអ្នកនាំចូល។ អត្រាប្ដូរប្រាក់ទាបពេកនឹងបង្កើនកម្រិតតម្លៃក្នុងស្រុក និងធ្វើឱ្យប៉ះពាល់ដល់កម្រិតជីវភាពរស់នៅរបស់ជនក្រីក្រ។

អត្រាប្ដូរប្រាក់ទំនងជាប្រែប្រួល ជាពិសេសនៅក្នុងសេដ្ឋកិច្ចតូចតាចនិងសេរី ដែលគ្មានអានុភាពលើកំណើន ឬការធ្លាក់ចុះនៃតម្លៃទំនិញនៅក្នុងទីផ្សារអន្តរជាតិ។ ដោយមានអត្រាប្ដូរប្រាក់អណ្ដែត ប្រទេសទាំងនេះក៏អាចទទួលរងជំងឺហូឡង់ (Dutch Disease) ដែលនៅក្នុងនោះ ការហូរចូលនៃមូលធនដែលមិនមានឱកាសវិនិយោគគ្រប់គ្រាន់សម្រាប់ស្រូបយកមូលធនទាំងនេះ អាចតម្លើងអត្រាប្ដូរប្រាក់ដល់កម្រិតមិន

ប្រាកដនិយមមួយ។ ប្រការនេះអាចកើតឡើងដោយសារតែកំណើននៃតម្លៃទំនិញ ឧទាហរហណ៍ ដូចជាកំណើនតម្លៃប្រេងសម្រាប់ប្រទេសទីម័រខាងកើត។ ប៉ុន្តែ វាក៏អាចជាលទ្ធផលនៃការហូរចូលនៃជំនួយឬការមកដល់ផងដែរនៃមូលនិធិសម្រាប់សម្រាលបន្ទុកគ្រោះថ្នាក់ធម្មជាតិ ដូចជារលកយក្សស៊ូណាមីជាដើម។

ប្រទេសក្នុងតំបន់អាស៊ីភាគច្រើនដែលជោគជ័យបំផុតបានទទួលអត្ថប្រយោជន៏ជាយូរមក ហើយពីអត្រាប្តូរប្រាក់ដែលមានស្ថេរភាពអាស្រ័យលើការគ្រប់គ្រងរូបិយវត្ថុយ៉ាងសកម្ម។ សម្រាប់គោលដៅនេះនៅក្នុងដំណាក់កាលដំបូងនៃការធ្វើសេរីភាវូបនីយកម្ម ជាជាងការមានអត្រាប្តូរប្រាក់អណ្តែតសេរី បណ្តាប្រទេសដែលមានការពាក់ព័ន្ធកាន់តែច្រើនឡើងនៅក្នុងពាណិជ្ជកម្មអន្តរជាតិ អាចពិចារណាអំពីអត្រាប្តូរប្រាក់អណ្តែតក្រោមការគ្រប់គ្រងរបស់ខ្លួន ដែលអនុញ្ញាតឱ្យរូបិយវត្ថុរបស់ខ្លួនចុះតម្លៃបន្តិចម្តងៗ ដោយហេតុថានៅក្នុងដំណាក់កាលដំបូងនៃការធ្វើសេរីភាវូបនីយកម្ម ជាធម្មតា ការនាំចូលកើនឡើងយ៉ាងលឿងជាងការនាំចេញ។ ប៉ុន្តែ អាទិភាពទូទៅគឺត្រូវធានាឱ្យបានថាអត្រាប្តូរប្រាក់ស្ថិតនៅមិនប្រែប្រួល និងមានលក្ខណ:ប្រាកដនិយម។

## ៧- ស៊ូទ្រាំជាមួយពហុភាពនិយម

ល្បឿនយឺតនៃការរីកចម្រើននៅក្នុងការចរចារពាណិជ្ជកម្មពហុភាគីនៅក្រុងដូហាបានធ្វើឱ្យខូចទឹកចិត្តដល់ប្រទេសកំពុងអភិវឌ្ឍន៏ជាច្រើន។ ប្រទេសទាំងនេះអាចមើលឃើញការរីកចម្រើននៅក្នុងការចរចារនេះធ្លាក់ចុះទៅក្នុងឧបសគ្គដែលធ្លាប់មានរួចមកហើយ ជាពិសេសការជំទាស់ពីបណ្តាប្រទេសជឿនលឿនចំពោះគោលនយោបាយឧបត្ថម្ភធនលើវិស័យកសិកម្ម។ ប្រការនេះបង្កឱ្យមានទុទិដ្ឋិនិយម ហើយរឹតតែអាក្រក់នោះគឺបណ្តាលឱ្យមានការធ្លាក់ចុះនូវសេចក្តីរំពឹងដែលអាចធ្វើឱ្យប្រទេសកំពុងអភិវឌ្ឍន៏បោះបង់ចោលពហុភាពនិយមទាំងអស់គ្នាតែម្តង។

ដោយសារតែការអស់សង្ឃឹមនៅក្នុងការចរចារនៅអង្គការពាណិជ្ជកម្មពិភពលោក ប្រទេសជាច្រើនស្វះស្វែងធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយនឹងប្រទេសជឿនលឿន។ ប្រទេសខ្លះលើកហេតុផលមកសំអាងថា តាមន័យពាណិជ្ជកម្ម ប្រការនេះគឺប្រសើរណាស់ ដោយហេតុថាវាផ្តល់ឱ្យមានការចូលរួមជាសមាជិកតាមចំណូលចិត្ត ប៉ុន្តែក្នុងន័យនៃការអភិវឌ្ឍមនុស្ស វាអាចបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំង ដោយហេតុថាកិច្ចព្រមព្រៀងទ្វេភាគី ជាធម្មតាគឺពាក់ព័ន្ធដល់ការធ្វើសម្បទានយ៉ាងច្រើនលើតារាងអត្រាពន្ធដោយប្រទេសកំពុងអភិវឌ្ឍន៏ និងធ្វើការទាមទារលើបញ្ហានានា ដូចជាកម្មសិទ្ធិបញ្ញាដែលហួសឆ្ងាយជាងអ្វីដែលសមាជិកអង្គការពាណិជ្ជកម្មពិភពលោកកំណត់ចំពោះគ្នាទៅវិញទៅមក និងអាចគម្រាមកំហែងសុខភាពនិងជីវភាពរបស់ជនក្រីក្រ។

ប្រទេសជាច្រើននៅក្នុងតំបន់នឹងមានភាពល្អប្រសើរជាង ដើម្បីទប់ទល់ចំពោះការប៉ុនប៉ងភ្លាមៗឱ្យមានការប្រកាន់យកទ្វេភាគី និងកសាងទំនាក់ទំនងពហុភាគីដោយមានល្បឿនយ៉ាងយឺតតែហុចផលយ៉ាងច្រើនបំផុតដែលអាចបណ្តាលឱ្យមានលទ្ធផលយូរអង្វែងនៅក្នុងការអភិវឌ្ឍមនុស្ស។

## ៨- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រទេសជិតខាង

ជម្រើសដ៏ប្រសើរមួយផ្សេងទៀត គឺការព្យាយាមធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងផ្សេងទៀតជាមួយនឹងប្រទេសនានានៅក្នុងតំបន់ និងអនុតំបន់របស់ខ្លួន។ ប្រការទាំងនេះរួមមានទាំងកតិកាសញ្ញាប្រចាំតំបន់ ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីប្រចាំតំបន់អាស៊ីខាងត្បូង

*មានភាពល្អប្រសើរជាង ដើម្បីទប់ទល់ចំពោះការប៉ុនប៉ងភ្លាមៗឱ្យមានការប្រកាន់យកទ្វេភាគី និងកសាងទំនាក់ទំនងពហុភាគីដោយមានល្បឿនយ៉ាងយឺតតែហុចផលយ៉ាងច្រើនបំផុត*

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៃសមាគមប្រជាជាតិអាស៊ីភាគអាគ្នេយ៍ ឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនៃបណ្ដាប្រទេសនៅក្នុងកោះប៉ាស៊ីហ្វិក។ ប្រការទាំងនេះផ្ដល់ជាអត្ថប្រយោជន៍ដែលអាចឱ្យមានការចរចាយ៉ាងឆាប់រហ័សជាងកិច្ចព្រមព្រៀងពហុភាគី ដោយបង្កឱ្យមានហានិភ័យតិចតួចចំពោះការអភិវឌ្ឍមនុស្សជាងនៅក្នុងកិច្ចព្រមព្រៀងទ្វេភាគី។ បន្ថែមលើនេះ កិច្ចព្រមព្រៀងទាំងនេះធ្វើឱ្យមានសង្គតិភាពយ៉ាងប្រសើរជាមួយនឹងប្រព័ន្ធផលិតកម្មឆ្លងកាត់ព្រំដែនជាតិដែលត្រូវបានធ្វើសមាហរណកម្មនៅក្នុងតំបន់ និងនាំឱ្យមានការបង្កើតពាណិជ្ជកម្ម។

កិច្ចព្រមព្រៀងប្រចាំតំបន់អាចត្រូវបានបំពេញបង្គ្រប់ដោយកិច្ចសហប្រតិបត្តិការក្នុងទម្រង់ផ្សេងៗទៀត ជាពិសេសនៅក្នុងវិស័យហិរញ្ញវត្ថុ។ ប្រទេសជាច្រើននៅក្នុងតំបន់បានស្ដុកទុករូបិយវត្ថុបរទេស ដែលមានចំនួនសរុបរហូតដល់ទៅ ១៩ ម៉ឺនកោដិដុល្លារសហរដ្ឋអាមេរិក ដែលមានចំនួនពាក់កណ្ដាលនៅប្រទេសចិន ដោយមួយផ្នែកសម្រាប់ការពារខ្លួនឯងទល់នឹងវិបត្តិហិរញ្ញវត្ថុនៅតំបន់អាស៊ី។ មូលនិធិទាំងនោះ អាចត្រូវបានប្រើប្រាស់បានយ៉ាងប្រសើរ ប្រសិនបើត្រូវបានប្រមូលទុកនៅមួយកន្លែង ដែលអាចឱ្យប្រទេសដែលត្រូវប្រឈមមុខជាមួយនឹងវិបត្តិភ្លាមៗនៃតុល្យភាពជញ្ជីងពាណិជ្ជកម្ម ដែលត្រូវបានបង្កឡើង ឧទាហរណ៍ ដោយសារកំណើនតម្លៃប្រេងកាតអាចពឹងផ្អែកលើធនធានប្រចាំតំបន់អាស៊ីនេះ។ រដ្ឋាភិបាលនានា អាចពិចារណាអំពីការប្រើមូលនិធិស្ដុកទុកទាំងនេះផងដែរ សម្រាប់ពង្រីកមូលនិធិអភិវឌ្ឍន៍អាស៊ីដែលអាចប្រើធនធានសម្រាប់ការធ្វើវិនិយោគធំៗលើអាទិភាពនៃការកសាងហេដ្ឋារចនាសម្ព័ន្ធ និងលើការអភិវឌ្ឍមនុស្ស ដូចជា សុខាភិបាល និងការអប់រំជាដើម។

## ទៅដល់ព្រំដែនផ្សេងៗគ្នា

ដោយមានឬគ្មានកិច្ចព្រមព្រៀងពហុភាគី ការធ្វើសេរីភាវូបនីយកម្មនៅតែបោះជំហានទៅមុខ។ ហើយកម្មករជាច្រើនលាននាក់បន្ថែមទៀតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក នឹងក្លាយទៅជាអ្នកផលិតទំនិញសម្រាប់មនុស្សដែលរស់នៅក្នុងតំបន់ផ្សេងទៀតនៃពិភពលោកនេះ ក៏ដូចជាទិញទំនិញដែលមានតម្លៃថោក ដែលឪពុកម្ដាយរបស់ខ្លួនបានស្រមើស្រមៃជាយូរមកហើយ។

ប៉ុន្តែ គ្រោះថ្នាក់ជាចម្បងគឺថាអ្នកផ្សេងទៀតរាប់លាននាក់នឹងទទួលបរាជ័យនៅតាមផ្លូវដោយបោះបង់ចោលតំបន់នៅទីជនបទដែលសេដ្ឋកិច្ចកសិកម្ម ត្រូវធ្លាក់ចូលទៅក្នុងការខិនថយ និងជាចុងក្រោយ ត្រូវរកស៊ីចិញ្ចឹមជីវិតនៅតាមជាយទីក្រុងធំៗនៃតំបន់អាស៊ីក្នុងស្ថានភាពជាវណ្ណៈថ្នាក់ក្រោម។ សូម្បីតែអ្នកដែលបច្ចុប្បន្ននេះមានការងារធ្វើក៏ដោយ ក៏នៅពេលក្រោយអាចត្រូវបានបណ្ដេញចេញពីប្រព័ន្ធផលិតកម្មទំនើបបំផុត។ ប្រការនេះមិនគ្រាន់តែបដិសេធមនុស្សមិនឱ្យទទួលបាននូវសិទ្ធិមានការងារសមស្រប និងមានជីវភាពរស់នៅសមរម្យប៉ុណ្ណោះទេ ក៏ប៉ុន្តែ វាថែមទាំងបង្កឱ្យមានហានិភ័យចំពោះការបះបោរនៅពេលខាងមុខផងដែរ ដូច្នេះការធ្វើសេរីភាវូបនីយកម្មមិនគ្រាន់តែចែកចាយផលិតផលប៉ុណ្ណោះទេ ក៏ប៉ុន្តែ ប្រកាសផ្សាយអំពីគំនិតថ្មីនិងព័ត៌មានផងដែរ ដែលធ្វើឱ្យមានការកែប្រែចំពោះការចង់បានរបស់មនុស្ស។

បណ្ដាប្រទេសនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកមានកេរ្តិ៍ឈ្មោះល្បីល្បាញចំពោះល្បឿន ដែលប្រទេសទាំងនេះបានអភិវឌ្ឍនៅក្នុងវិស័យសេដ្ឋកិច្ច។ ពេលនេះពួកគេបានទៅដល់ព្រំដែនមួយផ្សេងទៀត ដោយព្យាយាមផ្សារភ្ជាប់កំណើនសេដ្ឋកិច្ចដែលអាស្រ័យលើពាណិជ្ជកម្មដែលមានល្បឿនយ៉ាង

ល្បឿន ជាមួយនឹងការកាត់បន្ថយភាពក្រីក្រដែលមានល្បឿនស្មើគ្នានេះដែរ ហើយទូលំទូលាយមែនទែននោះ គឺការអភិវឌ្ឍមនុស្ស។ តាមពិតទៅប្រការនេះ គឺជាការងារមួយដែលស្មុគស្មាញនិងពិបាក ហើយដូចកាលពីមុនដែរ អ្នកទាំងនេះចាំបាច់ត្រូវរិះរកដំណោះស្រាយដោយខ្លួនឯង។ ដំណោះស្រាយមួយចំនួនត្រូវបានបង្ហាញជូននៅក្នុងរបាយការណ៍នេះ ចំណែកឯមធ្យោបាយផ្សេងទៀត នឹងលេចចេញពីបទពិសោធ។ ប្រការមួយគឺមានលក្ខណៈប្រាកដប្រជា ពោលគឺតំបន់អាស៊ុីនិងតំបន់ប៉ាស៊ីហ្វិកនឹងស្ថិតនៅជួរមុខនៃការអភិវឌ្ឍពិភពលោក ហើយនឹងផ្តល់មេរៀនថ្មីៗដល់តំបន់ដទៃទៀតនៃពិភពលោក។

*តំបន់អាស៊ុីនិងតំបន់ប៉ាស៊ីហ្វិកនឹងស្ថិតនៅជួរមុខនៃការអភិវឌ្ឍពិភពលោក ហើយនឹងផ្តល់មេរៀនថ្មីៗដល់តំបន់ដទៃទៀតនៃពិភពលោក*



# 1



# ការប្រើប្រាស់ពាណិជ្ជកម្មអន្តរជាតិ ដើម្បីជម្រុញការអភិវឌ្ឍមនុស្ស

**ការធ្វើសមាហរណកម្មយ៉ាងជ្រៅទៅក្នុងទីផ្សារអន្តរជាតិអាចលើកស្ទួយកំណើនសេដ្ឋកិច្ច និងបង្កើតការងារថ្មីៗជាច្រើនលាន។ ប៉ុន្តែវាក៏នាំមកនូវហានិភ័យថ្មីៗផងដែរ ដូចជាការធ្វើឱ្យបណ្តាប្រទេសអភិវឌ្ឍន៍តិចតួចកាន់តែបាត់បង់លទ្ធភាព និងធ្វើឱ្យខូចប្រយោជន៍របស់សហគមន៍ដែលងាយរងគ្រោះ។ ការប្រឈមគឺត្រូវបង្កើតរបបពាណិជ្ជកម្មដែលមិនត្រឹមតែមានតុល្យភាព និងមានសមធម៌ជាងមុនប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រយុទ្ធប្រឆាំងយ៉ាងសកម្មផងដែរនឹងភាពក្រីក្រ ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍមនុស្ស។**

ប៉ុន្មានឆ្នាំដំបូងនៃដើមសហស្សវត្សរ៍ថ្មីនេះ មានការរីកចម្រើនយ៉ាងខ្លាំងនៃពាណិជ្ជកម្មនៅលើពិភពលោក។ នៅឆ្នាំ ២០០៤ ពាណិជ្ជកម្មទំនិញនៅលើពិភពលោកបានទទួលតួលេខខ្ពស់បំផុត គិតចាប់តាំងពីឆ្នាំ ២០០៤មក ដែលបរិមាណទំនិញបានកើនឡើង ៩% ឯតម្លៃសរុបនៃទំនិញបានកើនឡើង ២១%[1]។ ផ្នែកកម្មន្តសាលបានដើរតួឈានមុខ ទោះបីផលិតផលខាងផ្នែកកម្មន្តសាលបានកើនឡើងត្រឹម ៤% ក្តី ដោយសារកំណើនសមាមាត្រនៃផលិតផលទាំងនេះ ត្រូវបានធ្វើពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិ។ ជាលទ្ធផល បរិមាណផលិតផលខាងផ្នែកកម្មន្តសាលដែលបាននាំចេញ មានការកើនឡើង ១០%។

ទោះជាបែបនេះក្តី តម្លៃសរុបនៃកសិផលនៅក្នុងពាណិជ្ជកម្មក៏បានកើនឡើងក្នុងអត្រា ១៥% ផងដែរ។ ទន្ទឹមគ្នានេះដែរ មានការកើនឡើងយ៉ាងខ្លាំងនៃពាណិជ្ជកម្មលើសេវាកម្មខាងជំនួញ ដែលតម្លៃសរុបបានកើនឡើងក្នុងអត្រា ១៨%។ តួលេខនេះជាការបន្ថែមទៅលើស្ថានភាពកំណើនដែលមានរួចមកហើយនៅឆ្នាំ ២០០៣។

កំណើនសមាហរណកម្មពិភពលោកបានពង្រីកកាលានុវត្តភាពសម្រាប់ពាណិជ្ជកម្មពិភពលោក។ ប៉ុន្តែ តើពាណិជ្ជកម្មអាចរួមចំណែកអ្វីខ្លះចំពោះការអភិវឌ្ឍ? ទស្សនៈភាគច្រើនបង្ហាញថា ការចូលរួមជាមួយទីផ្សារអន្តរជាតិមិនគ្រាន់តែមិនអាចជៀសវាងបានប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់ផលមកវិញផងដែរ ដោយសារពាណិជ្ជកម្មអាចសម្រួល ជម្រុញ និងធានាឱ្យមានដំណើរការអភិវឌ្ឍ។ ជាក់ស្តែង សម្រាប់ប្រទេសនីមួយៗ ពាណិជ្ជកម្មត្រូវបានមើលឃើញថាជាលក្ខខណ្ឌដំបូងសម្រាប់កំណើនដោយចីរភាព។ រដ្ឋាភិបាលឯកភាពតាមទស្សនៈនេះ ហើយបានធ្វើការពិចារណា ដើម្បីបង្កើនពាណិជ្ជកម្ម បង្កើតទម្រង់ និងកម្រិតនៃការចូលរួមរបស់ជាតិ ជាមួយសេដ្ឋកិច្ចអន្តរជាតិ។ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ធំៗនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក (ប្រអប់ ១) ក៏បានបង្កើនឥទ្ធិពលខ្លាំងក្លាបំផុតផងដែរ ប៉ុន្តែបណ្តាប្រទេសតូចៗក៏ប្រឹងប្រែងឆក់យកកាលានុវត្តភាពថ្មីៗទាំងនេះ ដើម្បីធ្វើពាណិជ្ជកម្មខាងសេវាកម្ម តាមរយៈទេសចរណ៍ ដូចជា ចំណាកស្រុកនៃកម្មករ និងការធ្វើលទ្ធកម្មដំនើរការជំនួញ។

ទោះជាយ៉ាងណាក៏ដោយ របាយការណ៍នេះអះអាងថា ពាណិជ្ជកម្មមិនត្រូវមានគោលដៅត្រឹមត្រូវតែធ្វើជំនួយតែមួយមុខនោះទេ។ ប៉ុន្តែ ពាណិជ្ជកម្មគួរតែទទួលស្គាល់នូវគោលដៅទូលំទូលាយនៃការអភិវឌ្ឍមនុស្ស និងជាពិសេសនៅក្នុងបណ្តាប្រទេសដែលក្រីក្រជាងគេ និងដែលអភិវឌ្ឍ

**ប្រអប់ ១.១**

**ចំណាត់ថ្នាក់ប្រទេសនានាដែលមានប្រើប្រាស់ក្នុងរបាយការណ៍នេះ**

របាយការណ៍នេះប្រមូលផ្ដុំទិន្នន័យពីប្រភពផ្សេងៗ ដែលច្រើនតែមានចំណាត់ជាក្រុមខុសៗគ្នាសម្រាប់តំបន់ និងអនុតំបន់នានា។ ដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នា ចំណាត់ថ្នាក់ដូចខាងក្រោមនេះ ត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះ។ ជារួមតំបន់នេះត្រូវបានចាត់ទុកជាអាស៊ី និងប៉ាស៊ីហ្វិក ឬអាស៊ី-ប៉ាស៊ីហ្វិក។ អនុតំបន់ចម្បង៧គឺ អាស៊ីខាងត្បូង ប៉ាស៊ីហ្វិក និងអាស៊ីបូព៌ា។ ក្នុងករណីសមស្រប អាស៊ីបូព៌ាត្រូវបានចែកជាអាស៊ីអាគ្នេយ៍ និង អាស៊ីភាគឦសាន។ ប្រទេសនានានៅក្នុងអនុតំបន់ទាំងនេះត្រូវបានចាត់ជាក្រុមដូចខាងក្រោម។

អាស៊ីភាគឦសាន: ប្រទេសចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ ម៉ុងហ្គោលី និង សាធារណរដ្ឋកូរ៉េ។

អាស៊ីអាគ្នេយ៍: ប្រទេសកម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី ភូមា ហ្វីលីពីន ទីម័រខាងកើត ថៃ និងវៀតណាម។

អាស៊ីខាងត្បូង: អាហ្វហ្កានីស្ថាន បង់ក្លាដេស ប៊ូតាណ ឥណ្ឌា អ៊ីរ៉ង់ ម៉ាល់ឌីវ ណេប៉ាល់ ប៉ាគីស្ថាន និងស្រីលង្កា។

ប៉ាស៊ីហ្វិក: កោះឃុក រដ្ឋសហព័ន្ធមីក្រូណេស៊ី ហ្វីជី គីរីបាទី កោះម៉ាស្សាល់ ណៅរូ នីអ៊ូ ប៉ាឡាវ ប៉ាពូញូហ្គីនេ សាម៉ាវ កោះសូឡូម៉ុង តូកេឡូ តុងហ្គា ទូវ៉ាលូ និង វ៉ាណាទូ។

*ពាណិជ្ជកម្មពិតជាអាចពង្រឹងការអភិវឌ្ឍមនុស្ស ប៉ុន្តែ វាក៏អាចជាការរាំងស្ទះដំណើរការនេះផងដែរ។ មានហេតុផលតាមទិសដៅពីរគឺពីពាណិជ្ជកម្មទៅការអភិវឌ្ឍមនុស្ស និងច្រាសត្រឡប់មកវិញ*

តិចតួច។ ពាណិជ្ជកម្មគួរតែជួយកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយភាពខ្វះខាតរបស់មនុស្ស។ ការអភិវឌ្ឍមនុស្សនៅក្នុងន័យនេះ សំដៅលើការពង្រីកជម្រើសរបស់ប្រជាពលរដ្ឋ និងធ្វើឱ្យពួកគាត់មានលទ្ធភាពឈានទៅរស់នៅបានយូរប្រកបដោយសុខភាពល្អ ដោយធានាថាពួកគាត់បានទទួលអាហារូបត្ថម្ភគ្រប់គ្រាន់ និងមានលទ្ធភាពប្រើប្រាស់ទឹកស្អាត បរិក្ខារអនាម័យ និងជម្រក ដោយផ្ដល់ឱ្យពួកគាត់នូវឱកាសដូចគ្នា ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច តាមរយៈការអប់រំ និង ការងារថ្លៃថ្នូរ និងដោយផ្ដល់ឱ្យពួកគាត់នូវសេរីភាពក្នុងការសម្រេចយកជម្រើសទាំងនេះ និងបំពេញសក្ដានុពលរបស់ខ្លួន។

ពាណិជ្ជកម្មពិតជាអាចពង្រឹងការអភិវឌ្ឍមនុស្ស ប៉ុន្តែ វាក៏អាចជាការរាំងស្ទះដំណើរការនេះផងដែរ។ យ៉ាងហោចណាស់ ពាណិជ្ជកម្មគឺជាសកម្មភាពស្វែងរកផលចំណេញ ហើយមានគំរូជាច្រើនក្នុងប្រវត្តិសាស្ត្រ ដែលបង្ហាញថាមានអ្វីកើតឡើង នៅពេលផលចំណេញពីជំនួញបានទទួលអាទិភាពខ្ពស់ជាងសុខុមាលភាពរបស់មនុស្ស។ ឧទាហរណ៍: ទាសករ អាណានិគមនិយម និងអាប៉ាថេត។ ដូចគ្នានេះដែរ បច្ចុប្បន្នការជម្រុញឱ្យមានកំណើននៃការនាំចេញ និងនាំចូលទំនិញ និងសេវា បានបង្កឱ្យមានដំណើរការដ៏សាំញ៉ាំ និងឱណាមិកជាច្រើន ដែលធ្វើឱ្យមានទាំងអ្នកឈ្នះ និងអ្នកចាញ់។ គ្រាន់តែធ្វើឱ្យមានសេរីភាវូបនីយកម្មខាងពាណិជ្ជកម្ម ក៏អាចបង្កើនកាលានុវត្តភាពសម្រាប់ការនាំចេញ ហើយក៏ធ្វើឱ្យផលិតករក្នុងស្រុកធ្វើការប្រកួតប្រជែងជាមួយបរទេស ដែលសម្រាប់ប្រទេសក្រីក្រ ផលិតករទាំងនោះពិតជាមិនអាចប្រឈមបានឡើយ។ ទន្ទឹមនឹងបង្កើតកាលានុវត្តភាពថ្មី ជាពិសេសនៅក្នុងវិស័យទំនើប វាក៏អាចបំផ្លាញរបរចិញ្ចឹមជីវិតរបស់ប្រជាជនដែលធ្វើការក្នុងកម្មន្តសាលតូចតាច និងកសិកម្មផងដែរ។

ឥទ្ធិពលទាំងនេះ និងចំណងទាក់ទងរវាងពាណិជ្ជកម្ម និងការអភិវឌ្ឍមនុស្ស ត្រូវបានសង្ខេបនៅក្នុងរូបទី ១.១។ នៅក្នុងដ្យាក្រាមនេះមានផ្នែកបីជាមូលដ្ឋានគឺ ពាណិជ្ជកម្ម ការអភិវឌ្ឍមនុស្ស និងចំណងទាក់ទងរវាងកត្តាទាំងពីរ។ លំនាំនៃសម្មតិកម្មគឺ ពាណិជ្ជកម្ម → កំណើន → ការអភិវឌ្ឍមនុស្ស → ពាណិជ្ជកម្ម។ ដូច្នេះ មានហេតុផលតាមទិសដៅពីរ គឺពីពាណិជ្ជកម្មទៅការអភិវឌ្ឍមនុស្ស និងច្រាសត្រឡប់មកវិញ។

## ធ្វើឱ្យមានតុល្យភាពរវាងកំណើន និងការអភិវឌ្ឍមនុស្ស

ពាណិជ្ជកម្មអាចបំពេញសក្ដានុពលរបស់ខ្លួន សម្រាប់កាត់បន្ថយភាពក្រីក្រ និងពង្រឹងការអភិវឌ្ឍមនុស្ស ប៉ុន្តែ វាអាចធ្វើទៅបានតែកាលណារចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងអន្តរជាតិត្រូវបាន

កែប្រែ ហើយរដ្ឋាភិបាលនៃទាំងប្រទេសជឿនលឿន និងនៃប្រទេសកំពុងអភិវឌ្ឍន៍ បង្ហាញពីការសម្រេចចិត្ត និងការប្តេជ្ញាមោះមុតដែលចាំបាច់។

មួយក្នុងចំណោមកិច្ចការចម្បងគឺការបង្កើតចរិតលក្ខណៈនៃកំណើនសេដ្ឋកិច្ច។ បទពិសោធបានបង្ហាញថាកំណើនអាចប្រែក្លាយទៅជាការអភិវឌ្ឍមនុស្សកម្រិតខ្ពស់។ ប៉ុន្តែមិនសុទ្ធតែកើតឡើងតាមបែបនេះឡើយ ភាគច្រើនគឺអាស្រ័យលើទម្រង់នៃកំណើន។ ក្នុងករណីខ្លះ លទ្ធផលបានពីការអភិវឌ្ឍមនុស្សអាចមានកម្រិតកំណត់ ឬអាចអវិជ្ជមានថែមទៀតផង។ ជាក់ស្តែង ប្រទេសខ្លះនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដែលមានកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់ដោយសារពាណិជ្ជកម្ម បានបង្កជាកង្វល់ ពោលគឺ ឧស្សាហកម្ម និងសេវាកម្មបានកើនឡើងឆាប់រហ័សបំផុតធៀបនឹងកសិកម្ម ហើយកសិករត្រូវធ្វើចំណាកស្រុកក្រោមទ្រង់ទ្រាយធំ វិសមភាពរវាងជនបទ និងទីក្រុង និងរវាងបុគ្គលបានកើនឡើង កំណើនផ្នែកកម្មន្តសាលមិនមានលទ្ធភាពដើម្បីផ្តល់ការងារថ្មីឱ្យបានគ្រប់គ្រាន់ឡើយ ហើយភាគច្រើននៃការងារដែលមានស្រាប់ បានក្លាយជាការងារធម្មតា ឬមិនផ្លូវការ។

អ្នកកសាងគោលនយោបាយភាគច្រើនដែលព្យាយាមធ្វើកំណែទម្រង់បែបនេះ ដឹងថាពួកខ្លួនមិនធ្វើការនៅក្នុងបរិបទដែលមិនផ្លាស់ប្តូរនោះឡើយ។ ទំនាក់ទំនងរវាងកំណើននិងការអភិវឌ្ឍមនុស្ស មានលក្ខណៈឌីណាមិក ហើយមានឥទ្ធិពលលើគ្នាទៅវិញទៅមក។ តាមទិសមួយ កំណើនសេដ្ឋកិច្ចផ្តល់នូវធនធានដែលអាចអនុញ្ញាតឱ្យមានកំណែលំអការអភិវឌ្ឍមនុស្សជាប្រចាំ។ ម្យ៉ាងវិញទៀត កំណែលំអការអភិវឌ្ឍមនុស្សនាំឱ្យមានកំនើនសមត្ថភាពរបស់ប្រជាពលរដ្ឋដើម្បីធ្វើឱ្យមានកំណើនសេដ្ឋកិច្ច។

ប៉ុន្តែ មានជម្រើសពីរគឺ "អតុល្យភាព" និង "តុល្យភាព"។[២] យុទ្ធសាស្ត្រអតុល្យភាពអាចផ្តល់អាទិភាពទៅឱ្យកំណើនសេដ្ឋកិច្ច ឬមួយទៅឱ្យការអភិវឌ្ឍមនុស្ស។ ពុំមានយុទ្ធសាស្ត្រណាមួយក្នុងចំណោមទាំងពីរនេះ នឹងមាននិរន្តរភាពទេ។ យុទ្ធសាស្ត្រ "អភិវឌ្ឍន៍មនុស្សមុន" អាចត្រូវប្រឈមនឹង




រូបទី ១.១: ដ្យាក្រាមអំពីទំនាក់ទំនងពាណិជ្ជកម្ម និងការអភិវឌ្ឍមនុស្ស

ពាណិជ្ជកម្មធ្វើឱ្យរចនាសម្ព័ន្ធសេដ្ឋកិច្ចផ្លាស់ប្តូរ រួមទាំងអត្រាកំណើនដែលមានឥទ្ធិពលបន្តទៅលើការប្រើប្រាស់ទាំងកម្លាំងពលកម្មនិងមូលធន។ ពាណិជ្ជកម្មអាចផ្តល់ផលដល់កម្មករដែលមានជំនាញច្រើនជាងកម្មករដែលគ្មានជំនាញ និងអាចនាំឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាដែលត្រូវការមូលធនច្រើន ដែលជាហេតុនាំឱ្យមានកំណើនវិសមភាព។ ទោះជាយ៉ាងណាក៏ដោយ គេអាចប្រើប្រាស់គោលនយោបាយសាធារណៈ ដើម្បីធានាថា ពាណិជ្ជកម្មនាំមកនូវផលប្រយោជន៍សម្រាប់ការអភិវឌ្ឍធនធានមនុស្ស។ ក្រៅពីនេះ ក៏មានការឆ្លើយតបពីការអភិវឌ្ឍធនធានមនុស្សមកពាណិជ្ជកម្មវិញដែរ ដែលកើតឡើងដោយផ្ទាល់ឬតាមរយៈការសម្របសម្រួលពីក្របខ័ណ្ឌគោលនយោបាយក្នុងស្រុក។ ប្រតិកម្មត្រលប់មកវិញនេះមានឥទ្ធិពលទៅលើការងារ តាមរយៈកម្រិតខ្ពស់នៃប្រាក់ចំណូល សមត្ថភាពបច្ចេកទេសនិងជំនាញ ឬតាមរយៈអំណាចក្នុងការតស៊ូមតិ ដែលមានឥទ្ធិលទៅលើអ្នកកសាងគោលនយោបាយ។ ទីបំផុត ការអភិវឌ្ឍមនុស្សក៏អាចមានឥទ្ធិពលដោយផ្ទាល់ទៅលើរចនាសម្ព័ន្ធសេដ្ឋកិច្ច អត្រាកំណើន និងពាណិជ្ជកម្មខ្លួនឯងវិញផងដែរ។

បញ្ហាសារពើពន្ធ និងមានវិបត្តិលើការចំណាយ។ រីឯយុទ្ធសាស្ត្រ "កំណើនសេដ្ឋកិច្ចមុន"អាចជួបការលំបាក ដោយសារការផ្គត់ផ្គង់កម្លាំងពលកម្មប្រកបដោយជំនាញ ពុំគ្រប់គ្រាន់តាមតម្រូវការនៅក្នុងស្រុក ឬដោយសារអស្ថិរភាពនយោបាយ។ ប្រការដែលប្រសើរគឺត្រូវប្រកាន់យកវិធានដែលមានតុល្យភាពជាង។ ប៉ុន្តែក្នុងចំណោមវិធានទាំងពីរដែលមានភាពលំអៀង វិធាន"អភិវឌ្ឍមនុស្សមុន" មានកម្រិតមិនពេញចិត្តទាបជាងគេ ដោយសារសង្គមដែលប្រកាន់យកយុទ្ធសាស្ត្រនេះ យ៉ាងហោចណាស់ មានឱកាសប្រសើរជាងយ៉ាងច្រើនក្នុងការលុបបំបាត់វិបត្តិសេដ្ឋកិច្ច នឹងអាចវិលត្រឡប់មករកស្ថានភាពប្រសើរឡើងវិញ។

## ប្រកាន់យកកំណើនសេដ្ឋកិច្ចតាមរយៈពាណិជ្ជកម្ម

សូម្បីតែអ្នកកសាងគោលនយោបាយឯកភាពទទួលយកនូវតម្រូវការឱ្យមានកំណើនប្រកបដោយតុល្យភាពក៏ដោយ តើការបង្កើនពាណិជ្ជកម្មជាវិធីប្រសើរដើម្បីសម្រេចគោលដៅនេះឬ? ចម្លើយគឺ "មែនហើយ"។ អ្នកគាំទ្រសេរីភាវូបនីយកម្មអះអាងថា បច្ចុប្បន្ន របបផ្តាច់ការនិយមមិនមែនជាជម្រើសដែលត្រូវប្រកាន់យកទេ ហើយការប្រកាន់យកយុទ្ធសាស្ត្រកំណើន ដែលពឹងផ្អែកលើការបង្កើតផលិតផលនៅក្នុងស្រុកសម្រាប់ជំនួសការនាំចូល និងឈានដល់កម្រិតកំណត់មួយនៅពេលដ៏ខ្លីខាងមុខ ព្រោះថា សម្រាប់ផលិតផលជាច្រើន ទីផ្សារក្នុងស្រុកមានទំហំតូចពេកដើម្បីស្រូបយកផលិតផលនៅក្នុងស្រុកទាំងនោះ។

ដូច្នេះសេរីភាវូបនីយកម្មពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងការកាត់បន្ថយអត្រាពន្ធដើម្បីការពារផលិតផលណាមួយ អាចនាំទៅរកលទ្ធផលដែលមានប្រសិទ្ធភាពជាងមុនដោយលុបបំបាត់ទំនាក់ទំនងរវាងការផ្គត់ផ្គង់ក្នុងស្រុកជាមួយការប្រើប្រាស់ក្នុងស្រុក។ ប្រទេសមួយដែលផ្តោតតែលើកំណើន អាចប្រឈមនឹងកង្វះមូលធន ឬខ្វះមុខផលិតផលជាក់លាក់ណាមួយ ឬខ្វះកម្លាំងពលកម្មប្រកបដោយជំនាញដែលពុំអាចរកបាននៅក្នុងស្រុក។ វិធីមួយដើម្បីជំនះការលំបាកទាំងនេះ គឺត្រូវនាំចូលមកពីក្រៅប្រទេសនូវប្រភេទទំនិញដែលត្រូវការនៅក្នុងស្រុក។ ប៉ុន្តែការធ្វើបែបនេះទៅបាន ដោយពុំបង្កឱ្យមានវិបត្តិជញ្ជីងទូទាត់ ទាមទារឱ្យមានរូបិយប័ណ្ណបរទេសគ្រប់គ្រាន់។ ហេតុនេះ ប្រទេសមួយចាំបាច់ត្រូវធ្វើពាណិជ្ជកម្មដើម្បីទទួលបានរូបិយប័ណ្ណបរទេសសម្រាប់ទូទាត់ការនាំចូល។ សូម្បីតែប្រទេសចិន ដែលមានកំណើនយ៉ាងឆាប់រហ័សនៃការនាំចេញអស់រយៈពេលជាយូរមកហើយក្តី នៅតែពុំអាចទទួលបានអតិរេកពាណិជ្ជកម្មឡើយ រហូតមកទល់ពេលថ្មីៗនេះ។ យូរៗម្តង ប្រទេសនេះមានឱនភាពពាណិជ្ជកម្ម ព្រោះបានប្រើប្រាស់ប្រាក់ចំណូលពីពាណិជ្ជកម្ម ដើម្បីបំពេញការចំណាយលើការនាំចូល ពិសេសសម្រាប់ការនាំចូលប្រេង និងគ្រឿងយន្ត។

សេរីភាពវូបនីយកម្ម គួរតែអាចផ្តល់លទ្ធភាពដល់ប្រទេសកំពុងអភិវឌ្ឍន៍ដែលក្រីក្រជាង ឱ្យប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនូវឧត្តមភាពរបស់ខ្លួន ដូចជា ភាពសំបូរស្តុកស្តម្ភខាងកម្លាំងពលករដែលពុំសូវមានជំនាញ និងដែលទាមទារកម្រៃថោក។ ហេតុនេះនៅដំណាក់កាលដើមដំបូង ប្រទេសទាំងនោះអាចពង្រឹងឯកទេសកម្មលើការផលិត និងនាំចេញកសិផល និងផលិតផលឧស្សាហកម្មងាយៗ ដូចជា វាយនភណ្ឌ និងសម្លៀកបំពាក់។ ការធ្វើបែបនេះក៏នឹងនាំឱ្យមានកំណើនតម្រូវការ និងប្រាក់បៀវត្សរ៍សម្រាប់កម្មករឥតជំនាញផងដែរ ដូច្នេះអាចជួយកាត់បន្ថយភាពក្រីក្រ។

ប៉ុន្តែ បើមើលឱ្យវែងឆ្ងាយហួសពីកំណើន "ស្ថាទិក" ទាំងនេះ ដែលទទួលបានពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម គេក៏អាចឃើញមានអត្ថប្រយោជន៍ផ្សេងទៀត ប្រកបដោយលក្ខណៈ

ឱណាមិកផងដែរ ដែលអាចនឹងទទួលបានជាបន្តបន្ទាប់នៅពេលខាងមុខ។ ឧទាហរណ៍: សហគ្រាសដែលបានប្រឈមជាញឹកញាប់ក្នុងការប្រកួតប្រជែង និងប្រើប្រាស់ទីផ្សារអន្តរជាតិនឹងត្រូវបង្ខំចិត្តឱ្យបង្កើនប្រសិទ្ធិភាពនៃផលិតកម្មរបស់ខ្លួន។ ពួកគេក៏អាចទទួលផលចំណេញពីការវិនិយោគបរទេសផងដែរ ដែលជាដំបូងមានភាពទាក់ទាញសម្រាប់តែពលកម្មដែលទាមទារកម្រៃទាប ប៉ុន្តែ បន្ទាប់មកនឹងនាំមកជាមួយនូវបច្ចេកវិទ្យា និងដំណើការផលិតកម្មថ្មីៗ។ ដូច្នេះ សេរីភាវូបនីយ-កម្ម ពាណិជ្ជកម្មអាចជួយបង្កើនផលិតភាព បង្កើនការនាំចេញ សម្រួលសេដ្ឋកិច្ចឱ្យមានកំណើនលឿនបន្ថែមទៀត និងនាំទៅរកកំណើនកម្រៃជាក់ស្តែង ជាពិសេស សម្រាប់កម្មករដែលពុំមានជំនាញ។

ជាអកុសល ប្រទេសជាច្រើនពុំទាន់ឈានដល់កម្រិតនេះនៅឡើយទេ។ យន្តការទីផ្សារច្រើនតែទទួលបរាជ័យ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលពួកគេពុំបើកឱកាសឱ្យមានភាពបត់បែនគ្រប់គ្រាន់នៅឡើយ ដើម្បីបែងចែកកម្មករ ឬមូលធនឱ្យបានរលូនទៅដល់វិស័យដែលផ្តល់ផលច្រើន។ ជាលទ្ធផល សេរីភាវូបនីយកម្មនឹងខកខាន ពុំអាចបង្កើតសេចក្តីសង្ឃឹមសម្រាប់សហគ្រាសនាំចេញ ទន្ទឹមនឹងការប្រឈមជាមួយហានិភ័យយ៉ាងច្រើននៃការនាំទំនិញចូលដោយតម្លៃថោក ដែលធ្វើឱ្យសហគ្រាសក្នុងស្រុក ត្រូវដួលរលំ។

លើសពីនេះ សូម្បីតែឧស្សាហកម្មនាំចេញត្រូវបានបង្កើតឡើងហើយក៏ដោយ ក៏នៅមានហានិភ័យដែលបន្តិច ម្តងៗ ធ្វើឱ្យឧស្សាហកម្មទាំងនោះ លែងនៅជាឧស្សាហកម្មអតិពលកម្ម។ សហគ្រាសនានាដែលចង់ពង្រឹងភាពប្រកួតប្រជែងរបស់ខ្លួន អាចព្យាយាមធ្វើបែបនេះ ដោយបោះបង់ចោលកម្លាំងពលករដែលលើសពីតម្រូវការ និងប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិ ដើម្បីបង្កើតផលិតផលដែលមានគុណ-ភាពខ្ពស់ទៅតាមស្តង់ដារអន្តរជាតិ។ ហេតុនេះជាជាងជួលកម្មករច្រើនដែលពុំមានជំនាញ ឧស្សាហកម្មនាំចេញអាចរឹតតែបង្កើនភាពខុសគ្នានៃទីផ្សារកម្លាំងពលកម្ម។ ទីផ្សារបែបនេះផ្សំដោយវិស័យផ្លូវការដែលមានទំហំតូច និងដែលកម្រិតប្រាក់កម្រៃស្ថិតនៅក្រោមឥទ្ធិពលនៃច្បាប់របស់រដ្ឋាភិបាលនិងការចរចារួមគ្នា និងដោយក្រុមសេដ្ឋកិច្ចមិនផ្លូវការដែលមានទំហំធំជាងយ៉ាងខ្លាំង ហើយដែលប្រាក់កម្រៃច្រើនតែមានកម្រិតទាប។

## សក្តានុពលសម្រាប់ចំណាត់ការរបស់រដ្ឋ

មានទស្សនៈថា វិធានតុល្យភាពដែលអាចផ្តល់លទ្ធភាពដល់ពាណិជ្ជកម្ម ក្នុងការលើកកម្ពស់ការអភិវឌ្ឍមនុស្សអាចសម្រេចទៅបានតាមរយៈការបែងចែកនូវការទទួលខុសត្រូវច្បាស់លាស់ ពោលគឺទុកឱ្យទីផ្សារសេរី និងសេរីភាវូបនីយ-កម្មជាអ្នកសម្រេចលើកំណើនសេដ្ឋកិច្ច ចំណែករដ្ឋាភិបាលធ្វើការដោះស្រាយតែអំពីបរាជ័យខាងទីផ្សារ និងចាប់យកការទទួលខុសត្រូវអាទិភាពខាងផ្នែកសង្គម និង ខាងការអភិវឌ្ឍមនុស្ស។

ទោះជាយ៉ាងណាក៏ដោយ ការធ្វើបែបនេះពុំបានគិតដល់ទំនាក់ទំនងនៃភាពពឹងផ្អែកគ្នាទៅវិញទៅមក រវាងកំណើនសេដ្ឋកិច្ចនិងភាពជឿនលឿនខាងការអភិវឌ្ឍមនុស្សឡើយ ជាពិសេសមិនបានគិតគូរអំពីគោលនយោបាយនានា ដែលមានគោលដៅបង្កើនជាអតិបរមានូវកំណើន ឬដែលជារបាំងចំពោះសក្តានុពលសម្រាប់ចំណាត់ការជាសាធារណៈ។ ឧទាហរណ៍ សេរីភាវូបនីយកម្មនឹងកាត់បន្ថយពន្ធដែលទាក់ទងនឹងពាណិជ្ជ-កម្ម ហើយសម្រាប់ប្រទេសជាច្រើន ប្រាក់បានពីពន្ធ រួមចំណែកយ៉ាងច្រើននៅក្នុងប្រាក់ចំណូលរបស់រដ្ឋាភិបាល។ ជារួម នៅបណ្តាប្រទេសអាស៊ីខាងត្បូង អត្រាប្រាក់ចំណូលបានពីពន្ធ បានធ្លាក់ចុះពី ២៧ ទៅ ១៩% នៅរវាងឆ្នាំ ១៩៩០ និង ២០០៣។[៣]

*អ្នកគាំទ្រសេរីភាវូប-និយកម្មអះអាងថា បច្ចុប្បន្ន របបផ្តាច់ការនិយមមិនមែនជាជម្រើសដែលត្រូវប្រកាន់យកទេ*

ប្រទេសប៉ាគីស្ថាន គឺជាឧទាហរណ៍ជាក់លាក់មួយ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ពន្ធលើការនាំចូលបានធ្លាក់ចុះជិត ៤% នៃផលទុនក្នុងស្រុកសរុប។ បរិមាណនេះអាចទូទាត់បានមួយចំណែកតាមរយៈកំណើន ១%នៃផលទុនក្នុងស្រុកសរុប ដែលជាចំណូលបានពីពន្ធលើប្រាក់ចំណូល។ ទោះជាយ៉ាងនេះក្តី ការបាត់បង់ជារួមនៃប្រាក់ចំណូលបានពីពន្ធក្នុងបរិមាណ ៣% នៃ GDP ពិតជាបង្កឱ្យមានឥទ្ធិពលអវិជ្ជមានដល់ការអភិវឌ្ឍមនុស្ស។ នៅក្នុងបណ្តាប្រទេសជាដែនកោះនៅតំបន់ប៉ាស៊ីហ្វិក ពន្ធគយ និងពន្ធផ្សេងទៀតអាចផ្តល់រហូតដល់ ៧០% នៃប្រាក់ចំណូលរបស់រដ្ឋាភិបាល។[6]ម្យ៉ាងវិញទៀត ប្រទេសបង់ក្លាដេសអាចមានលទ្ធភាពធ្វើការទូទាត់នូវការបាត់បង់បណ្តាលពីការកាត់បន្ថយអត្រាពន្ធនាំចូល និងកំណើនបរិមាណផលិតផលនាំចូលដោយដាក់ឱ្យមានការប្រមូលពន្ធលើប្រាក់ចំណូល ដូចជា VAT (ប្រអប់ ១.២)។

## ប្រអប់ ១.២

### ស្ថានការបាត់បង់ប្រាក់ចំណូលពីសេរីភាវូបនីយកម្មនៅបង់ក្លាដេស

ប្រទេសបង់ក្លាដេសបានធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ហើយនៅក្នុងអំឡុងទសវត្សរ៍នេះ បានកាត់បន្ថយពាក់កណ្តាលនូវអត្រាជាក់ស្តែងនៃពន្ធនាំចូល។ ប៉ុន្តែ ការបាត់បង់ប្រាក់ចំណូលមានកម្រិតត្រឹមតិចជាង ៥% នៃ GDP។ មានហេតុផលចំនួនពីរដែលនាំឱ្យមានប្រការនេះ។ ទីមួយ ដោយសារនៅពេលដែលពន្ធនាំចូលបានធ្លាក់ចុះ បរិមាណនាំចេញបានកើនឡើង ១៧% ក្នុងមួយឆ្នាំ សម្រាប់អំឡុងពេលនៃទសវត្សរ៍នោះ (គិតជារូបិយប័ណ្ណក្នុងស្រុក) នៅពីក្រោយកំនើនយ៉ាងឆាប់រហ័សនៃការនាំចេញ ជាពិសេសវាយនភ័ណ្ឌ។ លើសពីនេះ មូលដ្ឋានពន្ធត្រូវបានពង្រីក នៅពេលដែលមានការពង្រីកឧស្សាហកម្មនាំចេញ។ ទីពីរ បង់ក្លាដេសបានបង្កើត VAT និងអាករបន្ថែមដែលអាចប្រមូលប្រាក់ចំណូលបានយ៉ាងច្រើន និងឆាប់រហ័សដោយសារមូលដ្ឋានពន្ធទូលំទូលាយ។ កិច្ចប្រឹងប្រែងពិសេសក៏បានផ្តោតផងដែរ នៅក្នុងឆ្នាំថ្មីៗនេះ ទៅលើការបង្កើនចំណូលពីពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណេញ ជាពិសេសតាមរយៈការលុបបំបាត់អំពើគេចពន្ធ (តារាងទី ១)។

**តារាងទី ១: អនុបាតពន្ធ- GDP នៅប្រទេសបង់ក្លាដេស**

| | ១៩៩៣-៩៤ | ១៩៩៩-២០០០ | ២០០៣-០៤ |
|---|---|---|---|
| VAT និងអាករបន្ថែម | ៣.១ | ៣.៦ | ៤.២ |
| ពន្ធគយ | ២.២ | ១.៨ | ២.១ |
| ពន្ធលើប្រាក់ចំណូលនិងប្រាក់ចំណេញ | ១.៣ | ១.០ | ១.៤ |
| ពន្ធផ្សេងទៀត | 0.៦ | 0.៤ | 0.៦ |
| ចំណូលពន្ធសរុប | ៧.២ | ៦.៨ | ៨.២ |

ប្រភព: IMF ២០០៦។

មតិជំទាស់ទីពីរទៅនឹងផ្នែកខុសគ្នាទាំងស្រុងនេះ ទាក់ទងនឹងលំដាប់លំដោយ ដោយហេតុថាការអភិវឌ្ឍមនុស្សអាចជាប្រការចាំបាច់ដើម្បីជម្រុញកំណើនសេដ្ឋកិច្ច។ នៅក្នុងរយៈពេលខ្លី ប្រទេសនានាអាចត្រូវចំណាយធនធានទៅលើការអភិវឌ្ឍមនុស្ស សូម្បីតែត្រូវកាត់បន្ថយអត្រាកំណើនក៏ដោយ ពីព្រោះពួកគេជឿថា សមត្ថភាពខ្ពស់នឹងនាំឱ្យមានកំណើនដោយចីរភាពសម្រាប់រយៈពេលវែង។ ជោគជ័យនៃឧស្សាហូបនីយកម្មត្រូវការមិនត្រឹមតែមូលធន និងបច្ចេកវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែនៅត្រូវការពលករប្រកបដោយជំនាញគ្រប់គ្រាន់ ពោលគឺកម្លាំងដែលអាចគ្រប់គ្រងមូលធន និងបច្ចេកវិទ្យាទាំងនោះ ព្រមទាំងអាចគោរពតាមបទបញ្ជាផងដែរ ដែលជាតម្រូវការនៅក្នុងផលិតកម្មតាមរោងចក្រ។ សមត្ថភាពនេះទាក់ទងដោយផ្ទាល់ទៅនឹងអក្ខរភាព ការអប់រំ និងស្ថានភាពសុខភាព។ ឧទាហរណ៍នៅក្នុងប្រទេសជឿនលឿននានា កម្មវិធីសង្គមខាងផ្នែកសុខភាព និងការអប់រំ បានជួយគាំទ្រការអភិវឌ្ឍឧស្សាហកម្ម និងបង្កើនផលិតភាព។ ប្រសិនបើកំណើនធ្វើឱ្យរាំងស្ទះឬកាត់បន្ថយការអភិវឌ្ឍមនុស្ស ក្នុងករណីនេះ កំណើននេះអាចមិនមាននិរន្តរភាពឡើយ។

ហេតុនេះហើយ រដ្ឋាភិបាលភាគច្រើនបានយល់ឃើញពីតម្រូវការធ្វើអន្តរាគមន៍ ដើម្បីសម្រេចជោគជ័យខាងពាណិជ្ជកម្ម ដែលជាដំណើរការប្រកបដោយឫសគល់ចាក់យ៉ាង

ជ្រៅទៅក្នុងប្រវត្តិសាស្ត្រ (ប្រអប់ ១.៣)។ លទ្ធផលល្អដែលទទួលបានពីពាណិជ្ជកម្មអន្តរជាតិ ត្រូវបានចាត់ទុកថា អាស្រ័យលើអន្តរាគមន៍បីបែបរបស់រដ្ឋ។ ទីមួយ : រដ្ឋអាចបង្កើនសមត្ថភាព ដើម្បីចូលរួមដោយជោគជ័យនៅក្នុងពាណិជ្ជកម្ម ការពង្រឹងគុណភាព និង ភាពប្រកួតប្រជែងរបស់កម្លាំងពលកម្មនៅក្នុងស្រុក សម្រួលការធ្វើចរាចរឆ្លងដែននូវផលិតផល និងសេវា និងការវិនិយោគលើការអភិវឌ្ឍទីផ្សារដែលអនុញ្ញាតឱ្យមានការចូលរួម និងកំណើននៃអ្នកចូលរួមប្រកួតប្រជែង ។

ទីពីរៈរដ្ឋចាំបាច់ត្រូវការពារអ្នកទន់ខ្សោយ។ ការពង្រឹងពាណិជ្ជកម្មនឹងនាំមកនូវអ្នកឈ្នះនិងអ្នកចាញ់។ បណ្តាអ្នកដែលទៅពុំទាន់គេ អាចបាត់បង់មុខរបរឬមានប្រាក់ចំណូលធ្លាក់ចុះ ឬត្រូវប្រឈមកាន់តែខ្លាំងឡើងចំពោះអសន្តិសុខស្បៀង។ ការថយចុះនៃការអភិវឌ្ឍមនុស្ស មិនត្រឹមតែមិនអាចទទួលយកបានប៉ុណ្ណោះទេ វាអាចថែមទាំងធ្វើឱ្យបាត់បង់ការឯកភាពមតិនៅក្នុងសង្គម ដែលជាប្រការចាំបាច់ ដើម្បីអនុវត្តយុទ្ធសាស្ត្រនៃការចូលរួមកាន់តែច្រើនឡើង នៅក្នុងពាណិជ្ជកម្ម។ ហេតុនេះ រដ្ឋត្រូវតែបង្កើតផងដែរនូវបណ្តាញសុវត្ថិភាពដែលជាប្រការចាំបាច់សម្រាប់ការពារអ្នកទន់ខ្សោយ។

ទីបី : រដ្ឋគួរតែអាចផ្តល់ការណែនាំអំពីយុទ្ធសាស្ត្រឧស្សាហកម្ម។ ដោយផ្អែកលើចក្ខុវិស័យទូលំទូលាយ រដ្ឋគួរតែមានលទ្ធភាពវាយតម្លៃអំពីបរិបទអន្តរជាតិនិងការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធផលិតកម្មពិភពលោក។ ហេតុនេះ រដ្ឋគួរតែមានលទ្ធភាពធ្វើអត្តសញ្ញាណវិស័យដែលមានអំណោយផល លើកទឹកចិត្តឱ្យមានសកម្មភាពក្នុងវិស័យទាំងនេះ និងវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ដែលចាំបាច់ដើម្បីកសាងភាពប្រកួតប្រជែងនៅក្នុងវិស័យដែលលេចឡើងថ្មីនានា។

មុខងារទាំងបីនេះមានសារៈសំខាន់ណាស់ ប៉ុន្តែអាចនៅពុំទាន់គ្រប់គ្រាន់នៅឡើយទេ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយ រដ្ឋក៏ត្រូវតែស្វែងរកវិធីដើម្បីឆ្លើយតបនឹងអតុល្យភាពនៅក្នុងទីផ្សារអន្តរជាតិផងដែរ។ ឧទាហរណ៍ រដ្ឋចាំបាច់ត្រូវគិតគូរអំពីភាពខុសគ្នាយ៉ាងខ្លាំងនៃសមត្ថភាពជាតិ ក្នុងការធ្វើពាណិជ្ជកម្ម គម្លាតយ៉ាងខ្លាំងនៃទំហំទីផ្សារ វត្តមាននៃទីផ្សារនិងដៃគូដែលមានភាពប្រកួតប្រជែងគ្នា ព្រមទាំងវិធានការត្រួតពិនិត្យធ្វើឡើងដោយក្រុមតូចមួយដែលជាអ្នកដើរតួសំខាន់ៗមកពីប្រទេសជឿនលឿនមួយចំនួន ទៅលើបច្ចេកវិទ្យាទំនើបៗមួយចំនួន។

ដោយត្រូវប្រឈមនឹងអតុល្យភាពទាំងនេះ រដ្ឋាភិបាល ខ្លះដែលមាន "ទុទិដ្ឋិនិយមអំពីការនាំចេញ" បានដកខ្លួនថយចេញពីការពុះពារប្រកបដោយវិសមភាពនិងបានផ្តោតតែលើការផលិតសម្រាប់ទីផ្សារក្នុងស្រុកនៅពីក្រោយរបាំងពន្ធដែលមានអត្រាខ្ពស់។ ស្ថានភាពបែបនេះ អាចធ្វើឱ្យយើងយល់បាន ប៉ុន្តែការធ្វើបែបនេះពុំមាននិរន្តរភាពទេ។ គ្មានប្រទេសណាមួយអាចជម្រុញការធ្វើឧស្សាហូបនីយកម្ម តាមបែបមូលធននិយមដោយជោគជ័យបានឡើយ នៅពេលដែលស្ថិតនៅដាច់ដោយឡែកពីទីផ្សារពិភពលោក។ ផ្ទុយទៅវិញ ក្នុងនាមជាចំណែកមួយនៃយុទ្ធសាស្ត្រដើម្បីកំណើន បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ត្រូវតែចូលរួមប្រកបដោយវិចារណញ្ញាណជាមួយទីផ្សារទាំងនោះ។

## វិធានត្រៀមបង្ការជាមុន

ការចូលប្រឡូកជាមួយពាណិជ្ជកម្មអន្តរជាតិមិនមែនមានន័យថា ជាការធ្វើសមាហរណកម្មអសកម្មនោះទេ។ ដើម្បីដោះស្រាយវិសមភាពនៅក្នុងប្រព័ន្ធពាណិជ្ជកម្មពិភពលោក ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវប្រកាន់គោលជំហរប្រកបដោយការប្រុងប្រយ័ត្នជាមុន។ ប៉ុន្តែ ដើម្បីធ្វើដូច្នេះបាន ប្រទេសទាំងនោះត្រូវធ្វើការញែកដាច់គ្នារវាងគោលនយោបាយរួមនានា ដែល

*រដ្ឋាភិបាលភាគច្រើនបានយល់ឃើញពីតម្រូវការធ្វើអន្តរាគមន៍ ដើម្បីសម្រេចជោគជ័យខាងពាណិជ្ជកម្ម*

មានគោលដៅ "ចូលរួមកាន់តែសកម្មនៅក្នុងពាណិជ្ជកម្ម" ដូចជាកាត់បន្ថយថ្លៃចំណាយលើការដឹកជញ្ជូន និងគោលនយោបាយដែលពាក់ព័ន្ធជាមួយ "ការបើកចំហ" ដូចជាកាត់បន្ថយរបាំងពន្ធ។ ប្រការទាំងនេះ នាំឱ្យមានសំនួរខុសគ្នា។ សំនួរទីមួយគឺ តើពាណិជ្ជកម្មអន្តរជាតិពង្រឹងកំណើនសេដ្ឋកិច្ចដែរឬទេ? ចម្លើយទូទៅគឺ ទំនងជា "ពិតហើយ"។ សំណួរទីពីរគឺ "តើប្រទេសនានាដែលកាត់បន្ថយរបាំងពន្ធ មានការលូតលាស់រហ័សជាងប្រទេសដទៃផ្សេងទៀតឬ?" នេះជាសំនួរដែលមានភាពចម្រូងចម្រាស់ដែលទាក់ទងនឹងការរកភស្តុតាងបញ្ជាក់។[៩]

ប្រការនេះ នាំឱ្យមានសំណើកញ្ចប់វិធានការដ៏សាំញ៉ាំ និងវិធានប្រកបដោយការប្រុងប្រយ័ត្ន និងពុំសូវសាំញ៉ាំទាក់ទងនឹងការលុបចោលរបាំងពាណិជ្ជកម្ម (ប្រអប់១.៤)។ គោលបំណងមួយក្នុងចំណោមគោលបំណងសំខាន់ៗ គួរតែជាការលើកទឹកចិត្ត និងការពារផលិតផលក្នុងស្រុក នៅក្នុងវិស័យ

## ប្រអប់ ១.៣

### អន្តរាគមន៍របស់រដ្ឋទៅលើពាណិជ្ជកម្ម - បាតុភូតដែលមានជាយូរលង់មកហើយ

នៅក្នុងរវាងឆ្នាំ៦០ អ្នកជំនួញមួយរូបធ្វើដំណើរមកពីក្រុងដាកា ប្រទេសបង់ក្លាដេស ចេញពី Jeddah មកដល់ទីក្រុងរ៉ូម ដោយនាំមកជាមួយនូវសាច់ក្រណាត់ដ៏ល្អ។ គាត់ស្ទើរតែបានធ្វើឱ្យមានកុប្បកម្ម និងត្រូវបានគេសន្យាផ្តល់ជាប្រាក់កាក់ មាស និងសាច់ប្រាក់ និងរហូតដល់សត្វសេះដែលមានតម្លៃសមមូលគ្នា។ អធិរាជ Toberius មានការបារម្ភជាខ្លាំង ព្រោះថាតម្រូវការមុខទំនិញបែបនេះបាននាំឱ្យធនធានរបស់ទីក្រុងរ៉ូម ត្រូវថយចុះជារៀងរាល់ឆ្នាំក្នុងអត្រាជិត ៥០លាន sesterces (ដុំមាស សម្រាប់ការដោះដូរ)។ ដូច្នេះគាត់បានដាក់ការហាមឃាត់ចំពោះការលក់សាច់ក្រណាត់ខាងលើនេះ។ ជាក់ស្តែង គាត់មានការបារម្ភយ៉ាងខ្លាំងរហូតដល់បញ្ជាឱ្យរាយទាហាន ដើម្បីរាំងស្កាត់ការនាំចូលសាច់ក្រណាត់ប្រភេទនេះមកក្នុងទីក្រុងរ៉ូម។ លំហូរជំនួញឆ្លងដែននេះ គឺជាបាតុភូតដែលមានជាយូរលង់មកហើយ ហើយគោលនយោបាយរបស់រដ្ឋក្នុងការត្រួតត្រាពាណិជ្ជកម្ម ដើម្បីបម្រើគោលដៅ សាធារណៈក៏មានជាយូរលង់មកហើយដែរ។

ប្រភព: Bandyopadhyay ២០០៥។

យុទ្ធសាស្ត្រនានា ដោយផ្តល់ឱ្យវិស័យទាំងនោះនូវលំហ និង កាលសម្រាប់ពង្រីកផលិតកម្ម ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ទន្ទឹមនឹងការពង្រឹងសមត្ថភាពរបស់ពួកគេ ដើម្បីប្រកួតប្រជែងជាអន្តរជាតិ។ យុទ្ធសាស្ត្រនេះដែលធ្លាប់បានអនុវត្តដោយបណ្តាប្រទេសនៅអឺរ៉ុបខាងលិច គឺជាដាក់កំហិតដល់ការនាំចូលផលិតផលសម្រេចខ្លះៗ ទន្ទឹមនឹងការអនុញ្ញាតឱ្យនាំចូលមូលធនសំខាន់ៗ វត្ថុធាតុដើម និងផលិតផលពាក់កណ្តាលសម្រេច ដែលនឹងអនុញ្ញាតឱ្យផលិតករក្នុងស្រុកអាចប្រកួតជាមួយដៃគូបរទេស។ បណ្តាប្រទេសដែលប្រកាន់យកយុទ្ធសាស្ត្របែបនេះចាំបាច់ត្រូវតែប្រឆាំងនឹងការបង្ខំឱ្យធ្វើឱ្យមានអត្រាពន្ធដូចគ្នាសម្រាប់ក្រុមទំនិញខុសៗគ្នាចំនួន ឬរវាងប្រទេសទាំងនោះជាមួយប្រទេសផ្សេងទៀតលើពិភពលោក។ ទន្ទឹមនឹងនេះ រដ្ឋអាចដាក់ឱ្យអនុវត្តពន្ធសមស្រប ប្រឆាំងនឹងការនាំចូល ដើម្បីចាក់ចោល និងធានាថា ក្នុងករណីអាចធ្វើបានរដ្ឋផ្តល់អាទិភាពដល់ផលិតករជាតិ ដើម្បីប្រកួតប្រជែងធ្វើលទ្ធកម្មសម្រាប់បំពេញតម្រូវការរបស់រដ្ឋ។ ទោះជាយ៉ាងនេះក៏ដោយ ប្រការសំខាន់គឺត្រូវធានាថា កិច្ចការពារបែបនេះមិននាំឱ្យមានអំពើផ្តាច់មុខនៅក្នុងប្រទេស ដែលបង្កឱ្យមានភាពខ្ជិលច្រអូស ឈានទៅនិន្នាការចម្រាញ់យកផលប្រយោជន៍ពីទីផ្សារក្នុងស្រុកឡើយ។

បន្ទាប់មក រដ្ឋត្រូវលើកទឹកចិត្តដល់អ្នកនាំចេញ។ ការនាំចេញមិនអាចគ្រាន់តែជាមូលដ្ឋានសម្រាប់កំណើនប៉ុណ្ណោះទេ ប៉ុន្តែ នៅក្នុងពិភពលោកដែលពឹងផ្អែកលើគ្នាទៅវិញទៅមក ការនាំចេញមានសារៈសំខាន់ជាអាយុជីវិតសម្រាប់ទូទាត់ជាមួយការនាំចូលសំខាន់ៗ។ ជាដំបូង ប្រទេសនានាត្រូវពិនិត្យមើលទំនិញកម្មន្តសាលដែលមានលក្ខណៈសាមញ្ញដែលអាចទាញយកផលចំណេញពីកម្រៃទាបនៃកម្លាំងពលកម្ម និងអាចជាទំនិញដែលមិនមានចែងច្បាស់លាស់ក្នុងក្របខ័ណ្ឌច្បាប់ ឬដែលសិទ្ធិការងារមិនសូវបើកទូលាយ ដូចជា នៅក្នុងតំបន់ពាណិជ្ជកម្មសម្រាប់ការ

នាំចេញ (ប្រអប់ ១.៥)។ គ្រប់ប្រទេសដែលទទួលជោគជ័យលើឧស្សាហូបនីយកម្មនៅពេលចុងក្រោយនេះ រួមទាំង "សេដ្ឋកិច្ចឧស្សាហកម្មថ្មីៗ" នេះផង បានប្រកាន់យកយុទ្ធសាស្ត្រ "ពាណិជ្ជវិស័យ" បែបនេះ ដោយជម្រុញរាល់ការនាំចេញ ទោះបីត្រូវចំណាយបែបណាក៏ដោយ ដើម្បីបង្កើតទីតាំងរឹងមាំនៅលើទីផ្សារអន្តរជាតិ។

វិធានការនានាដើម្បីជម្រុញឧស្សាហកម្មជាតិក៏ត្រូវតែដើរទន្ទឹមជាមួយការគោរពវិន័យក្នុងកម្រិតសមស្របផងដែរ។ នៅពេលផ្តល់ការលើកទឹកចិត្តដល់ឧស្សាហករ រដ្ឋត្រូវតែរក្សាអំណាចក្នុងការពង្រឹងការអនុវត្តច្បាប់ និងក្នុងករណីសមស្រប ត្រូវតែមានឥទ្ធិពលទៅលើជម្រើសមុខផលិតផល ដូចជា បច្ចេកវិទ្យាសម្រាប់ប្រើប្រាស់ ទំហំនៃផលិតកម្ម និងថ្លៃទំនិញ។

## តម្រូវការធ្វើវិនិយោគ

ទោះជាយ៉ាងណាក៏ដោយ ជាបណ្តើរៗឧស្សាហករ

ប្រអប់ ១.៤

### សមាហរណកម្មជាយុទ្ធសាស្ត្ររបស់អន្តរជាតិ នៅក្នុងសកលភាវូបនីយកម្មពិភពលោក

បរិស្ថានសកល ដែលនៅក្នុងនោះប្រទេសកំពុងអភិវឌ្ឍន៍ត្រូវលើកកម្ពស់ផលិតភាពរបស់ប្រជាពលរដ្ឋខ្លួន មានភាពខុសគ្នាយ៉ាងខ្លាំងធៀបនឹងកាលៈទេសៈនៃពេលដែល "គោលនយោបាយឧស្សាហកម្ម" ត្រូវបានអនុវត្តដោយជោគជ័យ នៅក្នុងបណ្តាប្រទេសដែលបច្ចុប្បន្នជាប្រទេសឧស្សាហកម្ម។ ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវប្រឈមដោះស្រាយទម្រង់ថ្មីៗ របស់អង្គការឧស្សាហកម្ម ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃបច្ចេកទេស និងការថយចុះនៃភាពនៅឯកាខាងសេដ្ឋកិច្ច។ Lall (២០០៥) រៀបរាប់អំពីចំណុចដូចខាងក្រោមនេះ ថាមានសារៈសំខាន់ណាស់នៅក្នុងបរិបទសព្វថ្ងៃនេះ :

- **ភាពជ្រើសយកបាន** ការជ្រើសយកវិស័យមួយចំនួននៅពេលណាមួយ ដើម្បីធ្វើការអភិវឌ្ឍ តែមិនជម្រុញសកម្មភាពឧស្សាហកម្មទាំងអស់ដោយគ្មាន រើសមុខនោះទេ។
  **បច្ចេកវិទ្យា និងចំណងទាក់ទង** ការផ្តោតលើសកម្មភាពដែលអាចបន្សាយបច្ចេកវិទ្យានិងចំណងទាក់ទងខ្លាំងក្លាបំផុត ជាមួយឧស្សាហកម្មផ្សេងទៀត។
- **ការចូលទៅក្នុងទីផ្សារពិភពលោកនៅដំណាក់កាលដំបូង** ការជួយសហគ្រាសឱ្យចូលរួមនៅក្នុងទីផ្សារអន្តរជាតិនៅក្នុងដំណាក់កាលដើមដំបូងរបស់ខ្លួន។
- **ផ្នែកឯកជននាំមុខ** ជួយនៅក្នុងតួនាទីនាំមុខរបស់សហគ្រាសឯកជន ដោយមានការគាំទ្រពីសហគ្រាសសាធារណៈ។
- **កសាងជំនាញ និងហេដ្ឋារចនាសម្ព័ន្ធ** វិនិយោគលើជំនាញដែលត្រូវការនៅក្នុងវិស័យនានាដែលបានទទួលការជ្រើសរើសសម្រាប់ការកែលំអ។
- **ជ្រើសប្រើប្រាស់ការវិភាគវិនិយោគបរទេស (FDI)** លើកទឹកចិត្តឱ្យមានការវិនិយោគបរទេសដោយផ្ទាល់ ដើម្បីជួយកសាងសមត្ថភាពនៅក្នុងមូលដ្ឋាន និងដើម្បីអាចចូលទៅប្រើប្រាស់បច្ចេកវិទ្យាផលិតកម្មកម្រិតខ្ពស់ និងទីផ្សារបរទេស។
- **អភិបាលកិច្ចល្អ** ពង្រឹងលទ្ធភាពរបស់ទីភ្នាក់ងារសាធារណៈ ដើម្បីបន្សាំគោលនយោបាយសាធារណៈទៅនឹងការផ្លាស់ប្តូរនៃទីផ្សារអន្តរជាតិនិងភាពរីកចម្រើននៃបច្ចេកវិទ្យាដោយធ្វើការជិតស្និទ្ធជាមួយវិស័យឯកជន។

ប្រទេសនីមួយៗ នឹងមានយុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មខុសៗគ្នា ស្របទៅតាមលក្ខខណ្ឌធម្មជាតិ ដែលផ្តល់ឱ្យទីតាំងភូមិសាស្ត្រ សមត្ថភាពរបស់រដ្ឋាភិបាល។ ចំណាត់ការដ៏ខ្លាំងរបស់សាធារណរដ្ឋកូរ៉េ ក្នុងការដាក់ឱ្យមានកាតព្វកិច្ចលើការនាំចេញចំពោះសហគ្រាសដែលមានការអនុគ្រោះ ត្រូវបានដឹងឮសុះសាយ។ សិង្ហបុរី ពឹងផ្អែកយ៉ាងខ្លាំងលើ FDI ប៉ុន្តែពុំដែលភ្ជាប់ការអភិវឌ្ឍរបស់ខ្លួនទៅនឹងការប្រព្រឹត្តរបស់សហគ្រាសពហុជាតិណាមួយឡើយ។ ប្រទេសនានាដែលទទួលជោគជ័យក្នុងការអនុវត្តយុទ្ធសាស្ត្រសេរីភាពរូបនីយកម្មនៃការនាំចេញនៅក្នុងដំណាក់កាលជាក់លាក់ណាមួយនៃការអភិវឌ្ឍដើម្បីលើកកម្ពស់លទ្ធភាពបានឈោងទៅប្រើប្រាស់ផលិតផលពាក់កណ្តាលសម្រេច និងបច្ចេកវិទ្យា ដើម្បីបង្កើតសម្ពាធនៃការប្រកួតប្រជែង។ ប្រទេសខ្លះបានបង្វែរឥណទាន និងធាតុចូល ទៅក្នុងវិស័យជាអាទិភាព។

អាចចាប់ផ្តើមឈានទៅរកខ្សែសង្វាក់ផលិតកម្មកម្រិតខ្ពស់។ ការធ្វើបែបនេះនឹងទាមទារឱ្យមានការវិនិយោគច្រើន មិនគ្រាន់តែដើម្បីពង្រីកផលិតកម្មប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើកំណែទម្រង់ និងទំនើបកម្មមូលដ្ឋានផលិតកម្មថែមទៀតផង។ វិធានការងាយស្រួលមួយដើម្បីធ្វើឱ្យរីកចម្រើនតាមទិសដៅនេះ គឺ "អត្រាវិនិយោគ" ដែលជាអនុបាត (Ratio) ការវិនិយោគជាមួយផលចំណូលជាតិ។ ការវិនិយោគកម្រិតខ្ពស់ នឹងនាំទៅរកអត្រាខ្ពស់នៃកំណើនសេដ្ឋកិច្ច។

ការវិភាគមួយអំពីបទពិសោធនេះនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ២៥ នៅរវាងឆ្នាំ ១៩៦៨-៨៨ បានបង្ហាញ

ប្រអប់ ១.៥

## តំបន់កែច្នៃសម្រាប់ការនាំចេញ

តំបន់កែច្នៃសម្រាប់ការនាំចេញ (EPZs) បានដើរតួនាទីសំខាន់នៅក្នុងការបង្កើតការងារដែលឱ្យផលនិងប្រាក់កម្រៃ នៅក្នុងសេដ្ឋកិច្ចមួយចំនួននៅអាស៊ី រួមទាំង នៅតៃវ៉ាន់ (ចិន) សាធារណរដ្ឋកូរ៉េ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ថៃ និងហ្វីលីពីន ហើយថ្មីៗនេះនៅក្នុងប្រទេសចិន វៀតណាម បង់ក្លាដេស និងស្រីលង្កា។

នៅប្រទេសចិន EPZs រួមចំណែកច្រើនជាង ៩៥% នៃការនាំចេញសរុប និងបានបង្កើតការងារធ្វើចំនួន ៤០ លាន (Fong ២០០៦)។ បច្ចុប្បន្នការងារដែលបានបង្កើតដោយវិស័យកម្មន្តសាលនៅក្នុង EPZs មាន ៦% នៅបង់ក្លាដេស និង ១០% នៅស្រីលង្កា។

នៅខែមករា ឆ្នាំ ២០០៦ UNDP បានធ្វើការអង្កេតបឋមក្នុងចំណោម EPZs ធំជាងគេចំនួនបីនៅឥណ្ឌា: ទីក្រុងមុំបៃ ណូអីដា និងចិនណៃ ដោយបានសម្ភាសកម្មករចំនួន ២២៩នាក់។ ការអង្កេតនោះ និងទិន្នន័យដែលមានស្រាប់ បង្ហាញដូចតទៅ (Aggarwal ២០០៦):

**ស្ត្រី** : ស្ត្រីមានត្រឹមតែប្រមាណ ៤៦% នៃកម្មករនៅក្នុង EPZs នៃប្រទេសឥណ្ឌា និងជាអត្រាដែលកំពុងធ្លាក់ចុះ នៅពេលដែល EPZs ប្រើប្រាស់បច្ចេកវិទ្យាកាន់តែទំនើប។

**ការបណ្តុះបណ្តាល** : EPZs នៅឥណ្ឌាមានការវិវត្តឈានដល់ដំណាក់កាលទីពីរទៅហើយ ដែលទាមទារឱ្យមានកម្មករជំនាញកាន់តែច្រើនឡើង។ ទោះជាបែបនេះក្តី មានតែចំនួនពាក់កណ្តាលនៃអ្នកដែលបានឆ្លើយនៅក្នុងសម្ភាស ដែលបានទទួលការបណ្តុះបណ្តាលជាផ្លូវការ។

**ច្បាប់ការងារ** : ច្បាប់ការងារចែងថា ពុំមានការបង្ខំឱ្យកម្មករធ្វើការនៅក្នុងរោងចក្រលើសពី ៤៨ ម៉ោងក្នុងមួយសប្តាហ៍ ឬច្រើនជាង ៩ ម៉ោងឡើយនៅក្នុងថ្ងៃណាមួយ។ ជាទូទៅ នេះជាករណីមួយដែលត្រូវបានរកឃើញថាមានការគោរពបានល្អ។

**បរិក្ខារសុខភាព** : ច្រើនជាង ៩០% នៃក្រុមហ៊ុនដែលបានអង្កេត បានរាយការណ៍ថា ខ្លួនបានផ្តល់សេវាសុខភាព។ ប្រមាណ ៧០% ឆ្លើយថា ពួកគេបានផ្តល់បរិក្ខារដើម្បីការពារពលករពីគ្រោះថ្នាក់នានា។

**លក្ខខណ្ឌការងារ** : កម្មករភាគច្រើននិយាយថា ពួកគេចូលធ្វើការនៅក្នុងតំបន់នោះដោយសារលក្ខខណ្ឌការងារប្រសើរ និងមានប្រាក់បៀវត្សរ៍ខ្ពស់ ហើយ ៧០% បានពេញចិត្តចំពោះលក្ខខណ្ឌនោះ។ ជាទូទៅ និយោជកមិនផ្តល់កន្លែងស្នាក់នៅដល់កម្មកររបស់ខ្លួនទេ ប៉ុន្តែក្រុមហ៊ុនភាគច្រើននៅក្នុងតំបន់នោះអនុញ្ញាតឱ្យកម្មកររបស់ខ្លួន បានឈប់សម្រាកធម្មតា ឈប់ដើម្បីពិនិត្យជម្ងឺ និងឈប់សម្រាកសម្រាប់ថ្ងៃដែលខ្លួនបានសន្សំពីមុនមក។

**ប្រាក់កម្រៃ និងចំណូល** : យោងតាមការអង្កេត ប្រាក់កម្រៃនៅក្នុង EPZs មិនខ្ពស់ជាងនៅតំបន់ខាងក្រៅឡើយ ប៉ុន្តែប្រាក់ចំណូលដែលរាប់បញ្ចូលទាំងប្រាក់លើកទឹកចិត្ត ត្រូវបានកម្មករភាគច្រើនពេញចិត្ត។

**ភាពក្រីក្រ** : ទោះបីស្ថានភាពរស់នៅរបស់កម្មករនៅក្នុងភែឈសត្រូវបានកែលំអក្តី ឥទ្ធិពលទៅលើភាពក្រីក្រមានតិចតួចតែប៉ុណ្ណោះ ដោយសារទំនាក់ទំនងនៅខាងក្រោយសេដ្ឋកិច្ចផ្សេងទៀតមានកម្រិតទាប។

**ការអង្កេតនៅក្នុងប្រទេសប៉ាគីស្ថាន និងស្រីលង្កា** : ក្នុងឆ្នាំ ២០០៦ បានផ្តល់លទ្ធផលប្រហាក់ប្រហែលគ្នា (Kemal ២០០៦; Marga Institute ២០០៦)។

ពីទំនាក់ទំនងជិតស្និទ្ធរវាងអត្រាវិនិយោគ និងកំណើននៃធាតុចូល ។[៦] ការសិក្សាដដែលនេះ បានរកឃើញពីទំនាក់ទំនងជិតស្និទ្ធរវាងអត្រាវិនិយោគនិងកំណើននៃការនាំចេញ ។[៧] ហេតុអ្វីកំណើននៃការវិនិយោគនាំឱ្យមានកំណើនបរិមាណនៃការនាំចេញ? សម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ប្រការនេះកើតឡើងជាបឋម ដោយសារពួកគេអាចប្រើប្រាស់ការវិនិយោគសម្រាប់កែទម្រង់រចនាសម្ព័ន្ធផលិតកម្ម និងការនាំចេញ ដោយឈានពីមុខទំនិញនានាដែលពាណិជ្ជកម្មពិភពលោកពុំសូវមានការរីកចម្រើនទៅបង្កើតផលិតផល ដែលពាណិជ្ជកម្មពិភពលោកមានការកើនឡើងយ៉ាងឆាប់រហ័សជាង ។ កាលណាអនុបាតវិនិយោគកាន់តែខ្ពស់ ការបំលែងនៅក្នុងផលិតកម្ម និងរចនាសម្ព័ន្ធនឹងធ្វើទៅបានកាន់តែរហ័ស ហើយសមត្ថភាពដើម្បីចូលរួមនៅក្នុងពាណិជ្ជកម្មពិភពលោកក៏កាន់តែកើនឡើងផងដែរ ។

ទោះបីជាយ៉ាងណាក៏ដោយ ទន្ទឹមនឹងលើកទឹកចិត្តឱ្យមានការវិនិយោគ រដ្ឋក៏ត្រូវតែដើរតួជាអ្នកសម្របសម្រួលផងដែរ ដោយធានាថាការវិនិយោគត្រូវតែផ្តោតលើវិស័យអាទិភាព ដែលអាចយកទៅប្រើប្រាស់សម្រាប់បង្កើនកម្រិតបច្ចេកវិទ្យា និងសម្រេចបាននូវសេដ្ឋកិច្ចទ្រង់ទ្រាយធំ ដើម្បីអាចពង្រឹងភាពប្រកួតប្រជែងជាអន្តរជាតិ ។ សេដ្ឋកិច្ច ដូចជានៅប្រទេសជប៉ុន សាធារណរដ្ឋកូរ៉េ និងតៃវ៉ាន់ (ចិន) ទោះបីមានលក្ខណៈខុសគ្នាក្តី សុទ្ធតែអនុវត្តតាមយុទ្ធសាស្ត្រនៃគោលនយោបាយឧស្សាហកម្មបែបនេះ ដែលព្យាករណ៍ទុកអំពីកាលានុវត្តភាពទៅអនាគត និងបង្វែរការវិនិយោគទៅរកទិសដៅដែលអាចទទួលជោគជ័យជាងគេ ។ ប្រការគួរឱ្យចាប់អារម្មណ៍ គឺថានៅពេលដែលប្រទេសទាំងនោះ រុះរើក្របខ័ណ្ឌគោលនយោបាយឧស្សាហកម្មទាំងនេះ ពួកគេក៏ជួបប្រទះវិបត្តិហិរញ្ញវត្ថុភ្លាម ។

## គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង អត្រាប្តូរប្រាក់

ត្រូវមានអន្តរាគមន៍យុទ្ធសាស្ត្រផងដែរ នៅក្នុងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងដោយឡែកសម្រាប់គ្រប់គ្រងអត្រាប្តូរប្រាក់ ។ បច្ចុប្បន្ន ពិភពលោកកំពុងពើបប្រទះកំណើនយ៉ាងឆាប់រហ័សនៃលំហូរមូលធនឆ្លងដែន ។ នៅក្នុងអំឡុងពេលដែលសេដ្ឋកិច្ចលូតលាស់បំផុត លំហូរចូលយ៉ាងឆាប់រហ័សនៃមូលធន អាចធ្វើឱ្យអត្រាប្តូរប្រាក់កើនឡើងខ្ពស់ និងធ្វើឱ្យបាត់បង់ភាពប្រកួតប្រជែង ។ ចំណែកលំហូរចេញយ៉ាងឆាប់រហ័សនៃមូលធន ទោះបីវាមិននាំឱ្យមានវិបត្តិទាំងស្រុងខាងរូបិយវត្ថុក៏ដោយ វាអាចនាំឱ្យមានបញ្ហាក្នុងការបញ្ចេញទ្រព្យសកម្មផងដែរ ។

នៅក្នុងដំណាក់កាលដើមដំបូងនានានៃសេរីភាវូបនីយកម្ម តុល្យភាពជញ្ជីងពាណិជ្ជកម្មទំនងជាមានសភាពកាន់តែអាក្រក់ ព្រោះថាបរិមាណនាំចូលបានកើនឡើងរហ័សជាងការនាំចេញ ។ ដូច្នេះ សេរីភាវូបនីយកម្មគួរតែបានទទួលការគាំទ្រដោយកំណែទម្រង់បន្ថែមមួយចំនួន រួមទាំងការគ្រប់គ្រងតម្រូវការក្នុងស្រុក និងអត្រាប្តូរប្រាក់ ។ ជាជាងទុកឱ្យអត្រាប្តូរប្រាក់នៅប្រែប្រួលដោយសេរី បណ្តាសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ទំនងជាអាចទាញយកផលបានពីការគ្រប់គ្រងអត្រាប្តូរប្រាក់ ។

នៅដំណាក់កាលដើមដំបូងនានានៃសេរីភាវូបនីយកម្ម ប្រសិនបើចាំបាច់ គួរតែទុកឱ្យអត្រានេះធ្លាក់ចុះ ។ ធ្វើបែបនេះ និងអាចដោះស្រាយតម្រូវការសម្រាប់ការនាំចូល និងសម្រួល ឱ្យមានការនាំចេញ ។ វាក៏ជួយបង្ការការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃប្រាក់ចំណូលរបស់រដ្ឋាភិបាល និងអាចពង្រីកមូលដ្ឋានពន្ធផងដែរ ទោះបីវាបន្ទាបអត្រាពន្ធក៏ដោយ ។ ធ្វើបែប

*ទន្ទឹមនឹងលើកទឹកចិត្តឱ្យមានការវិនិយោគ រដ្ឋក៏ត្រូវតែដើរតួជាអ្នកសម្របសម្រួលផងដែរ ដោយធានាថាការវិនិយោគត្រូវតែផ្តោតលើវិស័យអាទិភាព*

នេះ គួរតែអាចជួយកែលំអតុល្យភាពជញ្ជីងពាណិជ្ជកម្ម ទោះបីឥទ្ធិពលរួមទៅលើសេដ្ឋកិច្ច អាស្រ័យទៅលើកត្តាដទៃទៀតដែរ ដូចជា ការឆ្លើយតបនឹងការផ្គត់ផ្គង់សម្រាប់នាំចេញ ភាពរឹងត្អឹងនៃរចនាសម្ព័ន្ធ និងភាពរលូននៃសារពើពន្ធ ព្រមទាំងគោលនយោបាយរូបិយវត្ថុ។ បទពិសោធន៍អំពីអត្រាប្តូរប្រាក់ពីប្រទេសមួយចំនួននៅក្នុងតំបន់នេះ មានបង្ហាញជូននៅក្នុងប្រអប់ ១.៦។

ប្រអប់ ១.៦

### អត្រាប្តូរប្រាក់ជាក់ស្តែង : បទពិសោធប្រចាំតំបន់

នៅក្នុងដំណាក់កាលដំបូងនៃសេរីភាវូបនីយកម្ម តុល្យភាពជញ្ជីងពាណិជ្ជកម្មទំនងជាកាន់តែដុនដាប ដោយសារកំណើនការនាំចូលរហ័សជាងការនាំចេញ។ ដូច្នេះសេរីភាវូបនីយកម្មពាណិជ្ជកម្ម គួរតែបានទទួលការគាំទ្រដោយការគ្រប់គ្រងអត្រាប្តូរប្រាក់។ ជាក់ស្តែង ភស្តុតាងបង្ហាញថា ជាជាងទុកឱ្យអត្រានេះប្រែប្រួលដោយសេរី ប្រទេសកំពុងអភិវឌ្ឍន៍ទំនងជាអាចទទួលផលពីការគ្រប់គ្រងអត្រានេះ។ ប្រទេសមួយចំនួននៅក្នុងតំបន់នេះ បានធ្វើទៅតាមគំរូមួយចំនួននៃយុទ្ធសាស្ត្រនេះ។

**អាស៊ីខាងត្បូង** : ផ្អែកលើទិន្នន័យក្នុងឧបសម្ព័ន្ធ តារាង ៤.៤ អត្រាប្តូរប្រាក់ជាក់ស្តែងនៅក្នុងប្រទេសភាគច្រើននៅអាស៊ីខាងត្បូង ទំនងជាប្រែប្រួលប្រហាក់ប្រហែលគ្នា ប៉ុន្តែវដ្តនៃការប្រែប្រួលទំនងជាកាន់តែខ្លី បានន័យថា អត្រាប្តូរប្រាក់ជាក់ស្តែង (REER) បានឡើងខ្ពស់ ឬ ចុះទាបកាន់តែញឹកញាប់។ នៅក្នុងប្រទេសបង់ក្លាដេស ប៉ាគីស្ថាន និង ស្រីលង្កា REER បានកើនឡើងនៅក្នុងពាក់កណ្តាលដើមទសវត្សរ៍ឆ្នាំ ១៩៩០ បន្ទាប់មក បានថយចុះរហូតដល់ឆ្នាំ ១៩៩៨។ ចាប់ពីពេលនោះមក វដ្តនេះកាន់តែខ្លីជាងមុន : REER បានថយចុះនៅក្នុងអំឡុងឆ្នាំ ២000 និង ២00១ បន្ទាប់មកកើនឡើងនៅក្នុងអំឡុងពីរឆ្នាំបន្ទាប់។ លើកលែងតែប្រទេសឥណ្ឌា ដែលភាគច្រើននៃការធ្លាក់ថ្លៃពិតប្រាកដនៃរូបិយប័ណ្ណបានកើនឡើងនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ ការប្រែប្រួលនៃ REER ទំនងជាឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរជាចម្បងនៃស្ថានភាពជញ្ជីងទូទាត់។ ដោយគណនាកម្រិតមធ្យមនៃវដ្តនានា និន្នាការរយៈពេលវែងគឺការធ្លាក់ចុះនៃ REER នៅក្នុងប្រទេសឥណ្ឌា ណេប៉ាល់ និងប៉ាគីស្ថាន និងកើនឡើងនៅប្រទេសស្រីលង្កា និងស្ថិរភាពនៅប្រទេសបង់ក្លាដេស។

**អាស៊ីបូព៌ា** : នៅក្នុងអំឡុងនៃវិបត្តិហិរញ្ញវត្ថុនៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសជាច្រើននៅអាស៊ីបូព៌ា បានប្រទះការធ្លាក់ថ្លៃយ៉ាងខ្លាំងនូវរូបិយប័ណ្ណរបស់ខ្លួន លើកលែងតែប្រទេសម៉ាឡេស៊ីដែលអនុវត្តរបបអត្រាប្តូរប្រាក់កំណត់ទុកនៅក្នុងរយៈកាលក្រោយវិបត្តិ។ ទោះជាយ៉ាងនេះក្តី ដោយសារមូលដ្ឋានគ្រឹះនៃពាណិជ្ជកម្មនៅតែមានភាពរលូននៅឡើយ ការធ្លាក់ថ្លៃគំហុកបាននាំឱ្យមានកំណែលំអតុល្យភាពពាណិជ្ជកម្មធ្វើឱ្យមានស្ថិរភាពជញ្ជីងទូទាត់ និងធ្វើឱ្យប្រទេសនានានៅក្នុងអនុតំបន់នេះ អាចស្តារឡើងវិញបាននៅក្នុងរយៈពេលដ៏ខ្លីមួយពីវិបត្តិហិរញ្ញវត្ថុ។ ការផ្លាស់ប្តូរក្រោយមកទៅរកអត្រាប្តូរប្រាក់ដែលមានការគ្រប់គ្រង បានធ្វើឱ្យរូបិយប័ណ្ណនៃប្រទេសទាំងនេះធ្លាក់ថ្លៃក្នុងអត្រារហ័សជាង ធៀបនឹងអំឡុងពេលមុន។ លទ្ធផលចុងក្រោយគឺបណ្តាប្រទេសនៅអាស៊ីបូព៌ាបានកសាងមូលធនបម្រុងជារូបិយប័ណ្ណបរទេសយ៉ាងច្រើន ហើយបច្ចុប្បន្នបានបង្ហាញនូវរោគសញ្ញាជម្ងឺហូឡង់ "Dutch disease" នៃការឡើងថ្លៃរូបិយប័ណ្ណបណ្តាលមកពីការសន្សំទុករូបិយប័ណ្ណបរទេសយ៉ាងច្រើន។ រវាងឆ្នាំ ២00១ និង២00៣ វិសាលភាពនៃការកើនថ្លៃ REER មាន ៧% នៅក្នុងប្រទេសចិន ៣៤% នៅឥណ្ឌូណេស៊ី ១0% នៅម៉ាឡេស៊ី និង ១៥% នៅប្រទេសថៃ។

ការកើនថ្លៃតិចតួចនៃប្រាក់យ៉ាន់នៃប្រទេសចិន នៅពេលមានវត្តមានយ៉ាងច្រើននៃធនបម្រុងជារូបិយប័ណ្ណបរទេស បាននាំឱ្យមានសំណួរថា តើរូបិយប័ណ្ណប្រទេសចិនត្រូវបានឱ្យតម្លៃទាបពេកឬយ៉ាងណា? នៅក្នុងខែកក្កដា ឆ្នាំ ២00៥ ប្រទេសចិនបានបញ្ចប់ការដាក់កំហិតតឹងរ៉ឹង ធៀបនឹងប្រាក់ដុល្លារ។ តម្លៃប្រាក់យ៉ាន់បានកើនឡើងភ្លាមៗក្នុងអត្រា ២.១% ហើយចាប់តាំងពី ខែកុម្ភៈឆ្នាំ ២00៦ បានកើនឡើង (ធៀបនឹងដុល្លារអាមេរិក) ក្នុងអត្រាប្រចាំឆ្នាំ ៤%។ តាមអត្រានេះ រូបិយប័ណ្ណនេះ នឹងឈានដល់កម្រិតជាក់ស្តែង និងនិរន្តរភាព នៅចុងឆ្នាំ ២00៨។

ការសន្សំទុកធនបម្រុងច្រើនឆាប់រហ័សពេក អាចប្រឈមនឹងហានិភ័យមួយចំនួន។ វាបង្កើនបន្ទុកលើសារពើពន្ធក្នុងការបន្សុទ្ធកំណើនដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់សាច់ប្រាក់ ជម្រុញការទិញលក់ដីធ្លី និងអាចធ្វើភាពទន់ខ្សោយនៃប្រព័ន្ធធនាគារកាន់តែធ្ងន់ធ្ងរ។ ផ្ទុយទៅវិញ ការកើនថ្លៃក្នុងកម្រិតលឿន នឹងទប់ស្កាត់កំណើនយ៉ាងឆាប់រហ័ស និងជាបន្តបន្ទាប់នៃធនបម្រុងជារូបិយប័ណ្ណបរទេស ទន្ទឹមនឹងការបញ្ចៀសបញ្ហាធ្លាក់ចុះគំហុកនៃចំនួនការងារ ប្រសិនបើការនាំចេញធ្លាក់ចុះគំហុក។

## ចំណាត់ការកម្រិតពហុភាគី កម្រិតតំបន់ និងទ្វេភាគី

រដ្ឋាភិបាលនានាអាចប្រកាន់យកជម្រើសជាច្រើនខាងសេរីភាវូបនីយកម្មជាឯកតោភាគី។ តាមពិតសេចក្ដីសម្រេចដើម្បីបង្កើន ឬបន្ទាបអត្រាពន្ធ ឬរបាំងពាណិជ្ជកម្មដទៃទៀត គឺជាការសម្រេចរបស់ជាតិ។ ជាក់ស្ដែង ភាគច្រើននៃវិធានការសេរីភាវូបនីយកម្មនៃប្រទេសកំពុងអភិវឌ្ឍន៍ គឺជាលទ្ធផលបានពីចំណាត់ការជាឯកតោភាគី សូម្បីតែស្ថិតនៅក្រោមកិច្ចការពារនិងគាំទ្រពីកម្មវិធីកែទម្រង់រចនាសម្ព័ន្ធដែលនាំមុខដោយ IMF និងដោយស្ថាប័នដទៃទៀតក៏ដោយ។

ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ ភាគច្រើននៃការយកចិត្តទុកដាក់បានប្ដូរទៅបង្កើតទំនាក់ទំនងដែលមានលក្ខណៈឆ្លើយតបគ្នាទៅវិញទៅមក នៅពេលដែលប្រទេសនានាមានការឯកភាពក្នុងក្របខ័ណ្ឌពហុភាគី ឬទ្វេភាគី ដើម្បីកាត់បន្ថយរបាំងពាណិជ្ជកម្មសម្រាប់ជាប្រយោជន៍ដល់គ្នាទៅវិញទៅមក។ វេទិកាពហុភាគីចម្បង១ គឺអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងការចរចាទីក្រុងដូហា ដែលកំពុងតែប្រព្រឹត្តទៅ។ ជាដំបូង មានមូលដ្ឋាននៃសុទិដ្ឋិនិយម ដោយសារប្រទេសជឿនលឿននានា ទំនងជាទទួលស្គាល់នូវតម្រូវការជាក់លាក់របស់ប្រទេសកំពុងអភិវឌ្ឍន៍ និងបានបញ្ចូលប្រការនេះទៅក្នុង "របៀបវារៈអភិវឌ្ឍន៍ ទីក្រុងដូហា"។

ចាប់ពីពេលនោះមក មហិច្ឆិតាទំនងជាត្រូវបានបង្រួមតូចជាច្រើន។ មនុស្សជាច្រើនចាប់អារម្មណ៍ថា WTO ពុំបានផ្ដល់លក្ខខណ្ឌអនុគ្រោះដល់ប្រទេសក្រីក្រដូចដែលបានសន្យានោះទេ។[៤] ជាក់ស្ដែងអង្គការនេះបានដាក់លក្ខខណ្ឌកាន់តែច្រើនបន្ថែមទៀតលើប្រទេសកំពុងអភិវឌ្ឍន៍នានា និងបង្រួមជម្រើសនានារបស់ប្រទេសទាំងនោះក្នុងការឈានទៅសម្រេចគោលបំណងអភិវឌ្ឍន៍មនុស្សរបស់ខ្លួន។

ដោយរបៀបវារៈទីក្រុងដូហា អាចនឹងត្រូវបរាជ័យ ហើយប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបានស្វែងរកជម្រើសផ្សេង។ ក្នុងករណីជាច្រើន ប្រទេសទាំងនោះបានចុះកិច្ចព្រមព្រៀងទ្វេភាគី ជាពិសេសជាមួយប្រទេសជឿនលឿន។ ឧទាហរណ៍ ប្រទេសថៃបានចុះកិច្ចព្រមព្រៀងទ្វេភាគីជាមួយអូស្ត្រាលី ជប៉ុន និងនូវែលហ្សេឡង់ ហើយកំពុងធ្វើការចរចាអស់រយៈពេលដ៏វែងជាមួយសហរដ្ឋអាមេរិក។ ទោះបីកិច្ចព្រមព្រៀងទ្វេភាគីអាចមានឧត្តមភាពលើកិច្ចព្រមព្រៀងពហុភាគីក្ដី តាមទស្សនៈនៃការអភិវឌ្ឍមនុស្ស ការធ្វើបែបនេះអាចពុំមានភាពច្បាស់លាស់ ដោយសារវាច្រើនតែទាមទារឱ្យមានសម្បទានកាន់តែច្រើនថែមទៀត ជាងនៅក្នុងកិច្ចព្រមព្រៀងពហុភាគី ទន្ទឹមនឹងការផ្ដល់លទ្ធភាពប្រើប្រាស់ទីផ្សារកាន់តែទូលាយ។

ទន្ទឹមនឹងនេះ ប្រទេសនានានៅអាស៊ីនិងប៉ាស៊ីហ្វិកបាននឹងកំពុងជម្រុញពាណិជ្ជកម្មរវាងគ្នា តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មកម្រិតតំបន់ (RTAs)។ នេះជាផ្នែកមួយនៃបាតុភាពដែលកើតមានឡើងនៅលើពិភពលោក ដែលប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោកបានចុះកិច្ចព្រមព្រៀងយ៉ាងហោចណាស់នៅក្នុង RTA ណាមួយ (ប្រអប់ ១.៧)។ រវាងឆ្នាំ ១៩៩០ និង ២០០៥ ចំនួនកិច្ចព្រមព្រៀង ដែលបានជូនដំណឹងទៅ GATT/WTO បានកើនឡើងពី ២៧ រហូតដល់ច្រើនជាង ១៨០ ហើយតួលេខនេះទំនងជានឹងកើនឡើងបន្តទៀត។ ទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី (BTAs) និង RTAs ទំនងជាកាន់តែមានសារៈសំខាន់ ដោយសារមូលហេតុមួយចំនួន ៖

**ភាពមិនច្បាស់លាស់នៃក្របខ័ណ្ឌពហុភាគី** ៖ ប្រទេសជាច្រើនកំពុងពិនិត្យជម្រើសផ្សេងពីកិច្ចព្រមព្រៀងពហុភាគី។ កិច្ចព្រមព្រៀងនៅកម្រិតតំបន់ មានភាពងាយស្រួលអនុវត្តជាង ហើយ RTAs និង BTAs ក៏អាចបង្កជាការគំរាមកំហែងផងដែរ

*មនុស្សជាច្រើនចាប់អារម្មណ៍ថា WTO ពុំបានផ្ដល់លក្ខខណ្ឌអនុគ្រោះដល់ប្រទេសក្រីក្រដូចដែលបានសន្យានោះទេ*

ដែលបង្ខំភាគីគ្មានឆន្ទះឱ្យធ្វើការចរចាយ៉ាងប្តូរផ្តាច់នៅកម្រិតពហុភាគី ។

**ឥទ្ធិពលដូមីណូ** : នៅពេលដែល RTA ចាប់ចូលជាធរមាន ប្រទេសជិតខាងដែលមិនមែនជាសមាជិកនឹងត្រូវបានទាក់ទាញឱ្យចូលរួម ដើម្បីជៀសវាងការនៅក្រៅលំហូរពាណិជ្ជកម្ម ។

**លទ្ធភាពប្រើប្រាស់ទីផ្សារសម្រាប់ប្រទេសជឿនលឿន** : ប្រទេសជឿនលឿនកំពុងប្រកួតប្រជែងដណ្តើមទីផ្សារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ សហភាពអឺរ៉ុប គឺជាអ្នកទីមួយក្នុងការធ្វើបែបនេះនិងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយចំនួន ជាមួយប្រទេសនានានៅអឺរ៉ុបខាងកើត តំបន់មេឌីទែរ៉ាណេ អាហ្វ្រិក និងអាស៊ី ។ ឥឡូវនេះសហរដ្ឋអាមេរិកក៏កំពុងពង្រីកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) យ៉ាងឆាប់រហ័សផងដែរ និងបានពង្រឹងជំហររបស់ខ្លួននៅអាស៊ីតាមរយៈកិច្ចព្រមព្រៀងសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក (APEC) ។ ប្រទេសកំពុងអភិវឌ្ឍន៍ក៏កំពុងរួមវិភាគទានចំពោះកិច្ចព្រមព្រៀងនេះដែរ ដោយស្វែងរកដំណោះស្រាយដោយឡែក ជាមួយការប្តេជ្ញាដែលមិនជាទីចូលចិត្ត ឧទាហរណ៍ៈ នៅក្នុង IPRs ដើម្បីទទួលបានមកវិញ នូវការអនុគ្រោះលើផលប្រយោជន៍ពីការនាំចេញក្នុងកម្រិតមួយ ។

**ប្រតិកម្មចំពោះការបង្កើតកិច្ចព្រមព្រៀងតំបន់នៅកន្លែងផ្សេង** : ប្រទេសអាស៊ីដែលជាអ្នកនាំចេញមានការព្រួយបារម្ភថា ពួកគេកាន់តែងាយរងគ្រោះដោយសារការរីកសើងនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មនៅក្នុងតំបន់ផ្សេង ឧទាហរណ៍ នៅ EU ឬតំបន់សេដ្ឋកិច្ចសេរីដែលស្នើរបង្កើតឡើងនៅអាមេរិក ។ ដូច្នេះ ប្រទេសទាំងនោះបានធ្វើការឆ្លើយតបដោយធ្វើសមា-ហរណកម្ម កាន់តែទូលាយឡើងជាមួយតំបន់របស់ខ្លួន ។

**កាលានុវត្តភាពសម្រាប់ការប្តេជ្ញាកាន់តែស៊ីជម្រៅ** : ប្រទេសជឿនលឿននានាអាចប្រើប្រាស់ BTAs ដើម្បីជះឥទ្ធិពលទៅលើប្រទេសជាដៃគូជាងដែលខ្លួនអាចធ្វើបានជាមួយ WTO ។ ហេតុនេះពួកគេអាចធ្វើការជ្រើសរើសដៃគូរបស់ខ្លួន និងថែមទាំងទាមទារឱ្យមានការវិនិយោគ កម្លាំងពលកម្ម ស្តង់ដារខាងបរិស្ថាន និងការប្រកួតប្រជែងកាន់តែ

ប្រអប់ ១.៧

### ភាពប្លែកៗគ្នានៃកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់

អាស្រ័យតាមកម្រិតសមាហរណកម្មរបស់ខ្លួន ទម្រង់ជាមូលដ្ឋាននៃកិច្ចសហប្រតិបត្តិការនៅកម្រិតតំបន់ ដែលឱ្យឈ្មោះថា កិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ (RTAs) អាចចែកចេញជាប្រាំក្រុមគឺ កិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះ (FTAs) សហភាពរួចពន្ធគយ (CUs) ទីផ្សាររួម និងសហភាពសេដ្ឋកិច្ច ។ PTA មួយ គឺជាសហភាពមួយ ដែលនៅក្នុងនោះ ប្រទេសជាសមាជិកបានដាក់របាំងពាណិជ្ជកម្មកម្រិតទាបទៅលើទំនិញដែលផលិតនៅក្នុងសហភាពនោះ ដោយមានភាពបត់បែនមួយចំនួនសម្រាប់សមាជិកនីមួយៗ អំពីវិសាលភាពនៃការកាត់បន្ថយពន្ធនោះ ។ FTA មួយ គឺជាករណីពិសេសនៃ PTA ដែលប្រទេសជាសមាជិក លុបចោលទាំងស្រុងនូវរបាំងពាណិជ្ជកម្ម ( ទាំងរបាំងពន្ធ និងរបាំងដែលមិនទាក់ទងនឹងពន្ធ) ទៅលើទំនិញដែលមានប្រភពពីក្នុងប្រទេសជាសមាជិក ។ គួរបញ្ជាក់នៅទីនេះផងដែរថា ក្នុងករណីភាគច្រើន ប្រទេសនានាពុំលុបចោលរបាំងពាណិជ្ជកម្មទាំងស្រុងនោះឡើយ សូម្បីតែនៅក្នុង FTAs ក៏ដោយ ។ កិច្ចព្រមព្រៀងភាគច្រើនមានការលើកលែងសម្រាប់វិស័យដែលងាយប្រែប្រួល ។

សហភាពរួចពន្ធគយត្រូវបានមើលឃើញថាមានកម្រិតនៃការធ្វើសមាហរណកម្មស៊ីជម្រៅជាង FTA ។ វាខុសពី FTA ត្រង់ប្រទេសនីមួយជាសមាជិកមានសេរីភាពក្នុងការរក្សាទុកកម្រិតពន្ធខុសៗគ្នារៀងខ្លួន សម្រាប់ទំនិញដែលត្រូវបាននាំចូលពីបណ្តាប្រទេសដែលជាសមាជិក ។ នៅក្នុងប្រទេសជាសមាជិក CU ក៏មានប្រើប្រាស់ប្រព័ន្ធតារាងពន្ធរួមពីក្រៅ (CET) ផងដែរ សម្រាប់ទំនិញដែលត្រូវបាននាំចូលពីក្រៅប្រទេសទាំងនេះ ។ CET អាចខុសគ្នាទៅតាមប្រភេទមុខទំនិញ ប៉ុន្តែមិនខុសគ្នាទៅតាមដៃគូនៃសហភាពនេះទេ ។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅ PTAs, FTAs និង CU ត្រូវបានចាត់ទុកថា មានកម្រិតចាត់ថែង "សមាហរណកម្មទាបនៅឡើយ" នៅក្នុងឯកសារស្តីពីពាណិជ្ជកម្ម ។

មានកម្រិតខ្ពស់ជាងផងដែរ ។

អ្នកខ្លះអះអាងថា RTAs បង្កើតជាមូលដ្ឋានសម្រាប់កិច្ចព្រមព្រៀងពហុភាគីនៅពេលខាងមុខ ។ ដោយសារពួកគេអាចចរចាលើ RTAs បានឆាប់រហ័ស កិច្ចព្រមព្រៀងទាំងនេះផ្តល់ឱ្យរដ្ឋាភិបាលនូវកាលានុវត្តភាពសម្រាប់ "ការធ្វើផងរៀនផង" និងត្រួសត្រាយគំនិតថ្មីៗ ដែលអាចនឹងឃើញមាននៅក្នុងកិច្ចព្រមព្រៀងពហុភាគីនៅពេលខាងមុខ ។ អ្នកដទៃទៀតចាត់ទុក RTAs ថាជាឧបសគ្គ ដែលពុំជម្រុញឱ្យមានពាណិជ្ជកម្មជាបន្ថែមឡើយ ប៉ុន្តែ គ្រាន់តែបង្វែរលំហូរដែលមានស្រាប់ ពង្រឹងការចរចារបស់ពពួកអ្នកចង់ការពារ ដែលបន្ទាប់មកនឹងប្រឆាំងក្របខ័ណ្ឌពហុភាគី ។ RTAs ក៏អាចបង្វែរការខិតខំប្រឹងប្រែងរបស់មន្ត្រីនានាដែលព្រួយបារម្ភហួសហេតុ និងដែលមានភារៈត្រូវដោះស្រាយ "ឆ្នាំងបាយ" នៃតារាងពន្ធ និងបទបញ្ញាផ្សេងៗ ដែលមានលក្ខណៈត្រួតគ្នា ។ ទោះជាយ៉ាងណាក្តី ទំនងជាមានការឯកភាពមតិថា ការបង្កើតកិច្ចព្រមព្រៀងកម្រិតតំបន់ និងរបបពហុភាគីអាចជាការបំពេញបន្ថែមរវាងគ្នា ។

ប្រអប់ ១.៨

### កិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ដែលបានបង្កើតឡើង និងដែលទាក់ទងជាមួយប្រទេសនៅអាស៊ី-ប៉ាស៊ីហ្វិក

| RTA | ឈ្មោះ និង ឆ្នាំចូលជាធរមាន | ប្រទេសជាសមាជិក |
|---|---|---|
| AFTA | តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (១៩៩៣) | ប្រ៊ុយណេ កម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី ភូមា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម |
| SAFTA | តំបន់ពាណិជ្ជកម្មសេរីអាស៊ីខាងត្បូង (២០០៦) | បង់ក្លាដេស ប៊ូតាណ ឥណ្ឌា ម៉ាល់ឌីវ ណេប៉ាល់ ប៉ាគីស្ថាន និងស្រីលង្កា |
| PICTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មប្រទេសជាកោះនៅប៉ាស៊ីហ្វិក (២០០១) | កោះឃុក ហ្វីជី គីរីបាទី ណោរូ នីអ៊ូ ប៉ាពួញូហ្គីណេ សាម៉ាវ កោះសូឡូម៉ុង តុងហ្គា ទូវ៉ាលូ និងវ៉ានូអាទូ |

**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (AFTA)** : កិច្ចព្រមព្រៀងនេះ ព្យាយាមកាត់បន្ថយអត្រាពន្ធនៅក្នុងតំបន់លើគ្រប់មុខទំនិញកម្មន្តសាលពីបណ្តាប្រទេសអាស៊ានមកត្រឹម ៥% ឬទាបជាងនេះ និងដើម្បីលុបចោលរាល់ការដាក់កំហិតលើបរិមាណ និងរបាំងមិនមែនពន្ធ ។ ការធ្វើបែបនេះបានពង្រឹងពាណិជ្ជកម្មនៅក្នុងអាស៊ាន ជាពិសេសនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ។ រវាងឆ្នាំ ១៩៩០ និង១៩៩៥ សម្រាប់ប្រទេសជាសមាជិក ភាគចំណែកនៃការនាំចេញរបស់ពួកគេទៅបណ្តាប្រទេស ASEAN-១០ បានកើនឡើងពី ២០% ទៅជិតដល់ ២៦% ទោះបីពេលក្រោយវិបត្តិនៅអាស៊ី អត្រានេះបានថយចុះមកត្រឹម ២៤% នៅឆ្នាំ ២០០២ ក៏ដោយ ។

**តំបន់ពាណិជ្ជកម្មសេរីអាស៊ីខាងត្បូង (SAFTA)** : កិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់បានវិវត្តយ៉ាងយឺត ។ កិច្ចការនេះពុំមានការរីកចម្រើនឡើយ រហូតដល់ឆ្នាំ ២០០៥ នៅពេលដែលរដ្ឋមន្ត្រីនានាបានឯកភាពលើការចាត់ចែងពាណិជ្ជកម្មអនុគ្រោះ SAARC (SAPTA) ។ កិច្ចព្រមព្រៀងនេះ មានដាក់កំហិត និងបានផ្តល់សម្បទានតិចតួចប៉ុណ្ណោះ ដូច្នេះនៅឆ្នាំ ២០០១ ពាណិជ្ជកម្មក្នុងតំបន់នេះមានត្រឹមតិចជាង ៥% នៃពាណិជ្ជកម្មសរុបរបស់ប្រទេសជាសមាជិកទាំងអស់ ។ នៅក្នុងខែមករា ឆ្នាំ ២០០៦ SAPTA ត្រូវបានជំនួសដោយតំបន់ពាណិជ្ជកម្មសេរីអាស៊ីខាងត្បូង (SAFTA) ។ កម្មវិធីសេរីភាវូបនីយកម្ម SAFTA បានអំពាវនាវឱ្យមានការកាត់បន្ថយពន្ធលើការនាំចូលមកត្រឹម ២០% នៅឆ្នាំ ២០០៦ និង ឱ្យដល់ ០-៥% នៅឆ្នាំ ២០១៣ ឬ ២០១៥ សម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិចតួច ។ យន្តការនេះក៏នៅតែមានកម្រិតកំណត់ ហើយអាចមិនមានអ្វីផ្តល់ឱ្យបានច្រើនជាង WTO ឡើយ ។

**កិច្ចព្រមព្រៀងពាណិជ្ជកម្មប្រទេសជាកោះនៅប៉ាស៊ីហ្វិក (PICTA)** : នេះជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលគួរតែនាំទៅរកការបង្កើតតំបន់ពាណិជ្ជកម្មសេរី ។ ក្នុងរយៈពេលពី ១០ ទៅ ១២ឆ្នាំ ក្រោយពេលចូលជាធរមាន នៅឆ្នាំ ២០០១ PICTA បានប្រមើលមើលអត្រាពន្ធលើគ្រប់ "មុខទំនិញដើម" ឱ្យធ្លាក់ចុះដល់សូន្យ ដោយមានការផ្តល់សម្បទានកាន់តែរហ័សសម្រាប់ប្រទេសធំជាងគេចំនួនពីរគឺ ប៉ាពួញូហ្គីណេ និងហ្វីជី ។ PICTA គួរតែនាំមកនូវអត្ថប្រយោជន៍មួយចំនួន ដោយបង្កើតទីផ្សារដែលមានប្រជាជនប្រមាណ ៧លាននាក់ និងបើកឱ្យមានសេដ្ឋកិច្ចទ្រង់ទ្រាយធំ ព្រមទាំងលើកទឹកចិត្តឱ្យមានការវិនិយោគផងដែរ ។

*ទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងកិច្ចព្រមព្រៀងពាណិជ្ជកម្មប្រចាំតំបន់ ទំនងជាកាន់តែមានសារៈសំខាន់។ ទោះជាយ៉ាងណាក្តី ទំនងជាមានការឯកភាពមតិថា ការបង្កើតកិច្ចព្រមព្រៀងកម្រិតតំបន់ និងរបបពហុភាគីអាចជាការបំពេញបន្ថែមរវាងគ្នា*

អង្គការថ្នាក់តំបន់នានានៅក្នុងតំបន់មួយ ដែលមានវិសាលភាពធំទូលាយ និងចម្រុះ ដូចជាតំបន់អាស៊ីប៉ាស៊ីហ្វិក ទំនងជាផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងអនុតំបន់។ កិច្ចព្រមព្រៀងទាំងនោះរួមមាន តំបន់សេដ្ឋកិច្ចសេរីអាស៊ាន (AFTA) តំបន់សេដ្ឋកិច្ចសេរីអាស៊ីខាងត្បូង (SAFTA) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មនៃបណ្តាប្រទេសជាកោះនៅសមុទ្រប៉ាស៊ីហ្វិក (PICTA) (ប្រអប់ ១.៨)។

## ភាពចាំបាច់នៃការអភិវឌ្ឍមនុស្ស

ប្រទេសជាច្រើននៅក្នុងតំបន់នេះ បានពាក់ព័ន្ធយ៉ាងជ្រៅទៅនឹងបញ្ហាពាណិជ្ជកម្ម។ ប៉ុន្តែជាញឹកញាប់ ការពិភាក្សាច្រើនទាក់ទងតែនឹងបញ្ហាសេដ្ឋកិច្ចប៉ុណ្ណោះ។ ផ្ទុយទៅវិញ ប្រទេសនានាក្នុងតំបន់នេះចាំបាច់ត្រូវពិចារណាអំពីពាណិជ្ជកម្មតាមរយៈចក្ខុវិស័យទូលំទូលាយអំពីការអភិវឌ្ឍមនុស្ស។ រាល់ការសម្រេចអំពីពាណិជ្ជកម្ម ត្រូវតែមានការពិចារណា មិនត្រឹមតែអំពីលក្ខណៈវិនិច្ឆ័យខាងសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែពិនិត្យមើលអំពីឥទ្ធិពលលើការអភិវឌ្ឍមនុស្សផងដែរ ដើម្បីលើកកម្ពស់ការរស់នៅរបស់ប្រជាពលរដ្ឋ និងពង្រីកជម្រើសរបស់ពួកគាត់។ សំណួរដ៏មានប្រយោជន៍មួយចំនួន មានដូចជា ៖

តើផលចំណេញមាន*និរន្តរភាព*ដែរឬទេ? ទាក់ទងនឹងឥទ្ធិពលទៅលើបរិស្ថាន ឧទាហរណ៍ តើពាណិជ្ជកម្មបង្កើនសម្ពាធសម្រាប់ការលក់ដូរកសិផល និងផលនេសាទកម្រិតណា? តើការធ្វើបែបនេះ នាំឱ្យមានការធ្វើដំណាំប្រពលវប្បកម្ម ឬឯកវប្បកម្ម? បើនិយាយឱ្យបានទូលាយជាងនេះ គេអាចសួរថា តើផលចំណេញនេះអាចរក្សានិរន្តរភាពសម្រាប់រយៈពេលវែងបានក្នុងកម្រិតណា ឧទាហរណ៍ ទាក់ទងនឹងការផ្លាស់ប្តូរបច្ចេកវិទ្យា ឧត្តមភាពនៃការប្រកួតប្រជែងដែលមានលក្ខណៈប្រែប្រួល ឬការពិចារណាសម្រាប់ផលប្រយោជន៍របស់មនុស្សឆ្លងកាត់ជំនាន់។

តើផលចំណេញមាន*សមធម៌*ដែរឬទេ? តើអ្នកខ្លះមានកាលានុវត្តភាពច្រើនជាងអ្នកដទៃដែរឬទេ? តើក្រុមណាទទួលផលច្រើនជាងគេ? តើមានអ្នកចាញ់ដែរឬទេ ហើយប្រសិនបើមាន តើស្ថានភាពអ្នកទាំងនេះកាន់តែធ្លាក់ចុះឬយ៉ាងណា? តើពាណិជ្ជកម្មរួមចំណែកក្នុងការកាត់បន្ថយ ឬពង្រីកវិសមភាពដែរឬទេ? តើប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសដែលប្រឈមភាពងាយរងគ្រោះដែលទាក់ទងនឹងពាណិជ្ជកម្មរីកចម្រើនបែបណាដែរ? នៅពេលដែលប្រជាពលរដ្ឋ និងប្រទេសនានាស្ថិតនៅដំណាក់កាលខុសគ្នានៃការចាប់ផ្តើមចូលរួមនៅក្នុងពាណិជ្ជកម្ម តើអ្នកមានទទួលប្រយោជន៍ច្រើនជាងគេឬយ៉ាងណា? តើគោលនយោបាយនិងស្ថាប័ន ត្រូវតែ "វិសមភាព" ទើបអាចជម្រុញសមធម៌ ឧទាហរណ៍ តាមរយៈមាត្រាដែលចែងឱ្យមានការយកចិត្តទុកដាក់ពិសេស និងខុសគ្នាដែរឬយ៉ាងណា?

តើឥទ្ធិពលរបស់វានាំឱ្យមានការ*ផ្ទេរអំណាច*ដែរឬទេ? តើ "ស្ថាប័ន" របស់ក្រុមខ្លះកាន់តែទន់ខ្សោយ ឬកាន់តែត្រូវបានពង្រឹង? តើប្រជាជនអាចរស់នៅដោយថ្លៃថ្នូរនិងពង្រឹងអំណាចក្នុងការរស់នៅដែរឬទេ ឧបមាថា តាមរយៈកាលានុវត្តភាពការងារថ្មី ឬការងារកាន់តែប្រសើរឡើង ឧទាហរណ៍៖ តាមរយៈដំណើរការជំនួញនៅក្រៅប្រទេស? តើពាណិជ្ជកម្មដោយបើកចំហជាងមុន ធ្វើឱ្យបាត់បង់ការងារក្នុងកម្រិតណា ឧបមាសម្រាប់កសិករ ឬកម្មកររោងចក្រកាត់ដេរនៅអាស៊ី? តើគំនិត និងបទពិសោធថ្មី បានផ្តល់អំណាចដែរឬទេ?

តើមាន*ផលិតភាព*ជាក់ស្តែងដែរឬទេ? តើការផ្លាស់ប្តូរទំនិញ សេវា លុយ និងគំនិត រួមចំណែកកែលំអបច្ចេកវិទ្យាដែរឬទេ? តើប្រការនេះកើតឡើងច្រើននៅក្នុងវិស័យដែលទទួលផលចំណេញស្រាប់ហើយឬអ្វី បើប្រៀបធៀបនឹងវិស័យ

ដែលប្រើប្រាស់កម្លាំងពលកម្មដែលគ្មានជំនាញ? តើប្រាក់ចំណូលនៅក្នុងដៃរបស់ប្រជាជននាំមកនូវសុខភាពប្រសើរជាងមុន ពុំសូវអវត្តមានពីការងារ ឬពុំសូវឈប់សម្រាកដែរឬទេ? តើប្រជាជនធ្វើការវិនិយោគច្រើនជាងមុនទៅលើការអប់រំដែរឬទេនៅពេលដែលគេមើលឃើញថាវាផ្តល់ប្រយោជន៍? តើជម្រើសនៃការអប់រំ ទទួលឥទ្ធិពលពីកាលានុវត្តភាពទីផ្សារដែរឬទេ?

*និរន្តរភាព-សមធម៌-ការផ្ទេរអំណាច-ផលិតភាព* តើការអភិវឌ្ឍមនុស្ស "SEEP" ធ្វើឡើងដល់ចំណោមមនុស្សស្រទាប់ក្រោមដែរឬទេ? មានប្រការដែលត្រូវធ្វើសម្បទានផងដែររវាងផលិតភាព ឧទាហរណ៍ ជាមួយសមធម៌។ ទោះបីកត្តាទាំងនេះមិនគ្រោបគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍមនុស្សក្តី វាជួយជាឧបករណ៍ដើម្បីវាយតម្លៃពាណិជ្ជកម្មអន្តរជាតិអំពីលក្ខខណ្ឌមនុស្ស។

នៅក្នុងកាលៈទេសៈទាំងនេះ ទីផ្សារតែឯងមិនអាចផ្តល់នូវរបបពាណិជ្ជកម្មដែលលើកកម្ពស់ការអភិវឌ្ឍមនុស្សបានទេ។ រដ្ឋចាំបាច់ត្រូវផ្តល់ដំណឹង ការណែនាំ និងកិច្ចការពារ។ ប៉ុន្តែ ប្រការនេះមិនមែនត្រឹមតែទាក់ទងជាមួយក្រសួងពាណិជ្ជកម្ម ឬជំនួញប៉ុណ្ណោះនោះទេ។ ពាណិជ្ជកម្មគួរតែទទួលបាននូវការយកចិត្តទុកដាក់ឱ្យជិតដល់ពីសំណាក់នាយកដ្ឋាននានារបស់រដ្ឋាភិបាល។ ទីមួយ ដោយសារពាណិជ្ជកម្មដែលផ្តល់ផលចំណេញច្រើន នឹងទាមទារភាពរឹងមាំខាងសមត្ថភាពមនុស្ស ដូច្នេះត្រូវមានការចូលរួមពីសំណាក់ក្រសួងកិច្ចការសង្គម ដូចជាក្រសួងសុខាភិបាល និងក្រសួងអប់រំ។ ទីពីរ ដោយសារផលវិបាកនៃពាណិជ្ជកម្មដែលមានលក្ខណៈសេរីជាង ត្រូវបានចាប់អារម្មណ៍ថាកើតមាននៅគ្រប់វិស័យ ហើយទាមទារឱ្យមានអន្តរាគមន៍ពីសំណាក់ក្រសួងខុសៗគ្នា អាចជាការផ្តល់បណ្តាញសុវត្ថិភាពសម្រាប់អ្នកដែលបានបាត់បង់របរចិញ្ចឹមជីវិតឬក្នុងការកែប្រែប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល ដើម្បីបំពេញតម្រូវការនៃវចនាសម្ព័ន្ធថ្មីសម្រាប់សេដ្ឋកិច្ច។

ទទ្ទឹមនឹងនេះ រដ្ឋត្រូវប្រមូលផ្តុំការគាំទ្រសាធារណៈទូលំទូលាយពីទាំងវិស័យឯកជននិងសង្គមស៊ីវិល។ រដ្ឋាភិបាលត្រូវកសាងភាពរឹងមាំនៃការឯកភាពមតិសម្រាប់ធ្វើកំណែទម្រង់ពាណិជ្ជកម្ម។ បុគ្គល និងអង្គការជាច្រើន ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ កាន់តែបានដឹងច្បាស់អំពីឥទ្ធិពលនៃរបបពាណិជ្ជកម្មបែបថ្មី ហើយប្រឆាំងវិធានការដែលមិនផ្តល់ផលចំណេញដល់អ្នកក្រីក្រ។

## ទម្រង់នៃរបាយការណ៍នេះ

ជំពូកខាងក្រោយនៅក្នុងរបាយការណ៍នេះពិនិត្យមើលយ៉ាងល្អិតនូវកត្តាទាំងនេះនិងបញ្ហាពាក់ព័ន្ធ ដោយសង្កេតមើលភស្តុតាង និងធ្វើអត្តសញ្ញាណប្រភេទគោលនយោបាយដែលលើកកម្ពស់ទំនាក់ទំនងវិជ្ជមានរវាងពាណិជ្ជកម្ម និងការអភិវឌ្ឍមនុស្ស ទទ្ទឹមនឹងផ្តល់កិច្ចការពារដល់អ្នកដែលអាចនឹងត្រូវខូចខាតដោយសារការរំខានបណ្តាលពីរបបពាណិជ្ជកម្មបែបថ្មី។

**ជំពូកពីរ** ៖ ជំពូកនេះពិនិត្យមើលភស្តុតាងរយៈពេល ២០ ឆ្នាំ នៃសេរីភាវូបនីយកម្មជំនួញ ដូចជាផលប៉ះពាល់របស់វាទៅលើកំណើនសេដ្ឋកិច្ច និងដោយឡែកអំពីថាតើវាមានឥទ្ធិពលបែបណាទៅលើការអភិវឌ្ឍមនុស្ស តាមរយៈការបង្កើតការងារ។

**ជំពូកបី** ៖ កសិកម្មរួមវិភាគទានជាសមាមាត្រខ្ពស់បំផុតនៃចំនួនការងារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍និងជាវិស័យមួយក្នុងចំណោមវិស័យដែលមានភាពចម្រូងចម្រាស់ជាងគេនៅក្នុងការចរចាពាណិជ្ជកម្មពហុភាគី។ ជំពូកនេះពិនិត្យមើលផលប៉ះពាល់នៃការពង្រីកពាណិជ្ជកម្មអន្តរជាតិលើកសិផល ទៅលើភាពក្រីក្រ និងវិះរកគោលនយោបាយ ដែល

អាចយកមកប្រើប្រាស់ ដើម្បីធានាថាពាណិជ្ជកម្មបែបនេះជម្រុញគោលដៅអភិវឌ្ឍមនុស្ស។

**ជំពូកបួន** : វិស័យមួយផ្សេងទៀតដែលផ្តល់ប្រយោជន៍ដោយផ្ទាល់សម្រាប់ជនក្រីក្រគឺវាយនភណ្ឌ និងសម្លៀកបំពាក់។ ជំពូកនេះពិនិត្យមើលថាតើការលុបចោលកូតាមានឥទ្ធិពលបែបណាចំពោះប្រទេសក្រីក្រជាងគេ ដែលជាអ្នកនាំចេញ ដូចជា ប្រទេសបង់ក្លាដេស និង កម្ពុជា។

**ជំពូកប្រាំ** : ជំពូកនេះពិនិត្យមើលពាណិជ្ជកម្មខាងផ្នែកសេវា និងជាពិសេសទាក់ទងនឹងចំណាកស្រុករបស់កម្មករឆ្លងកាត់ប្រទេស ការធ្វើលទ្ធកម្មសេវាពីក្រៅឱ្យធ្វើការតាមប្រព័ន្ធអេឡិចត្រូនិក និងលំហូរទេសចរអន្តរជាតិ។ ជំពូកនេះ ក៏ពិនិត្យមើលផងដែរអំពីសក្តានុពលនៃសកម្មភាពទាំងនេះ និងចំណាត់ការដែលរដ្ឋាភិបាលអាចធ្វើបានដើម្បីធានាថា ពួកគេអាចបំពេញការសន្យារបស់ខ្លួនបានល្អបំផុត។

**ជំពូកប្រាំមួយ** : ការពង្រីកពាណិជ្ជកម្មអន្តរជាតិយ៉ាងឆាប់រហ័ស មានឥទ្ធិពលទៅលើប្រទេសទាំងអស់នៅក្នុងតំបន់ ប៉ុន្តែ កង្វល់ខ្លះក្នុងចំណោមកង្វល់ធំបំផុតគឺសម្រាប់ប្រទេសអភិវឌ្ឍតិចតួចជាងគេ។ ជំពូកនេះពិចារណាអំពីមាគ៌ាប្រសើរបំផុតសម្រាប់ប្រទេសទាំងនោះ ដើម្បីធ្វើសមាហរណកម្មពាណិជ្ជកម្ម។

**ជំពូកប្រាំពីរ** : ជំពូកចុងក្រោយនេះបង្ហាញជូននូវរបៀបវារៈប្រាំបីចំណុចដែលប្រទេសកំពុងអភិវឌ្ឍន៍អាចពិចារណា ដើម្បីប្រើប្រាស់សមាហរណកម្មពាណិជ្ជកម្មក្នុងការសម្រេចឱ្យបាននូវការរីកចម្រើនលើការអភិវឌ្ឍមនុស្ស។

# 2



## ជំពូក ២

# ពាណិជ្ជកម្ម និង ការអភិវឌ្ឍមនុស្ស បទពិសោធនៅអាស៊ី-ប៉ាស៊ីហ្វិក

សកលភាវូបនីយកម្ម កំពុងនាំទៅរកការពង្រីកយ៉ាងឆាប់រហ័សនូវពាណិជ្ជកម្មអន្តរជាតិ និងជាមធ្យោបាយមួយក្នុងចំណោមគ្រឿងយន្តនៃកំណើនសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ យន្តការនេះបានជួយជម្រុញកំណើនសេដ្ឋកិច្ច និងផ្ដល់ការងារសម្រាប់ប្រជាពលរដ្ឋជាច្រើនលាននាក់ ប៉ុន្តែការសាកល្បងពិតប្រាកដតែមួយ អំពីជោគជ័យ ឬបរាជ័យ គឺផលប៉ះពាល់របស់វាទៅលើការអភិវឌ្ឍមនុស្ស។ ជំពូកនេះធ្វើអត្ថសញ្ញាណនិន្នាការចម្បងៗនៅក្នុងពាណិជ្ជកម្មអន្តរជាតិ និងពិនិត្យមើលថា តើវាមានន័យអ្វីខ្លះសម្រាប់ប្រជាពលរដ្ឋខ្លះដែលក្រីក្រជាងគេនៅក្នុងតំបន់នេះ។

នៅក្នុងទសវត្សរ៍ថ្មីៗនេះ អាស៊ី-ប៉ាស៊ីហ្វិកគឺជាតំបន់ដែលមានការរីកចម្រើនឆាប់រហ័សជាងគេបង្អស់នៅលើពិភពលោក។ នៅក្នុងអំឡុងឆ្នាំ ១៩៩០-២០០៣ ផលទុនក្នុងស្រុកសរុប (GDP) បានកើនឡើងជាមធ្យមច្រើនជាង ៧% ក្នុងមួយឆ្នាំ។ ដោយសារកំណើនចំនួនប្រជាជន ការកើនឡើងនៃអត្រា GDP ក្នុងមនុស្សម្នាក់ៗមានកម្រិតទាបជាង ពោលគឺត្រឹម ៥% ប៉ុន្តែនៅតែខ្ពស់ជាងយ៉ាងខ្លាំងធៀបនឹងកំណើននៅបណ្ដាប្រទេស OECD ដែលមានត្រឹមតែ ៣%។

## និន្នាការនៃពាណិជ្ជកម្មអន្តរជាតិ

ភាគច្រើននៃកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សនេះបានកើតឡើង នៅក្នុងអំឡុងពេលនៃស្ថិរភាពសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដែលជាដំបូងបានបម្លែងកូតានាំចេញទៅជាអត្រាពន្ធ ហើយបន្ទាប់មកបញ្ចូលអត្រាពន្ធគយចូលគ្នាឱ្យមានចំនួនតិចជាងមុន។ ទន្ទឹមនឹងនេះ ប្រទេសជាច្រើននៅក្នុងតំបន់នេះបានកាត់បន្ថយ ឬលុបចោលនូវ ឧបត្ថម្ភធន និងពន្ធលើការនាំចេញ។

នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក សេរីភាវូបនីយកម្មបានចាប់ផ្ដើមនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ លុះដល់ឆ្នាំ ១៩៩០ អត្រាមធ្យមនៃពន្ធនាំចូលនៅក្នុងប្រទេសទាំងនេះ បានចុះមកនៅត្រឹម ២០% ហើយមកដល់ឆ្នាំ ២០០០ បានចុះរហូតដល់ ៨% (រូបទី ២.១)។ ឧទាហរណ៍ នៅប្រទេសម៉ាឡេស៊ី ភាគច្រើននៃទំនិញអាចនាំចូលដោយគ្មានបង់ពន្ធ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងបណ្ដាប្រទេសកោះនៅប៉ាស៊ីហ្វិក អត្រានេះនៅខ្ពស់នៅឡើយ (តារាង ២.២)។

តារាង ២.១

ស្ថានភាពនៃកំណើនប្រចាំតំបន់

| | កំណើន GDP (មធ្យមប្រចាំឆ្នាំ %) | | GDP ក្នុងម្នាក់ៗ (អត្រាកំណើនប្រចាំឆ្នាំ %) |
|---|---|---|---|
| | ១៩៨០-១៩៩០ | ១៩៩០-២០០៣ | ១៩៩០-២០០២ |
| អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក | ៧.៩០ | ៧.៦០ | ៥.៤ |
| អាស៊ីខាងត្បូង | ៥.៥០ | ៥.៤០ | ៣.២ |
| អឺរ៉ុប និងអាស៊ីកណ្ដាល | .. | ០.៦០ | -០.៩ |
| អាមេរិកឡាទីន និងការ៉ាអ៊ីប | ១.៥០ | ២.៧០ | ១.៣ |
| មជ្ឈឹមបូព៌ានិងអាហ្វ្រិកខាងជើង | ១.៣០ | ៣.២០ | .. |
| អនុតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិក | ១.៧០ | ២.៨០ | .. |

**ប្រភព: ធនាគារពិភពលោក ២០០៥; IMF ២០០៤។**

*នៅក្នុងទសវត្សរ៍ថ្មីៗនេះ អាស៊ី-ប៉ាស៊ីហ្វិក គឺជាតំបន់ដែលមានការរីកចម្រើនឆាប់រហ័សជាងគេបង្អស់នៅលើពិភពលោក*

សេរីភាវូបនីយកម្មនៅអាស៊ីខាងត្បូងបានប្រព្រឹត្តទៅយឺតនៅឡើយ។ នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ពន្ធនាំចូលជាមធ្យមមាន ៦០% ហើយចុះមកនៅត្រឹមប្រមាណ ៤៧% នៅចុងទសវត្សរ៍នោះ។ ប៉ុន្តែនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ ពន្ធនេះបានធ្លាក់ចុះយ៉ាងឆាប់រហ័ស ហើយនៅឆ្នាំ ២០០០ ពន្ធជាមធ្យមនៅអាស៊ីខាងត្បូងបានថយមកត្រឹម ១៨% និងបានបន្តកាត់បន្ថយទៅទៀតនៅស្រីលង្កា។ លើកលែងតែប្រទេសឥណ្ឌាអត្រាពន្ធបានថយចុះសម្រាប់ផលិតផលបឋមជាងសម្រាប់ផលិតផលកម្មន្តសាល ហើយក្នុងចំណោមផលិតផលកម្មន្តសាលអត្រាពន្ធនេះត្រូវបានបញ្ចុះជាបន្ថែម សម្រាប់ទំនិញជាផលពាក់កណ្តាលសម្រេចជាងផលិតផលសម្រេច។

## កំណើនយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្ម

*ការកាត់បន្ថយអត្រាពន្ធ បានរួមចំណែកនាំឱ្យមានកំណើនយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្ម*

ការកាត់បន្ថយអត្រាពន្ធ បានរួមចំណែកនាំឱ្យមានកំណើនយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្ម។ ភស្តុតាងបង្ហាញថា ភាគចំណែក ពីអាស៊ី-ប៉ាស៊ីហ្វិកនៅក្នុងពាណិជ្ជកម្មពិភព លោកបានកើនឡើងជិតពីរដងនៅក្នុងអំឡុងឆ្នាំ ១៩៩០-២០០៣។ ការចូលរួមពីអនុតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិក មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងត្បូង ទៅក្នុងពាណិជ្ជកម្មអន្តរជាតិ បានថយចុះយ៉ាងខ្លាំងនៅក្នុងពីរទសវត្សរ៍ចុងក្រោយនេះ រីឯភាគចំណែកពីអាមេរិកឡាទីន បានថយចុះនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ប៉ុន្តែបានស្តារឡើងវិញនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ហើយក៏ធ្លាក់ចុះវិញនៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ។ បាតុភូតនេះបានឆ្លុះបញ្ចាំងថា ទាំងការនាំចូល និងនាំចេញពីតំបន់អាស៊ី-ប៉ាស៊ីហ្វិក កំពុងកើនឡើងតាមអត្រាយ៉ាងលឿនជាងពីតំបន់ផ្សេងៗទៀតនៅលើពិភពលោក ហើយបានបង្ហាញពីជោគជ័យនៃបណ្តាប្រទេសនៅអាស៊ីនៅក្នុងពាណិជ្ជកម្មអន្តរជាតិ នៅក្រោយសេរីភាវូបនីយកម្ម។[១]

នៅក្នុងអំឡុងនៃដំណាក់កាលដើមដំបូង ការនាំចេញពីអាស៊ីបូព៌ា និងប៉ាស៊ីហ្វិកបានកើនឡើងរហ័សជាងពីអាស៊ីខាងត្បូង។ ជាក់ស្តែង នៅមុន និងនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ ការលូតលាស់បែបនេះមានតែក្នុងចំណោមបណ្តាសេដ្ឋកិច្ចឧស្សាហកម្មថ្មីនៅក្នុងលំដាប់ទីមួយ និងលំដាប់ទីពីរតែប៉ុណ្ណោះ (NIEs)។ ជាលទ្ធផលនៃរយៈពេលពីរទសវត្សរ៍ដែលមានកំណើនខ្ពស់ នៅឆ្នាំ ២០០៣ តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បានឃើញកំណើនអនុភាពរបស់ខ្លួនរហូតដល់ ២ លានលានដុល្លារ ច្រើនជាងកំណើនដូចគ្នានេះនៅអាមេរិកឡាទីន និងតំបន់ការ៉ាអ៊ីបទៅទៀត។ ម្យ៉ាងវិញទៀត អាស៊ីខាងត្បូងដែលមានអត្រាកំណើន GDP ក្នុងលំដាប់ទីពីរ មានអនុបាតពាណិជ្ជកម្ម GDP ក្នុងកម្រិតទាបជាងយ៉ាងច្រើន ដែលបង្ហាញថា កំណើនបានកើតឡើងដោយមានការចូលរួមកម្រិតទាបទៅក្នុងពាណិជ្ជកម្ម។

ប៉ុន្តែនិន្នាការនេះបានផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ដែលមានសញ្ញាកំណើនដែលមានភាពបែកខ្ញែកនៅទូទាំងតំបន់។ នៅរវាងឆ្នាំ ១៩៩០ និងឆ្នាំ ២០០៣ នៅពេលដែលអាស៊ីបូព៌ានិងប៉ាស៊ីហ្វិក បានបន្តឈានមុខជាលំដាប់ ហើយពាណិជ្ជកម្មគិតជាភាគរយនៃ GDP បានកើនឡើង ពី ៤៥ ទៅ ៨១% ឯសមាមាត្រសម្រាប់អាស៊ីខាងត្បូង ក៏កើនឡើងផងដែរពី ២០ ទៅ ៣៤% ដែរ។[២] តួលេខទាំងនេះ ទាក់ទងតែ




រូបទី ២.១ : អត្រាពន្ធលើទំនិញនាំចូល ឆ្នាំ ១៩៨០-២០០០

ប្រភព : ធនាគារពិភពលោក ២០០៥

ជាមួយពាណិជ្ជកម្មទំនិញតែប៉ុណ្ណោះ។ ប្រសិនបើចំណូលបានពីសេវាផ្ញើប្រាក់ ទេសចរណ៍ និងប្រភពផ្សេងទៀត ត្រូវបានរាប់បញ្ចូល ភាពខុសគ្នារវាងអនុតំបន់ទាំងពីរមានកម្រិតទាបជាង ហើយកំណើនសរុបនឹងមានភាពអស្ចារ្យជាងនេះទៅទៀត។ អាស៊ីកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័សក្នុងនាមជារោងចក្រសម្រាប់ពិភពលោក (ប្រអប់ ២.១)។

ការនាំចូលក៏មានកំណើនឡើងផងដែរ។ ជាក់ស្តែងនៅក្នុងអំឡុងឆ្នាំ១៩៨៥-១៩៩៥ អត្រាកំណើនប្រចាំឆ្នាំនៃបរិមាណទំនិញនាំចូលមានច្រើនជាងបរិមាណនាំចេញ រហូតដល់ ១០.៥% ប៉ុន្តែថយចុះទៅវិញនៅចុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ មកត្រឹមតែ ៥.៥% ប៉ុណ្ណោះ។ ជាលទ្ធផល តាមទស្សនៈសកល ភាគរយនៃការនាំចូលក្នុងតំបន់នេះបានកើនឡើងពី

ប្រអប់ ២.១

## អាស៊ី - រោងចក្រថ្មីរបស់ពិភពលោក

តំបន់អាស៊ី-ប៉ាស៊ីហ្វិកបានបង្កើនការនាំចេញរបស់ខ្លួនប្រកបដោយស្ថិរភាពនូវទំនិញកម្មសាល។ ឥឡូវតំបន់នេះរួមចំណែកប្រមាណ ៣០% នៃការនាំចេញលើពិភពលោក ហើយនៅរយៈពេលដប់ឆ្នាំខាងមុខ អាចកើនឡើងដល់ ៥០%។ ក្នុងចំណោមតួលេខនេះ ៩៧% បានមកពីអាស៊ី-បូព៌ា។ ឥឡូវនេះ អាស៊ីបានរួមចំណែក ៥៥% នៃពាណិជ្ជកម្មពិភពលោកលើបរិក្ខារការិយាល័យ និងទូរគមនាគមន៍ ៤៥% លើវាយនភណ្ឌ ៤៧% លើសម្លៀកបំពាក់ និង ៣៥% លើសម្ភារៈប្រើប្រាស់របស់បុគ្គល និងគ្រួសារ។ ក្រុមទំនិញនាំចេញច្រើនជាងគេតែមួយគត់គឺ បរិក្ខារការិយាល័យ និងទូរគមនាគមន៍ ដែលក៏ជាក្រុមផលិតផល ដែលកើនរហ័សជាងគេនៅក្នុងពាណិជ្ជកម្មអន្តរជាតិផងដែរ។

**ភាគរយនៃការនាំចេញផលិតផលកម្មន្តសាលពីអាស៊ីនៅទូទាំងពិភពលោក**

| | %នៃផលិតផលនាំចេញពិភពលោក | អត្រាកំនើនទីផ្សារពិភពលោក | ភាគចំណែកពីអាស៊ី |
|---|---|---|---|
| | ២០០៤ | ១៩៩០-២០០៤ | ២០០៤ |
| ដែក និងដែកថែប | ៤ | ៦ | ២៥ |
| សារធាតុគីមី | ១៥ | ១០ | ១៧ |
| បរិក្ខារការិយាល័យនិងទូរគមនាគមន៍ | ១៧ | ១១ | ៥៥ |
| បរិក្ខារសម្រាប់ការដឹកជញ្ជូន | ១៨ | ៧ | ២១ |
| វាយនភណ្ឌ | ៣ | ៤ | ៤៥ |
| សម្លៀកបំពាក់ | ៤ | ៧ | ៤៧ |
| គ្រឿងយន្តផ្សេងទៀត | ៦ | ៨ | ២៧ |
| សម្ភារៈបុគ្គលនិងគ្រួសារ | ៣ | ៩ | ៣៥ |
| បរិក្ខារវិទ្យាសាស្ត្រ និងវង្វាស់ | ៣ | ១២ | ៣០ |
| ទំនិញផ្សេងទៀត | ១៧ | ៩ | ២៦ |
| សរុប | ១០០ | ៨ | ៣០ |

សម្គាល់: រួមទាំងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍នៅអាស៊ី បន្ថែមប្រទេសជប៉ុន អូស្ត្រាលី និង នូវែលហ្សេឡង់

**ប្រភព: អង្គការពាណិជ្ជកម្មពិភពលោក ២០០៥**




រូបទី ២.២ : ភាគហ៊ុនអាស៊ី-ប៉ាស៊ីហ្វិកនៅក្នុងពាណិជ្ជកម្មពិភពលោក ឆ្នាំ ១៩៧៣-២០០០

ប្រភព : អង្គការពាណិជ្ជកម្មពិភពលោក២០០៥

**តារាង ២.២**

ពន្ធជាក់ស្តែងលើការនាំចូលសម្រាប់ប្រទេសខ្លះៗ ឆ្នាំ ១៩៩០ និង ២០០០ (%)

| ប្រទេស | ១៩៩០ | ២០០០ |
|---|---|---|
| ចិន | ៤ | ៤ |
| ហ្វីជី | ១៥ | ១១ |
| ឥណ្ឌូណេស៊ី | ៤ | ៣ |
| ម៉ាឡេស៊ី | ៦ | ១ |
| ប៉ាពួញូហ្គីណេ | ១០ | ១៦ |
| ហ្វីលីពីន | ១៧ | ៦ |
| វៀតណាម | ១៤ | ៦ |
| អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក | ៥ | ៤ |
| ឥណ្ឌា | ៤៥ | ២០ |
| នេប៉ាល់ | ១០ | ៩ |
| ប៉ាគីស្ថាន | ២៥ | ១១ |
| ស្រីលង្កា | ១៤ | ៤ |
| អាស៊ីខាងត្បូង | ៣៤ | ១៤ |

សម្គាល់: ពន្ធលើការនាំចូលជាក់ស្តែង=ចំណូលពីពន្ធលើការនាំចូល/តម្លៃសរុបនៃការនាំចូល

**ប្រភព: ធនាគារពិភពលោក ២០០៥**

១៣% ទៅ ២១% នៅរវាងឆ្នាំ ១៩៧៣ និង ២០០៣ (រូបទី ២.២)។

ការនាំចេញទំនិញពីអាស៊ីបូព៌ានិងប៉ាស៊ីហ្វិក ដែលជាមធ្យមបានកើនឡើង ៩% ក្នុងមួយឆ្នាំ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ បានកើនឡើងដល់ ១៣% នៅទសវត្សរ៍ឆ្នាំ ១៩៩០ (តារាង ២.៣)។ ក្នុងចំណោមកត្តាដទៃទៀត នេះគឺជាផលវិបាក ដែលមួយផ្នែកទទួលបានពីកិច្ចប្រឹងប្រែងលើសេរីភាវូបនីយកម្ម ដែលបានបង្កើតជាមូលដ្ឋានសម្រាប់បើកលទ្ធភាពឱ្យក្រុមហ៊ុនចូលទៅប្រកួតប្រជែងជាអន្តរជាតិ។ បរិយាកាសអំណោយផលនៃការវិនិយោគ ក៏បានលើកទឹកចិត្តឱ្យមានលំហូរចូលយ៉ាងច្រើននៃការវិនិយោគបរទេសផងដែរ។ ជាលទ្ធផលនៅទសវត្សរ៍ឆ្នាំ ១៩៩០ តំបន់អាស៊ីបូព៌ាដែលមានឧស្សាហកម្មប្រកបដោយប្រសិទ្ធិភាពខ្ពស់ និងផ្តល់ផលច្រើន បានផ្តល់ឱកាសសម្រាប់ចាប់ផ្តើមធ្វើឱ្យមានកំណើនសេដ្ឋកិច្ច។

ប្រទេសចិនជាអ្នកទទួលផលបានច្រើនជាងគេ។ ប្រទេសនេះមានកម្លាំងពលកម្មច្រើនប្រកបដោយជំនាញខ្ពស់ និងទាមទារកម្រៃទាប។ ប្រទេសនេះក៏មានតំបន់សេដ្ឋកិច្ចពិសេសផងដែរ ដែលផ្តល់ប្រយោជន៍ខាងសារពើពន្ធ និងប្រយោជន៍ផ្សេងទៀត ដែលមានភាពទាក់ទាញដល់ក្រុមហ៊ុនពហុជាតិជាច្រើន ដែលនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ បានវិនិយោគច្រើនជាង ៣០០.០០០ លានដុល្លារ។ ជាលទ្ធផលក្នុងទសវត្សរ៍នោះ កំណើនការនាំចេញមានច្រើនជាង ១៥% ហើយនៅឆ្នាំ ២០០៤ ចិនបានជំនួសជប៉ុនជាអ្នកនាំចេញធំជាងគេនៅអាស៊ី (តារាង ២.៣)។

ជោគជ័យមួយផ្សេងទៀតនៃការនាំចេញពីអាស៊ីបូព៌ារួមមាន ម៉ាឡេស៊ី និង ថៃ។ ឥណ្ឌូណេស៊ី និង ហ្វីលីពីន ក៏បានប្រឹងប្រែងយ៉ាងខ្លាំងផងដែរនៅដំណាក់កាលក្រោយមក។ ប៉ុន្តែអ្នកដែលលូតលាស់រហ័សគឺប្រទេសវៀតណាម ដែលការនាំចេញ

បានកើនឡើង ២០% ក្នុងមួយឆ្នាំ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៨០ ដែលសង្ឃឹមថានឹងក្លាយជាមណ្ឌលសេដ្ឋកិច្ចមួយទីពីរ ដែលមានប្រាក់ចំណូលកណ្តាល នៅក្នុងតំបន់អាស៊ីបូព៌ានេះ។

ប្រការដែលគួរឱ្យចាប់អារម្មណ៍ជាងនេះប្រហែលជាការប្រព្រឹត្តទៅរបស់ប្រទេសអភិវឌ្ឍន៍តិចតួចខ្លះៗនៅអាស៊ីអាគ្នេយ៍។ ប្រទេសមួយចំនួនមោះមុតក្នុងការក្លាយជាអ្នកសកលភាវូបនីយកម្ម។ ចាប់ផ្តើមពីមូលដ្ឋានតូចទាប ឧទាហរណ៍ ប្រទេសកម្ពុជាបានធ្វើឱ្យមានកំណើនគួរឱ្យចាប់អារម្មណ៍ ក្នុងការនាំចេញទំនិញ ៣៧% ក្នុងមួយឆ្នាំ ដែលភាគច្រើនជាវាយនភណ្ឌ និងសម្លៀកបំពាក់។ ប្រទេសឡាវ និងភូមាក៏បានដំណើរការល្អផងដែរ ដែលមានអត្រាកំណើនការនាំចេញ ១៨% និង ១៩%។

ស្ថានភាពខុសប្លែកពីនេះនៅអាស៊ីខាងត្បូង។ នៅទីនេះ កំណើននៃការនាំចេញទំនិញពុំសូវជាការគួរឱ្យចាប់អារម្មណ៍នោះទេ។ ឥណ្ឌាដែលជាអ្នកនាំចេញធំជាងគេនៅក្នុងអនុតំបន់នេះ មានការយឺតយ៉ាវក្នុងការកាត់បន្ថយអត្រាពន្ធ និងបង្វែរផលិតកម្មពីការផលិតសម្រាប់ជំនួសការនាំចូល ទៅជាការនាំចេញសម្រាប់ទីផ្សារ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសតូចៗខ្លះធ្វើបានប្រសើរជាង ជាពិសេសប្រទេសបង់ក្លាដេស និងណេប៉ាល់ លើការនាំចេញវាយនភណ្ឌ និងសម្លៀកបំពាក់ ទោះបីកំណើននេះកើតឡើងដោយសាររបបកូតាក៏ដោយហើយត្រូវបានលុបចោលហើយនៅពេលនេះ។ អាស៊ីខាងត្បូងទាំងមូលអនុវត្តបានប្រសើរខ្លាំងជាងខាងផ្នែកនាំចេញសេវាកម្ម ដែលមានអត្រាកំណើននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ខ្ពស់ជាងអត្រាដូចគ្នានេះនៅអាស៊ីបូព៌ា។ នៅទីនេះ ឥណ្ឌាជាប្រទេសនាំមុខ ដែលផ្តល់សេវាសម្រាប់លទ្ធកម្មពីក្រៅរោងចក្រ ជាពិសេសវិស័យព័ត៌មានវិទ្យា ដល់ប្រទេស OECD ជាច្រើន។

ទម្រង់នៃកំណើនការនាំចេញមានលក្ខណៈប្រហាក់ប្រហែលគ្នា (តារាង ២.៤)។ អត្រានាំចូលក៏បានកើនឡើងផងដែរ មួយផ្នែកដោយសារការថយចុះនៃអត្រាពន្ធ ដែលធ្វើឱ្យការនាំចូលថោកជាងធៀបនឹងការផលិតផលនៅក្នុងស្រុក ហេតុនេះជាការជំនួសផលិតមួយចំនួនដែលបានផលិតឡើងសម្រាប់លក់ក្នុងស្រុក។ ប៉ុន្តែ ការនាំចូលខ្លះជាការចាំបាច់ដើម្បីប្រើប្រាស់ជា

តារាង ២.៣

អត្រាកំណើននៃការនាំចេញ ទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ (%)

| | ទំនិញ | | សេវា | | សរុប | |
|---|---|---|---|---|---|---|
| | ១៩៨០ | ១៩៩០ | ១៩៨០ | ១៩៩០ | ១៩៨០ | ១៩៩០ |
| កម្ពុជា | ២៣ | ៣៧ | .. | ៣៦ | .. | .. |
| ចិន | ១៣ | ១៥ | ១២ | ១៩ | ១៣ | ១៦ |
| ហ្វីជី | ១ | ៣ | ៩ | ៣ | ៥ | ២ |
| ឥណ្ឌូណេស៊ី | ១ | ១០ | ២២ | ៩ | ២ | ៩ |
| ឡាវ | ១៣ | ១៨ | ១១ | ២៥ | ១៨ | ២០ |
| ម៉ាឡេស៊ី | ៩ | ១៣ | ១៤ | ១៥ | ១០ | ១៤ |
| ម៉ុងហ្គោលី | ៥ | -0.៥ | ៨ | ១០ | .. | ៦ |
| ភូមា | -0.៥ | ១៩ | ៩ | ២៦ | .. | .. |
| ប៉ាពួញូហ្គីនេ | ២ | ៧ | ២១ | ៤ | ៤ | ៧ |
| ហ្វីលីពីន | ៤ | ១៧ | ១០ | ៨ | ៥ | ១៤ |
| សាម៉ាវ | -៣ | ១២ | ១៧ | ៧ | - | ១០ |
| ថៃ | ១៥ | ១២ | ១៧ | ៩ | ១៥ | ១១ |
| វៀតណាម | ២៣ | ២១ | .. | ៥ | .. | ២៣ |
| អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក | ៩ | ១៤ | ១៤ | ១១ | ១០ | ១៣ |
| បង់ក្លាដេស | ៩ | ១៥ | ៧ | ៨ | ១០ | ១៤ |
| ប៊ូតាណ | ១៨ | ៦ | ២៨ | -៣.៥ | ១៨ | ៥ |
| ឥណ្ឌា | ៨ | ៩ | ៥ | ១៥ | ៧ | ១១ |
| ម៉ាល់ឌីវ | ២១ | ៥ | ៦ | ១៤ | ២២ | ៩ |
| ណេប៉ាល់ | ១៤ | ១៦ | ៣ | ១៣ | ៦ | ១៤ |
| ប៉ាគីស្ថាន | ៩ | ៥ | ៩ | ១ | ៨ | ៣ |
| ស្រីលង្កា | ៧ | ១១ | ៧ | ៨ | ៧ | ១១ |
| អាស៊ីខាងត្បូង | ៨ | ៩ | ៦ | ១២ | ៧ | ១០ |

**ប្រភព: ធនាគារពិភពលោក ២០០៥**

*អ្នកដែលលូតលាស់របស់គឺប្រទេសវៀតណាម ដែលការនាំចេញបានកើនឡើង ២០% ក្នុងមួយឆ្នាំ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៨០*

វត្ថុធាតុដើមសម្រាប់ការនាំចេញ ដែលជាការឆ្លុះបញ្ចាំងអំពីបណ្តាញ ដែលកាន់តែមានភាពចម្រុះសម្រាប់ផលិតកម្មសកល ដោយសារតំបន់ខុសគ្នាអាចផ្តល់បំណែកខុសគ្នាទៅក្នុងចង្វាក់នៃតម្លៃបន្ថែម។ ដូច្នេះ ការនាំចេញនិងការនាំចូល មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ជាពិសេសនៅអាស៊ីខាងត្បូង ដែលកំណើននៃការនាំចេញ បានធ្វើឱ្យការនាំចូលមានស្ថិរភាព ដោយកាត់បន្ថយឧបសគ្គក្នុងការប្តូររូបិយប័ណ្ណ។

តារាង ២.៤

អត្រាកំណើននៃការនាំចូល ទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ (%)

| | ទំនិញ | | សេវា | | សរុប | |
|---|---|---|---|---|---|---|
| | ១៩៨០ | ១៩៩០ | ១៩៨០ | ១៩៩០ | ១៩៨០ | ១៩៩០ |
| កម្ពុជា | ០ | ២៧ | .. | ២៥ | .. | |
| ចិន | ១២ | ១៦ | ១២ | ២៨ | ១២ | ១៧ |
| ហ្វីជី | ៤ | ២ | ៩ | ៥ | ៥ | ២ |
| ឥណ្ឌូណេស៊ី | ៩ | ៦ | ៣ | ១១ | ៧ | ៨ |
| ឡាវ | ៨ | ១៤ | -១១ | ១៣ | ២ | ១២ |
| ម៉ាឡេស៊ី | ១២ | ១២ | ៧ | ១៣ | ១១ | ១២ |
| ម៉ុងហ្គោលី | ៦ | ២ | ៤៥ | ៥ | .. | ៦ |
| ភូមា | -១ | ៣០ | ៤ | ២៩ | .. | .. |
| ប៉ាពួញូហ្គីនេ | ១ | ១ | ៤ | ៨ | ២ | ៤ |
| ហ្វីលីពីន | ៦ | ១២ | ៤ | ១៨ | ៦ | ១២ |
| សាម៉ាវ | ៤ | ៤ | ៦ | ៣ | .. | ២ |
| ថៃ | ១៦ | ៨ | ១៦ | ១១ | ១៦ | ៩ |
| វៀតណាម | ៨ | ២១ | .. | ១០ | .. | ២១ |
| អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក | ១០ | ១២ | ៩ | ១៣ | ១០ | ១២ |
| បង់ក្លាដេស | ៤ | ៩ | ៤ | ១០ | ៣ | ៩ |
| ប៊ូតាណ | ៧ | ១១ | ២ | ១៥ | ៨ | ១៣ |
| ឥណ្ឌា | ៥ | ៩ | ៨ | ១៣ | ៥ | ១០ |
| ម៉ាល់ឌីវ | ២០ | ១១ | ០ | ១១ | ២២ | ៨ |
| ណេប៉ាល់ | ៨ | ១០ | ៧ | ៣ | ៩ | ៧ |
| ប៉ាគីស្ថាន | ៤ | ៥ | ៩ | ២ | ៤ | ៥ |
| ស្រីលង្កា | ៣ | ១១ | ៦ | ១០ | ៤ | ១០ |
| អាស៊ីខាងត្បូង | ៤ | ៨ | ៧ | ១០ | ៥ | ៨ |

**ប្រភព: ធនាគារពិភពលោក ២០០៥**

ទោះជាយ៉ាងណាក៏ដោយ ជាទូទៅ ការនាំចូលបានកើនឡើងយឺតជាងការនាំចេញ ជាពិសេសនៅអាស៊ីខាងត្បូង។ ករណីលើកលែងពិសេសគឺប្រទេសចិន ដែលតម្រូវការខាងការនាំចូលបានកើនឡើង ១៧% ក្នុងមួយឆ្នាំ និងបានរុញច្រានសមាមាត្រការនាំចេញទាំងមូលពីតំបន់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិកពី ៤% ទៅ ៧%។ យ៉ាងណាក៏ដោយ ភាគចំណែកពីអាស៊ីខាងត្បូងមានកម្រិតប្រហាក់ប្រហែលគ្នានេះដែរ។

បន្ទុំរវាងកំណើននៃការនាំចេញនិងនាំចូល បង្ហាញថាសេដ្ឋកិច្ចនៃប្រទេសអាស៊ីទាំងអស់កាន់តែមានការ "បើកចំហ"។ កម្រិតនៃ "ការបើកចំហ" សេដ្ឋកិច្ចដែលគិតជាអនុបាតនៃពាណិជ្ជកម្មអន្តរជាតិ (ទំនិញនិងសេវា) និង GDP បានកើនឡើងស្មើដូចដែលឃើញនៅខាងលើ ទាំងនៅអាស៊ីបូព៌ា និងអាស៊ីខាងត្បូង រវាងឆ្នាំ ១៩៩០ និង ២០០៣។

## តុល្យភាពខាងការនាំចូល និងការនាំចេញ

ភាពប្រែប្រួលនៃពាណិជ្ជកម្មអន្តរជាតិនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ ក៏បាននាំមកនូវការផ្លាស់ប្តូរតុល្យភាពរវាងការនាំចូលនិងការនាំចេញផងដែរ។ លទ្ធផលមានសង្ខេបជូនក្នុងរូបទី ២.៣។ នៅអាស៊ីបូព៌ានិងប៉ាស៊ីហ្វិក តុល្យភាពនៃពាណិជ្ជកម្មទំនិញបានផ្លាស់ប្តូរពីអវិជ្ជមានមកវិជ្ជមាន ដែលនាំឱ្យសមតុល្យសរុបប្តូរពី -០.៥% មក +១.៩% នៃ GDP។ ឥឡូវនេះ អាស៊ីខាងត្បូងក៏មានការរីកចម្រើនផងដែរ និងធ្វើឱ្យមានសមតុល្យវិជ្ជមានខាងផ្នែកសេវាកម្ម។ ជារួមសមតុល្យនៅអវិជ្ជមាននៅឡើយ ប៉ុន្តែ កំពុងឈានទៅរកទិសដៅល្អ ចាប់ពី -៣.៧% ទៅ -១.៩%។

បទពិសោធពីបណ្តាប្រទេសនៅអាស៊ី-ប៉ាស៊ីហ្វិកក៏អាចដាក់បញ្ចូលទៅក្នុងបរិបទនៃប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតផងដែរ។ ឧទាហរណ៍: UNCTAD បានសិក្សាអំពីផលប៉ះពាល់នៃសេរីភាវូបនីយកម្មពាណិជ្ជកម្មទៅលើតុល្យភាពពាណិជ្ជកម្មក្នុងប្រទេសចំនួន ១៦ នៅតាមតំបន់ខុសៗគ្នា

សម្រាប់ចន្លោះឆ្នាំ ១៩៧០ ដល់ ១៩៩៩ និងបានសន្និដ្ឋានថាមាននិន្នាការដែលនាំឱ្យបាត់បង់តុល្យភាពជញ្ជីងទូទាត់[៣] ជាពិសេសនៅក្នុងដំណាក់កាលដើមដំបូងនៃដំណើរការនេះ។ ការសិក្សាមួយផ្សេងទៀតអំពីប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ២២ បានសន្និដ្ឋានថា ការកាត់បន្ថយពន្ធមួយភាគរយ ការនាំចេញនឹងកើនឡើងបន្ថែមជាមធ្យម 0.២% ចំណែកការនាំចូលកើនឡើងរវាង 0.២% ទៅ 0.៤% ហើយជារួម សេរីភាវូបនីយកម្មបានធ្វើឱ្យខូចតុល្យភាពជញ្ជីងពាណិជ្ជកម្មក្នុងអត្រា ២% នៃ GDP។[៤] លទ្ធផលនេះបានទទួលការអះអាងគាំទ្រដោយការសិក្សាជាបន្ថែមរបស់ UNCTAD។[៥]




រូបទី ២.៣: តុល្យភាពជញ្ជីងពាណិជ្ជកម្ម អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក និងអាស៊ីខាងត្បូង ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០

ប្រភព : ធនាគារពិភពលោក ២០០៥

យោងតាមស្តង់ដារនេះ តំបន់នេះទាំងមូលបានទទួលបទពិសោធវិជ្ជមានច្រើន ដោយឃើញថាស្ថានភាពតុល្យភាពជញ្ជីងទូទាត់ទំនងជាមានការកែលំអ។ តំបន់អាស៊ីបូព៌ា សម្រេចបានលទ្ធផលល្អ : នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ តំបន់នេះមានអតិរេកពាណិជ្ជកម្មប្រមាណ ២% នៃ GDP ហើយនៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ បានកើនឡើងដល់ ៤% ដែលនាំឱ្យសន្សំបានយ៉ាងច្រើននូវរូបិយប័ណ្ណបរទេស។

តំបន់អាស៊ីខាងត្បូង ក៏បានកែលំអស្ថានភាពរបស់ខ្លួនដូច្នោះដែរ សូម្បីតែជញ្ជីងពាណិជ្ជកម្មនៅតែអវិជ្ជមានក៏ដោយ ដែលមានពីរភាគបីនៃកំណែលំអបានមកពីទំនិញកម្មន្តសាល។ ហេតុអ្វីលទ្ធផលបានពីសេរីភាវូបនីយកម្មពុំសូវមានអ្នកណានិយាយសោះនៅទីនេះ? ចម្លើយប្រហែលជាស្ថិតនៅជាមួយអ្នកវិនិយោគឯកជន ដែលបានឆ្លើយតបយ៉ាងយឺតចំពោះការផ្លាស់ប្តូរនូវសញ្ញាអំពីភាពដែលអាចរកចំណេញបាន។ ទោះបីមានកំណែទម្រង់ពាណិជ្ជកម្មក្តី កម្រិតនៃការវិនិយោគឯកជនក្នុងវិស័យកម្មន្តសាល នៅតែទាបនៅឡើយ ហើយអ្នកវិនិយោគបានចាត់វិធានការបណ្តើរៗ សំដៅទៅរកតែវិស័យនាំចេញតែប៉ុណ្ណោះ។

ប្រទេសប៉ាគីស្ថានបានបង្ហាញអំពីចំណុចនេះ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ កំណើនការនាំចេញបានធ្លាក់ចុះពី ៩% មកត្រឹម ៩%។ ការវិនិយោគឯកជននៅតែមានកម្រិតទាបមួយភាគគឺដោយសារប្រទេសនេះបានជួបប្រទះអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចធ្ងន់ធ្ងរនៅក្នុងអំឡុងពេលនោះ។ វិនិយោគិនបានទទួលការរារាំងដោយសារដំណើរការកំណែទម្រង់រចនាសម្ព័ន្ធនៅក្នុងអំឡុងពេលនៃកម្មវិធី IMF ដែលធ្វើឱ្យកំណើនស្ថិតនៅទ្រឹង។ ទោះជាយ៉ាងណាក៏ដោយ នៅពេលក្រោយមក ការវិនិយោគក៏បានស្តារឡើងវិញ ជាពិសេសសម្រាប់ការធ្វើទំនើបកម្មវិស័យវាយនភណ្ឌ ហើយការនាំចេញបានកើនឡើង ២០%។

## ការផ្លាស់ប្តូររចនាសម្ព័ន្ធពាណិជ្ជកម្ម

*ទន្ទឹមនឹងកំណើនទំហំនៃពាណិជ្ជកម្ម រចនាសម្ព័ន្ធពាណិជ្ជកម្មក៏ផ្លាស់ប្តូរខ្លាំងណាស់ដែរ*

ទន្ទឹមនឹងកំណើនទំហំនៃពាណិជ្ជកម្ម រចនាសម្ព័ន្ធពាណិជ្ជកម្មក៏ផ្លាស់ប្តូរខ្លាំងណាស់ដែរ។ ប្រការនេះ បានកើតឡើងជាបីកម្រិត: ទីមួយ នៅក្នុងទាំងការនាំចេញ និងការនាំចូលដែលមានការផ្លាស់ប្តូររវាងទំនិញនិងសេវាកម្ម។ ទីពីរ នៅក្នុងចំណោមការនាំចេញទំនិញ ដែលមានការផ្លាស់ប្តូររវាងផលិតផលបឋម និងផលិតផលកម្មន្តសាល និងទីបី នៅក្នុងផលិតកម្មកម្មន្តសាល មានការប្រែប្រួលនៃតុល្យភាពរវាងផលិតកម្មអតិពលកម្មនិងផលិតកម្មអតិមូលធន។

ការផ្លាស់ប្តូរតុល្យភាពរវាងការនាំចេញទំនិញ និងការនាំចេញសេវាកម្ម ត្រូវបានកត់សម្គាល់ជាចម្បងនៅអាស៊ីខាងត្បូង ជាពិសេសនៅក្រោយពេលការរីកចម្រើនដល់កំពូល

*នៅក្នុងការនាំចេញផលិតផលកម្មន្តសាល ក៏មានការរីកចម្រើនយ៉ាងច្រើននៃបច្ចេកវិទ្យា ឈានទៅបង្កើតផលិតផលទំនើបផងដែរ*

នៅឥណ្ឌា ខាងផ្នែកផ្តល់សេវា IT ។ ជាលទ្ធផល ២៦% នៃការនាំចេញបច្ចុប្បន្នពីអាស៊ីខាងត្បូង គឺសេវាកម្ម ។ ទោះជាយ៉ាងណាក៏ដោយ នៅអាស៊ីបូព៌ា ការផ្លាស់ប្តូរបានកើតឡើងទៅតាមទិសដៅផ្សេង នៅពេលដែលការនាំចេញទំនិញសម្រាប់លក់បានកើនឡើងពី ៨៦% ទៅ ៨៨% នៃផលនាំចេញសរុប (រូបទី ២.៤) ។




រូបទី ២.៤: សមាសភាពនៃទំនិញនាំចេញ និងនាំចូល

ប្រភព : ធនាគារពិភពលោក

តារាង ២.៥

សមាសភាពនៃទំនិញនាំចេញ និងនាំចូលសម្រាប់លក់

| | នាំចេញ (%) | | | នាំចូល (%) | | |
|---|---|---|---|---|---|---|
| | ១៩៨០ | ១៩៩០ | ២០០០ | ១៩៨០ | ១៩៩០ | ២០០០ |
| *អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក* | | | | | | |
| កសិកម្ម | | ២១ | ១២ | | ១១ | ៩ |
| ឥន្ធនៈ | | ១៤ | ៨ | | ៦ | ១០ |
| កម្មន្តសាល | | ៥៩ | ៨០ | | ៧៧ | ៧៦ |
| ផ្សេងទៀត | | ៦ | ០ | | ៦ | ៥ |
| សរុប | | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| *អាស៊ីខាងត្បូង* | | | | | | |
| កសិកម្ម | ៣៨ | ២១ | ១៧ | ១៤ | ១៣ | ១០ |
| ឥន្ធនៈ | ៣ | ២ | ៤ | ៣៥ | ២៣ | ៣៥ |
| កម្មន្តសាល | ៥៤ | ៧១ | ៧៨ | ៤៦ | ៥៤ | ៤៨ |
| ផ្សេងទៀត | ៥ | ៦ | ១ | ៣ | ១០ | ៧ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

**ប្រភព: ធនាគារពិភពលោក ២០០៥**

នៅក្នុងចំណោមការនាំចេញទំនិញសម្រាប់លក់ ក៏មានការផ្លាស់ប្តូររចនាសម្ព័ន្ធជាចម្បងផងដែរ ជាពិសេស ការផ្លាស់ប្តូរឆ្ពោះទៅផលិតផលកម្មន្តសាល ដែលនៅអាស៊ីបូព៌ាមានរហូតដល់ ៨០% និងអាស៊ីខាងត្បូង ៧៨% នៃការនាំចេញទំនិញនៅក្នុងឆ្នាំ ២០០០ (តារាង ២.៥) ។ ទិដ្ឋភាពគួរឱ្យកត់សម្គាល់ពីរផ្សេងទៀតគឺទាក់ទងនឹងទំនិញកសិផល និងប្រេង ។ មិនត្រឹមតែការនាំចេញកសិផលទេដែលបានថយចុះ ប្រទេសមួយចំនួនក៏បានក្លាយជាអ្នកនាំចូលស្បៀងអាហារទ្រង់ទ្រាយធំផងដែរ ។ ឧទាហរណ៍ ប្រទេសចិនគឺជាអ្នកនាំចូលសុទ្ធនូវកសិផល ដោយតម្លៃ ២.០០០លានដុល្លារ នៅក្នុងឆ្នាំ ១៩៩០ ។ នៅឆ្នាំ ២០០៣ ស្ថានភាពនេះបានត្រូវផ្លាស់ប្តូរទៅជាអ្នកនាំចូលសុទ្ធ ដោយតម្លៃ ១៤.០០០លានដុល្លារ ដែលជាកំណើនតម្រូវការដែលមានឥទ្ធិពលជាចម្បង ទៅលើអនាគតនៃតម្លៃស្បៀងនៅលើពិភពលោក (ប្រអប់ ២.២) ។

ទាក់ទងនឹងឥន្ធនៈ មានការថយចុះនូវការនាំចេញពីក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ទោះបីប្រទេសនានាដូចជា ម៉ាឡេស៊ីបានក្លាយជាអ្នកនាំចេញសុទ្ធក៏ដោយ ។ ប្រទេសឥណ្ឌូណេស៊ីដែលជាសមាជិកចម្បងនៃ OPEC នៅក្នុងតំបន់នេះ មានការថយចុះនូវផលិតផលលើសនៃប្រេងកាតឆៅ និងប្រេងជាផលិតផលសម្រេចដែលអាចនាំចេញ ។ អាស៊ីខាងត្បូងមានការពឹងផ្អែកកាន់តែច្រើនលើការនាំចូលប្រេងជាងអាស៊ីបូព៌ា អាស្រ័យហេតុនេះនឹងទទួលរងគ្រោះកាន់តែច្រើនឡើងដោយសារកំណើនថ្លៃប្រេង (ប្រអប់ ២.៣) ។

នៅក្នុងការនាំចេញផលិតផលកម្មន្តសាល ក៏មានការរីកចម្រើនយ៉ាងច្រើននៃបច្ចេកវិទ្យាឈានទៅបង្កើតផលិតផលទំនើបផងដែរ ប៉ុន្តែប្រការនេះបានបង្ហាញច្បាស់នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ជាងនៅអាស៊ីខាងត្បូង (រូបទី២.៥) ។ ក្នុងរវាងឆ្នាំ ១៩៩០ និង ២០០០ នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក សមាមាត្រនៃការនាំចេញផ្អែកលើធនធានធម្មជាតិ និង ទំនិញពីផលិតកម្មអតិពលកម្ម និងបច្ចេកវិទ្យាទាប បានធ្លាក់ចុះពី ៥៣% មក

៣៧% ចំណែកសមាមាត្រដែលផ្អែកលើទំនិញដែលផលិតដោយបច្ចេកវិទ្យាខ្ពស់ បានកើនឡើងពី ២៤% ដល់ ៤១%។ ភាគច្រើននៃសមាមាត្រនេះបានមកពីប្រទេសដែលមានប្រាក់ចំណូលខ្ពស់ជាងថ្នាក់កណ្តាលដូចជា ប្រទេសម៉ាឡេស៊ី និង ថៃ។ ប្រទេសទាំងនេះបានបង្កើនផលិតផលរបស់ខ្លួន ដូចជា គ្រឿងអេឡិចត្រូនិក ម៉ាស៊ីនប្រើក្នុងការិយាល័យ និងបរិក្ខារទូរគមនាគមន៍ ដែលនាំឱ្យមានកំណើនយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្មពិភពលោក។ ម្យ៉ាងវិញទៀតនៅអាស៊ីខាងត្បូង ប្រមាណ ៨៥% នៃទំនិញនាំចេញ នៅតែជាផលិតផលដែលផ្អែកលើធនធានធម្មជាតិ ឬទំនិញអតិពលកម្មនៅឡើយ។

ប្រអប់ ២.២

### ផ្តើមចេញពីបរិមាណស្បៀងលើសទៅឱនភាពស្បៀង

សេដ្ឋកិច្ចបួនក្នុងចំណោមដប់ដែលមានប្រាក់ចំណូលពីកម្រិតទាបដល់ចំណូលកម្រិតកណ្តាលនៅក្នុងតំបន់នេះ ឥឡូវមានឱនភាពស្បៀងអាហារទាំងស្រុង។ ប្រទេសទាំងនោះ គឺ បង់ក្លាដេស ចិន ប៉ាគីស្ថាន និងហ្វីលីពីន។ ក្នុងចំណោមប្រទេសទាំងនេះ ចិនមានបរិមាណស្បៀងលើសរហូតដល់ឆ្នាំ ២០០៣ និង ហ្វីលីពីនរហូតដល់ឆ្នាំ ១៩៩៤។ បរិមាណលើសនេះនៅថេរនៅក្នុងប្រទេសឥណ្ឌា និងក្នុងបរិមាណតិចតួចនៅក្នុងប្រទេសស្រីលង្កា។ នៅប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងថៃ បរិមាណលើសបានកើនឡើង។

**បរិមាណស្បៀងលើស និងឱនភាពសុទ្ធ ក្នុងប្រទេសមួយចំនួន (ពាន់លានដុល្លារ)**

| ប្រទេស | ១៩៩០ | ២០០០ |
|---|---|---|
| បង់ក្លាដេស | -០.៤ | -១.២ |
| ចិន | ៣.២ | -០.៣ |
| ឥណ្ឌា | ៣ | ៣ |
| ឥណ្ឌូណេស៊ី | ១.៧ | ៤.៣ |
| ម៉ាឡេស៊ី | ១.៤ | ៤.៣ |
| ប៉ាគីស្ថាន | -០.៨ | -០.៥ |
| ហ្វីលីពីន | ០.២ | -០.៦ |
| ស្រីលង្កា | ០.១ | ០.១ |
| ថៃ | ៤.៩ | ៧.៦ |
| វៀតណាម | - | ៣ |

**ប្រភព: ធនាគារពិភពលោក ២០០៥**

## កំណើន ឬ ពាណិជ្ជកម្ម តើមួយណាគួរតែកើតមុន?

តំបន់អាស៊ីប៉ាស៊ីហ្វិកបានទទួលបទពិសោធនៃកំណើនសេដ្ឋកិច្ចយ៉ាងច្រើន ហើយការកើនឡើងយ៉ាងឆាប់រហ័សជាពិសេស នៅអាស៊ីបូព៌ានិងនៅអាស៊ីខាងត្បូងដែលមានកំណើនតិចជាង។ ប៉ុន្តែ តើការនាំចេញនាំឱ្យមានកំនើននេះ ឬផ្ទុយមកវិញៈ តើការកើនឡើងនៃការនាំចេញ គឺជាលទ្ធផលនៃកំណើនសេដ្ឋកិច្ចឬ? នេះជាសំណួរដែលមានការពិភាក្សាយ៉ាងទូលំទូលាយ។[៦]

មានទស្សនៈមួយថាកម្លាំងចលករចម្បងគឺ កំណើនពោលគឺនៅពេលលទ្ធផលកើនឡើង ពេលនោះនឹងមានផលលើសដែលអាចនាំចេញ។ ឧទាហរណ៍ បើប្រទេសកំពុងអភិវឌ្ឍន៍តូចមួយប្រមូលផលដំណាំបានល្អដែលនាំឱ្យមានស្បៀងនៅសល់ ប្រទេសនោះអាចលក់ទៅទីផ្សារអន្តរជាតិ និងធ្វើបែបនេះតាមតម្លៃទូទៅនៅលើពិភពលោក ដោយសារបរិមាណទំនិញនោះមានតិចតួច។

ទស្សនៈមួយផ្សេងទៀតថា កំណើនជាកត្តានាំឱ្យមានការនាំចេញ។ ប្រទេសមួយដែលមានទីផ្សារក្នុងស្រុកទំហំតូចអាចសម្រេចកំណើនដោយចីរភាពបានដោយសារការលក់ទំនិញរបស់ខ្លួនទៅក្នុងទីផ្សារពិភពលោកដែលធំជាង។ ទស្សនៈនេះមានភាពស្របគ្នាជាមួយការស្រាវជ្រាវដែលសំអាងលើការពិសោធន៍។[៧] ទស្សនៈនេះមានបង្ហាញជូននៅក្នុងរូបទី ២.៦ ដែលជាគម្រូបានពីបណ្តាសេដ្ឋកិច្ចធំ នៅតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដែលមានប្រាក់ចំណូលពីកម្រិតទាបដល់កណ្តាល ដោយតាងជាដ្យាក្រាមអំពីកំណើន GDP ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ ធៀបនឹងកំណើននៃការនាំចេញ។ លទ្ធផលនេះសន្និដ្ឋានអំពីទំនាក់ទំនងវិជ្ជមាន។ ទោះជាយ៉ាងណាក៏ដោយ ដ្យាក្រាមនេះ មានចំណុចដែលស្ថិតនៅជាយខាងក្រៅ ដូចជាប្រទេសចិននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ មានកំណើនការនាំចេញតិចតួច

ប្រអប់ ២.៣

## ការប៉ះទង្គិចទាក់ទងនឹងការផ្គត់ផ្គង់ប្រេង

ទោះបីប្រទេសឥណ្ឌូណេស៊ី ក្នុងនាមជាអ្នកនាំចេញសុទ្ធ បានទទួលប្រយោជន៍ពីកំណើនថ្លៃប្រេងកាតក៏ដោយ ប្រទេសផ្សេងទៀតជាច្រើនត្រូវរងគ្រោះដោយសារការប៉ះទង្គិចនៃការផ្គត់ផ្គង់ប្រេង។ វិសាលភាពនៃការប៉ះទង្គិចនេះ អាចវាស់បានតាមរយៈការពិចារណាអំពីកំណើននៃការចំណាយលើការនាំចូលគិតជាភាគរយនៃមូលធនបម្រុងជារូបិយប័ណ្ណបរទេសដែលមាននៅក្នុងប្រទេស។

អត្រានៃការប៉ះទង្គិច = ២០%
ប៉ាគីស្ថាន ហ្វីលីពីន ស្រីលង្កា និងវៀតណាម

អត្រានៃការប៉ះទង្គិច = ១០ - ២០%
បង់ក្លាដេស ឥណ្ឌា នេបាល់ ថៃឡង់

អត្រានៃការប៉ះទង្គិច < ១០%
ចិន

ឧបមាថាថ្លៃប្រេងកាតនៅបានកើនឡើង ៥០% រវាងឆ្នាំ ២០០៤ និង ២០០៥ ក្នុងចំណោមប្រទេសធំៗដែលងាយរងគ្រោះជាងគេគឺ ប៉ាគីស្ថាន ហ្វីលីពីន ស្រីលង្កា និងវៀតណាម ដែលកំណើននេះអាចមានខ្ពស់ជាង ២០%។ ឧទាហរណ៍ ប្រទេសប៉ាគីស្ថានដែលមានរូបិយប័ណ្ណបរទេសបម្រុងទុកត្រឹមតិចជាង ១០.០០០លានដុល្លារ ត្រូវប្រឈមនឹងថ្លៃបន្ថែមចំនួន ២.០០០លានដុល្លារ។ ប្រទេសចិនក៏ប្រឈមនឹងកំណើននៃការចំណាយលើការនាំចូលផងដែរ ពោលគឺ ២៤.០០០លានដុល្លារ ប៉ុន្តែផលប៉ះពាល់មានកម្រិតទាបជាង ដោយសារប្រទេសនេះមានរូបិយប័ណ្ណបរទេសបម្រុងច្រើនបំផុត។

ការប៉ះទង្គិចនៃថ្លៃប្រេងក្នុងវិសាលភាពនេះដែលត្រូវប្រឈមដោយ ប្រទេសប៉ាគីស្ថាន ហ្វីលីពីន ស្រីលង្កា និងវៀតណាម នឹងមិនធ្លាក់ចុះក្នុងរយៈពេលមួយឆ្នាំនោះទេ វានឹងនៅតែបន្តក្នុងរយៈពេលណាមួយ អាស្រ័យលើភាពរឹងមាំនៃរចនាសម្ព័ន្ធ និងកត្តាដទៃផ្សេងទៀត។

**ប្រភព: ធនាគារពិភពលោក ២០០៥**

ប៉ុណ្ណោះ ប៉ុន្តែ នៅតែអាចគ្រប់គ្រងដើម្បីសម្រេចកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សបាន។ ម៉្យាងវិញទៀត វៀតណាមមានកំណើនការនាំចេញឆាប់រហ័ស ប៉ុន្តែ មានកំណើនសេដ្ឋកិច្ចតិចតួចតែប៉ុណ្ណោះ។




រូបទី ២.៥: សមាសភាពនៃផលិតផលកម្មន្តសាលដែលនាំចេញ ឆ្នាំ ១៩៨០-២០០០

ប្រភព: UNIDO ២០០៤

គេក៏អាចបែងជាក្រុមនូវបណ្តាប្រទេសទាំងនេះទៅតាមលទ្ធផលរបស់ខ្លួននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ធៀបនឹងទសវត្សរ៍ឆ្នាំ ១៩៨០ ផងដែរ។

១. កំណើនសំទុះនៃការនាំចេញនិងកំណើនសេដ្ឋកិច្ច - ចិន ម៉ាឡេស៊ី ហ្វីលីពីន វៀតណាម បង់ក្លាដេស ស្រីលង្កា

២. កំណើនសំទុះនៃកំណើនការនាំចេញ ប៉ុន្តែគំហាយសំទុះនៃកំណើនសេដ្ឋកិច្ច - ឥណ្ឌា និងឥណ្ឌូណេស៊ី

៣. គំហាយទាំងសំទុះនៃការនាំចេញ និងសន្ទុះកំណើនសេដ្ឋកិច្ច - ថៃ និងប៉ាគីស្ថាន ។

ប្រទេសនានាដែលធ្លាក់ទៅក្នុងក្រុមទីពីរអាចត្រូវបានចាត់ទុកជាករណីពិសេស ដោយសារពួកគេមិនប្រព្រឹត្តតាមទម្រង់ដែលរំពឹងទុក។ ឥណ្ឌាមានកត្តាមួយចំនួនដែលអាចរួមចំណែកនាំឱ្យមានផលបែបនេះ។ ទីមួយ គួរតែចងចាំថា វិស័យនាំចេញ គឺគ្រាន់តែជាចំណែកតូចមួយនៃសេដ្ឋកិច្ចរបស់ប្រទេស




រូបទី ២.៦ : កំណើនការនាំចេញទំនិញ និងសេវា និង GDPនៅក្នុងប្រទេសក្នុងអាស៊ី និងប៉ាស៊ីហ្វិក

ប្រភព : Palanivel ២០០៦

ឥណ្ឌាប៉ុណ្ណោះ ហេតុនេះនឹងមានផលប៉ះពាល់តិចតួចប៉ុណ្ណោះ។ ទីពីរ កំណើនទាំងមូលមានភាពយឺតយ៉ាវ ដោយសារដំណើរការមិនល្អនៅក្នុងផលិតកម្មកសិកម្ម។ កត្តាទីបីដែលរួមចំណែកដែរនោះ អាចជាកំណើនការនាំចេញក្រោយសេរីភាវូបនីយកម្ម ដែលធ្វើឱ្យខូចឧស្សាហកម្មក្នុងស្រុកដែលដំណើរការ ដើម្បីបញ្ចៀសការនាំចូល។ ម្យ៉ាងវិញទៀត នៅប្រទេសឥណ្ឌូណេស៊ី កត្តាចម្បងគឺអាចជាវិបត្តិហិរញ្ញវត្ថុនៅអាស៊ីបូព៌ា ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រទេសទាំងនេះ ធ្វើឱ្យ GDP ធ្លាក់ចុះយ៉ាងខ្លាំង ទោះបីមានកំណើនយ៉ាងឆាប់រហ័សលើការនាំចេញក៏ដោយ។ គួរកត់សម្គាល់ដែរថានៅក្នុងតំបន់នេះទាំងមូល ពុំមានប្រទេសមួយដែលមានកំណើនយឺតយ៉ាវលើការនាំចេញ តែមានកំណើនសេដ្ឋកិច្ចឆាប់រហ័សនោះឡើយ។

ដូច្នេះ ទំនាក់ទំនងគ្មានរវាងកំណើននៃការនាំចេញជាមួយកំណើនសេដ្ឋកិច្ចពុំទំនងជាមានលក្ខណៈទូលំទូលាយឡើយ ហើយទំនាក់ទំនងនេះកាន់តែរឹងមាំ នៅពេលមានការយកចិត្តទុកដាក់ច្រើនលើការនាំចេញ។ ទោះជាយ៉ាងក៏ដោយ វាក៏អាចទទួលឥទ្ធិពលពីកត្តាតម្រូវការ និងការផ្គត់ផ្គង់ក្នុងស្រុកផងដែរ ហើយលទ្ធផលទទួលបាន អាចពុំមានភាពច្បាស់លាស់ ប្រសិនបើកំណើនលឿនជាងនេះនៃការនាំចេញត្រូវបានទូទាត់ជាមួយកំណើនឆាប់រហ័សនៃការនាំចូល។

នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក កត្តាភាគច្រើនដែលជម្រុញឱ្យមានកំណើន បណ្ដាលពីការនាំចេញទំនងជាពុំសូវបណ្ដាលមកពីផ្នែកកសិកម្មឡើយ និងភាគច្រើនបានមកពីផ្នែកមិនមែនកសិកម្ម ជាពិសេសមកពីកម្មន្តសាលដែលបានកើនឡើងជារៀងរាល់ឆ្នាំប្រមាណ ១១% នៅក្នុងទសវត្សរ៍ ឆ្នាំ ១៩៩០ (តារាង ២.៦)។ នេះគឺជាលទ្ធផលនៃសេចក្ដីសម្រេចគោលនយោបាយនៅក្នុងប្រទេសទាំងនេះ ក្នុងការងាកចេញពីកសិកម្មដំបូងទៅរកទំនិញកម្មន្តសាលអតិពលកម្ម ហើយបន្ទាប់មកទៅរកផលិតផលប្រកបដោយបច្ចេកវិទ្យាខ្ពស់។ លទ្ធផលបានមកគឺអត្រាកំណើនរហ័សជាង។

ជាលទ្ធផល វិស័យកសិកម្មបានទទួលការវិនិយោគតិចតួច និងមានការអន់ថយ។ យ៉ាងណាក៏ដោយការបំលែងរចនាសម្ព័ន្ធសេដ្ឋកិច្ចនៅអាស៊ីបូព៌ា នៅពុំទាន់បញ្ចប់នៅឡើយទេ ហើយកសិកម្មនៅតែរួមចំណែកស្រូបយកជិតពាក់កណ្ដាលនៃកម្លាំងពលកម្មនៅក្នុងអនុតំបន់នេះ ធៀបនឹងអត្រា ៥% នៅក្នុងប្រទេសជឿនលឿននានា។ ដើម្បីលើកកម្ពស់ស្ថានភាពប្រជាពលរដ្ឋនៅជនបទ ត្រូវផ្ដល់ការងារជាច្រើនបន្ថែមទៀតសម្រាប់អ្នកទាំងនោះ នៅក្នុងវិស័យសេដ្ឋកិច្ចនានាដែលទំនើប

ជាងបច្ចុប្បន្ន និងត្រូវផ្ដល់ការយកចិត្តទុកដាក់បន្ថែមទៀតដល់វិស័យកសិកម្ម។

នៅអាស៊ីខាងត្បូង ផលប៉ះពាល់នៃសេរីភាវូបនីយកម្មពុំសូវមានភាពច្បាស់លាស់ឡើយ។ ជាក់ស្ដែង កំណើនសេដ្ឋកិច្ចមានភាពរអាក់រអួលខ្លះៗក្នុងរវាងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០។ តារាង ២.៦ បង្ហាញថា សូម្បីតែផ្នែកកម្មន្តសាលក៏ថយល្បឿនដែរ មួយផ្នែកដោយសារការនាំចូលនៃផលិតផលឧស្សាហកម្ម ដូចជា ស្បែក និងស្បែកជើង ផលិតផលឈើ គីមីឧស្សាកម្ម ផលិតផលកៅស៊ូ ផលិតផលផ្លាស្ទិក ក្រដាស និងផលិតផលក្រដាស ផលិតផលកែវ ផលិតផលសរសៃលោហៈ និងបរិក្ខារបម្រើការវិជ្ជាជីវៈ និងវិទ្យាសាស្ត្រ។ កសិកម្មក៏បានទទួលរងគ្រោះនៅក្នុងរយៈពេលនេះដែរ ដោយមានកំណើនតិចជាង ៣%។ ភាគខ្លះនៃកំនើននេះបានកើតឡើងដោយសារសេរីភាវូបនីយកម្ម និងការបើកចំហទីផ្សារកសិផលដែលធ្វើឱ្យមានកំណើនការនាំចូលកសិផលជិត ១៥០%។

តារាង ២.៦

អត្រាកំនើនតាមវិស័យ និងអត្រាកំនើន GDP

| | ទសវត្សរ៍ឆ្នាំ ១៩៨០ | ទសវត្សរ៍ឆ្នាំ ១៩៩០ |
|---|---|---|
| *អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក* | | |
| កសិកម្ម | ៥.១ | ៣.៣ |
| ឧស្សាហកម្ម | ៨.០ | ១១.០ |
| (កម្មន្តសាល) | (៨.៦) | (១០.៩) |
| សេវាកម្ម | ៨.៩ | ៧.១ |
| ផលទុនក្នុងស្រុកសរុប (GDP) | ៧.៤ | ៨.២ |
| *អាស៊ីខាងត្បូង* | | |
| កសិកម្ម | ៣.៥ | ២.៩ |
| ឧស្សាហកម្ម | ៧.០ | ៥.៦ |
| (កម្មន្តសាល) | (៧.៤) | (៥.៩) |
| សេវាកម្ម | ៦.២ | ៦.៨ |
| ផលទុនក្នុងស្រុកសរុប (GDP) | ៥.៧ | ៥.២ |

**ប្រភព: ធនាគារពិភពលោក ២០០៥**

## ឥទ្ធិពលនៃបញ្ហាថាមពល

ប្រទេសទាំងអស់ត្រូវពឹងផ្អែកលើពាណិជ្ជកម្ម ដើម្បីអាចទូទាត់ការចំណាយសម្រាប់នាំចូល ហើយប្រទេសទាំងនោះភាគច្រើន ជាពិសេសប្រទេសក្រីក្រជាងគេ ត្រូវចំណាយច្រើនជាងគេលើប្រេង។ ថ្លៃប្រេងនៅលើពិភពលោក បានកើនឡើងយ៉ាងខ្លាំង។ នៅឆ្នាំ ២០០២ ថ្លៃប្រេងកាតឆៅនៅកន្លែងផលិតមានជាមធ្យម ២៥ដុល្លារក្នុងមួយធុង។ នៅឆ្នាំ ២០០៣ ថ្លៃនេះបានកើនឡើងដល់ ២៩ដុល្លារ នៅឆ្នាំ ២០០៤ ដល់ ៤៣ដុល្លារ ហើយនៅពាក់កណ្ដាលឆ្នាំ ២០០៦ បានឈានទៅដល់អត្រា ៧៥ដុល្លារ។ តើការកើនឡើងបែបនេះ មានឥទ្ធិពលបែបណា? ការបកស្រាយប្រកបដោយទុទិដ្ឋិនិយម និងអ្នកបំភ័យ បានបង្ហាញថា ពិភពលោកបានឈានជិតដល់ចំណុច "កំពូលនៃប្រេងកាត" ហើយដែលផលិតកម្មអតិបរមាមុនផ្ដល់ជាផលសម្រេច បានថយចុះនៅពេលដែលធនធានត្រូវបាត់បង់។ ទស្សនៈរបស់អ្នកសុទិដ្ឋិនិយម បង្ហាញថា ក្រោយកែតម្រូវថ្លៃប្រេងដែលបានកំណត់ដោយឆ្លុះបញ្ចាំងពីការប្រែប្រួលថ្លៃទំនិញដទៃផ្សេងទៀត តួលេខថ្មីនេះបង្ហាញថា ថ្លៃប្រេងនៅតែមានកម្រិតទាបបង្គួរនៅឡើយទេ។ ឧទាហរណ៍នៅឆ្នាំ ១៩៨០ ថ្លៃប្រេងឆៅ ពីអារ៉ាប់គឺ ៣៦ដុល្លារក្នុងមួយធុង ប៉ុន្តែក្រោយកែតម្រូវតាមអត្រាអតិផរណាឆ្នាំ ២០០៥ ថ្លៃនេះនឹងឡើងដល់ ៨៤ដុល្លារ/ធុង ដូច្នេះមានកម្រិតខ្ពស់ជាងថ្លៃជាក់ស្ដែងទៅទៀត។

ប៉ុន្តែ ប្រសិនបើថ្លៃជាក់ស្ដែងបច្ចុប្បន្ននៅទាបជាងថ្លៃខ្ពស់បំផុតកាលពីមុន បានន័យថាកំណើនថ្លៃបច្ចុប្បន្ននឹងមានឥទ្ធិពលធ្ងន់ធ្ងរ។ ជារួម តំបន់អាស៊ី-ប៉ាស៊ីហ្វិកនៅតែជាអ្នក

នាំចូលសុទ្ធនូវផលិតផលប្រេង ហើយកំណើនឆាប់រហ័សជាពិសេសនៅក្នុងវិស័យកម្មន្តសាល បាននាំឱ្យមានកំណើនជាបន្តបន្ទាប់នៃតម្រូវការប្រេង។ ជាលទ្ធផល ទោះបីថ្លៃប្រេងខ្ពស់ក៏ដោយ ប្រទេសជាច្រើននៅក្នុងតំបន់នេះបានបង្កើនយ៉ាងខ្លាំងនូវការនាំចូលប្រេង តាំងតែពីឆ្នាំ ២00៤ មកម្លេះ។ មានតែប្រទេសមួយចំនួនតូចដែលមានការលូតលាស់រហ័សតែប៉ុណ្ណោះ ដូចជាប្រទេសម៉ាឡេស៊ី ហ្វីលីពីន និងសិង្ហបុរី ដែលបានចាយតិចលើឥន្ធនៈនៅពាក់កណ្តាលចុងទសវត្សរ៍ ឆ្នាំ ១៩៩០ កន្លងមកនេះ។

មិនដូចជានៅពេលមានវិបត្តិប្រេងលើកមុននោះទេ នៅពេលនេះ ប្រទេសជាច្រើនមានលទ្ធភាពបំពេញការចំណាយលើការនាំចូលប្រេងដែលមានថ្លៃខ្ពស់ ដោយពុំមានការលំបាកជាដុំកំភួនឡើយ។ ឧទាហរណ៍ ប្រទេសចិនអាចនៅតែបន្តប្រើប្រាស់ប្រេងយ៉ាងច្រើន ដោយសារកំណើនជាបន្តបន្ទាប់នូវចំណូលបានពីការនាំចេញ។ ប្រទេសឥណ្ឌាគ្រប់គ្រងស្ថានការណ៍នេះ ដោយសារប្រាក់ចំណូលដ៏ច្រើនទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន។ ប្រទេសផ្សេងទៀត អាចបន្តរក្សាកំណើនបានដោយសារមានជំនួយនៃប្រាក់ផ្ញើមកពីកម្មករធ្វើការនៅក្រៅប្រទេស។ ប្រទេសអ្នកមានក៏មានលទ្ធភាពប្រសើរជាងផងដែរក្នុងការប្រើប្រាស់ទ្រព្យសកម្ម ក្រោមរូបភាពជាបំណុលផលប័ត្រនៃការវិនិយោគ ឬការវិនិយោគបរទេសដោយផ្ទាល់ ដើម្បីទប់ទល់នឹងឥទ្ធិពលនៃកំណើនថ្លៃប្រេង។ ជាលទ្ធផល តម្រូវការប្រេងនៅតែមានកម្រិតខ្ពស់ ហើយថ្លៃប្រេងនៅតែមានកម្រិតខ្ពស់ផងដែរ។

ប៉ុន្តែ ប្រទេសក្រីក្រជាងគេ ជាពិសេស LDCs ដែលគ្មានលទ្ធភាពប្រើប្រាស់ឥណទានបរទេស កំពុងប្រឈមនឹងការប្រែប្រួលខ្លាំងនៃថ្លៃប្រេង ហើយអាចនាំចូលប្រេងតែតាមរយៈការលក់ផលិតផលរបស់ខ្លួនកាន់តែច្រើននៅលើទីផ្សារពិភពលោកប៉ុណ្ណោះ (ប្រអប់ ២.៣)។ ស្ថានភាពនេះ តម្រូវឱ្យរកវិធីដោះស្រាយជាបន្ទាន់ ដើម្បីធានាថា ការធ្វើពាណិជ្ជកម្មកើតឡើងតាមរបៀបដែលជម្រុញការអភិវឌ្ឍមនុស្សផងដែរ។

## ឥទ្ធិពលទៅលើការអភិវឌ្ឍមនុស្ស

តើកំណើនឆាប់រហ័សនៃពាណិជ្ជកម្មមានឥទ្ធិពលបែបណាទៅលើការអភិវឌ្ឍមនុស្ស? ប្រការនេះលំបាកនឹងវាយតម្លៃណាស់នៅទូទាំងតំបន់ធំទូលាយបែបនេះ ដែលមានប្រជាពលរដ្ឋជិត ៦0% នៃចំនួនប្រជាពលរដ្ឋសរុបនៅលើពិភពលោក។ តំបន់នេះក៏មានភាពប្លែកគ្នាខ្លាំងដែរ ដោយសារភាពផ្ទុយគ្នាយ៉ាងខ្លាំងនៃទំហំទ្រព្យសម្បត្តិ។ ប្រាក់ចំណូលរបស់បុគ្គលម្នាក់ៗ នៅក្នុងប្រទេសដែលមានជាងគេ គឺច្រើនជាង ៣0 ដងនៃប្រាក់ចំណូលនៅក្នុងប្រទេសក្រីក្រជាងគេ។ នៅក្នុងប្រទេសទាំងនេះក៏មានភាពផ្ទុយគ្នាខ្លាំងផងដែរនូវប្រាក់ចំណូលនិងគុណភាពនៃការរស់នៅរវាងអ្នកមាននិងអ្នកក្រជាងគេ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសមួយចំនួនទំនងជានៅមាននិន្នាការរួមខ្លះៗនៅឡើយ។

## កំណើនវិសមភាព

មានសេចក្តីសន្និដ្ឋានទូទៅបំផុតថា ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើននៅក្នុងតំបន់នេះ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៩0 ការចូលរួមកាន់តែសកម្មនៅក្នុងទីផ្សារអន្តរជាតិ បានកើតឡើងទន្ទឹមនឹងកំណើនវិសមភាពនៃប្រាក់ចំណូល។ ប្រការនេះបង្ហាញច្បាស់ពីនិន្នាការនៃវិធានការវិសមភាពធម្មតា ពោលគឺមេគុណ Gini ដែលប្រែប្រួលពីសូន្យ (សមភាពដាច់ខាត) ដល់ ១ (បុគ្គលម្នាក់មានអ្វីៗទាំងអស់)។ សេដ្ឋកិច្ចដែលលូតលាស់រហ័សជាងគេ ដូចជា ប្រទេសចិនមានកំណើនវិសមភាពយ៉ាងខ្លាំង ប៉ុន្តែ ប្រទេសខ្លះ ដូចជា សាធារណរដ្ឋកូរ៉េ និង ថៃ

*ការបំប្លែងរចនាសម្ព័ន្ធសេដ្ឋកិច្ចនៅអាស៊ីបូព៌ានៅពុំទាន់បញ្ចប់នៅឡើយទេ ហើយកសិកម្មនៅតែរួមចំណែកស្រូបយកជិតពាក់កណ្តាលនៃចំនួនកម្លាំងពលកម្មសរុប*

*ការចូលរួមកាន់តែសកម្មនៅក្នុងទីផ្សារអន្តរជាតិបានកើតឡើងទន្ទឹមនឹងកំណើនវិសមភាពនៃប្រាក់ចំណូល*

មានអត្រាវិសមភាពថយចុះទៅវិញ (តារាង ២.៧)។

## ភាពក្រីក្រ

ទោះបីមានកំណើនវិសមភាពក្តី ភាពក្រីក្រក៏បានថយចុះយ៉ាងខ្លាំងផងដែរ។ រវាងឆ្នាំ ១៩៩០ និង ២០០១ ចំនួនប្រជាជនដែលរស់នៅដោយមានចំណូលតិចជាង ១ដុល្លារក្នុងមួយថ្ងៃ បានថយចុះជិតមួយភាគបួននៃមួយពាន់លាន។ ប្រការនេះច្រើនតែទាក់ទងនឹងកំណើនជាប់ជានិច្ចនៅក្នុងប្រទេសចិន និងសំទុះកំណើននៅប្រទេសឥណ្ឌា។ ប៉ុន្តែ ភាពជឿនលឿនបែបនេះ ត្រូវតែរីកដាលទៅទូទាំងអនុតំបន់នានា។ នៅក្នុងអំឡុងពេលដូចគ្នា សមាមាត្រចំនួនប្រជាជនរស់នៅដោយសារចំណូលតិចជាង ១ដុល្លារក្នុងមួយថ្ងៃ បានថយចុះពី ៤១% មក ៣១% នៅអាស៊ីខាងត្បូង និងពី ៣០% មក ១៥% នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។[៩]

តារាង ២.៧

និន្នាការនៃមេគុណ Gini ទសវត្សរ៍ឆ្នាំ ១៩៦០ ដល់ ១៩៩០

| | មធ្យម ១៩៦០ | មធ្យម ១៩៧០ | មធ្យម ១៩៨០ | មធ្យម ១៩៩០ | ចុង ១៩៩០ |
|---|---|---|---|---|---|
| *អាស៊ីភាគឦសាន* | | | | | |
| ចិន | - | - | 0.៣១៥ (i) | *0.៣៣៥ (i)* | *0.៤០៣ (i)* |
| សាធារណរដ្ឋកូរ៉េ | 0.៣២៣ (i) | 0.៣៦១ (i) | 0.៣៥៩ (i) | 0.២៩៤ (i) | 0.៣០០ (i) |
| *អាស៊ីអាគ្នេយ៍* | | | | | |
| ឥណ្ឌូណេស៊ី | - | - | 0.៣១៧ (c) | 0.៣១៧ (c) | 0.៣១៧ (c) |
| ឡាវ | - | - | - | 0.២៩៦ (c) | 0.៣៦៥ (c) |
| ម៉ាឡេស៊ី | - | 0.៥១៥ (i) | 0.៤៦៩ (i) | 0.៤២៩ (i) | 0.៤៤៣ (i) |
| ហ្វីលីពីន | 0.៥០៥ (i) | 0.៤៩៤ (i) | 0.៤០៩ (i) | 0.៤៣៨ (i) | 0.៤៦២ (i) |
| ថៃ | 0.៤២០ (i) | 0.៤១៧ (i) | 0.៤៦០ (i) | 0.៤៨៨ (i) | 0.៤៣២ (i) |
| វៀតណាម | - | - | - | 0.៣៥៧ (c) | 0.៣៦១ (c) |
| *អាស៊ីខាងត្បូងនិងពាយព្យ* | | | | | |
| បង់ក្លាដេស | 0.៣៥៨ (i) | 0.៣៧៥ (i) | 0.២៦០ (c) | 0.២៦៦ (c) | 0.៣១៥ (c) |
| ឥណ្ឌា | 0.៣០៥ (c) | 0.២៩៧ (c) | 0.២៩៣ (c) | 0.៣១៥ (c) | 0.៣៧៨ (c) |
| ប៉ាគីស្ថាន | 0.៣៥៩ (i) | 0.៣៤៦ (i) | 0.៣៥០ (i) | 0.៣៤៨ (i) | 0.៤១០ (i) |
| ស្រីលង្កា | 0.៤០៧ (i) | 0.៣៨៨ (i) | 0.៤៤៧ (i) | 0.៣០១ (c) | 0.៣៤៤ (c) |

សម្គាល់ : "i" = ទិន្នន័យប្រាក់ចំណូល "c" ទិន្នន័យនៃការប្រើប្រាស់។ សន្ទស្សន៍ស៊េរីនៃ Gini អាចប្រៀបធៀបគ្នាបានតែកាលណាមានការគណនាប្រាក់ចំណូល និងទិន្នន័យនៃការប្រើប្រាស់ដាច់ដោយឡែកពីគ្នា។

**ប្រភព: Adapted from ADB ២០០១ និង ធនាគារពិភពលោក ២០០៥**

ប៉ុន្តែ ការប្រែប្រួលយ៉ាងឆាប់រហ័សបំផុតប្រហែលជាបានកើតឡើងនៅអាស៊ីភាគឦសាន ដែលកំណើនដោយសារការនាំចេញបានកើតឡើងទន្ទឹមនឹងការថយចុះយ៉ាងខ្លាំងនៃភាពក្រីក្រ និងកំណែលំអជាទូទៅនៃសមភាពក្នុងការរស់នៅ។ រវាងឆ្នាំ ១៩៩០ និង ២០០១ សមាមាត្រចំនួនប្រជាជនរស់នៅក្នុងភាពក្រីក្របំផុត ដែលគណនាដោយអនុបាតនៃចំនួនមនុស្ស បានថយចុះពី ៣៣% មកត្រឹម ១៧%។ ដូច្នេះ អាស៊ីបូព៌ាលេចធ្លោជាករណីជោគជ័យនៃកំណើនខ្ពស់ ពាណិជ្ជកម្មរីកចម្រើនខ្លាំង និងការអភិវឌ្ឍមនុស្សកម្រិតខ្ពស់។ ភាពក្រីក្រនៃប្រាក់ចំណូលនៅអាស៊ីអាគ្នេយ៍ក៏ថយចុះផងដែរ ទោះបីត្រឹមកម្រិតតិចតួចក្តី ប៉ុន្តែមានតែប្រទេសម៉ាឡេស៊ីទេ ដែលអនុវត្តបានប្រសើរជាងគេ (ប្រអប់ ២.៤)។

ស្ថានភាពនេះមានការខុសគ្នានៅអាស៊ីខាងត្បូង។ នៅក្នុងអំឡុងពេលនេះ អត្រាពាណិជ្ជកម្ម និងអត្រាកំណើនជាមធ្យមមានកម្រិតទាប និងយឺតយ៉ាវជាងផងដែរ។ ភាពក្រីក្រខាងប្រាក់ចំណូលពិតជាបានធ្លាក់ចុះ ប៉ុន្តែប្រព្រឹត្តទៅយឺតៗ និងនៅមានកម្រិតខ្ពស់នៅឡើយ (រូបទី ២.៧)។ នេះជាការចង្អុលបង្ហាញពីសារៈសំខាន់នៃកំណើន ដើម្បីកាត់បន្ថយភាពក្រីក្រ។ កំណើនអាចពុំមានកម្រិតគ្រប់គ្រាន់ ដើម្បីអាចកាត់បន្ថយភាពក្រីក្របានឡើយ ទោះបីវាអាចមិនមែនជាលក្ខខណ្ឌចាំបាច់ដំបូងក៏ដោយ។

ប្រអប់ ២.៤

### ពាណិជ្ជកម្ម និងកំណើននៅក្នុងការធ្លាក់ចុះយ៉ាងខ្លាំងនៃភាពក្រីក្រក្នុងប្រទេសម៉ាឡេស៊ី

ម៉ាឡេស៊ីជាប្រទេសគំរូមួយដែលសេរីភាវូបនីយកម្ម ទន្ទឹមនឹងគោលនយោបាយក្នុងប្រទេសដែលគាំទ្រអ្នកក្រីក្រ បាននាំឱ្យមានការកាត់បន្ថយភាពក្រីក្រគួរឱ្យកត់សម្គាល់។ ប្រទេសម៉ាឡេស៊ីបានអនុម័តយុទ្ធសាស្ត្រទូលំទូលាយ និងទាក់ទងគ្នាចំនួនពីរដើម្បីលុបបំបាត់ភាពក្រីក្រ។ ការយកចិត្តទុកដាក់ទីមួយផ្តោតលើកំណើនសេដ្ឋកិច្ចតាមរយៈការប្រកាន់យកគោលនយោបាយពាណិជ្ជកម្មបើកចំហ។ ទីពីរ គូសបញ្ជាក់ពីតួនាទីរបស់គោលនយោបាយសាធារណៈក្នុងការលើកកម្ពស់យុទ្ធសាស្ត្រកំណើនដែលគាំទ្រជនក្រីក្រ ដែលផ្តល់ហេដ្ឋារចនាសម្ព័ន្ធសង្គម និងរូបវន្តចាំបាច់សម្រាប់ធ្វើឱ្យមានកំណើនសេដ្ឋកិច្ច និងជួយដោយប្រយោលដល់គោលដៅជាក់លាក់ក្នុងចំណោមក្រុមដែលមានអត្រាភាពក្រីក្រកម្រិតខ្ពស់ជាងគេ។

ប្រទេសម៉ាឡេស៊ីបានធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មរបស់ខ្លួនជាបន្តបន្ទាប់ និងសម្រេចបានកំណើនសេដ្ឋកិច្ច ទោះបីអត្រានៃកំណើននេះប្រែប្រួលក៏ដោយ។ ជាមធ្យម នៅក្នុងអំឡុងឆ្នាំ ១៩៧០-២០០៥ សេដ្ឋកិច្ចប្រទេសម៉ាឡេស៊ីបានកើនជាក់ស្តែងច្រើនជាង ៦% ក្នុងមួយឆ្នាំ។ ប្រការនេះបានធ្វើឱ្យប្រទេសនេះ ផ្លាស់ប្តូរពីការនាំចេញដែលផ្អែកលើវត្ថុធាតុដើមទៅពឹងផ្អែកលើកម្មន្តសាល។ វិស័យដែលមានភាពរីកចម្រើនជាងគេ គឺអេឡិចត្រូនិក ហើយប្រទេសម៉ាឡេស៊ី បច្ចុប្បន្នជាប្រទេសដែលនាំចេញចម្បងនៅលើពិភពលោកនូវបរិក្ខារសីមីកុងឌុចទ័រ និងគ្រឿងអេឡិចត្រូនិក។

ការប្រែប្រួលនៃតម្រូវការនៅលើពិភពលោកនិងការធ្លាក់ថ្លៃ បាននាំឱ្យមានការបង្វែរធនធាននៅក្នុងវិស័យកសិកម្មពីដំណាំកៅស៊ូ ដែលបានបាត់បង់ភាពប្រកួតប្រជែងរបស់ខ្លួន ទៅជាដំណាំដូងប្រេងដែលមានកំណើននៃតម្រូវការ។ ការគ្រប់គ្រងកសិដ្ឋានតាមបែបទំនើប តាមរយៈប្រព័ន្ធអភិវឌ្ឍន៍ដីធ្លីបានជួយធ្វើឱ្យមានទំនើបកម្ម និងការផ្លាស់ប្តូរទ្រង់ទ្រាយធំនៅក្នុងវិស័យកសិកម្ម។ ទន្ទឹមនឹងកំណើនប្រាក់ចំណូលនៅជនបទ អាំងស៊ីដង់នៃភាពក្រីក្រនៅជនបទក៏បានធ្លាក់ចុះ យ៉ាងខ្លាំងផងដែរ។

តម្រូវការអន្តរជាតិនូវផលិតផលអតិពលកម្មបានបម្លែងវិស័យកម្មន្តសាលនៃប្រទេសម៉ាឡេស៊ី តាមរយៈកំណើនឧស្សាហកម្មដែលផ្តោតលើការនាំចេញ។ ការវិនិយោគដោយផ្ទាល់ពីបរទេសដែលបានទាក់ទាញដោយហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងការលើកទឹកចិត្តរបស់រដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី បានរួមចំណែកគួរឱ្យកត់សម្គាល់ចំពោះការអភិវឌ្ឍឧស្សាហកម្ម ដែលផ្តោតលើការនាំចេញ ហើយដែលអេឡិចត្រូនិកជាផ្នែកសំខាន់ជាងគេ។ អត្រាប្តូរប្រាក់មានស្ថិរភាព ដោយពុំមានការឱ្យតម្លៃខ្ពស់ជ្រុលទៅលើរូបិយប័ណ្ណជាតិឡើយ។ ឧស្សាហកម្មដែលផ្តោតលើការនាំចេញ និងដែលកើនឡើងស្របនឹងកំណើនកាលានុវត្តភាពការងារក្នុងវិស័យទំនើប ជាពិសេសសម្រាប់ស្ត្រី និងប្រាក់ចំណូលដែលកើនឡើង បានរួមវិភាគទានយ៉ាងសំខាន់ចំពោះការកាត់បន្ថយភាពក្រីក្រនៅក្នុងទីក្រុង។

នៅឆ្នាំ ១៩៧០ ប្រមាណពាក់កណ្តាលនៃចំនួនគ្រួសារដែលមានជនជាតិចម្រុះនៅក្នុងប្រទេសម៉ាឡេស៊ីគឺជាអ្នកក្រ។ ប៉ុន្តែនៅឆ្នាំ ១៩៩០ សមាមាត្រនេះបានថយចុះមកត្រឹម ១៧% ហើយនៅឆ្នាំ ២០០២ បានថយចុះមកនៅត្រឹម ៥% តែប៉ុណ្ណោះ។ លើសពីនេះ មិនដូចនៅប្រទេសផ្សេងទៀតឡើយ ការកាត់បន្ថយភាពក្រីក្របានធ្វើឡើងទន្ទឹមនឹងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូលនៅក្នុងអំឡុងឆ្នាំ ១៩៧០-២០០២ ដែលមេគុណ Gini បានធ្លាក់ចុះពី ០.៥២ នៅឆ្នាំ ១៩៧៦ មកត្រឹម ០.៤៦ នៅឆ្នាំ ២០០២។

បទពិសោធរបស់ប្រទេសម៉ាឡេស៊ីបានបង្ហាញពីកំណើនសេដ្ឋកិច្ចរយៈពេលវែងសម្រាប់ទាំងអស់គ្នា ដោយសារសេរីភាវូបនីយកម្ម ទោះបីមានអ្នកឈ្នះ និងអ្នកចាញ់រយៈពេលខ្លី ហើយអ្នកក្រីក្រអាចងាយរងគ្រោះក៏ដោយ។ ដូច្នេះ ចាំបាច់ត្រូវតែបង្កើតគោលនយោបាយក្នុងស្រុក ដើម្បីជួយអ្នកក្រីក្រ ដោះស្រាយការចំណាយលើការផ្លាស់ប្តូរលើកំណែទម្រង់ និងដើម្បីទទួលប្រយោជន៍ពីរបបពាណិជ្ជកម្មថ្មី និងដែលមានលក្ខណៈបើកចំហ។ ដូច្នេះ សេរីភាវូបនីយកម្មពាណិជ្ជកម្មនៅក្នុងប្រទេសម៉ាឡេស៊ី កើតមានទន្ទឹមនឹងគោលនយោបាយសង្គមជាក់ស្តែង និងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជាការវិនិយោគលើមូលធនមនុស្ស ជាពិសេសលើសុខភាព ការអប់រំ និងការផ្តល់អំណាចដល់ស្ត្រីផងដែរ។

**ប្រភព: UNDP Malaysia ២០០៦**




រូបទី ២.៧៖ ភាពក្រីក្រនៃប្រាក់ចំណូល ឆ្នាំ ១៩៨១-២០០១ % នៃចំនួនប្រជាជនរស់នៅដោយចំណូលតិចជាង ១$ ក្នុង១ថ្ងៃ

ប្រភព ៖ ធនាគារពិភពលោក ២០០៥

*នៅពេលដែលអាស៊ីខាងត្បូង និងអាស៊ីបូព៌ាជ្រើសរើសយកផ្លូវខុសគ្នា ពួកគេអាចឈានដល់គោលដៅដូចគ្នា*

ប៉ុន្តែនៅមានលក្ខខណ្ឌមួយ អាចភាពផ្ទុយគ្នារវាងអនុតំបន់ពីរ។ ជាពិសេស គួរតែមានការគូសបញ្ជាក់ថា កំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍមនុស្ស ទាក់ទងគ្នាតាមទិសពីរ។ ដូច្នេះនៅពេលដែលអាស៊ីខាងត្បូងនិងអាស៊ីបូព៌ាជ្រើសរើសយកផ្លូវខុសគ្នា ពួកគេអាចឈានដល់គោលដៅដូចគ្នា។

អាស៊ីខាងត្បូង ជាពិសេសនៅមុនទសវត្សរ៍ឆ្នាំ ១៩៩០ ដោយចាប់ផ្តើមពីកម្រិតទាបខ្លាំងនៃការអភិវឌ្ឍមនុស្ស និងការប្រកាន់យកយុទ្ធសាស្ត្រនានា បានផ្អែកជាចម្បងលើកិច្ចការពារទីផ្សារក្នុងស្រុក តាមរយៈអត្រាពន្ធ និងការកំហិតលើបរិមាណនាំចូល។ ការធ្វើបែបនេះបាននាំឱ្យមានកំណើនយឺតជាង។ វាក៏នាំឱ្យការអភិវឌ្ឍមនុស្សប្រព្រឹត្តទៅយឺតផងដែរ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ទង្វើបែបនេះបានជួយធានាថា សេរីភាវូបនីយកម្មនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និងសំទុះសមាហរណកម្ម នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ បានកើតឡើងទន្ទឹមជាមួយនិន្នាការនៃអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ជាង។

ម្យ៉ាងវិញទៀត អាស៊ីបូព៌ាបានចាប់ផ្តើមដោយកម្រិតអភិវឌ្ឍន៍ដែលមានអំណោយផលច្រើនជាង ជាពិសេស មានប្រជាពលរដ្ឋដែលបានទទួលការអប់រំ និងមានលទ្ធភាពក្នុងការទាញយកប្រយោជន៍ពីកត្តានេះដើម្បីសម្រេចកំណើនសេដ្ឋកិច្ចដោយផ្អែកលើការនាំចេញ។

បទពិសោធទាំងពីរគូសបញ្ជាក់ពីកត្តាដែលថា លក្ខខណ្ឌអភិវឌ្ឍន៍មនុស្ស ពោលគឺ ការអប់រំ ការរស់នៅដោយមានអាយុវែងប្រកបដោយសុខភាពល្អ កាលានុវត្តភាពដូចគ្នា និងវិស័យសាធារណៈរឹងមាំ ព្រមទាំងគាំទ្រការអភិវឌ្ឍ រួមទាំងអភិបាលកិច្ចល្អ គឺជាលក្ខខណ្ឌដើមដំបូង មិនត្រឹមតែសម្រាប់កំណើនសេដ្ឋកិច្ចខ្លួនឯងតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានឥទ្ធិពលទៅលើទម្រង់ និងគុណភាពនៃកំណើន និងអាចរួមចំណែកជាបន្ថែមទៀតចំពោះការបង្កើនគុណភាពនៃការរស់នៅ និងពង្រីកជម្រើសនានារបស់ប្រជាជនថែមទៀតផង។

## បទពិសោធពីប្រទេសអភិវឌ្ឍន៍តិចតួច

ទោះជាយ៉ាងណាក៏ដោយ ភាពរីកចម្រើននៅក្នុងប្រទេសដែលមានការអភិវឌ្ឍតិចតួច (LDCs) មានភាពយឺតយ៉ាវជាង។ ទោះបីមានកំណើនខាងពាណិជ្ជកម្មក្តី LDCsជាច្រើនបានទទួលជោគជ័យតិចតួចជាងក្នុងការកាត់បន្ថយភាពក្រីក្រ។




រូបទី ២.៨៖ LDCs និងប្រទេសកំពុងអភិវឌ្ឍន៍ពាណិជ្ជកម្មតិចជាង % នៃ GDP ១៩៧០-២០០២

ប្រភព ៖ ធនាគារពិភពលោក ២០០៥

ដូចប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងតំបន់នេះដែរ ពួកគេបានបង្កើនពាណិជ្ជកម្មសមាមាត្រទៅនឹង GDP ដែលបានកើនចាប់ពី ២០% នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ដល់ ៣៣% នៅក្នុងឆ្នាំ ១៩៩០-២០០២ (រូបទី ២.៨)។ លើសពីនេះ ការពង្រីកពាណិជ្ជកម្មបែបនេះ បានធ្វើឱ្យ LDCs នៅអាស៊ី-ប៉ាស៊ីហ្វិក សម្រេចបានកំណើនឆាប់រហ័សជាង LDCs នៅក្នុងតំបន់ផ្សេងទៀត (រូបទី ២.៩) និងបានបង្រួមគម្លាតនៃការអភិវឌ្ឍមនុស្សជាមួយប្រទេសកំពុងអភិវឌ្ឍន៍នានានៅក្នុងតំបន់នេះ ទោះបីគម្លាតគ្នានេះនៅមានច្រើនក៏ដោយ។ យ៉ាងណាក៏ដោយ អត្រាភាពក្រីក្រនៅក្នុង LDCs ជាច្រើន មិនបានធ្លាក់ចុះឆាប់រហ័សនោះទេ ចំណែកនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៃតំបន់នេះ សមាមាត្រនៃចំនួនប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ (១ដុល្លារ/ថ្ងៃ) មាន ២២% សម្រាប់ LDCs អត្រានេះមាន ៣៨%។

## អសន្តិសុខស្បៀង

ទោះបីអត្រាភាពក្រីក្របានថយចុះក្តី តំបន់នេះនៅតែបន្តរងគ្រោះយ៉ាងធ្ងន់ធ្ងរពីការបាត់បង់សិទ្ធិ។ ឧទាហរណ៍ ប្រការនេះបង្ហាញយ៉ាងច្បាស់ទាក់ទងនឹងការបរិភោគអាហារ។ សេរីភាវូបនីយកម្មទីផ្សារកសិផលប្រហែលជាបានជួយកាត់បន្ថយថ្លៃស្បៀងអាហារ ជាពិសេសស្បៀងដែលផលិតដោយមានការឧបត្ថម្ភធននៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។ ប៉ុន្តែប្រការនេះពុំទំនងជានាំឱ្យមានការកែលំអជាប់លាប់ទៅលើសន្តិសុខស្បៀងឡើយ។ ឥឡូវមានប្រទេសកាន់តែច្រើនឡើងខ្វះខាតស្បៀង (ប្រអប់២.២) ហើយនៅអាស៊ីមានប្រជាជនអត់ឃ្លានចំនួនច្រើនជាងនៅតំបន់ណាៗទាំងអស់លើពិភពលោក ដោយចំនួននេះមានច្រើនជាង ៥០០លាននាក់នៅឆ្នាំ២០០២។[១០] នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ចំនួននេះបានកើនឡើង ហើយ




រូបទី ២.៩: អត្រាកំណើនជាមធ្យមប្រចាំឆ្នាំរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច ១៩៧០-២០០២

ប្រភព : ធនាគារពិភពលោក ២០០៥

មនុស្សម្នាក់ក្នុងចំណោមប្រាំមួយនាក់ មិនបានទទួលអាហារូបត្ថម្ភគ្រប់គ្រាន់ឡើយ។[១១] នេះគឺដោយសារការរីកចម្រើនមានភាពយឺតយ៉ាវនៅប្រទេសចិន ថៃ និងវៀតណាម ហើយនៅក្នុងប្រទេសខ្លះ ការរីកចម្រើននៅដើមពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ កើតឡើងបញ្ច្រាសទិស ដូចជានៅឥណ្ឌា ឥណ្ឌូណេស៊ី និងប៉ាគីស្ថាន។[១២]

ការបាត់បង់អាហារគឺជាឧបសគ្គចំពោះកិច្ចប្រឹងប្រែងក្នុងការដោះស្រាយកង្វះអាហារូបត្ថម្ភ។ អសន្តិសុខស្បៀងប្រចាំគ្រួសារ គួបផ្សំជាមួយទម្លាប់បរិភោគអាហារមិនបានគ្រប់គ្រាន់ និងឥទ្ធិពលនៃភាពទន់ខ្សោយបណ្តាលពីជម្ងឺឆ្លង ធ្វើឱ្យកុមាររាប់លាននាក់ ពុំបានទទួលអាហារូបត្ថម្ភគ្រប់គ្រាន់ឡើយ និងត្រូវប្រឈមនឹងហានិភ័យខ្ពស់នៃការស្លាប់តាំងពីនៅក្មេង។ សមាមាត្រកុមារអាយុក្រោមប្រាំឆ្នាំដែលមិនគ្រប់ទម្ងន់ ត្រូវបានកាត់បន្ថយ។ នៅរវាងឆ្នាំ ១៩៩០ និង ២០០៣ នៅអាស៊ីខាងត្បូង សមាមាត្រនេះបានថយចុះពី ៥៣% មក ៤៧% នៅអាស៊ីអាគ្នេយ៍ពី ៣៨% មក ២៩% និង អាស៊ីភាគព្យសានពី ១៩% មក ១០%។[១៣] យ៉ាងណាក៏ដោយ ភាពរីកចម្រើននេះយឺតយ៉ាវខ្លាំងណាស់ ហើយក្នុងឆ្នាំ ២០០៣ កង្វះអាហារូបត្ថម្ភ

*ក្នុងឆ្នាំ ២០០៣ កង្វះអាហារូបត្ថម្ភ នៅអាស៊ីអាគ្នេយ៍ នៅតែមានអត្រាខ្ពស់ គឺជិតមួយភាគបីនៃ កុមារទាំងអស់ ចំណែក នៅអាស៊ីខាងត្បូងមាន ជិតពាក់កណ្ដាល នៃកុមារទាំងអស់*

នៅអាស៊ីអាគ្នេយ៍ នៅតែមានអត្រាខ្ពស់ គឺជិតមួយភាគបីនៃកុមារទាំងអស់ ចំណែកនៅអាស៊ីខាងត្បូងមានជិតពាក់កណ្ដាលនៃកុមារទាំងអស់។

## សុខភាព

មានការរំពឹងថា ពាណិជ្ជកម្មអាចជួយលើកកម្ពស់សុខភាព ដោយបង្កើនភាពមានការងារធ្វើនិងប្រាក់ចំណូល។ ឥឡូវ មានការគំរាមកំហែងបណ្ដាលពីកិច្ចព្រមព្រៀង TRIPS ដែលអាចធ្វើឱ្យថ្លៃថ្នាំកើនឡើង ទោះបីករណីនេះវាពុំទាន់ចូលជាធរមានក្ដី។ ជាទូទៅ អំឡុងពេលនៃកំណើនពាណិជ្ជកម្ម មានទន្ទឹមគ្នាជាមួយការលើកកម្ពស់សុខភាព ប៉ុន្តែ ករណីនេះទំនងជាមានភាពយឺតយ៉ាវនៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ។ ការរីកចម្រើនខ្លាំងក្លាបំផុត បានកើតមាននៅអាស៊ីអាគ្នេយ៍ ដែលក្នុងរវាងឆ្នាំ ១៩៩០ និង ២០០៣ អត្រាមរណៈភាពនៃកុមារអាយុក្រោមប្រាំឆ្នាំ ក្នុងចំណោម ១.០០០នាក់ បានថយចុះពី ៧៨ មក ៤៦។ នៅអាស៊ីភាគព្យសាន អត្រានេះបានធ្លាក់ចុះពី ៤៨ មក ៣៧។ ភាពរីកចម្រើនក៏មាននៅអាស៊ីខាងត្បូងផងដែរ ដែលអត្រានេះបានថយចុះពី ១២៦ មក ៩០ ប៉ុន្តែអាត្រានេះនៅខ្ពស់នៅឡើយ។ អនុតំបន់មួយចំនួនក៏មានអត្រាខ្ពស់នៃមរណភាពមាតាផងដែរ។ នៅឆ្នាំ ២០០០ អត្រានេះមាន ៥៤០ ក្នុងចំណោម ១០០.០០០ នៅអាស៊ីខាងត្បូង និង ២១០ នៅអាស៊ីបូព៌ា ប៉ុន្តែអត្រានេះមាន៥៥នៅអាស៊ីភាគព្យសាន។[១៤]

## ការអប់រំ

ពាណិជ្ជកម្មអាចត្រូវបានរំពឹងថានឹងជួយបង្កើនស្តង់ដានៃការអប់រំ ដោយផ្តល់ការលើកទឹកចិត្តបន្ថែមទៀតដល់ប្រជាជនឱ្យបង្កើនជំនាញរបស់ខ្លួន។ ប៉ុន្តែ ភាពរីកចម្រើនពុំមានគ្រប់គ្រាន់ឡើយ។ បញ្ហាធំបំផុតគឺនៅអាស៊ីខាងត្បូង ដែលកុមារម្នាក់ក្នុងចំណោមប្រាំនាក់ មិនបានចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សា។ តាំងពីឆ្នាំ ១៩៩០-៩១ នៅពេល ដែលអត្រាចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សាមាន ៧៣% អត្រានេះបានកើនឡើង ប៉ុន្តែនៅឆ្នាំ ២០០១-០២ បានឈានដល់ត្រឹមតែ ៧៩% តែប៉ុណ្ណោះ។ លើសពីនេះ ក៏មានសមាមាត្រខ្ពស់នៃកុមារដែលបានចុះឈ្មោះ ប៉ុន្តែមិនបានរៀនចប់ថ្នាក់បឋមសិក្សាផងដែរ។ អត្រាចុះឈ្មោះទំនងជាមានកម្រិតខ្ពស់នៅក្នុងអនុតំបន់ផ្សេងទៀត ប៉ុន្តែនៅទីនេះ អត្រានេះអាចធ្លាក់ចុះ។ ក្នុងរយៈពេលដូចគ្នានៅអាស៊ីបូព៌ា ការចុះឈ្មោះបានថយចុះពី ៩២% មក ៩១% ហើយ នៅអាស៊ីភាគព្យសាន បានថយចុះពី ៩៧% មក ៩៥%។[១៥] កុមារនៅក្នុងអនុតំបន់ទាំងពីរនេះ ក៏ប្រឹងប្រែងបានល្អផងដែរដើម្បីបញ្ចប់កម្រិតសិក្សា។ នៅអាស៊ីអាគ្នេយ៍ ៩០% នៃកុមារដែលបានចុះឈ្មោះចូលរៀន បានរៀនដល់ថ្នាក់ចុងក្រោយនៃកម្រិតបឋមសិក្សា ហើយនៅអាស៊ីភាគព្យសាន កុមារទាំងអស់ត្រូវបានរាយការណ៍ថាបានបញ្ចប់កម្រិតបឋមសិក្សា។[១៦]

ដូចនៅក្នុងកន្លែងផ្សេងទៀតជាច្រើនផងដែរ អត្រាកុមារីមានឱនភាពខ្លាំងជាងកុមារា។ នៅអាស៊ីខាងត្បូង រវាងឆ្នាំ ១៩៩០-៩១ និង២០០១-០២ ចំនួនកុមារីបានចុះឈ្មោះនៅកម្រិតបឋមសិក្សាក្នុងចំណោមកុមារា ១០០នាក់ បានកើនឡើងពី ៧៦ ទៅ ៨៥ ប៉ុន្តែនៅឃ្លាតគ្នាឆ្ងាយនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ អាស៊ីអាគ្នេយ៍ និង អាស៊ីភាគព្យសាន មានអត្រានេះគួរឱ្យចាប់អារម្មណ៍ជាង ដោយបានកើនឡើងពី ៩៦% ទៅ ៩៧% និងពី ៩៣% ទៅ ១០០%។ នៅថ្នាក់មធ្យមសិក្សា ស្ថានភាពនៃការចុះឈ្មោះមានភាពប្រហាក់ប្រហែលគ្នា។ នៅឆ្នាំ ២០០១-០២ សម្រាប់អនុតំបន់ទាំងបី ចំនួនកុមារីក្នុងចំណោមកុមារា ១០០នាក់ មាន ៧៩% សម្រាប់អាស៊ីខាងត្បូង ៩៨% អាស៊ីអាគ្នេយ៍ និង ៩៣% អាស៊ីភាគព្យសាន។[១៧]

ទោះជាយ៉ាងណាក៏ដោយ ឥទ្ធិពលដោយផ្ទាល់ខ្លះៗនៃពាណិជ្ជកម្មទៅលើការអប់រំ អាចឃើញមានច្រើនខាងផ្នែកឯកទេសកម្ម។ ឧទាហរណ៍ នៅឥណ្ឌា ដែលតម្រូវការបុគ្គលិកដើម្បីផ្គត់ផ្គង់សេវា បាននាំឱ្យមានកំណើនយ៉ាងខ្លាំងនូវគ្រឹះស្ថានបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា។

## យេនឌ័រ

ភាពខុសគ្នាខាងយេនឌ័រដែលចាប់ផ្តើមនៅ

ប្រអប់ ២.៥

### ការរួមបញ្ចូលស្ត្រីទៅក្នុងសកលភាវូបនីយកម្ម

*ការរួមវិភាគទានពិសេសពី Ela R. Bhatt ស្ថាបនិកនៃសមាគមស្ត្រីបម្រើខ្លួនឯង (SEWA), Ahmedabad ប្រទេសឥណ្ឌា*

ហេតុអ្វីស្ត្រីមិនត្រូវបានរួមបញ្ចូលទៅក្នុងដំណើរការសកលភាវូបនីយកម្ម ដែលគ្របដណ្តប់មនុស្សគ្រប់គ្នា និងនៅគ្រប់ទីកន្លែង? ហេតុផលមួយគឺថាស្ត្រីក្រីក្ររស់នៅកន្លែងដាច់ឆ្ងាយពីគ្នា។ ពួកគេរស់នៅរាយប៉ាយទូទាំងជនបទ និងទីក្រុង គ្របដណ្តប់វិស័យនានានៃសេដ្ឋកិច្ចនៅគ្រប់កម្រិតនៃលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ និងនៅលំដាប់នានានៃដំណើរការឧស្សាហកម្ម។

ហេតុផលមួយផ្សេងទៀតគឺថា ពួកគេពុំបានដឹងអំពីទីផ្សារដោយផ្ទាល់នោះទេ។ ឧទាហរណ៍ អ្នកដែលមានមុខជំនួញតូចមួយខាងកាត់ដេរសម្លៀកបំពាក់ដោយខ្លួនឯង ពុំដឹងថាតើអ្នកណាទិញសម្លៀកបំពាក់ដែលខ្លួនបានផលិតនោះឡើយ តើផលិតផលទាំងនោះអាចមានថ្លៃបែបណានៅលើទីផ្សារពិភពលោក ឬតើនឹងមានតម្រូវការរយៈពេលយូរបែបណានូវគំរូម៉ូត ឬ ប្រភេទក្រណាត់នោះ។ ជាលទ្ធផល ការយល់ដឹងរបស់ពួកគេអំពីទីផ្សារពិភពលោក ត្រូវបានទទួលតាមរយៈឈ្មួញកណ្តាល។

ប្រការទីមួយដែលស្ត្រីចាំបាច់ត្រូវធ្វើ គឺត្រូវបង្កើតជាក្រុម ពោលគឺត្រូវបង្កើតជាសមាគមក្នុងចំណោមប្រជាជនដែលមានមុខរបរប្រហាក់ប្រហែលគ្នា និងដែលមានជំនាញស្រដៀងគ្នា។ ធ្វើបែបនេះអាចឱ្យពួកគាត់មានលទ្ធភាពប្រើប្រាស់ឥណទាន ព័ត៌មាន ទំនាក់ទំនងទីផ្សារ និងបច្ចេកវិទ្យាថ្មីៗ ដោយទាញយកផលប្រយោជន៍ពីភាពចម្រុះនៃប្រការមួយ ឬច្រើនខាងលើ ពោលគឺជាកញ្ចប់អត្ថប្រយោជន៍ដែលសមស្របដែលអាចជាវបាន និងអាចជ្រើសរើសបាន ព្រមទាំងគ្រប់គ្រងបានដោយខ្លួនឯង។

សូម្បីតែធ្វើបែបនេះក៏បានត្រឹមតែអនុញ្ញាតឱ្យស្ត្រីដើរទាន់សភាពការណ៍ ប៉ុន្តែអាចមិនឈានទៅមុខបានឡើយ។ ដូច្នេះ ស្ត្រីក្រីក្រត្រូវការនូវកំណែទម្រង់ ដែលផ្តល់លទ្ធភាពដើម្បីបង្កើតភាពជាដៃគូជាមួយរដ្ឋាភិបាល និង គ្រឹះស្ថានហិរញ្ញវត្ថុនានា :

១. ដាក់ស្ត្រីក្រីក្រជាស្នូលនៃរាល់កំណែទម្រង់សេដ្ឋកិច្ច ជាពិសេស នៅក្នុងវិស័យសំខាន់ៗចំនួនប្រាំគឺ សេវាជាមូលដ្ឋាន ធនាគារ ពលកម្ម ការធានារ៉ាប់រង និង ពាណិជ្ជកម្ម។
២. ទទួលស្គាល់ "ការងារ" ថាជាស្នូលនៃគ្រប់កំណែទម្រង់សេដ្ឋកិច្ច ដែលដោះស្រាយភាពក្រីក្រ។ ចំពោះអ្នកក្រីក្រ ការងារមានសារៈសំខាន់ជាអាយុជីវិតសម្រាប់ពួកគេ។
៣. ធ្វើការវិនិយោគឱ្យបានគ្រប់គ្រាន់ទៅលើកិច្ចផ្តួចផ្តើមរបស់ស្ត្រីក្រីក្រទាំងនោះ ដែលមានសក្តានុពលសម្រាប់កំណើន។
៤. អភិវឌ្ឍ និង ពង្រីកប្រព័ន្ធសន្តិសុខសង្គម ដែលដំណើរការតាមវិធីគ្រប់ជ្រុងជ្រោយសម្រាប់ជនក្រីក្រ និងស្ត្រី។
៥. កសាងសមត្ថភាពស្ត្រីដែលធ្វើការសម្រាប់ខ្លួនឯង ដើម្បីអាចចូលទៅក្នុងទីផ្សារពិភពលោក ដោយបណ្តុះជំនាញ និងចំណេះដឹងដែលអាចរកទីផ្សារបានជាលក្ខណៈបុគ្គល ក៏ដូចជាស្ថាប័នផងដែរ។

ការផ្លាស់ប្តូរទាំងនោះពិតជាលំបាក និងទាមទារច្រើនណាស់ ប៉ុន្តែអាចធ្វើទៅបាន។ ពួកគេធ្វើការបានយ៉ាងច្រើនសម្រាប់ SEWA និងដើម្បីគ្រឹះស្ថានដទៃទៀតជាច្រើននៅទូទាំងប្រទេសឥណ្ឌា។ គ្រឹះស្ថានខ្លះធ្វើការមិនចុះសម្រុងជាមួយរដ្ឋាភិបាលមូលដ្ឋាន ចំណែកគ្រឹះស្ថានខ្លះទៀតធ្វើការជាមួយរដ្ឋាភិបាលមូលដ្ឋាន ប៉ុន្តែពួកគេទាំងអស់មានកង្វល់រួមសម្រាប់ជនក្រីក្រ និងមានការប្តេជ្ញាដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរ។ ប្រជាជនក្រីក្របានបង្ហាញអំពីការផ្លាស់ប្តូរ ដែលពួកគេបានធ្វើឡើងតាមរយៈកិច្ចប្រឹងប្រែងរួមរបស់ខ្លួន។

សាលារៀន ទំនងជានៅបន្ត ហើយជូនកាលកាន់តែរីកធំឡើង នៅពេលកុមារចម្រើនវ័យ។ ប្រការនេះបង្ហាញច្បាស់ ដូចជាលើសមាមាត្រស្ត្រី នៅក្នុងការងារដែលផ្ដល់កម្រៃក្រៅពីកសិកម្ម ដែលនៅចន្លោះឆ្នាំ ១៩៩០ និង ២០០៣ បានកើនឡើងត្រឹមតែប៉ុន្មានភាគរយតែប៉ុណ្ណោះ គឺចាប់ពី ១៣% ទៅ ១៨% នៅអាស៊ីខាងត្បូង ៣៧% ទៅ ៣៩% នៅអាស៊ីអាគ្នេយ៍ និង ៣៨% ទៅ ៤០% នៅអាស៊ីភាគឦសាន។ កំណើនឆាប់រហ័សបំផុតនៅអាស៊ីខាងត្បូង មានការទាក់ទងនឹងកំណើននៃការនាំចេញវាយនភណ្ឌ និងសម្លៀកបំពាក់។

តាំងពីដំបូង ការនាំចេញរបស់អាស៊ីបូព៌ានៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០ ក៏បានពឹងផ្អែកលើការកៀងគរកម្លាំងកម្មករជាស្ត្រីដែរ។ ដោយអាចរកប្រាក់ចំណូលដាច់ដោយឡែកពីគ្រួសាររបស់ខ្លួន ស្ត្រីជាច្រើនបានទទួលសេរីភាពយ៉ាងច្រើនជាលក្ខណៈបុគ្គល ប៉ុន្តែពួកគេច្រើនតែនៅមានឱកាសទាបនៅឡើយ ដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចនានាអំពីលក្ខខណ្ឌការងាររបស់ខ្លួន ហើយជាញឹកញាប់ ស្ត្រីត្រូវបានចាត់ទុកថាជាប្រជាពលរដ្ឋលំដាប់ទីពីរ នៅពេលជ្រើសរើសចូលធ្វើការខាងផ្នែកគ្រប់គ្រង និងចាត់ចែង (ប្រអប់២.៥)។ លើសពីនេះ សម្រាប់ស្ត្រីនៅលើពិភពលោកទាំងមូល ការចេញទៅធ្វើការនៅក្រៅផ្ទះ បានបន្ថែមបន្ទុកទ្វេរដង ហើយត្រូវប្រឈមនឹងហានិភ័យនៃការបៀតបៀនខាងផ្លូវភេទនៅកន្លែងធ្វើការផងដែរ។

*ជាញឹកញាប់ ស្ត្រីត្រូវបានចាត់ទុកថាជាប្រជាពលរដ្ឋលំដាប់ទីពីរនៅពេលជ្រើសរើសចូលធ្វើការខាងផ្នែកគ្រប់គ្រងនិងចាត់ចែង*

## ផលប៉ះពាល់សង្គម_នយោបាយ

ក្រៅពីការបង្កើនចំណូលប្រចាំគ្រួសារ ពាណិជ្ជកម្មក៏អាចលើកកម្ពស់ទិដ្ឋភាពផ្សេងទៀតនៃការអភិវឌ្ឍមនុស្សផងដែរ។ ឧទាហរណ៍ នៅបណ្តាប្រទេសលោកខាងលិច សក្តានុពលសម្រាប់ពាណិជ្ជកម្មបានជម្រុញឱ្យមានឧស្សាហូបនីយកម្ម ដែលផ្អែកលើរោងចក្រ និងបានបង្កើតជំពូកថ្មីនៃអ្នកធ្វើការ។ កម្លាំងពលកម្មថ្មីនេះមានឥទ្ធិពលយ៉ាងច្រើនខាងសង្គម និងនយោបាយ។ កម្មករអាចមិនមែនជាម្ចាស់បរិក្ខារផលិតកម្មទោះជាយ៉ាងណាក៏ដោយ ពួកគេមានសេរីភាពក្នុងការជ្រើសរើសមុខរបរ និងរកចំណូលដាច់ដោយឡែកពីបរិបាលកិច្ចនៃក្រុមអ្នកមានអំណាច។ ដូច្នេះ ពាណិជ្ជកម្មអាចត្រូវបានមើលឃើញថាបានជួយសម្រួលឱ្យមានការលេចឡើងនៃអ្នកបោះឆ្នោតឯករាជ្យ និងកែលំអប្រជាធិបតេយ្យ។[១៨]

## ច្រកការងារ

ច្រកចម្បងដែលបង្កើតឥទ្ធិពលពាណិជ្ជកម្មទាំងអស់នេះ ទៅលើការអភិវឌ្ឍមនុស្សគឺតាមរយៈការងារ។ ជាទស្សនៈកំណើនពាណិជ្ជកម្មគួរតែបង្កើនចំនួនការងារ និងការថយចុះនៃភាពគ្មានការងារធ្វើ។ ប៉ុន្តែ ជាញឹកញាប់ពុំមានការកែលំអលើផ្នែកនេះឡើយ។ រវាងឆ្នាំ ១៩៩៣ និង ២០០៣ គឺ ជារយៈពេលដែលមានការពង្រីកពាណិជ្ជកម្មយ៉ាងឆាប់រហ័ស អត្រាភាពគ្មានការងារធ្វើនៅលើពិភពលោកបានថយចុះ តែនៅក្នុងសេដ្ឋកិច្ចឧស្សាហកម្មតែប៉ុណ្ណោះ។ នៅក្នុងតំបន់ផ្សេងទៀត អត្រានេះច្រើនតែនៅពុំប្រែប្រួល (រូបទី ២.១០)។ ស្ត្រី និង បុរសក្មេងៗដែលមានអាយុរវាង ១៥ និង ២៤ឆ្នាំ ត្រូវរងបន្ទុកនៃភាពគ្មានការងារធ្វើកាន់តែច្រើនឡើង។ នៅឆ្នាំ ២០០៤ ចំនួនក្មេងជំទង់ មានមួយភាគប្រាំនៃកម្លាំងពលកម្មសរុបនៅអាស៊ី-ប៉ាស៊ីហ្វិក ហើយជិតពាក់កណ្តាលនៃចំនួនមនុស្សក្នុងក្រុមនេះគឺជាអ្នកគ្មានការងារធ្វើនៅក្នុងតំបន់នេះ។ មនុស្សជំទង់ដែលគ្មានការងារធ្វើមានអត្រាខ្ពស់ដល់ ១៧% នៅអាស៊ី-ប៉ាស៊ីហ្វិក។ អត្រាស្ត្រីគ្មានការងារធ្វើ បានកើនឡើងនៅក្នុងឆ្នាំថ្មីៗកន្លងទៅនេះ និងមានកម្រិតខ្ពស់ជាអត្រាបុរសនៅក្នុងប្រទេសជាច្រើននៃតំបន់នេះ។

នៅពេលដែលកម្លាំងពលកម្មបានកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ពោលគឺ ២៤% នៅអាស៊ីខាងត្បូង និង ១៤.៥% នៅអាស៊ីបូពា៌ និងប៉ាស៊ីហ្វិក សម្ពាធនៃភាពគ្មានការងារធ្វើក៏បានកើនឡើងដែរ។ ឥឡូវ អ្នកដែលស្ថិតនៅក្នុងទីផ្សារពលកម្មបានដឹងថាចំនួនការងារកាន់តែខ្សត់ទៅៗ។ អត្រាភាពគ្មានការងារធ្វើនៅអាស៊ីអាគ្នេយ៍ ជាការបង្ហាញយ៉ាងច្បាស់អំពីប្រការខាងលើនេះ ដែលនៅរវាងឆ្នាំ ១៩៩៣ និង ២០០៣ បានកើនឡើងពី ៣.៩% ដល់ ៦.៣%។ ជាក់ស្តែង ចាប់តាំងពីឆ្នាំ ១៩៩០មក ប្រទេសខ្លះក្នុងចំណោមប្រទេសដែលធ្វើពាណិជ្ជកម្មច្រើន ដូចជា ប្រទេសចិន និងសឹង្ហបុរី បានសង្កេតឃើញអត្រាភាពគ្មានការងារធ្វើកើនឡើងយ៉ាងច្រើន។

បណ្តាប្រទេសនៅអាស៊ី បានបង្កើតចំនួនការងារយ៉ាងឆាប់រហ័សនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ រហូតដល់ចំនួនសរុប ៣៣៧លាន។ ទោះជាបែបនេះក្តី នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសទាំងនេះបានបង្កើតការងារជាចំនួនតិចតួចណាស់គឺត្រឹមតែ ១៧៦លានប៉ុណ្ណោះ។ ហេតុអ្វីចំនួនការងារដែលបង្កើតបាន មានត្រឹមតែពាក់កណ្តាលបែបនេះ? ភាគច្រើននៃឱនភាពនេះឆ្លុះបញ្ចាំងអំពីការអភិវឌ្ឍនៅអាស៊ីបូពា៌។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ អនុតំបន់នេះបានបន្ថែមការងារថ្មីចំនួន ២៧៣លាន ត្រូវជា ៧០% នៃចំនួនសរុបនៅក្នុងតំបន់។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ទោះបីជាមានសំទុះកំណើនខ្លាំងក៏ដោយ ប្រទេសនានានៅក្នុងអនុតំបន់នេះបានបន្ថែមចំនួនការងារត្រឹមតែ ១០៤លានប៉ុណ្ណោះ។ ជាលទ្ធផល អត្រាភាពគ្មានការងារធ្វើ បានកើនឡើងជាថ្មីទៀត។ ម្យ៉ាងវិញទៀត នៅអាស៊ីខាងត្បូងមានកំណើនចំនួនការងារតិចតួច។ អនុតំបន់នេះបានបង្កើតការងារចំនួន ៦៤លាន នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ហើយបន្ទាប់មក ទោះបីមានការធ្លាក់ចុះនូវអត្រា




រូបទី ២.១០: អត្រាគ្មានការងារធ្វើប្រចាំតំបន់ ឆ្នាំ ១៩៩៣ និង ២០០៣

ប្រភព : អង្គការពលកម្មអន្តរជាតិ ២០០៥

រួមនៃកំណើនសេដ្ឋកិច្ចក៏ដោយ ចំនួនការងារដែលបានបង្កើតបន្ថែមនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ គឺ ៧២លាន។

ដើម្បីពិនិត្យមើលឱ្យបានហ្មត់ចត់អំពីអ្វីដែលកំពុងកើតឡើង ប្រការសំខាន់គឺត្រូវពិចារណាអំពី "Elasticity-ភាពយឺត" នៃចំនួនការងារទាក់ទងនឹងកំណើនដែលគណនាដោយចែកអត្រាកំណើនចំនួនការងារជាមួយអត្រាកំណើននៃលទ្ធផល។

បទពិសោធនៅក្នុងតំបន់នេះមានសង្ខេបជូននៅក្នុងតារាងទី ២.៨។ នៅអាស៊ីបូពា៌ មានការធ្លាក់ចុះយ៉ាងគំហុកនៃការបង្កើតចំនួនការងារ។ រវាងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ ទោះបីជាមានសំទុះនៃកំណើនលទ្ធផលក្តី កំណើនចំនួនការងារបានធ្លាក់ចុះពី ៤.២% មកត្រឹម ១.២% ដែលជាការធ្លាក់ចុះចំនួន ៣%។ ប្រការនេះឆ្លុះបញ្ចាំងពីការធ្លាក់ចុះនូវភាពយឺតនៃចំនួនការងារពី ០.៥៦ មក ០.១៥ ។

បន្ទាប់មក ទិន្នន័យនេះអាចត្រូវយកទៅប្រើប្រាស់ដើម្បី "បំបែក" កំណើនចំនួនការងារទៅជាពីរផ្នែក។ ទីមួយ ផ្នែកដែលកើតឡើងដោយសារការកើនឡើង ឬការថយចុះសកម្មភាពសេដ្ឋកិច្ច ពោលគឺ "ឥទ្ធិពលនៃលទ្ធផល"។ ទីពីរ ផ្នែកដែលឆ្លុះបញ្ចាំងអំពីសមត្ថភាពនៃលទ្ធផលនោះ ក្នុងការបង្កើត

*បណ្តាប្រទេសនៅអាស៊ីបានបង្កើតចំនួនការងារយ៉ាងឆាប់រហ័សក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ប៉ុន្តែ បង្កើតបានតិចតួចណាស់ នៅទសវត្សរ៍ឆ្នាំ ១៩៩០*

ចំនួនការងារ ពោលគឺ "ឥទ្ធិពលនៃភាពយឺត"។ តួលេខបានពីការបំបែកនេះ មានបង្ហាញជូននៅក្នុងតារាង ២.៩។ ដូច្នេះ សម្រាប់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក ការថយចុះ ៣%នៃកំណើនចំនួន

តារាង ២.៨

កំណើនចំនួនការងារ និងផលិតផល ព្រមទាំងភាពយឺតនៃចំនួនការងារតាមវិស័យ

| | ទសវត្សរ៍ឆ្នាំ ១៩៨០ | | | ទសវត្សរ៍ឆ្នាំ ១៩៩០ | | |
|---|---|---|---|---|---|---|
| | កំណើនចំនួនការងារ | កំណើនផលិតផល | ភាពយឺតនៃចំនួនការងារ | កំណើនចំនួនការងារ | កំណើនផលិតផល | ភាពយឺតនៃចំនួនការងារ |
| *អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក* | ៤.២ | ៧.៤ | 0.៥៦ | ១.២ | ៨.២ | 0.១៥ |
| កសិកម្ម | ១.៨ | ៥.១ | 0.៣៥ | -0.២ | ៣.៣ | -0.0៥ |
| ឧស្សាហកម្ម | ៤.៧ | ៨.0 | 0.៥៩ | 0.៨ | ១១.0 | 0.0៧ |
| សេវាកម្ម | ៥.២ | ៨.៩ | 0.៥៩ | ៣.៥ | ៧.១ | 0.៤៩ |
| *អាស៊ីខាងត្បូង* | ១.៦ | ៥.៧ | 0.២៨ | ១.៦ | ៥.២ | 0.៣១ |
| កសិកម្ម | ១.៣ | ៣.៥ | 0.៣៧ | 0.៦ | ២.៩ | 0.២១ |
| ឧស្សាហកម្ម | ២.៣ | ៧ | 0.៣៣ | ២.៥ | ៥.៦ | 0.៤៥ |
| សេវាកម្ម | ២.៣ | ៦.២ | 0.៣៧ | ៣.៦ | ៦.៨ | 0.៥២ |

**ប្រភព: Palanivel ២00៦**

តារាង ២.៩

កត្តានានាដែលរួមចំណែកធ្វើឱ្យប្រែប្រួលអត្រាកំណើនចំនួនការងារ

| | ការប្រែប្រួលអត្រាកំនើនចំនួនការងារ (១) | ឥទ្ធិពលទៅលើលទ្ធផល (២) | ឥទ្ធិពលលើភាពយឺត (៣) |
|---|---|---|---|
| *អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក* | -0.៣ | 0.១ | -៣.១ |
| កសិកម្ម | -២.0 | 0.១ | -២.១ |
| ឧស្សាហកម្ម | -៣.៩ | 0.២ | -៤.១ |
| សេវាកម្ម | -១.៧ | -0.៨ | -0.៩ |
| *អាស៊ីខាងត្បូង* | 0.0 | -0.២ | 0.២ |
| កសិកម្ម | -0.៧ | -0.១ | -0.៦ |
| ឧស្សាហកម្ម | 0.២ | -0.៦ | 0.៨ |
| សេវាកម្ម | 0.៣ | 0.៤ | 0.៩ |

សម្គាល់: ជួរឈរទី ១ គឺជាផលបូកនៃជួរឈរទី ២ និងទី ៣

**ប្រភព: Palanivel ២00៦**

ការងាររវាងទសវត្សរ៍ឆ្នាំ ១៩៨0 និង ១៩៩0 បានផ្សំឡើងដោយកំណើន 0.១% ដោយសារឥទ្ធិពលនៃលទ្ធផល និងការថយចុះ ៣.១% ដោយសារឥទ្ធិពលនៃភាពយឺត។

ភាគច្រើននៃការប្រែប្រួលក្នុងអនុតំបន់នេះបណ្តាលពីអ្វីដែលបានកើតឡើងនៅក្នុងវិស័យឧស្សាហកម្ម និងជាពិសេសនៅក្នុងផ្នែកកម្មន្តសាល ព្រោះថា ទោះបីលទ្ធផលពីកម្មន្តសាលបានកើនឡើងចំនួនជិត ១៨0% នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩0 ក៏ដោយ ចំនួនការងារដែលពាក់ព័ន្ធ បានកើនឡើងត្រឹមតែ ៣% ប៉ុណ្ណោះ ដែលត្រូវបានហៅថា "កំណើនភាពគ្មានការងារធ្វើ"។ ដូចដែលមានបង្ហាញក្នុងតារាងទី ២.៨ ភាពយឺតនៃចំនួនការងារក្នុងឧស្សាហកម្មធ្លាក់ចុះយ៉ាងគំហុកពី 0.៥៩ ទៅ 0.0៧។

ការបង្កើតចំនួនការងារនៅអាស៊ីបូព៌ា ក៏មានភាពទន់ខ្សោយផងដែរនៅក្នុងវិស័យសេវាកម្ម។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីនេះ ស្ថានភាពនេះបានកើតឡើងដោយសារទាំងតំហយសំទុះនៃកំណើនលទ្ធផល និងការចុះខ្សោយនូវភាពយឺតនៃចំនួនការងារ។ ការធ្លាក់ចុះនៃអត្រាកំណើនចំនួនការងារពីច្រើនជាង ៥% មកប្រមាណ ៣.៥% ត្រូវបានចែករម្លែកស្មើគ្នាក្នុងចំណោមឥទ្ធិពលទាំងពីរនេះ។

ទោះជាយ៉ាងណាក៏ដោយ លទ្ធផលទាបជាងគេបំផុតគឺនៅក្នុងវិស័យកសិកម្ម។ នៅទីនេះក៏មានការថយចុះនៃកំណើនលទ្ធផល និងការចុះខ្សោយនូវភាពយឺតនៃចំនួនការងារផងដែរ។ ជាក់ស្តែង ចំនួនការងារក្នុងវិស័យកសិកម្មបានថយចុះ សូម្បីតែគិតជាចំនួនដាច់ខាតក៏ដោយ។

## បំលាស់ប្តូរសមាសភាពនៃផលិតផលកម្មន្តសាល

ជារួម ភាគច្រើននៃកំណើនមិនគ្រប់គ្រាន់នូវចំនួនការងារនៅអាស៊ីបូព៌ា គឺដោយសារឥទ្ធិពលនៃភាពយឺត។ តើអ្វីដែលបង្កឱ្យមានស្ថានភាពនេះ? ហើយជាពិសេស ហេតុអ្វីបានជា

ការផលិតពុំអាចផ្តល់ចំនួនការងារធ្វើបានគ្រប់គ្រាន់ ដើម្បីស្រូបយកចំនួនមនុស្សដែលប្តូរមកពីវិស័យកសិកម្ម? ចម្លើយគឺថា វាបណ្តាល មកពីការផ្លាស់ប្តូរសមាសភាពនៅក្នុងវិស័យកម្មន្ត-សាល។ ទីមួយ ផលិតកម្មបានផ្លាស់ប្តូរពីឧស្សាហកម្មបច្ចេកវិទ្យាទាប និងអតិពលកម្ម ដូចជាការកាត់ដេរសម្លៀកបំពាក់ មកជាឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់ និងប្រើប្រាស់មូលធនខ្ពស់ ដូចជាអេឡិចត្រូនិក។ តារាងទី ២.១០ បង្ហាញអំពីដំណើរការនេះ សម្រាប់ប្រទេសចិន និងម៉ាឡេស៊ី ដែលប្រទេសទាំងពីរបានឆ្លងកាត់ស្ថានភាពនៃការធ្លាក់ចុះយ៉ាងគំហុកនូវផលិតកម្មអតិពលកម្ម។ ទីពីរ សូម្បីតែនៅក្នុងកម្មន្តសាលអតិពលកម្ម ក្រុមហ៊ុននានាបានបន្តវិនិយោគលើបរិក្ខារដែលទាមទារការប្រើប្រាស់កម្លាំងពលកម្មតិច។ ឧទាហរណ៍ ការអង្កេតមួយទៅលើឧស្សាហកម្មចំនួន ២៨ នៅក្នុងប្រទេសម៉ាឡេស៊ី បានបង្ហាញថា មានការថយចុះយ៉ាងខ្លាំងនូវកម្រិតអតិពលកម្មនៅក្នុងឧស្សាហកម្មចំនួន ១៣។

គួរចងចាំថាវិស័យផលិតកម្មក៏មានឥទ្ធិពលដោយផ្ទាល់ទៅលើចំនួនការងារផងដែរ នៅពេលដែលសហគ្រាសផលិតកម្មផ្តល់មុខជំនួញសម្រាប់ការលក់ដុំនិងការលក់រាយ ការដឹកជញ្ជូននិងទូរគមនាគមន៍ និងធនាគារ និងការធានារ៉ាប់រង។ ប្រាក់ចំណូលរកបាននៅក្នុងវិស័យផលិតកម្មក៏ជម្រុញឱ្យមានតម្រូវការសេវាកម្មពីអ្នកប្រើប្រាស់ផងដែរ។

តារាង ២.១១ បង្ហាញថា នៅពេលដែលមានកំណើនយ៉ាងច្រើនក្នុងវិស័យសេវាកម្ម ចំនួនការងារមិនបានកើនឡើងសមស្របឡើយ។ នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ភាពយឺតនៃចំនួនការងារនៅក្នុងលក្ខខណ្ឌកំណើន បានធ្លាក់ចុះសម្រាប់គ្រប់វិស័យរងទាំងអស់ លើកលែងតែក្នុងផ្នែកហិរញ្ញវត្ថុ និងការធានារ៉ាប់រង។ ម្យ៉ាងវិញទៀត នៅអាស៊ីខាងត្បូង សមត្ថភាពបង្កើតចំនួនការងារនៃគ្រប់វិស័យរងទាំងអស់ត្រូវបានពង្រីក។

**តារាង ២.១០**

**សមាសភាពនៃតម្លៃបន្ថែមលើផលិតផលកម្មន្តសាលក្នុងប្រទេសចិន និងម៉ាឡេស៊ី (%)**

| ឧស្សាហកម្ម | ១៩៨០ | ១៩៩០ | ២០០០ |
|---|---|---|---|
| | | ចិន | |
| អតិពលកម្ម | - | ២៩ | ២១ |
| ធនធានធម្មជាតិ | - | ២៥ | ២៧ |
| អាហារ ភេសជ្ជៈ និងថ្នាំជក់ | - | ១៥ | ១៤ |
| បរិក្ខារដឹកជញ្ជូន | - | ៤ | ៧ |
| លោហកម្មសម្ភារៈការិយាល័យ ។ល។ | - | ២៤ | ២៧ |
| ផ្សេងៗ | - | ៣ | ៤ |
| | | ម៉ាឡេស៊ី | |
| អតិពលកម្ម | ២៦ | ៦៧ | ១៨ |
| ធនធានធម្មជាតិ | ២៥ | ២៣ | ១៩ |
| អាហារ ភេសជ្ជៈ និងថ្នាំជក់ | ២១ | ១៣ | ១០ |
| បរិក្ខារដឹកជញ្ជូន | ៤ | ៦ | ៤ |
| លោហកម្មសម្ភារៈការិយាល័យ ។ល។ | ២១ | ៣០ | ៤៧ |
| ផ្សេងៗសេវាកម្ម | ៣ | ១ | ២ |

**ប្រភព: UNIDO ២០០៦**

ទម្រង់នៃកំណើនភាពគ្មានការងារធ្វើបែបនេះត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងសេដ្ឋកិច្ចទាំងអស់នៅអាស៊ីបូព៌ា (តារាង ២.១២)។ ឧទាហរណ៍ នៅប្រទេសចិនដែលកំណើននៃការនាំចេញបានរួមចំណែកធ្វើឱ្យមានអត្រាខ្ពស់បំផុតនៃកំណើនសេដ្ឋកិច្ចជិតដល់ ១០% ប៉ុន្តែមានកំណើនចំនួនការងារត្រឹមតែ ១.១% តែប៉ុណ្ណោះ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។

ស្ថានភាពនៃចំនួនការងារ មានលក្ខណៈខុសគ្នានៅអាស៊ីខាងត្បូង។ នៅទីនេះ ទោះបីមានការថយចុះនៃអត្រាកំណើនសេដ្ឋកិច្ចក៏ដោយ កំណើននៃចំនួនការងារនៅតែថេរត្រឹមអត្រាទាបប្រមាណ ១.៦% ដែលមានន័យថា កំណើនភាពយឺតនៃចំនួនការងារ រួមទាំងភាពយឺតសម្រាប់ឧស្សាហកម្មផងដែរ (តារាង ២.៨)។ នេះដោយសារនៅអាស៊ីខាងត្បូង មានការ

តារាង ២.១១

កំណើនផលិតផល និងចំនួនការងារនៅក្នុងវិស័យសេវាកម្ម

| | ទសវត្សរ៍ឆ្នាំ ១៩៨០ | | | ទសវត្សរ៍ឆ្នាំ ១៩៩០ | | |
|---|---|---|---|---|---|---|
| | កំណើនចំនួនការងារ | កំណើនផលិតផល | ភាពយឺតនៃចំនួនការងារ | កំណើនចំនួនការងារ | កំណើនផលិតផល | ភាពយឺតនៃចំនួនការងារ |
| *អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក* | | | | | | |
| ពាណិជ្ជកម្មលក់ដុំ និងលក់រាយ | ៦.២ | ៩.៥ | ០.៦៥ | ៥.០ | ៧.៨ | ០.៦៤ |
| ការដឹកជញ្ជូន រក្សាទុក និងគមនាគមន៍ | ៦.១ | ១០.៤ | ០.៥៩ | ៣.៤ | ៨.៤ | ០.៤០ |
| ហិរញ្ញប្បទាន និងធានារ៉ាប់រង | ៧.៥ | ៥.៦ | ១.៣៤ | ៦.០ | ៣.៦ | ១.៦៧ |
| សេវាសហគមន៍ សង្គម និងបុគ្គល | ៤.២ | ២.០ | ២.១០ | ១.៦ | ១.៥ | ១.០៧ |
| *អាស៊ីខាងត្បូង* | | | | | | |
| ពាណិជ្ជកម្មលក់ដុំ និងលក់រាយ | ២.៥ | ៥.០ | ០.៥០ | ៤.៥ | ៣.៥ | ១.២៩ |
| ការដឹកជញ្ជូន រក្សាទុក និងគមនាគមន៍ | ២.៣ | ៦.៣ | ០.៣៧ | ៤.៨ | ៨.០ | ០.៦០ |
| ហិរញ្ញប្បទាន និងធានារ៉ាប់រង | ៥.២ | ៩.៥ | ០.៥៥ | ៥.៩ | ៩.១ | ០.៦៥ |
| សេវាសហគមន៍ សង្គម និងបុគ្គល | ១.០ | ៦.៣ | ០.១៦ | ២.០ | ១.៣ | ១.៥៤ |

**ប្រភព: Palanivel ២០០៦**

ផ្លាស់ប្តូររចនាសម្ព័ន្ធបន្តិចបន្តួចតែប៉ុណ្ណោះ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ ឧស្សាហកម្មតាមបែបបុរាណដែលផ្អែកលើអតិពលកម្ម និងធនធានធម្មជាតិ បានរក្សាស្ថិរភាព និងអាចថែមទាំងធ្វើឱ្យមានកំណើនភាគចំណែករបស់ខ្លួននៅក្នុងតម្លៃបន្ថែមផងដែរ។ ឧទាហរណ៍ នៅប្រទេសឥណ្ឌា សមាមាត្រនៃតម្លៃបន្ថែមរបស់ផលិតផលដែលបានពីផលិតកម្មអតិពលកម្ម នៅថេរដដែលត្រឹម ២៩% នៅរវាងឆ្នាំ ១៩៩០ និង ២០០០ (តារាង ២.១៣)។

បន្ទុកកាន់តែច្រើនឡើងនៃចំនួនការងារនៅក្នុងប្រទេសឥណ្ឌា ត្រូវបានស្រូបដោយវិស័យក្រៅផ្លូវការធំៗ ដែលបន្តទម្លាប់បង្កើតការងារសម្រាប់ប្រជាពលរដ្ឋដែលពុំអាចរកការធ្វើបាននៅក្នុងវិស័យកសិកម្ម និងជាអ្នកដែលបានចាកចោលទីជនបទ។

តារាង ២.១១ បង្ហាញថា ចំនួនការងារបែបនេះជាច្រើនមាននៅក្នុងពាណិជ្ជកម្មលក់ដុំ និងលក់រាយ ដែលភាគច្រើនស្ថិតនៅក្នុងវិស័យក្រៅផ្លូវការ។ ផ្ទុយទៅវិញ នៅទីនេះ ភាពយឺតនៃចំនួនការងារបានកើនឡើងជាច្រើន ដែលបង្ហាញថា ប្រជាពលរដ្ឋមានចំនួនកាន់តែច្រើនឡើងកំពុងធ្វើការនៅក្នុងវិស័យនេះ ប៉ុន្តែពុំបានផ្តល់កំណើនលទ្ធផលតាមសមាមាត្រដូចគ្នានោះទេ ដូច្នេះនឹងនាំឱ្យមានការទទួលកម្រៃកាន់តែទាប។ ទោះជាយ៉ាងណាក៏ដោយ ជារួម កំណើនចំនួនការងារនៅប្រទេសឥណ្ឌាមានអត្រាទាបត្រឹមប្រមាណ ១% ប៉ុណ្ណោះ។

ស្ថានភាពនេះមានភាពប្រសើរនៅក្នុងប្រទេសខ្លះៗទៀតនៃតំបន់នេះ។ ឧទាហរណ៍ នៅប្រទេសបង់ក្លាដេស កំណើនចំនួនការងារមានកម្រិតខ្ពស់ ជាពិសេសដោយសារការពង្រីកឧស្សាហកម្មអតិពលកម្ម ដែលផលិតសម្លៀកបំពាក់សម្រាប់ការនាំចេញ ហើយក៏មានការកែលំអខ្លះៗផងដែរ នៅក្នុងប្រទេសប៉ាគីស្ថាន និងស្រីលង្កាផងដែរ។

## លក្ខខណ្ឌនៅក្នុងទីផ្សារការងារ

ផ្អែកលើទស្សនៈនៃការអភិវឌ្ឍមនុស្ស ការកើនឡើងនៃលទ្ធផលដោយពុំមានកំណើនត្រូវគ្នានៃចំនួនការងារ គឺជាការចាញ់ប្រៀប។ ទោះជាយ៉ាងណាក៏ដោយ វាពិតជាមានទិដ្ឋភាពវិជ្ជមាន ដោយសារវាផ្តល់សញ្ញាអំពីកំណើននៃផលិតភាពពលកម្ម។ សហគ្រាសជាច្រើនបានប្រើប្រាស់ទុនកាន់តែច្រើនឡើង ដើម្បីធ្វើការវិនិយោគលើបរិក្ខារថ្មី ឬលើបរិក្ខារដែលជំនួសកម្លាំងមនុស្ស ឬមួយដោយសារពួកគេបានឆ្លើយតប

នឹងសម្ពាធនៃភាពប្រកួតប្រជែងនៅក្នុងទីផ្សារក្នុងស្រុក ឬនៅក្នុងទីផ្សារអន្តរជាតិ ដោយត្រូវជម្រុះកម្លាំងពលកម្មចោលខ្លះ។

នៅក្នុងអាស៊ីបូព៌ា ផលិតភាពការងារបានកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ក្នុងអត្រា ៧% ក្នុងមួយឆ្នាំ និងអត្រាកំណើន ១០% នៅក្នុងឧស្សាហកម្ម ។ នៅអាស៊ីខាងត្បូង អត្រាកំណើនត្រូវគ្នានេះមានរវាង ៣% និង ៣.៥%។ នៅទូទាំងតំបន់នេះ កំណើននេះកើតឡើងទន្ទឹមនឹងកំណើននៃផលិតភាពកត្តាសរុប (TFP) ដែលជាឥទ្ធិពលនៃបច្ចេកវិទ្យា និងការគ្រប់គ្រងទៅលើលទ្ធផល។ ទោះជាយ៉ាងណាក៏ដោយកំណើន TFP មានភាពខុសគ្នាយ៉ាងច្រើនរវាងបណ្ដាប្រទេសមួយចំនួន (តារាង ២.១៤)។ ឧទាហរណ៍ ប្រទេសវៀតណាម បានលើកកំពស់ភាពប្រកួតប្រជែងរបស់ខ្លួន ដោយបានធ្វើឱ្យមានកំណើនប្រចាំឆ្នាំជិត ៤% ដែលជាការពន្យល់ហេតុផលនៃការរីកចំរើនលើការនាំចេញ។ ដូចគ្នានេះដែរ នៅប្រទេសឥណ្ឌា កំណើន TFP មានក្នុងអត្រា ២.៥%។ ទោះជាយ៉ាងណាក៏ដោយ នៅប្រទេសថៃ TFP ស្ថិតនៅឥតប្រែប្រួល ហើយនៅប្រទេស ហ្វីលីពីន TFP បានថយចុះ។

ការប្រែប្រួលផលិតភាពបែបនេះ ក៏មានឥទ្ធិពលទៅលើប្រាក់កម្រៃផងដែរ។ នៅក្នុងបណ្ដាប្រទេសដែលមានទីផ្សារពលកម្មមានសភាពតឹងតែង និងមានអត្រាគ្មានការងារធ្វើទាប ការបង្កើនផលិតភាពទំនងជានឹងនាំឱ្យមានកំណើនប្រាក់កម្រៃជាក់ស្ដែង។ តាមពិតនៅអាស៊ីបូព៌ា ប្រាក់កម្រៃជាក់ស្ដែង បានកើនឡើងយ៉ាងឆាប់រហ័សក្នុងអត្រា ៧% ក្នុងមួយឆ្នាំនៅម៉ាឡេស៊ី ១១% នៅចិន និង ១២% នៅឥណ្ឌូណេស៊ី។ ម៉្យាងវិញទៀត នៅអាស៊ីខាងត្បូងដែលកំណើនផលិតភាពមានកម្រិតទាប ហើយអត្រាភាពគ្មានការងារធ្វើមានកម្រិតខ្ពស់ជាង ការប្រែប្រួលនេះមានតិចតួចប៉ុណ្ណោះ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ពោលគឺមានការកែលំអតិចតួចនៅបង់ក្លាដេស គ្មានការផ្លាស់ប្ដូរនៅឥណ្ឌា ណេប៉ាល់ និងស្រីលង្កា និងធ្លាក់ចុះបន្តិចនៅប៉ាគីស្ថាន។[១៩]

តារាង ២.១២

កំណើនទូទៅនៃចំនួនការងារ និង GDP ព្រមទាំងភាពយឺតក្នុងប្រទេសមួយចំនួន

| | ទសវត្សរ៍ឆ្នាំ ១៩៨០ | | | ទសវត្សរ៍ឆ្នាំ ១៩៩០ | | |
|---|---|---|---|---|---|---|
| | កំណើនចំនួនការងារ | កំណើន GDP | ភាពយឺតនៃចំនួនការងារ | កំណើនចំនួនការងារ | កំណើន GDP | ភាពយឺតនៃចំនួនការងារ |
| ចិន | ៤.៣ | ៩.៤ | ០.៤៦ | ១.១ | ១០.១ | ០.១១ |
| ឥណ្ឌូណេស៊ី | ៣.៩ | ៦.៤ | ០.៦១ | ១.៧ | ៤.៤ | ០.៣៩ |
| ម៉ាឡេស៊ី | ៣.៤ | ៦.០ | ០.៥៧ | ៣.៤ | ៧.២ | ០.៤៧ |
| ហ្វីលីពីន | ២.៨ | ១.៨ | ១.៥៦ | ២.១ | ៣.១ | ០.៦៨ |
| ថៃ | ៣.២ | ៧.៩ | ០.៤១ | ០.៧ | ៤.៦ | ០.១៥ |
| វៀតណាម | ៤.២ | ៤.៦ | ០.៩១ | ២.២ | ៧.៦ | ០.២៩ |
| អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក | ៤.២ | ៧.៤ | ០.៥៦ | ១.២ | ៨.២ | ០.១៥ |
| បង់ក្លាដេស | ៣.១ | ៤.១ | ០.៧៦ | ៤.១ | ៤.៨ | ០.៨៥ |
| ឥណ្ឌា | ១.៥ | ៥.៨ | ០.២៦ | ១.២ | ៥.៥ | ០.២២ |
| ប៉ាគីស្ថាន | ២.០ | ៦.៣ | ០.៣២ | ២.២ | ៤.០ | ០.៥៥ |
| ស្រីលង្កា | ១.០ | ៤.២ | ០.២៤ | ១.៤ | ៥.២ | ០.២៧ |
| អាស៊ីខាងត្បូង | ១.៦ | ៥.៧ | ០.២៨ | ១.៦ | ៥.២ | ០.៣១ |

**ប្រភព: Palanivel ២០០៦**

តារាង ២.១៣

សមាសភាពនៃតម្លៃបន្ថែមនៅក្នុងផលិតផលកម្មន្តសាលនៅប្រទេសឥណ្ឌា (%)

| | ១៩៨០ | ១៩៩០ | ២០០០ |
|---|---|---|---|
| អតិពលកម្ម | ៣៧ | ២៩ | ២៩ |
| ធនធានធម្មជាតិ | ២៤ | ២៦ | ៣១ |
| អាហារ ភេសជ្ជៈ និងថ្នាំជក់ | ៩ | ១២ | ១៣ |
| បរិក្ខារដឹកជញ្ជូន | ៨ | ១០ | ៧ |
| លោហកម្ម សម្ភារៈការិយាល័យ ។ល។ | ២១ | ១៩ | ១៧ |
| ផ្សេងៗ | ១ | ៤ | ៣ |

**ប្រភព: UNIDO ២០០៤**

តារាង ២.១៤

**កំណើននៃផលិតភាពកត្តាសរុបនៅក្នុងប្រទេសមួយចំនួន**

| | ទសវត្សរ៍ឆ្នាំ ១៩៨០ | ទសវត្សរ៍ឆ្នាំ ១៩៩០ |
|---|---|---|
| *អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក* | | |
| ម៉ាឡេស៊ី | 0.៥ | ១.៨ |
| ហ្វីលីពីន | -0.៩ | -0.៣ |
| ថៃ | ២.0 | 0.0 |
| វៀតណាម | ២.0 | ៣.៧ |
| *អាស៊ីខាងត្បូង* | | |
| ឥណ្ឌា | ១.៦ | ២.៥ |

**ប្រភព: គណនាពី Palanivel ២00៦**

មានការប្រែប្រួលផងដែរលើកម្រិតជំនាញនៃពលករនៅទូទាំងតំបន់នេះ។ ប្រការនេះអាចសង្កេតឃើញតាមរយៈកម្រិតអប់រំរបស់អ្នកគ្មានការងារធ្វើ ដែលទំនងជាមានកម្រិតទាបជាង នៅក្នុងករណីដែលប្រទេសឈានទៅប្រើប្រាស់បច្ចេកវិទ្យាខ្ពស់។ ដូចមានបង្ហាញក្នុងរូបទី ២.១១ នៅក្នុងប្រទេសឥណ្ឌូណេស៊ី និងថៃ សមាមាត្រអ្នកគ្មានការងារធ្វើ ដែលមានការអប់រំខ្ពស់ បានធ្លាក់ចុះនៅរវាងឆ្នាំ ១៩៩០ និង ២000។ នេះគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ នៅពេលដែលមានការឈានទៅឧស្សាហកម្មដែលប្រើប្រាស់បច្ចេកវិទ្យាកម្រិតមធ្យមនិងខ្ពស់ និងសេវាទំនើបនៃវិស័យផ្លូវការ ដូចជា ទូរគមនាគមន៍ ធនាគារ និងការរ៉ាប់រង ដែលទំនងជាប្រើប្រាស់កម្មករជំនាញច្រើនជាង។ ម្យ៉ាងវិញទៀត នៅប្រទេសឥណ្ឌា និងស្រីលង្កា សមាមាត្រនៃអ្នកដែលមានការអប់រំខ្ពស់ក្នុងចំណោមអ្នកគ្មានការងារធ្វើបានកើនឡើង នាំឱ្យមានកំណើនទៅរកបាតុភូតភាពអ្នកមានសញ្ញាប័ត្រតែគ្មានការងារធ្វើ។




រូបទី ២.១១: កម្រិតអប់រំនៃអ្នកគ្មានការងារធ្វើ

ប្រភព : ធនាគារពិភពលោក ២00៥

អត្រាចូលធ្វើការរបស់ស្ត្រីក៏មានភាពខុសគ្នាផងដែររវាងអនុតំបន់។ នៅអាស៊ីបូព៌ា អត្រានៃការចូលរួមរបស់ស្ត្រីមានកម្រិតខ្ពស់ជិត ៨0% ប៉ុន្តែ ស្ត្រីច្រើនតែមានទំនោរទៅរកភាពគ្មានការងារធ្វើជាងបុរស (រូបទី ២.១២)។ នៅអាស៊ីខាងត្បូង អត្រានៃការចូលរួមរបស់ស្ត្រីមានកម្រិតទាបត្រឹម ៣0% ទៅ ៧0% ប៉ុន្តែហាក់ដូចជាមានគម្លាតគ្នាតិចតួចជាងនៅក្នុងអត្រាអ្នកគ្មានការងារធ្វើ។ តាមពិត នៅបង់ក្លាដេស នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩0 អត្រានេះមានកម្រិតទាបណាស់សម្រាប់ស្ត្រី ដោយសារពួកគេមានកាលានុវត្តភាពច្រើនដើម្បីធ្វើការក្នុងវិស័យកាត់ដេរ។

## សេចក្តីសន្និដ្ឋាន

ការពិភាក្សាខាងលើបង្ហាញថា មានភាពខុសគ្នាជាមូលដ្ឋាននូវចំណងទាក់ទងរវាងពាណិជ្ជកម្ម កំណើននិងភាពមានការងារធ្វើ រវាងអាស៊ីបូព៌ា និងអាស៊ីខាងត្បូង នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩0។ បើពិនិត្យមើលអាស៊ីខាងត្បូង ដំណើរការសេរីភាវូបនីយកម្មពាណិជ្ជកម្មពិតជាបានកើតឡើងនៅក្នុងអំឡុងពេលនៃទសវត្សរ៍នោះ។ ការនាំចេញ ទាំងទំនិញនិងសេវាបានឆ្លើយតបជាវិជ្ជមាន ប៉ុន្តែក៏មានការកើនឡើងយ៉ាងគំហុកនៃការនាំចូលផងដែរ រួមទាំងផលិតផលកសិកម្ម។ អត្រាកំណើន




រូបទី ២.១២: អត្រាអ្នកគ្មានការងារធ្វើតាមភេទ ទសវត្សរ៍ឆ្នាំ ១៩៩០

ប្រភព : អង្គការពលកម្មអន្តរជាតិ ២០០៥ ( ILO )

ទូទៅបានធ្លាក់ចុះមួយកម្រិត ហើយកត្តាជម្រុញលើការនាំចេញលែងមានឥទ្ធិពល ប្រហែលជាដោយសារឥទ្ធិពលនៃកាត់បន្ថយការនាំចូលទៅលើវិស័យឧស្សាហកម្ម និងកសិកម្ម។

ទោះជាយ៉ាងណាក៏ដោយ អត្រាកំណើនការងារដែលមានកម្រិតតិចតួចនោះមិនមានការផ្លាស់ប្តូរទេ ជាសំខាន់ដោយសារកត្តាចំនួនបីគឺ : ទីមួយ ស្ថិរភាពនៃរចនាសម្ព័ន្ធឧស្សាហកម្ម ដែលអាចរក្សាបានដោយសារការពឹងផ្អែកជាបន្តទៀតទៅលើការនាំចេញផលិតផលកម្មន្តសាលអតិពលកម្ម។ ទីពីរ ការលេចឡើងនៃសេវាអតិពលកម្ម ដោយសារកំណើនយ៉ាងឆាប់រហ័សនៃការនាំចេញសេវា និងតួនាទីរបស់វិស័យក្រៅផ្លូវការ។ ទីបី ការប្រែប្រួលតិចតួចលើជម្រើសបច្ចេកទេសនៅក្នុងឧស្សាហកម្មនានា នៅពេលដែលអត្រាការប្រាក់ជាក់ស្តែងមានកម្រិតខ្ពស់ ដែលនាំឱ្យមានកំណើនថ្លៃនៃមូលធន និងភាពមិនសូវផ្លាស់ប្តូរនៃប្រាក់កម្រៃជាក់ស្តែង។

ផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើភាពក្រីក្រមានលក្ខណៈផ្ទុយមកវិញ ក្នុងករណីការវិនិច្ឆ័យផ្អែកលើទស្សនៈនៃការធ្លាក់ចុះនូវអត្រាកំណើន ជាពិសេសវិស័យកសិកម្ម។ ទោះជាបែបនេះក្តី វាមានលក្ខណៈវិជ្ជមាន បើយោងតាមទស្សនៈនៃភាពរីកចម្រើនយ៉ាងឆាប់រហ័សជាងមុនលើការនាំចេញផលិតផលកម្មន្តសាលអតិពលកម្ម និងសេវាកម្ម និងកំណែលំអខ្លះៗនៃទីផ្សារពលកម្មសម្រាប់កម្មករដែលពុំសូវមានជំនាញ និងកម្មការិនី។

នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ដំណើរការសេរីភាវូបនីយកម្មពាណិជ្ជកម្ម បានប្រព្រឹត្តទៅមួយរយៈរួចមកហើយនៅក្នុងប្រទេសភាគច្រើននៅអាស៊ីបូព៌ា។ លក្ខខណ្ឌនេះមានភាពទុំជោរ ដើម្បីឈានទៅបង្កើនអត្រាកំណើនដែលផ្អែកលើការនាំចេញ។ នេះគឺអ្វីដែលបានកើតឡើង : ការនាំចេញបានបង្ហាញអំពីអត្រាកំនើនពីរខ្ទង់ ជញ្ជីងពាណិជ្ជកម្មបានកែលំអជាច្រើន ហើយអត្រាកំណើនសេដ្ឋកិច្ចបានកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសនៅក្នុងវិស័យកម្មន្តសាល ប៉ុន្តែវិស័យកសិកម្មបានបាត់បង់ថាមភាពខ្លះៗ។ សមាសភាពនៃការនាំចេញមានការប្រែប្រួលយ៉ាងខ្លាំងផងដែរ។ ភាគរយនៃកសិផលបានធ្លាក់ចុះចំណែកទំនិញកម្មន្តសាលបានកើនឡើងយ៉ាងខ្លាំង។ នៅពេលដែលអាស៊ីបូព៌ាឈានទៅធ្វើការបែងចែកតាមបែបអន្តរជាតិនូវកម្លាំងពលករ ភាគរយនៃផលិតផលឧស្សាហកម្ម និងការនាំចេញផលិតផលបច្ចេកវិទ្យាខ្ពស់និងជំនាញខ្ពស់បានកើនឡើង ចំណែកផលិតផលអតិពលកម្មបានធ្លាក់ចុះ។ ទន្ទឹមនឹងនេះ ជម្រើសបច្ចេកទេសនៅក្នុងឧស្សាហកម្មនីមួយៗបានផ្លាស់ប្តូរទៅរកការប្រើប្រាស់មូលធនច្រើន។ ការអភិវឌ្ឍបែបនេះទទួលផលពីអត្រាការប្រាក់ទាប និងកំណើនយ៉ាងឆាប់រហ័សនៃប្រាក់កម្រៃជាក់ស្តែង ជាពិសេសដោយសារកំណើនផលិតភាពពលកម្ម។

ផលវិបាកគឺថា អត្រាកំណើនចំនួនការងារបានធ្លាក់ចុះ សូម្បីតែនៅក្នុងស្ថានភាពដែលមានកំណើនយ៉ាងឆាប់រហ័សនៃផលសម្រេចក៏ដោយ។ មាន "កំណើនភាពគ្មានការងារធ្វើ" ទាំងនៅក្នុងវិស័យកសិកម្ម និងកម្មន្តសាល។ អត្រារួមនៃភាពគ្មានការងារធ្វើបានកើនឡើង ហើយលក្ខខណ្ឌទីផ្សារការងារប្រហែលជាត្រូវធ្លាក់ចុះសម្រាប់កម្មករដែលគ្មានជំនាញ។ ការកើនឡើង

នៃគម្លាតរវាងប្រាក់ចំណូលនៅទីក្រុងនិងជនបទ រវាងមូលធន និងប្រាក់ចំណូលពីការងារ និងរវាងប្រាក់ចំណូលរបស់កម្មករជំនាញ និងកម្មករគ្មានជំនាញ បាននាំឱ្យមានកំណើនយ៉ាងខ្លាំងនូវវិសមភាព។ បរាជ័យនៃកំណើនចំនួនការងារ និងការកើនឡើងនូវគម្លាតនៃប្រាក់ចំណូលមានន័យថា ឥទ្ធិពល "ទំនាញ" នៃពាណិជ្ជកម្មយ៉ាងឆាប់រហ័ស និងកំណើនប្រាក់ចំណូលទៅលើការអភិវឌ្ឍមនុស្ស និងការកាត់បន្ថយភាពក្រីក្រមានកម្រិតកំណត់។

ជារួម ចំណងទាក់ទងរវាងពាណិជ្ជកម្ម និង កំណើន មានភាពជិតស្និទ្ធនៅអាស៊ីបូព៌ា ប៉ុន្តែចំណងទាក់ទងរវាងកំណើន និងភាពមានការងារធ្វើមានភាពទន់ខ្សោយ។ នៅអាស៊ីខាងត្បូង ទំនាក់ទំនងរវាងពាណិជ្ជកម្មនិងកំណើន មានភាពទន់ខ្សោយ ចំណែកទំនាក់ទំនងរវាងកំណើន និងភាពមានការងារធ្វើ មានភាពរឹងមាំជាង។

គួរកត់សម្គាល់ផងដែរថា ទោះបីមានបទពិសោធផ្ទុយគ្នានៃកំណើនតិចតួចជាងក៏ដោយ ប៉ុន្តែជាកំណើនដែលគាំទ្រជនក្រីក្រជាងនៅអាស៊ីខាងត្បូង ធៀបនឹងស្ថានភាពនៅអាស៊ីបូព៌ា។ តំបន់ទាំងពីរនេះបានបង្ហាញអត្រាថយចុះដូចគ្នាប្រមាណ ១% ក្នុងមួយឆ្នាំ នៅក្នុងអាំងស៊ីដង់នៃភាពក្រីក្រនៅក្នុងរយៈពេលពាក់កណ្តាលទីពីរនៃទសវត្សរ៍ឆ្នាំ ១៩៩០។ មេរៀនជាមូលដ្ឋានគឺថា ទោះបីកំណើនជារឿងសំខាន់ក្តី សភាពលក្ខណៈនៃកំណើននេះក៏សំខាន់ផងដែរ។

# 3



# ការធ្វើឱ្យពាណិជ្ជកម្មកសិផលជួយដល់ជនក្រីក្រ

៣
ជំពូក

ពាណិជ្ជកម្មអន្តរជាតិលើកសិផលអាចផ្តល់នូវលទ្ធផលចម្រុះ។ ម្យ៉ាងវាជួយផ្តល់ប្រយោជន៍ដល់អ្នកប្រើប្រាស់ដែលមានប្រាក់ចំណូលទាប ដោយបើកឱកាសឱ្យមានអាហារថោកៗ។ ម្យ៉ាងវិញទៀត វាគំរាមកំហែងមុខរបរចិញ្ចឹមជីវិតរបស់កសិករក្រីក្រ និងសហគមន៍អ្នកនេសាទ។ អ្នកកសាងគោលនយោបាយនៅអាស៊ីនិងប៉ាស៊ីហ្វិក ត្រូវធ្វើឱ្យមានតុល្យភាពរវាងកត្តាទាំងនេះនិងកត្តាដទៃទៀត ប្រសិនបើពួកគេត្រូវធានាថាពាណិជ្ជកម្មកសិផលលើកកម្ពស់ការអភិវឌ្ឍមនុស្ស។

ការបំលែងសេដ្ឋកិច្ច ជាធម្មតាផ្តោតជាពិសេសលើទំនើបកម្មតែនៅក្នុងទីក្រុង ប៉ុន្តែ នៅក្នុងប្រទេសដែលក្រីក្រជាងគេ ប្រជាពលរដ្ឋភាគច្រើនរស់នៅតាមទីជនបទ។ ដូច្នេះភាពជឿនលឿននៃការអភិវឌ្ឍមនុស្សនឹងកើតឡើងបានអាស្រ័យលើថាតើមានអ្វីកើតឡើងជាមួយសហគមន៍ជនបទតើទាក់ទងនឹងកសិកម្មឬជលផលដែរឬទេ។ ការរស់នៅរបស់អ្នកក្រីក្រនៅទីក្រុងក៏ពឹងផ្អែកផងដែរលើការសម្រេចបានយ៉ាងប្រសើរជាងមុននូវសន្តិសុខស្បៀង។

កសិកម្មមានសារៈសំខាន់ណាស់នៅទូទាំងតំបន់នេះ ប៉ុន្តែ សារៈសំខាន់នេះមានភាពខុសគ្នាយ៉ាងខ្លាំងពីប្រទេសមួយទៅប្រទេសមួយទៀត។ បើគិតជាសមាមាត្រនៃ GDP វិភាគទានរបស់កសិកម្មនៅក្នុងឆ្នាំ ២០០២ មានពី ៦% នៅសាធារណរដ្ឋកូរ៉េ រហូតដល់ ៥២% នៅប្រទេសឡាវ (តារាង ៣.១)។ សមាមាត្រចំនួនការងារនៃវិស័យនេះក៏មានភាពខុសគ្នាផងដែរ។ នៅឆ្នាំ ២០០០ អត្រានេះមានជិត ៧០% នៅប្រទេសវៀតណាម និងឥណ្ឌា មកតិចជាង ១% នៅសឹង្ហបូរី និងហុងកុង (តារាង ៣.២)។ ជាទូទៅ កសិកម្មមានសារៈសំខាន់ខ្លាំងជាងសម្រាប់ប្រទេសក្រីក្រ។

## អសន្តិសុខស្បៀងនៅអាស៊ី

នៅពេលដែលកសិកម្មទន់ខ្សោយ វាក៏មានឥទ្ធិពលធ្ងន់ធ្ងរផងដែរទៅលើសន្តិសុខស្បៀង។ អាស៊ីជាកន្លែងរស់នៅនៃប្រជាពលរដ្ឋ ៦៥% ដែលខ្វះសន្តិសុខស្បៀងនៅលើពិភពលោក ត្រូវជាច្រើនជាង ៥១០ លាននាក់ នៅទូទាំងតំបន់នេះ។

តារាង ៣.១

តម្លៃបន្ថែមក្នុងវិស័យកសិកម្មគិតជាភាគរយនៃ GDP

| 0.១-១0% | ១៥-២៥% | ២៥-៤0% | ៤0-៥៥% |
|---|---|---|---|
| ហុងកុង (ចិន) | ហ្វីលីពីន | បង់ក្លាដេស | នេប៉ាល់ |
| សឹង្ហបូរី | ចិន | ប៉ាគីស្ថាន | ឡាវ |
| ជប៉ុន | ហ្វីជី | ម៉ុងហ្គោលី | អាហ្គានីស្ថាន |
| អូស្ត្រាលី | គីរីបាទី | ប៊ុយតាន | ភូមា |
| ពិភពលោក | ឥណ្ឌូណេស៊ី | កម្ពុជា | |
| សាធារណរដ្ឋកូរ៉េ | ស្រីលង្កា | | |
| ម៉ូរីឡូស | វៀតណាម | | |
| ម៉ាឡេស៊ី | ឥណ្ឌា | | |
| ថៃ | | | |

**ប្រភព: ធនាគារពិភពលោក ២០០៥**

នៅពាក់កណ្តាលដើមទសវត្សរ៍ឆ្នាំ ១៩៩០ មានការរីកចម្រើនខ្លះៗ ប៉ុន្តែចាប់តាំងពីពេលនោះមក នៅក្នុងប្រទេសជាច្រើនលើកលែងតែប្រទេសចិន វៀតណាម និងថៃ ចំនួនជនអត់ឃ្លានបានកើនឡើង។ នៅចុងសតវត្សរ៍កន្លងទៅនេះ សូម្បីតែសាធារណរដ្ឋ កូរ៉េ និងម៉ាឡេស៊ី បានសង្កេតឃើញថា តួលេខអំពីចំនួនមនុស្សដែលខ្វះអាហារូបត្ថម្ភបាននៅទ្រឹងឬកើនឡើង។[1]

ឧទាហរណ៍ រវាងឆ្នាំ ១៩៩០ និង ១៩៩៥ ប្រទេសឥណ្ឌា មានការរីកចម្រើនយ៉ាងច្រើន ដោយបានកាត់បន្ថយចំនួនសរុបនៃជនអត់ឃ្លានបាន ១៣លាននាក់ ប៉ុន្តែនៅពាក់កណ្តាលទីពីរនៃទសវត្សរ៍ឆ្នាំ ១៩៩០ ទោះបីមានកំណើនសេដ្ឋកិច្ចក្តី ចំនួនជនអត់ឃ្លានបានកើនឡើង ១៨លាននាក់ ។[2] តាមពិតអាស៊ីបូព៌ាទាំងមូលមានប្រជាពលរដ្ឋដែលខ្វះអាហារូបត្ថម្ភជាចំនួនច្រើនបំផុតគឺ ២២% ដែលជាលំដាប់ទីពីរបន្ទាប់ពីអនុតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិក។

*កង្វះអាហារូបត្ថម្ភមិនមែនត្រឹមតែជាការបដិសេធសិទ្ធិក្នុងការទទួលសេវាសុខភាពប៉ុណ្ណោះទេ វាថែមទាំងមានឥទ្ធិពលធ្ងន់ធ្ងរខាងសេដ្ឋកិច្ចផងដែរ*

កង្វះអាហារូបត្ថម្ភមានឥទ្ធិពលជ្រាលជ្រៅ ដោយធ្វើឱ្យខូចសុខភាព និងធ្វើឱ្យពិការមួយជីវិតខាងកាយសម្បទា និងការយល់ដឹង ដែលជាការកាត់បន្ថយឱកាសក្នុងការរស់រានមានជីវិត។ វាក៏អាចបញ្ជូនពីជំនាន់មួយទៅជំនាន់បន្ទាប់ផងដែរ។ កង្វះអាហារូបត្ថម្ភមានឥទ្ធិពលបំផុតចំពោះស្ត្រី ហើយនៅពេលស្ត្រីខ្វះអាហារូបត្ថម្ភសម្រាលទារកភេទស្រីដែលពុំមានទម្ងន់គ្រប់គ្រាន់ ទារកទាំងនោះក៏ធំឡើងក្លាយជាមាតាដែលខ្វះអាហារូបត្ថម្ភផងដែរ ដែលជាការធ្វើឱ្យប្រការនេះនៅវិលវល់ឆ្លងកាត់ជំនាន់មនុស្ស។ នៅឥណ្ឌា និង បង់ក្លាដេស កុមារច្រើនជាង ៣០% កើតមកមិនគ្រប់ទម្ងន់ ។

កង្វះអាហារូបត្ថម្ភមិនមែនត្រឹមតែជាការបដិសេធសិទ្ធិក្នុងការទទួលសេវាសុខភាពប៉ុណ្ណោះទេ វាថែមទាំងមានឥទ្ធិពលធ្ងន់ធ្ងរខាងសេដ្ឋកិច្ចផងដែរ។ កុមារដែលខ្វះអាហារូបត្ថម្ភពុំសូវមានលទ្ធភាពក្នុងការប្រមូលផ្តុំអារម្មណ៍នៅក្នុងការសិក្សាឡើយ ហើយមនុស្សជំទង់ដែលខ្វះអាហារូបត្ថម្ភ ពុំសូវមានលទ្ធភាពធ្វើការប្រកបដោយប្រសិទ្ធភាពឡើយ ដូច្នេះធ្វើឱ្យខូចផលិតភាពនិងកំណើនសេដ្ឋកិច្ច។ បន្ថែមលើនេះទៀតគឺមានការចំណាយបន្ថែម ទាំងការចំណាយផ្ទាល់ខ្លួន និងសាធារណៈក្នុងការដោះស្រាយបញ្ហាសុខភាពទន់ខ្សោយ។ នៅបង់ក្លាដេស កង្វះអាហារូបត្ថម្ភត្រូវបានចាត់ទុកថានាំឱ្យមានការចំណាយរហូតដល់ ៨% នៃ GDP។ នៅឥណ្ឌា ការចំណាយលើបញ្ហាកង្វះជាតិដែកតែមួយមុខ មានរហូតដល់ច្រើនជាង ៣០.០០០លានដុល្លារ។[3]

តារាង ៣.២

ភាគរយនៃចំនួនការងារនៅក្នុងវិស័យកសិកម្ម

| ០-៦% | ១២-២៥% | ៣៧-៥០% | ៥០-៨០% |
|---|---|---|---|
| សឹង្ហបូរី | សាធារណរដ្ឋកូរ៉េ | ស្រីលង្កា | ថៃ |
| ហុងកុង | ម៉ូរីទ្យុស | ពិភពលោក | ឥណ្ឌា |
| ជប៉ុន | ម៉ាឡេស៊ី | ហ្វីលីពីន | វៀតណាម |
| ហ្វីជី | ម៉ាល់ឌីវ | ម៉ុងហ្គោលី | ណេប៉ាល់ |
| អូស្ត្រាលី | | ឥណ្ឌូណេស៊ី | |
| ជប៉ុន | | ប៉ាគីស្ថាន | |
| គីរីបាទី | | ចិន | |

**ប្រភព: ធនាគារពិភពលោក ២០០៥**

## ឥទ្ធិពលនៃពាណិជ្ជកម្ម

នៅក្នុងកាលៈទេសៈទាំងនេះ ការចូលរួមកាន់តែសកម្មនៅក្នុងពាណិជ្ជកម្មកសិផលជាអន្តរជាតិ ទំនងជាមានឥទ្ធិពលចំបងវិជ្ជមានឬអវិជ្ជមាន ទៅលើការរស់នៅរបស់ប្រជាជនក្រីក្រ។ ឥទ្ធិពលវិជ្ជមានគឺកំណើនការនាំចេញកសិផលគួរតែសម្រួលឱ្យមានកំណើនការងារ និងប្រាក់ចំណូលនៅក្នុងវិស័យនេះ និងមានឥទ្ធិពលទ្វេគុណទៅលើផលប្រយោជន៍ទាក់ទងនឹងការផ្គត់ផ្គង់និងឧស្សាហកម្មសេវាកម្ម។

ទោះជាយ៉ាងណាក៏ដោយ សេណារីយ៉ូប្រកបដោយមោទនភាពប្រហែលមិនអាចសម្រេចទៅបានទេ។ ទីមួយ កិច្ចប្រឹងប្រែងដើម្បីជម្រុញការនាំចេញ អាចត្រូវរារាំងដោយអ្នកធ្វើគោលនយោបាយនៅក្នុងប្រទេសនាំចូល។ បើទោះជាការនាំចេញកើនឡើងក៏ដោយ វាអាចបានត្រឹមតែទូទាត់ជាមួយកំណើននៃការនាំចូលប៉ុណ្ណោះ ដែលអាចធ្វើឱ្យក្រុមមនុស្សខុសគ្នាអស់ការងារធ្វើ។ ឧស្សាហកម្មនាំចេញក៏ពុំសុទ្ធតែផ្ដល់ប្រយោជន៍ដល់ផ្នែកផ្សេងទៀតនៃសេដ្ឋកិច្ចឡើយ។ ប្រសិនបើវាពុំទាក់ទងជាមួយសហគ្រាសជនបទទេនោះ "មេគុណ" សេដ្ឋកិច្ចអាចមានកម្រិតទាប។ ប្រាក់ចំណូលរបស់រដ្ឋាភិបាលក៏អាចមានទំហំតូចជាងការរំពឹងទុកផងដែរ ប្រសិនបើរដ្ឋកាត់បន្ថយអត្រាពន្ធដើម្បីលើកទឹកចិត្តឱ្យមានពាណិជ្ជកម្ម នោះប្រាក់ចំណូលអាចនឹងធ្លាក់ចុះ។

កត្តាផ្សេងៗទៀតក៏អាចធ្វើឱ្យសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងកំណើនការនាំចេញផ្ដល់ផលមិនសមបំណងដែរ។ ឧទាហរណ៍ ប្រសិនបើប្រទេសនាំចេញផ្ដោតតែលើមុខទំនិញបឋម ដូចជាកាហ្វេឬតែ នោះកំណើនបរិមាណនាំចេញអាចធ្វើឱ្យជន់ទៅទីផ្សារពិភពលោកដែលធ្វើឱ្យធ្លាក់ថ្លៃ។ ប្រទេសខ្លះអាចមានលទ្ធភាពបញ្ចៀសអន្ទាក់នេះបាន ដោយបង្កើនមុខផលិតផលដែលមានតម្លៃខ្ពស់ ប៉ុន្តែ ប្រទេសក្រីក្រអាចពុំមានសមត្ថភាព ឬហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់។ លទ្ធភាពមួយផ្សេងទៀតគឺថា ភាគច្រើននៃអត្ថប្រយោជន៍ដែលបានពីកំណើនការនាំចេញអាចត្រូវស្រូបយកដោយពាណិជ្ជកម្មអន្តរជាតិ និងក្រុមហ៊ុនកម្មន្តសាល ហើយអ្នកដាំដុះបានទទួលផលចំណេញត្រឹមតិចតួចតែប៉ុណ្ណោះ។

## ទម្រង់នៃពាណិជ្ជកម្មកសិផលពិភពលោក

ទោះបីពាណិជ្ជកម្មទំនិញកសិផលបានកើនឡើងក្តី មានតែសមាមាត្រតិចតួចនៃកសិផលតែប៉ុណ្ណោះ ដែលត្រូវបាននាំចេញ ហើយភាគច្រើននៅតែបានត្រឹមប្រើប្រាស់នៅក្នុងប្រទេសនៅឡើយ។ សម្រាប់ផលដំណាំដែលជាអាហារសំខាន់ៗ មានតែស្រូវសាលីទេដែលមានការធ្វើពាណិជ្ជកម្មជាប្រចាំក្នុងបរិមាណច្រើនជាង ១០% នៃផលិតផលសរុបលើពិភពលោក

តារាង ៣.៣

ភាគចំណែកនៃកសិផលមួយចំនួនដែលបានធ្វើពាណិជ្ជកម្មឆ្លងដែនលើពិភពលោក ឆ្នាំ ២០០៥

| មុខទំនិញ | សមាមាត្រដែលធ្វើពាណិជ្ជកម្មជាអន្តរជាតិ (%) |
|---|---|
| កាហ្វេ | ៦៨ |
| តែ | ៤០ |
| សណ្ដែកសៀង | ៣៤ |
| ស្ករ | ២១ |
| ចេក | ២០ |
| កប្បាស | ១៨ |
| ស្រូវសាឡី | ១៧ |
| ធញ្ញជាតិជាអាហារ | ១១ |
| ស្រូវ | ២ |

ប្រភព: FAS, USDA ២០០៥




រូបទី ៣.១: ថ្លៃចំណាយលើការនាំចូលស្បៀងជាលក្ខណៈជំនួញ

ប្រភព : FAO ២០០៣

(តារាង ៣.៣)។ សមាមាត្រនេះ ទំនងជាខ្ពស់ជាងនេះសម្រាប់ដំណាំចំការធំៗ ហើយទោះបីសម្រាប់ដំណាំទាំងនេះក្តី មានតែមុខដំណាំមួយចំនួនតូចតែប៉ុណ្ណោះ ដូចជាកាហ្វេ ដែលមានសមាមាត្រច្រើនជាង ៥០% នៃផលិតផលលើពិភពលោក។

ភាគច្រើននៃពាណិជ្ជកម្មកសិផលលើពិភពលោកគឺរវាងប្រទេសជឿនលឿននានា ដែលផលនាំចេញ និងនាំចូលរវាងប្រទេសទាំងនេះនៅលើពិភពលោក មានប្រមាណ ៧០%។ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ពុំសូវអនុវត្តបានល្អទេ។ ពួកគេពុំត្រឹមតែមានអត្រាទាបនៃកសិផលនៅក្នុងពាណិជ្ជកម្មប៉ុណ្ណោះទេ ប្រទេសទាំងនោះក៏រកចំណូលបានតិចតួចផងដែរពីពាណិជ្ជកម្ម។ នៅក្នុងឆ្នាំថ្មីៗនេះ ប្រទេសទាំងនោះបានបាត់បង់តុល្យភាពពាណិជ្ជកម្ម រវាងការនាំចេញ និងនាំចូល។ នៅដើមទសវត្សរ៍ឆ្នាំ ១៩៦០ ប្រទេសទាំងនោះមានអតិរេកពាណិជ្ជកម្មកសិផលជារួមប្រចាំឆ្នាំ ប្រមាណ ៧.០០០លានដុល្លារ ប៉ុន្តែនៅដើមទសវត្សរ៍ឆ្នាំ ១៩៧០ អតិរេកពាណិជ្ជកម្មនៃប្រទេសទាំងនោះ បានថយចុះមកត្រឹមប្រមាណ ១.០០០លានដុល្លារ ហើយនៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ អតិរេកនេះបានបាត់ទាំងស្រុង។ តាមពិត ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០មកជាទូទៅ ប្រទេសកំពុងអភិវឌ្ឍន៍បានក្លាយជាអ្នកនាំចូលសុទ្ធនូវកសិផល ដោយមានឱនភាព ១១.០០០លានដុល្លារ នៅក្នុងឆ្នាំ ២០០១។[៦]

ឱនភាពនេះបានកើនឡើងដោយសារកំណើនការនាំចូលស្បៀង។ នៅឆ្នាំ ២០០១ នៅទូទាំងពិភពលោក ប្រទេសអភិវឌ្ឍន៍តិចតួចបាននាំចូលស្បៀងដោយតម្លៃ ៤.៨០០លានដុល្លារ ដែលត្រូវនឹង ១០% ទៅ ១២% នៃអត្រាកាឡូរីដែលបរិភោគនៅក្នុងប្រទេស។ "ប្រទេសកំពុងអភិវឌ្ឍន៍ដែលជាអ្នកនាំចូលសុទ្ធនូវស្បៀងអាហារ" មានការពឹងផ្អែកលើការនាំចូលកាន់តែច្រើនឡើង។ នៅក្នុងឆ្នាំដដែលនោះ ប្រទេសទាំងនោះនាំចូលក្នុងតម្លៃ ១០.១០០លានដុល្លារ ដែលត្រូវនឹង ៣៥% នៃអត្រាកាឡូរីដែលបរិភោគនៅក្នុងប្រទេស។ តម្លៃនៃការនាំចូល អាចត្រូវបានចាត់ទុកថាទាបជាងកម្រិតអតិបរមានៅក្នុងឆ្នាំ ១៩៩៦ (រូបទី ៣.១) នៅពេលដែលថ្លៃស្បៀងកើនឡើងខ្ពស់ ប៉ុន្តែក្នុងលក្ខខណ្ឌជាក់ស្តែង នៅក្នុងទសវត្សរ៍ថ្មីៗនេះ មានការកើនឡើងច្រើនជាង ៦% ក្នុងមួយឆ្នាំ។

ការប្រែប្រួលនេះមានភាពធ្ងន់ធ្ងរបំផុតសម្រាប់ LDCs។ ពីដំបូងប្រទេសទាំងនេះគឺជាអ្នកនាំចេញសុទ្ធនូវស្បៀងអាហារ តែក្រោយមកបានក្លាយជាអ្នកនាំចូលសុទ្ធនូវស្បៀង។ តាមពិត នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ ការនាំចូលរបស់ប្រទេសទាំងនេះមានច្រើនជាងពីរដងនៃការនាំចេញ។ សម្រាប់ប្រទេសទាំងពីរក្រុមនេះ គម្លាតនៃពាណិជ្ជកម្មនេះ ទំនងជាកាន់តែកើនឡើងជាបន្ថែមទៀត។ រវាងឆ្នាំ ១៩៧០ និង ២០០១ ប្រទេសកំពុងអភិវឌ្ឍន៍ទាំងមូលបានឃើញថា ស្បៀងរបស់ខ្លួនកើនឡើង ១១៥% ប៉ុន្តែនៅឆ្នាំ ២០៣០ ការនាំចូលប្រចាំឆ្នាំរបស់ប្រទេសទាំងនោះ ត្រូវបានរំពឹងថានឹងកើនឡើងដល់ ៥០.០០០លានដុល្លារ។ ប្រទេសជឿនលឿនក៏នឹងមានការកើនឡើងនៅក្នុងរយៈពេលដូចគ្នានេះដែរ ប៉ុន្តែ ត្រឹមប្រមាណ ៤៥% ប៉ុណ្ណោះ។[៧]

ប្រទេសជឿនលឿនមិនត្រឹមតែបានប្រទះនឹងកំណើនឱនភាពពាណិជ្ជកម្មស្បៀងនោះទេ ពួកគេក៏ទទួលការខូចខាតផងដែរទាក់ទងនឹងពាណិជ្ជកម្មកសិផល។ ទោះបីជារួម ថ្លៃទំនិញទាំងនេះបានធ្លាក់ចុះនៅក្នុងអំឡុង ៤០ឆ្នាំ កន្លងមកនេះក៏ដោយ ការធ្លាក់ចុះយ៉ាងគំហុកបំផុតគឺប្រភេទនៃការនាំចេញដែលភាគច្រើនមកពីប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា វត្ថុធាតុដើម ភេសជ្ជៈត្រូពិក ដំណាំយកប្រេង និងធញ្ញជាតិ ជាងចំពោះទំនិញដែលភាគច្រើននាំចេញដោយប្រទេសជឿនលឿន ដូចជា ផលិតផលសាកវប្បកម្ម សាច់ និងផលិតផលទឹកដោះ។

ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះបានឆ្លើយតបដោយធ្វើការ

*ប្រទេសជឿនលឿនមិនត្រឹមតែប្រទះនឹងកំណើនឱនភាពពាណិជ្ជកម្មស្បៀងនោះទេ ពួកគេក៏ទទួលការខូចខាតផងដែរទាក់ទងនឹងពាណិជ្ជកម្មកសិផល*

ផ្លាស់ប្តូរពីភេសជ្ជៈត្រូពិក និងវត្ថុធាតុដើម ដូចជាកាហ្វេ តែ កាកាវ ស្ករ កប្បាស និងថ្នាំជក់ ទៅដំណាំមានតម្លៃខ្ពស់វិញ។ ប៉ុន្តែ ការធ្វើបែបនេះមានភាពលំបាកសម្រាប់កសិករនៅ LDCs ដែលភាគច្រើនខ្វះមូលនិធិសម្រាប់វិនិយោគ។ ជាលទ្ធផល ចំពោះ LDCs នៅវាងទសវត្សរ៍ឆ្នាំ ១៩៦០ និងឆ្នាំ ១៩៩៩-២០០០ សមាមាត្រនៃការនាំចេញវត្ថុធាតុដើម និងភេសជ្ជៈត្រូពិកពីប្រទេសទាំងនោះបានកើនឡើងពី ៥៩% ទៅ ៧២%។

## បណ្តាប្រទេសធ្វើពាណិជ្ជកម្មស្បៀង

ប្រទេសកំពុងអភិវឌ្ឍន៍ដែលធ្វើពាណិជ្ជកម្មជាអន្តរជាតិនូវដំណាំស្បៀង ពិសេសធញ្ញជាតិ អង្ករ និងសាច់ ត្រូវបានចាត់ទៅក្នុងក្រុមមួយក្នុងចំណោមក្រុមបីខាងក្រោម៖

១. *អ្នកនាំចេញផលធម្មជាតិ* ៖ ប្រទេសទាំងនេះមានលក្ខខណ្ឌភូមិសាស្ត្រអំណោយផល ប្រជាជនរស់នៅដាច់ឆ្ងាយពីគ្នា ឬមានបទពិសោធដោយឡែកដែលបានលើកទឹកចិត្តឱ្យមានដំណាំកសិកម្មលើវិសាលភាពដីធំទូលាយ និងចំណាយតិច ដែលផ្តល់ឱ្យនូវផលជាស្បៀងអាហារច្រើនលើសតម្រូវការចាំបាច់។[៦] នៅអាស៊ី ប្រទេសទាំងនេះរួមមាន ថៃ (ស្រូវ និងសត្វចិញ្ចឹម) និងវៀតណាម (ស្រូវ)។

២. *ប្រទេសដែលពឹងផ្អែកលើខ្លួនឯង* ទាំងនេះ គឺជាបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ធំៗ ដែលច្រើនទ្រទ្រង់ខ្លួនឯងបានលើផ្នែកស្បៀង។ នៅពេលប្រទេសទាំងនេះធ្វើពាណិជ្ជកម្មនៅលើទីផ្សារពិភពលោក ពួកគេច្រើនតែទិញជាងលក់ ប៉ុន្តែ ជាទូទៅ ពួកគេមានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការនាំចូល ដោយនាំចេញកសិផលដទៃទៀត ជាពិសេសផលដំណាំត្រូពិក។

៣. *ប្រទេសអ្នកនាំចូលសុទ្ធ* ៖ ប្រទេសទាំងនេះជាច្រើនក៏ស្ថិតក្នុងចំណោមប្រទេសក្រីក្របំផុតផងដែរ ដែលពឹងផ្អែកជាយូរលង់លើការនាំចូលស្បៀងជាមូលដ្ឋាន។ ចំនួនប្រទេសបែបនេះអាចនឹងកើនឡើងនៅក្រោយសេរីភាវូបនីយកម្មពាណិជ្ជកម្ម ប្រសិនបើស្បៀងអាហារដែលនាំចូលប្រកបដោយថ្លៃថោកអាចលើកទឹកចិត្តឱ្យកសិករ និងអ្នកជំនួញផ្លាស់ប្តូរទៅរកមុខដំណាំពាណិជ្ជកម្មដែលឱ្យផលចំណេញច្រើនជាង។

បណ្តាប្រទេសជឿនលឿនអាចត្រូវបែងចែកជាក្រុមដូចគ្នានេះដែរ។ ប្រទេសអូស្ត្រាលី កាណាដា និងសហរដ្ឋអាមេរិក ក៏ជាប្រទេសនាំចេញផលធម្មជាតិដែលជាស្បៀងសំខាន់ៗផងដែរ។ អឺរ៉ុបក៏មានការនាំចេញស្ករយ៉ាងច្រើនផងដែរ ប៉ុន្តែ ប្រទេសនៅសហភាពអឺរ៉ុបអាចមានឈ្មោះប្រសើរជាងថាជា "អ្នកនាំចេញផលមិនមែនធម្មជាតិ" ព្រោះថា ផលលើសពីតម្រូវការរបស់ប្រទេសទាំងនេះច្រើនតែកើនឡើងដោយសារការឧបត្ថម្ភធន។ ប្រទេសផ្សេងទៀតជាច្រើនគឺជាអ្នកនាំចូលសុទ្ធ ប៉ុន្តែពុំមានការលំបាកក្នុងការរកហិរញ្ញវត្ថុសម្រាប់ទូទាត់ការនាំចូលនេះទេ ដោយធ្វើតាមរយៈការនាំចេញផលិតផលឧស្សាហកម្ម។

ជញ្ជីងពាណិជ្ជកម្មស្បៀងទាំងមូលរវាងប្រទេសជឿនលឿននិងប្រទេសកំពុងអភិវឌ្ឍន៍ មានភាពខុសគ្នាទៅតាមមុខផលិតផល។ ឧទាហរណ៍ភាគច្រើននៃការនាំចូលស្រូវ និងស្រូវសាឡី (៨០% នៃបរិមាណសរុបដែលធ្វើពាណិជ្ជកម្មនៅលើពិភពលោក) ក៏ដូចជាបរិមាណដ៏ច្រើននៃធញ្ញជាតិ និងសណ្តែក

សៀងផងដែរ បានធ្វើឡើងដោយប្រទេសកំពុងអភិវឌ្ឍន៍។ ចំពោះផលិតផលពីសត្វ ទម្រង់នាំចេញមានភាពខុសគ្នា។ គ្រប់ការនាំចូលផលិតផលពីសត្វដែលមានតម្លៃខ្ពស់ដូចជា សាច់គោ សាច់ជ្រូក សត្វស្លាប និងហ្វ្រូម៉ាស បានធ្វើឡើងដោយប្រទេសជឿនលឿនមកពីប្រទេសជឿនលឿនដូចគ្នា ឬមកពីប្រទេសកំពុងអភិវឌ្ឍន៍។ ផលិតផលតែមួយមុខដែលត្រូវបាននាំចូលក្នុងបរិមាណច្រើនដោយប្រទេសកំពុងអភិវឌ្ឍន៍គឺ ម្សៅទឹកដោះ

តារាង ៣.៤

ប្រទេសនាំមុខក្នុងការនាំចេញកសិផលនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្នាំ ២០០៣

| | លានដុល្លារ | ភាគលើទីផ្សារ (%) |
|---|---|---|
| ចិន | ២២.១៥៨ | ៣.៣ |
| អូស្ត្រាលី | ១៦.៣៣៧ | ២.៤ |
| ថៃ | ១៥.០៨១ | ២.២ |
| ម៉ាឡេស៊ី | ១១.០៦១ | ១.៦ |
| ឥណ្ឌូណេស៊ី | ៩.៩៤២ | ១.៥ |
| នូវ៉ែលហ្សេឡង់ | ៩.៦០៣ | ១.៤ |

**ប្រភព៖ គណនាដោយផ្អែកលើមូលដ្ឋានទិន្នន័យស្ថិតិ Online របស់ WTO ដែលបានបើកមើលនៅ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៥**




រូបទី ៣.២៖ លំដាប់នៃប្រទេសនាំចេញ : ការប្រៀបធៀបរវាងទំនិញសម្រាប់លក់ និងកសិផល

ប្រភព : ផ្អែកលើធនាគារពិភពលោក

ដែលមានថ្លៃថោក ដែលក្នុងនោះ ៨៥% នៃពាណិជ្ជកម្មពិភពលោកគឺបញ្ជូនទៅទិសខាងត្បូង។

## ពាណិជ្ជកម្មកសិផលនៅតំបន់អាស៊ី_ប៉ាស៊ីហ្វិក

បណ្តាប្រទេសនៅតំបន់អាស៊ីប៉ាស៊ីហ្វិក មានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើពាណិជ្ជកម្មកសិផល។ ប៉ុន្តែ ជាទូទៅ ពួកគេកម្រក្លាយជាការីចម្បងៗណាស់។ សូម្បីតែប្រទេសនាំចេញធំជាងនៅតំបន់នេះក្តី ដូចជាចិន ត្រូវបានចាត់ថ្នាក់នៅលំដាប់ទី ៩ ដែលមានបរិមាណត្រឹម ៣% នៃពាណិជ្ជកម្មពិភពលោកប៉ុណ្ណោះ (តារាង ៣.៤)។

ទោះបីប្រទេសមួយចំនួននៅអាស៊ីបាននាំចេញកសិផលខ្លះៗក្តី ពួកគេមានតួនាទីសំខាន់ជាងនៅក្នុងផ្នែកផ្សេងនៃពាណិជ្ជកម្មអន្តរជាតិជាពិសេសការនាំចេញផលិតផលកម្មន្តសាល។ ប្រការនេះមានបង្ហាញនៅក្នុងរូប ៣.២ ដែលបង្ហាញពីប្រទេសនានាទៅតាមលំដាប់ជាអ្នកនាំចេញទំនិញសម្រាប់លក់និងជាអ្នកនាំចេញកសិផល។ ប្រទេសជប៉ុនស្ថិតនៅក្នុងលំដាប់ទី ២ ខាងការធ្វើពាណិជ្ជកម្មលើទំនិញសម្រាប់លក់ ប៉ុន្តែស្ថិតនៅលំដាប់ទី ៨ ខាងការធ្វើពាណិជ្ជកម្មកសិផល។ តាមពិត ប្រទេសណាមួយដែលស្ថិតនៅក្រោមខ្សែបន្ទាត់ ៤៥ អង្សា គឺជាប្រទេសដែលផ្តោតជាសំខាន់លើការនាំចេញទំនិញសម្រាប់លក់ ជាងការនាំចេញកសិផល។ ម៉្យាងវិញទៀត អូស្ត្រាលី ថៃ ឥណ្ឌូនេស៊ី និងនូវ៉ែលហ្សេឡង់ ស្ថិតនៅលំដាប់ខ្ពស់ជាងនៃការធ្វើពាណិជ្ជកម្មកសិផល។ ក្នុងចំណោមការនាំចេញដែលនាំមុខគេនូវទំនិញជំពូកណាមួយខាងលើ មានតែប្រទេសចិនទេដែលឈរក្នុងលំដាប់ដូចគ្នាសម្រាប់ទំនិញទាំងពីរបែប។

ជាគោលការណ៍ មាគ៌ាឆ្ពោះទៅជោគជ័យសម្រាប់ប្រទេសជាច្រើននៅអាស៊ី ទំនងជាផ្អែកច្រើនជាងទៅលើវិស័យមិនមែនកសិកម្ម ទោះបីប្រទេសខ្លះ ដូចជា ម៉ាឡេស៊ី និង

សាធារណរដ្ឋកូរ៉េ បានអភិវឌ្ឍវិស័យនាំចេញរបស់ខ្លួនដោយវិនិយោគលើផលលើសពីតម្រូវការនៃកសិផលនៅក្នុងប្រទេសខ្លួនក៏ដោយ។ សូម្បីតែឥឡូវនេះ វៀតណាម មានការនាំចេញកសិផលដែលជាប្រភពដ៏សំខាន់នៃរូបិយប័ណ្ណបរទេសក៏ដោយ ប្រទេសនេះនឹងនៅតែត្រូវរងគ្រោះដោយសាររាល់ការគាបសង្កត់ក្នុងផ្នែកពាណិជ្ជកម្ម។

ការព្រួយបារម្ភបន្ថែមទៀតទៅអនាគតគឺលទ្ធភាពនៃកង្វះស្បៀង។ ឥឡូវប្រទេសចិនបានក្លាយជាអ្នកនាំស្បៀងចេញចម្បង។ ការផ្គត់ផ្គង់ស្បៀងលើពិភពលោកអាចកាន់តែតឹងតែងជាងនេះច្រើន ដែលនាំឱ្យមានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរសម្រាប់អ្នកនាំចូលស្បៀងចម្បងៗ។ ស្បៀងមិនដូចទំនិញផ្សេងទៀតដែលអាចធ្វើពាណិជ្ជកម្មបាននោះទេ ដូច្នេះ ប្រទេសមួយចំនួននៅក្នុងតំបន់នេះអាចជាប់ដៃកាន់តែខ្លាំងឡើងជាមួយបញ្ហាសន្តិសុខស្បៀងនៅក្នុងប្រទេស ហើយអាចនឹងប្រឹងប្រែងធ្វើខ្លួនឱ្យក្លាយជាប្រទេសដែលពឹងផ្អែកលើខ្លួនឯងសម្រាប់ការផ្គត់ផ្គង់ស្បៀង។ ប្រការនេះនឹងមានឥទ្ធិពលកាន់តែខ្លាំងឡើងទៅលើកិច្ចការពារកសិករដែលមានការលំបាកក្នុងការប្រកួតប្រជែងតាមថ្លៃលើទីផ្សារពិភពលោក ជាពិសេសនៅពេលដែលថ្លៃទាំងនេះស្ថិតក្រោមការគាបសង្កត់ពីការឧបត្ថម្ភធននៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។

## ការនិយមនយោបាយការពារនៅភាគខាងជើង

មូលហេតុមួយដែលនាំឱ្យប្រទេសកំពុងអភិវឌ្ឍន៍មានតួនាទីតិចតួចនៅក្នុងទីផ្សារកសិផលអន្តរជាតិ គឺដោយសារការប្រឈមនឹងកិច្ចការពារយ៉ាងដាច់ខាត និងអយុត្តិធម៌។ ទោះបីមានការសន្យាកាត់បន្ថយរបាំងពាណិជ្ជកម្មក្តី ប្រទេសជឿនលឿនជាច្រើននៅតែបន្តការពារកសិកររបស់ខ្លួនពីការប្រកួតប្រជែងពីបរទេស។[៧]

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ មានភាពរីកចម្រើនខ្លះៗ។ សម្រាប់ OECD ទាំងមូល រវាងឆ្នាំ ១៩៨៦-៨៨ និង ១៩៩៥-៩៧ កម្រិតនៃការឧបត្ថម្ភដល់ផលិតករ គិតជាភាគរយនៃផលចំណូលនៅកសិដ្ឋាន បានធ្លាក់ចុះពី ៣៧% មក ៣០%។[៨] ជាអកុសលអត្រានេះនៅពុំប្រែប្រួលតាំងពីពេលនោះមក។ នៅឆ្នាំ ២០០៤ ការឧបត្ថម្ភធននេះមានតម្លៃ ២៧៩.០០០លានដុល្លារ ដែលរាប់បញ្ចូលការឧបត្ថម្ភសម្រាប់សេវាទូទៅក្នុងវិស័យកសិកម្ម ដូចជា ការស្រាវជ្រាវ ហេដ្ឋារចនាសម្ព័ន្ធ ការត្រួតពិនិត្យ ការរកទីផ្សារនិងការផ្សព្វផ្សាយ។ ការឧបត្ថម្ភសរុបដល់វិស័យកសិកម្មមានដល់ ១.២% នៃ GDP របស់ OECD។ សមាសភាពនៃការឧបត្ថម្ភនេះអាចមានការប្រែប្រួលពោលគឺវិធានការជំនួសដែលត្រូវបានចាត់ទុកថាជាការគាបសង្កត់ពាណិជ្ជកម្ម ជាមួយផ្នែកដែលមិនគួរបានទទួលការឧបត្ថម្ភ ប៉ុន្តែអត្រារួមនៅតែមិនប្រែប្រួល និងមានកម្រិតខ្ពស់សម្រាប់ផលិតផលដែលសំខាន់បំផុតចំពោះអាស៊ី ដូចជាស្រូវ ស្ករទឹកដោះ ស្រូវសាឡី និងសាច់។

ដោយសារការឧបត្ថម្ភធនទាំងនេះ ផលិតករនៃផលិតផលជាច្រើនមុខ រួមទាំង ពោត ស្រូវសាឡី ស្រូវ សណ្តែក ផលិតផលពីទឹកដោះ សាច់ និងកប្បាស អាចចាក់ចោលផលិតផលទាំងនេះនៅលើទីផ្សារពិភពលោក ធ្វើឱ្យប្រទេសកំពុងអភិវឌ្ឍន៍មានការលំបាកក្នុងការប្រកួតប្រជែង។

នៅក្នុងកិច្ចព្រមព្រៀងស្តីពីកសិកម្មដែលកើតឡើងពីការចរចាពាណិជ្ជកម្មនៅអ៊ុយរ៉ាហ្គាយឆ្នាំ ១៩៨៦-១៩៩៤ ប្រទេសជឿនលឿនបានប្តេជ្ញាកាត់បន្ថយវិសាលភាពនៃការឧបត្ថម្ភនៅក្នុងប្រទេសរបស់ខ្លួន។ ប៉ុន្តែ បទបញ្ញានេះមិនចំទិសទេ ដោយសារទោះបីបទបញ្ញាទាំងនោះទប់ស្កាត់ប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលកម្រិតកណ្តាលពីការឧបត្ថម្ភធន

មូលហេតុមួយដែលនាំឱ្យប្រទេសកំពុងអភិវឌ្ឍន៍មានតួនាទីតិចតួចនៅក្នុងទីផ្សារកសិផលអន្តរជាតិគឺដោយសារការប្រឈមនឹងកិច្ចការពារយ៉ាងដាច់ខាត និងអយុត្តិធម៌

ក្តី វាបានបើកលទ្ធភាពឱ្យសហភាពអឺរ៉ុបបន្តផ្តល់ការឧបត្ថម្ភបែបនេះ (តារាង ៣.៥) និងបង្កើនការឧបត្ថម្ភធននៅសហរដ្ឋអាមេរិក។

តាមពិត សហរដ្ឋអាមេរិកបានបង្កើនយ៉ាងច្រើននូវបរិមាណដែលខ្លួនចំណាយលើការឧបត្ថម្ភធន (តារាង៣.៧)។ ប្រការនេះបានធ្វើប្រទេសនេះ នៅរក្សាការត្រួតត្រាលើពោត និងសណ្តែកសៀង ដែលពាក់កណ្តាលនៃផលិតផលនេះលើផ្សារពិភពលោក បានត្រួតត្រាដោយសហរដ្ឋអាមេរិក។ ប្រទេសនេះក៏ក្លាយជាអ្នកនាំចេញស្រូវនាំមុខផងដែរ។

*ការឧបត្ថម្ភធនបានធ្វើឱ្យប្រទេស OECD អាចនាំចេញមុខទំនិញមួយចំនួនតាមថ្លៃដែលទាបជាងថ្លៃផលិត*

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងស្តីពីកសិកម្ម ភាគច្រើននៃការចំណាយនេះ (៧០% ធ្វើឡើងដោយអាមេរិក និង ៤៤% ដោយសហភាពអឺរ៉ុប) ត្រូវបានចាត់ទុកថា មិនមែនជាការឧបត្ថម្ភធនសម្រាប់ការនាំចេញទេ ប៉ុន្តែ ថាជាការចំណាយលើ "ប្រអប់បៃតង" លើលក្ខខណ្ឌដូចជាការស្រាវជ្រាវ និងផ្សព្វផ្សាយ ដែលត្រូវបានចាត់ទុកថា មានឥទ្ធិពលអប្បរមាលើពាណិជ្ជកម្ម ហើយដែលការឧបត្ថម្ភអាចពុំមានកម្រិតកំណត់។[៩] សហភាពអឺរ៉ុបក៏បានផ្តល់ការឧបត្ថម្ភរបស់ខ្លួនខ្លះៗនៅក្រោមពាក្យថា "ប្រអប់បៃតង" ផងដែរ ដែលទាក់ទងនឹងវិធានការដើម្បីដាក់កំហិតលើផលិតកម្ម។[១០]

## ផលប៉ះពាល់ចំពោះប្រទេសកំពុងអភិវឌ្ឍន៍

ការឧបត្ថម្ភធនទាំងនេះបានធ្វើឱ្យប្រទេស OECD អាចនាំចេញមុខទំនិញមួយចំនួនតាមថ្លៃដែលទាបជាងថ្លៃផលិត។[១១] ឧទាហរណ៍ នៅឆ្នាំ ២០០២ កម្រិតនៃការកាត់បន្ថយថ្លៃលក់ឱ្យនៅទាបជាងថ្លៃផលិតមានដូចតទៅ៖

- ស្រូវសាឡី : ៤៣%
- សណ្តែកសៀង : ២៥%
- ពោត : ១៣%
- កប្បាស : ៦១%
- ស្រូវ : ៣៥%

ការឧបត្ថម្ភធនទាំងនេះមានឥទ្ធិពលធ្ងន់ធ្ងរដល់

តារាង ៣.៥

សហភាពអឺរ៉ុប-ការប៉ាន់ប្រមាណអំពីការគាំទ្រចំពោះកសិកម្ម គិតជាលានដុល្លារ

| | ១៩៨៦-៨៨ | ២០០២-០៤ | ២០០២ | ២០០៣ | ២០០៤* |
|---|---|---|---|---|---|
| តម្លៃផលិតផលនៅកសិដ្ឋាន | ២១១.៤០៧ | ២៤៥.២៨៩ | ២៤២.៥០៦ | ២៤២.៤២៨ | ២៥០.៩៣៣ |
| ចំនួនប្រហែលនៃការគាំទ្រ (TSE) | ១០៦.៣៧២ | ១១៣.៤០១ | ១០៩.៩៧២ | ១១៧.២២៣ | ១១៣.០០៧ |
| ផ្ទេរពីអតិថិជន | ៨២.១៤២ | ៥៥.៣៤៣ | ៥៣.៦៨៤ | ៥៧.៥៥០ | ៥៤.៧៩៥ |
| ផ្ទេរពីអ្នកបង់ពន្ធ | ២៥.៧៤៧ | ៥៨.៩៦០ | ៥៦.៦៧៦ | ៦១.០៥៩ | ៥៩.១៤៦ |
| ចំណូលជាថវិកា | -១.៥១៧ | -៩០៣ | -៣៨៨ | -១.៣៨៦ | -៩៣៥ |
| ភាគចំណែកនៃ TSE នៅក្នុង GDP (%) | ២.៨២ | ១.២០ | ១.២០ | ១.២៦ | ១.១៦ |

**សម្គាល់៖ សហភាពអឺរ៉ុបសំដៅលើប្រទេស EU-១៥ នៅឆ្នាំ ២០០៤**

*** តួលេខបណ្តោះអាសន្ន**

**ប្រភព៖ OECD ២០០៥**

តារាង ៣.៦

ស.រ.អា - ការប្រមាណអំពីការគាំទ្រចំពោះវិស័យកសិកម្ម គិតជាលានដុល្លារ

| | ១៩៨៦-៨៨ | ២០០២-០៤ | ២០០២ | ២០០៣ | ២០០៤* |
|---|---|---|---|---|---|
| តម្លៃផលិតផលនៅកសិដ្ឋាន | ១៤៣.៤៦៩ | ២១០.៨៧១ | ១៩៣.១៥១ | ២១៤.០២៣ | ២២៥.៤៣៧ |
| ចំនួនប្រហែលនៃការគាំទ្រ (TSE) | ៦៤.០០៩ | ៩៦.៩៧២ | ៩០.០២០ | ៩២.១៩៩ | ១០៨.៦៩៦ |
| ផ្ទេរពីអតិថិជន | ១៥.២២៣ | ១៦.២០៣ | ១៧.១៤៨ | ១៣.៤៦១ | ១៧.៩៩៨ |
| ផ្ទេរពីអ្នកបង់ពន្ធ | ៥០.២៧៤ | ៨២.៧០០ | ៧៤.៩១៥ | ៨០.៦៥០ | ៩២.៩៣៤ |
| ចំណូលជាថវិកា | -១.៤៨៧ | -១.៩៣១ | -២.០៤៣ | -១.៩១២ | -១.៨៣៧ |
| ចំណែកនៃ TSE នៅក្នុង GDP (%) | ១.៣៤ | ០.៨៨ | ០.៨៦ | ០.៨៤ | ០.៩៣ |

**សម្គាល់: * តួលេខបណ្តោះអាសន្ន**

**ប្រភព: OECD ២០០៥**

កសិករ ជាពិសេសកសិករក្រីក្រនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ ឧទាហរណ៍ ការឧបត្ថម្ភធនលើផលស្រូវនៅសហរដ្ឋអាមេរិក ដែលធ្វើឱ្យប្រទេសនេះអាចរក្សាការនាំចេញ សូម្បីតែនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ នៅពេលដែលថ្លៃនៅលើពិភពលោកបានធ្លាក់ចុះ បានធ្វើឱ្យប៉ះពាល់ដល់កសិករនៅទូទាំងតំបន់នេះ ជាពិសេសកសិករនៅប្រទេសថៃ វៀតណាម និង ឥណ្ឌា។ ការឧបត្ថម្ភធនលើដំណាំពោតក៏ធ្វើឱ្យធ្លាក់ថ្លៃផលិតផលនេះផងដែរ ដែលប៉ះពាល់ដល់កសិករនៅហ្វីលីពីន និងចិន។ ការឧបត្ថម្ភធនលើដំណាំសណ្តែកបានធ្វើឱ្យខូចមុខរបររបស់កសិករឥណ្ឌូណេស៊ីប្រមាណ ២.៥ លាននាក់។

ការធ្លាក់ថ្លៃមានន័យថា ផលិតករជាច្រើននៅក្នុងតំបន់នេះ ពុំអាចមានលទ្ធភាពលក់ សូម្បីតែនៅក្នុងទីផ្សារនៅក្នុងប្រទេសរបស់ខ្លួន ដែលបង្កឱ្យមានភាពគ្មានការងារធ្វើជាក់ស្តែង និងបង្កើនភាពក្រីក្រ។

## របាំងអត្រាពន្ធ

របាំងអត្រាពន្ធប្រទេស OECD ផ្តល់ការឧបត្ថម្ភធនយ៉ាងច្រើនដល់កសិកររបស់ខ្លួនតាមរយៈការឧបត្ថម្ភធន។ នៅចំពោះមុខកាយវិការនេះ កិច្ចការពារតាមរយៈតារាងពន្ធអាចមានកម្រិតទាប ឬយ៉ាងហោចណាស់ទាបជាងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៏ ដោយសារការអនុវត្តអត្រាពន្ធលើការនាំចូលពីប្រទេសកំពុងអភិវឌ្ឍន៏ត្រូវបានប៉ាន់ប្រមាណថាមាន ១២% សម្រាប់សហរដ្ឋអាមេរិក ២០% សម្រាប់សហភាពអឺរ៉ុប និង ១៨% សម្រាប់កាណាដា។[១១] ប៉ុន្តែ ដោយសារហេតុផលមួយចំនួន អត្រាមធ្យមនេះនាំឱ្យមានការយល់ខុស។ ពួកគេសំដៅទៅលើពន្ធ ad volarem (ពន្ធដែលគិតជាភាគរយនៃថ្លៃទំនិញ

តារាង ៣.៧

ការឧបត្ថមធនរបស់ ស.រ.អា ចំពោះកសិផលមួយចំនួន (លានដុល្លារ)

| | ១៩៩៥ | ២០០១ |
|---|---|---|
| ពោត | ៣២ | ២.៨០០ |
| សណ្តែកសៀង | ១៦ | ៣.៦០០ |
| កប្បាស | ៣២ | ២.៨០០ |
| ស្រូវ | ១២ | ៧៦៣ |

**ប្រភព: Dhar ២០០៥**

តែមិនមែនតាមបរិមាណ) ប៉ុន្តែ ពន្ធដែលមានអត្រាខ្ពស់សម្រាប់កសិផល (ពោលគឺ ៤៤% សម្រាប់សហភាពអឺរ៉ុប និង ៤៣% សម្រាប់ស.រ.អា) មិនមែនជាពន្ធ ad volarem ទេ ដែលនៅពេលបំលែងទៅជាសមមូលនឹងពន្ធ ad volarem វាមានកម្រិតខ្ពស់ជាង។ លើសពីនេះ តួលេខទាំងនេះជាអត្រាមធ្យមសម្រាប់ខ្ទង់ទាំងអស់នៃតារាងពន្ធ។ ចំពោះក្រុមនៃមុខទំនិញខ្លះដែលមានសារៈសំខាន់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ អត្រានេះមានខ្ពស់ណាស់។ ចំពោះប្រទេស OECD ទាំងមូល បរិមាណនេះមានរហូតដល់ប្រមាណ ៣៥០% សម្រាប់ថ្នាំជក់ ២៧៧% សម្រាប់សូកូឡា ១៧១% សម្រាប់គ្រាប់ធញ្ញជាតិផ្តល់ប្រេង និង ១២៤% សម្រាប់សត្វស្លាបចិញ្ចឹម។[១៣]

កិច្ចការពារតាមទម្រង់ផ្សេងទៀតគឺតាមរយៈកំណើននៃតារាងពន្ធ ដែលកំណត់អត្រាពន្ធទាបសម្រាប់វត្ថុធាតុដើម ប៉ុន្តែអត្រានេះកើនឡើងជាបន្តបន្ទាប់នៅពេលដែលមុខទំនិញទាំងនោះត្រូវបំលែងទៅជាផលិតផលសម្រេច។កំណើនបែបនេះមានខ្លាំងគួរឱ្យកត់សម្គាល់សម្រាប់វិស័យមុខទំនិញដែលមានសារៈសំខាន់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្រីក្រជាងគេដូចជាសាច់ ស្ករ ផ្លែឈើ កាហ្វេ កាកាវ បន្ទះស្បែកសត្វ និងស្បែក។[១៤] ឧទាហរណ៍ ស.រ.អា មានអត្រាពន្ធសូន្យសម្រាប់កាកាវនៅ ០.២% សម្រាប់ផលិតផលកាកាវពាក់កណ្តាលសម្រេច និង ១៥.៣% សម្រាប់ផលិតផលសម្រេចនៃកាកាវ។ លើសពីនេះ តួលេខនេះត្រូវបានគណនាជាមធ្យម និងបិទបាំងអត្រាខ្ពស់បំផុតដែលមានដល់ ១៨៦% សម្រាប់ផលិតផលសម្រេច។ ស្ថានភាពនេះក៏ប្រហាក់ប្រហែលគ្នាដែរនៅសហភាពអឺរ៉ុប ឧទាហរណ៍ទាក់ទងនឹងផ្លែឈើ។ អត្រាពន្ធមាន ៩.៩% សម្រាប់ផ្លែឈើនៅ ១៨.៥% សម្រាប់ផ្លែឈើកែច្នៃពាក់កណ្តាលសម្រេច និង ១៨.០% សម្រាប់ផលកែច្នៃសម្រេចដោយមានអត្រាអតិបរមាសម្រាប់ផលិតផលពីផ្លែឈើរហូតដល់ ៥៦%។ ដូចគ្នានេះដែរ ភាគច្រើននៃអត្រាទាំងនេះ មិនមែនជាពន្ធ ad valorem ទេ ដូច្នេះភាគរយនេះមិនបានរាប់បញ្ចូលអត្រាពេញលេញនៃតារាងពន្ធនេះទេ។[១៥]




រូបទី ៣.៣: អត្រាពន្ធកំណត់ដោយប្រទេសជឿនលឿនលើទំនិញនាំចូលពីតំបន់នីមួយៗ (%)

ប្រភព: FAO ២០០៤

កំណើនតារាងពន្ធនឹងកាត់បន្ថយឱកាសរបស់ប្រទេសនានាក្នុងការនាំចេញផលិតផលកែច្នៃ។ ប៉ុន្តែ ប្រទេសជឿនលឿនអាចទទួលជោគជ័យក្នុងការជំនះឧបសគ្គនេះ។ ជារួមពួកគេទទួលបាន ៦៨% នៃប្រាក់ចំណូល ពីការនាំចេញកសិផលជាផលិតផលកែច្នៃ ចំណែកសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍វិញ សមាមាត្រនេះមានត្រឹមតែ ៥៧% ហើយសម្រាប់ LDCs មានត្រឹមតែ ២០% ប៉ុណ្ណោះ។[១៦]

ជាលទ្ធផលនៃវិធីការពារបែបជ្រើសរើសរបស់ខ្លួន ប្រទេសជឿនលឿនទាំងមូលបានអនុវត្តអត្រាពន្ធខ្ពស់ជាងសម្រាប់ស្បៀងពីប្រទេសកំពុងអភិវឌ្ឍន៍ធៀបនឹងការដែលពួកគេធ្វើចំពោះទំនិញដូចគ្នាពីប្រទេសជឿនលឿនដទៃទៀត។ ដូចដែលមានបង្ហាញច្បាស់ក្នុងរូបទី ៣.៣ អត្រានេះមានកម្រិតខ្ពស់បំផុតសម្រាប់ទំនិញពីអាស៊ីបូព៌ា និងអាស៊ីខាងត្បូង។

## ក្រុមហ៊ុនអន្តរជាតិនិងកសិករតូចតាច

ការគាបសង្កត់លើទីផ្សារ មិនមែនកើតឡើងត្រឹមតែដោយសារការឧបត្ថម្ភធន និងតារាងពន្ធប៉ុណ្ណោះទេ ប៉ុន្តែដោយសារអំណាចនៃក្រុមហ៊ុនចម្រុះជាតិមួយចំនួនផងដែរ ដែលត្រួតត្រាចង្វាក់អាហារទាំងមូលផងដែរ ពោលគឺចាប់ពីការចែកចាយគ្រាប់ពូជ រហូតដល់ការដាក់ផលិតផលនៅតាមធ្នើនៅក្នុងផ្សារទំនើប។ ឧទាហរណ៍ សម្រាប់សណ្តែក កិនច្រើនជាង ៧០% នៃទីផ្សារនៅស.រ.អា និងប្រមាណ ៨០% នៅទីផ្សារអឺរ៉ុប ត្រូវបានត្រួតត្រាដោយក្រុមហ៊ុនបី។[១៧] ដូចគ្នានេះដែរ សម្រាប់គ្រាប់ធញ្ញជាតិ។ នៅកម្រិតពិភពលោក មានតែក្រុមហ៊ុនធំៗមួយចំនួនតូចតែប៉ុណ្ណោះ ជាអ្នកត្រួតត្រាការធ្វើជំនួញ ការរក្សាទុក កែច្នៃ និងកិន។

ប្រការនេះនាំឱ្យមានការព្រួយបារម្ភ ដោយសារហេតុផលមួយចំនួន។ ទីមួយ សាជីវកម្មធំៗចូលចិត្តរកស៊ីជាមួយផលិតករធំៗមួយចំនួនតូចជាងជាមួយអ្នកផ្គត់ផ្គង់តូចៗដែលមានចំនួនច្រើន ដូច្នេះជាការគាបសង្កត់ឱ្យផលិតករតូចតាចខ្ទាតចេញពីទីផ្សារ។ ទីពីរ ពួកគេមានឥទ្ធិពលខ្លាំងណាស់ ឬអាចសូម្បីតែទៅលើការកំណត់ថ្លៃនៅលើទីពិភពលោក ដែលនាំឱ្យមានឥទ្ធិពលទៅលើមិនត្រឹមតែស្បៀង ដែលធ្វើពាណិជ្ជកម្មជាអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅលើថ្លៃផលិតផលដែលមាននៅក្នុងទីផ្សារតូចតាចក្នុងភូមិនានាផងដែរ។

អ្នកប្រើប្រាស់ងាយសង្កេតឃើញការត្រួតត្រាបែបនេះបំផុតតាមរយៈការកើនឡើងនៃផ្សារទំនើប។ នៅលើពិភពលោក ផ្សារទំនើបធំៗចំនួន ៣០ ត្រួតត្រាជិតមួយភាគបីនៃទំនិញសម្រាប់ធ្វើម្ហូបដែលមានដាក់លក់ ហើយពួកគេបានពង្រីកយ៉ាងឆាប់រហ័សជាទីបំផុតនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ ឧទាហរណ៍ នៅអាស៊ីបូព៌ា ក្នុងអំឡុងទសវត្សរ៍កន្លងទៅ ភាគចំណែកនៃអាហារដែលលក់រាយនៅតាមផ្សារទំនើប បានកើនឡើងពីតិចជាង ២០% ទៅច្រើនជាង ៥០%។ ផ្សារទំនើបនានាចង់រកស៊ីជាមួយអ្នកផ្គត់ផ្គង់ចំនួនតិចដែលអាចទុកចិត្តបាន និងដែលអាចផ្គត់ទំនិញតាមកាលកំណត់ក្នុងបរិមាណច្រើននូវផលិតផលប្រកបដោយគុណភាពខ្ពស់ ដែលជាទូទៅសម្រាប់កសិករ វាជាតម្រូវការឱ្យមានការវិនិយោគជាច្រើនទៅលើការស្រោចស្រពផ្ទះកញ្ចក់ រថយន្តដឹកទំនិញ រោងសម្រាប់ធ្វើឱ្យមានម្លប់ និងបច្ចេកវិទ្យាវេចខ្ចប់។ នេះគឺជាតម្រូវការកម្រិតខ្ពស់សម្រាប់កសិករតូចតាច ទោះបីអ្នកខ្លះបានទទួលជោគជ័យក្នុងការចុះកិច្ចសន្យាជាមួយកសិករក៏ដោយ។

## ការគាបសង្កត់លើពាណិជ្ជកម្ម និងការអភិវឌ្ឍមនុស្ស

ការគាបសង្កត់ទាំងនេះទៅលើពាណិជ្ជកម្មកសិផលពិភពលោក អាចបង្កផលប៉ះពាល់អវិជ្ជមានដល់កសិករ ដោយធ្វើឱ្យចុះខ្សោយនូវមធ្យោបាយរបស់ពួកគាត់ ក្នុងការចិញ្ចឹមជីវិត និងសន្តិសុខ។ ជាលទ្ធផលសូម្បីតែប្រទេសដែលជាអ្នកនាំចេញកសិផលប្រកបដោយជោគជ័យក៏ដោយ ពួកគេពុំសុទ្ធតែសម្រេចបាននូវស្តង់ដារខ្ពស់នៃការអភិវឌ្ឍមនុស្សឡើយ។ ឧទាហរណ៍ ប្រទេសថៃ គឺជាប្រទេសនាំចេញស្បៀងធំបំផុតនៅអាស៊ី ប៉ុន្តែកសិករតូចតាចក្នុងប្រទេសនេះ បានទទួលផលតិចតួចប៉ុណ្ណោះពីកំណើននៃការនាំចេញស្រូវ។ តាំងពីឆ្នាំ ២០០១មក ប្រទេសថៃ បាននាំចេញប្រចាំឆ្នាំច្រើនជាង ៧លានតោន ត្រូវជាប្រមាណ ៣០% នៃការនាំចេញស្រូវលើពិភពលោក ប៉ុន្តែប្រមាណ ៤០% នៃគ្រួសារនៅជនបទរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ។ រដ្ឋាភិបាលបានចាត់ជាអាទិភាពនូវ ផលិតកម្ម ស្រូវសម្រាប់ការ ធ្វើជំនួញ រីឯកសិករតូចតាចជាច្រើនច្រើនលានគ្រួសារបានជាប់ជំពាក់បំណុល និងបាត់បង់ដីធ្លីរបស់ខ្លួនមួយចំណែកគឺ ដោយសារផលដំណាំរបស់ពួកគេលក់បានថោក។ ប្រមាណ ៤.៧លាន

ក្នុងចំណោម ៥.៧លាន នៃគ្រួសារកសិករពុំមានដីធ្លី ឬពុំមានដីធ្លីគ្រប់គ្រាន់ដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួនឡើយ។ កង្វះអាហារូបត្ថម្ភ បានកើនឡើងទៅឆ្នាំ ២០០០ ក្នុងនោះគ្រួសារជនជាតិថៃចំនួន ១៨% ពុំបានទទួលអាហារូបត្ថម្ភគ្រប់គ្រាន់ទេ។ ប្រទេសថៃអាចជាអ្នកផ្តល់អាហារដល់ពិភពលោកទៅពីលើខ្នងរបស់កសិករក្រីក្ររបស់ខ្លួន។

ដូចគ្នានេះដែរ ធនាគារពិភពលោកបានរកឃើញថាចាប់តាំងពីប្រទេសចិនចូលជាសមាជិក WTO នៅក្នុងឆ្នាំ២០០១ និងការធ្វើសេរីភាវូបនីយកម្មកសិកម្មរបស់ខ្លួន គ្រួសាក្រីក្រនៅជនបទមានស្តង់ដារនៃការរស់នៅធ្លាក់ចុះ ៦% ដោយសារឥទ្ធិពលចម្រុះបណ្តាលពីការធ្លាក់ចុះនៃប្រាក់កម្រៃជាក់ស្តែង និងកំណើនថ្លៃគ្រឿងឧបភោគបរិភោគ។[១៩]

ការសិក្សានេះក៏រកឃើញផងដែរថា សេរីភាវូបនីយកម្មបានពង្រីកគម្លាតប្រាក់ចំណូលរវាងជនបទ និងទីក្រុង។ តាំងពីឆ្នាំ ២០០១មក ភាគច្រើននៃអ្នករស់នៅទីក្រុង បានឃើញប្រាក់ចំណូលរបស់ខ្លួនកើនឡើង ចំណែកគ្រួសារនៅជនបទ បានឃើញថាជាមធ្យមប្រាក់ចំណូលរបស់ខ្លួនបានធ្លាក់ចុះដែលអ្នកក្រីក្ររងគ្រោះធ្ងន់ធ្ងរជាងគេ។ ការធ្លាក់ចុះនេះនាំឱ្យមានការមិនសប្បាយចិត្តខ្លះៗនៅទីជនបទ។

មិនមែនប្រការទាំងអស់នេះសុទ្ធតែជាឥទ្ធិពលនៃគំរូពាណិជ្ជកម្មអន្តរជាតិដែលរងការគាបសង្កត់នោះទេ។ ប្រការជាច្រើនជាប់ទាក់ទងជាមួយវិធានការសេរីភាវូបនីយកម្មដែលពាក់ព័ន្ធជាមួយកំណែទម្រង់រចនាសម្ព័ន្ធ និងលក្ខខណ្ឌនានាដែលកំណត់ដោយធនាគារពិភពលោក និង IMF ដែលជាម្ចាស់ប្រាក់កម្ចី។ តាមពិត កម្មវិធីទាំងនេះច្រើនតែទាមទារឱ្យមានសេរីភាវូបនីយកម្មក្នុងទម្រង់ទ្រាយដែលទូលំទូលាយជាងអ្វីដែលមានជាលក្ខខណ្ឌនៅក្នុងកិច្ចប្រជុំនៅប្រទេសអ៊ុយរ៉ាហ្គាយទៅទៀត។ ពួកគេត្រូវការឱ្យមានវិធានការផ្សេងទៀតមួយចំនួនដូចជាធ្វើឯកជនភាវូបនីយកម្មសហគ្រាសដែលគ្រប់គ្រងដោយរដ្ឋ លុបបំបាត់ការឧបត្ថម្ភធន និងការត្រួតត្រាថ្លៃ និងលុបចោលក្រុមប្រឹក្សាទីផ្សារ (ប្រអប់ ៣.១)។

ហេតុអ្វី សេរីភាវូបនីយកម្មធ្វើឱ្យខូចខាតផលប្រយោជន៍របស់កសិករក្រីក្រ? មានកត្តាទាក់ទងមួយចំនួនដែលអាចពាក់ព័ន្ធ។[២០] កត្តាទាំងនោះរួមមាន ៖

- *ការធ្លាក់ថ្លៃ* ៖ សេរីភាវូបនីយកម្មបើកចំហទីផ្សារក្នុងស្រុកសម្រាប់ការនាំចូល ដែលអាចនាំឱ្យមានទំនិញថោកៗ ចូលពីក្រៅប្រទេស។ កសិករអាចឆ្លើយតបដោយ ប្តូរពីដំណាំស្បៀងទៅជាដំណាំសម្រាប់ជំនួញ ទោះបីពួកគាត់អាចមិនធ្វើបានល្អជាងមុនក៏ដោយ ព្រោះថាថ្លៃនៃទំនិញទាំងនេះក៏ធ្លាក់ចុះផងដែរ នៅពេលដែលប្រទេសកាន់តែច្រើនប្រឡូកក្នុងទីផ្សារ។
- *កំណើនថ្លៃផលិត* ៖ ឥឡូវកសិករត្រូវចំណាយកាន់តែច្រើន ដូចជាលើជី ដោយសារថ្លៃជីនៅលើទីផ្សារកើនឡើង និងដោយសាររដ្ឋាភិបាលបានលុបចោលការឧបត្ថម្ភធន។
- *ការដកខ្លួននៃសេវាកម្មរបស់រដ្ឋ* ៖ ការដកចេញនូវសេវាសម្រាប់ការស្រោចស្រព បរិក្ខារក្រោយការប្រមូលផល និងផ្លូវថ្នល់ពីកសិដ្ឋានទៅទីផ្សារ ឧទាហរណ៍ នៅក្នុងប្រទេសហ្វីលីពីន។ នេះមានន័យថា កសិករតូចតាចពុំអាចលើកកម្ពស់ផលិតភាព ឬបញ្ជូនផលិតផលទៅទីផ្សារតាមថ្លៃដែល បំពេញការចំណាយបានឡើយ។
- *ការចាប់យកដីធ្លី* ៖ សេរីភាពវូបនីយកម្ម

ប្រអប់ ៣.១

### សេរីភាវូបនីយកម្មពាណិជ្ជកម្មកសិផលនៅឥណ្ឌូណេស៊ី

ក្រោយវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ១៩៩៧ IMF បានដាក់ឱ្យអនុវត្តលក្ខខណ្ឌសេរីភាវូបនីយកម្មពាណិជ្ជកម្មទាំងស្រុង ជាផ្នែកមួយនៃការផ្តល់ប្រាក់កម្ចីជាច្រើនលានដុល្លារដល់ឥណ្ឌូណេស៊ី។ លក្ខខណ្ឌទាំងនោះរួមមាន ការបញ្ចុះអត្រាពន្ធនិងលុបចោលបទប្បញ្ញត្តិរបស់ BULOG ដែលជាទីភ្នាក់ងារទិញ និងចែកចាយស្បៀងរបស់រដ្ឋ ដូច្នេះបានផ្តល់ទៅឱ្យអ្នកនាំចេញកសិផលធំៗ ដូចជាសហរដ្ឋអាមេរិក នូវលទ្ធភាពប្រើប្រាស់ទីផ្សារធំៗ សម្រាប់កសិផលដែលលើសរបស់ខ្លួន។

អត្រាពន្ធដែលអនុវត្តនៅប្រទេសឥណ្ឌូនេស៊ីត្រូវបានបញ្ចុះដល់ ៥% ឬទាបជាងនេះទៀតសម្រាប់ផលិតផលចម្បងៗ។ ពន្ធលើសណ្តែកនិងស្រូវត្រូវបានកំនត់អត្រាសូន្យ និងពោត ៥%។ នៅក្រោយភាពច្របូកច្របល់ ខាងសង្គមនិងនយោបាយ ភាពចលាចលបានកើតឡើងទាក់ទងនឹងអត្រាពន្ធលើស្រូវដែលត្រូវបានកែតម្រូវដល់ ៣០% (Kwa ២០០៤)។

នៅមុនពេលលុបចោលបទប្បញ្ញត្តិនេះ BULOG មានអំណាចត្រួតត្រាផ្តាច់មុខលើការនាំចូលនូវមុខទំនិញជាអាហារចំបងៗដែលនាំចូលទៅក្នុងប្រទេសឥណ្ឌូណេស៊ី ដូច្នេះអាចគ្រប់គ្រងការផ្គត់ផ្គង់ស្បៀង និងថ្លៃក្នុងស្រុក។ តួនាទីនេះត្រូវបានលុបចោលស្ទើរតែទាំងស្រុង។ BULOG បានបញ្ឈប់ការត្រួតត្រាលើបរិមាណដែលត្រូវនាំចូល ហើយឈ្មួញឯកជនមានសេរីភាពពេញលេញលើផ្នែកនេះ។ តួនាទីពីមុនរបស់ BULOG ក្នុងការធានាចែកចាយស្រូវ និងស្បៀងសំខាន់ៗដទៃទៀតរវាងតំបន់នានា ក៏ត្រូវបានកាត់បន្ថយយ៉ាងច្រើនផងដែរ។

លទ្ធផលនៃសេរីភាវូបនីយកម្មមានលក្ខណៈគួរឱ្យកត់សម្គាល់។នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ ឥណ្ឌូណេស៊ីអាចពឹងផ្អែកលើការផ្គត់ផ្គង់ស្រូវដោយខ្លួនបាន ប៉ុន្តែនៅក្នុងអំឡុងឆ្នាំ ១៩៨៨-២០០២ ការនាំចូលរបស់ប្រទេសនេះ ជាមធ្យមមាន ២០% នៃតម្រូវការក្នុងស្រុក។ សហរដ្ឋអាមេរិក គឺជាអ្នកឈ្នះនៅក្នុងការបើកចំហទីផ្សារនេះ។ ការនាំចេញរបស់អាមេរិកទៅប្រទេសឥណ្ឌូនេស៊ី ចំនួន ៤១១លានដុល្លារ នៅឆ្នាំ ២០០០ បានកើនឡើងដល់ ៧២០លានដុល្លារនៅឆ្នាំ២០០១។ ចាប់ពីពេលនោះមក ការនាំចូលបានកើនឡើងជាបន្ថែមទៀត (Setiwant ២០០៣)។

ផលប៉ះពាល់លើចំនួនការងារនៅជនបទបានបង្ហាញយ៉ាងច្បាស់លើការដាំសណ្តែកសៀង។ នៅក្នុងឆ្នាំ ១៩៩៦ មានអ្នកដាំសណ្តែកសៀងចំនួន ៥លាននាក់ លុះដល់ឆ្នាំ ២០០១ ចំនួននេះមានត្រឹម២.៥លាននាក់ប៉ុណ្ណោះ។ ឧបមារថាផលិតករម្នាក់ត្រូវទ្រទ្រង់គ្រួសារដែលមានគ្នាបួននាក់ ដូច្នេះ ប្រជាជន ១០លាននាក់បានត្រូវរងផលប៉ះពាល់នេះ។ ចំណែកកសិករដំណាំសណ្តែកសៀងខ្លះ អាចប្តូរទៅដាំពោតនិងស្រូវ ហើយសេណារីយ៉ូដែលទំនងជាកើតឡើងគឺ ពួកគេត្រូវចាកចោលកសិដ្ឋានទាំងអស់គ្នា។

ពាណិជ្ជកម្មអាចធ្វើឱ្យដីធ្លីខ្លះមានតម្លៃ សម្រាប់ការដាំដំណាំប្រភេទខ្លះ ដោយប្រើប្រាស់គ្រឿងចក្រ។ ប្រការនេះ នាំឱ្យមានការប្រមូលផ្តុំគ្នានូវដីធ្លី ។ ទោះបីការប្រមូលផ្តុំកសិដ្ឋានអាចបង្កើនផលិតភាព និងភាពប្រកួតប្រជែងក្តី វាក៏រុញច្រានម្ចាស់កម្មសិទ្ធិ និងកសិករចេញពីដីទាំងនោះ ហើយក្នុងករណីខ្លះបណ្តាញសន្តិសុខ វាបន្ថែមទម្ងន់ ទៅលើភាពគ្មានការងារធ្វើ និងភាពក្រីក្រ។[១១] ឧទាហរណ៍ នៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដីធ្លីត្រូវបានប្រមូលផ្តុំ នៅក្នុងកណ្តាប់ដៃមនុស្សមួយក្រុមតូច ហើយនៅក្នុងរវាងឆ្នាំ ១៩៨៣ និង២០០២ សមាមាត្រគ្រួសារនៅជនបទដែលគ្មានដីធ្លីបានកើនឡើងពី ៣% ទៅ ២០%។

- *កំណើនវិសមភាពនៃយេនឌ័រ* : មុនសេរីភាវូបនីយកម្ម ស្ត្រីជាច្រើនលក់ផលិតផលរបស់ខ្លួនទៅឱ្យសហគ្រាសរបស់រដ្ឋាភិបាល។ ឥឡូវនេះ ពួកគេត្រូវតែលក់ទៅឱ្យឈ្មួញ ដែលអាចទទួលផលចំណេញបានច្រើនជាង។ ស្ត្រីក៏រងគ្រោះក្នុងកម្រិតវិសមាមាត្រផងដែរ ដោយសារការ

លុបចោលការឧបត្ថម្ភធន ការឈប់ផ្តល់ឥណទាន និងកំណើនការនាំចូលស្បៀង។

- *ភាពគ្មាននិរន្តរភាព* : ទីផ្សារស្បៀងលើពិភពលោកលើកទឹកចិត្តកសិករ ឱ្យធ្វើកសិកម្មឯកវប្បកម្មនៅលើផ្ទៃដីធំ ដោយប្រើប្រាស់ជីនិងថ្នាំកំចាត់សត្វចង្រៃច្រើន ដែលអាចធ្វើឱ្យខូចទាំងដី និងប្រភពទឹក។

សេរីភាវូបនីយកម្មពាណិជ្ជកម្មពិតជាមានឥទ្ធិពលវិជ្ជមាន។ វាមិនត្រឹមតែបន្ទាបថ្លៃសម្រាប់អ្នកប្រើប្រាស់ប៉ុណ្ណោះទេ វាថែមទាំងអាចធ្វើឱ្យសហគមន៍ជនបទ ជាពិសេសស្ត្រីចូលរួមនៅក្នុងសកម្មភាពកសិកម្ម ឧទាហរណ៍ តាមរយៈសហគ្រាសខ្នាតតូច និងមីក្រូសហគ្រាស។ ទោះជាយ៉ាងណាក៏ដោយ ឥទ្ធិពលវិជ្ជមានច្រើនតែមានកម្រិតទាបជាងច្រើនណាស់ធៀបនឹងឥទ្ធិពលអវិជ្ជមាន។

## ការធ្វើឱ្យពាណិជ្ជកម្មកសិផលជួយដល់អ្នកក្រីក្រ

ទាំងកំណើនសេដ្ឋកិច្ចឬការពង្រីកពាណិជ្ជកម្ម មិនសុទ្ធតែផ្តល់ប្រយោជន៍ដល់អ្នកក្រនោះឡើយ តាមពិតវាអាចផ្តល់គ្រោះថ្នាក់ដល់អ្នកទាំងនោះផងដែរ។ តើត្រូវមានលក្ខខណ្ឌអ្វីខ្លះដើម្បីធ្វើឱ្យពាណិជ្ជកម្មជួយដល់ជនក្រីក្រ? ការផ្លាស់ប្តូរបទបញ្ញាពាណិជ្ជកម្មអន្តរជាតិមានសារៈសំខាន់ណាស់ ប៉ុន្តែរដ្ឋាភិបាលនៅថ្នាក់ជាតិក៏អាចចាត់វិធានការចាំបាច់ដើម្បីផ្លាស់ប្តូរបរិបទ ដែលនៅក្នុងនោះសេរីភាវូបនីយកម្មប្រតិបត្តិការផងដែរ។

## ១. លើកកម្ពស់ការអភិវឌ្ឍន៍ឧស្សាហកម្ម

ទោះបីប្រជាពលរដ្ឋជាងពាក់កណ្តាលនៅក្នុងតំបន់នេះពឹងផ្អែកលើកសិកម្មសម្រាប់ការចិញ្ចឹមជីវិតរបស់ខ្លួនក្តី មានភាពចម្រើនតិចតួចតែប៉ុណ្ណោះត្រូវបានធ្វើឡើង ដើម្បីលើកកម្ពស់ផលិតភាពនិងភាពមានការងារធ្វើ។ តាមពិត ការចំណាយសាធារណៈលើកសិកម្មបានថយចុះ។ រវាងឆ្នាំ ១៩៩០ និង ២០០១ ការចំណាយសាធារណៈលើកសិកម្មគិតជាសមាមាត្រនៃ GDP នៅក្នុងប្រទេសចំនួនបួននៅអាស៊ីអាគ្នេយ៍ធ្លាក់ចុះពី ៨.៤% មក ៣.៨% និងនៅក្នុងប្រទេសចំនួនពីរនៅប៉ាស៊ីហ្វិកខាងត្បូងពី ១.០ ទៅ ០.៨%។[២២]

ឥណ្ឌាគឺជាឧទាហរណ៍ស្រាប់ដែលកាលពីទសវត្សរ៍មុន ច្រើនតែមិនយកចិត្តទុកដាក់លើវិស័យកសិកម្ម។ ទោះបីអ្នកក្រីក្រភាគច្រើនរស់នៅតាមជនបទក៏ដោយ ការវិនិយោគលើកសិកម្មបានថយចុះយ៉ាងខ្លាំង ហើយរវាងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ បានធ្លាក់ចុះ ២៩%។ ប្រការសំខាន់ដូចគ្នាដែរនោះគឺការខ្វះខាតឥណទានកសិកម្ម។ ទោះបីអ្នកប្រើប្រាស់អាចខ្ចីប្រាក់ដើម្បីទិញផ្ទះ ឬរថយន្ត ដោយអត្រាការប្រាក់ ៩% ទៅ ១១% ប៉ុន្តែ កសិករដែលចង់ទទួលឥណទានអាចត្រូវបង់ការប្រាក់ តាមអត្រា ១៧%។ នៅពេលនោះ កសិករភាគច្រើនមិនត្រឹមតែពុំអាចសុំប្រាក់កម្ចីពីរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែត្រូវពឹងផ្អែកលើអ្នកផ្តល់ប្រាក់ឱ្យខ្ចី ដែលអាចទាញកម្រៃពីកសិករដោយអត្រាជាច្រើនរយភាគរយ។

ប្រសិនបើរដ្ឋាភិបាលចង់ឱ្យមានការអភិវឌ្ឍទូលំទូលាយ និងប្រកបដោយសមធម៌ ពួកគេចាំបាច់ត្រូវធ្វើការវិនិយោគបន្ថែមទៀតលើកសិកម្ម ជាពិសេសសម្រាប់ការបង្កើតមូលធន ទន្ទឹមនឹងផ្តល់ការគាំទ្រចំពោះថ្លៃកសិផល ប្រាក់កម្ចី

ដែលអាចទទួលបាន ជួយលើការស្រោចស្រព ជួយរកទីផ្សារ ជួយក្នុងការរក្សាទុក កែច្នៃ និងបរិក្ខារចែកចាយ ។

## ២. អនុវត្តកំណែទម្រង់ដីធ្លី

ការយកចិត្តទុកដាក់ហួតចត់របស់រដ្ឋាភិបាលនានាលើការអភិវឌ្ឍកសិកម្មនឹងទាមទារឱ្យមានការប្រឹងប្រែងហ្មត់ចត់ជាបន្ថែមទៀតលើកំណែទម្រង់ដីធ្លី ។ នៅអាស៊ី មួយភាគបី ទៅពាក់កណ្ដាលនៃចំនួនម្ចាស់ហ៊ុនតូចៗ ប្រឹងប្រែងដើម្បីរក្សាអត្ថិភាពលើផ្ទៃដីតូចជាងមួយហិកតា ។ ឧទាហរណ៍ នៅប្រទេសបង់ក្លាដេស ៧៨% នៃចំនួនគ្រួសារនៅជនបទត្រូវបានចាត់ជាអ្នកខ្វះដី ។ នៅឥណ្ឌាសមាមាត្រនេះគឺ ៧១% ។ នៅប្រទេសផ្សេងទៀត សមាមាត្រនេះអាចទាបជាង ប៉ុន្តែនៅតែមានកម្រិតខ្ពស់នៅឡើយ ពោលគឺច្រើនជាងមួយភាគបីនៅក្នុងប្រទេសឥណ្ឌូណេស៊ី ហ្វីលីពីន និងស្រីលង្កា ។ បញ្ហានេះទំនងជាកាន់តែធ្ងន់ធ្ងរឡើងនៅពេលដែលការផ្ដោតលើកសិកម្មសម្រាប់នាំចេញ និងកំណើនរួមគ្នានៃចំនួនទីក្រុងនិងឧស្សាហកម្មបានរុញច្រានគ្រួសារក្រីក្រកាន់តែច្រើនឡើងឱ្យឃ្លាតឆ្ងាយពីដីធ្លីរបស់ពួកគាត់ ។

កម្មសិទ្ធិដីធ្លីគឺជារឿងមួយដែលលំបាកសម្រាប់ស្ត្រី ។ ឧទាហរណ៍ នៅប្រទេសណេប៉ាល់ សូម្បីតែពីរភាគបីនៃកម្លាំងពលកម្មក្នុងវិស័យកសិកម្មគឺជាស្ត្រីក៏ដោយ រហូតដល់ពេលថ្មីៗនេះ ពួកគាត់ត្រូវបានអនុញ្ញាតឱ្យមានកម្មសិទ្ធិដីធ្លីត្រឹមតែជាចំណែកមួយនៃអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ ហើយនៅពេលដែលលែងលះគ្នា សិទ្ធិលើដីធ្លីនោះត្រូវបានទៅខាងប្ដី ។ ទោះបីជាស្ត្រីអាចទទួលមរតកចាប់ពីត្រឹមឆ្នាំ ២០០២មកក្ដី សិទ្ធិទាំងនេះត្រូវបានបង្វែរទៅសមាជិកគ្រួសារដែលកើតនៅក្រោយអាពាហ៍ពិពាហ៍ ។[៣]

កិច្ចប្រឹងប្រែងថ្មីៗនេះដើម្បីធ្វើកំណែទម្រង់ដីធ្លីមិនបានដំណើរការវែងឆ្ងាយនោះឡើយ ។ ឧទាហរណ៍ នៅប្រទេសហ្វីលីពីន កម្មវិធីរបស់រដ្ឋាភិបាលអំពីកំណែទម្រង់ទូលំទូលាយលើកសិកម្ម (CARP) ពុំដែលបានអនុវត្តពិតប្រាកដនោះឡើយ ។ ប្រទេសហ្វីលីពីនក៏បានព្យាយាមធ្វើ "កំណែទម្រង់ដីធ្លីតាមយន្តការទីផ្សារ" ផងដែរ ដោយជួយអ្នកគ្មានដីធ្លីដើម្បីធ្វើលទ្ធកម្មដីដោយផ្ទាល់ពីម្ចាស់ដី ។ ប៉ុន្តែ អ្នកទទួលផលអាចទទួលការជួយនោះប្រសិនបើពួកគាត់អាចបង្ហាញអំពីផែនការដាំដំណាំដែលផ្ដោតលើដំណាំដែលអាចធ្វើពាណិជ្ជកម្មតែប៉ុណ្ណោះ ។ ហេតុនេះកម្មវិធីនេះពុំបានលើកកម្ពស់វប្បកម្មខ្នាតតូចឡើយ ។ ឥឡូវនេះ ម្ចាស់ដីប្រឆាំងតបវិញយ៉ាងខ្លាំង ហើយដោយសារដីធ្លីមានដោយកម្រ ដែលពួកគេពុំចង់លក់នោះឡើយ ។ ប៉ុន្តែក៏មានចលនារបស់កសិករផ្ទុយមកវិញផងដែរ ដោយសារស្ថានភាពវិសមភាពក្នុងការតថ្លៃរវាងម្ចាស់ដី និងកសិករ ។ ទីបំផុត កម្មវិធីនេះមិនសូវបានទទួលជោគជ័យនោះឡើយ ។

## ៣. ដំណោះស្រាយអំពីតម្លៃផ្សេងៗ

សេរីភាវូបនីយកម្មពាណិជ្ជកម្មក៏ធ្វើឱ្យផ្លាស់ប្ដូរថ្លៃផលិតផលផងដែរ ដូច្នេះផលប៉ះពាល់របស់វាទៅលើការកាត់បន្ថយភាពក្រីក្រ គឺអាស្រ័យទៅលើទិសដៅនៃការផ្លាស់ប្ដូរថ្លៃ និងឥទ្ធិពលរបស់វាទៅលើការចំណាយ ព្រមទាំងប្រាក់ចំណូលរបស់កសិករ ។ ប្រសិនបើថ្លៃដែលប្រែប្រួលនោះមាននិន្នាការគាំទ្រជនក្រីក្រ នៅពេលនោះការប្រែប្រួលនឹងមាននិន្នាការពង្រឹងឥទ្ធិពលនៃកំណើនវិជ្ជមាននូវកំណែទម្រង់ពាណិជ្ជកម្មទៅលើជនក្រីក្រ ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលក៏

*ការយកចិត្តទុកដាក់ហ្មត់ចត់របស់រដ្ឋាភិបាលនានាលើការអភិវឌ្ឍកសិកម្ម ទាមទារឱ្យមានការប្រឹងប្រែងហ្មត់ចត់ជាបន្ថែមទៀតលើកំណែទម្រង់ដីធ្លី*

អាស្រ័យផងដែរទៅលើភាពប្រែប្រួលនៃគោលនយោបាយដែលមានលក្ខណៈបំពេញបន្ថែម ជាពិសេសទៅលើថាតើពួកគេអាចឬមិនអាច :

- បង្កើតទីផ្សារថ្មីៗដែលគាំទ្រជនក្រីក្រ
- សម្រួលជនក្រីក្រឱ្យឆ្លើយតបនឹងការប្រែប្រួល
- ថ្លៃ និងកាលានុវត្តភាពទីផ្សារ
- ផ្តល់ឥទ្ធិពលបន្សាយជុំទីពីរដែលគាំទ្រជនក្រីក្រ
- កាត់បន្ថយអត្រាគ្មានការងារបណ្តោះអាសន្ន
- ដែលផ្តោតលើជនក្រីក្រ
- បង្កើនប្រាក់ចំណូលរបស់រដ្ឋាភិបាលដែលនាំឱ្យ
- មានការចំណាយសម្រាប់ គាំទ្រជនក្រីក្រ និង
- កាត់បន្ថយភាពងាយរងគ្រោះរបស់ជនក្រីក្រ[២៤]

## ៤. ផ្តល់កិច្ចគាំពារចំពោះផលិតករក្រីក្រ

បច្ចុប្បន្ន កសិករក្រីក្រជាច្រើនមានការលំបាកដើម្បីធ្វើការប្រកួតប្រជែង។ ដូច្នេះ រដ្ឋាភិបាលត្រូវរិះរកវិធីការពារកសិករតូចតាចដែលជាអ្នកចាត់ចែងដំណើរការផលិតស្បៀងបានល្អ ប៉ុន្តែដែលទទួលរងការគំរាមកំហែងដោយថ្លៃទាបនៅលើពិភពលោក ឬមួយដោយសារអត្រាពន្ធខ្ពស់ ការឧបត្ថម្ភដើម្បីរក្សាថ្លៃ ឬការឧបត្ថម្ភធនលើផលិតផល។

## គោលនយោបាយពាណិជ្ជកម្មកសិផលនៃប្រទេសកំពុងអភិវឌ្ឍន៍

ដោយសារទម្រង់ខុសគ្នានៃពាណិជ្ជកម្មកសិផល ប្រទេសកំពុងអភិវឌ្ឍន៍នីមួយៗក៏មានចំណាប់អារម្មណ៍ខុសៗគ្នាផងដែរ អាស្រ័យថាតើខ្លួនជាប្រទេសនាំចេញ ឬនាំចូល។ ផលិតករភេសជ្ជៈត្រូពិកនិងវត្ថុធាតុដើមមានគោលដៅដើម្បីចូលទៅក្នុងទីផ្សារពិភពលោកនិងធ្វើឱ្យមានប្រាក់ចំណូលថេរ។ ពួកគេចង់ជៀសវាងអស្ថិរភាពនៃថ្លៃ និងធានាថា ពួកគេមិនមែនជាអ្នកចាញ់រហូតនោះទេនៅក្នុងការផ្លាស់ប្តូរលក្ខខណ្ឌពាណិជ្ជកម្ម រវាងផលិតផលស្បៀង និងផលិតផលមិនមែនកសិកម្មពីត្រូពិក។ ដូច្នេះ ពួកគេអាចទទួលផលចំណេញដោយសម្របសម្រួលកម្មវិធីផលិតកម្មរបស់ខ្លួន ឧទាហរណ៍ដើម្បីរក្សាស្ថិរភាពការផ្គត់ផ្គង់ ទន្ទឹមនឹងបង្កើតប្រព័ន្ធធានារ៉ាប់រងប្រកបដោយប្រសិទ្ធភាព ដើម្បីបង្ការការធ្លាក់ចុះគំហុកជាយថាហេតុនៃតម្រូវការផលិតផល។ អ្នកនាំចេញស្បៀងក៏ស្វាគមន៍ចំពោះស្ថិរភាពទាក់ទងនឹងវត្តមាន និងថ្លៃផលិតផលផងដែរ។ ពួកគេក៏ចង់កែតម្រូវនូវទម្រង់ផលិតកម្មរបស់ខ្លួនផងដែរ ដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើការនាំចូល។

ប៉ុន្តែ ជម្រើសលំបាកពីរដ៏សំខាន់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ទាក់ទងនឹងផលប៉ះពាល់នៃពាណិជ្ជកម្មអន្តរជាតិទៅលើថ្លៃនៃស្បៀងសំខាន់ៗ។ តើរដ្ឋាភិបាលមានគោលដៅរក្សាថ្លៃដើម្បីធ្វើឱ្យការចិញ្ចឹមជីវិតរបស់កសិករមានភាពថ្លៃថ្នូរ ឬត្រូវបញ្ចុះថ្លៃ ដើម្បីជួយអ្នកប្រើប្រាស់ក្រីក្រនៅក្នុងទីក្រុងដែរឬទេ? នេះជាបញ្ហាចម្បង ឧទាហរណ៍ នៅក្នុងប្រទេសឥណ្ឌូណេស៊ី ដែលជាអ្នកផលិតស្រូវធំជាងគេនៅក្នុងស្រុក ប៉ុន្តែមិនអាចផ្គត់ផ្គង់ខ្លួនឯងបានគ្រប់គ្រាន់ ហើយត្រូវធ្វើការនាំចូលដើម្បីបំពេញតម្រូវការស្រូវ។ ការនាំចូលស្រូវដោយថ្លៃទាបអាចផ្តល់ឥទ្ធិពលអាក្រក់ដល់ផលិតករក្នុងស្រុក ដូច្នេះ ប្រទេសឥណ្ឌូណេស៊ី បានដាក់ឱ្យអនុវត្តពន្ធលើការនាំចូល។

ស្ថាប័នខ្លះរួមទាំងធនាគារពិភពលោកផងបានអះអាងថាពន្ធនេះគួរតែត្រូវលុបចោល ឬមួយគួរតែមានកម្រិតទាបបំផុតតាមតែអាចធ្វើបាន ដោយសារជនក្រីក្រឥណ្ឌូណេស៊ីចំណាយ ៣០% នៃប្រាក់ចំណូលរបស់ខ្លួនទៅលើអង្ករ។[២៥] អ្នកផ្សេងទៀតអះអាងថា គោលនយោបាយអង្ករថោកពុំផ្តល់

ប្រយោជន៍ទេ ។ ប្រសិនបើកសិករឥណ្ឌូណេស៊ីត្រូវលក់ទំនិញរបស់ខ្លួនដោយថ្លៃទាប ពួកគេនឹងពុំអាចកែលំអស្ថានភាពរបស់ខ្លួនបានឡើយ ហើយរឹតតែពុំអាចវិនិយោគលើការអប់រំ ដែលមានន័យថាឥណ្ឌូនេស៊ីនឹងនៅតែពុំមានជំនាញគ្រប់គ្រាន់ និងជាសេដ្ឋកិច្ចដែលផ្តល់ប្រាក់កម្រៃទាប ផលិតភាពទាប។[២៦] ការបន្តភាពក្រីក្រ ក៏ធ្វើឱ្យអំណាចទិញនៅក្នុងមូលដ្ឋាន និងតម្រូវការផលិតផលផ្សេងនៅក្នុងស្រុកចុះខ្សោយផងដែរ ដូច្នេះ វារារាំងការអភិវឌ្ឍជាតិ និងការបន្តអត្រាខ្ពស់នៃការពឹងផ្អែកលើទីផ្សារបរទេស។[២៧]

ក្នុងការអនុវត្តជាក់ស្តែង ពាណិជ្ជកម្មកសិផលមាននិន្នាការឈានទៅសេរីភាវូបនីយកម្មកាន់តែទូលាយឡើង។ នៅក្នុងករណីខ្លះ ប្រការនេះកើតឡើងដោយសារប្រទេសនានាបានចុះកិច្ចព្រមព្រៀងទ្វេភាគីប្រចាំតំបន់ ឬកិច្ចព្រមព្រៀងពហុភាគី ដែលទាមទារឱ្យមានពាណិជ្ជកម្មកាន់តែបើកចំហ។ ប៉ុន្តែ អាចនិយាយបានម្យ៉ាងទៀតថា ប្រទេសនានាបានធ្វើសេរីភាវូបនីយកម្មជាឯកតោភាគីឬធ្វើទៅតាមលក្ខខណ្ឌរបស់ទីភ្នាក់ងារអន្តរជាតិ ដែលជាបង្អែកសម្រាប់លំហូរចូលមូលធនដើម្បីបំពេញឱនភាពនៃជញ្ជីងទូទាត់។

ជាអកុសល ភាគច្រើននៃសេរីភាវូបនីយកម្មនេះមិនមានភាពឆ្លើយតបគ្នាទេ។ ប្រទេសកំពុងអភិវឌ្ឍន៍បានធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មកសិផលរបស់ខ្លួនបានច្រើនជាងប្រទេសជឿនលឿន ដែលនៅតែរក្សាកម្រិតខ្ពស់នៃការឧបត្ថម្ភធនដល់ផលិតករស្បៀងក្នុងស្រុក ក៏ដូចជានៅប្រើប្រាស់របាំងមិនមែនបច្ចេកទេសពន្ធ។ ភាពមិនឆ្លើយតបគ្នានេះត្រូវបានសង្កត់ធ្ងន់ ដោយកិច្ចព្រមព្រៀងប្រទេសអ៊ុយរ៉ាហ្គាយ ស្តីពីទិដ្ឋភាពទាក់ទងនឹងពាណិជ្ជកម្មនៃកម្មសិទ្ធិបញ្ញា (TRIPS) ដែលរហូតមកដល់ពេលនេះ ប្រការស្តីពីនិមិត្តរូបប្រចាំទីតាំងភូមិសាស្ត្រច្រើនតែត្រូវបានប្រទេសជឿនលឿនកេងយកផលចំណេញ។ ប៉ុន្តែ ប្រទេសកំពុងអភិវឌ្ឍន៍ក៏អាចប្រើប្រាស់ចំណុចនេះជាគន្លឹះដើម្បីពន្លឿនរបៀបវារៈអភិវឌ្ឍន៍មនុស្សរបស់ខ្លួនផងដែរ។

## ការចរចានាពេលបច្ចុប្បន្ន

ការចរចាបច្ចុប្បន្ននៅទីក្រុងដូហាអំពីពាណិជ្ជកម្មផ្តល់កាលានុវត្តភាពដើម្បីកែតម្រូវវិសមធម៌ទាំងនេះ។ ប៉ុន្តែ ការចរចានោះដូចជាពុំឈានទៅតាមទិសដៅត្រឹមត្រូវឡើយ ជាពិសេសទាក់ទងនឹង "ប្រអប់បៃតង" ដែលសំដៅលើការឧបត្ថម្ភដែលគ្មានកំណត់ និង "ប្រអប់ខៀវ" ដែលមានការដាក់កំហិតច្រើនជាង (សូមអានកំណត់សម្គាល់ ៩ និង ១០)។ នៅដើមនៃការចរចានេះ ស.រ.អា និងសហភាពអឺរ៉ុប មានជោគជ័យក្នុងការធានាថាពួកគេអាចបន្តប្រើប្រាស់ពុំត្រឹមត្រូវនូវវិធានការគាំទ្រប្រអប់បៃតង និងថែមទាំងអាចរក្សា និងពង្រីកវិធានការប្រអប់ខៀវ ដែលគួរតែត្រូវលុបចោលនៅចុងនៃជុំចរចានៅប្រទេសអ៊ុយរ៉ាហ្គាយ។[២៨]

មានភាពចំណេញខ្លះបានកើតឡើង។ កិច្ចប្រជុំនៃអគ្គក្រុមប្រឹក្សារបស់ WTO នៅក្នុងខែកក្កដា ឆ្នាំ ២០០៤ បាននាំមកនូវក្របខ័ណ្ឌមួយដែលតម្រូវឱ្យប្រទេសជឿនលឿនកាត់បន្ថយ និងបន្ទាប់មកលុបចោលនូវការឧបត្ថម្ភធនផ្ទាល់ ឬប្រយោលនៅក្នុងពាណិជ្ជកម្មកសិផល។ កិច្ចប្រជុំនោះក៏ទទួលបានការសន្យាផងដែរដើម្បីកាត់បន្ថយយ៉ាងច្រើននូវការឧបត្ថម្ភដល់កសិករនៅក្នុងស្រុក។[២៩] ទោះជាយ៉ាងណាក្តី អត្ថបទនោះបានអនុញ្ញាតឱ្យមានការលើកលែងខ្លះៗ ជាពិសេសតាមរយៈការអនុញ្ញាតឱ្យកាត់បន្ថយទាបជាងនូវ "ចំនួនសមស្រប" នៃ "ផលិតផលងាយប្រែប្រួល"។ ការធ្វើបែបនេះអនុញ្ញាតឱ្យ US ការពារផលិតផលដែលគ្មានភាព ប្រកួតប្រជែង ដូចជាស្ករ។

សូម្បីតែបែបនេះក៏ដោយ ប្រទេសកំពុងអភិវឌ្ឍន៍បាន

*ប្រទេសកំពុង
អភិវឌ្ឍន៍បានធ្វើ
សេរីភាវូបនីយកម្ម
ពាណិជ្ជកម្មកសិផល
របស់ខ្លួន បានច្រើនជាង
ប្រទេសជឿនលឿន*

ធ្វើឱ្យមានការរីកចម្រើនខ្លះៗ។ កិច្ចព្រមព្រៀងនេះទទួលស្គាល់យ៉ាងច្បាស់អំពីតម្រូវការឱ្យមាន "ការយកចិត្តទុកដាក់ពិសេស និងខុសគ្នា" សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ទាក់ទងនឹងកម្រិតកាត់បន្ថយអត្រាពន្ធ ចំនួនផលិតផលងាយប្រែប្រួល និងការយកចិត្តទុកដាក់ចំពោះផលិតផលងាយប្រែប្រួល និងរយៈពេលនៃការអនុវត្ត។ ជាក់ស្តែង ដូចដែលប្រទេសជឿនលឿនបានកំណត់ "ផលិតផលដែលងាយប្រែប្រួល" ខ្លះៗ ប្រទេសកំពុងអភិវឌ្ឍន៍ក៏អាចធ្វើអត្តសញ្ញាណចំនួនសមស្របនៃ "ផលិតផលពិសេស" ដែលសមនឹងបានទទួលបានការយកចិត្តទុកដាក់ទន់ភ្លន់ជាងមុន និងមិនស្ថិតនៅចំណុះការប្តេជ្ញាកាត់បន្ថយពន្ធ ដោយយោងតាមការរួមវិភាគទានរបស់ផលិតផលទាំងនោះ ឧទាហរណ៍ចំពោះសន្តិសុខស្បៀង និងតម្រូវការអភិវឌ្ឍន៍ជនបទ។ ក្របខ័ណ្ឌនេះក៏បានផ្តល់ផងដែរនូវ "យន្តការគាំពារពិសេស" ប្រឆាំងនឹងការនាំចូលដើម្បីបង្កការរំខាន កំណើនយ៉ាងគំហុកនៃការនាំចូល ឬការធ្លាក់ថ្លៃចុះយ៉ាងគំហុកនៃកសិផលជាក់លាក់មួយចំនួន។

តើប្រការទាំងនេះអាចសម្រេចបានប៉ុណ្ណាហើយ? ការលុបបំបាត់នៅពេលណាមួយនៃការឧបត្ថម្ភធននឹងបានទទួលការស្វាគមន៍ ប៉ុន្តែប្រការនេះគួរតែត្រូវបានលុបចោលរួចទៅហើយ សូម្បីតែនៅក្រោមបទប្បញ្ញត្តិបច្ចុប្បន្នរបស់ WTO។ ការផ្លាស់ប្តូរចម្បងគឺថា សហភាពអឺរ៉ុបដែលជាអ្នកប្រើប្រាស់បឋមនូវការឧបត្ថម្ភបែបនេះផ្ទាល់បានធ្វើការកាត់បន្ថយដោយដាក់លក្ខខណ្ឌឱ្យមានការកាត់បន្ថយស្របគ្នានេះដែរនូវការឧបត្ថម្ភធនប្រយោល ដូចជា ឥណទានសំរាប់ការនាំចេញដែលប្រើប្រាស់ជាបឋមដោយស.រ.អា ។

ទោះជាយ៉ាងណាក៏ដោយ ចំណុចដែលស្មុគជាងគេនោះ មិនមែនការឧបត្ថម្ភសម្រាប់ការនាំចេញនោះទេ ប៉ុន្តែគឺការគាំទ្រដោយផ្ទាល់ដល់ផលិតករក្នុងស្រុក។ មកទល់ពេលនេះ ប្រទេសជឿនលឿនបានផ្តល់សម្បទានតិចតួចណាស់លើផ្នែកនេះ ដែលបង្កើតជាចំណែកសំខាន់សម្រាប់ការគាំទ្រដល់វិស័យកសិកម្ម។

កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះភាគច្រើនត្រូវបានផ្តល់សច្ចាប័ននៅក្នុងកិច្ចប្រជុំរបស់ WTO នៅខែធ្នូ ឆ្នាំ ២00៥ ក្នុងទីក្រុងហុងកុង។ នៅក្នុងកិច្ចប្រជុំនេះ សហភាពអឺរ៉ុបបានទទួលឯកភាពថាខ្លួននឹងលុបចោលការឧបត្ថម្ភធនលើការនាំចេញនៅក្នុងឆ្នាំ ២០១៣ ប៉ុន្តែប្រការនេះត្រូវតែឆ្លើយតបនឹងការកាត់បន្ថយដែលបានពិចារណារួចមកហើយនៅក្នុងកំណែទម្រង់គោលនយោបាយកសិកម្មរួមរបស់សហភាពអឺរ៉ុប ដែលនឹងត្រូវបញ្ចប់នៅឆ្នាំ ២០១៣។ ចំពោះបញ្ហាកសិកម្មផ្សេងទៀត សេចក្តីថ្លែងការណ៍ទីក្រុងហុងកុងបានរំលឹកឡើងវិញអំពីតម្រូវការរិះរកវិធីនានាដើម្បីកាត់បន្ថយអត្រាពន្ធ និងការឧបត្ថម្ភធននៅក្នុងស្រុក និងថែងថា ការកាត់បន្ថយយ៉ាងច្រើនបំផុតត្រូវបានរំពឹងទុកពីសំណាក់ប្រទេសនានាដែលបានផ្តល់ការឧបត្ថម្ភក្នុងស្រុកច្រើនជាងគេ និងដែលបានអនុវត្តអត្រាពន្ធនាំចូលខ្ពស់ជាងគេ។ ទោះជាយ៉ាងណាក៏ដោយ ការកាត់បន្ថយយ៉ាងច្រើននៃការឧបត្ថម្ភធនមិនទំនងជានឹងធ្វើទៅបានឡើយ។

ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ កិច្ចប្រជុំទីក្រុងហុងកុង បានផ្តល់នូវផលចំណេញបីបែប : សហភាពអឺរ៉ុបប្តេជ្ញាលុបចោលការឧបត្ថម្ភធននៅឆ្នាំ ២០១៣។ កាលានុវត្តភាពដើម្បីកំណត់ "ផលិតផលពិសេស" ដែលនឹងមិនស្ថិតក្រោមការយកពន្ធនិង "យន្តការគាំពារពិសេស" ដើម្បីឆ្លើយតបនឹងការកើនឡើងយ៉ាងគំហុកនូវការនាំចូល ឬការធ្លាក់ថ្លៃយ៉ាងគំហុក។

## កម្មសិទ្ធិបញ្ញា

ទិដ្ឋភាពប្រកបដោយភាពចម្រូងចម្រាស់មួយផ្សេង

ទៀតនៃរបបពាណិជ្ជកម្មអន្តរជាតិ ដែលបានចែងតាមរយៈកិច្ចចរចាទីក្រុងអ៊ុយរ៉ាហ្គាយ គឺជាកិច្ចព្រមព្រៀងស្តីពី TRIPS ។ កិច្ចព្រមព្រៀងនេះមានគោលដៅការពារសិទ្ធិរបស់បុគ្គល និងក្រុមហ៊ុនដែលបានធ្វើការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ដោយផ្តល់ឱ្យអ្នកទាំងនោះនូវកាលានុវត្តភាព ដើម្បីរកចំណូលសម្រាប់ទូទាត់ការចំណាយរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋានដែលថា បើពុំមានកិច្ចការពារបែបនេះទេ ពួកគេនឹងមានការលើកទឹកចិត្តតិចតួចតែប៉ុណ្ណោះ ដើម្បីធ្វើការវិនិយោគប្រហាក់ប្រហែលគ្នានេះទៅអនាគត។

ទោះជាយ៉ាងណាក៏ដោយ អ្នកជំទាស់អះអាងថាពុំចាំបាច់ឱ្យមានកិច្ចការបែបនេះទេ ព្រោះថាអំឡុងពេលដែលគូប្រជែងព្យាយាមប្រឹងប្រែងធ្វើទំនើបកម្ម បានផ្តល់កាលានុវត្តភាពគ្រប់គ្រាន់រួចទៅហើយ ដើម្បីបំពេញការចំណាយលើ R&D ។ ហើយក្នុងករណីខ្លះនៃពេលបច្ចុប្បន្ននេះ ពុំគួរមានកិច្ចការពារខ្លាំងពេកនោះទេ ព្រោះថានៅពេលដែលផលិតផលទំនើបកាន់តែមានភាពសាំញ៉ាំ ការចំណាយលើមូលធននឹងកើនឡើង ដែលបង្កើតជារបាំងនៃការចូលរួម និងកាត់បន្ថយហានិភ័យនៃបរាជ័យ ហេតុនេះជាការរំខានគូប្រជែងរួចទៅហើយ។ លើសពីនេះ ការច្នៃប្រឌិតជាច្រើនសម្រាប់បង្កើតផលិតផលថ្មីនឹងផ្អែកតិចតួចទៅលើផលិតផលនោះដោយផ្ទាល់ ប៉ុន្តែពឹងផ្អែកច្រើនជាងទៅលើរបៀបនៃការផលិត។ ដំណើរការនៃការផ្លាស់ប្តូរបច្ចេកវិទ្យា ត្រូវបានបង្កប់នៅក្នុងក្រុមហ៊ុនតែម្តង ដែលមិនអាចឱ្យគូប្រជែងមានលទ្ធភាពប្រកួតប្រជែងបានឡើយ។

មានបញ្ហាជាច្រើនផងដែរទាក់ទងនឹងការឱ្យនិយមន័យពុំច្បាស់លាស់។ ឧទាហរណ៍ តើនៅចំណុចណាមួយដែលកំណើនចំណេះដឹងរបស់មនុស្សនឹងត្រូវបានបកស្រាយថាជាការច្នៃប្រឌិត? ហើយតើអាចធ្វើបែបណាដើម្បីអាចចាត់ទុកថាការច្នៃប្រឌិតណាមួយពឹងផ្អែកភាគច្រើនទៅលើទ្រព្យសម្បត្តិរួម ឧទាហរណ៍ថ្នាំពេទ្យដែលបង្កើតចេញពីផលិតផលធម្មជាតិ? ប្រសិនបើអនុញ្ញាតឱ្យអ្នកច្នៃប្រឌិតបង់ថ្លៃ តើប្រទេសឬសហគមន៍ដែលផ្តល់វត្ថុធាតុពីខាងដើម មិនមានសិទ្ធិដូចគ្នានេះដែរឬយ៉ាងណា?

ទោះបីមានការលើកឡើងបែបនេះ និងការជំទាស់ផ្សេងទៀតជាច្រើនក៏ដោយ ប្រទេសជឿនលឿនបានទាមទារកាន់តែខ្លាំងឡើងនូវកិច្ចការពារប៉ាតង់ជាអន្តរជាតិ និងជាពិសេសបានធ្វើការគាបសង្កត់តាមរយៈរបបពាណិជ្ជកម្មទៅតាមកិច្ចព្រមព្រៀង TRIPS។ ប្រការនេះនាំមកនូវអត្ថ-ប្រយោជន៍មួយចំនួន។ ទីមួយ ដោយសារវាបង្កើតកាលានុវត្តភាពសម្រាប់ពង្រឹងការអនុវត្ត។ ប្រទេសដែលពុំគោរពសិទ្ធិលើកម្មសិទ្ធិបញ្ញា TRIPS នឹងត្រូវប្រឈមការវាយបក តាមរយៈការដាក់ទណ្ឌកម្មពាណិជ្ជកម្ម។ ទីពីរ វាបង្កើតឱ្យមានអង្គភាពអន្តរជាតិ ក្រោមទម្រង់ជាក្រុម WTO សម្រាប់ដោះស្រាយជម្លោះ ដែលក្រុមនេះជាអ្នកដោះស្រាយករណីបទល្មើស IPRs។ ទីបី វាផ្ទេរទៅឱ្យរដ្ឋាភិបាលថ្នាក់ជាតិនូវការទទួលខុសត្រូវត្រួតពិនិត្យលើសិទ្ធិបញ្ញាដែលរដ្ឋាភិបាលទាំងនោះពុំចង់ឃើញអ្នកនាំចេញទាំងអស់ទទួលរងទណ្ឌកម្ម ដោយសារតែបទល្មើសដែលបានប្រព្រឹត្តដោយសហគ្រាសតែមួយនោះឡើយ។ ដូច្នេះ កិច្ចព្រមព្រៀងនៅប្រទេសអ៊ុយរ៉ាហ្គាយ មិនត្រឹមតែចាប់បង្ខំឱ្យប្រទេសនានាទទួលស្គាល់ IPRs ប៉ុណ្ណោះទេ ប៉ុន្តែ វាក៏បង្កើតយន្តការដែលប្រើការបានផងដែរ សម្រាប់ពង្រឹងការអនុវត្តសិទ្ធិទាំងនោះ។

រហូតមកទល់ពេលថ្មីៗនេះ ឥទ្ធិពលចម្បងនៃកិច្ចព្រមព្រៀងនេះទៅលើកសិកម្ម អាចទាក់ទងនឹងការប្រើប្រាស់ដូចជាជី ថ្នាំកំចាត់សត្វចង្រៃ និងគ្រឿងយន្តនានា។ ប្រការនេះមានការផ្លាស់ប្តូរដោយសារមានការវិវត្តបច្ចេកវិទ្យាពីរបែប។

ទីមួយ ចាប់តាំងពីឆ្នាំដែលមានបដិវត្តបៃតង ក្រុមហ៊ុនជាច្រើនបានផលិតអ៊ីប្រ៊ីត ឬពូជដែលបង្កើតបានពីការស្រាវជ្រាវវិទ្យាសាស្ត្រ។ ទីពីរ ថ្មីៗនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់វិស្វកម្មសេនេទិក និងជីវៈបច្ចេកវិទ្យា ដើម្បីកែច្នៃហ្សែនសម្រាប់ផលិតពូជដំណាំ ដែលផ្តល់ទិន្នផលខ្ពស់ជាង និងដែលធន់នឹងសត្វចង្រៃជាងមុន និងដែលសមស្របជាងសម្រាប់លក្ខខណ្ឌណាមួយនៃអាកាសធាតុ ដី និងសំណើម។

ដូច្នេះ សាជីវកម្មអន្តរជាតិសង្ឃឹមថាអនុវត្តប៉ាតង់ទៅលើ "កិច្ចការពូជរុក្ខជាតិ" ដោយអះអាងថាការធ្វើបែបនេះនឹងជួយធានាឱ្យមានការស្រាវជ្រាវបន្តទៀត។ ប្រការនេះ នាំឱ្យមានភាពមិនច្បាស់លាស់ផងដែរ ដោយសារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ការស្រាវជ្រាវបែបនេះបានទទួលហិរញ្ញប្បទានជាចម្បងពីរដ្ឋាភិបាល ហើយជាទូទៅពូជដំណាំដែលមាននៅក្នុងជំនួញ ផ្តល់នូវភាពខុសគ្នាតែរូបភាពខាងក្រៅប៉ុណ្ណោះ ដោយប្រើប្រាស់ខ្សែស្រឡាយ ដោយផ្អែកលើការស្រាវជ្រាវដែលគាំទ្រដោយគ្រឹះស្ថានសាធារណៈ។

តាមពិត ទម្រង់ខ្លះនៃកិច្ចការពារ គឺជាការរាំងស្ទះការស្រាវជ្រាវបន្ថែម។ ប្រការនេះបង្ហាញជាភស្តុតាងច្បាស់សូម្បីតែនៅក្នុងអំឡុងបដិវត្តន៍បៃតង នៅពេលដែលក្រុមហ៊ុនអន្តរជាតិនៃគ្រាប់ពូជ ដូចជា Monsanto និង Pioneer Hi-Bred International Inc បានព្យាយាមទទួលប៉ាតង់សម្រាប់រុក្ខជាតិ ដែលរាំងស្កាត់កសិករពីរក្សាទុកគ្រាប់ពូជនៃដំណាំដែលខ្លួនដាំបាន។ នេះមានន័យថា នៅពេលដែលមជ្ឈមណ្ឌលអន្តរជាតិកែលំអពោតនិងស្រូវសាឡី នៅម៉ិកស៊ិចកូ បានបង្កើតពូជស្រូវសាឡីពាក់កណ្តាលតឿ ដែលកែលំអសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ មជ្ឈមណ្ឌលនោះពុំអាចផ្តល់ពូជនោះទៅប្រទេសឥណ្ឌាឡើយ ដោយសារត្រូវការពារដោយប៉ាតង់នៅអាមេរិក។ ជាលទ្ធផល បដិវត្តន៍បៃតងនៅឥណ្ឌាមិនបានពង្រីកផលិតកម្មពោតឡើយ។ ដូច្នេះ កិច្ចការពារដោយប៉ាតង់អាចបង្កើតឧបសគ្គថ្មីចំពោះការកែលំអកសិកម្ម។

ក្រុមហ៊ុនទាំងនោះក៏ពង្រឹងការអនុវត្តកិច្ចការពារតាមច្បាប់នេះផងដែរ តាមទម្រង់បច្ចេកទេសដោយធ្វើវិស្វកម្ម ពូជដែលជា "គ្រាប់ពូជអា" មិនអាចបង្កកំណើតបាន ឬពូជដែលនៅក្នុងអំឡុងពេលនៃការបន្តពូជដោយធម្មជាតិ លក្ខណៈខ្លះៗត្រូវបាត់បង់ ឬមិនអាចបញ្ជូនបន្តតាមរយៈគ្រាប់ពូជទៅជំនាន់ក្រោយឡើយ។ ក្រុមហ៊ុនទាំងនោះក៏អាចកែតម្រូវរុក្ខជាតិផងដែរ ដើម្បីធ្វើឱ្យប្រាកដថាពូជទាំងនោះមិនសំដែងចេញនូវសំណុំលក្ខណៈមួយចំនួន ដូចជា ភាពធន់នឹងថ្នាំសម្លាប់ស្មៅ លើកលែងតែបាញ់ដោយលាយជាមួយសារធាតុគីមី ពិសេសដែលមានប្រតិកម្មទៅលើហ្សែនជាក់លាក់។



ប្រទេសកំពុងអភិវឌ្ឍន៍អាចអះអាងយ៉ាងត្រឹមត្រូវថាក្រុមហ៊ុនពហុជាតិកំពុងប្លន់យកធនធានរបស់ខ្លួន។ ប្រទេសនៅត្រូពិកសំបូរទៅដោយជីវចម្រុះ និងផ្តល់នូវប្រភេទពូជដើមដំបូងភាគច្រើន ដែលជាមូលដ្ឋាននៃការស្រាវជ្រាវនៅក្នុងប្រទេសជឿនលឿន។ ចំណុចនេះត្រូវបានសំដៅជា "អំពើប្លន់ជីវសាស្ត្រ" នៅពេលដែលក្រុមហ៊ុនបរទេសលួចយកបន្ទាប់មកដាក់ប៉ាតង់លើធនធានជីវសាស្ត្រ និងចំណេះដឹងប្រពៃណីពីប្រទេសកំពុងអភិវឌ្ឍន៍។ ប៉ាតង់របស់ស.រ.អា ទៅលើការប្រើប្រាស់ turnmeric សម្រាប់ព្យាបាលរបួស ដែលជាករណីមានការដឹងឮជាទូទៅ។

ប៉ុន្តែក៏មានករណីផ្សេងទៀតផងដែរ ដែលជីវបច្ចេកវិទ្យានិងប៉ាតង់ កំពុងបំផ្លាញប្រទេសកំពុងអភិវឌ្ឍន៍តាមវិធីប្រកបដោយគ្រោះថ្នាក់។ មកទល់ឥឡូវនេះ ពូជរុក្ខជាតិជាច្រើនជំនាន់នៅក្នុងប្រទេសខុសៗគ្នា បានផលិតចេញជាពូជខុសគ្នាដែលមានសារៈប្រយោជន៍។ ជីវបច្ចេកវិទ្យាអាចកែច្នៃ និងធ្វើវិស្វកម្មពូជទាំងនោះ ដោយអាចឱ្យពូជទាំងនោះលូតលាស់នៅ

ក្នុងតំបន់ផ្សេងទៀត ដូចជាករណីស្រូវបាស្មាទី ដែលក្រុមហ៊ុនជំនួញពូជរុក្ខជាតិឈ្មោះ Rice Tec បានអភិវឌ្ឍដោយផ្អែកលើចំណេះដឹងប្រពៃណី ដោយពុំបានបង់ថ្លៃសម្រាប់ការប្រើប្រាស់នោះឡើយនិងចាត់ចែងធ្វើផលិតផលរបស់ខ្លួនឱ្យខុសពីគេដើម្បីបង្ហាញ "លក្ខណៈថ្មី" សម្រាប់ទទួលប៉ាតង់។ ប៉ុន្តែជាទូទៅអ្វីដែលបានចាត់ទុកថាជាការបង្កើតថ្មី គឺគ្រាន់តែជាការវិនិច្ឆ័យតាមអំពើចិត្តរបស់ខ្លួនតែប៉ុណ្ណោះ។

## ការកំណត់ទីតាំងភូមិសាស្ត្រ

ទោះបីមានឥទ្ធិពលបែបនេះក្តី មានការអះអាងថា ទោះបីត្រឹមកម្រិតណាមួយក៏ដោយ ប្រទេសកំពុងអភិវឌ្ឍន៍អាចទាញយកប្រយោជន៍ពីកិច្ចព្រមព្រៀង TRIPS ដើម្បីផ្តល់ជាការអនុគ្រោះសម្រាប់ខ្លួន។ ឧទាហរណ៍ ដោយប្រើប្រាស់ប្រព័ន្ធ ការកំណត់ទីតាំងភូមិសាស្ត្រ (GI) មានការចង្អុលបង្ហាញពាក្យប្រយោគ និមិត្តសញ្ញា ឬរូបភាព ដែលជាអត្តសញ្ញាណថា ទំនិញមួយមានប្រភពនៅក្នុងដែនដីណាមួយ និងមានគុណភាពបែបណាមួយ កេរ្តិ៍ឈ្មោះ ឬសំណុំ លក្ខណៈផ្សេងទៀតរបស់ទំនិញនោះ មានសារៈសំខាន់ទាក់ទងទៅនឹងប្រភពដើមនៃភូមិសាស្ត្រនោះ។[៣០] ការកំណត់ទីតាំងភូមិសាស្ត្រមិនដូចប៉ាតង់ទេ ដោយពុំការពារស្នាដៃថ្មី ប៉ុន្តែគ្រាន់តែទទួលស្គាល់អ្វីដែលមានស្រាប់ប៉ុណ្ណោះ។

គំនិតនេះមានប្រភពដើមពីអឺរ៉ុប ហើយភាគច្រើននៃ GI សំដៅទៅផលិតផលពីប្រទេសជឿនលឿន ដូចជា ស្រា Champagne, Cognac, ហ្វ្រូម៉ាស Roquefort, ស្រា Napa Valley និងស្រា Scotch whisky។ ឧទាហរណ៍ អំពី GI នៅអាស៊ីរួមមាន ស្រូវបាស្មាទី ទឹកត្រីកោះត្រល់ តែឡុងជីន ទឹកពីភ្នំហេមពាន្ត ស្វាយ Alphonso និង Shindhri, Hunza apricots, អង្ករក្រហមភូមា Cashmere ពីម៉ុងហ្គោលី (ក្រណាត់បាំងខ្យល់) និង Ajrak (បង្កើតឡើងពី Sindh) អង្ករផ្កាម្លិះ (Hom Mali) សូត្រថៃ ទឹកក្រអូបក្រវាញពីឡាវ កាហ្វេ Mandheling ពីកោះស៊ូម៉ាត្រា ស្រា Shaoxing, Maotai, ម្រេច Xuancheng និង Ceylon ព្រមទាំង តែ Darjeeling។

GI ផ្តល់ជាប្រយោជន៍សម្រាប់អ្នកកសាងគោលនយោបាយ ដោយសារវាជាសម្បត្តិសាធារណៈ។ ជាធម្មតាកម្មសិទ្ធិបញ្ញាគឺជាកម្មសិទ្ធិរបស់បុគ្គល ឬសាជីវកម្ម ហើយ ៨៧% នៃប៉ាតង់ទាំងអស់នៅទូទាំងពិភពលោកគឺជាកម្មសិទ្ធិរបស់ប្រទេសជឿនលឿន។[៣១] ប៉ុន្តែ GI គឺជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ឬស្ថាប័នដែលមានសមត្ថកិច្ចគ្រប់គ្រងតាមផ្លូវច្បាប់។ សូម្បីតែក្រុមសង្គមមនុស្សដែលរកចំណូលទ្រង់ទ្រាយតូច ដែលមានបច្ចេកវិទ្យាទាបក៏ដោយក៏ជាគោលការណ៍អាចប្រើប្រាស់ GI ដើម្បីលើកកម្ពស់ផលិតផល និងចំណេះធ្វើជាប្រពៃណីរបស់ខ្លួនផងដែរ។

*GI ផ្តល់ជាប្រយោជន៍សម្រាប់អ្នកកសាងគោលនយោបាយ ដោយសារវាជាសម្បត្តិសាធារណៈ*

ការធ្វើបែបនេះបើកឱ្យមានកាលានុវត្តភាពអភិវឌ្ឍន៍ជាច្រើន។ ប្រជាជាតិនៅអាស៊ីមានផលិតផលជាច្រើនបែប ប៉ុន្តែមានតែមួយចំនួនតូចតែប៉ុណ្ណោះដែលត្រូវបានគេស្គាល់នៅលើពិភពលោក ដែលនេះមានន័យថា មានវិសាលភាពយ៉ាងធំសម្រាប់ការផ្សព្វផ្សាយជាសាធារណៈអំពីផលិតផលទាំងនោះ ទាំងនៅក្នុង និងក្រៅប្រទេស។ នៅពេលដែលមានការទទួលស្គាល់ GI សហគមន៍ និងសហគ្រាសនៅក្នុងតំបន់កំណត់ណាមួយអាចបញ្ឈប់អ្នកដទៃពីការប្រើប្រាស់ GI នោះ។ អ្នកទាំងនោះក៏មានអំណាចក្នុងការទារកម្រៃបុព្វលាភសម្រាប់អ្វី ដែលបានបញ្ជាក់រួចហើយថាជាផលិតផល "ពិតប្រាកដ" ឥតក្លែងក្លាយផងដែរ។ គេអាចអះអាងថា កំណើនថ្លៃធ្វើឱ្យខូចប្រយោជន៍របស់អ្នកប្រើប្រាស់ក្រីក្រ ប៉ុន្តែក្នុងករណីភាគច្រើន GI មិនមែនជាមុខទំនិញចាំបាច់សម្រាប់តម្រូវការជាមូលដ្ឋាននៃការបរិភោគ និង

ប្រើប្រាស់ទេ។ ជាទូទៅ វាជាផលិតផលពិសេសប្រកបដោយតម្លៃខ្ពស់ ដែលអ្នកក្រពុំសូវប្រើប្រាស់ឡើយ។

ក្រៅពីនេះក៏មានផលប្រយោជន៍ប្រយោលផងដែរ។ GI ច្រើនតែទាក់ទងជាមួយតំបន់ពេញនិយមរបស់ទេសចរ ដែលពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចសម្រាប់ប្រជាជនមូលដ្ឋាន តាមរយៈសហគ្រាសខ្នាតតូច និងអាចទាក់ទាញការវិនិយោគបន្ថែមទៅក្នុងតំបន់នោះ ដើម្បីអភិវឌ្ឍទីកន្លែង និងផលិតផលនោះ ដូចជានៅក្នុងកោះត្រល់ប្រទេសវៀតណាម។

GI មានសារៈសំខាន់សម្រាប់ការពារផលិតផលក្នុងស្រុក ក៏ដូចជាផ្តល់វិធីមួយសម្រាប់ការពារចំណេះដឹងមូលដ្ឋាន និងសម្បត្តិធម្មជាតិផងដែរ។ ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី និងអាហ្វ្រិក គឺជាជម្រកសម្រាប់ ៩០% នៃធនធានជីវសាស្ត្រ ដែលជាប្រភពនៃឱសថ និងដែលមានដើមកំណើតពីរុក្ខជាតិ។ នៅឆ្នាំ ២០០៤ តម្លៃនៅលើទីផ្សារនៃផលិតផលឱសថផលិតពីថ្នាំបុរាណរបស់ជនជាតិដើម ត្រូវបានប៉ាន់ប្រមាណថាមាន ៦០.០០០លានដុល្លារ។[៣២] នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ក្រុមហ៊ុនឱសថខ្លះពីលោកខាងលិចបានព្យាយាមយកអំណាចត្រួតត្រាចំណេះដឹងទាំងនេះតាមរយៈប៉ាតង់ ដូចជា ក្នុងករណីថ្នាំសម្លាប់ផ្សិតដែលមាននៅក្នុងសំបកឈើម៉្យាងនៅប្រទេសឥណ្ឌា។ មានឧទាហរណ៍ផងដែរអំពីអ្នកមកពីខាងក្រៅព្យាយាមចម្រាញ់យកសារធាតុដែលមាននៅក្នុងដំណាំចេកនៅប្រទេសហ្វីលីពីន ដែលអាចប្រឆាំងជម្ងឺទឹកនោមផ្អែម។ ប្រការទាំងនេះមានសក្តានុពលសម្រាប់បង្កើតផលប្រយោជន៍ ដែលផ្អែកលើប្រាក់ចំណូលដោយផ្ទាល់ និងសមធម៌ សម្រាប់ជនក្រីក្រនិងដែលទន់ខ្សោយ។

## កិច្ចព្រមព្រៀង TRIPS និង GI

កិច្ចព្រមព្រៀង TRIPS ផ្តល់កិច្ចការពារខ្លះៗដល់ GI ប៉ុន្តែវាមានកម្រិត។ វាហាមឃាត់ប្រទេសនានាពីការចុះបញ្ជីនូវសញ្ញាពាណិជ្ជកម្មដែលទាក់ទងនឹងប្រភពដើមនៃផលិតផលនៅក្នុងកន្លែងមួយដែលការពារដោយ GI ក្នុងករណីដែលការចុះបញ្ជីបែបនេះមានបំណងបំភ្លែមតិសាធារណជន។ ដូច្នេះប្រសិនបើប្រភពដើមត្រូវបានបញ្ជាក់ថា ទំនិញជា "ជំពូក" "ប្រភេទ" "រចនាបទ" ណាមួយ ឬសូម្បីគ្រាន់តែបញ្ជាក់ថា ទំនិញនោះយកគម្រូតាមផលិតផលពីកោះត្រល់ ការចុះបញ្ជីនឹងត្រូវបានអនុញ្ញាត។ ប្រការនេះបង្កើតឱ្យមានភាពមិនច្បាស់លាស់ ដោយសារផលិតករអាចប្រើប្រាស់ភាពល្បីល្បាញរបស់ផលិតផលមួយដោយមិនចាំបាច់បង់ថ្លៃ និងដោយពុំចាំបាច់បំភាន់មតិសាធារណជនឡើយ ហើយក៏អាចបង្កឱ្យមានភាពពុំប្រាកដប្រជាផងដែរលើការសម្រេចថា តើសាធារណជនត្រូវបានគេបំភាន់ ឬយ៉ាងណា។ លើសពីនេះ មានតែអ្នកកាន់ GI ប៉ុណ្ណោះដែលមានភស្តុតាងនេះ។

ករណីលើកលែងតែមួយគត់ចំពោះប្រការនេះគឺផលិតផលដែលមានតម្លៃចំពោះប្រទេសជឿនលឿនពោលគឺស្រា និងភេសជ្ជៈស្រវឹង។ ដូច្នេះ ក្រុមហ៊ុនមួយដែលចង់លក់ឧទាហរណ៍ "ប្រភេទស្រា Beaujolai ដែលផលិតនៅក្នុងប្រទេសវៀតណាម" នឹងពុំត្រូវបានហាមឃាត់ដោយផ្អែកលើការបំភាន់មតិសាធារណជនឡើយ ប៉ុន្តែអាចត្រូវហាមឃាត់ដោយមាត្រាមួយ ដែលផ្តល់កិច្ចការពារបន្ថែមទៀតសម្រាប់ស្រា និងភេសជ្ជៈស្រវឹង ដែលជាមាត្រាប្រឆាំងនឹងការរំលោភបំពានបែបនេះ។[៣៣]

## របប GI នៅអាស៊ី

ក្នុងការអនុវត្តជាក់ស្តែង អាស៊ីមាន GI យ៉ាងច្រើនអស់រយៈពេលជាច្រើនរយឆ្នាំមកហើយ ទោះបីទើបតែនៅពេលថ្មីៗនេះដែលប្រទេសនានាបានពិចារណាការពារ GI តាមរយៈ

កម្មសិទ្ធិបញ្ញាក៏ដោយ ។ សូម្បីតែឥឡូវនេះ ប្រទេសភាគច្រើនពុំមានបរិធានច្បាប់ sui generis ដោយឡែកនៅឡើយក្តី ។ ជាជំនួស ប្រទេសទាំងនោះផ្តល់កិច្ចការពារខ្លះៗ ទោះបីជាញឹកញាប់ពុំគ្រប់គ្រាន់ក៏ដោយ តាមរយៈមធ្យោបាយចំនួនពីរគឺ ច្បាប់សញ្ញាពាណិជ្ជកម្ម ឬច្បាប់ធ្វើជំនួញ ដូចជាច្បាប់ប្រឆាំងនឹងការប្រកួតប្រជែងមិនត្រឹមត្រូវ កិច្ចការពារអ្នកប្រើប្រាស់ ឬស្តង់ដារអាហារ ។ ទោះជាបែបនេះក្តី ជាញឹកញាប់ក្នុងការឆ្លើយតបចំពោះការគំរាមកំហែងមួយ ពួកគេបានប្រឹងប្រែងតាក់តែងច្បាប់កាន់តែជាក់លាក់ជាងមុន ដូចជានៅឥណ្ឌា ថៃ និងចិន (ប្រអប់ ៣.២) ។

ប្រអប់ ៣.២

### ការកំណត់ទីតាំងភូមិសាស្ត្រនៅអាស៊ី

ប្រទេសមួយចំនួននៅអាស៊ីបានបង្កើតប្រព័ន្ធនានាដើម្បីការពារនិមិត្ត រូបប្រចាំភូមិសាស្ត្ររបស់ខ្លួន :

*ឥណ្ឌា* : នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ ឥណ្ឌាបានប្រយុទ្ធក្នុងសង្គ្រាមដែលមានភាពល្បីល្បាញដើម្បីលុបចោលប៉ាតង់ខ្លះៗរបស់អាមេរិកលើស្រូវបាស្មាទី ប៉ុន្តែមិនសម្រេចទេ រហូតដល់ឆ្នាំ ១៩៩៩ ដោយបានអនុម័តច្បាប់ (ការពារ និងចុះបញ្ជី) នូវទំនិញជានិមិត្តរូបប្រចាំភូមិសាស្ត្រ ។ ច្បាប់នេះបានចូលជាធរមាននៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២000 ។ ការធ្វើបែបនេះអាចកំណត់ GI បានជាក់លាក់ជាង TRIPS ។ បន្ថែមលើទំនិញកសិផលដែលមានកំណត់ឈ្មោះតំបន់ភូមិសាស្ត្រ មានការកំណត់ផងដែរសម្រាប់ទំនិញធម្មជាតិ ដូចជា ត្បូងថ្ម និងបុកស៊ីត ក៏ដូចជាផលិតផលឧស្សាហកម្មផងដែរ ដូចជា សាច់ ក្រណាត់សារី Kanchipuram និងស្បែកជើង Kohlapuri ។ ច្បាប់នេះចែងថា សកម្មភាពមួយក្នុងចំណោមសកម្មភាពនានានៃការផលិត ឬកែច្នៃ ឬរៀបចំទំនិញដែលពាក់ព័ន្ធគួរតែធ្វើឡើងនៅក្នុងដែនដី តំបន់ ឬទីតាំងដើម ។ ប្រព័ន្ធរបស់ឥណ្ឌាមានការចែងលំអិតល្អបង្គួរ ទោះបីជម្រើសផ្សេងនៃកិច្ចការពារ GI តាមរយៈប្រព័ន្ធសញ្ញាពាណិជ្ជកម្មត្រូវបានចាត់ទុកថាមានលក្ខណៈហួសហេតុជាង និងពុំគ្រប់គ្រាន់ក៏ដោយ (Thual 2003) ។ ប្រព័ន្ធទាំងពីរអាចបង្កជាការគំរាមកំហែងចំពោះបុគ្គលឬផលិតករខ្នាតតូចដែលចង់ ការពារផលិតផលរបស់ខ្លួន ។

*ប្រទេសថៃ* : ប្រទេសថៃក៏បានចូលធ្វើសកម្មភាពដើម្បីគ្រាន់តែការពារខ្លួនឯង នៅពេលដែលអង្ករផ្កាម្លិះដែលល្បីល្បាញរបស់ខ្លួន ត្រូវបានចុះក្រោមប៉ាតង់នៅអាមេរិកថាជា ចាស្មាន់ទី ។ ទីបំផុតច្បាប់ sui generis ស្តីពី GI ត្រូវបានអនុម័ត និងចូលជាធរមាននៅខែមេសា ឆ្នាំ ២00៤ ។ ដោយបានការនិយមទទួលស្គាល់ថាជា "ច្បាប់ស្រាសំប៉ាញ" វាគឺជានីតិវិធីដែលមានលក្ខណៈស្តង់ដារសម្រាប់ការចុះបញ្ជី និងដាក់ទណ្ឌកម្មលើការប្រើប្រាស់មិនត្រឹមត្រូវ ដែលមានការផាកពិន័យដល់ ៥.000 ដុល្លារ ។ វាក៏ចែងផងដែរ អំពីការលុបចោល GI ប្រសិនបើ ឧទាហរណ៍វាប្រឆាំងនឹងសន្តិភាព និងសណ្តាប់ធ្នាប់ សីលធម៌សាធារណៈ និងគោលនយោបាយជាតិ (Chuen-jaipanich ២00៤) ។ ប្រទេសថៃ កំពុងប្រើប្រាស់ប្រព័ន្ធដែលជាចំណែកមួយនៃកម្មវិធី "តំបន់មួយ ផលិតផលមួយ" ។ ដោយបានប្រកាសនៅក្នុងឆ្នាំ ២00៣ ។ កម្មវិធីនេះបានជ្រើសរើសផលិតផលចំនួន ៦0 សម្រាប់សហគមន៍ ដើម្បីកែលំអ និងចុះបញ្ជីបញ្ជាក់គុណភាពក្នុងគោលដៅពង្រីកទីផ្សារក្នុងស្រុកជាដំបូង និងបន្ទាប់មកសម្រាប់ការនាំចេញ ។

*ប្រទេសចិន* : មានរបបពីរបែបខុសគ្នានៃកិច្ចការពារ GI ។ ទីមួយ ដែលត្រូវ បានបើកឡើងតាំងពីប្រទេសចិនបានចូលរួមនៅក្នុងអនុសញ្ញាទីក្រុងប៉ារីសនៅឆ្នាំ ១៩៨៥ គឺតាមរយៈការិយាល័យសញ្ញាពាណិជ្ជកម្មរបស់ប្រទេសចិន (CTMO) ហើយបទបញ្ជាដំបូងបង្អស់នានាត្រូវបានដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ១៩៩៣ ។ នៅក្នុងខែវិច្ឆិកាឆ្នាំ ២00៣ មាន ១00 GI ត្រូវបានចុះក្នុងបញ្ជី និងពាក្យសុំចំនួន ២៣៣ ផ្សេងទៀតកំពុងរង់ចាំពិនិត្យ ។ របបទីពីរគឺ sui generis តាមរយៈរដ្ឋបាលគ្រប់គ្រងគុណភាព អធិការកិច្ច និងចត្តាឡីស័ក (AQSIQ) ។ ឧទាហរណ៍ នៅឆ្នាំ ១៩៩៩ ដោយសហការជាមួយរដ្ឋាភិបាលបារាំង របបទីពីរនេះបានចាត់ចែង GI សម្រាប់ស្រាលឿង Shaoxing ។ នៅខែវិច្ឆិកាឆ្នាំ ២00៣ មានពាក្យសុំ GI ចំនួន ១២៣ ដែលត្រូវបានដាក់ជូនទៅ AQSIQ ក្នុងនោះ ចំនួន ៤៩ ត្រូវបានអនុម័តឯកភាព និង ៤១ ស្ថិតនៅក្រោមការពិចារណា (Li et al. ២00៣) ។ ផលិតផល GI ដ៏ល្បីល្បាញពីប្រទេសចិន ដូចជាតែឡុងជីង និងផលិតផលស្ពូន ដែលបានស្នើសុំកិច្ចការពារ បានបង្ហាញថា ការលក់ផលិតផលក្លែងក្លាយបានធ្លាក់ចុះ ចំណែកការលក់ និងថ្លៃផលិតផលទាំងនេះបានកើនឡើងយ៉ាងឆាប់រហ័ស ដែលអាចឱ្យពួកគេបង់ពន្ធបានកាន់តែច្រើនសម្រាប់ជាចំណូលរដ្ឋ ។

**ប្រភព : Waglé ២00៣ ។**

ទោះជាបែបនេះក្តី អាស៊ីនៅមានការងារជាច្រើនដែលត្រូវធ្វើដើម្បីបង្ហាញអំពីករណីរបស់ខ្លួន។ នៅក្នុងការចរចាប្រតិភូពីប្រទេសអាស៊ីនៅក្នុងកិច្ចប្រជុំទីក្រុងហ្សឺណែវ បានជ្រើសយកយុទ្ធសាស្ត្រចរចាសម្រាប់រយៈពេលខ្លី ជាងការរក្សាទុកជំហររបស់ខ្លួនជាមួយភាពរឹងមាំខាងការស្រាវជ្រាវ និងព័ត៌មាន។ ជាលទ្ធផល គុណសម្បត្តិពីធម្មជាតិរបស់ GI ត្រូវចុះខ្សោយ។ សមាគមន៍ផលិតករខ្លះ ដូចជា សមាគមន៍សូត្រថៃ និងបណ្តាញអន្តរជាតិថ្មី ដូចជា ORIGIN កំពុងធ្វើការឈានទៅប្រមូលការពិតនិងព័ត៌មានអំពីផលិតផលខ្លះៗ។ ប៉ុន្តែ ក្រសួងរបស់រដ្ឋាភិបាលគួរតែទទួលខុសត្រូវធ្វើការស្រាវជ្រាវ ដោយប្រមូលព័ត៌មានអំពីបរិមាណនិងតម្លៃនៅលើទីផ្សារ ចំនួនកម្មករដែលត្រូវបានជួលឧស្សាហកម្មជាសាខានៅតាមជនបទ ការខាតបង់ ជាក់ស្តែងទាក់ទងនឹងចំនួនការងារ និងប្រាក់ចំណូលតាមរយៈកង្វះកិច្ចការពារ និងសក្តានុពលសម្រាប់ការវិនិយោគ និងកំណើនទេសចរណ៍។

*តំបន់នេះនាំចេញផលត្រី ច្រើនជាងមួយភាគបីនៃការនាំចេញត្រី និងផលិតផលត្រីលើពិភពលោក ដែលត្រូវជា ៧ លានតោន ក្នុងមួយឆ្នាំ។ តំបន់នេះគឺជាជម្រកសម្រាប់ ៨៥% នៃចំនួនអ្នកនេសាទ និង ៩៥% នៃអ្នកចិញ្ចឹមត្រីសរុបលើពិភពលោក*

## ជលផល និង ការអភិវឌ្ឍមនុស្ស

ត្រីបានក្លាយជាមុខទំនិញដែលមានការដោះដូរយ៉ាងច្រើន។ មានត្រីច្រើនជាង ៨០០ប្រភេទ ត្រូវបានធ្វើពាណិជ្ជកម្មជាអន្តរជាតិយ៉ាងច្រើនបែបទៅតាមទម្រង់ សណ្ឋាន យីហោ និងការរៀបចំខុសៗគ្នា។ គិតជាទម្ងន់ប្រមាណ ៣៨% នៃផលិតផលជលផលសរុប បានចូលទៅក្នុងពាណិជ្ជកម្មអន្តរជាតិដោយមានតម្លៃជិត ៦០.០០០លានដុល្លារ ក្រោមភាពជាត្រី និងផលិតផលត្រី។

ត្រីមានសារៈសំខាន់ដោយឡែកសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ សមាមាត្រផលត្រីពីប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងការនាំចេញទៅលើពិភពលោកមាន ៣៨% នៅឆ្នាំ ២០០១។[៣៤] អត្រាដូចគ្នានេះសម្រាប់ឆ្នាំ ២០០០ មានទាបជាង ៥០% តែបន្តិចបន្តួចតែប៉ុណ្ណោះ។ ដូច្នេះ ត្រីគឺជាប្រភពដ៏មានតម្លៃ ក្នុងការរករូបិយបណ្ណបរទេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយមានចំណូលសុទ្ធទទួលបានប្រមាណ ១៧.០០០ លានដុល្លារ ច្រើនជាងបរិមាណសរុបចូលគ្នា បានពីការនាំចេញតែ ស្រូវ និងកាហ្វេ។[៣៥] ក្នុងចំណោមតួលេខនេះ ពាណិជ្ជកម្មនាំចេញសុទ្ធនៃអាហារសមុទ្រក្នុងរវាងឆ្នាំ ១៩៩០ និង ២០០០ បានកើនឡើងពី ១០.០០០លាន មក ១៨.០០០លានដុល្លារ ដែលជាកំណើនដាច់ខាត ៤៥% ដោយភាគច្រើនបានពីកំណើននៃវារីវប្បកម្ម។

តំបន់អាស៊ីអាចទទួលផលច្រើន តាមរយៈការលើកកម្ពស់ពាណិជ្ជកម្មកសិផលប្រកបដោយសមធម៌ជាទូទៅ ពិសេសចំពោះផលត្រី។ តំបន់នេះនាំចេញផលត្រីច្រើនជាងមួយភាគបីនៃការនាំចេញត្រី និងផលិតផលត្រីលើពិភពលោក ដែលត្រូវជា ៧ លានតោនក្នុងមួយឆ្នាំ។[៣៦] ឥឡូវនេះ ប្រទេសចិន គឺជាអ្នកនាំចេញត្រីច្រើនជាងគេលើពិភពលោក ចំណែកជប៉ុនគឺជាអ្នកនាំចូលធំជាងគេលើពិភពលោក ប៉ុន្តែ ពាណិជ្ជកម្មត្រីមានសារៈសំខាន់នៅទូទាំងតំបន់នេះ។

- *វៀតណាម* : ផលនេសាទតំណាងឱ្យ ៥% នៃ GDP ហើយ ៤០% នៃផលិតផលត្រីសរុបត្រូវបាននាំចេញ ដោយរកចំណូលបាន ២.១០០ លានដុល្លារ នៅក្នុងឆ្នាំ ២០០២ ច្រើនជាងការនាំចេញកសិផល ដូចជាស្រូវ និង កៅស៊ូ នឹងខ្ពស់បន្ទាប់ពីប្រេងឆៅ និងសម្លៀកបំពាក់។
- *ឥណ្ឌា* : ត្រីគឺជាផលនាំចេញធំជាងគេទីបីបន្ទាប់ពីវាយនភណ្ឌ និងកប្បាស។ ឥណ្ឌានាំចេញ ២៥% នៃផលិតផលត្រីសមុទ្រ។ នៅឆ្នាំ ២០០២-២០០៣ ប្រាក់ចំណូលរបស់ឥណ្ឌា បាន

ពីការនាំចេញអាហារសមុទ្រមាន ១.៤០០ លានដុល្លារ។

- *ថៃ* : ចំណូលពីផលនេសាទមាន ៤% នៃ GDP ហើយការនាំចេញរបស់ប្រទេសថៃមានច្រើនជាងបីភាគបួននៃផលិតផលសរុបរបស់ប្រទេសនេះ។

ប៉ុន្តែ ផលផលអាចកាន់តែសំខាន់ទៅទៀតសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍តូចៗ ដូចជាកម្ពុជា ដែលផលត្រីមានរហូតដល់ ៤% នៃ GDP និងជាពិសេស បណ្តារដ្ឋកំពុងអភិវឌ្ឍន៍នៅលើកោះតូចៗ ដូចជាហ្វីជី និងម៉ាល់ឌីវ ដែលរួមចំណែករហូតដល់ ៩% នៃ GDP។

## ចំនួនការងារនៅក្នុងវិស័យផលផល

ការនេសាទទាំងសម្រាប់ទីផ្សារក្នុងមូលដ្ឋាន និងសម្រាប់ការធ្វើពាណិជ្ជកម្មនាំចេញ ត្រូវការមនុស្សជាច្រើនលាននាក់។ តាមពិត តំបន់អាស៊ី-ប៉ាស៊ីហ្វិកគឺជាជម្រកសម្រាប់ ៨៥% នៃចំនួនអ្នកនេសាទ និង ៩៥% នៃអ្នកចិញ្ចឹមត្រីសរុបលើពិភពលោក។ ទោះផលនេសាទសមុទ្រគឺជាផ្នែកដែលប្រើប្រាស់កម្មករច្រើនជាងគេក្តី វារីវប្បកម្មក៏កំពុងតែរីកចម្រើនទៅក្នុងបណ្តាប្រទេសផលិតត្រីចម្បងៗផងដែរ។ តាមធម្មតា ការនេសាទសមុទ្រប្រើប្រាស់កម្មករជាបុរស ប៉ុន្តែវារីវប្បកម្ម ការកែច្នៃ និង ការលក់ត្រីច្រើនប្រើប្រាស់កម្លាំងពលករជាស្ត្រី។

- *វៀតណាម* : មានមនុស្សប្រមាណ ៣ លាននាក់ធ្វើការនៅក្នុងវិស័យនេសាទដោយផ្ទាល់ ហើយមានផែនការ ដើម្បីអភិវឌ្ឍវារីវប្បកម្មផងដែរ ដើម្បីស្រូបយកកម្លាំងពលករ ២ លាននាក់បន្ថែមទៀតនៅឆ្នាំ ២០១០។[៣៧]
- *ឥណ្ឌូណេស៊ី* : មានអ្នកនេសាទច្រើនជាង ២ លាននាក់ ចំនួនពាក់កណ្តាលធ្វើការពេញម៉ោង និងពាក់កណ្តាលទៀតមិនពេញម៉ោង និងមានអ្នកចិញ្ចឹមត្រីចំនួន ២ លាននាក់ផងដែរ។
- *ឥណ្ឌា* : មានអ្នកនេសាទពេញម៉ោង ៧២៥.០០០ នាក់ និងអ្នកនេសាទមិនពេញម៉ោងក្នុងចំនួនដូចគ្នានេះ។ លើសពីនេះ មានមនុស្ស ១ លាននាក់ ភាគច្រើនជាស្ត្រី ពាក់ព័ន្ធក្នុងសកម្មភាពមុននិងក្រោយការនេសាទ។
- *ថៃ*: មានកម្មករនេសាទច្រើនជាង ២៥០.០០០ នាក់។ ប្រមាណមួយភាគបីគឺជាកម្មករក្នុងវិស័យនេសាទទ្រង់ទ្រាយធំ មួយភាគបីផ្សេងទៀតជាម្ចាស់និងធ្វើការនៅក្នុងប្រតិបត្តិការទ្រង់ទ្រាយធំនិងតូច ហើយភាគច្រើននៃអ្នកនៅសល់ក្រៅពីនេះជាវារីវប្បករ។

អ្នកនេសាទមានស្ថានភាពនឹងនជាងកសិករ ដោយសារពួកគាត់លក់ផលិតផលយ៉ាងច្រើនរបស់ខ្លួនជាទៀងទាត់ និងជាប្រចាំ។[៣៨] ម្យ៉ាងវិញទៀត ពួកគាត់ក៏ងាយរងគ្រោះផងដែរ ដោយសារកត្តាធម្មជាតិ ដូចជាការប្រែប្រួលនៃផលនេសាទ ធាតុអាកាសមិនល្អ និងការប្រឈមជាមួយព្យុះ ឬដោយសារកត្តាសេដ្ឋកិច្ច ដូចជាការប្រែប្រួលថ្លៃនៅលើទីផ្សារ លទ្ធភាពប្រើប្រាស់ទីផ្សារ។ ភាពងាយរងគ្រោះនេះបង្ហាញយ៉ាងច្បាស់ ដោយព្យុះសមុទ្រនៅមហាសមុទ្រឥណ្ឌាក្នុងឆ្នាំ ២០០៤ ដែលបង្កការខូចខាតធ្ងន់ធ្ងរដល់ការចិញ្ចឹមជីវិតរបស់អ្នកនេសាទនៅឥណ្ឌូណេស៊ី ឥណ្ឌា និង ស្រីលង្កា។

ប្រាក់ចំណូលពីការនេសាទក៏ត្រូវបានបែងចែកដោយ

*សហគមន៍អ្នកនេសាទភាគច្រើន មានប្រាក់ចំណូលទាបរួចទៅហើយ ប៉ុន្តែស្ថានភាពរបស់ពួកគាត់អាចកាន់តែអាក្រក់បន្ថែមទៀត នៅពេលដែលផលស្តុកថយចុះ*

សមធម៌ជាងវិស័យផ្សេងទៀតផងដែរ។ ឧទាហរណ៍ នៅក្នុងការនេសាទ ប្រាក់ចំណូលត្រូវបានបែងចែករវាងម្ចាស់ទូក ម្ចាស់បរិក្ខារនេសាទ និងកម្មករ។ អ្នកនេសាទដែលធ្វើការសម្រាប់ទីផ្សារនាំចេញ ក៏អាចរកប្រាក់បានច្រើនជាងអ្នកដែលធ្វើការសម្រាប់ទីផ្សារក្នុងស្រុកផងដែរ។ ប្រភេទត្រីនាំចេញលក់ថ្លៃជាងប្រភេទមិននាំចេញ ហើយកម្មករដែលធ្វើការនៅលើទូកនេសាទ ដែលផ្តោតលើការនេសាទសម្រាប់នាំចេញ បានទទួលបរិមាណត្រីច្រើនជាងការនេសាទប្រភេទត្រីមិនមែនសម្រាប់នាំចេញផងដែរ។ ម៉្យាងវិញទៀត ការនេសាទ និងចិញ្ចឹមប្រភេទត្រីដែលមានតម្លៃខ្ពស់ក៏ជាទូទៅ ត្រូវចំណាយច្រើនជាងផងដែរ។

ទោះជាបែបនេះក្តី សហគមន៍អ្នកនេសាទជាច្រើននៅតែក្រដដែល។ អ្នកនេសាទពេញម៉ោង និងមិនពេញម៉ោងជាច្រើននៅក្នុងវិស័យនេសាទធុនតូច និងសិប្បកម្ម ពឹងផ្អែកទាំងស្រុងលើការនេសាទសម្រាប់ផ្គត់ផ្គង់គ្រួសារ ហើយអ្នកទាំងនោះជិត ៦ លាននាក់ ក្នុងនោះច្រើនជាង ៨០% រស់នៅអាស៊ី ត្រូវបានគេជឿថាអាចរកចំណូលបានតិចជាង ១ដុល្លារក្នុងមួយថ្ងៃ។[៤០] ក្នុងចំណោមក្រុមមនុស្សដែលមានប្រាក់ចំណូលទាបប្រមាណ ១៧ លាននាក់ ជាអ្នកធ្វើការក្នុងផ្នែកវារីវប្បកម្ម និងសកម្មភាពពាក់ព័ន្ធដទៃទៀត (ធ្វើទូក ចាក់មង លក់ និងកែច្នៃផលនេសាទ) ច្រើនជាង ១៤ លាននាក់ ត្រូវបានរកឃើញថាមានរស់នៅអាស៊ី។ នៅទូទាំងពិភពលោក ប្រជាជនដែលមានប្រាក់ចំណូលទាបប្រមាណ ២៣ លាននាក់ ធ្វើការនៅក្នុងវិស័យជលផល ក្នុងនោះ ១៩ លាននាក់ មកពីអាស៊ី។

ជាលទ្ធផល សហគមន៍អ្នកនេសាទអាចមានការអភិវឌ្ឍមនុស្សកម្រិតទាបជាង។ ឧទាហរណ៍ នៅក្នុងរដ្ឋតាមីលណាឌូ នៃប្រទេសឥណ្ឌា សហគមន៍អ្នកនេសាទមានអត្រាចេះអក្សរ ៦៥% ធៀបនឹងអត្រាមធ្យម ៧៤% នៅក្នុងរដ្ឋនេះទាំងមូល។ អ្នកនេសាទជាច្រើនរស់នៅក្នុងលក្ខខណ្ឌនៃជម្រកតោកយ៉ាក។ កំណើនចំនួនប្រជាជនក៏មានខ្ពស់ផងដែរនៅទីនេះធៀបនឹងកន្លែងដទៃទៀត។

## និរន្តរភាព

សហគមន៍អ្នកនេសាទភាគច្រើន មានប្រាក់ចំណូលទាបរួចទៅហើយ ប៉ុន្តែស្ថានភាពរបស់ពួកគាត់អាចកាន់តែអាក្រក់បន្ថែមទៀត នៅពេលដែលផលស្តុកថយចុះ។ ការប្រកួតប្រជែងដ៏ខ្លាំងក្លានៅក្នុងដែននេសាទ ដែលមានលក្ខណៈបើកចំហ នាំទៅរកការនេសាទច្រើនហួសកម្រិតនូវប្រភេទត្រីសំខាន់ៗមួយចំនួនសម្រាប់ការធ្វើជំនួញ។ ឧស្សាហូបនីយកម្មនៅក្នុងតំបន់ឆ្នេរដោយគ្មានការត្រួតត្រាក៏នាំឱ្យមានកំណើនបញ្ហាបំពុលនៅក្នុងតំបន់ឆ្នេរផងដែរ ដែលបានសម្លាប់ត្រី និងគំរាមកំហែងការចិញ្ចឹមជីវិតរបស់សហគមន៍អ្នកនេសាទនៅក្នុងប្រទេសជាច្រើននៅអាស៊ី រួមទាំង ឥណ្ឌា ចិន និងថៃ។ នៅកន្លែងផ្សេងទៀត មានករណីជោគជ័យមួយចំនួន ដូចជានៅម៉ាល់ឌីវ ដែលបានដាក់ឱ្យប្រើប្រាស់វិធីនេសាទ និងបច្ចេកវិទ្យានេសាទដែលមិនបំផ្លាញបរិស្ថាន ប៉ុន្តែនៅពុំទាន់បានពង្រីកវិធានការនេះនៅឡើយទេ។ ត្រីពីប្រទេសម៉ាល់ឌីវនៅក្នុងទីផ្សារអន្តរជាតិបានមកពីប្រភពដែលមាននិរន្តរភាព។

អាចមានការគិតថា វារីវប្បកម្មមាននិរន្តរភាពជាង។ ប៉ុន្តែតាមពិត អ្វីដែលទំនងជាពិតគឺផ្ទុយមកវិញទេ។ ការកើនឡើងនូវវារីវប្បកម្មបង្គារនៅក្នុងកន្លែងជាច្រើននៃតំបន់នេះ មិនត្រឹមតែធ្វើឱ្យខូចខាតបរិស្ថានជាដំណាំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានឥទ្ធិពលទៅលើការនេសាទសមុទ្រថែមទៀតផង។ មួយចំណែកនៃការខូចខាតនេះគឺ ដោយសារបរិមាណបង្គារចិញ្ចឹមដែលលក់នៅលើទីផ្សារអន្តរជាតិ បានធ្លាក់ថ្លៃធៀបនឹងបង្គានេសាទបានពីធម្មជាតិ ជាការបង្ខំឱ្យអ្នកអូសបង្គារជាច្រើន

ប្តូរទៅប្រើប្រាស់អួនអូសទឹកជ្រៅដែលបើកមាត់ធំនៅភាគខាងក្រោម និងដែលអាចនេសាទត្រីគ្រប់ប្រភេទទាំងអស់។ ការធ្វើបែបនេះ ធ្វើឱ្យអន្តរាយដល់មុខរបររបស់អ្នកនេសាទដែលមិនប្រើអួនអូស។ លើសពីនេះ ការចាប់កូនបង្គាពីក្នុងធម្មជាតិប្រមូលបានមិនត្រឹមតែកូនបង្គាប៉ុណ្ណោះទេ ថែមទាំងកូនត្រីសមុទ្រផ្សេងទៀតផងដែរ ជាហេតុនាំឱ្យមានការកាត់បន្ថយជាបន្ថែមនូវផលស្តុកត្រីក្នុងធម្មជាតិ។

## ផលប៉ះពាល់នៃវិធានការពន្ធ

វិស័យនេសាទនៅអាស៊ីក៏ប្រឈមនឹងបញ្ហាប្រើប្រាស់ទីផ្សារនៅក្នុងប្រទេសជឿនលឿនផងដែរ។ នៅពេលមើលមួយភ្លែត របាំងនេះមិនទំនងជាធ្ងន់ធ្ងរនោះទេ។ EU ជប៉ុន និង US ពង្រីកជម្រើសនៃការយកពន្ធនៅក្រោមប្រព័ន្ធអនុគ្រោះទូទៅ (GSP)។ សម្រាប់ត្រីពុំទាន់កែច្នៃ ត្រីបង្កក វង្កសត្វ និងសិប្បិសត្វ ប្រទេសជឿនលឿនភាគច្រើនអនុវត្តអត្រាពន្ធទាបជាបង្គួរ។ ប្រទេសជប៉ុនដែលជាទីផ្សារត្រី និងផលិតផលត្រីធំជាងគេនៅលើពិភពលោក មានអត្រាពន្ធប្រមាណ ៤%។ អាមេរិកមានអត្រាពន្ធកំណត់ ១% សម្រាប់ការនាំចូលត្រី។ ម៉្យាងវិញទៀត សហភាពអឺរ៉ុបអនុវត្តពន្ធលើផលិតផលបង្ការបវមពី ១២% ទៅ ១៨% និងមានអត្រាពន្ធមធ្យម ១០%។

ទោះជាយ៉ាងណាក៏ដោយអត្រាពន្ធមានកម្រិតខ្ពស់ជាងនេះខ្លាំងណាស់សម្រាប់ត្រីកែច្នៃរួច និងផលិតផលត្រី។ ឧទាហរណ៍ ជប៉ុនអនុវត្តអត្រាពន្ធ ៣.៥% លើត្រីទូណាស្រស់/ក្លាសេ្ស/បង្កក ប៉ុន្តែសម្រាប់ត្រីទូណាកែច្នៃរួច អត្រានេះមាន ៩.៦%។ ប្រទេសជឿនលឿនបានអនុវត្តកូតា ដោយមានអត្រាពន្ធខ្ពស់សម្រាប់បរិមាណផលិតផលលើសពីកូតា។ ឧទាហរណ៍ អាមេរិកអនុវត្តអត្រា ៦% លើត្រីទូណាកែច្នៃពីប្រទេសថៃនៅក្នុងកូតា ប៉ុន្តែរហូតដល់ ១២.៥% សម្រាប់បរិមាណហួសកូតា។

សម្រាប់សហភាពអឺរ៉ុបអត្រាពន្ធលើត្រីទូណាកែច្នៃរួចអាចដល់ ២៥%។

សូម្បីតែសម្រាប់ត្រីពុំទាន់កែច្នៃ អាចមានឧបសគ្គបន្ថែមទៀត។ សហភាពអឺរ៉ុបរើសអើងប្រឆាំងនឹងការនាំចូលត្រីនិងផលិតផលត្រីពីប្រទេសដែលមិនគោរពកាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងបរិស្ថានពហុភាគី ដោយអាចមានបាតុកម្មប្រឆាំងនឹងការមកដល់ដ៏ច្រើននៃផលិតផលណាមួយ។ ឧទាហរណ៍ រវាងឆ្នាំ ១៩៩៩ និង ២០០២ ប្រទេសវៀតណាមបង្កើនការនាំចេញហ្វីឡេបង្កកនៃត្រី Catfish ទៅស.រ.អា ពី ៥ លាន ទៅ ៣៤ លានដោន។ កសិករចិញ្ចឹមត្រីប្រភេទនេះនៅស.រ.អា ជាក្រុមមួយដែលតំណាងឱ្យអ្នកចិញ្ចឹមនិងកែច្នៃត្រីប្រភេទនេះ បានធ្វើការប្តឹងចោទប្រកាន់ពីការនាំចូលសម្រាប់ចាក់ចោល ហើយនៅក្នុងឆ្នាំ ២០០៣ គណៈកម្មការពាណិជ្ជកម្មអន្តរជាតិរបស់អាមេរិក សម្រេចថា ការនាំចេញរបស់វៀតណាមធ្វើឱ្យខូចខាតឧស្សាហកម្មត្រីប្រភេទនេះនៅស.រ.អា និងបានកំណត់ឱ្យយកពន្ធ ៣៧% ទៅ ៦៤%។ ជាលទ្ធផល អ្នកនេសាទនៅវៀតណាមបានរងគ្រោះដោយសារការធ្លាក់ថ្លៃ និងការថយចុះយ៉ាងខ្លាំងនូវប្រាក់ចំណូល។

បន្ថែមលើរបាំងពន្ធ ប្រទេសជឿនលឿនក៏អាចដាក់កំហិតលើការនាំចូល តាមរយៈរបាំងមិនមែនពន្ធផងដែរ។ របាំងទាំងនេះ រួមបញ្ចូលស្តង់ដារសុវត្ថិភាពអាហារ វិធានការបរិស្ថានដូចជាការដាក់ស្លាកសញ្ញាបរិស្ថាន និងកម្មវិធីចេញវិញ្ញាបនប័ត្របញ្ជាក់ និងតម្រូវឱ្យគោរពតាមកិច្ចព្រមព្រៀងបរិស្ថានពហុភាគី។

## ស្តង់ដារសុវត្ថិភាពអាហារ

ជាលទ្ធផលនៃសកលភាវូបនីយកម្មពាណិជ្ជកម្មផលនេសាទ និងកំណើនតម្រូវការត្រីប្រកបដោយគុណភាពខ្ពស់

*អ្នកកែច្នៃ ដែលនាំចេញជាពិសេសទៅទីផ្សារសហភាពអឺរ៉ុប និង ស.រ.អា ត្រូវតែគោរពតាមបទបញ្ជានាំចូលតឹងរ៉ឹង ដែលពួកគេមិនអាចធ្វើតាមបាន ហើយការពុំគោរពនឹងត្រូវប្រឈមចំពោះការបដិសេធទំនិញ*

និងសុត្ថិភាពក្នុងចំណោមអ្នកប្រើប្រាស់ ឥឡូវប្រទេសជឿនលឿនមាននីតិវិធីដែលមានលក្ខណៈប្រព័ន្ធជាងមុន ដែលធានាសុវត្ថិភាពស្បៀង ដោយប្រើប្រាស់ប្រព័ន្ធវិភាគគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យចាំបាច់ (HACCP)។[៦១] អ្នកកែច្នៃដែលនាំចេញជាពិសេសទៅទីផ្សារសហភាពអឺរ៉ុប និង ស.រ.អា ត្រូវតែគោរពតាមបទបញ្ជានាំចូលតឹងរ៉ឹងដែលពួកគេមិនអាចធ្វើតាមបាន ហើយការពុំគោរពនឹងត្រូវប្រឈមចំពោះការបដិសេធទំនិញ (ប្រអប់ ៣.៣)។ ស្តង់ដារទាំងនេះ ប្រែប្រួលពីទីផ្សារមួយទៅទីផ្សារមួយផ្សេងទៀត។ ឧទាហរណ៍ ស.រ.អា តម្រូវឱ្យកម្រិតអ៊ីស្តាមីននៅក្នុងកំប៉ុងត្រី សាឌីន កាម៉ុង និង anchovy មិនឱ្យលើសពី ៥០ភាគលាន (ppm) ចំណែកសហភាពអឺរ៉ុបជាទូទៅ អនុញ្ញាតឱ្យមានរហូតដល់ ១៥០ ppm នៅក្នុងត្រីកំប៉ុង។

ឥឡូវនេះ ការរីកចម្រើននៃបច្ចេកវិទ្យាក្នុងការវិភាគអាហារសមុទ្រ បានឈានដល់អាចរកឃើញសំណល់ថ្នាំកម្ចាត់សត្វចង្រៃ និងឱសថ ដល់កម្រិតភាគពាន់លាន (ppb) ហើយក្នុងករណីខ្លះទៀតរហូតដល់ភាគលានលាន (ppt)។ ឧទាហរណ៍ សហភាពអឺរ៉ុបប្រើប្រាស់វិធីសាស្ត្រក្រូម៉ាតូក្រាហ្វីរាវ ដែលមានអំណាចខ្លាំង ដែលអាចរកឃើញអង់ទីប្យូទិក ដូចជា ក្លរ៉ាំហ្វេនីកុល ក្នុងកម្រិត ០.៣ ppb និងនីត្រូហ្វួយរ៉ង់នៅកម្រិត ១ ppb។ នៅកម្រិតនេះ ផលិតផលដែលមាន "សុវត្ថិភាព" អាចក្លាយជា "លែងមានសុវត្ថិភាព"។[៦២] ក្នុងករណីមួយចំនួន សហភាពអឺរ៉ុបបានបដិសេធការនាំចូលបង្គាពីអាស៊ី នៅពេលរកឃើញថាមានអង់ទីប្យូទិកប្រឆាំងរោគមហារីកដែលត្រូវបានហាមឃាត់ ដូចជា នីត្រូហ្វួយរ៉ង់ និងក្លរ៉ាំហ្វេនីកុល ក៏ដូចជាសារធាតុប្រឆាំងបាក់តេរីផ្សេងទៀត ដូចជា អាមីណូគ្លីកូហ្ស៊ីត និងម៉ាក្រូលីត។

ប្រទេសនាំចូលក៏មាននីតិវិធីត្រួតពិនិត្យខុសៗគ្នាផងដែរ។ EU តម្រូវឱ្យត្រីដែលនាំចូលពីអ្នកកែច្នៃបរទេសមានភ្ជាប់ជាមួយវិញ្ញាបនប័ត្រពីស្ថាប័នជាតិ និងរក្សាសិទ្ធិធ្វើអធិការកិច្ចលើដំណើរការតាមផ្លូវច្បាប់ និងមិនទទួលស្គាល់ស្ថាប័នជាតិរហូតដល់មានចំណាត់វិធានការជួសជុល។ ក្នុងករណីស.រ.អា អ្នកនាំចូលនីមួយៗត្រូវតែបង្ហាញអំពីសមត្ថភាពផលិតអាហារសមុទ្រទៅតាមបទប្បញ្ញត្តិរបស់ស.រ.អា។

ការគោរពតាមបទប្បញ្ញត្តិទាំងនេះ និងតាមលក្ខខណ្ឌរបស់អង្គការស្តង់ដារអន្តរជាតិ ជាពិសេស ISO ៩០០២ សម្រាប់

---

ប្រអប់ ៣.៣

### ស្តង់ដារសុវត្ថិភាពចំណីអាហារ និងការនេសាទទ្រង់ទ្រាយតូច

តាមទស្សនៈរបស់អ្នកនេសាទខ្នាតតូច ទន្ទឹមនឹងថ្លៃចំណាយ បញ្ហាមួយក្នុងចំណោមបញ្ហាចម្បងនានាក្នុងការអនុម័តផែនការ HACCP គឺការលំបាកក្នុងការអនុវត្តផែនការនោះ នៅតាមទីកន្លែងដែលធ្វើនេសាទត្រីជាក់ស្តែង ជាពិសេស សម្រាប់ក្រុមអ្នកនេសាទដែលលើកត្រីឡើងគោកនៅតាមឆ្នេរ ដូចជា kattumarams និងកាណូតនៅក្នុងប្រទេសនានា ដូចជាឥណ្ឌា។ យោងតាមស្តង់ដារ EU និង US ត្រីត្រូវតែរក្សាទុកនៅក្នុងទឹកកក ឬក្នុងប្រអប់បង្កកនៅក្រោយការនេសាទបានភ្លាម។ ការរក្សាទុកត្រីនៅក្នុងធុងដែលមានទឹកកក អាចជាការលំបាកសម្រាប់ទូកនេសាទតាមបែបបូរាណ ដូចជា kattumarams ដែលធ្វើអំពីឈើចងភ្ជាប់គ្នា។ ប៉ុន្តែទូក kattumarams ជាច្រើនដែលប្រើប្រាស់សន្ទូចរាយ និងមងពន្លិច ក៏ធ្វើការនេសាទត្រីសម្រាប់ទីផ្សារនាំចេញដែរ។ ការអនុវត្តយ៉ាងតឹងរ៉ឹងនូវផែនការ HACCP អាចជាការបង្ខំឱ្យអ្នកទាំងនោះបោះបង់ចោលទីផ្សារនាំចេញ ។

ស្តង់ដារលើការចាត់ថ្នែងត្រីសម្រាប់ទីផ្សារនាំចេញជាច្រើនទាមទារកុំឱ្យត្រីជាប់ខ្សាច់។ ដោយសារភូមិនេសាទជាច្រើនដែលធ្វើការប្រមូលផលត្រីបង្គា និងមឹកសម្រាប់ទីផ្សារនាំចេញ មានតែឆ្នេរសម្រាប់ការផ្ទេរផលនេសាទឡើងគោក ដូច្នេះវាអាចជាការលំបាកសម្រាប់ពួកគាត់ក្នុងការគោរពតាមផែនការ HACCP លើកលែងតែពួកគាត់វិនិយោគលើធុងទឹកកក និងរក្សាទុកផលនេសាទឱ្យមានអនាម័យ។

រោងចក្រកែច្នៃផលត្រី ធ្វើឱ្យថ្លៃចំណាយកើនឡើងយ៉ាងច្រើនជាបន្ទុកសម្រាប់អ្នកនាំចេញ ដែលត្រូវបង់ថ្លៃលើទីប្រឹក្សា បុគ្គលិករក្សាទុកកំណត់ត្រា និងការបណ្តុះបណ្តាល។ តាមថ្លៃឆ្នាំ ២០០២ ឧទាហរណ៍ប្រព័ន្ធវិធានការ HPLC ត្រូវចំណាយប្រមាណ ២២០.០០០ដុល្លារក្នុងមួយគ្រឿង។ សូម្បីតែគោរពតាម HPLC ក៏នៅតែលំបាកផងដែរសម្រាប់រកស៊ីតូចៗ (ប្រអប់ ៣.៣)។ កំនើនថ្លៃដើម្បីទទួលវិញ្ញាបនប័ត្រ ត្រូវបានឆ្លុះបញ្ចាំងក្នុងការធ្លាក់ចុះនូវផលចំណេញដូចដែលមានឆ្លុះបញ្ចាំងនៅក្នុង "ភាពជាក់ស្តែងនៃតម្លៃក្នុងមួយឯកត្តា" ឧទាហរណ៍សម្រាប់បង្គាអត្រានេះកើនឡើងពី ១ ដុល្លារ នៅឆ្នាំ ១៩៦១ ដល់ ៩ ដុល្លារនៅឆ្នាំ ២០០១ ប៉ុន្តែនៅឆ្នាំ ២០០២ វាបានធ្លាក់ចុះមកត្រឹម ៧ ដុល្លារវិញ។

ស្តង់ដារខ្ពស់ដែលជាត្រូវការសម្រាប់ទីផ្សារនាំចេញក៏មានឥទ្ធិពលទៅលើទីផ្សារក្នុងស្រុកផងដែរ។ ភាគច្រើននៃប្រទេសនាំចេញ ពុំមានស្តង់ដារសម្រាប់សុវត្ថិភាពអាហារទេ។ ឧទាហរណ៍ ឥណ្ឌាពុំមានស្តង់ដារគុណភាពអំពីអាហារសមុទ្រសម្រាប់អ្នកបរិភោគនៅក្នុងប្រទេសរបស់ខ្លួនទេ។ តាមកិច្ចព្រមព្រៀង WTO ស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ បណ្តាសមាជិកត្រូវបង្កើតបទប្បញ្ញត្តិ និងដំណើរការច្បាប់ ដែលមានលក្ខណៈសមមូលរវាងប្រទេសនាំចូល និងប្រទេសនាំចេញ។ សម្រាប់ប្រទេសជឿនលឿនដែលជាអ្នកនាំចូល ប្រការនេះមិនចោទជាបញ្ហាទេ ដោយសារជាធម្មតាលក្ខខណ្ឌសម្រាប់ការនាំចូល គ្រាន់តែការពង្រីកបន្ថែមនូវស្តង់ដារក្នុងស្រុករបស់គេតែប៉ុណ្ណោះ។ ប៉ុន្តែ ប្រទេសកំពុងអភិវឌ្ឍន៍ចាំបាច់ត្រូវដាក់ឱ្យប្រើប្រាស់ប្រព័ន្ធថ្មីនេះ។

ការបង្កើតប្រព័ន្ធថ្មីគឺជាការទទួលខុសត្រូវរបស់ជាតិ។ ប្រទេសក្រីក្រជាង ក៏អាចពឹងផ្អែកលើការគាំទ្រពីប្រទេសជឿនលឿនផងដែរ។ ការប្តេជ្ញានេះមានបង្កប់នៅក្នុងចំណុចទី ៨ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលមានគោលដៅកសាងភាពជាដៃគូនៅលើពិភពលោក សម្រាប់ការអភិវឌ្ឍ និងជាពិសេសជួយកសាងសមត្ថភាពពាណិជ្ជកម្មឆ្ពោះទៅការប្រើប្រាស់ទីផ្សារឱ្យបានច្រើនជាងមុន ជាពិសេសសម្រាប់ LDCs។

## ការដាក់ស្លាកបរិស្ថាន

នៅក្នុងកិច្ចប្រឹងប្រែងដើម្បីធានាថា ត្រីនិងផលិតផលត្រីមានប្រភពពីការនេសាទដោយនិរន្តរភាព ប្រទេសមួយចំនួនកំពុងតែលើកទឹកចិត្ត ឬតម្រូវឱ្យមានប្រព័ន្ធដាក់ស្លាកបរិស្ថាន។ ឧទាហរណ៍ ជប៉ុនប្រើប្រាស់ស្លាកបរិស្ថានដើម្បីដាក់កំហិតលើការនាំចូលត្រី ទូណា សម្រាប់ទីផ្សារអាហារប្រណិតសាស៊ីមី។ ប្រការនេះមានគោលដៅទប់ស្កាត់ការនាំចូលដែលបានពីទូកនេសាទខុសច្បាប់ មិនបានរាយការណ៍ ឬដែលគ្មានការដាក់កំហិត។ ស.រ.អា និងសហភាពអឺរ៉ុប ក៏គាំទ្រការដាក់ស្លាកបរិស្ថាន និងការចេញវិញ្ញាបនប័ត្របញ្ជាក់នេះផងដែរ។ ប៉ុន្តែនៅពុំទាន់មានកិច្ចព្រមព្រៀងពហុភាគីលើបញ្ហានេះនៅឡើយទេ ហើយនៅពុំទាន់មានការបញ្ជាក់ច្បាស់នៅឡើយទេថា តើប្រព័ន្ធស្លាកសញ្ញាបរិស្ថានបែបនេះ ទាក់ទងកម្រិតណាជាមួយកិច្ចព្រមព្រៀង WTOស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម។

ប្រទេសកំពុងអភិវឌ្ឍន៍កំពុងមានការបារម្ភថា សូម្បីតែតម្រូវការដាក់ស្លាកសញ្ញាបរិស្ថានក៏នៅតែរាប់បញ្ចូលបានត្រឹមតែការនាំចូលពីការនេសាទទ្រង់ទ្រាយតូច និងការនេសាទសិប្បកម្មតែប៉ុណ្ណោះ។ ពួកគេមានការបារម្ភមួយចំនួន :

- *ថ្លៃចំណាយ* : ការដាក់ស្លាកសញ្ញាបរិស្ថាននឹងបន្ថែមការចំណាយរបស់ឧស្សាហកម្មនេសាទដែលពុំមានការធានាថាកំណើនបែបនេះនឹង

អាចទូទាត់បានតាមរយៈកំណើនប្រាក់ចំណូលពីផលិតផលដែលបានបញ្ជាក់នោះទេ។

- *បាត់បង់ស្វ័យភាព* : អ្នកនេសាទសិប្បកម្មទ្រង់ទ្រាយតូចបារម្ភថាពួកគេនឹងបាត់បង់ស្វ័យភាព ប្រសិនបើពួកគេត្រូវគោរពតាមស្តង់ដារដែលបង្កើតឡើង និងដាក់ឱ្យអនុវត្តដោយទីភ្នាក់ងារមកពីក្រៅ ពោលគឺស្តង់ដារដែលអាចបានគិតបញ្ចូលទិដ្ឋភាពជាក់លាក់នៃការនេសាទរបស់ពួកខ្លួន។
- *ស្ថានភាពជាក់ស្តែង* : ការចេញវិញ្ញាបនប័ត្រទំនងជាត្រូវផ្តល់សម្រាប់តែការនេសាទរបស់សហគ្រាសមួយទាំងមូល។ ឧទាហរណ៍ កម្មវិធីស្លាកសញ្ញាបរិស្ថាន "នេសាទជារៀងរហូត" ដែលបានបង្កើតឡើងនៅឆ្នាំ ១៩៩៧ ដោយក្រុមប្រឹក្សាគ្រប់គ្រងសមុទ្រ បានផ្តល់ស្លាកសញ្ញាមិនមែនទៅឱ្យក្រុមហ៊ុនមួយទេ ប៉ុន្តែទៅឱ្យឧស្សាហកម្មទាំងមូល ដូច្នេះទាមទារឱ្យមានកិច្ចសហប្រតិបត្តិការពីគ្រប់អង្គភាពនេសាទរបស់ខ្លួន។ តាមពិត មួយក្នុងចំណោមបញ្ហាចម្បងនៅក្នុងការនេសាទនៅអាស៊ីគឺជម្លោះរវាងអ្នកនេសាទអូសអួនដល់បាតដី និងក្រុមអ្នកនេសាទទ្រង់ទ្រាយតូចដែលនៅនឹងមួយកន្លែងដែលប្រកួតប្រជែងនៅក្នុងកន្លែងតែមួយដើម្បីធនធានតែមួយ។ កិច្ចសហប្រតិបត្តិការនៅទូទាំងវិស័យនេសាទទាំងមូលលំបាកសម្រេចឱ្យបានណាស់។

សូម្បីតែប្រព័ន្ធស្លាកសញ្ញាបរិស្ថានអាច អនុវត្តបាន វាអាចផ្តល់ផលផ្ទុយនឹងអ្វីដែលចង់បាន។ ឧទាហរណ៍ ប្រសិនបើត្រីដែលបានទទួលការបញ្ជាក់ក្រោមប្រព័ន្ធនេះតម្រូវឱ្យលក់ថ្លៃខ្ពស់ជាងមុន ប្រការនេះនាំឱ្យមានការបង្កើនការធ្វើនេសាទត្រីប្រភេទនោះ ជាពិសេសនៅក្នុងតំបន់នេសាទដែលលំបាកដាក់កំហិតទៅលើកិច្ចប្រឹងប្រែងធ្វើនេសាទ។[៤៣] ម្យ៉ាងវិញទៀត លទ្ធផលអាចបានមកតាមទិសដៅផ្ទុយទៅវិញ។ អ្នកនេសាទដែលពុំមានលទ្ធភាពឬពុំមានចេតនាគោរពតាមលក្ខខណ្ឌនៃការនេសាទដែលមានបញ្ជាក់ អាចត្រូវផ្ទេរទៅកន្លែងដែលមិនបញ្ជាក់ ឬដែលមិនអាចបញ្ជាក់បាន ដែលនៅទីនោះពួកគេអាចធ្វើនេសាទហួសកម្រិតនៃផលស្តុកធម្មជាតិ។

ក្នុងការអនុវត្តជាក់ស្តែង ដោយសារភាពទន់ខ្សោយនៃការគ្រប់គ្រងការនេសាទនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ការដាក់ស្លាកសញ្ញាបរិស្ថានស្ថិតនៅលើផ្លូវវែងឆ្ងាយណាស់។ ការនេសាទដែលមានភាពឈ្លាសវៃខ្លះ ដូចជាឧស្សាហកម្មនេសាទត្រីទូណានៅម៉ាល់ឌីវ អាចឆ្លើយតបបាន។ ប៉ុន្តែនៅកន្លែងផ្សេង ការរៀបចំឧស្សាហកម្មបែបនេះសម្រាប់ចេញវិញ្ញាបនប័ត្រនឹងមានភាពស្មុគស្មាញ និងត្រូវចំណាយច្រើន។ ឧទាហរណ៍ អ្នកនេសាទបង្កងសមុទ្រនៅ Caera ប្រទេសប្រេស៊ីល ដែលបានទទួលការគាំទ្រពីមូលនិធិឯកជនមួយបានដាក់ពាក្យសុំសម្រាប់ត្រៀមទទួលការបញ្ជាក់វិញ្ញាបនប័ត្រ។ ប៉ុន្តែការវាយតម្លៃបឋមបង្ហាញថា ការចេញវិញ្ញាបនប័ត្រមិនអាចធ្វើទៅកើតទេនៅក្នុងរយៈពេលខ្លី ដោយសារស្ថានភាពជលផលអាក្រក់រួចទៅហើយ។[៤៤]

សហភាពអឺរ៉ុប ជប៉ុន និងស.រ.អា ពុំទំនងជាតម្រូវឱ្យមានស្លាកសញ្ញាបរិស្ថានទេ ប៉ុន្តែនៅពេលណាមួយ ពួកគេអាចទាមទារឱ្យបង្ហាញភស្តុតាងថា ការនេសាទនោះយ៉ាងហោចណាស់មានផែនការគ្រប់គ្រងដែរ។ ដូច្នេះប្រទេសកំពុងអភិវឌ្ឍនឹងទទួលការណែនាំឱ្យចាប់ផ្តើមរៀបចំស្តង់ដារសម្រាប់ប្រមូល

ផលនេសាទ និងធនធានដោយនិរន្តរភាព ទទឹមនឹងមានស្តង់ដារសម្រាប់សុវត្ថិភាពអាហារ និងលក្ខខណ្ឌរស់នៅប្រសើរជាងមុនសម្រាប់កម្មករនេសាទ។

## កិច្ចព្រមព្រៀងបរិស្ថានពហុភាគី និងជលផល

កិច្ចព្រមព្រៀងបរិស្ថានពហុភាគី (MEAs) មួយចំនួនមានឥទ្ធិពលទៅលើពាណិជ្ជកម្មត្រី។ ឧទាហរណ៍ ច្បាប់ស្តីពីអនុសញ្ញាសមុទ្រឆ្នាំ ១៩៨២ រួមបញ្ចូលវិធានការ "ដើម្បីការពារនិងថែរក្សាប្រព័ន្ធអេកូឡូស៊ីដែលមានដោយកម្រ និងដែលងាយខូចខាត ក៏ដូចជាទីជម្រកសម្រាប់ប្រភេទត្រីដែលបាត់បាត់បង់ទៅហើយ ដែលរងការគំរាមកំហែង ឬដែលជិតផុតពូជ ព្រមទាំងសារពាង្គកាយមានជីវិតដទៃទៀតនៅក្នុងសមុទ្រ" (មាត្រា ១៩៤)។ MEAs ផ្សេងទៀត ដែលមានសក្តានុពលសម្រាប់វិធានការពាណិជ្ជកម្មក្នុងវិស័យជលផល និងកសិកម្មរួមមាន: អនុសញ្ញាតំបន់ដីសើមឆ្នាំ ១៩៧២ ដែលឱ្យឈ្មោះថា អនុសញ្ញារ៉ាមសារ អនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិនូវប្រភេទសត្វ និងរុក្ខជាតិដែលជិតផុតពូជ អនុសញ្ញាឆ្នាំ១៩៨០ ស្តីពីការអភិរក្សធនធានមានជីវិតនៅក្នុងសមុទ្រអង់តាកទិក អនុសញ្ញា ឆ្នាំ១៩៩២ ស្តីពីជីវៈចម្រុះ និងកិច្ចព្រមព្រៀងសហប្រជាជាតិ ឆ្នាំ១៩៩៥ ស្តីពីផលស្តុកត្រីក្នុងធម្មជាតិ។" ឧទាហរណ៍ មួយនៃកិច្ចព្រមព្រៀងបរិស្ថានពហុភាគី ដែលជាឧបសគ្គសម្រាប់អ្នកចិញ្ចឹមបង្គាមានបង្ហាញជូននៅក្នុងប្រអប់ ៣.៤។

កាតព្វកិច្ចទៅអនាគតនៃ MEAs ទំនងជាអាចដើរតួនាទីចម្បងនៅក្នុងការនាំចេញអាហារសមុទ្រ។ ពាណិជ្ជកម្មត្រីបានកើនឡើងយ៉ាងឆាប់រហ័សជាផ្នែកមួយដែលអាចមានជម្លោះ

ប្រអប់ ៣.៤

### CITES: ជម្លោះអំពីបង្គា-អណ្តើក និងកម្មករនេសាទនៅឥណ្ឌា

ជម្លោះលើបង្គា-អណ្តើកនៅឯ WTO រវាង US និងប្រទេសមួយចំនួននៅអាស៊ី គឺជាករណីទីមួយដែលទាក់ទងនឹង MEAS។ អនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីការធ្វើពាណិជ្ជកម្មប្រភេទសត្វ និងរុក្ខជាតិដែលជិតផុតពូជ (CITES) បានចាត់ទុកអណ្តើកសមុទ្រគ្រប់ប្រភេទទាំងអស់ថាកំពុងរងការគំរាមកំហែងឈានទៅផុតពូជ និងហាមឃាត់ការធ្វើពាណិជ្ជកម្មអន្តរជាតិនូវសត្វប្រភេទនេះ។ សត្វអណ្តើកសមុទ្រក៏ត្រូវបានចុះនៅក្នុងបញ្ជីទិន្នន័យក្រហមនៃប្រភេទដែលរងការគំរាមកំហែងរបស់អង្គការសហភាពអភិរក្សពិភពលោក (IUCN) ផងដែរ។

ស.រ.អា នឹងនាំចូលបង្គាតែពីប្រទេសដែលមានកម្មវិធីអភិរក្សសត្វអណ្តើកសមុទ្រ ប្រហាក់ប្រហែលនឹងនៅក្នុង US ដែរ។ នេះមានន័យថា ទូកនេសាទបង្គា ត្រូវតែបំពាក់ឧបករណ៍រំដោះអណ្តើក (TED) ទៅនឹងអួនអូសរបស់ខ្លួន។ ជាការឆ្លើយតប នៅឆ្នាំ២០០១ រដ្ឋអូរីសានៃប្រទេសឥណ្ឌាបានដាក់ TED ជាកាតព្វកិច្ចសម្រាប់គ្រប់ទូកនេសាទអូសអួន នៅ Gahirmatha, Devi និង Rushikuly ហើយបានចែកចាយ TED ចំនួន ៥០០ ក្រោមការជួយឧបត្ថម្ភធនទាំងស្រុង ឱ្យដល់ទូកនេសាទអូសអួន។

ទោះជាយ៉ាងណាក៏ដោយ ម្ចាស់ទូកនេសាទអូសអួនរារែកពុំចង់ប្រើប្រាស់ TED ឡើយ ដោយអះអាងថាផលនេសាទពី ២០% ទៅ ៣០% នឹងត្រូវបាត់បង់តាមច្រកដែលបើកចំហសម្រាប់សត្វអណ្តើក។ លទ្ធភាពមួយផ្សេងទៀតគឺ សត្វអណ្តើក ឬបបែល អាចទាក់ជាប់នឹងមាត់ TED ដែលរារាំងត្រីដទៃទៀតមិនឱ្យចូលទៅក្នុងអួនបាន។ ស្ថានភាពនេះកាន់តែលំបាកជាងនេះទៅទៀត នៅក្នុងការនេសាទត្រីចម្រុះប្រភេទ ដែល TED ត្រូវតែឆ្លើយតបនឹងប្រភេទត្រីដែលមានទំហំខុសគ្នា។

ជីវវិទូខាងសត្វអណ្តើកក៏ពុំឯកភាពអំពីផលប្រយោជន៍នៃ TED ឡើយ។ អ្នកខ្លះនិយាយថាប្រការដែលប្រសើរគួរតែផ្តោតលើ "ក្រុមដែលបន្តពូជ" គឺជាការប្រមូលផ្តុំនៃសត្វពេញវ័យបន្តពូជដែលត្រូវបានរកឃើញស្ទើរតែទាំងអស់ នៅចំងាយប្រមាណ ៥គ.មពីឆ្នេរខ្សាច់។ ពួកគេជឿថាការផ្តោតទៅលើកិច្ចការពារនៅទីនេះនឹងមានប្រសិទ្ធភាពជាង ព្រមទាំងត្រូវចំណាយតិចជាងធៀបនឹងកិច្ចការពារតំបន់ផ្ទៃទឹកធំធេងដែលពុំទំនងជាទីជម្រកសកម្មនៃសត្វអណ្តើកឡើយ។

ជាមួយកាតព្វកិច្ច MEAs និងបទបញ្ជាពាណិជ្ជកម្ម។

## ការឧបត្ថម្ភធនលើវិស័យនេសាទ និង WTO

ទោះជាយ៉ាងណាក៏ដោយ ការវិវត្តភ្លាមៗដែលអាចមានឥទ្ធិពលទៅលើលទ្ធភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការប្រើប្រាស់ទីផ្សារ គឺជាការជជែកវែកញែកជាបន្តបន្ទាប់ស្តីពីការឧបត្ថម្ភធនសម្រាប់វិស័យនេសាទ។ កិច្ចប្រជុំនៃ WTO នៅទីក្រុងដូហា គឺជាលើកដំបូងដែលបានលើកឡើងអំពីការឧបត្ថម្ភធនសម្រាប់វិស័យជលផល និងការប្រើប្រាស់វិធីនេះសម្រាប់ "សម្រេចគោលដៅអភិវឌ្ឍន៍ស្របច្បាប់"។ ការពិភាក្សានេះក៏ពិចារណាផងដែរអំពីការទាមទារស្របច្បាប់របស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលត្រូវចាត់ទុកការឧបត្ថម្ភធនខ្លះៗថា "មិនអាចចាត់ការបាន" រួមទាំងបច្ចេកវិទ្យា ការផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ បង្កើតនិងបង្កើនមុខផលិតផល និងការអនុវត្តវិធីសាស្ត្រផលិតដែលសមស្របខាងផ្នែកបរិស្ថាន។

នេះជាបញ្ហាអាយុជីវិតសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដែលការនេសាទទ្រង់ទ្រាយតូចជាប្រភពសំខាន់សម្រាប់ការចិញ្ចឹមជីវិត។ អ្នកខ្លះបានសំដែងការអល់អែកក្នុងការជជែកនៅក្នុង WTO អំពីការឧបត្ថម្ភធនសម្រាប់វិស័យនេសាទ។ រដ្ឋជាប្រទេសកំពុងអភិវឌ្ឍន៍នៅលើកោះតូចៗ (SIDS) រួមទាំង ហ្វីជី កោះសូឡូម៉ុង ប៉ាពូញូ ហ្គីនេ និងម៉ាល់ឌីវ បានស្នើឱ្យមានការយកចិត្តទុកដាក់ពិសេស និងខុសគ្នានៅក្នុងវិស័យនេសាទសម្រាប់រដ្ឋកំពុងអភិវឌ្ឍន៍នៅតាមតំបន់ឆ្នេរជាទូទៅ និងដោយឡែកសម្រាប់ SIDS។ SIDS ក៏ជាអ្នកដំបូងដែលបានប្រឹងប្រែងឱ្យនិយមន័យទូលាយអំពី "អ្នកនេសាទសិប្បកម្ម" និងបានស្នើថារាល់បទបញ្ជាថ្មីណាមួយអំពីការឧបត្ថម្ភធនសម្រាប់ការនេសាទ គួរតែលើកលែងកម្មវិធីរបស់រដ្ឋាភិបាលសំដៅបង្កើនកម្រិតប្រាក់ចំណូលរបស់អ្នកនេសាទសិប្បកម្ម។

ការលុបចោលនូវការឧបត្ថម្ភធនក្នុងបំណងពង្រឹងសមត្ថភាពនឹងមានឥទ្ធិពលជាចម្បងខាងផ្នែកសង្គមសម្រាប់វិស័យជលផលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងនាំឱ្យមានភាពគ្មានការងារយ៉ាងច្រើននៅក្នុងការនេសាទសមុទ្រ។ ត្រូវខិតខំស្វែងរកវិធីនានានៃការផ្តល់ជម្រើសផ្សេងនៃការងារ ឬមួយនៅក្នុងការនេសាទ ឬវារីវប្បកម្ម ឬនៅក្នុងសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត។ រាល់ការវិនិយោគឆ្ពោះទៅអភិវឌ្ឍន៍ជម្រើសផ្សេងបែបនេះ គួរតែត្រូវបានចាត់ទុកថាជាការឧបត្ថម្ភធនដែលមិនអាចចាត់ការបាន។

## ទិសដៅគោលនយោបាយសម្រាប់ពាណិជ្ជកម្មកសិផល

ប្រទេសកំពុងអភិវឌ្ឍន៍ ប្រឈមនឹងការជ្រើសរើសដ៏ស្មុគស្មាញនៃគោលនយោបាយលើពាណិជ្ជកម្មកសិផល។ ពួកគេត្រូវពិចារណាផលប៉ះពាល់នៃពាណិជ្ជកម្មបែបនេះ ទៅលើក្រុមមនុស្សផ្សេងៗនៅក្នុងចំណោមប្រជាពលរដ្ឋទាំងមូល ហើយពិនិត្យមើលជាពិសេសនូវឥទ្ធិពលទៅលើក្រុមដែលងាយរងគ្រោះជាងគេបំផុត។

ប្រទេសភាគច្រើនចង់បង្កើនជាអតិបរមានូវការនាំចេញ ដើម្បីរកចំណូលជារូបិយបណ្ណបរទេសដែលចាំបាច់សម្រាប់បំពេញការនាំចូលសំខាន់ៗ។ ជម្រើសនោះអាចងាយជាងសម្រាប់ប្រទេសដែលអាចផលិតបានស្បៀងនៅក្នុងស្រុកបានគ្រប់គ្រាន់ ទន្ទឹមនឹងលទ្ធភាពនាំចេញផងដែរ រួមទាំងស្បៀងដើម្បីរកចំណូលជារូបិយប័ណ្ណបរទេស។ ប៉ុន្តែ សូម្បីតែប្រទេសដែលពុំមានដីដែលមានជីជាតិគ្រប់គ្រាន់ ឬធនធានកសិកម្មផ្សេងទៀត ដើម្បីចិញ្ចឹមប្រជាពលរដ្ឋរបស់ខ្លួន ក៏អាចសន្និដ្ឋានថាការលៃទុកធនធានទេះខ្លះៗ ដែលមានតម្លៃខ្ពស់សម្រាប់មុខជំនួញដើម្បីនាំចេញ ហើយបន្ទាប់មកប្រើប្រាស់រូបិយប័ណ្ណបរទេស

ដើម្បីនាំចូលស្បៀងអាចមានប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់ជាង។ ទង្វើបែបនេះ អាចជាការឈ្លាសវៃបើផ្អែកលើប្រសិទ្ធិភាពសេដ្ឋកិច្ច ប៉ុន្តែ អាចមិនជាការឈ្លាសវៃបើផ្អែកលើការអភិវឌ្ឍមនុស្ស។ ដោយសារ ទោះបីការបង្កើនពាណិជ្ជកម្មតាមវិធីនេះអាចបង្កើនសេដ្ឋកិច្ច និងផ្តល់ប្រយោជន៍ដល់អ្នកប្រើប្រាស់ក្រីក្រក្តី វាទំនងជាធ្វើឱ្យថ្លៃនៅក្នុងមូលដ្ឋានធ្លាក់ចុះនិងធ្វើឱ្យខូចខាតជីវភាពរស់នៅរបស់កសិករក្រីក្រ។

គោលនយោបាយបែបនេះក៏ធ្វើឱ្យទន់ខ្សោយសន្តិសុខស្បៀងផងដែរ។ ជាគោលការណ៍ប្រសិនបើចាំបាច់ ប្រទេសទាំងអស់គួរតែមានលទ្ធភាពទិញស្បៀងពីទីផ្សារពិភពលោក។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ប្រទេសភាគច្រើនចង់កាត់បន្ថយភាពងាយរងគ្រោះទៅអនាគតដោយប្រឹងប្រែងបង្កើនផលិតកម្មស្បៀងសំខាន់ៗនៅក្នុងស្រុក។ ដូច្នេះ ប្រទេសទាំងនោះអាចជ្រើសយកការដាក់កំហិតទៅលើសេរីភាវូបនីយកម្ម ដោយបារម្ភអំពីការប៉ះទង្គិចយ៉ាងខ្លាំងពីខាងក្រៅ ដូចជាកំនើនយ៉ាងគំហុកនៃថ្លៃប្រេងកាត ឬកំនើនអត្រាការប្រាក់ ដែលធ្វើឱ្យពួកគេបាត់បង់សមត្ថភាពនាំចូលស្បៀងសម្រាប់បំពេញតម្រូវការគ្រប់គ្រាន់ក្នុងប្រទេស។

កាលៈទេសៈ និងសេណារីយ៉ូខុសគ្នាបែបនេះមានន័យថា ប្រទេសនីមួយៗទំនងជាត្រូវមានអាទិភាពរបស់ខ្លួន ដែលនឹងបង្ហាញពីគោលជំហររបស់ខ្លួននៅក្នុងការចរចាពាណិជ្ជកម្ម។ ប្រទេសនាំចេញ ដូចជា អូស្ត្រាលី នូវែលហ្សេឡង់ ថៃ និងវៀតណាម នឹងទទួលយកចំណុចជាច្រើននៃសេរីភាវូបនីយកម្ម ទោះបីវាពាក់ព័ន្ធជាមួយការពង្រីកលទ្ធភាពក្នុងទីផ្សារ កាត់បន្ថយការឧបត្ថម្ភធន ឬបង្កើនភាពប្រកួតប្រជែងជាទូទៅក្តី។ ប្រទេសដទៃទៀតអាចចាប់អារម្មណ៍ជាងទៅលើការដាក់កំហិតលើសេរីភាវូបនីយកម្មពាណិជ្ជកម្មកសិផល ដើម្បីធានាសន្តិសុខស្បៀង និងការពារមុខរបរចិញ្ចឹមជីវិតនៅក្នុងប្រទេស។ ភាពខុសគ្នាទាំងនេះអាចស្វែងយល់បាន ដូច្នេះម្ចាស់ជំនួយ ឬទីភ្នាក់ងារអន្តរជាតិ គួរតែបញ្ឈប់ការទាក់ទាញប្រទេសនានាទៅក្នុងគោលនយោបាយរួមអំពីពាណិជ្ជកម្មកសិផល។

ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់មិនត្រូវគ្នាទាំងស្រុងក៏ដោយ ក៏វាអាចមានប្រការត្រួតគ្នាមួយចំនួន។ ជាលទ្ធផលវាតែងតែមានសាមគ្គីភាពមួយកម្រិតនៅក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍។ ប្រការនេះបង្ហាញពីយុទ្ធសាស្ត្ររួមចំនួនបី :

- *បង្ហាញអំពីកង្វះសង្គតិភាពរបស់ប្រទេសជឿនលឿន* : ប្រទេសដែលមានជាង ច្រើនតែទាមទារឱ្យមានលទ្ធភាពច្រើនជាងក្នុងការប្រើប្រាស់ទីផ្សារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ទន្ទឹមនឹងការទាមទារសិទ្ធិការពារកសិកររបស់ខ្លួនផងដែរ។
- *ការពារផលិតផល "ងាយប្រែប្រួល"* : កិច្ចព្រមព្រៀង គួរតែដាក់បញ្ចូលវិធានការគាំពារនានាជាពិសេសសម្រាប់ផលិតផល "ងាយប្រែប្រួល" ដើម្បីការពារជីវភាពរស់នៅ និងធានាសន្តិសុខស្បៀង។
- *អះអាងឱ្យមានការយកចិត្តទុកដាក់ខុសគ្នា* : ប្រទេសកំពុងអភិវឌ្ឍន៍ជឿថាខ្លួននិងជាពិសេសប្រទេសក្រីក្រជាងគេគួរតែអាចពឹងផ្អែកលើការយកចិត្តទុកដាក់ខុសគ្នា។

នៅក្នុងកាលៈទេសៈទាំងនេះ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនត្រូវតែរក្សាទុកអត្រាពន្ធរបស់ខ្លួនលើកសិផល ដើម្បីការពារកសិករតូចតាចរបស់ខ្លួន និងធានាថាពួកគេអាចធ្វើ

ការប្រកួតប្រជែងនៅលើទីផ្សារក្នុងប្រទេស។ ប៉ុន្តែ ទន្ទឹមនឹងនេះ ពួកគេត្រូវពង្រឹងគោលជំហរទៅអនាគតរបស់កសិករបែបនេះ តាមរយៈកំណែទម្រង់ដីធ្លី និងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ អភិវឌ្ឍន៍ជនបទ បរិក្ខារសម្រាប់កែច្នៃនិងរក្សាទុក និងសម្ភារៈសំរាប់ការផលិត ហើយក្នុងករណីចាំបាច់ ត្រូវផ្តល់ការគាំទ្រចំពោះថ្លៃផលិតផល។ ធ្វើបែបនេះហាក់ដូចជាផ្តល់សិទ្ធិច្រើនដល់កសិករ ធៀបនឹងអ្នកប្រើប្រាស់ក្រីក្រនៅក្នុងទីក្រុង ដូច្នេះ រដ្ឋាភិបាលក៏គួរតែធានាឱ្យមានអាហារជាមូលដ្ឋានតាមកម្រិតដែលអាចទិញបាន ដែលមានន័យថា ជាតួនាទីបន្ទាប់បន្សំសម្រាប់សហគ្រាសពាណិជ្ជកម្មរបស់រដ្ឋ ឬការបង្កើតបណ្តាញសុវត្ថិភាពសម្រាប់គោលដៅជាក់លាក់។

ប៉ុន្តែ រដ្ឋាភិបាលមិនអាចបញ្ចប់ជំនួយរបស់ខ្លួនត្រឹមនេះឡើយ។ ប្រទេសនីមួយៗត្រូវបង្កើតគោលនយោបាយផ្ទាល់ខ្លួន អាស្រ័យលើថាតើខ្លួនជាប្រទេសនាំចូល ឬនាំចេញស្បៀង លើភាពចម្រុះរវាងកសិករតូចតាច និងកសិករជំនួញទ្រង់ទ្រាយធំ និងភាពប្រកួតប្រជែងនៃតម្រូវការរវាងជនបទ និងទីក្រុង។ ពុំមានបទបញ្ញាតែមួយដែលអាចបំពេញតម្រូវការអភិវឌ្ឍន៍មនុស្សសម្រាប់គ្រប់គ្នាឡើយ។

## ពង្រឹងកម្មសិទ្ធិបញ្ញា

ដើម្បីការពារកម្មសិទ្ធិបញ្ញា ការស្រាវជ្រាវជាច្រើនបន្ថែមទៀត ត្រូវតែផ្តោតទៅលើទិដ្ឋភាពច្បាប់ និង រដ្ឋបាលជាងលើផលប្រយោជន៍សេដ្ឋកិច្ច។ តាមពិត កិច្ចព្រមព្រៀង TRIPS ត្រូវបានតាក់តែងឡើងដោយមានការ "វិភាគតែបន្តិចបន្តួចប៉ុណ្ណោះ អំពីផលប៉ះពាល់សេដ្ឋកិច្ចដែលរំពឹងទុកពីកិច្ចព្រមព្រៀងនេះ"។[៨៦] វាអាចធ្វើឱ្យប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវចំណាយច្រើន។ ចំពោះប្រទេសក្រីក្រភាគច្រើន ថ្លៃចំណាយនេះអាចមានសមាមាត្រធំធេងនៅក្នុងថវិកាអភិវឌ្ឍន៍ ហើយអាចផ្តល់ផលបានច្រើនជាងប្រសិនបើយកទៅអភិវឌ្ឍនៅលើផ្នែកផ្សេង។ ទោះជាយ៉ាងណាក៏ដោយ អាចពុំមានគំរូស្តង់ដារនៃកិច្ចការពារ IPR ទេ។ ប្រទេសនានានឹងជ្រើសរើសយកគំរូដែលត្រូវនឹងធនធាន និងទស្សនៈវិស័យនៃការអភិវឌ្ឍរបស់ខ្លួន និងបារម្ភអំពីការចំណាយច្រើន។

## ការកំណត់ទីតាំងភូមិសាស្ត្រ (GI)

ការពង្រឹងកិច្ចការពារ GI ដ៏ល្បីល្បាញ គឺជាករណីដែលគួរយកចិត្តទុកដាក់ឱ្យបានច្រើនជាង ដោយសារវាទំនងជាត្រូវចំណាយតិចជាងករណីការពារសិទ្ធិលើកម្មសិទ្ធិបញ្ញា។[៨៧] សម្រាប់ប្រទេសភាគច្រើននៅអាស៊ីដែលកំពុងចាប់ផ្តើមសហគ្រាសនេះ ការងារដំបូងគឺជាកិច្ចប្រឹងប្រែងនៅកម្រិតទាបបំផុតរបស់រដ្ឋាភិបាល ដើម្បីចងក្រងអំពីអ្វីដែលបានការពារ និងអំពីអ្វីដែលពួកគេចង់ការពារ និងអភិវឌ្ឍ។ កិច្ចការនេះអាចរួមបញ្ចូល ឧទាហរណ៍ អាហារ ភេសជ្ជៈ សម្លៀកបំពាក់ និងគ្រឿងបរិក្ខារ ក៏ដូចជាធនធានជីវសាស្ត្រ ដូចជារុក្ខជាតិ តិណជាតិ និង ដើមឈើ។

ប្រទេសទាំងនោះក៏គួរតែធ្វើការប៉ាន់ប្រមាណតម្លៃនៃលទ្ធផល និងគិតអំពីថាតើធ្វើបែបណាដើម្បីបង្កើនតម្លៃនេះ ប្រសិនមានការវិនិយោគបានគ្រប់គ្រាន់ខាងផ្នែកច្បាប់ ទីផ្សារ និងបច្ចេកវិទ្យា។ ប្រទេសទាំងនោះគួរតែអាចចង្អុលបង្ហាញថាតើមានមនុស្សប៉ុន្មាននាក់ដែលនឹងទទួលផលប្រយោជន៍អំពីកំណើនលទ្ធផលដោយគិតចែកដាច់ពីគ្នា ទៅតាមភេទមនុស្ស ក្រុមជនជាតិ និងក្រុមដែលមានប្រាក់ចំណូលខុសគ្នា។

## ក្របខ័ណ្ឌគោលនយោបាយជលផល

ដូចនៅក្នុងប្រទេសជឿនលឿនផងដែរ ជាពិសេស LDCs គួរតែមានសេរីភាពខ្លះៗដើម្បីការពារកសិករក្រីក្ររបស់ខ្លួន ប្រទេសទាំងនោះក៏គួរតែអាចការពារសហគមន៍នេសាទផងដែរ។ ធ្វើបែបនេះនឹងទាមទារឱ្យមានចំណាត់ការពីសំណាក់ប្រទេសនាំចូល និងប្រទេសនាំចេញ។ ប្រទេសជឿនលឿនដែលជាអ្នកនាំចូល ត្រូវតែជៀសវាងការគាំទ្រ ឬការឧបត្ថម្ភធនលើការនាំចេញឱ្យដល់ផលិតកររបស់ខ្លួន និងទប់ទល់ចំពោះកិច្ចប្រឹងប្រែងដើម្បីការពារកសិករទាំងនោះពីការប្រកួតប្រជែងត្រឹមត្រូវពីសំណាក់ប្រទេសកំពុងអភិវឌ្ឍន៍។

ប៉ុន្តែ មានកិច្ចការជាច្រើនថែមទៀតដែលត្រូវធ្វើនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលនាំចេញត្រី។ ទីមួយ ប្រទេសទាំងនោះត្រូវតែដាក់ឱ្យអនុវត្តវិធានការគ្រប់គ្រង ដើម្បីទប់ស្កាត់ការនេសាទនៅក្នុងដែនទឹករបស់ប្រទេសខ្លួន មិនឱ្យមានការនេសាទច្រើនហួសកម្រិត ឬមិនឱ្យមានការនេសាទច្រើនដល់កម្រិតកំពូលជីវសាស្ត្រ (Biological limtes) របស់ខ្លួន។ វិធានការទាំងនោះរួមមាន បទប្បញ្ញត្តិកំណត់ទំហំក្រឡាសាច់មង កំណត់តំបន់/រដូវហាមឃាត់ការនេសាទ និងហាមឃាត់ការនេសាទប្រភេទត្រីខ្លះៗ និងចុះបញ្ជីនូវប្រភេទដែលមិនអាចនាំចេញកាលណាមានទំហំតូចក្រោមកម្រិតអប្បបរមា។ នៅក្នុងករណីខ្លះ គួរតែអាចបង្វែរទិសកិច្ចប្រឹងប្រែងនេសាទទៅកន្លែងផ្សេង។ ប្រទេសមួយចំនួននៅអាស៊ី-ប៉ាស៊ីហ្វិក បានចាត់វិធានការបែបនេះរួចទៅហើយ ប៉ុន្តែចាំបាច់ត្រូវធ្វើឱ្យប្រការនេះកើតមានជាទូទៅ និងពង្រឹងបន្ថែម។

ជម្រើសទីពីរគឺត្រូវបង្កើតផលិតផលឱ្យបានកាន់តែច្រើនឡើងតាមរយៈវារីវប្បកម្ម។ ឧទាហរណ៍ ប្រទេសចិនមានគោលនយោបាយមិនឱ្យមានកំណើនការនេសាទសមុទ្រពីដែនទឹកសមុទ្រក្នុង និងសមុទ្រក្រៅរបស់ខ្លួន និងមានបំណងបង្កើនផលិតផលរបស់ខ្លួនពីវារីវប្បកម្ម និងការនេសាទនៅដែនសមុទ្រឆ្ងាយៗ។ ប៉ុន្តែ ដោយសារវារីវប្បកម្មអាចបង្កការបំផ្លិចបំផ្លាញបរិស្ថាន ប្រទេសចិនបានដាក់ឱ្យអនុវត្តអ្វីដែលត្រូវបានហៅថា "វារីវប្បកម្មអេកូឡូស៊ី" ដើម្បីរួមបញ្ចូលគោលការណ៍អេកូឡូស៊ីធម្មជាតិ និងសង្គម កសាងផែនការសម្រាប់ "ការអភិវឌ្ឍសហគមន៍ និងកង្វល់សម្រាប់បរិបទធំទូលាយខាងសង្គម សេដ្ឋកិច្ច និងបរិស្ថាននៃវារីវប្បកម្ម"។[៨៨]

ផ្នែកផ្សេងទៀតដែលជាអាទិភាពក្នុងវិស័យជលផលគឺ :

- *ស្តង់ដារសុវត្ថិភាពអាហារ* : បង្កើតស្តង់ដារសុវត្ថិភាពស្បៀងជាតិប្រកបដោយប្រសិទ្ធិភាព និងដែលអាចអនុវត្តបាន និងបង្កើតសមមូលរបស់ខ្លួនជាមួយស្តង់ដារ ដែលមានប្រើប្រាស់ជាទូទៅនៅក្នុងទីផ្សារនាំចូល។ សម្រាប់គោលបំណងនេះ ជាពិសេស LDCs គួរតែអាចពឹងផ្អែកលើជំនួយអភិវឌ្ឍន៍អន្តរជាតិ។
- *ការចេញវិញ្ញាបនប័ត្របញ្ជាក់ផលនេសាទ* : ជាចំណែកមួយនៃការនាំមុខដើម្បីអនុវត្តប្រព័ន្ធដាក់ស្លាកសញ្ញាបរិស្ថានជាអន្តរជាតិ។ ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះគួរតែអាចចាប់ផ្តើមកម្មវិធីជាតិចេញវិញ្ញាបនប័ត្របញ្ជាក់ ដោយប្រមូលផ្តុំកិច្ចប្រឹងប្រែងនៃអាជ្ញាធរជលផលនៅថ្នាក់ជាតិ ឬរដ្ឋ រួមជាមួយអង្គការកម្មករនេសាទ និងសហគមន៍អ្នកវិទ្យាសាស្ត្រ។ ជាមួយបទពិសោធន៍នេះ ប្រទេសនៅអាស៊ានអាចពាក់ព័ន្ធកាន់តែច្រើននៅក្នុងការបង្កើតគណៈកម្មការ

បច្ចេកទេស ISO ស្តីពីផលផលដែលអាចធ្វើការផ្គោះទៅបង្កើតពិធីសារ "ដាក់ស្លាកសញ្ញាបរិស្ថាន" អន្តរជាតិ ។

- *ចរចាអំពីការឧបត្ថម្ភធន* : នៅក្នុងរយៈពេលយូរអង្វែង គួរតែអាចលុបចោលការឧបត្ថម្ភធននៅក្នុងប្រទេសភាគច្រើន។ ប៉ុន្តែនៅក្នុងការជជែកវែកញែករបស់WTO ស្តីពីការឧបត្ថម្ភធន ប្រទេសនៅអាស៊ីគួរធ្វើការតាមសង្កត់ឱ្យប្រការនេះកើតឡើងបានកាន់តែឆាប់រហ័សនៅក្នុងប្រទេសជឿនលឿន និងដែលមានប្រាក់ចំណូលខ្ពស់ ។ចំពោះការឧបត្ថម្ភធនសម្រាប់ពង្រឹងសមត្ថភាពប្រទេសទាំងនោះ អាចអះអាងឱ្យមានការលើកលែងទាំងស្រុង សម្រាប់ LDCs ។

## គោលនយោបាយជាអាទិភាព

ជាសង្ខេប ផ្នែកគន្លឹះសម្រាប់គោលនយោបាយគឺ :

១. *ធានាថាមានការយកចិត្តទុកដាក់ជានិច្ចលើកសិកម្ម:* ភាគច្រើននៃអ្នកក្រីក្រជាងគេនៅលើពិភពលោកពឹងផ្អែកលើកសិកម្ម និងលទ្ធភាពទទួលស្បៀងអាហារដែលអាចទុកចិត្តបាន។ ដូច្នេះ គោលនយោបាយប្រកបដោយប្រសិទ្ធិភាពអំពីពាណិជ្ជកម្មកសិផល មានសារៈសំខាន់ណាស់ សម្រាប់ការអភិវឌ្ឍមនុស្ស និងគួរតែរក្សាទុកនៅជួរមុខនៃការជជែកវែកញែកជាសាធារណៈ។

២. *លើកកម្ពស់សាមគ្គីភាពក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ :* ក្នុងពាណិជ្ជកម្មកសិផល ប្រទេសកំពុងអភិវឌ្ឍន៍មានចំណាប់អារម្មណ៍រួមគ្នាយ៉ាងច្រើន។ ឧទាហរណ៍ ពួកគេអាចរួបរួមគ្នា ដើម្បីបង្ហាញឱ្យឃើញនូវកង្វះសង្គតភាពនៃគោលនយោបាយរបស់ប្រទេសជឿនលឿន។ ប្រទេសទាំងនោះក៏អាចធ្វើការអះអាងរួមគ្នា ដើម្បីឱ្យមានការយកចិត្តទុកដាក់ខុសគ្នាសម្រាប់ប្រទេសដែលងាយរងគ្រោះជាងគេ ជាពិសេស LDCs ។ ដោយរួបរួមគ្នាជាក្រុម ប្រទេសទាំងនេះអាចចង់ធ្វើឱ្យមានស្ថិរភាពនូវថ្លៃស្បៀង និងកសិផលមិនមែនស្បៀង។

៣. *បំពេញឱ្យបាននូវផលប្រយោជន៍ជាតិខុសគ្នា :* ទោះជាយ៉ាងណាក៏ដោយ ដោយផ្អែកលើប្រការដែលថា ឧទាហរណ៍ តើប្រទេសនោះជាអ្នកនាំចូលសុទ្ធ ឬជាអ្នកនាំចេញសុទ្ធ ប្រទេសនីមួយៗ ត្រូវតែបង្កើតគោលនយោបាយផ្ទាល់ខ្លួន អំពីភាពចម្រុះរវាងកសិករតូចតាច និងកសិករធ្វើជំនួញ និងអំពីភាពប្រកួតប្រជែងនៃតម្រូវការនៅជនបទនិងទីក្រុង។ ត្រូវទទួលស្គាល់ និងពិភាក្សាដោយបើកចំហ និងតម្លាភាពនៅថ្នាក់ជាតិនិងអន្តរជាតិអំពីភាពខុសគ្នាទាំងនេះ និងអំពីទំនាស់ផលប្រយោជន៍។

៤. *លើកកម្ពស់ផលប្រយោជន៍របស់អ្នកក្រ* : សេរីភាវូបនីយកម្មមិនមែនជាគោលដៅចុងក្រោយនោះទេ។ វាមានតម្លៃតែកាលណាវាអាចនាំមកនូវប្រយោជន៍សម្រាប់អ្នកក្រ។ ដូច្នេះ គោលនយោបាយពាណិជ្ជកម្មត្រូវរួមបញ្ចូលបរិធានជាច្រើនបែប រួមទាំងអត្រាពន្ធ និងការគាំទ្រផ្សេងៗសម្រាប់ក្រុមជនទន់ខ្សោយ។

បើពុំមានប្រការនេះទេ វិធានទូលំទូលាយ ការគាំទ្រជាសាធារណៈសម្រាប់ប្រភេទណាមួយនៃសេរីភាវូបនីយកម្ម ទំនងជានឹងត្រូវដួលរលំ និងជម្រុញឱ្យមានការប្រកាន់យករបបការពារនិយម។

៥. *ពង្រឹងនិមិត្តរូបប្រចាំភូមិសាស្ត្រ និងសិទ្ធិលើកម្មសិទ្ធិបញ្ញា* : អាទិភាពមួយគួរតែជាការបង្កើត និងការពារនិមិត្តរូបប្រចាំភូមិសាស្ត្រ ដែលមានការចងក្រងបានលំអិតនូវសម្បត្តិជាតិ និងផលប្រយោជន៍ដែលអាចទទួលបានពីវា។ ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះក៏អាចបង្កើតប្រព័ន្ធរបស់ជាតិ សម្រាប់ការពារកម្មសិទ្ធិបញ្ញាផងដែរ ប៉ុន្តែ សម្រាប់ប្រទេសជាច្រើន ប្រការនេះអាចត្រូវចំណាយខ្ពស់ណាស់។

៦. *កំណែទម្រង់វិស័យជលផលប្រទេសកំពុងអភិវឌ្ឍន៍* : ត្រូវការពារផលប្រយោជន៍របស់សហគមន៍នេសាទខ្នាតតូច និងលើកកម្ពស់ការនេសាទសមុទ្រ និងវារីវប្បកម្មឱ្យមាននិរន្តរភាព តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពជាងមុន។ ប៉ុន្តែ ប្រទេសទាំងនេះត្រូវតែឆ្លើយតបផងដែរ ទៅនឹងការអភិវឌ្ឍអន្តរជាតិបច្ចុប្បន្ន និងទៅអនាគត ឧទាហរណ៍ ដោយបង្កើតស្តង់ដារសុវត្ថិភាពអាហារ និងកសាងទម្រង់ថ្មី នៃការចេញវិញ្ញាបនប័ត្របញ្ជាក់។

៧. *វិនិយោគលើការអភិវឌ្ឍជនបទ* : សម្រាប់រយៈពេលវែង ពាណិជ្ជកម្មកសិផលអន្តរជាតិទំនងជានឹងកើនឡើង។ ដូច្នេះ ប្រទេសកំពុងអភិវឌ្ឍន៍គួរជួយសហគមន៍ជនបទឱ្យមានភាពបត់បែនជាងមុន ដោយជម្រុញការអភិវឌ្ឍជនបទ ប្រកបដោយសមធម៌ តាមរយៈកំណែទម្រង់ដីធ្លី និងចាត់វិធានការផ្សេងទៀត ដែលបង្កើតផលិតភាពជាមួយសមធម៌ ទន្ទឹមនឹងលើកកម្ពស់ការអភិវឌ្ឍមនុស្ស។



# 4



**៤**

**ជំពូក**

# ការកែទម្រង់ឱ្យស្របនឹងយុគសម័យថ្មី សម្រាប់វាយនភណ្ឌ និង សម្លៀកបំពាក់

ប្រទេសជាច្រើននៅអាស៊ី ដូចជាប្រទេសជឿនលឿនដែលបានធ្វើដំណើរនាំមុខកាលពីមុនដែរ បានចាប់ផ្ដើមធ្វើពាណិជ្ជកម្មទ្រង់ទ្រាយធំនូវផលិតផលឧស្សាហកម្ម តាមរយៈវាយនភណ្ឌ និងសម្លៀកបំពាក់។ ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៦០មក ប្រទេសក្រីក្រជាច្រើននៅក្នុងតំបន់នេះចាប់មានលទ្ធភាពទាញយកផលចំណេញពីប្រព័ន្ធកូតា ដែលផ្ដល់នូវការអនុគ្រោះខុសគ្នាក្នុងការប្រើប្រាស់ទីផ្សារនៅក្នុងប្រទេសជឿនលឿន។ ឥឡូវយុគសម័យនោះបានកន្លងផុតហើយ ប្រទេសមួយចំនួនកំពុងប្រឹងប្រែងដើម្បីកែទម្រង់ឱ្យស្របនឹងការរំពឹងទុកអំពី ភាពប្រកួតប្រជែងយ៉ាងខ្លាំងក្លា ជាពិសេសពីសំណាក់ប្រទេសចិន។

ឥឡូវប្រទេសកំពុងអភិវឌ្ឍន៍បាននាំចេញបរិមាណពាក់កណ្ដាលនៃផលិតផលវាយនភណ្ឌនៅលើពិភពលោក និងជិតបីភាគបួននៃការនាំចេញសម្លៀកបំពាក់។[១] តួលេខនេះបង្ហាញពីការផ្លាស់ប្ដូរយ៉ាងខ្លាំងនៅក្នុងវិស័យដែលធ្លាប់តែស្ថិតក្រោមឥទ្ធិពលរបស់ប្រទេសជឿនលឿន ប៉ុន្តែ ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៨០មក ប្រទេសកំពុងអភិវឌ្ឍន៍បានដែងយកតួនាទីនេះ ហើយឥឡូវបានពឹងផ្អែកលើវាយនភណ្ឌ និងសម្លៀកបំពាក់ (T&C) ដើម្បីបង្កើនផលិតផលឧស្សាហកម្ម និងការងារធ្វើយ៉ាងច្រើន។

*ឥឡូវប្រទេសកំពុងអភិវឌ្ឍន៍បាននាំចេញបរិមាណពាក់កណ្ដាលនៃផលិតផលវាយនភណ្ឌនៅលើពិភពលោក និងជិតបីភាគបួននៃការនាំចេញសម្លៀកបំពាក់*

សេដ្ឋកិច្ចជាច្រើននៅអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍បានបង្ហាញពីភាពលេចធ្លោនៅក្នុងពាណិជ្ជកម្មនេះ ដោយប្រើប្រាស់វិស័យ T&C ជាគ្រឹះសម្រាប់ការចេញដំណើរនៃឧស្សាហកម្ម ដូចជា ហុងកុង សិង្ហបុរី តៃវ៉ាន់ សាធារណរដ្ឋកូរ៉េ និងប្រទេសម៉ាឡេស៊ី ដែលជាអ្នកនាំមុខបន្ទាប់មកគឺ ប្រទេសចិន វៀតណាម ថៃ និង ឥណ្ឌូណេស៊ី។

តែការពង្រីកនេះនៅតែមានកម្រិតទាបយ៉ាងខ្លាំងធៀបនឹងសក្ដានុពលពេញលេញ។ ដោយបារម្ភអំពីល្បឿននៃការធ្លាក់ចុះនៃឧស្សាហកម្មរបស់ខ្លួន ប្រទេសជឿនលឿនបានបង្កើតកូតាយ៉ាងតឹងរ៉ឹងទៅតាមប្រទេសនីមួយៗលើការនាំចូលពីប្រទេសកំពុងអភិវឌ្ឍន៍។ នៅក្រោមការចាត់ចែងរបស់ GATT ក្នុងឆ្នាំ ១៩៦២ ប្រទេសទាំងនោះបានធ្វើការចរចាលើការចាត់ចែងរយៈពេលវែងទាក់ទងនឹងពាណិជ្ជកម្មអន្តរជាតិសម្រាប់វាយនភណ្ឌកប្បាស និងផលិតផលជំនួសដែលត្រូវបានបន្តរហូតដល់ឆ្នាំ ១៩៧៤ ដែលត្រូវបានក្លាយជាកិច្ចព្រមព្រៀងពហុសរសៃអំបោះ (MFA)។ ការធ្វើបែបនេះ បានកាត់បន្ថយការនាំចូលសរុប និងកំហិតលើការនាំចេញពីផលិតករធំៗ ដូចជាប្រទេសចិន និងឥណ្ឌា ប៉ុន្តែ ក៏ផ្ដល់ផលចំណេញសម្រាប់ប្រទេសតូចជាងផងដែរ ដូចជា បង់ក្លាដេសនិងណេប៉ាល់ ដែលកូតាមានបរិមាណគ្រប់គ្រាន់សម្រាប់ប្រទេសទាំងនេះបង្កើតឧស្សាហកម្មថ្មី។

លទ្ធផលទទួលបានធ្វើឱ្យឧស្សាហកម្ម T&C កើតមាននៅតាមកន្លែងដាច់ស្រយាលដែលបានផ្ដល់ការងារសម្រាប់កម្មករទន់ខ្សោយ និងដែលមានជំនាញតិចតួចជាច្រើនពាន់នាក់នៅទូទាំងតំបន់នេះ។ ស្ត្រីក៏បានឆក់យកកាលានុវត្តភាពនេះផង

ដែរ។ សូម្បីតែនៅក្នុងសង្គមមនុស្សដែលរស់នៅតាមបែបបុរាណ និងដាច់ឆ្ងាយពីគេ ស្ត្រីកាន់តែច្រើនឡើងបានចូលរួមនៅក្នុងកម្លាំងពលកម្មនេះ។ នេះអាចជាបទពិសោធដ៏ខ្លាំងក្លាមួយដែលជាលើកទីមួយសម្រាប់ស្ត្រីជាច្រើនក្នុងការទទួលប្រាក់ចំណូលដោយខ្លួនផ្ទាល់ខ្លួន និងមានអំណាចក្នុងការសំដែងមតិកាន់តែច្រើនឡើងនៅក្នុងគ្រួសារ។ ក្រៅពីលើកកម្ពស់សមភាពយេនឌ័រ ប្រការនេះបាននាំមកនូវផលប្រយោជន៍ជាវិជ្ជមានសម្រាប់សង្គមទាំងមូល ដោយសារស្ត្រីទំនងជាប្រើប្រាស់ប្រាក់ចំណូលនេះ ដើម្បីវិនិយោគលើការអប់រំ និងសុខភាពគ្រួសាររបស់ខ្លួន។

ឧស្សាហកម្មថ្មីៗទាំងនេះក៏នាំមកនូវផលប្រយោជន៍ខាងសេដ្ឋកិច្ចទូលំទូលាយផងដែរ។ វាបានផ្តល់ឱ្យសេដ្ឋកិច្ចនាំចេញនូវកាលានុវត្តភាពដើម្បីទទួលបានជំនាញថ្មី និងបង្កើនផលិតភាព ព្រមទាំងចែករំលែកចំណេះដឹង និងបច្ចេកវិទ្យា ហើយជម្រុញឱ្យឧស្សាហកម្ម និងសេវាផ្សេងទៀត ដែលលូតលាស់នៅជុំវិញរោងចក្រនោះនិងជុំវិញកម្លាំងកម្មករ។ វិស័យវាយនភណ្ឌនិងសម្លៀកបំពាក់ដែលលូតលាស់ល្អនៅក្នុងប្រទេសមួយ ត្រូវបានបង្ហាញឡើងដោយការវិភាគស្ថិតិអន្តរប្រទេសថា នាំឱ្យមានប្រាក់ចំណូលខ្ពស់ជាងកម្រិតកណ្តាលផងដែរ។[២]

ប៉ុន្តែការឈានទៅមុខនៃសេដ្ឋកិច្ចនេះក៏ធ្វើឱ្យមានការខូចខាតខាងសង្គមផងដែរ។ លក្ខខណ្ឌការងារនៅក្នុងវិស័យ T&C អាចមានភាពលំបាកនិងប្រកបដោយភាពកេងប្រវ័ញ្ច។ តម្រូវការសម្លៀកបំពាក់មានទៅតាមរដូវ និងមិនអាចព្យាករណ៍បាន ដូច្នេះ ម្ចាស់ឧស្សាហកម្មជួលកម្មករជាច្រើនក្រោមរូបភាពការងារក្រៅម៉ោង ឬផ្តល់កម្រៃទៅតាមបរិមាណផលិតផល ដោយពុំផ្តល់កិច្ចសន្យាការងារ ឬអត្ថប្រយោជន៍ខាងសុខភាព ឬអត្ថប្រយោជន៍ផ្សេងទៀតឡើយ។ ស្ត្រីជាអ្នកងាយរងគ្រោះជាងគេ។ ពួកគាត់អាចមានឯករាជ្យភាពច្រើនជាងមុន ដោយបានធ្វើការនៅក្រៅផ្ទះ ប៉ុន្តែច្រើនតែប្រឈមនឹងការរើសអើងនៅក្នុងរោងចក្រដោយបានទទួលកម្រៃតិចជាងបុរស និងតម្រូវឱ្យធ្វើការដែលមិនទាក់ទងនឹងការគ្រប់គ្រងដោយផ្តល់ឱកាសតិចតួចសម្រាប់ការពង្រឹងជំនាញខ្លួនឯង។

ឥឡូវសម័យកូតាបានបញ្ចប់ទៅហើយ ហើយវិស័យ T&C លើពិភពលោក កំពុងស្ថិតនៅចំណុចកណ្តាលនៃភាពចលាចលយ៉ាងខ្លាំង។ ប្រទេសតូចៗដែលជាអ្នកនាំចេញមិនអាចបន្តពឹងផ្អែកលើរបបកូតាដែលផ្តល់ការអនុគ្រោះរយៈពេល ៤០ឆ្នាំមកហើយនោះទៀតទេ ហើយត្រូវប្រឈមនឹងការប្រកួតប្រជែងជាអន្តរជាតិយ៉ាងខ្លាំងក្លា។ ជំពូកនេះពិនិត្យមើលឥទ្ធិពលនៃការផ្លាស់ប្តូរទាំងនេះ និងស្វែងរកវិធី ដែលវិស័យ T&C អាចរួមចំណែកបានប្រសើរជាងមុន ចំពោះការអភិវឌ្ឍមនុស្ស។

## និន្នាការពាណិជ្ជកម្មពិភពលោកលើវាយនភណ្ឌ និង សម្លៀកបំពាក់

ក្នុងអំឡុង ៤០ឆ្នាំកន្លងទៅ ពាណិជ្ជកម្មពិភពលោកលើវាយនភណ្ឌនិងសម្លៀកបំពាក់បានកើនឡើង ៦០ដង។ រវាងឆ្នាំ ១៩៦២ និងឆ្នាំ ២០០៤ មានការកើនឡើងពី ៦.០០០ លានដុល្លារ/ឆ្នាំ រហូតដល់ ៤៥០.០០០លានដុល្លារ (តារាង ៤.១)។ ឥឡូវនេះ T&C គឺជាវិស័យផលិតមួយដែលមានការផ្លាស់ប្តូរបំផុត ដែលតំណាងឱ្យ ៧% នៃផលិតផលកម្មន្តសាលនាំចេញលើពិភពលោក។ សម្លៀកបំពាក់គឺជាផ្នែកធំជាងគេក្នុងចំណោមផ្នែកទាំងពីរនេះ ដែលតំណាងឱ្យ ៥៧% នៃពាណិជ្ជកម្ម T&C សរុប។ វាក៏មានការលូតលាស់រហ័សផងដែរ ដែលក្នុងរវាងឆ្នាំ ១៩៩៧ និង ២០០៤ ការនាំចេញវាយនភណ្ឌបានកើនឡើងជាមធ្យមត្រឹម ៣% ប៉ុណ្ណោះក្នុងមួយឆ្នាំ ប៉ុន្តែការនាំចេញសម្លៀកបំពាក់បានកើនឡើង ប្រមាណ ៦%។[៣]

ពាណិជ្ជកម្មនេះក៏មានលក្ខណៈអន្តរជាតិខ្លាំងផងដែរ ដោយមានប្រទេសប្រមាណ ១៣០ ផលិត និងនាំចេញវាយនភណ្ឌ ឬសម្លៀកបំពាក់។ ទោះជាយ៉ាងណាក៏ដោយ មានប្រទេសចំនួនតិចតួចប៉ុណ្ណោះ ដែលធ្វើការនាំចេញបានច្រើនប្រមាណជា ៣០% ក្នុងនោះប្រទេសធំជាងគេគឺ ស.រ.អា សហភាពអឺរ៉ុប និងជប៉ុន។[៤.៥]

## ការផ្លាស់ប្តូរទម្រង់នៃការនាំចេញ

ការប្រែប្រួលយ៉ាងឆាប់រហ័សបំផុតនៅក្នុងជញ្ជីងពាណិជ្ជកម្មបានកើតឡើងរវាងដើមទសវត្សរ៍ឆ្នាំ ១៩៨០ និង ឆ្នាំ ២០០០។ នៅក្នុងអំឡុងពេលនេះ ភាគចំណែកនៃការនាំចេញវាយនភណ្ឌរបស់ប្រទេសកំពុងអភិវឌ្ឍន៍នៅទូទាំងពិភពលោកបានកើនឡើងពី ៨% ទៅ ៤៦% ហើយភាគចំណែកនៃសម្លៀកបំពាក់ពីប្រទេសទាំងនេះ បានកើនឡើងពី ៩% ទៅ ៦០%។[៦] នៅដើមទសវត្សរ៍ឆ្នាំ ២០០០ មិនត្រឹមតែតម្លៃនៃការនាំចេញពីប្រទេសកំពុងអភិវឌ្ឍន៍ប៉ុណ្ណោះទេ ដែលកើនឡើង សូម្បីតែសេដ្ឋកិច្ចអន្តរកាលក៏បានចាប់ផ្តើមលេចមុខនៅក្នុងទិដ្ឋភាពរួមនៃពិភពលោកផងដែរ (រូបទី ៤.១)។ ប្រទេសដែលនាំមុខលើការនាំចេញសម្លៀកបំពាក់គឺប្រទេស ចិន ហុងកុង ម៉ិកស៊ិក ឥណ្ឌា បង់ក្លាដេស និង ឥណ្ឌូណេស៊ី។ ចំពោះវាយនភណ្ឌ ប្រទេសកំពុងអភិវឌ្ឍន៍ដែល ជាអ្នកនាំមុខ គឺ ចិន ហុងកុង តៃវ៉ាន់ ឥណ្ឌា និង ប៉ាគីស្ថាន។

និន្នាការថ្មីៗនេះសម្រាប់ប្រទេសនាំចេញចម្បងៗមានសង្ខេបជូននៅក្នុងតារាងទី ៤.២ និង ៤.៣។ តារាងទាំងនេះបង្ហាញថា ប្រទេសជឿនលឿនបានរក្សាផលប្រយោជន៍យ៉ាងខ្ជាប់ខ្ជួននៅក្នុងវិស័យនេះ។ តាមពិតនៅក្នុងវាយនភ័ណ្ឌ ពួកគេនៅតែមានការលូតលាស់កម្រិតខ្ពស់ដោយសារផលិតកម្មវាយនភណ្ឌទំនងជាត្រូវចំណាយមូលធនកាន់តែច្រើនឡើងជាងឧស្សាហកម្មកាត់ដេរ។ ទិដ្ឋភាពមួយផ្សេងទៀតនៃពាណិជ្ជកម្មរបស់ប្រទេសជឿនលឿនគឺភាគច្រើន ជាការធ្វើពាណិជ្ជកម្មជាមួយគ្នា ឧទាហរណ៍រវាង ស.រ.អា និងសហភាពអឺរ៉ុប រវាង ស.រ.អា និងកាណាដា។[៧]

តារាង ៤.១

ការនាំចេញវាយនភណ្ឌនិងសម្លៀកបំពាក់លើពិភពលោក (លានដុល្លារ)

| ឆ្នាំ | វាយនភណ្ឌ (T) | សម្លៀកបំពាក់ (C) | សរុប T&C |
|---|---|---|---|
| ១៩៨០ | ៥៤.៩៥០ | ៤០.៥៩០ | ៩៥.៥៨០ |
| ១៩៩០ | ១០៤.៣៥៤ | ១០៨.១២៩ | ២១២.៤៨៣ |
| ២០០០ | ១៥៤.១៨០ | ១៩៧.០២៩ | ៣៥១.២០៩ |
| ២០០២ | ១៥២.១៥១ | ២០០.៨៥១ | ៣៥៣.០០២ |
| ២០០៣ | ១៦៩.០០០ | ២២៦.០០០ | ៣៩៥.០០០ |
| ២០០៤ | ១៩៥.០០០ | ២៥៨.០០០ | ៤៥៣.០០ |

**ប្រភពៈ ធនាគារពិភពលោក ២០០៥**

តារាងទាំងនេះក៏បង្ហាញផងដែរអំពីសារៈសំខាន់នៃអាស៊ីនៅក្នុងពាណិជ្ជកម្មពិភពលោកលើវិស័យនេះ។ ចិនជាប្រទេសនាំចេញច្រើនជាងគេទីពីរ ខាងវាយនភណ្ឌនិងសម្លៀកបំពាក់នៅទូទាំងពិភពលោក និងស្ទើរតែស្ថិតក្នុងលំដាប់លេខ




រូបទី ៤.១: ការផ្លាស់ប្តូរទម្រង់នៃការនាំចេញលើពិភពលោក ១៩៩០-២០០៣

ប្រភព : UN Comtrade.

មួយលើការនាំចេញសម្លៀកបំពាក់។ ប្រទេសនីមួយៗផ្សេងទៀតនៅអាស៊ី ពុំបាននាំចេញក្នុងសមាមាត្រច្រើនឡើយក្នុងទីផ្សារពិភពលោក ប៉ុន្តែរួមគ្នា ប្រទេសទាំងអស់នៅក្នុងតំបន់នេះ បានក្លាយជាអ្នកដើរតួយ៉ាងសំខាន់លើទីផ្សារនាំចេញក្នុងពិភពលោក។

តារាង ៤.២

ប្រទេសនាំចេញវាយនភណ្ឌឈានមុខគេ ឆ្នាំ ២០០៤

| | តម្លៃ (ពាន់លានដុល្លារ) | % នៃការនាំចេញវាយនភណ្ឌលើពិភពលោក | | | |
|---|---|---|---|---|---|
| | ២០០៤ | ១៩៨០ | ១៩៩០ | ២០០០ | ២០០៤ |
| សហភាពអឺរ៉ុប (២៥) | ៧១.៣ | .. | .. | ៣៦.៥ | ៣៦.៦ |
| ការនាំចេញបន្ថែម-EU | ២៤.៣ | .. | .. | ១១.២ | ១២.៥ |
| ចិន (a) | ៣៣.៤ | ៤.៦ | ៦.៩ | ១០.៤ | ១៧.២ |
| ហុងកុង (ចិន) | ១៤.៣ | .. | .. | .. | .. |
| - ការនាំចេញក្នុងស្រុក | ០.៧ | ១.៧ | ២.១ | ០.៨ | .. |
| - ការនាំចេញបន្ត | ១៣.៦ | .. | .. | .. | ០.៤ |
| ស.រ.អា | ១២.០ | ៦.៨ | ៤.៨ | ៧.១ | ៦.២ |
| សាធារណរដ្ឋកូរ៉េ | ១០.៩ | ៤.០ | ៥.៨ | ៨.២ | ៥.៦ |
| តៃប៉ិ (ចិន) | ១០.០ | ៣.២ | ៥.៩ | ៧.៧ | ៥.២ |
| ជប៉ុន | ៧.១ | ៩.៣ | ៥.៦ | ៤.៥ | ៣.៧ |
| ឥណ្ឌា (b) | ៦.៩ | ២.៤ | ២.១ | ៣.៩ | ៤.០ |
| ទួគី | ៦.៤ | ០.៦ | ១.៤ | ២.៤ | ៣.៣ |
| ប៉ាគីស្ថាន | ៦.១ | ១.៦ | ២.៦ | ២.៩ | ៣.១ |
| ឥណ្ឌូណេស៊ី | ៣.២ | ០.១ | ១.២ | ២.៣ | ១.៦ |
| ថៃ (c) | ២.៦ | ០.៦ | ០.៩ | ១.៣ | ១.៣ |
| កាណាដា | ២.៤ | ០.៦ | ០.៧ | ១.៤ | ១.២ |
| ម៉ិចស៊ិកូ (a,c) | ២.២ | ០.២ | ០.៧ | ១.៧ | ១.១ |
| ស្វីស | ១.៦ | ២.៨ | ២.៥ | ១.០ | ០.៨ |

**សម្គាល់ : a. រួមទាំងការបញ្ជូនទំនិញជាច្រើនតាមតំបន់កែច្នៃសម្រាប់នាំចេញ។ b. ឆ្នាំ ២០០៣ តែមិនមែនឆ្នាំ ២០០៤ ទេ។ c. រួមទាំងការប៉ាន់ប្រមាណរបស់លេខាធិការដ្ឋាន។**

**ប្រភព: WTO ២០០៥**

ចំណែកការនាំចូល ពុំមានការប្រែប្រួលច្រើននោះទេ។ ប្រទេសនាំចូលចម្បងគឺ ស.រ.អា សហភាពអឺរ៉ុបនិងជប៉ុន។ ចិនក៏ជាប្រទេសនាំចូលវាយនភណ្ឌច្រើនផងដែរ ប៉ុន្តែច្រើនតែសម្រាប់ប្រើប្រាស់នៅក្នុងឧស្សាហកម្មសម្លៀកបំពាក់ប៉ុណ្ណោះ។

ដោយសារមានការពង្រីកវិស័យ T&C បែបនេះនៅអាស៊ី ធ្វើឱ្យប្រទេសជាច្រើនឥឡូវពឹងផ្អែកយ៉ាងខ្លាំងលើពាណិជ្ជកម្មនេះ។ នេះមិនមែនជាបញ្ហាធំដុំទេសម្រាប់ប្រទេសធំៗ។ ឧទាហរណ៍ ប្រទេសចិន ការនាំចេញ T&C មានត្រឹមតែ ១៦% នៃការនាំចេញផលិតផលសម្រាប់លក់សរុប ហើយសម្រាប់ឥណ្ឌាគឺមានតែ ២១% ប៉ុណ្ណោះ។ ប្រទេសតូចៗផ្សេងទៀតដែលពឹងផ្អែកយ៉ាងខ្លាំងលើវិស័យនេះគឺ កម្ពុជា ៧១% ប៉ាគីស្ថាន ៦៨% បង់ក្លាដេស ៥៩% ស្រីលង្កានិងនេប៉ាល់ ប្រមាណ ៥០% (រូបទី ៤.២)។ ទម្រង់ប្រហែលគ្នានេះបានលេចឡើងនៅពេលការនាំចេញ T&C ត្រូវបានគិតជាសមាមាត្រនៃផលិតផលឧស្សាហកម្ម ដែលមានភាគរយខ្ពស់ជាង។

## ចំនួនការងារ

ការពង្រីកវិស័យ T&C បានបង្កើតឱ្យមានចំនួន




រូបទី ៤.២: ភាគចំណែកនៃការនាំចេញវាយនភណ្ឌ និងសម្លៀកបំពាក់ នៅក្នុងប្រទេសមួយចំនួននៅអាស៊ីឆ្នាំ ២០០៤

ប្រភព : UN Comtrade

ការងារថ្មីជាច្រើនលាន។ ការនិយាយពីចំនួនជាក់ស្តែងពិតជាលំបាក ដោយសារស្ថិតិជាតិជាទូទៅពុំបែងចែករវាងអ្នកដែលធ្វើការសម្រាប់ទីផ្សារក្នុងស្រុក និងអ្នកដែលពាក់ព័ន្ធក្នុងពាណិជ្ជកម្មនាំចេញឡើយ ជាហេតុមិនបានរាប់បញ្ចូលមនុស្សជាច្រើន ដែលធ្វើការនៅក្នុងវិស័យដែលគ្មានការចាត់ចែងបានត្រឹមត្រូវ។ ដោយសារចំណុចខ្សោយនេះ ការប៉ាន់ប្រមាណអំពីចំនួនការងារបានធ្វើឡើងសម្រាប់តែប្រទេសខ្លះៗតែប៉ុណ្ណោះ (តារាងទី ៤.៤)។ ការប៉ាន់ប្រមាណផ្សេងទៀតសន្និដ្ឋានថា វិស័យ T&C ប្រើប្រាស់កម្មករប្រមាណ ៣៤០.០០០នាក់ នៅហ្វីលីពីន ច្រើនជាង ១លាននាក់ នៅឥណ្ឌូណេស៊ី និងជិតបីលាននាក់នៅវៀតណាម ដែលភាគច្រើនជាស្ត្រីមកពីទីជនបទ។[៨]

ភាគច្រើននៃកម្មករទាំងនេះគឺជាស្ត្រី ដែលមានសមាមាត្រខ្ពស់ដល់ ៩០% នៅប្រទេសបង់ក្លាដេស និងកម្ពុជា និង ៨៧% នៅស្រីលង្កា (រូបទី ៤.៣)។ នេះដោយសារមួយចំណែកមកពីល្បឿននៃកំណើនចំនួនការងារជាទូទៅ ដែលទាក់ទាញមនុស្សកាន់តែច្រើនមកធ្វើជាកម្មករ និងដោយសារវិស័យនេះច្រើនត្រូវការកម្មករក្រៅម៉ោង និងធ្វើការផ្អែកលើលទ្ធផល ដែលក្នុងកាលៈទេសៈនោះស្ត្រីទំនងជាមានភាពពលប់ជាង។ ឧទាហរណ៍ នៅប៉ាគីស្ថាន ជាប្រទេសមួយដែលចំនួនស្ត្រីមាន ១៥% នៃកម្លាំងពលកម្មទូទៅ កម្មការិនីមានចំនួន ៣០% នៅក្នុង T&C និង ៧៥% នៅក្នុងផ្នែកដេរ ដែលជួលកម្មករឱ្យធ្វើការតាមរយៈអ្នកម៉ៅការបន្ត និងបង់កម្រៃទៅតាមចំនួនផលិតផល។

ការចូលការងារនេះបានផ្តល់បទពិសោធសម្រាប់ស្ត្រីជាច្រើនពាន់នាក់ ហើយបើពុំមានឧស្សាហកម្មនេះទេ ពួកគេនឹងត្រូវនៅធ្វើការក្នុងភូមិរបស់ខ្លួន ឬនៅតែក្នុងផ្ទះរបស់ខ្លួន។ ឧទាហរណ៍ នៅកម្ពុជាស្ត្រីភាគច្រើនមកពីទីជនបទ។ ពួកគេទទួលបានកម្រៃ ៦០-៧០ដុល្លារ/ខែ ក្នុងនោះចំនួនប្រមាណពីរភាគបីត្រូវបានផ្ញើជូនទៅគ្រួសាររបស់ខ្លួនឯជនបទ។ ដោយមានការរួមចំណែកបែបនេះទៅក្នុងប្រាក់ចំណូលគ្រួសារ ពួកគេមានអំណាចច្រើនជាងមុន ក្នុងការធ្វើសេចក្តីសម្រេចលើកិច្ចការដូចជា អាពាហ៍ពិពាហ៍ ទំហំគ្រួសារ ការអប់រំ និងសុខភាព។ ស្ត្រី ១.៨លាននាក់ ដែលធ្វើការក្នុងឧស្សាហកម្មកាត់ដេរនៅប្រទេស

*ការពង្រីកវិស័យវាយនភណ្ឌ និង សម្លៀកបំពាក់ បានបង្កើតឱ្យមានចំនួនការងារថ្មីជាច្រើនលាន*

តារាង ៤.៣

ប្រទេសនាំចេញសម្លៀកបំពាក់ឈានមុខគេ ឆ្នាំ ២០០៤

| | តម្លៃ (ពាន់លានដុល្លារ) | %នៃការនាំចេញសម្លៀកបំពាក់លើពិភពលោក | | | |
|---|---|---|---|---|---|
| | ២០០៤ | ១៩៨០ | ១៩៩០ | ២០០០ | ២០០៤ |
| សហភាពអឺរ៉ុប (២៥) | ៧១.៣ | .. | .. | ៣៦.៥ | ៣៦.៦ |
| ការនាំចេញបន្ថែម-EU | ២៤.៣ | .. | .. | ១១.២ | ១២.៥ |
| ចិន (a) | ៣៣.៤ | ៤.៦ | ៦.៩ | ១០.៤ | ១៧.២ |
| ហុងកុង (ចិន) | ១៤.៣ | .. | .. | .. | .. |
| - ការនាំចេញក្នុងស្រុក | ០.៧ | ១.៧ | ២.១ | ០.៨ | .. |
| - ការនាំចេញបន្ត | ១៣.៦ | .. | .. | .. | ០.៤ |
| ទួគី | ១២.០ | ៦.៨ | ៤.៨ | ៧.១ | ៦.២ |
| ម៉ិចស៊ិកូ (a,b) | ១០.៩ | ៤.០ | ៥.៨ | ៨.២ | ៥.៦ |
| ឥណ្ឌា (c) | ១០.០ | ៣.២ | ៥.៩ | ៧.៧ | ៥.២ |
| ស.រ.អា | ៧.១ | ៩.៣ | ៥.៦ | ៤.៥ | ៣.៧ |
| រូម៉ានី | ៦.៩ | ២.៤ | ២.១ | ៣.៩ | ៤.០ |
| ឥណ្ឌូណេស៊ី | ៦.៤ | ០.៦ | ១.៤ | ២.៤ | ៣.៣ |
| បង់ក្លាដេស | ៦.១ | ១.៦ | ២.៦ | ២.៩ | ៣.១ |
| ថៃ (b) | ៣.២ | ០.១ | ១.២ | ២.៣ | ១.៦ |
| វៀតណាម (b) | ២.៦ | ០.៦ | ០.៩ | ១.៣ | ១.៣ |
| សាធារណរដ្ឋកូរ៉េ | ២.៤ | ០.៦ | ០.៧ | ១.៤ | ១.២ |
| ទុយណេស៊ី | ២.២ | ០.២ | ០.៧ | ១.៧ | ១.១ |
| ប៉ាគីស្ថាន | ១.៦ | ២.៨ | ២.៥ | ១.០ | ០.៨ |

**សម្គាល់ : a. ឬឆ្នាំជិតជាងគេ។ b. រួមទាំងការនាំចេញជាច្រើនពីតំបន់កែច្នៃសម្រាប់នាំចេញ។ c. រួមទាំងការប៉ាន់ប្រមាណរបស់លេខាធិការដ្ឋាន។**

**ប្រភព: WTO ២០០៥**

បង់ក្លាដេសក៏បានទទួលពីការងាររបស់ខ្លួនទាំងខាងហិរញ្ញវត្ថុ និងសង្គមផងដែរ ។

## លក្ខខណ្ឌការងារ

វិស័យ T&C មានភាពប្រកួតប្រជែងខ្លាំងណាស់ ដោយមានទំនាក់ទំនងជាច្រើនស្រទាប់យ៉ាងសាំញ៉ាំរវាងផលិតករខុសៗគ្នា នៅតាមខ្សែចង្វាក់ផលិតកម្ម ហើយនិយោជកក៏ស្ថិតនៅក្រោមសម្ពាធជាប្រចាំឱ្យកាត់បន្ថយការចំណាយផងដែរ ។ ប្រការនេះច្រើនតែនាំឱ្យលក្ខខណ្ឌការងារមានការកេងប្រវ័ញ្ច និងប្រកបដោយគ្រោះថ្នាក់ រួមទាំងធ្វើការច្រើនម៉ោង កង្វះសេរីភាពក្នុងការបង្កើតសមាគម ការប្រឈមនឹងសារធាតុពុល និងការហាមឃាត់ពីការសម្រាក[៥] ដែលត្រូវបានបង្ហាញយ៉ាងក្បោះក្បាយតាមរយៈការចាត់ចែងកម្មករកាត់ដេរនៅក្នុងផ្នែកផលិតកម្មនៅក្រុងដេលី (ប្រអប់ ៤.២) ។ បន្ថែមពីលើលក្ខខណ្ឌការងារលំបាកនេះ ផ្នែកខ្លះនៃឧស្សាហកម្មមានប្រវត្តិមិនល្អខាងបរិស្ថាន ។ ជាក់ស្តែង ឧស្សាហកម្មវាយនភណ្ឌបានប្រើប្រាស់សូលុយស្យុងរំលាយថ្នាំសម្លាប់សត្វចង្រៃ លក្ខណ៍ និងថ្នាំបន្សាបនៅក្នុងដំណើរការផលិតកម្មរបស់ខ្លួន ប៉ុន្តែច្រើនតែមានការប្រឹងប្រែងតិចតួចតែប៉ុណ្ណោះដើម្បីធ្វើប្រព្រឹត្តកម្មសម្អាតទឹកក្រខ្វក់ទាំងនោះ ជាហេតុធ្វើឱ្យមានការបំពុលទឹក ។

## គម្លាតគ្នាទាក់ទងនឹងយេនឌ័រ

មានការជួលស្ត្រីជាចំនួនច្រើននៅក្នុងឧស្សាហកម្ម T&C ប៉ុន្តែពួកគេនៅតែបានទទួលការយកចិត្តទុកដាក់ទាប បើប្រៀបធៀបនឹងដៃគូបុរស (ប្រអប់ ៤.១) ។ នៅក្នុងប្រទេសភាគច្រើន កម្មការិនីបានទទួលប្រាក់កម្រៃទាបជាងបុរសសម្រាប់ការងារដូចគ្នា ហើយស្ត្រីច្រើនតែត្រូវបានជួលឱ្យធ្វើការនៅកន្លែងដែលត្រូវការជំនាញតិច ជាហេតុនាំឱ្យបានទទួលកម្រៃ

តារាង ៤.៤

ចំនួនការងារក្នុងផ្នែកវាយនភណ្ឌ និងកាត់ដេរក្នុងប្រទេសមួយចំនួននៅអាស៊ី

| | ឆ្នាំ | ចំនួនការងារ (ពាន់) | % នៃចំនួនការងារក្នុងផ្នែកកម្មន្តសាល |
|---|---|---|---|
| បង់ក្លាដេស | ២០០៤ | ១.៨០០ | គ្មានទិន្នន័យ |
| កម្ពុជា | ២០០៥ | ៤៧៣ | ៨០ |
| ចិន | ២០០៤ | ១៩.០០០ | ១៩ |
| ឥណ្ឌា | ២០០១ | ១.៦៤៥ | ២២ |
| ប៉ាគីស្ថាន | ២០០១ | ២.៣០០ | ៤៣ |
| ស្រីលង្កា | ២០០០ | ២៣៧ | ៤៩ |
| ម៉ូរីទ្យុស | ២០០១ | ៨៥ | ៧៣ |

**សម្គាល់ : សម្រាប់តួលេខចំនួនការងារសរុបក្នុងផ្នែកវាយនភណ្ឌ និងកាត់ដេរនៃប្រទេសកម្ពុជា : ចំនួនការងារក្នុងផ្នែកកាត់ដេរគឺចាប់ពីឆ្នាំ ២០០៥ ឯចំនួនការងារក្នុងផ្នែកវាយនភណ្ឌគឺពីឆ្នាំ ២០០០**

**ប្រភព: ILO ២០០៥**




រូបទី ៤.៣: ភាគរយនៃស្ត្រីនៅក្នុងការងារមានប្រាក់កម្រៃក្នុងផ្នែកវាយនភណ្ឌ និងសម្លៀកបំពាក់

ប្រភព : ផ្អែកលើ ILO ២០០៣ រូបសម្រាប់ប៉ាគីស្ថានដកស្រង់ពី Siegmann 2004

ទាប និងធ្វើការនៅផ្នែកខាងក្រោមនៃឧស្សាហកម្មនេះ ដូចជា ផ្នែកត្បាញ និងរវៃ ដោយមានឱកាសតិចតួចប៉ុណ្ណោះ ដើម្បីពង្រឹងជំនាញរបស់ខ្លួន។ សូម្បីតែនៅក្នុងឧស្សាហកម្មនៃប្រទេសស្រីលង្កា ដែលគម្លាតប្រាក់កម្រៃរវាងបុរសនិងស្ត្រី មិនសូវខុសគ្នាក៏ដោយ កម្មការិនីត្រូវទ្រាំទ្រនឹងទម្រង់ផ្សេងនៃការលំបាក ដូចជា ការបៀតបៀន បញ្ហាធ្វើដំណើរទៅមកកន្លែងធ្វើការ និងការទទួលខុសត្រូវពីរបែប ទាំងនៅក្នុងគ្រួសារ និងនៅកន្លែងធ្វើការ។

កម្មការិនីច្រើនតែប្រឈមនឹងទម្រង់នានានៃការបៀតបៀន។ ឧទាហរណ៍ នៅប្រទេសឥណ្ឌា នៅពេលដែលស្ត្រីកាន់តែច្រើនចូលប្រឡូកក្នុងការងារ អំពើហឹង្សាក្នុងគ្រួសារទំនងជាមានការកើនឡើង។ នៅក្នុងសង្គមខ្លះដែលយកបុរសជា

ប្រអប់ ៤.១

### ស្ត្រីក្នុងការងារនៅក្នុងឧស្សាហកម្មកាត់ដេរនៃប្រទេសបង់ក្លាដេស

ការពង្រីកការនាំចេញសម្លៀកបំពាក់ពីប្រទេសបង់ក្លាដេសបាននាំឱ្យមានកំណើនកាលានុវត្តភាពការងារសម្រាប់ស្ត្រីបង់ក្លាដេស ដែលបច្ចុប្បន្ននេះបានកើនឡើងដល់ ៨០% នៃកម្លាំងពលកម្ម ១.៨ លាននាក់នៅក្នុងវិស័យនេះ។ ប្រាក់ចំណូលរបស់ស្ត្រីបានកើនឡើងជាក់ស្តែងនៅពេលដែលប្រាក់កម្រៃប្រចាំថ្ងៃនៅក្នុងឧស្សាហកម្មកាត់ដេរ មានកម្រិតស្មើនឹងពីរដងនៃប្រាក់កម្រៃនៅក្នុងវិស័យកសិកម្មនិងសំណង់។ កំណើនចំនួនការងារសម្រាប់ស្ត្រី និងការមានប្រាក់ចំណូលរបស់ស្ត្រី បានធ្វើឱ្យស្ត្រីមានឥទ្ធិពលវិជ្ជមានទៅលើគ្រួសារ។ ស្ត្រីដែលបានចូលធ្វើការនៅក្នុងផលិតកម្មសម្លៀកបំពាក់សម្រាប់ការនាំចេញ បានរួមចំណែកប្រមាណ ៦% ទៅក្នុងប្រាក់ចំណូលប្រចាំគ្រួសារ ហើយប្រាក់ចំណូលរបស់ខ្លួនមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យគ្រួសារដែលមានសមាជិកច្រើនរស់នៅខ្ពស់ជាងខ្សែបន្ទាត់នៃភាពក្រីក្រ។ ដោយមានការត្រួតត្រាខ្លះទៅលើចំណែកនៃប្រាក់ចំណូលរបស់ខ្លួន ស្ត្រីបានវិនិយោគលើសុខភាព ការអប់រំ នឹងទំនងជាសន្សំបានច្រើនជាងមុន។

កំណើនប្រាក់ចំណូលនៅក្នុងឧស្សាហកម្មនេះ ក៏ផ្តល់នូវឥទ្ធិពលវិជ្ជមានទៅលើកម្រិតអប់រំរបស់ស្ត្រីផងដែរ។ លទ្ធផលនៃការអង្កេតបង្ហាញថា ស្ត្រី ៧៨% បានទទួលយ៉ាងហោចណាស់ការចូលរៀន រយៈពេលមួយឆ្នាំនៅក្នុងឆ្នាំ ១៩៩៧ ធៀបនឹង ៦៥% នៅក្នុងឆ្នាំ ១៩៩០ (Paulmajumder and Begum ២000)។ ឯករាជ្យភាព និងកាលានុវត្តភាពសេដ្ឋកិច្ចក្នុងការលើកកម្ពស់កម្រិតអប់រំ បានបង្កើនសិទ្ធិអំណាចរបស់ពួកគេនៅក្នុងគ្រួសារ (Bhattarcharya and Rhaman ១៩៩៩)។

ទោះជាយ៉ាងនេះក្តី នៅក្នុងឧស្សាហកម្មនេះ ស្ត្រីនៅតែទទួលការរើសអើងខាងយេនឌ័រផងដែរ:

*គម្លាតលើប្រាក់កម្រៃ* សូម្បីតែអត្រា កំណត់ និងប្រាក់កម្រៃជាក់ស្តែង នៅក្នុងវិស័យ T&C បានកើនឡើងនៅក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះក្តី ស្ត្រីបានបានទទួលផលតិចជាងបុរសយ៉ាងខ្លាំង។ ប្រាក់កម្រៃបានកើនឡើងភាគច្រើន សម្រាប់កម្មករដែលមានជំនាញ ដែលជាធម្មតាគឺជាបុរស។ រវាងឆ្នាំ ១៩៩០ និង ១៩៩៧ គម្លាតប្រាក់កម្រៃរវាង បុរសនិងស្ត្រីបានកើនឡើង។ ប្រាក់កម្រៃសម្រាប់ស្ត្រីធ្លាក់ចុះសមាមាត្រនឹង ៦៦% នៃប្រាក់កម្រៃសម្រាប់បុរសនៅក្នុង ឆ្នាំ ១៩៩០ រហូតដល់ ៥៩% នៅក្នុងឆ្នាំ ១៩៩៧។ សូម្បីនៅមានការត្រួតពិនិត្យលើជំនាញក៏ដោយ គម្លាតរវាងប្រាក់កម្រៃទាក់ទងនឹងយេនឌ័រ នៅតែបន្តជាដរាប។

*ការដាក់ឱ្យធ្វើការងារដែលត្រូវការជំនាញទាប* ស្ត្រីត្រូវបានជ្រើសរើសឱ្យចូលធ្វើការងារដែលត្រូវការជំនាញទាប ដូចជា កម្មករផលិតកម្ម ឬជំនួយការ ដែលមានឱកាសតិចតួចសម្រាប់ការឈានទៅតួនាទីដែលត្រូវការជំនាញខ្ពស់ និងដែលផ្តល់កម្រៃប្រសើរជាង នៅក្នុងផ្នែកចាត់ចែង និងគ្រប់គ្រង។ លើសពីនេះ នៅពេលមានការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មី កម្មករជាស្ត្រីច្រើន តែពុំបានទទួលការបណ្តុះបណ្តាលដើម្បីប្រើប្រាស់បច្ចេកវិទ្យាទាំងនោះទេ។

*ការថែទាំសុខភាពនិងការឈប់សម្រាក* លទ្ធផលពីការអង្កេតក៏ឱ្យដឹងផងដែរថា ស្ត្រីពុំបានទទួលការព្យាបាលប្រមាណ ៤០% នៃរោគនិងជម្ងឺរបស់ខ្លួន ចំណែកបុរសសមាមាត្រនេះមានតែ ៣៣% ប៉ុណ្ណោះ។ មានតែកម្មករជាស្ត្រី ៣៥% តែប៉ុណ្ណោះ ដែលបានដាក់ពាក្យសុំឈប់សម្រាក និងបានទទួលការអនុញ្ញាតតាមសំណើធៀបនឹង ៦០% សម្រាប់កម្មករជាបុរស។

**ប្រភព: Tran-Nguyen and Zampetti ២00៤។**

ប្រអប់ ៤.២

### លក្ខខណ្ឌការងារដ៏លំបាកនៅក្នុងឧស្សាហកម្មកាត់ដេរក្នុងក្រុងដេលី

នៅភាគខាងជើងនៃប្រទេសឥណ្ឌា ៩០% នៃសម្លៀកបំពាក់ត្រូវបានផលិតសម្រាប់ការនាំចេញ និងមានទីតាំងនៅក្នុងទីក្រុងដេលី។ រោងចក្រកាត់ដេរទាំងនោះប្រើប្រាស់កម្មករជិត ១០៣.០០០ នាក់ ដែលត្រូវជា ៦% នៃពលករក្នុងវិស័យឧស្សាហកម្មទាំងអស់ហើយនៅក្នុងឆ្នាំ២០០១ ពួកគេបានរួមចំណែកចំនួន ៣៥% នៃប្រាក់ចំណូលរបស់ប្រទេសដែលបានពីការនាំចេញសម្លៀកបំពាក់។

ឧស្សាហកម្មនេះមានភាពប្លែកគ្នាជាខ្លាំង។ រោងចក្រធំៗប្រកបដោយគ្រឿងចក្រ បង្កើតផលិតផលតាមស្តង់ដារ ដែលត្រូវគ្នានឹងវត្ថុមានយ៉ាងច្រើននៃបណ្តាញអ្នកម៉ៅការដែលបង្កើតផលិតផលអតិពលកម្មក្នុងនោះមានតែ ២០% ដែលបានចុះឈ្មោះនៅក្នុងវិស័យ "ផ្លូវការ"។ ទោះបីវាជារោងចក្រខ្នាតធំ ឬរោងកាត់ដេរតូចតាច (karkhanas) ក្តី រោងចក្រកាត់ដេរទាំងនេះព្យាយាមទូទាត់ថ្លៃចំណាយទូទៅ ដោយកាត់បន្ថយការចំណាយលើការងារប្រតិបត្តិ។ ពួកគេឱ្យកម្មករធ្វើការរយៈពេលជាច្រើនម៉ោង ដោយមានការឈប់សម្រាកតិចតួច និងប្រើប្រាស់ម៉ាស៊ីនដែលចាស់ហួសសម័យ។ ថ្លៃចំណាយត្រូវបានរក្សាឱ្យនៅទាប ដោយផ្តល់ប្រាក់កម្រៃទាប និងបញ្ចៀសកាតព្វកិច្ចនានា ដែលជាលក្ខខណ្ឌសម្រាប់និយោជកនៅក្នុងវិស័យផ្លូវការ។ ប្រព័ន្ធផលិតកម្មដែលបត់បែនបានក៏នាំឱ្យកម្មករបាត់បង់ជំនាញផងដែរ ដែលធ្វើឱ្យទន់ខ្សោយប្រព័ន្ធកសាងជំនាញដែលផ្អែកលើប្រពៃណីពីបុរាណ។

**ប្រភព: Verma ២០០៤។**

ជំហរ ប្រការនេះអាចកើតឡើងដោយសារស្ត្រីដែលឈានហួសតួនាទីក្នុងផ្ទះ ហើយក្លាយជាអ្នករកប្រាក់ចិញ្ចឹមគ្រួសារ ត្រូវបានចាត់ទុកថាជាការគម្រាមកំហែង។ សូម្បីតែនៅក្រៅគ្រួសារ និងសង្គមនៃក្រុមមនុស្សជុំវិញខ្លួនក៏ដោយ កម្មការិនីច្រើនតែក្លាយជាជនរងគ្រោះនៃការកេងប្រវ័ញ្ច ការជិះជាន់សង្កត់សង្កិន និងការរំខាននៅកន្លែងធ្វើការរបស់ខ្លួន។

ប្រអប់ ៤.៣

### LDCs: អ្នកទទួលផលចម្បងពីកិច្ចព្រមព្រៀងពហុសរសៃអំបោះ

កិច្ចព្រមព្រៀងពហុសរសៃអំបោះបានផ្តល់នូវអត្ថប្រយោជន៍ដោយឡែកសម្រាប់ ប្រទេស LDCs មួយចំនួន។

*បង់ក្លាដេស* ចាប់ពីឆ្នាំ ១៩៨១ មក រោងចក្រកាត់ដេរនៅបង់ក្លាដេសបាន លូតលាស់ក្នុងអត្រា ២០%ក្នុងមួយឆ្នាំ ដែលមានចំនួនរោងចក្រកើនឡើងពី ៧០ ទៅ ប្រមាណ ៣.០០០ ។ ផលិតផលនាំចេញដែលនៅក្នុងឆ្នាំ ១៩៨៣ មានត្រឹម ៣.៩% នៃផលនាំចេញសរុប បានកើនឡើងដល់ ៨៦% នៅឆ្នាំ ២០០២។

*នេប៉ាល់* ឧស្សាហកម្មកាត់ដេរនៅនេប៉ាល់បានកើនឡើងដោយសារលទ្ធផលផ្ទាល់នៃការដាក់កំហិតលើការនាំចេញពីឥណ្ឌា។ ការនាំចេញសម្លៀកបំពាក់បាននាំមកនូវផលចំណេញច្រើន និងនាំមកនូវចំណូល ១៦២ លានដុល្លារ នៅឆ្នាំ ២០០៣ ប៉ុន្តែអត្រានេះ បានធ្លាក់ចុះមកត្រឹម ១៨% នៅក្នុងរយៈពេល ៨ ខែដើមដំបូងនៃឆ្នាំ ២០០៤ (EIU ២០០៤)។ នៅដំណាក់កាលកំពូលរបស់ខ្លួននាដើមទសវត្សរ៍ឆ្នាំ ១៩៩០ វិស័យវាយនភណ្ឌរបស់ប្រទេសនេប៉ាល់បានប្រើប្រាស់កម្មករច្រើនជាង ១០០.០០០ នាក់។

*កម្ពុជា* នៅក្នុងអំឡុងទសវត្សរ៍មុននេះ របបកូតាសម្រាប់ការនាំចេញសម្លៀកបំពាក់បានអនុញ្ញាតឱ្យប្រទេសកម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលលូតលាស់រហ័សខាងការនាំចេញសម្លៀកបំពាក់។ រវាងឆ្នាំ ១៩៩៥ និង២០០៣ ប្រាក់ចំណូលពីការនាំចេញបានកើនឡើងពី ២៦ លានដុល្លារ ដល់ ១.៦០០ លានដុល្លារ ដែលនៅពេលនោះ ការនាំចេញមាន ៩០% នៃផលនាំចេញពីប្រទេសនេះ។ ឧស្សាហកម្មនេះបានជួលកម្មករច្រើនជាងគេនៅក្នុងប្រទេស។ ប្រមាណ ៩០% នៃកម្មករគឺមកពីទីជនបទ។ ប្រាក់ដែលបានផ្ញើទៅគ្រួសារវិញមានប្រមាណពីរភាគបីនៃប្រាក់កម្រៃប្រចាំខែ ៦០-៧០ ដុល្លារ។ ប្រាក់ដែលបានផ្ញើទៅឱ្យគ្រួសារមានឥទ្ធិពលយ៉ាងសំខាន់លើភាពក្រីក្រនៅជនបទ ដោយសារភាគច្រើន នេះជាប្រភពចម្បងតែមួយគត់នៃប្រាក់ចំណូលសម្រាប់គ្រួសារ និងជួយបង្កើតការងារផ្សេងៗទៀតនៅក្នុងជនបទ។ ដោយសារ ៩០% នៃកម្មករនៅក្នុងរោងចក្របែបនេះជាស្ត្រី ការពង្រីកឧស្សាហកម្មបែបនេះក៏ផ្តល់អំណាចខ្លាំងក្លាផងដែរ។

## ការផ្លាស់ប្ដូររបបពាណិជ្ជកម្ម

កិច្ចព្រមព្រៀងពហុសរសៃអំបោះ (MFA) បានដាក់កំហិតទៅលើការនាំចូលវាយនភណ្ឌ និងសម្លៀកបំពាក់ ដោយកំណត់កូតាសម្រាប់ប្រទេសនាំចេញ។ ផលិតករធំៗ ដូចជា ចិន និងឥណ្ឌានឹងឈានដល់កម្រិតកំពូលនៃកូតារបស់ខ្លួនយ៉ាងឆាប់រហ័ស ប៉ុន្តែប្រទេសដទៃមួយចំនួនមិនអាចប្រើប្រាស់កូតារបស់ខ្លួនអស់ឡើយ ហើយធ្វើការអភិវឌ្ឍឧស្សាហកម្ម T&C ដើម្បីទាញយកប្រយោជន៍ពីប្រការនេះ។ ឧទាហរណ៍ ប្រទេសហ្វីលីពីន ដែលកាលពីមុនមិនបានក្លាយជាអ្នកនាំចេញច្រើននោះបានរៀបចំខ្លួនជាស្រេច ដើម្បីពង្រីកឧស្សាហកម្មរបស់ខ្លួន ដែលនៅឆ្នាំ ២០០៤ បានបញ្ជូនច្រើនជាង ៨០% នៃការនាំចេញសម្លៀកបំពាក់របស់ខ្លួនទៅតាមកូតាទីផ្សារនៅអឺរ៉ុប និងអាមេរិក។ LDCs ដូចជាបង់ក្លាដេស និងកម្ពុជា បានទទួលផលប្រយោជន៍បន្ថែមទៀត ដោយសារស្ថានភាព LDCs របស់ខ្លួនផ្ដល់លទ្ធភាពក្នុងការនាំចេញដោយអនុវត្តប្រព័ន្ធគ្មានកូតា និងឥតពន្ធនៅក្នុងទីផ្សារសហភាពអឺរ៉ុប (ប្រអប់ ៩.៣)។

សម័យកាលបែបនេះបានកន្លងផុតហើយ។ ដោយសារសម្ពាធពីប្រទេសដែលជាអ្នកនាំចេញធំៗខ្លះ ក៏ដូចជាពីអ្នកលក់រាយនៅក្នុងប្រទេសនាំចូល នៅឆ្នាំ ១៩៩៤ អង្គការ WTO បានបង្កើតកិច្ចព្រមព្រៀងស្ដីពីវាយនភណ្ឌ និងសម្លៀកបំពាក់ (T&C) ដែលយោងតាមកិច្ចព្រមព្រៀងនោះ ចាប់ពីឆ្នាំ ១៩៩៥មក ការដាក់កំហិតតាមរយៈកូតា MFA នឹងត្រូវលុបចោលតាមដំណាក់កាលជាបន្តបន្ទាប់។ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៤ កូតានៃក្រុមផលិតផលដែលជាប្រយោជន៍សម្រាប់អ្នកនាំចេញជាប្រទេសក្រីក្រ ត្រូវបានបាត់បង់ទាំងស្រុង រីឯវាយនភណ្ឌ និងសម្លៀកបំពាក់ត្រូវបានរួមបញ្ចូលទៅក្នុងប្រព័ន្ធពាណិជ្ជកម្មសេរីរបស់ WTO។[១០]

ទោះជាយ៉ាងណាក៏ដោយ កម្លាំងសរុបនៃ ATC ត្រូវបានទូទាត់ដោយកត្តាមួយចំនួន ដែលនៅបន្តជាឧបសគ្គចំពោះការនាំចូលពីបណ្ដាប្រទេសនៅអាស៊ី។

*ការពារពីការរំខានពីប្រទេសចិន* ៖ នៅពេលប្រទេសចិនចូលជាសមាជិក WTO ក្នុងឆ្នាំ ២០០១ កិច្ចព្រមព្រៀងសមាជិកភាពបានរួមបញ្ចូលការគាំពារ ដើម្បីការពារប្រទេសនាំចូលពី "ការរំខានខាងទីផ្សារ"។ ប្រការនេះបានអនុញ្ញាតឱ្យប្រទេសនាំចូលដាក់ស្នើ "កម្រិតហាមឃាត់" ដែលនឹងត្រូវដាក់ឱ្យអនុវត្តរហូតដល់ចុងឆ្នាំ ២០០៨។ ប្រការនេះនឹងត្រូវអនុវត្តចំពោះគ្រប់ផលិតផល ប៉ុន្តែឥទ្ធិពលរបស់វា ទំនងជាមានកម្រិតខ្ពស់បំផុតសម្រាប់ T&C។

*ពន្ធលើការនាំចូល* ៖ ប្រទេសនាំចូលលែងអនុវត្តកូតាទៀតហើយ ប៉ុន្តែ គេនៅមានការរើសអើងរវាងប្រទេសនាំចេញតាមរយៈអត្រាពន្ធ។ នេះជាឧបករណ៍ដែលមានប្រសិទ្ធិភាព ដោយសារអត្រាពន្ធមានកម្រិតខ្ពស់យ៉ាងខ្លាំងសម្រាប់ T&C ជាងសម្រាប់ផលិតផលឧស្សាហកម្មផ្សេងទៀត។ ឧទាហរណ៍ នៅស.រ.អា ពន្ធជាមធ្យមលើផលិតផលឧស្សាហកម្មគឺ ៣.៥% ប៉ុន្តែសម្រាប់ T&C គឺ ១៤.៦%។ ចំពោះសហភាពអឺរ៉ុប តួលេខត្រូវគ្នានេះគឺ ៣.៦% និង ៩.១% និងសម្រាប់ជប៉ុន ១.៧% និង ៧.៦%។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសនាំចូលផ្ដល់សម្បទានលើពន្ធទាំងនេះឱ្យដល់ប្រទេសខ្លះដែលទទួលការអនុគ្រោះ។ ឧទាហរណ៍ ស.រ.អាផ្ដល់អត្រាពន្ធទាបដល់ប្រទេសនានានៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង (NAFTA) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកកណ្ដាល (CAFTA) និងបានផ្ដល់អត្រាអនុគ្រោះដល់ប្រទេសមួយចំនួននៅអាហ្វ្រិកផងដែរ តាមរយៈច្បាប់កំណើន និងកាលានុវត្តភាពសម្រាប់អាហ្វ្រិក (AGOA)។ ដូចគ្នានេះដែរ សហភាពអឺរ៉ុបមិនយកពន្ធពីអ្នកនាំចេញទាំងអស់ដែលជាប្រទេសសមាជិកឡើយ ដែលរួមបញ្ចូលប្រទេសមួយចំនួននៅអឺរ៉ុបកណ្ដាល និង

ខាងកើត ដែលផលិតវាយនភណ្ឌ និងសម្លៀកបំពាក់។ តាមរយៈយន្តការទាំងអស់របស់ខ្លួន លើកលែងតែកិច្ចព្រមព្រៀងសញ្ញវុធ (EBA) សហភាពអឺរ៉ុបលើកលែងពន្ធសម្រាប់ការនាំចូលទំនិញពីប្រទេស LDCs ទាំងអស់។

*ច្បាប់ប្រឆាំងការលក់បង្ខូចថ្លៃ:* ប្រទេសនាំចូលក៏អាចសម្រេចបញ្ឈប់ការនាំចូលពីប្រទេសនានានូវទំនិញដែលទំនងជាបាននាំចូលដោយថ្លៃទាបបំផុត រហូតដល់ទាបជាងថ្លៃផលិតទៅទៀត។ ឧទាហរណ៍ សហភាពអឺរ៉ុបបានចាត់វិធានការជាញឹកញាប់ប្រឆាំងការលក់បង្ខូចថ្លៃ។ រវាងឆ្នាំ ១៩៩៣ និង ១៩៩៨ សហភាពអឺរ៉ុបបានចាត់វិធានការប្រឆាំងនឹងផលិតផលក្រណាត់កប្បាសពីប្រទេសឥណ្ឌា ឥណ្ឌូណេស៊ី និងប៉ាគីស្ថាន។ ជាញឹកញាប់សកម្មភាពបែបនេះធ្វើឡើងផ្អែកលើព័ត៌មានមិនពិត។[១១] សកម្មភាពបែបនេះមិនទំនងជានឹងត្រូវលុបចោលទេនៅក្រោយការលុបចោលកូតា។[១២]

*របាំងបច្ចេកទេស:* ប្រទេសនានាក៏អាចដាក់ឱ្យអនុវត្តស្តង់ដារបច្ចេកទេសថ្មីផងដែរ។ មាត្រានៅក្នុងការចរចាប្រទេសអ៊ុយរ៉ាហ្គាយបានទុកចោលភាពមិនច្បាស់លាស់ជាច្រើន ដោយនិយាយថា ត្រូវដាក់ឱ្យអនុវត្តស្តង់ដារបច្ចេកទេសតាមវិធីដែលមិនអាចបង្ហាញថាមានភាពរើសអើងរវាងអ្នកទិញពីបរទេស និងក្នុងប្រទេស។ ទោះជាយ៉ាងណាក៏ដោយ មកទល់ពេលនេះពុំទំនងជាមានការកើនឡើងនូវការប្រើប្រាស់យន្តការនេះសម្រាប់កិច្ចការពារនិយមឡើយ។[១៣]

## អ្នកឈ្នះ និង អ្នកចាញ់

ការផ្លាស់ប្តូរទៅរបបពាណិជ្ជកម្មអន្តរជាតិ និងវិធីជាច្រើន ដែលនៅក្នុងនោះ ប្រទេសនាំចូលអាចបង្កើតទម្រង់នៃការនាំចូល បានបង្កើតភាពពុំប្រាកដប្រជានៅក្នុងឧស្សាហកម្មវាយនភណ្ឌនិងសម្លៀកបំពាក់នៅលើពិភពលោក។ ក្នុងចំណោមអ្នកឈ្នះនៅក្នុងបរិស្ថានថ្មីនេះ គឺជាអ្នកទិញ T&C នៅក្នុងប្រទេសនាំចូល ដែលឥឡូវនេះមានសេរីភាពច្រើនជាងមុន ដើម្បីជ្រើសរើសយកពីប្រទេសដទៃឬអ្នកផ្គត់ផ្គង់ដែលផ្តល់បង្គុំតម្លៃសមស្រប ការប្រគល់ទំនិញប្រកបដោយគុណភាព និងល្បឿនលឿន។ អ្នកដែលទំនងជាចំណេញដែរនោះ គឺប្រទេសអ្នកនាំចេញធំៗ ដែលកាលពីមុន ត្រូវបានរារាំងដោយប្រព័ន្ធកូតា។ នៅទីនេះ ផលិតករដែលមានប្រសិទ្ធិភាពខ្ពស់ជាងគេគួរតែអាចពង្រីកការប្រតិបត្តិរបស់ខ្លួន ដោយជួលមនុស្សកាន់តែច្រើន និងផ្តល់ប្រយោជន៍ដល់អ្នកប្រើប្រាស់តាមរយៈអត្រាថ្លៃទាប។

អ្នកចាញ់គឺប្រទេសតូចៗខ្លះដែលបានទាញយកចំណេញពីកូតានៅក្នុង MFA។ ទោះបីពួកគេអាចទាញយកប្រយោជន៍ពីកាលានុវត្តភាពដែលមានក្តី ឧស្សាហកម្ម T&C របស់ប្រទេសទាំងនោះអាចនៅតែពុំមានភាពប្រកួតប្រជែងជាអន្តរជាតិ ដូច្នេះពួកគេទំនងជានឹងត្រូវបាត់បង់ទីផ្សារនាំចេញ ដោយមានឥទ្ធិពលសេដ្ឋកិច្ចធ្ងន់ធ្ងរទៅលើចំនួនការងារ និងប្រាក់ចំណូល។

ការសិក្សាមួយចំនួនបានព្យាយាមវាយតម្លៃផលប៉ះពាល់សរុបនៃបរិយាកាសថ្មី។ ការសិក្សានោះមានភាពខុសគ្នាមួយចំនួន ប៉ុន្តែមានការឯកភាពថា ជារួមនឹងមានកំណើនការនាំចេញពីអាស៊ីហើយអត្ថប្រយោជន៍ទទួលបាននឹងពុំស្មើគ្នាទេ។ អ្នកឈ្នះចម្បងគឺចិន និងឥណ្ឌា ដែលមានជំហរក្នុងការផ្គត់ផ្គង់ទំនិញប្រកបដោយភាពប្រកួតប្រជែងតាមតម្លៃគ្រប់កម្រិត និងគុណភាពទាំងអស់។ អ្នកចាញ់អាចនឹងរួមបញ្ចូលប្រទេសជាអ្នកនាំចេញតូចៗ ដែលធ្លាប់បានទទួលប្រយោជន៍ពីប្រព័ន្ធកូតា។

តើមានអ្វីដែលបានកើតឡើង? ទោះបីការលុបចោលកូតាទើបតែកន្លងផុតទៅរយៈពេលខ្លីនេះក៏ដោយ លទ្ធផលទំនងជាមានស្ថានភាពដូចដែលបានព្យាករណ៍ទុក។ UNDP បានវិភាគលំហូរ T&C ទៅស.រ.អា[១៤] ដោយលទ្ធផលមាន

*ក្នុងចំណោមអ្នកឈ្នះនៅក្នុងបរិស្ថានថ្មីនេះ គឺជាអ្នកទិញ T&C នៅក្នុងប្រទេសនាំចូល ដែលឥឡូវនេះមានសេរីភាពច្រើនជាងមុន ដើម្បីជ្រើសរើសយក ពីប្រទេសដទៃ ឬអ្នកផ្គត់ផ្គង់ដែលផ្តល់បង្គុំតម្លៃសមស្រប ការប្រគល់ទំនិញប្រកបដោយគុណភាព និងល្បឿនលឿន។ អ្នកដែលទំនងជាចំណេញដែរនោះ គឺប្រទេសអ្នកនាំចេញធំៗ ដែលកាលពីមុន ត្រូវបានរារាំងដោយប្រព័ន្ធកូតា។ នៅទីនេះ ផលិតករដែលមានប្រសិទ្ធិភាពខ្ពស់ជាង គេគួរតែអាចពង្រីកការប្រតិបត្តិរបស់ខ្លួន ដោយជួលមនុស្សកាន់តែច្រើន និងផ្តល់ប្រយោជន៍ដល់អ្នកប្រើប្រាស់តាមរយៈអត្រាថ្លៃទាប។ អ្នកចាញ់គឺប្រទេសតូចៗខ្លះ ដែលបានទាញយកចំណេញពីកូតានៅក្នុង MFA។*

បង្ហាញជូននៅក្នុងតារាងទី ៤.៥ និង ៤.៦។

ការវិភាគតួលេខរបស់ស.រ.អា និងសហភាពអឺរ៉ុប អំពីប្រទេសចំនួន ១២ ពីអាស៊ី នៅដំណាក់កាលដំបូងក្រោយចប់ប្រព័ន្ធកូតា នាំឱ្យមានការសន្និដ្ឋានបណ្ដោះអាសន្នដូចតទៅ:

១. នៅឆ្នាំ ២០០៥ ភាគហ៊ុនរបស់ផលិតករចម្បងៗ ចំនួន ១២ នៅក្នុងទីផ្សារនាំចេញ T&C សរុប ទៅស.រ.អាបានកើនឡើង ៨.៤% និងទៅសហភាពអឺរ៉ុបកើនឡើង ៦%។ ប្រការនេះស្របគ្នាជាមួយអត្រាកំណើនដែលមានកន្លងមក។ ដូច្នេះ ការបញ្ចប់ប្រព័ន្ធកូតាពុំនាំឱ្យមានការឃើញច្បាស់អំពីកំណើនការនាំចូលនៅក្នុងផ្សារទាំងនេះឡើយ ឬនាំឱ្យមានការផ្លាស់ប្ដូរផលិតករនៅក្នុងប្រទេស និងបាត់បង់ចំនួនការងារឡើយ។ ទោះបីមានកំណើនការប្រកួតប្រជែងក៏ដោយ ថ្លៃក្នុងមួយឯកត្តានៃផលនាំចូលមិនបានធ្លាក់ចុះខ្លាំងនោះនោះឡើយហើយ ប្រការនេះធ្វើឱ្យផលិតករ T&C នៅស.រ.អា និងសហភាពអឺរ៉ុបធន់ទ្រាំចំពោះការប្រកួតប្រជែង។ លើសពីនេះ កិច្ចការពារដែលមាន

តារាង ៤.៥

វាយនភណ្ឌនិងសម្លៀកបំពាក់នាំចូល ស.រ.អា និងសហភាពអឺរ៉ុប ២០០៤ និង ២០០៥

| ប្រទេស | ការនាំចូលរបស់ ស.រ.អា និង សហភាពអឺរ៉ុប | | | | | |
|---|---|---|---|---|---|---|
| | បរិមាណ (ពាន់ដុល្លារ) | | | បរិមាណ (ពាន់ដុល្លារ) | | |
| | ២០០៤ | ២០០៥ | % ប្រែប្រួល | ២០០៤ | ២០០៥ | % ប្រែប្រួល |
| បង់ក្លាដេស | ៦.៨៣១.៥២៩ | ៦.៩៨៦.៣៧១ | ២.៣ | ៧៧២.៣៩៨ | ៨០៥.០៧៤ | ៤.២ |
| កម្ពុជា | ២.០៧៧.២៨៧ | ២.៣០៩.៣០២ | ១១.២ | ១៣៩.៥៨២ | ១៥៧.៣៣៧ | ១២.៧ |
| ចិន | ៣៣.១៨៤.១៨៨ | ៤៨.៣២៨.៦៤០ | ៤៥.៦ | ៣.៤១៥.៨៤៦ | ៤.៩០២.៩១៣ | ៤៣.៥ |
| ឥណ្ឌា | ៩.៤៦១.៦៦២ | ១១.៤៩៨.៧១១ | ២១.៥ | ១.២០១.៦៥៧ | ១.៣៣៦.៦៤៥ | ១១.២ |
| ឥណ្ឌូណេស៊ី | ៤.៧៨០.៤៣៧ | ៥.០៦១.៨៩៩ | ៥.៩ | ៤៧៥.៩០៩ | ៤.៩៦.៣៦២ | ៤.៣ |
| ឡាវ | ១៤៩.១៣៥ | ១៥០.៨៩៩ | ១.២ | ១០.១៤៥ | ១០.៣៣០ | ១.៨ |
| នេប៉ាល់ | ២២៩.៣២២ | ១៨៩.២៩៧ | -១៧.៥ | ១៨.៩២១ | ១៣.៣៥៨ | -២៩.៤ |
| ប៉ាគីស្ថាន | ៥.៤៣៨.១០៦ | ៥.៣៩៣.៧៧៤ | -០.៨ | ៩៤៧.៣២០ | ១.០០០.៨៦០ | ៥.៧ |
| ហ្វីលីពីន | ២.៣១៩.៥០២ | ២.១៨៧.៣៥១ | -៥.៧ | ១៦២.៣៦៤ | ១៤៥.៩៣០ | -១០.១ |
| ស្រីលង្កា | ២.៦៤៦.៩៦៧ | ២.៧២៧.២០០ | ៣.០ | ២១២.២៩៧ | ២០៦.៥៩៦ | -២.៧ |
| ថៃ | ៣.៦៦៩.៣៨៥ | ៣.៥១៩.៦៩៧ | -៤.០ | ៣៣០.០៨៦ | ៣៣២.៧១៧ | ០.៨ |
| វៀតណាម | ៣.៤៧៨.៩៩០ | ៣.៦៨៧.០៥៥ | ៦.០ | ២៧៣.៥៩៣ | ២៧៤.៩០២ | ០.៥ |
| អាស៊ាន-១២ | ៧៤.២៦២.៩១០ | ៩២.០៤០.២១៥ | ២៣.៩ | ៧.៩៦០.១១៨ | ៩.៦៨៣.០២៤ | ២១.៦ |

ប្រភព: Adhikari និង Yamamoto ២០០៦

បកស្រាយខាងក្រោមត្រូវបានស្នើឱ្យអនុវត្ត ជាពិសេស ដើម្បីទប់ទល់នឹងការនាំចូលពីប្រទេសចិន។

២. ផលិតករចម្បង៧ទាំង ១២ នៅអាស៊ី និងអ្នកនាំចេញ បានបង្កើតរួមគ្នានូវភាគចំណែករបស់ខ្លួនទាំងនៅក្នុងទីផ្សារស.រ.អា និងសហភាពអឺរ៉ុប។ ជារួមនៅក្នុងទីផ្សារទាំងពីរនេះ ភាគចំណែកទាំងពីរនេះសរុបគ្នា បានកើនឡើងពី ៤៤% នៅក្នុងឆ្នាំ ២០០៤ រហូតដល់ច្រើនជាង ៥១% នៅឆ្នាំ ២០០៥។ កំណើននេះទទួលបានទន្ទឹមនឹងការបង់ខាតរបស់ប្រទេសនានានៅអាមេរិកឡាទីន ការ៉ាអ៊ីប និងតំបន់ផ្សេងទៀត។

៣. ក្នុងចំណោមប្រទេសនាំចេញនៅអាស៊ី ប្រទេសចិននិងឥណ្ឌាបានទទួលកំណើនច្រើនជាងគេ។ នៅក្នុងទីផ្សាររួមបញ្ចូលគ្នា (ស.រ.អា និងសហភាពអឺរ៉ុប) ភាគចំណែករបស់ប្រទេសចិនបានកើនឡើងពី ២០% ទៅ ២៧% រីឯភាគចំណែករបស់ប្រទេសឥណ្ឌាបានកើនឡើងពី ៥% ទៅច្រើនជាង ៦%។ ភាគចំណែករបស់កម្ពុជា ឥណ្ឌូណេស៊ី និងវៀតណាម ជាទូទៅមិនប្រែប្រួលទេ។

៤. អ្នកដែលបង់ខាតនៅដំណាក់កាលដំបូងនេះទាក់ទងនឹងការថយចុះនូវតម្លៃសរុបនៃការនាំចេញទៅទីផ្សារ ស.រ.អា និងសហភាពអឺរ៉ុបរួមគ្នាគឺប្រទេសនេប៉ាល់ ហ្វីលីពីន ថៃ និងប៉ាគីស្ថាន (រូបទី ៤.៤)។

តារាង ៤.៦

ភាគចំណែកនៃតម្លៃលើវាយនភណ្ឌ និងសម្លៀកបំពាក់ (%)

| ប្រទេស | ស.រ.អា | | សហភាពអឺរ៉ុប | |
|---|---|---|---|---|
| | ២០០៤ | ២០០៥ | ២០០៤ | ២០០៥ |
| បង់ក្លាដេស | ២.៣ | ២.៦ | ៥.៦ | ៥.០ |
| កម្ពុជា | ១.៧ | ១.៩ | ០.៧ | ០.៦ |
| ចិន | ១៧.២ | ២៤.២ | ២៣ | ៣០.៧ |
| ឥណ្ឌា | ៤.៦ | ៥.៤ | ៦.៨ | ៧.៥ |
| ឥណ្ឌូណេស៊ី | ៣.០ | ៣.៣ | ២.៦ | ២.២ |
| ឡាវ | - | - | - | - |
| ណេប៉ាល់ | ០.២ | ០.១ | ០.១ | ០.១ |
| ប៉ាគីស្ថាន | ២.៩ | ៣.១ | ៣.៦ | ៣.០ |
| ហ្វីលីពីន | ២.១ | ២.០ | ០.៥ | ០.៣ |
| ស្រីលង្កា | ១.៨ | ១.៨ | ១.៣ | ១.១ |
| ថៃ | ២.៥ | ២.៤ | ១.៩ | ១.៦ |
| វៀតណាម | ៣.០ | ២.៩ | ១.១ | ១.១ |
| អាស៊ាន-១២ | ៤១.៣ | ៤៩.៧ | ៤៧.២ | ៥៣.២ |
| តំបន់ផ្សេងទៀត | ៥៨.៧ | ៥០.៣ | ៥២.៨ | ៤៦.៨ |
| ពិភពលោក | ១០០.០ | ១០០.០ | ១០០.០ | ១០០.០ |

**ប្រភព: Adhikari និង Yamamoto ២០០៦**

## ប្រទេសចិន

សូម្បីតែនៅក្នុងសម័យកូតា ប្រទេសចិនបានក្លាយជាអ្នកនាំចេញធំជាងគេ។ នៅឆ្នាំ ២០០៣ ប្រទេសនេះមាន ២០% នៃការនាំចេញវាយនភណ្ឌនៅលើពិភពលោក ហើយ ២៨% នៃផលិតផលទាំងនោះគឺសម្លៀកបំពាក់។ ប៉ុន្តែ បរិមាណនេះមានកម្រិតខ្ពស់ជាងយ៉ាងច្រើនធៀបនឹងប្រទេសដទៃទៀត ខាងសមត្ថភាពក្នុងការឆ្លើយតបចំពោះកាលានុវត្តភាព ដែលផ្តល់ដោយលទ្ធភាពទីផ្សារប្រសើរជាងមុន ហើយគឺពិតជាប្រទេសដែលទទួលផលបានច្រើនជាងគេនៅក្នុងរបបពាណិជ្ជកម្មពិភពលោកក្រោយ MFA។

ប្រទេសធំនៅអាស៊ីទទួលបានផលចំណេញជាច្រើន។ ប្រទេសនេះមានកម្លាំងពលកម្មដោយតម្លៃថោក ទោះបីមិនថោកជាងគេនៅលើពិភពលោកក្តី វាមានកម្រិតទាបគ្រប់គ្រាន់ក្នុងការធ្វើឱ្យប្រទេសជាច្រើនផ្សេងទៀតចុះខ្សោយ។ ប្រទេសនោះមានកម្លាំងពលករគ្របដោយផលិតភាព និងមានវិន័យខ្ពស់ ដោយពុំមានសហជីពកម្មករឯករាជ្យ។ ប្រទេសនេះមានបណ្តាញជំនួយយ៉ាងរឹងមាំដែលមានប្រភពពីហុងកុង និង តៃវ៉ាន់។ ប្រទេសនេះក៏មានទំនាក់ទំនងល្អខាងនាវាដឹកទំនិញ ដែលអាចឱ្យការបញ្ជូនទំនិញបានឆាប់រហ័សទៅស.រ.អា និងសហភាពអឺរ៉ុបផងដែរ។

នៅពេលបញ្ចប់កូតា ក្រុមហ៊ុនចិនបានចាត់ការយ៉ាងឆាប់រហ័ស ដើម្បីឆក់យកកាលានុវត្តភាពធំទូលាយនេះ។ បច្ចុប្បន្ន ប្រទេសចិននាំចូលប្រមាណពាក់កណ្តាលនៃវាយនភណ្ឌដែលខ្លួនត្រូវការ ដែលធ្វើឱ្យប្រទេសនេះក្លាយជាអ្នកនាំចូលធំជាងគេទីបីនៅលើពិភពលោក បន្ទាប់ពីស.រ.អានិងសហភាពអឺរ៉ុប។ ចិនក៏ជាប្រទេសនាំចូលកប្បាសនៅច្រើនជាងគេនៅលើពិភពលោក និងស្ថិតក្នុងចំណោមអ្នកនាំចូលសរសៃឡែនច្រើនជាងគេលើពិភពលោកផងដែរ។ ប៉ុន្តែទៅអនាគត អ្នកផ្គត់ផ្គង់ពីប្រទេសចិននឹងអាចរកបានប្រភពវាយនភណ្ឌកាន់តែច្រើនឡើងនៅក្នុងមូលដ្ឋាន។ នៅឆ្នាំ២០០៤ អ្នកផ្គត់ផ្គង់ទាំងនោះបាននាំចូលគ្រឿងម៉ាស៊ីន T&C ដោយតម្លៃ ៥.៥០០លានដុល្លារ ក្នុងនោះ ៤៣% នាំចូលពីសហភាពអឺរ៉ុបដែលអាចធ្វើឱ្យផលិតករចិន អាចបង្កើតផលិតផលប្រកបដោយគុណភាពខ្ពស់ទៅតាមកាលកំណត់ និងអាចប្រគល់ទំនិញយ៉ាងទៀងទាត់។ ប្រការទាំងនេះនឹងធ្វើឱ្យមានកំណើនចំនួនការងារយ៉ាងច្រើន។

ទោះជាយ៉ាងណាក៏ដោយ ការពង្រីកការនាំចេញរបស់ប្រទេសចិនប្រឈមនឹងការលំបាកខ្លះៗ។ នៅក្នុងរយៈពេលខ្លី ប្រទេសនាំចេញដែលបានបារម្ភអំពីកំណើនការនាំចេញរបស់ប្រទេសចិន អាចការពារខ្លួនដោយដាក់ចេញកូតា។ នៅក្នុងរយៈពេលមធ្យម នៅពេលដែលទីផ្សារអ្នកប្រើប្រាស់របស់ខ្លួនកើនឡើង ចិនទំនងជាស្រូបយកកាន់តែច្រើនឡើងនូវផលិតផលក្នុងស្រុករបស់ខ្លួន ក៏ដូចជាការនាំចូលពីប្រទេសដទៃផងដែរ។ នៅក្នុងរយៈពេលវែង ចិនក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ឧស្សាហកម្មនានាផ្សេងទៀតដែរទំនងជាបែរចេញពីការផលិតមុខទំនិញងាយៗដូចជា T&C ហើយធ្វើការសង្កត់ធ្ងន់ទៅលើផលិតផលឧស្សាហកម្មដែលទាមទារបច្ចេកវិទ្យាខ្ពស់ ដូចជាអេឡិចត្រូនិក។

ដូចការរំពឹងទុក ការនាំចេញរបស់ប្រទេសចិនបានកើនឡើងយ៉ាងឆាប់រហ័ស នៅក្រោយការបញ្ចប់របបកូតា។ រវាងឆ្នាំ ២០០៤ និង ២០០៥ តម្លៃសរុបនៃការនាំចេញទៅស.រ.អា និងសហភាពអឺរ៉ុបបានកើនឡើង ៤៦% ហើយបរិមាណការនាំចេញបានកើនឡើង៤៤% ។កំណើននេះកើតឡើងសម្រាប់ស្ទើរតែគ្រប់មុខផលិតផលសម្លៀកបំពាក់។ ទោះជាយ៉ាងណាក៏ដោយ អាចមានកត្តាពិសេសជាច្រើនដែលធ្វើឱ្យតួលេខនេះកើនឡើង។ ក្នុងករណីខ្លះការនាំចេញទាំងនេះ អាចជំនួសទំនិញដែលកាលពីមុនអាចត្រូវបាននាំចូលមក តាមរយៈតំបន់រដ្ឋបាល

*ប្រទេសចិនគឺពិតជាប្រទេសដែលទទួលផលបានច្រើនជាងគេនៅក្នុងរបបពាណិជ្ជកម្មពិភពលោកក្រោយ MFA*




រូបទី ៤.៤: កំណើនតម្លៃផលនាំចេញវាយនភណ្ឌនិងសម្លៀកបំពាក់ទៅ EU និង US ឆ្នាំ ២០០៤-២០០៥

ប្រភព : Adhikari and Yamamoto, 2006.

ពិសេសហុងកុង និងម៉ាកាវ ក៏ដូចជាតៃវ៉ាន់ផងដែរ។ អ្នកជំនួញខ្លះអាចឃើញប្រការនេះថាជាឱកាសដើម្បីបង្កើនការបញ្ជូនទំនិញចេញនៅមុនពេលដែលស.រ.អា និងសហភាពអឺរ៉ុបឆ្លើយតបតាមរយៈ វិធានការការពារ។

ដូចការរំពឹងទុក ស.រ.អា និងសហភាពអឺរ៉ុបបានចាប់ផ្តើមដាក់ការកំហិត។ ឧទាហរណ៍ នៅថ្ងៃ ២៣ ខែឧសភា ឆ្នាំ ២០០៥ ស.រ.អាបានដាក់កំហិតលើអាវចាក់ និងអាវវែងធ្វើពីកប្បាស ខោធ្វើពីកប្បាស ខោជើងវែង និងខោខ្លី និងសម្លៀកបំពាក់ក្នុងធ្វើពីកប្បាស និងសសៃសំយោគ។ ដូច្នេះ ប្រភេទទំនិញដែលរងការដាក់កំហិតស្ថិតក្នុងចំណោមមុខទំនិញដែលស្ថិតក្រោមការដាក់កំហិតកូតាធ្ងន់ធ្ងរកាលក្នុងរបប ATC។

ក្រុមហ៊ុនដែលផលិតទំនិញទាំងនេះ ដែលភាគច្រើនជាសហគ្រាសខ្នាតតូចនិងមធ្យមនឹងត្រូវរងគ្រោះធ្ងន់ធ្ងរ។ ដោយសារពួកគេអាចបំពេញកូតារបស់ខ្លួនតែក្នុងរយៈពេលប៉ុន្មានខែតែប៉ុណ្ណោះ ពួកគេត្រូវតែបញ្ឈប់ផលិតកម្មសំរាប់រយៈពេលដទៃទៀតនៅក្នុងឆ្នាំនីមួយៗ។ ប្រការនេះមានឥទ្ធិពលទៅលើចំនួនការងារប្រមាណ ១៤០.០០០ ដែលភាគច្រើនជាស្ត្រីក្មេងៗ ឬស្ត្រីពីជនបទ ដែលមិនស្ថិតនៅក្រោមបណ្តាញសុវត្ថិភាពសង្គមរបស់ប្រទេសចិន។

បន្ទាប់ពីមានវិធានការទាំងនេះ និងសំណើបន្ថែមជាបន្តបន្ទាប់មកទៀតដើម្បីឱ្យចាត់វិធានការការពារ នៅខែវិច្ឆិកា ឆ្នាំ ២០០៥ ស.រ.អា និងសហភាពអឺរ៉ុប បានឈានដល់កិច្ចព្រមព្រៀងទូលាយមួយ។ ជាការប្តូរនឹងលទ្ធភាពប្រើប្រាស់ទីផ្សារស.រ.អាប្រកបដោយការធានា ប្រទេសចិនបានឯកភាពដាក់កំហិតលើការនាំចេញរបស់ខ្លួនសម្រាប់រយៈពេលបីឆ្នាំទៅលើសម្លៀកបំពាក់ ៣៤បែប ដែលត្រូវជា ៤៦% នៃការនាំចេញវាយនភណ្ឌរបស់ចិនទៅស.រ.អា។ កិច្ចព្រមព្រៀងនេះអនុញ្ញាតឱ្យមានកំណើនជាមធ្យមប្រចាំឆ្នាំ ១១% ដែលជាអត្រាទាបជាងយ៉ាងខ្លាំងធៀបនឹងការទាមទាររបស់ចិន ពី ២០-៣០%។

នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥ សហភាពអឺរ៉ុបក៏ចាត់ឱ្យមានការស៊ើបអង្កេតទៅលើការនាំចូលរបស់ចិនផងដែរ ពោលគឺអាវយឺត អាវរងារចាក់ ខោជើងវែងបុរស អាវវែងស្រោមបា និងស្រោមជើង អាវស្ត្រីសម្រាប់ពាក់ពីខាងលើ អាវទ្រនាប់ស្ត្រី សរសៃកប្បាស និងក្រណាត់ត្បាញធ្វើពីកប្បាស។ កំណើននៃការនាំចូលអាវយឺតគឺជាការព្រួយបារម្ភដោយឡែក។ នៅក្នុងអំឡុងខែមករា-មេសា ឆ្នាំ ២០០៥ បរិមាណអាវយឺតនាំចូលពីប្រទេសចិន បានកើនឡើង ១៨៧% ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ ២០០៤។ កំណើនភាគចំណែករបស់ប្រទេសចិនពី ៧ ទៅ ១៥% បាននាំឱ្យការធ្លាក់ថ្លៃនាំចូល ៣៦%។ ការនាំចូលទាំងនេះបានជំនួសឱ្យការផលិតនៅក្នុងប្រទេសមួយចំនួននៅសហភាពអឺរ៉ុប រួមទាំងប្រទេសក្រិកព័រទុយហ្គាល់ និងស្លូវេនៀ និងបដិសេធនូវការនាំចូលដោយអ្នកផ្គត់ផ្គង់ពីមុនមកដូចជា ប្រទេសម៉ារ៉ុក ទុយនីស៊ី រ៉ូម៉ានី ស្រីលង្កា និងបង់ក្លាដេស។

នៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៥ សហភាពអឺរ៉ុប និងប្រទេសចិនបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ ដែលចែងពីការនាំចូលពីប្រទេសចិននូវផលិតផលចំនួន ១០បែប កំណត់កូតាសម្រាប់រយៈពេលនៅសល់ក្នុងឆ្នាំ ២០០៥ និងសម្រាប់ឆ្នាំ ២០០៦ និង ២០០៧ ដែលអនុញ្ញាតឱ្យមានកំណើនបរិមាណនាំចូល ១០% ក្នុងមួយឆ្នាំ។ ប៉ុន្តែនៅចុងខែសីហា ឆ្នាំ ២០០៥ ផលិតករប្រទេសចិនបានបំពេញកូតា ឬលើសកូតាទាំងនោះរួចទៅហើយ និងដោយសារទំនិញទាំងនោះត្រូវបានបញ្ជូនចេញផុតទៅហើយ វាត្រូវបានស្តុកទុកក្នុងឃ្លាំងនៅសហភាពអឺរ៉ុប ដែលទំនិញទាំងនោះមានតម្លៃច្រើនជាង ៧៥ លាន។ ក្រោយការចរចាបន្ថែម គណៈកម្មការអឺរ៉ុបបានឯកភាពឱ្យពាក់កណ្តាលនៃទំនិញនោះចូលលក់ ហើយប្រទេសចិនបាន

ឯកភាពថាទំនិញនៅសល់ក្រៅពីនោះត្រូវកាត់ចេញពីកូតាសម្រាប់ឆ្នាំ ២០០៦ ឬទូទាត់ជាមួយមុខទំនិញដែលពុំទាន់គ្រប់កូតា ។

បន្ថែមលើកិច្ចព្រមព្រៀងទាំងនេះជាមួយស.រ.អា និងសហភាពអឺរ៉ុប ប្រទេសចិនបានចាត់វិធានការជាឯកត្តោភាគី ដើម្បីកាត់បន្ថយការនាំចេញ ។ ឧទាហរណ៍ ប្រទេសនេះបានបន្ទាបអត្រាបង្វិល VAT មកវិញលើការនាំចេញ T&C និងយកពន្ធលើការនាំចេញផលិតផលមួយចំនួនដើម្បីលើកទឹកចិត្តសហគ្រាសចិនឱ្យប្តូរទៅផលិតផលដែលបន្ថែមតម្លៃខ្ពស់ជាងមុន ប៉ុន្តែក្រោយមកបានលុបចោលពន្ធទាំងនេះវិញ ក្រោយពីការដាក់កំហិតរបស់ស.រ.អា និងសហភាពអឺរ៉ុប ដើម្បីទប់ស្កាត់អ្នកនាំចេញវាយនភណ្ឌពីប្រទេសចិនពីការទទួលពិន័យទ្វេដង ។[១៥]

## ប្រទេសបង់ក្លាដេស

បង់ក្លាដេសបានពង្រីកការនាំចេញទ7ជយ៉ាងឆាប់រហ័សនៅក្រោមរបបកូតា ។ នេះគឺភាគច្រើនដោយសារមានកម្លាំងពលកម្មប្រកបដោយកម្រៃថោកៗ ទោះបីមានផលិតភាពទាបក៏ដោយ ។ នៅឆ្នាំ ២០០៤ មានកម្មករចំនួន ៥០០.០០០នាក់ធ្វើការនៅក្នុងផ្នែកសម្លៀកបំពាក់ចាក់ និង ១.៣លាននាក់ ក្នុងផ្នែកសម្លៀកបំពាក់ត្បាញ[១៦] ក្នុងនោះ ៨០% ជាកម្មការិនី ។

នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ សហគ្រាសនៃប្រទេសបង់ក្លាដេសបានកែលំអយ៉ាងច្រើន ដោយកាត់បន្ថយពេលវេលាមិនស៊ីសង្វាក់គ្នាក្នុងផលិតកម្ម បង្កើនតម្លៃបន្ថែម និងបានធ្វើឱ្យផ្លែមានលក្ខណៈប្រកួតប្រជែង ។ ទោះជាយ៉ាងនេះក្តី បង់ក្លាដេសនៅតែពឹងផ្អែកយ៉ាងខ្លាំងលើកូតា ដោយបានបញ្ជូន ៩០% នៃការនាំចេញរបស់ខ្លួនទៅស.រ.អា និង សហភាពអឺរ៉ុប ។ អ្នកវិភាគជាច្រើនបានសន្និដ្ឋានថា បើគ្មានកូតាទេ វិស័យ T&C នឹងដួលរលំ ។

លទ្ធផលដែលទទួលមានមានក្ខណៈចម្រុះ ដោយអាចធ្វើបានប្រសើរនៅក្នុងស.រ.អា និងទន់ខ្សោយជាងនៅក្នុងសហភាពអឺរ៉ុប ។ អ្វីដែលទំនងជាបានកើតឡើងគឺថាសម្រាប់សម្លៀកបំពាក់ពីសសៃត្បាញ គោលការណ៍ដ៏តឹងរ៉ឹងរបស់សហភាពអឺរ៉ុបទាក់ទងនឹងប្រភពដើម បង្កើតជាឧបសគ្គយ៉ាងតឹងតែងជាងរបាំងកូតារបស់ស.រ.អា ទៅទៀត ។

មកទល់ពេលនេះពុំទាន់មានភស្តុតាងបង្ហាញពីរោងចក្របិទទ្វារឬកាត់បន្ថយកម្មករឡើយ ។ តាមពិត ការអង្កេតមួយបានរកឃើញថា ក្រុមហ៊ុនចំនួន ១៩ ក្នុងចំណោម ៣៥ បានបង្កើនចំនួនកម្មករ[១៧] ចំណែកចំនួនការងារនៅក្នុងក្រុមហ៊ុនផ្សេងទៀតមិនប្រែប្រួលឡើយ ។

ស្ថានភាពនៅកន្លែងធ្វើការងារ អាចត្រូវបានកែលំអដោយសារការអង្កេតមួយផ្សេងទៀតបានរកឃើញថាមានកំណើនសម្ពាធដើម្បីឱ្យគោរពតាមក្រមការងារ និងស្តង់ដារខាងសង្គមដែលបានកំណត់ដោយអ្នកទិញខុសៗគ្នា[១៨] ។ ទោះជាយ៉ាងណាក៏ដោយបន្ទុកបានធ្លាក់មកលើនិយោជក បន្ទាប់មកធ្លាក់មកលើកម្មករ ដោយពុំមានការគាំទ្រច្រើនពីអ្នកទិញ ឬពីរដ្ឋាភិបាលឡើយ ។ ការទាមទារក៏មានភាពខុសគ្នាពីអ្នកទិញមួយទៅអ្នកទិញមួយផ្សេងទៀតផងដែរ ។ អ្នកទិញមួយអាចតម្រូវឱ្យកម្មករមានស្បែកជើងផ្ទាត់ រីឯអ្នកទិញផ្សេងទៀតអាចតម្រូវឱ្យមានស្បែកជើងសម្រាប់ការងារ ។ ចំនួនម៉ោងធ្វើការក៏បានកាត់បន្ថយដោយសារអ្នកទិញទាមទារឱ្យរោងចក្រគោរពតាមកម្រិតស្របច្បាប់ត្រឹម ៦០ ម៉ោងក្នុងមួយសប្តាហ៍ ។ ទោះបីប្រការនេះ ទំនងជាមានភាពជឿនលឿនទៅមុខមួយផ្នែក នេះក៏មានន័យថាមនុស្សទាំងឡាយអាចរកចំណូលបានតិចជាងមុន និងពុំបានទទួលអាហារសម្រន់ដែលផ្តល់ដោយរោងចក្រសម្រាប់កម្មករធ្វើការបន្ថែមម៉ោងឡើយ ។

## ប្រទេសកម្ពុជា

ប្រទេសកម្ពុជាក៏ត្រូវបញ្ចប់របបកូតាដូចគ្នាដែរ។ អ្នកវិនិយោគពីហុងកុង តៃវ៉ាន់ និងសឹង្ហបូរី ទន្ទឹមនឹងអ្នកជំនួញក្នុងស្រុក ដែលភាគច្រើនគឺអ្នកមានដើមកំនើតជាជនជាតិចិន បានកសាងឧស្សាហកម្មមួយដែលមានរោងចក្រកាត់ដេរ សម្លៀកបំពាក់ចំនួន ២០០ ដែលនៅឆ្នាំ ២០០៤ បាននាំចេញទំនិញដែលមានតម្លៃ ១.៩០០លានដុល្លារ។ ប៉ុន្តែ ប្រទេសកម្ពុជាទំនងជាងាយរងគ្រោះដោយសារការលុបចោលកូតា។ ប្រមាណ ៤០% នៃការនាំចេញពីកម្ពុជា គឺសម្រាប់អ្នកលក់រាយនៅស.រ.អា ដូចជា Gap ដែលទទួលទំនិញប្រមាណមួយភាគប្រាំមួយពីប្រទេសចិនផងដែរ។ ដោយសារថ្លៃចំណាយលើផលិតកម្មនៅកម្ពុជា មានប្រមាណ ២៥% ថ្លៃជាងនៅក្នុងប្រទេសចិន ហើយការដឹកជញ្ជូនតាមកំពង់ផែបរទេសត្រូវចំណាយពេលយូរជាងយ៉ាងច្រើនមានការបារម្ភថា ចំនួនដ៏ច្រើននៃផលិតកម្មនេះអាចនឹងប្តូរទៅប្រទេសចិន។

ក្នុងស្ថានភាពដែលលទ្ធផលទទួលបានប្រសើរជាងការរំពឹងទុក ដោយសារការនាំចេញទៅស.រ.អា និងសហភាពអឺរ៉ុបបានកើនឡើង ១១% គិតជាតម្លៃសរុប និង ១៣% គិតជាបរិមាណនៅក្នុងឆ្នាំ ២០០៥។ នេះទំនងជាផ្លែផ្កានៃកិច្ចប្រឹងប្រែងរបស់កម្ពុជាដើម្បីកែលំអស្ថានភាពក្នុងរោងចក្រ និងការចូលរួមរបស់ខ្លួន នៅក្នុងកម្មវិធីអធិការកិច្ចរបស់ ILO ដែលបានធ្វើឱ្យអ្នកទិញពីបរទេស មានការទទួលយកបាននូវស្ថានភាពក្នុងប្រទេសកម្ពុជា។ កម្មករនៅកម្ពុជាមានសិទ្ធិធ្វើបាតុកម្ម។ កម្មករជាច្រើនបានចាត់ចែងទៅជាសហជីពឯករាជ្យ។ របាយ-ការណ៍ថ្មីៗនេះពុំបានរកឃើញអំពីការងារដោយបង្ខិតបង្ខំកម្មករមិនគ្រប់អាយុឬការរើសអើងឡើយ។ ដោយសារលក្ខខណ្ឌការងារប្រសើរជាងមុន ស.រ.អាបានផ្តល់ឱ្យកម្ពុជានូវការអនុគ្រោះ ពិសេសក្រោមរូបភាពជាអត្រាខ្ពស់នៃកូតា និងអត្រាពន្ធទាប។[១៩] ទោះជាយ៉ាងណាក៏ដោយ របាយការណ៍មួយរបស់ ILO បានព្រមានអំពីការិយាធិបតេយ្យ និងអំពើពុករលួយធ្ងន់ធ្ងរ ហើយរបាយការណ៍ពីសហព័ន្ធអន្តរជាតិសម្រាប់សហជីពពាណិជ្ជកម្មសេរីបង្ហាញពីកំណើនសម្ពាធលើសិទ្ធិរបស់សហជីពកម្មករ ដែលជាការគំរាមកំហែងធ្វើឱ្យខូចកិត្តិយសរបស់ប្រទេសនេះ។[២០]

## ប្រទេសឥណ្ឌា

ឧស្សាហកម្ម T&C របស់ឥណ្ឌា មានប្រមាណ ១៤% នៃផលិតផលឧស្សាហកម្មសរុប និងជិត ៣០% នៃផលិតផលនាំចេញសរុប។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ប្រទេសឥណ្ឌាបាននាំចេញប្រមាណពាក់កណ្តាលនៃផលិតផលរបស់ខ្លួនទៅ USSR និងអឺរ៉ុបខាងកើត ប៉ុន្តែចាប់ពីចុងទសវត្សរ៍ឆ្នាំ ១៩៧០ បានប្តូរកាន់តែច្រើនឡើងទៅទីផ្សារស.រ.អា និងអឺរ៉ុបដែលបានប្រឈមនឹងការដាក់កំហិតដោយកូតា។ ភាគច្រើននៃការសិក្សាបានសន្និដ្ឋានថា ឥណ្ឌាអាចទទួលប្រយោជន៍ពីការលុបចោលកូតា ហើយអ្នកខ្លះគិតថា ឥណ្ឌាតែងមានលទ្ធភាពប្រកួតប្រជែងជាមួយចិន។ សក្តានុពលនៃចំណូលដែលទទួលបានមានប្រមាណ ២.០០០លានដុល្លារ/ឆ្នាំ។[២១]

ឥណ្ឌាទំនងជាបានរីកចម្រើនទាំងខាងវាយនភណ្ឌនិងសម្លៀកបំពាក់។ រវាងឆ្នាំ ២០០៤ និង ២០០៥ ការនាំចេញទៅស.រ.អា និងសហភាពអឺរ៉ុប បានកើនឡើង ២២% គិតជាតម្លៃ និងច្រើនជាង ១១% គិតជាបរិមាណ។ បើគិតពីចំនួនដាច់ខាតតម្លៃនៃការនាំចេញបានកើនឡើងជិត ២.០០០លានដុល្លារ ដូចការរំពឹងទុក។ ប៉ុន្តែ ឥណ្ឌាបានបាត់បង់ភាគចំណែកក្នុងទីផ្សារសម្រាប់ខោពីកប្បាស ប៉ុន្តែមានការកើនឡើងលើសម្លៀកបំពាក់ផ្សេងទៀតធ្វើពីសសៃកប្បាស និងអាវចាក់បុរសធ្វើពីកប្បាស។ ទោះបីគ្មានសេចក្តីរាយការណ៍អំពីការបាត់បង់ការងារនៅពេលដែលឧស្សាហកម្មវាយនភណ្ឌបានប្តូរពីកីតម្បាញដោយដៃទៅ

*ដោយសារលក្ខខណ្ឌការងារប្រសើរជាងមុន ស.រ.អាបានផ្តល់ឱ្យកម្ពុជានូវការអនុគ្រោះពិសេសក្រោមរូបភាពជាអត្រាខ្ពស់នៃកូតា និងអត្រាពន្ធទាប*

ម៉ាស៊ីនក៏ដោយ។

## ឥណ្ឌូណេស៊ី

វិស័យ T&C របស់ឥណ្ឌូណេស៊ីគឺជាផ្នែកដែលរួមចំណែកជាចម្បងលើការនាំចេញដែលមិនមែនប្រេង និងឧស្ម័ន។ មនុស្សប្រមាណ ៣.៥លាននាក់ កំពុងធ្វើការនៅក្នុងវិស័យនេះដោយផ្ទាល់ និងដោយប្រយោល។ តាមការអង្កេតរបស់អង្គការកម្លាំងកម្មករជាតិឆ្នាំ ២០០៤ មានមនុស្ស ១.១លាននាក់ ត្រូវបានជួលឱ្យធ្វើការជាផ្លូវការនៅក្នុងវិស័យនេះនៅឆ្នាំ ២០០៤ ថយចុះពី ១.៤លាននាក់ នៅឆ្នាំមុន។ បន្ថែមលើកម្មកររោងចក្រវិស័យ T&C ពិសេសសម្លៀកបំពាក់កាត់ដេររួច បានជួលកម្មករក្រៅផ្លូវការជាច្រើន។ ឧទាហរណ៍ នៅបាលី ក្រុមអ្នកភូមិត្រូវបានជួលឱ្យដេរ។ ប្រាក់កម្រៃស្ថិតក្នុងចំណោមអត្រាទាបបំផុតនៅក្នុងតំបន់ ដែលមានជាមធ្យម ០.២៧ដុល្លារ/ម៉ោង។ នៅក្នុងតំបន់កែច្នៃសម្រាប់ការនាំចេញ ប្រាក់កម្រៃជាមូលដ្ឋានសម្រាប់កម្មការិនីក្នុងវិស័យកាត់ដេរមានពី ៥៥ ទៅ ៧៤ដុល្លារ/ខែ ដែលអត្រាប្រាក់កម្រៃអប្បបរមា ៧៤ដុល្លារ។ ដូច្នេះ ស្ត្រីមិនអាចរកកម្រៃបានខ្ពស់ជាងកម្រិតអប្បបរមាឡើយនៅក្នុងឧស្សាហកម្មកាត់ដេរ។[២២]

រវាងឆ្នាំ ២០០៤ និង ២០០៥ វិស័យនេះបានបង្កើតផលិតផលរបស់ខ្លួន។ ការនាំចេញទៅស.រ.អា និងសហភាពអឺរ៉ុបមានប្រមាណពីរភាគបីនៃការនាំចេញសរុបដែលបង្ហាញពីកំណើន ៦% គិតជាតម្លៃ។ ទោះជាបែបនេះក៏ដោយ មានភស្តុតាងបង្ហាញថា រោងចក្របានបន្ថយចំនួនកម្មករដោយសារការធ្លាក់ចុះនៃចំនួនបញ្ជាទិញ និងការកើនថ្លៃចំណាយ។

## ប្រទេសនេប៉ាល់

នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ អ្នកនាំចេញពីប្រទេសឥណ្ឌា ដែលមានឧបសគ្គដោយសារកូតាបានមកប្រទេសនេប៉ាល់ និងបង្កើតឧស្សាហកម្មកាត់ដេរសម្រាប់ការនាំចេញ។ លទ្ធផលនៃសម្លៀកបំពាក់ដេររួចដែលបានរីកចម្រើនខ្ពស់ នៅឆ្នាំ ២០០០ បានធ្លាក់ចុះនៅក្នុងរយៈពេលពីរឆ្នាំបន្ទាប់មក ដោយសារមានការរំពឹងអំពីការបញ្ចប់របបកូតា។ តម្លៃនៃផលនាំចេញទៅទីផ្សារ ស.រ.អា និងសហភាពអឺរ៉ុប ក្នុងឆ្នាំ ២០០៥ បានធ្លាក់ចុះយ៉ាងខ្លាំងក្នុងកម្រិត ១៨% គិតជាតម្លៃ និង ២៥% គិតជាបរិមាណ។

## ប្រទេសប៉ាគីស្ថាន

ជារួម វិស័យ T&C មាន ៦០%នៃការនាំចេញសរុប។ នៅឆ្នាំ ២០០០ វិស័យនេះមានកម្មករ ២.៣លាននាក់ រួមទាំងកម្មករក្រៅផ្លូវការ ដែលមាន ៤៣% នៃចំនួនការងារសរុបក្នុងឧស្សាហកម្មនេះ ហើយគឺជាវិស័យដែលមានកម្មករស្ត្រីច្រើនជាងគេបន្ទាប់ពីវិស័យកសិកម្ម។ ភាគច្រើនជាប្រភេទសិប្បកម្មដែលប្រមាណ ៩០% នៃការងារសរុបត្រូវបានម៉ៅការបន្តទៅឱ្យសហគ្រាសខ្នាតតូច និងមធ្យម។

រវាងឆ្នាំ ២០០៤ និង ២០០៥ ប៉ាគីស្ថានបានបាត់បង់ការនាំចេញខ្លះៗទៅសហភាពអឺរ៉ុប ទន្ទឹមនឹងកំណើនការនាំចេញទៅស.រ.អា។ ប៉ុន្តែជារួម មានភាពមិនច្បាស់អំពីកំណើនវិស័យនេះ បន្ទាប់ពីការលុបចោលកូតា។ តម្លៃនៃការនាំចេញបានថយចុះ ១% ចំណែកបរិមាណបានកើនឡើងប្រមាណ ៦%។ ឥទ្ធិពលទៅលើចំនួនការងារនៅពុំទាន់ដឹងច្បាស់នៅឡើយទេ ប៉ុន្តែមានសញ្ញាថាកម្មករបុរសក្នុងផ្នែកផលិតកម្ម ត្រូវបានជំនួសដោយស្ត្រី។[២៣]

## ប្រទេសស្រីលង្កា

ជោគជ័យរបស់ប្រទេសស្រីលង្កាកើតឡើងមួយចំណែកដោយសារគោលនយោបាយគាំទ្ររបស់រដ្ឋាភិបាល

ដែលកាត់បន្ថយពន្ធលើផលចំណេញការនាំចូលម៉ាស៊ីន និងវត្ថុធាតុដើមដោយឥតពន្ធ ព្រមទាំងការឧបត្ថម្ភធន និងប្រព័ន្ធបង្វិលសងប្រាក់ពន្ធ។ ប៉ុន្តែ ប្រទេសស្រីលង្កាក៏មានកូតាក្នុងបរិមាណខ្ពស់ផងដែរ និងមានកិច្ចធានាលើទីផ្សារ តាមរយៈកិច្ចព្រមព្រៀងជាមួយស.រ.អា សហភាពអឺរ៉ុប កាណាដា និងន័រវេ។ ភាគច្រើននៃវិស័យ T&C នៅទីនេះគឺសម្លៀកបំពាក់ ដោយសារពុំមានស្សាហកម្មវាយនភណ្ឌច្រើនឡើយ។ សូម្បីតែមុនពេលដែលរបបកូតាត្រូវបានលុបចោលក៏ដោយ ថ្លៃពលកម្មបានកើនឡើងហើយការនាំចេញសម្លៀកបំពាក់បានធ្លាក់ចុះ។ នៅពេលចប់កូតា អ្នកវិភាគខ្លះបានសន្និដ្ឋានថា ប្រមាណពាក់កណ្តាលនៃឧស្សាហកម្មក្នុងស្រុកនឹងត្រូវបិទទ្វារ។[២៤]

នៅក្នុងការអង្កេតឆ្នាំ ២០០៥ មានរោងចក្រកាត់ដេរសម្លៀកបំពាក់ចំនួន ៧៣៣ ហើយចំនួនការងារទំនងជាកំពុងធ្លាក់ចុះពី ៣៤០.៣៦៧ នៅឆ្នាំ ២០០៣ មក ២៧៣.៦០០នាក់ នៅឆ្នាំ ២០០៥។ ប្រមាណ ៨៥% នៃកម្មករគឺជានារី។ ចំណែកខ្លះនៃការថយចុះនេះកើតឡើងដោយសារការពង្រឹងការងារនៅក្នុងឧស្សាហកម្មនេះ ប៉ុន្តែរោងចក្រខ្លះបានបិទទ្វារភ្លាមៗ ដោយពុំមានទូទាត់សំណងឡើយ។

នៅឆ្នាំ ២០០៥ ការនាំចេញចម្រុះទៅស.រ.អា និងសហភាពអឺរ៉ុប បានកើនឡើង ៣% គិតជាតម្លៃ និងថយចុះក្នុងអត្រាដូចគ្នានេះ បើគិតជាបរិមាណ។ សហភាពអឺរ៉ុបបានផ្តល់ឱ្យប្រទេសស្រីលង្កានូវការអនុគ្រោះ GSP ជាបន្ថែមនៅក្នុងឆ្នាំ ២០០៥។ ប៉ុន្តែដោយពុំមានវិស័យកែច្នៃវាយនភណ្ឌបានរឹងមាំ ប្រទេសនេះ នឹងពុំទទួលប្រយោជន៍ច្រើនពីប្រព័ន្ធនេះទេ។

## ប្រទេសវៀតណាម

វៀតណាមក៏ទំនងជាខាតបង់ដោយសារការថយចុះកូតាផងដែរ។ មកទល់ពេលនេះ លទ្ធផលពុំទំនងជាមានលក្ខណៈអវិជ្ជមានឡើយ។ ការនាំចេញទៅស.រ.អា និងសហភាពអឺរ៉ុប នៅក្នុងឆ្នាំ ២០០៥ បានកើនឡើងប្រមាណ ៦% គិតជាតម្លៃ និង ០.៥% គិតជាបរិមាណ។ ទោះជាយ៉ាងនេះក៏ដោយ មានបរិយាកាសមិនច្បាស់លាស់ក្នុងចំណោមផលិតករជាតិ។ វៀតណាមបានទទួលផលចំណេញពីការដាក់កំហិតឡើងវិញចំពោះប្រទេសចិន ដែលធ្វើឱ្យការលក់ទំនិញពីវៀតណាមបានកើនឡើងមួយកម្រិត។ ទោះជាយ៉ាងណាក៏ដោយ យោងតាមប្រភពពីរដ្ឋាភិបាល ការរំពឹងសម្រាប់ពេលខាងមុខមិនសូវល្អទេ មិនមែនត្រឹមតែដោយសារការលុបចោលកូតា ប៉ុន្តែដោយសារថ្លៃចំណាយផលិតកម្មខ្ពស់ផងដែរ។[២៥]

## ផលប៉ះពាល់ចំពោះកម្មករនិងសហគមន៍

ប្រសិនបើប្រទេស និងអ្នកផ្គត់ផ្គង់នានា ត្រូវបន្តការងាររបស់ខ្លួននៅក្នុងបរិយាកាសពាណិជ្ជកម្មសកលថ្មីនេះ ពួកគេត្រូវតែមានភាពប្រកួតប្រជែងជាងមុន។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងកិច្ចប្រឹងប្រែងធ្វើបែបនេះ ពួកគេអាចបញ្ជូនបន្ទុកទៅឱ្យកម្មករ ដោយកាត់បន្ថយប្រាក់កម្រៃ និងទាមទារឱ្យធ្វើការបន្ថែមម៉ោងដោយឥតកម្រៃ និងគំរាមបិទទ្វាររោងចក្រ ឬដូរកន្លែងប្រសិនបើកម្មករមិនគោរពតាម។ កំណើនភាពប្រកួតប្រជែងក៏នាំទៅរកទម្រង់ការងារដែលពុំសូវមានការធានាផងដែរ ដូចជា ការបង់កម្រៃទៅតាមចំនួនផលិតផល ដែលមានន័យថាត្រូវប្រឈមនឹងហានិភ័យខាងសុខភាព និងសុវត្ថិភាពសម្រាប់កម្មករ ក៏ដូចជាការបាត់បង់ផលបន្ថែមដូចជាការធានារ៉ាប់រងខាងសុខាភិបាលផងដែរ។

ទោះជាយ៉ាងណាក៏ដោយ ក៏អាចមានសម្ពាធឱ្យបង្កើនស្ថានភាពការងារផងដែរ។ អ្នកប្រើប្រាស់នៅក្នុងប្រទេសនាំចូលបានសុំឱ្យអ្នកលក់រាយបង្ហាញថាទំនិញទាំងនោះមិនត្រូវបានផលិតក្រោមស្ថានភាពការងារយ៉ាប់យ៉ឺននោះទេ។ ប្រការ

នេះអាចកែលំអស្តង់ដារសម្រាប់កម្មករជាច្រើន ទោះបីមានហានិភ័យដែលថាការទាមទាររបស់អ្នកលក់រាយអាចតឹងតែងពេកដែលធ្វើឱ្យអ្នកជំនួញនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍បញ្ឈប់ជំនួញរបស់ខ្លួន។

ការថយចុះនៃឧស្សាហកម្មកាត់ដេរនៅក្នុងប្រទេសណាមួយ នឹងធ្វើឱ្យបាត់បង់ចំនួនការងារ ជាពិសេសសម្រាប់ស្ត្រី។ សូម្បីនៅក្នុងប្រទេសដែលអាចរក្សាបាននូវផលិតកម្មក្តី ចំនួនការងាររបស់ស្ត្រីអាចថយចុះ ដោយសារកំណើនខាងយន្តូបនីយកម្ម និងការផ្ទេរការងារទៅរោងចក្រធំៗ ដែលជួលបុរសច្រើនជាង។ ការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មី ច្រើនតែនាំឱ្យមានកំណើនភាពគ្មានការងារធ្វើសម្រាប់ស្ត្រី។ ទីមួយដោយសារបច្ចេកវិទ្យាថ្មីនឹងជំនួសមុខការ ដូចជាតម្បាញ ដែលធ្លាប់តែធ្វើដោយស្ត្រី និងទីពីរ ដោយសារស្ត្រីដែលមានជំនាញទាប ច្រើនតែខ្វះចំណេះដឹងដើម្បីគ្រប់គ្រងបរិក្ខារថ្មី។

ស្ត្រីដែលធ្វើការតាមអត្រាចំនួនផលិតផលនៅក្នុងវិស័យមិនផ្លូវការក៏ងាយរងគ្រោះផងដែរ ប្រសិនបើស្ថានភាពការងារប្រសើរជាងបានបង្វែរផលិតកម្មកាន់តែច្រើនឡើងទៅក្នុងរោងចក្រ។ ដោយពុំអាចរកការងារធ្វើបាននៅក្នុងរោងចក្រកាត់ដេរទំនើប ស្ត្រីទាំងនេះទំនងជាទៅរកសហគ្រាសខ្នាតតូចដូចជានៅក្នុងកន្លែងបោកគក់ និងការលក់ដូរ នៅតាមចិញ្ចើមថ្នល់។

## ទិសដៅនៃគោលនយោបាយជាតិ

ឧស្សាហកម្ម T&C នៅទូទាំងពិភពលោក កំពុងស្ថិតក្នុងរបត់នៃការផ្លាស់ប្តូរចម្បង ដោយកំណើននៅក្នុងប្រទេសខ្លះនឹងត្រូវទូទាត់ជាមួយការខាតបង់នៅក្នុងប្រទេសខ្លះទៀត នៅពេលដែលរោងចក្រត្រូវបិទទ្វារនិងអត្រាគ្មានការងារធ្វើកើនឡើង។ ប៉ុន្តែ សូម្បីតែនៅក្នុងបណ្តាប្រទេសដែលគ្រប់គ្រង ដើម្បីបង្កើនប្រាក់ចំណូលពីការនាំចេញក្តី នឹងមិនទំនងជាផ្តល់ចំនួនការងារកាន់តែច្រើនឡើងឬស្ថានភាពការងារប្រសើរជាងមុនឡើយ។ កម្រិតកាន់តែខ្ពស់នៃពាណិជ្ជកម្ម T&C អាចនាំឱ្យមានការអភិវឌ្ឍមនុស្សកាន់តែខ្ពស់ជាងមុន ប៉ុន្តែអាចនឹងកើតឡើងតែក្នុងករណីដែលរដ្ឋាភិបាល និងនិយោជកចាត់វិធានការចាំបាច់តែប៉ុណ្ណោះ។ នៅក្នុងរយៈពេលវែងខាងមុខ វិធីតែមួយដែលអាចរក្សាមុខជំនួញឱ្យនៅដំណើរការបាននៅក្នុងទីផ្សារពិភពលោកប្រកបដោយការប្រកួតប្រជែង គឺត្រូវលើកកម្ពស់គុណភាពឧស្សាហកម្ម និងលុបចោលរបាំងខ្លះៗ ដើម្បីបង្កើនទាំងបរិមាណ និងគុណភាពផលិតផល។

## ការងារផ្ទះ

ប្រទេសដែលពុំមានច្បាប់ គួរតែអនុម័តច្បាប់ការងារដើម្បីធានាសិទ្ធិរបស់កម្មករ ជាពិសេសស្ត្រី។ គោលការណ៍ណែនាំបែបនេះ ដែលស្របតាមអនុសាសន៍របស់អង្គការ ILO គួរតែមានការកំហិតលើចំនួនម៉ោងធ្វើការប្រចាំសប្តាហ៍ ទន្ទឹមនឹងផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនឱ្យបង្កើនភាពប្រកួតប្រជែងតាមរយៈការបង្កើនផលិតភាពនៃពលកម្ម។ ទន្ទឹមនឹងនេះ ប្រទេសដែលបានអនុម័តរួចមកហើយនូវច្បាប់បែបនេះ ត្រូវចាត់វិធានាការជាមុនក្នុងការធានាឱ្យមានការគោរពតាម និងដាក់ទណ្ឌកម្មចំពោះសហគ្រាសដែលល្មើសនឹងបទប្បញ្ញត្តិ។

នៅក្នុងស្ថានភាពបច្ចុប្បន្ននេះ អ្នកលក់រាយអន្តរជាតិ និងឧស្សាហករសម្លៀកបំពាក់ បានធ្វើការពិនិត្យពិច័យយ៉ាងល្អិតល្អន់នៅក្នុងប្រទេសរបស់ខ្លួនអំពីលក្ខខណ្ឌការងារនៅក្នុងរោងចក្រនៃអ្នកផ្គត់ផ្គង់របស់ខ្លួន។ ឧទាហរណ៍ ប្រទេសកម្ពុជាបានបង្ហាញរួចមកហើយអំពីថា កំណែលំអលក្ខខណ្ឌការងារអាចជួយបង្កើនការនាំចេញ។ ទោះជាយ៉ាងណាក៏ដោយ ប្រការសំខាន់គឺប្រទេសជឿនលឿនពុំគួរប្រើប្រាស់លក្ខខណ្ឌទាំងនេះ

*ប្រទេសដែលពុំមានច្បាប់ គួរតែអនុម័តច្បាប់ការងារ ដើម្បីធានាសិទ្ធិរបស់កម្មករ ជាពិសេសស្ត្រី*

ជាការទាមទារបន្ថែមដើម្បីជំនួសឬជាមូលហេតុដើម្បីបង្កើតអត្រាពន្ធ និងទម្រង់ផ្សេងទៀតនៃកិច្ចការពាររបស់ខ្លួនឡើយ ។

ប្រទេសជាអ្នកនាំចេញអាចទាញយកផលចំណេញពីកង្វល់បែបនេះ ដោយគោរពតាមក្រមអនុវត្ត ដែលកំណត់ដោយអ្នកលក់រាយចម្បងៗមួយចំនួនដើម្បីការពារសិទ្ធិពលកម្មនៅក្នុងរោងចក្រដែលជាប់កិច្ចសន្យារបស់ខ្លួន។ ប្រការទាំងនេះរួមមានប្រាក់កម្រៃគ្រប់គ្រាន់ និងចំនួនម៉ោងធ្វើការ សន្តិសុខការងារ ការធានាសុខភាព និងសុវត្ថិភាព និងសិទ្ធិក្នុងការបង្កើតសហជីពកម្មករឯករាជ្យ ។ ប្រទេសដែលមានច្បាប់ការងារស្របគ្នាជាមួយក្រមអនុវត្តទាំងនេះ និងមានមធ្យោបាយដើម្បីពង្រឹងការអនុវត្តច្បាប់ទាំងនេះ អាចបង្ហាញថាខ្លួនមានការយល់ដឹងច្រើនអំពីកត្តាសង្គមក្នុងចំណោមអ្នកលក់រាយ និងឧស្សាហករនៅស.រ.អា និងសហភាពអឺរ៉ុប ។

## កិច្ចការពារបរិស្ថាន

វិស័យ T&C អាចជម្រុញការអភិវឌ្ឍមនុស្សដោយនិរន្តរភាពបានតែក្នុងករណីដែលមានការទទួលខុសត្រូវលើផ្នែកបរិស្ថានផងដែរ។ ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ ត្រូវការនូវក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនិងដែលអាចអនុវត្តបាន ដែលអាចកាត់បន្ថយឥទ្ធិពលអវិជ្ជមានពីឧស្សាហកម្មទៅលើបរិស្ថានដោយប្រើប្រាស់បច្ចេកវិទ្យាស្អាត កាត់បន្ថយការប្រើប្រាស់ទឹកជៀសវាងការបំពុល និងបង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់ដំណើរការដែលពាក់ព័ន្ធនឹងសារធាតុគីមី ។

## ទូទាត់ឥទ្ធិពលនៃការលុបចោលកូតា

នៅក្នុងប្រទេសទាំងឡាយ ដែលរំពឹងថានឹងមានការបាត់បង់ចំនួនការងារ រដ្ឋត្រូវធានាការពារ និងស្តារលទ្ធភាពរបស់កម្មករដែលរងគ្រោះ។ ដើម្បីគ្រប់គ្រងប្រការនេះ គេអាចបង្កើតផ្នែកមួយនៅក្នុងក្រសួងរបស់រដ្ឋាភិបាល ដើម្បីធ្វើការតាមដានអំពីវិស័យនេះ។

ប្រទេសដែលងាយរងគ្រោះជាងគេ ជាប្រទេសដែលមានឧស្សាហកម្មប្រកបដោយប្រសិទ្ធិភាព និងផលិតភាពទាបដែលផលិតទំនិញអន់គុណភាព។ ឧស្សាហកម្មទាំងនេះមិនទំនងជាមានលទ្ធភាពបន្តជីវិតរបស់ខ្លួនបានឡើយ។ នៅក្នុងពិភពដែលគ្មានកូតា សហគ្រាសត្រូវធ្វើការប្រកួតប្រជែងដែលផ្អែកលើមូលដ្ឋានផ្សេងពីពលកម្មថោក។ ដូច្នេះ រដ្ឋាភិបាលត្រូវជួយបង្កើតលក្ខខណ្ឌសម្រាប់បង្កើតជម្រើសផ្សេងនៃការងារ ដូចជាកែលំអហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសក្នុងផ្នែកទូរគមនាគមន៍។ រដ្ឋាភិបាលក៏ត្រូវចរចាឱ្យមានកិច្ចព្រមព្រៀងផលប្រយោជន៍ថ្មីផងដែរសម្រាប់ផលិតផលផ្សេងទៀតដែរ ដូចជាធ្វើការតាមរយៈក្រុមការងារ និងប្លុកពាណិជ្ជកម្មដែលអាចចែករំលែកធនធាន និងព័ត៌មាន។

ទន្ទឹមនឹងនេះ រដ្ឋាភិបាលនិងឧស្សាហកម្មត្រូវធ្វើការជាមួយគ្នា ដើម្បីរកវិធីឈានឡើងទៅរកចង្វាក់នៃតម្លៃ ពោលគឺបង្កើនម៉ាស៊ីនផលិតកម្ម បង្កើតប្រភពនៅក្នុងស្រុកនៃវាយនភណ្ឌ និងធាតុចូលដទៃទៀត។

- *ការបិទទ្វាររោងចក្រដោយមានការទទួលខុសត្រូវ* : រដ្ឋាភិបាលត្រូវអនុម័តគោលការណ៍ណែនាំអំពីការបញ្ឈប់ជំនួញប្រកបដោយការទទួលខុសត្រូវ រួមទាំងតម្រូវឱ្យធ្វើសេចក្តីជូនដំណឹង និងការបិទទ្វារទៅតាមដំណាក់កាល។ ក្រុមហ៊ុនទាំងអស់ រួមទាំងអ្នកលក់រាយធំៗដែលទទួលទំនិញពីអាស៊ី គួរតែមានបណ្តាញសុវត្ថិភាពសង្គម ដើម្បីការពារកម្មករដែលត្រូវបានបញ្ឈប់ពីការងារ។ កម្មករទាំងនេះគួរតែ

បានទទួលប្រាក់កម្រៃរបស់ខ្លួន មុនឥណទានដទៃទៀត។ ប្រទេសជាច្រើនមានច្បាប់ដើម្បីការពារកម្មករពីការបណ្ដេញដោយឆាប់រហ័ស ប៉ុន្តែ ការពង្រឹងការអនុវត្តច្បាប់ទាំងនោះពុំអាចយកជាការបាន ហើយការបិទទ្វាររោងចក្រត្រូវបានទទួលការតាមដានដោយយកចិត្តទុកដាក់ ដើម្បីធានាថាកម្មករទាំងអស់បានទទួលប្រាក់ទូទាត់នៅពេលបាត់អាជីពសន្តិសុខសង្គម និងប្រាក់សោធននិវត្តន៍ ទន្ទឹមនឹងបណ្ដាញសុវត្ថិភាពសង្គម និងកម្មវិធីសម្រាប់ការជួលឱ្យធ្វើការងារវិញ។

- *កម្មវិធីកែទម្រង់ពលកម្ម* : កម្មករដែលបាត់អាជីពអាចត្រូវជួយដើម្បីអាចរកការងារថ្មីធ្វើតាមរយៈកម្មវិធីកែតម្រូវទីផ្សារពលកម្ម។ ការជួយទាំងនេះអាចរួមបញ្ចូលផ្សព្វផ្សាយព័ត៌មានអំពីទីផ្សារពលកម្ម បង្កើតធនាគារការងារ ផ្ដល់ការឧបត្ថម្ភធន និងការបណ្ដុះបណ្ដាលអំពីការងារ និងបណ្ដុះបណ្ដាលឡើងវិញអំពីជំនាញផ្សេងសម្រាប់ចូលធ្វើការនៅក្នុងវិស័យដែលទាក់ទងនឹង T&C។ ការយកចិត្តទុកដាក់គួតែផ្តោតជាពិសេសចំពោះកម្មករក្នុងវិស័យក្រៅផ្លូវការជាពិសេស ស្ត្រីដែលគួរតែបានទទួលឱកាសដើម្បីបង្កើនជំនាញរបស់ខ្លួន។ ប៉ុន្តែកម្មវិធីទាំងនេះត្រូវតែពង្រីកទៅការសិក្សាក្រៅបន្ទប់រៀន ដើម្បីផ្តល់ជំនាញជាក់លាក់និងការបណ្ដុះបណ្ដាលតាមបែបធ្វើផងរៀនផង។ ដើម្បីគោលបំណងនេះ រដ្ឋាភិបាលខ្លះបានចងជាដៃគូជាមួយផ្នែកឯកជននិងអង្គការសហគមន៍។ ឧទាហរណ៍ នៅប្រទេសបង់ក្លាដេស Nari Udyug Kendra ដែលជាមជ្ឈមណ្ឌលសម្រាប់ការផ្តួចផ្តើមស្ត្រីបានធ្វើការសិក្សាអំពីតម្រូវការបណ្ដុះបណ្ដាលសម្រាប់ស្ត្រី ហើយរដ្ឋាភិបាលបានគ្រោងលើកកម្ពស់ជំនាញសម្រាប់កម្មករកាត់ដេរចំនួន ៤០.០០០នាក់ ក្រោមភាពជាដៃគូជាមួយ NGO BRAC (ដែលកាលពីមុនត្រូវបានឱ្យឈ្មោះថាគណៈកម្មាធិការអភិវឌ្ឍន៍ជនបទនៅបង់ក្លាដេស)។ ការបណ្ដុះបណ្ដាលបែបនេះអាចជួយបង្កើនមុខជំនាញទៅក្នុងផលិតកម្មដែលផ្តល់តម្លៃបន្ថែមខ្ពស់ដូចជាសម្លៀកបំពាក់ម៉ូដសម្រាប់ស្ត្រី។ ប្រទេសខ្លះបានផ្តួចផ្តើមរួចមកហើយនូវដំណើរការនេះ។ ឧទាហរណ៍ នៅស្រីលង្កា រដ្ឋាភិបាលបានយកពន្ធលើសម្លៀកបំពាក់ ដើម្បីផ្តល់ជាមូលនិធិដល់ការបង្កើនបច្ចេកវិទ្យា និងពង្រឹងជំនាញ។ ប្រព័ន្ធឥណទានក៏អាចបង្កើតឡើងបានផងដែរ ដើម្បីជួយកម្មករដែលបាត់អាជីពឱ្យចាប់ផ្តើមជំនួញខ្នាតតូចរបស់ខ្លួន។

- *កែលំអហេដ្ឋារចនាសម្ព័ន្ធ* : ប្រទេសជាច្រើនដែលនាំចេញសម្លៀកបំពាក់ ជួបនឹងឧបសគ្គដោយសារហេដ្ឋារចនាសម្ព័ន្ធទន់ខ្សោយ ពុំមានការផ្គត់ផ្គង់ថាមពលគ្រប់គ្រាន់ បណ្ដាញផ្លូវនៅជនបទ និងផ្លូវដែកមានសភាពលំបាក និងត្រូវការពេលច្រើនដើម្បីបញ្ជូនទំនិញនៅតាមកំពង់ផែ។ តាមការប៉ាន់ប្រមាណរបស់ធនាគារពិភពលោក ពេលវេលាដែលត្រូវចំណាយជាមធ្យមសម្រាប់គយពិនិត្យទំនិញចេញទៅ

សមុទ្រ គឺយូរជាងដប់ថ្ងៃ នៅអាស៊ី ធៀបនឹងត្រឹមតែពីរថ្ងៃ នៅប្រទេសជឿនលឿន។ ប្រការនេះជាឧបសគ្គធ្ងន់ធ្ងរចំពោះសម្លៀកបំពាក់ម៉ូដ។ ប្រទេសនានាត្រូវធ្វើការវិនិយោគលើការបង្កើតផែស្ងួត និងតំបន់កែច្នៃសម្រាប់ការនាំចេញថ្មីៗ ទន្ទឹមនឹងបង្កើតសេវា និងឧស្សាហកម្មគាំទ្រ ព្រមទាំងលុបចោលភាពយឺតយ៉ាវលើការបញ្ជូន និងឆែកឆេរទំនិញដែលធ្វើឡើងដោយគយ។ ឧទាហរណ៍ ការផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកនៅតាមកំពង់ផែ និងទីចាត់ការគយអាចជួយបង្កើនល្បឿនគយពិនិត្យ។

- *បង្កើនកម្រិតជំនាញ* : ការបណ្តុះបណ្តាលមានសារៈសំខាន់ជាពិសេសនៅកម្រិតដំបូង ជាពិសេសនៅក្នុងប្រទេសកម្ពុជាដែលមានប្រព័ន្ធអប់រំនៅទន់ខ្សោយ ដែលជាឧបសគ្គធ្ងន់ធ្ងរចំពោះផលិតភាពការងាររបស់កម្មករ។ ចាំបាច់ត្រូវមានការបណ្តុះបណ្តាលជាពីរលំដាប់។ ទីមួយ សម្រាប់កម្មករ ដើម្បីពង្រឹងជំនាញ បង្កើនល្បឿននៃដំណើរការផលិតកម្ម និងកាត់បន្ថយសំណល់ និងទីពីរ អ្នកចាត់ចែងថ្នាក់កណ្តាល ដើម្បីឱ្យពួកគេអាចគ្រប់គ្រងការងារមានប្រសិទ្ធិភាពជាងមុន ធ្វើការប្រាស្រ័យទាក់ទងបានល្អជាមួយអ្នកទិញ ឬភ្នាក់ងាររបស់អ្នកទិញ និងឆ្លើយតបចំពោះការបញ្ជាទិញប្រកបដោយប្រសិទ្ធិភាព។ នេះជាផ្នែកដែលអាចបង្កើនកិច្ចសហប្រតិបត្តិការសម្រាប់ភាពជាដៃគូសាធារណៈ និងឯកជន។

- *ពង្រឹងបច្ចេកវិទ្យា* : ជាទូទៅ T&C គឺជាវិស័យដែលទាមទារបច្ចេកវិទ្យាទាប។ សូម្បីតែបែបនេះក្តី សហគ្រាសនៅក្នុង LDCs និងប្រទេសដែលមានប្រាក់ចំណូលទាបត្រូវរាំងស្ទះដោយសារកង្វះលទ្ធភាពដើម្បីបង្កើតម៉ូតដោយកុំព្យូទ័រ និងផលិតកម្មដោយមានជំនួយពីម៉ាស៊ីនកុំព្យូទ័រ មិនត្រឹមតែដើម្បីបង្កើនប្រសិទ្ធិភាពរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីពង្រឹងគុណភាព និងឆ្លើយតបចំពោះតម្រូវការរបស់អ្នកទិញផងដែរ។ បច្ចេកវិទ្យាទាំងនេះមានជាទូទៅ នៅក្នុងប្រទេសដែលមានប្រាក់ចំណូលកណ្តាល ហើយក្រុមហ៊ុននាំចេញធំៗនៅបង់ក្លាដេសបានតម្លើងប្រព័ន្ធបែបនេះរួចហើយដែរ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុង LDCs និងប្រទេសដែលមានប្រាក់ចំណូលទាបផ្សេងទៀត ការតម្លើងម៉ាស៊ីនបែបនេះ ប្រហែលមិនអាចធ្វើទៅបានទេ។ នៅទីនេះ លទ្ធភាពមួយគឺក្រុមហ៊ុនត្រូវធ្វើការជាមួយគ្នាជាក្រុម ដើម្បីប្រើប្រាស់បរិក្ខារបែបនេះ។ យោបល់មួយផ្សេងទៀតគឺត្រូវប្រើប្រាស់ការវិនិយោគដោយផ្ទាល់ពីបរទេសតាមរយៈកិច្ចសហប្រតិបត្តិការត្បូង-ត្បូង។

- *ការគាំទ្រសារពើពន្ធ* : នៅក្នុងប្រទេសខ្លះ សហគ្រាសដែលនាំចេញទាំងស្រុងត្រូវបានទទួលការអនុគ្រោះជាពិសេស ដូចជា ការសងពន្ធវិញទាំងស្រុងលើទំនិញដែលត្រូវនាំចេញទៅវិញ និងការលើកលែងពន្ធនាំចូល។ ការលើកទឹកចិត្តខាងសារពើពន្ធបែបនេះក៏អាច

ពង្រីកសម្រាប់ក្រុមហ៊ុនដែលនាំចេញត្រឹមតែផ្នែកខ្លះនៃផលិតផលរបស់ខ្លួនផងដែរ។ ការលើកទឹកចិត្តផ្សេងទៀត អាចរួមបញ្ចូលការកាត់បន្ថយឬលុបចោលទាំងស្រុងនូវអត្រាពន្ធលើផលិតផលពាក់កណ្ដាលសម្រេចមួយចំនួន អនុញ្ញាតឱ្យអ្នកនាំចេញសម្លៀកបំពាក់នូវសេរីភាពក្នុងការជ្រើសរើសរវាងការប្រើប្រាស់សាច់ក្រណាត់ដែលផលិតក្នុងស្រុក និងសាច់ក្រណាត់នាំចូល ដូចក្នុងករណីប្រទេសចិន និងប៉ាគីស្ថាន បញ្ចុះពន្ធលើការលក់នៅក្នុងទីផ្សារក្នុងស្រុកនូវផលិតផល T&C ដែលមិនគ្រប់ស្តង់ដារសម្រាប់ការនាំចេញ កែទម្រង់ប្រព័ន្ធធានាឥណទានសម្រាប់ការនាំចេញដើម្បីគ្រប់គ្រងលើហានិភ័យសម្រាប់ទំនិញមុន និងក្រោយបញ្ជូនចេញ តម្រូវការហិរញ្ញប្បទាន និងបង្កើនរយៈពេលកំណត់សម្រាប់ទូទាត់ឥណទានលើការនាំចេញ។ ឧទាហរណ៍ នៅប្រទេសបង់ក្លាដេស រដ្ឋាភិបាលបានលុបចោលពន្ធលើអគ្គិសនី និងសេវាផ្សេងទៀតដែលប្រើប្រាស់ដោយរោងចក្រកាត់ដេរ។

- *លើកកម្ពស់កេរ្តិ៍ឈ្មោះនិងយីហោ* ៖ រដ្ឋាភិបាលអាចជួយសហគ្រាសតូចៗកសាងកេរ្តិ៍ឈ្មោះលើគុណភាព ភាពដែលអាចទុកចិត្តបាន ការគោរពស្តង់ដារផលិតផល និងដំណើរការ។ ឧទាហរណ៍ រដ្ឋាភិបាលអាចផ្តោតលើផលិតផលដែលមានគុណភាព ជាពិសេស ដូចជា កម្រាលពូក ឬស្វែងរកអត្ថប្រយោជន៍តាមរយៈការចុះផ្សាយឱ្យបានទូលំទូលាយអំពីការគោរពទៅតាមស្តង់ដារអង្គការពលកម្មអន្តរជាតិ និងស្តង់ដារបរិស្ថាន ដូចដែលបានធ្វើរួចមកហើយនៅក្នុងប្រទេសកម្ពុជា។ ពួកគេក៏អាចធ្វើកិច្ចការទាំងនេះខ្លះៗ តាមរយៈពិព័រណ៍ពាណិជ្ជកម្ម និងបេសកកម្មនៅក្រៅប្រទេស ក៏ដូចជា តាមរយៈការជួយផលិតករក្នុងស្រុកបង្កើតទំនាក់ទំនងជាមួយអ្នកលក់រាយធំៗ។

## វិធានការអន្តរជាតិដើម្បីបង្កើនការប្រើប្រាស់ទីផ្សារ

ទន្ទឹមនឹងនេះដែរ រដ្ឋាភិបាលទាំងប្រទេសនាំចេញ និងប្រទេសនាំចូលត្រូវចាត់វិធានការនៅកម្រិតអន្តរជាតិ ដើម្បីធានាថាពាណិជ្ជកម្ម T&C លើកកម្ពស់ការអភិវឌ្ឍមនុស្សនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវធានាថាការពិចារណាអំពីការអភិវឌ្ឍមនុស្សត្រូវបានរួមបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្ម។ ក្រៅពីព្យាយាមរក្សាទុកលទ្ធភាពប្រើប្រាស់ទីផ្សារ ប្រទេសទាំងនោះក៏ត្រូវតែរក្សាទុកឧត្តមភាពដែលប្រទេសទាំងនោះអាចមានសមត្ថភាពផលិតតាមបែបប្រពៃណី។ ជាផ្នែកមួយនៃការចូលជាសមាជិកនៃ WTO ឧទាហរណ៍ ប្រទេសម៉ុងហ្គោលីត្រូវតែលុបបំបាត់ការដាក់កំហិតលើការនាំចេញក្រណាត់ការស្មែរនៅ។ ប្រការនេះបានធ្វើឱ្យខូចខាតភាពប្រកួតប្រជែងនៃសហគ្រាសសម្លៀកបំពាក់ ដោយសារអ្នកប្រកួតប្រជែងចំបងរបស់ខ្លួននៅក្នុងប្រទេសចិន អាចឥឡូវនេះទិញក្រណាត់កាស្មែរប្រកបដោយគុណភាពខ្ពស់ពីប្រទេសម៉ុងហ្គោលី ទោះបី GDP ក្នុងបុគ្គលម្នាក់ៗទាបជាង ១.០០០ ដុល្លារ ប្រទេសម៉ុងហ្គោលីមិនត្រូវបានអនុញ្ញាតឱ្យរក្សាទុកការឧបត្ថម្ភធនសម្រាប់ការនាំចេញទេ ជាប្រការមួយដែលសមាជិក

WTO នៅកម្រិតប្រហាក់ប្រហែលគ្នានៃការអភិវឌ្ឍ បានទទួលការអនុញ្ញាត ។

គោលបំណងគួរតែជាការព្យាយាមស្វែងរកលទ្ធភាពប្រើប្រាស់ទីផ្សារកាន់តែច្រើនឡើង ទន្ទឹមនឹងការអនុគ្រោះបន្តិចបន្តួចសម្រាប់ LDCs ប៉ុន្តែការពុំទាមទារឱ្យមានការកាត់បន្ថយដូចគ្នានេះ អាចធ្វើឱ្យខូចខាតផលិតកម្មតាមបែបប្រពៃណី ជាពិសេសនៅក្នុងវិស័យត្បាញតាមបែបបុរាណ និងសិប្បកម្មដែលជួលកម្មករនារីច្រើន ។

## ប្រឆាំងនឹងការលក់បង្ខូចថ្លៃនិងពន្ធគយទូទាត់

វិស័យ T&C បានរងគ្រោះជាយូរមកហើយដោយសារវិធានការប្រឆាំងការបង្ខូចថ្លៃ ។ រវាងឆ្នាំ ១៩៩៤ និង ២០០១ សហភាពអឺរ៉ុបបានផ្តួចផ្តើមឱ្យមានសកម្មភាពចំនួន ៥៣ ប្រឆាំងនឹងការបង្ខូចថ្លៃ និងពន្ធគយទូទាត់នៅក្នុងវិស័យវាយនភណ្ឌ ចំណែកស.រ.អា បានដាក់វិធានការគាំពារចំនួន ២៨ នៅក្រោម ATC រវាងឆ្នាំ ១៩៩៥ និង ២០០១ ។[២៦] នៅក្នុងរបបពាណិជ្ជកម្មសេរីជាងមុនសម្រាប់ T&C មានការរំពឹងទុកជាទូទៅថាប្រទេសជឿនលឿនអាចនឹងពឹងផ្អែកកាន់តែច្រើនឡើងលើវិធានការបែបនេះ ។ ដូច្នេះ ការពិភាក្សាអំពីបទបញ្ជារបស់ WTO គួរតែផ្តោតលើការកាត់បន្ថយទំហំនៃវិធានការនេះ ដោយដាក់ការព្យួរសកម្មភាពនានាប្រឆាំងនឹងផលិតករនៅក្នុង LDCs ។

## លើកកម្ពស់កិច្ចសហប្រតិបត្តិការត្បូង_ត្បូង

ទីផ្សារតាមបែបបុរាណ ដូចជាស.រ.អា សហភាពអឺរ៉ុប ជប៉ុន និងកាណាដា នៅតែមានជិត ៨០% នៃការនាំចូលនៅលើពិភពលោក ប៉ុន្តែកំណើនរបស់ប្រទេសទាំងនេះទៅអនាគតត្រូវបានរំពឹងថាមានបន្តិចបន្តួចតែប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ទីផ្សារធំជាងរបស់ប្រទេសកំពុងអភិវឌ្ឍន៍កំពុងកើនឡើងយ៉ាងឆាប់រហ័ស ។ ប្រទេសចិនបានក្លាយទៅជាទីផ្សារធំជាងគេទីបួននៅលើពិភពលោករួចទៅហើយ សម្រាប់សម្លៀកបំពាក់ដែលមាន ៥% នៃតម្រូវការសរុប ។ ប្រទេសប្រេស៊ីល និងអាហ្វ្រិកខាងត្បូង ក៏កំពុងកើនឡើងដែរ ទោះបីតាមល្បឿនទាបជាងក៏ដោយ ។

ដូច្នេះ ប្រទេសអាស៊ានមានកាលានុវត្តភាពដើម្បីបង្កើនពាណិជ្ជកម្ម T&C ទោះបីកិច្ចព្រមព្រៀងនានាកម្រិតតំបន់បានលើកកម្ពស់ពាណិជ្ជកម្មត្បូង-ត្បូងក៏ដោយ ដូច្នេះវាកាត់បន្ថយការពឹងផ្អែកលើទីផ្សារនៅអឌ្ឍគោលខាងជើង ។ ប្រការនេះអាចសម្រេចទៅបាននៅបើកម្រិតគឺលក់ទៅឱ្យទីផ្សារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ស្វែងរកផលិតផលពាក់កណ្តាលសម្រេចពីប្រទេសកំពុងអភិវឌ្ឍន៍ និងបង្កើតទំនាក់ទំនងជាមួយអ្នកវិនិយោគរបស់ខ្លួន និងបង្កើនកិច្ចសហប្រតិបត្តិការបច្ចេកទេសរវាងប្រទេសកំពុងអភិវឌ្ឍន៍ ។

ការធ្វើដំណើរទៅតាមទិសនេះ ទាមទារឱ្យមានការវិនិយោគជាច្រើនលើធនធាននិងពេលវេលា ដោយសិក្សាអំពីវប្បធម៌ដែលពុំសូវយល់ដឹង រចនាសម្ព័ន្ធទីផ្សារ និងប្រព័ន្ធចែកចាយនានា ។ ប៉ុន្តែ បញ្ហាមួយដែលអាចដោះស្រាយបានភ្លាមៗគឺកិច្ចការពារអត្រាពន្ធ ។ ទីផ្សារទាំងនេះ ជាច្រើនមានអត្រាពន្ធខ្ពស់ ។ ឧទាហរណ៍ នៅប្រទេសឥណ្ឌា និងម៉ិកស៊ិកូ អត្រាពន្ធលើការនាំចូលជាមធ្យមសម្រាប់ T&C គឺ ៣៥% ។ ជម្រើសមួយគឺការប្រើប្រាស់កិច្ចព្រមព្រៀងលើប្រព័ន្ធសកលនៃការអនុគ្រោះពាណិជ្ជកម្មក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ (GSTP) ដែលចាត់ចែងដោយ UNCTAD ដើម្បីជួយបង្កើនការស៊ីជម្រៅអំពីទំហំនៃការអនុគ្រោះពន្ធក្នុងចំណោម G-៧៧ ។ ប្រទេសកំពុងអភិវឌ្ឍន៍ធំៗ និងដែលជឿនលឿនជាង អាចប្រើប្រាស់កិច្ចព្រមព្រៀងនេះដើម្បីផ្តល់ការអនុគ្រោះដល់ LDCs ក្នុងការប្រើប្រាស់ទីផ្សារដែលជួយពួកគេរកបានច្រកចេញថ្មីៗ

ដែលអាចទូទាត់ការបាត់បង់នៅក្នុងទីផ្សារប្រពៃណី។

## ការអនុគ្រោះសម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិច

ប្រទេសជឿនលឿនផ្តល់លទ្ធភាពប្រើប្រាស់ទីផ្សារដោយគ្មានការដាក់កំហិតសម្រាប់ការនាំចេញ T&C ពី LDCs ខ្លះៗ ប៉ុន្តែមិនមែនពី LDCs ទាំងអស់នោះទេ។ ស.រ.អា ផ្តល់ការអនុគ្រោះនេះដល់ LDCs នៅតំបន់ក្បែរសាហារ៉ានៃទ្វីបអាហ្វ្រិក នៅក្រោម AGOA ប៉ុន្តែពុំផ្តល់ដល់ LDCs ណាមួយនៅអាស៊ីដែលផលិត T&C ដូចជា បង់ក្លាដេស កម្ពុជា ឡាវ និងនេប៉ាល់ឡើយ។ ផ្ទុយទៅវិញ សហភាពអឺរ៉ុបមិនយកពន្ធលើការនាំចេញពី LDCs ទាំងអស់នៅក្រោមកិច្ចផ្តួចផ្តើមរបស់ខ្លួនស្តីពី "អ្វីៗទាំងអស់លើកលែងតែសព្វាវុធ (EBA) ទោះបីអ្នកនាំចេញអាចមានលទ្ធភាពប្រើប្រាស់ការអនុគ្រោះនេះបានប្រសើរជាងក៏ដោយ ប្រសិនបើសហភាពអឺរ៉ុបធ្វើសុខុដុមនីយកម្មវិធានទាក់ទងនឹងប្រភពដើម ដើម្បីឱ្យអ្នកទទួលផលពុំចាំបាច់បំពេញតាមលក្ខណៈវិនិច្ឆ័យនៅក្នុងប្រព័ន្ធអនុគ្រោះខុសគ្នា។ ប៉ុន្តែ សូម្បីតែប្រទេសកំពុងអភិវឌ្ឍន៍ធំៗ ដូចជាចិន និងឥណ្ឌា ក៏អាចពិចារណាពង្រីកការអនុគ្រោះបែបនេះដល់ LDCs នៅអាស៊ីផងដែរ។

ការដោះស្រាយបញ្ហាទាំងនេះនឹងនាំឱ្យមានលទ្ធផលដែលផ្តល់ប្រយោជន៍យ៉ាងច្រើនសម្រាប់ការអភិវឌ្ឍមនុស្ស ជាពិសេសដោយសារស្ត្រីជាច្រើននៅ LDCs ធ្វើការនៅក្នុងឧស្សាហកម្មនេះ។

## ការផ្លាស់ប្តូរចម្បងនៅខាងមុខ

ឧស្សាហកម្មនៅទូទាំងពិភពលោកអាចស្ថិតនៅលើចំណុចចាប់ផ្តើមនៃការផ្លាស់ប្តូរចម្បងៗ។សម្រាប់រយៈពេលវែង សេរីភាវូបនីយកម្មពាណិជ្ជកម្ម តាមរយៈការលុបចោលកូតាអាចផ្តល់ការងារកាន់តែច្រើនឡើងនៅក្នុងប្រទេសខ្លះ និងលើកកម្ពស់ការអភិវឌ្ឍមនុស្ស។ ទន្ទឹមនឹងនេះ ប្រទេសដែលងាយរងគ្រោះអាចប្រឈមនឹងការអាក់ខាន ប្រសិនបើរោងចក្របិទទ្វារ ហើយភាពគ្មានការងារធ្វើកើនឡើង។

ប៉ុន្តែលទ្ធភាពប្រើប្រាស់ទីផ្សារពុំទាន់គ្រប់គ្រាន់ទេ។ ប្រទេសនាំចេញក៏ត្រូវតែកែលំអភាពប្រកួតប្រជែងផងដែរ រួមទាំងធ្វើការវិនិយោគលើការអភិវឌ្ឍជំនាញ កែលំអបច្ចេក-វិទ្យា បង្កើនប្រភេទមុខផលិតផល និងទីផ្សារ ព្រមទាំងធ្វើសមាហរណកម្មឱ្យប្រសើរថែមទៀតទៅក្នុងចង្វាក់នៃការផ្គត់ផ្គង់ពិភពលោក។

លើសពីនេះ កំណើនបរិមាណទំនិញក្នុងពាណិជ្ជកម្មបានពង្រីកចំណូលពីពាណិជ្ជកម្ម មិនសុទ្ធតែនាំឱ្យមានកំណើនចំនួនការងារធ្វើនោះឡើយ ហើយដោយសារលក្ខខណ្ឌធ្វើការមានភាពលំបាកនៅក្នុងរោងចក្រកាត់ដេរជាច្រើន កំណើនចំនួនការងារធ្វើមិនមែនសុទ្ធតែមានន័យថា ស្តង់ដារនៃការអភិវឌ្ឍមនុស្សមានកម្រិតខ្ពស់ដោយស្វ័យប្រវត្តិនោះឡើយ។ ដោយសារមានស្ត្រីជាច្រើនធ្វើការនៅក្នុងវិស័យនេះនៅអាស៊ី នេះក៏មានន័យថា មានឥទ្ធិពលយ៉ាងច្រើនខាងយេនឌ័រផងដែរ ទាំងឥទ្ធិពលវិជ្ជមាន និងអវិជ្ជមាន។


5

ជំពូក ៩

# ការលក់សេវាឆ្លងដែន

ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសទាំងអស់មានទាក់ទងនិងការបង្វែរការយកចិត្តទុកដាក់ពីកសិកម្មឬផលិតកម្មទៅក្នុងវិស័យសេវាកម្ម។ ប្រការនេះក៏កើតផងដែរនៅកម្រិតអន្តរជាតិ នៅពេលដែលបច្ចេកវិទ្យារីកចម្រើន និងការធ្លាក់ចុះនៃថ្លៃចំណាយលើការដឹកជញ្ជូន បានធ្វើឱ្យមានភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មសេវាកម្មឆ្លងកាត់ព្រំប្រទល់ប្រទេស។ តំបន់អាស៊ី-ប៉ាស៊ីហ្វិកធ្លាប់ស្ថិតនៅជួរមុខនៃការផ្លាស់ប្តូរនេះដែរ ជាពិសេស តាមរយៈចំណាកស្រុកនៃកម្លាំងពលកម្ម ការស្វែងរកលទ្ធកម្មពីប្រភពខាងក្រៅ និងឧស្សាហកម្មទេសចរណ៍។ ប៉ុន្តែ អ្នកកសាងគោលនយោបាយត្រូវតែចាត់វិធានការម៉ឺងម៉ាត់ ប្រសិនបើចង់ឱ្យពាណិជ្ជកម្មអន្តរជាតិលើសេវាកម្មផ្តល់អត្ថប្រយោជន៍កាន់តែច្រើនឡើងសម្រាប់ប្រជាពលរដ្ឋក្រីក្រ។

ប្រទេសនៅអាស៊ីបន្តពឹងផ្អែកលើពាណិជ្ជកម្មអន្តរជាតិខាងទំនិញ។ ប៉ុន្តែនៅក្នុងរយៈពេលបីទសវត្សរ៍ចុងក្រោយនេះ ប្រទេសទាំងនេះបានទាញយកផលចំណេញពីឱកាសដើម្បីបង្កើនពាណិជ្ជកម្មខាងសេវា ហើយជាលទ្ធផល ពាណិជ្ជកម្មអន្តរជាតិបានក្លាយជាមានភាពសាំញ៉ាំ និងសំបូរបែប។ ជំពូកនេះផ្តោតលើទម្រង់បីយ៉ាងនៃចលនាឆ្លងដែន។ នៅក្នុងទម្រង់ទីមួយ អ្នកលក់ធ្វើបម្លាស់ទី ដូចជានៅក្នុងការធ្វើចំណាកស្រុកជាអន្តរជាតិនៃកម្លាំងពលករ។ នៅក្នុងទម្រង់ទីពីរ ការងារជាអ្នកផ្លាស់ទី ដូចជាការស្វែងរកប្រភពជំនួញ និងទីបី អ្នកទិញជាអ្នកផ្លាស់ទី ដូចជាវិស័យទេសចរណ៍អន្តរជាតិ។[១,២]

ទម្រង់ទាំងបីនៃការផ្លាស់ទីបានកើនឡើងយ៉ាងច្រើន។ ចំពោះចំណាកស្រុក កម្មករដែលមានជំនាញតិចតួចបន្តធ្វើដំណើរទៅក្រៅប្រទេសដើម្បីធ្វើការតាមកិច្ចសន្យារយៈពេលខ្លី ជាពិសេសពីប្រទេសបង់ក្លាដេស កម្ពុជា ចិន នេប៉ាល់ ហ្វីលីពីន និងស្រីលង្កា។ ចំនួនប្រមាណ ១០% នៃពលករពីប្រទេសហ្វីលីពីន និង ១២% ពីប្រទេសស្រីលង្កា បច្ចុប្បន្នកំពុងធ្វើការនៅក្រៅប្រទេស។ អ្នកធ្វើចំណាកស្រុកនៅក្នុងប្រទេសបានលើកកម្ពស់គុណភាពនៃការរស់នៅរបស់ខ្លួន ហើយសូម្បីតែអ្នកក្រីក្រជាងគេក៏រកប្រាក់ចំណូលបានគ្រប់គ្រាន់សម្រាប់លើកស្ទួយគ្រួសាររបស់ខ្លួនឱ្យផុតពីភាពក្រីក្រផងដែរ។

អាស៊ីក៏ធ្លាប់ជាអ្នកឈានមុខក្នុងការផ្តល់សេវា IT និងសេវាលើដំណើរការជំនួញផងដែរ។ នៅក្នុងករណីខ្លះកម្មករ IT បន្តធ្វើដំណើរទៅក្រៅប្រទេស ប៉ុន្តែ ភាពជឿនលឿនខាងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង និងការចុះថោកនៃបណ្តាញអ៊ីនធឺណិត បានធ្វើឱ្យមានការផ្តល់ឱ្យពីចម្ងាយនូវសេវាទាំងនេះកាន់តែច្រើនឡើង ដែលជាការផ្តល់ការងារសម្រាប់មនុស្សក្មេងៗដែលមានការអប់រំខ្ពស់ ហើយប្រសិនបើពុំមានការងារបែបនេះទេ ក្មេងៗទាំងនោះនឹងត្រូវប្រឈមនឹងការលំបាកដើម្បីស្វែងរកការងារដែលទាញយកផលចំណេញពីមុខជំនាញរបស់ក្មេងៗទាំងនោះ។

នៅក្នុងផ្នែកទេសចរណ៍ក៏ដូច្នោះដែរ តំបន់អាស៊ី-ប៉ាស៊ីហ្វិកគឺជាអ្នកដឹកនាំមួយនៅក្នុងពិភពលោកដែលបានបង្កើនភាគចំណែករបស់ខ្លួនលើការធ្វើចរាចរពិភពលោកពី ១០% នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០មក ៤០% នៅឆ្នាំ ២០០៤។

ទេសចរណ៍អាចផ្តល់ការងារធ្វើសូម្បីនៅទីកន្លែងដាច់ស្រយាល។

មានសេវាជាច្រើនផ្សេងទៀតដែលត្រូវបានធ្វើពាណិជ្ជកម្មឆ្លងដែន រួមទាំងសេវាសុខភាព សេវាហិរញ្ញវត្ថុ និងសេវាបរិស្ថាន។ ផ្នែកខាងក្រោយនៃជំពូកនេះ ពិនិត្យមើលជាពិសេសអំពីទម្រង់ចម្បងនៃសេវាសេដ្ឋកិច្ច។

## ចំណាកស្រុករយៈពេលខ្លី

*អាស៊ីធ្លាប់បានមានលំហូរចំណាកស្រុកយ៉ាងច្រើន*

អាស៊ីធ្លាប់បានមានលំហូរចំណាកស្រុកយ៉ាងច្រើនទាំងនៅក្នុង និងឆ្លងកាត់ទៅក្រៅតំបន់នេះ។ ឧទាហរណ៍ នៅសតវត្សរ៍ទី ១៩ កម្មករក្រោមកិច្ចព្រមព្រៀងជាច្រើនលាននាក់បានចាកចេញពីប្រទេសនៅអាស៊ីខាងត្បូង និងចិន អ្នកខ្លះធ្វើដំណើរទៅកន្លែងផ្សេងនៅអាស៊ី និងខ្លះទៀតទៅអាមេរិកខាងជើង ការ៉ាអ៊ីប និងអាហ្វ្រិក។ នៅសតវត្សរ៍ទី ២០ មនុស្សជាច្រើនបានចាកចេញពីតំបន់នេះ ដើម្បីទៅតាំងទីលំនៅរយៈពេលវែងនៅអឺរ៉ុប និងអាមេរិកខាងជើង។

ឥឡូវ លំហូរនៃការធ្វើចំណាកស្រុកច្រើនតែមានភាពកាន់តែសាំញ៉ាំ ប៉ុន្តែអ្នកចំណាកស្រុកស្ថិតក្នុងក្រុមណាមួយក្នុងចំណោមក្រុមទាំងបីខាងលើ។ ក្រុមទីមួយ គឺជាកម្មករឯកទេសដែលមានការអប់រំ និងជំនាញខ្ពស់ ដែលធ្វើដំណើរឆ្ពោះជាពិសេសទៅប្រទេសជឿនលឿន ពោលគឺ ស.រ.អា អឺរ៉ុបខាងលិច អូស្ត្រាលី និងនូវែលហ្សេឡង់។ ក្រុមទីពីរគឺ កម្មករគ្មានជំនាញឬមានជំនាញតិចតួច ដែលធ្វើដំណើរទៅប្រទេសជាច្រើនរួមទាំងទៅក្រៅតំបន់នេះផង ឧទាហរណ៍ ទៅបណ្តារដ្ឋនៅឈូងសមុទ្រ ឬទៅប្រទេសអាស៊ីដែលមានការអភិវឌ្ឍលឿនបំផុត។ ក្រុមទីបីដែលមានចំនួនមនុស្សតិចតួច គឺអ្នកជំនួញ និងអ្នកឯកទេស ដែលត្រូវបានបញ្ជូនទៅតាមក្រុមហ៊ុនអន្តរជាតិ។ ទម្រង់រួមនៃចលនាកម្មករគ្មានជំនាញមានបង្ហាញជូននៅក្នុងប្រអប់ ៥.១។

ចំណាកស្រុកអាចត្រូវបានចាត់ទុកថា ជាការឆ្លើយតបចំពោះអតុល្យភាពអន្តរជាតិ នៅពេលដែលកម្មករផ្លាស់ទីពីប្រទេសដែលមានចំនួនពលករច្រើនហួសពីតម្រូវការទៅប្រទេសដែលខ្វះកម្លាំងពលកម្ម។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងស្ថានភាពជាក់ស្តែង ប្រទេសដែលជាគោលដៅទំនងជាមានអំណាចត្រួតត្រាលំហូរ ដោយសារពួកគេព្យាយាមរកពលករ ដើម្បីបំពេញភាពខ្វះចន្លោះនៅក្នុងទីផ្សារពលកម្មរបស់ខ្លួន ឬមួយនៅកម្រិតខាងលើ សម្រាប់អ្នកឯកទេសដែលមានការសិក្សាខ្ពស់ ដូចជាសាស្ត្រាចារ្យ ឬវេជ្ជបណ្ឌិត ឬនៅខាងក្រោម សម្រាប់កម្មករគ្មានជំនាញនៅក្នុងចំការដំណាំធំៗ ឬនៅតាមការដ្ឋាន។

នៅក្នុងតំបន់នេះ ប្រទេសដែលជាគោលដៅចម្បងរួមមាន ប្រទេសជប៉ុន សិង្ហបុរី និងសាធារណរដ្ឋកូរ៉េ ប៉ុន្តែចាប់ពីដើមទសវត្សរ៍ឆ្នាំ ១៩៨០ ដល់ពាក់កណ្តាលទសវត្សរ៍ ឆ្នាំ ១៩៩០ កំណើនអតិបរមានៃសេដ្ឋកិច្ចក៏បានបង្កើតឱ្យមានកង្វះពលករនៅប្រទេសម៉ាឡេស៊ី និងថៃផងដែរ និងបានទាក់ទាញកម្មករពីប្រទេសជិតខាង។ នៅក្រៅតំបន់នេះ ប្រទេសដែលជាគោលដៅចម្បងគឺ ជាប្រទេសនាំចេញប្រេងនៅអាស៊ីខាងលិច និងឈូងសមុទ្រពែរ្ស ដែលមិនត្រឹមតែទាក់ទាញកម្មករគ្មានឬមានជំនាញតិចតួច សម្រាប់ការសាងសង់ និងសេវាកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាក់ទាញអ្នកឯកទេសជាចំនួនច្រើនជាពិសេសអ្នកដែលធ្វើការខាងផ្នែកវិស្វកម្ម គណនេយ្យ និងផ្នែកសេវាសុខភាព។ ទន្ទឹមនឹងអាស៊ីខាងលិចដែលនៅតែជាប្រទេសសំខាន់សម្រាប់ការងាររយៈពេលខ្លីនៅក្រៅប្រទេស ស.រ.អា និងសហភាពអឺរ៉ុបនៅតែជាគោលដៅសំខាន់សម្រាប់ចំណាកស្រុកជាទូទៅ។ ថ្មីៗបំផុតនេះមានកំណើនចំណាកស្រុករយៈពេលខ្លីនៃអ្នកឯកទេសខាងកម្មវិធីកុំព្យូទ័រទៅស.រ.អា។

គ្រប់ប្រទេសនៅក្នុងតំបន់នេះបានផ្តល់ពលករចំណាក

ស្រុក ប៉ុន្តែប្រភពធំជាងគេតែមួយធ្លាប់ជាប្រទេសហ្វីលីពីន។ កម្មករហ្វីលីពីនដែលមានកម្រិតជំនាញខុស១គ្នាបានធ្វើដំណើរទៅទូទាំងពិភពលោក ប៉ុន្តែទំនងជាប្រមូលផ្តុំនៅតាមគោលដៅជាក់លាក់មួយចំនួន ឧទាហរណ៍ជាអ្នកជួយធ្វើការក្នុងផ្ទះ បានប្រមូលផ្តុំនៅហុងកុង និងប្រទេសអារ៉ាប់ រួមជាអ្នកផ្តល់សេវាខាងការកំសាន្តក្នុងប្រទេសជប៉ុន និងនៅតាមប្រទេសអាស៊ីបូព៌ា ចំណែកអ្នកឯកទេស IT និងគិលានុប្បដ្ឋាក គឺនៅក្នុងស.រ.អា និងចក្រភពអង់គ្លេស។

## អត្ថប្រយោជន៍ពីការធ្វើចំណាកស្រុករយៈពេលខ្លី

ចំណាកស្រុកនាំមកនូវផលប្រយោជន៍ជាច្រើន ទាំងខាងសេដ្ឋកិច្ចនិងសង្គម ទាំងសម្រាប់បុគ្គលដែលធ្វើចំណាកស្រុក និងប្រទេសដែលខ្លួនចាកចេញ។

ប្រាក់ផ្ញើមកផ្ទះសម្រាប់ប្រទេសជាប្រភពដើមផលប្រយោជន៍មួយក្នុងចំណោមប្រយោជន៍ដោយផ្ទាល់គឺលំហូរសាច់ប្រាក់ដែលផ្ញើមកផ្ទះវិញ នៅពេលដែលអ្នកចំណាកស្រុកបញ្ជូនឬយកមកផ្ទះវិញនូវប្រាក់ដែលខ្លួនរកបាន។ នៅទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ ភាគច្រើននៃប្រទេសជាប្រភពដើម ជាពិសេសឥណ្ឌា និងហ្វីលីពីន បានទទួលកំណើនយ៉ាងខ្លាំងនៃប្រាក់ចំណូលបានពីការផ្ញើ (រូបទី ៥.១)។

សម្រាប់ប្រទេសជាច្រើន ប្រាក់ផ្ញើទៅឱ្យគឺជាប្រភពដ៏សំខាន់នៃរូបិយបណ្ណបរទេស។ ឧទាហរណ៍ នៅវៀតណាម រវាងឆ្នាំ ១៩៩៩ និង ២០០២ លំហូរចូលនៃប្រាក់ផ្ញើឱ្យនេះបានកើនឡើងពី ១.០០០លានដុល្លារ ដល់ ១.៥០០លានដុល្លារ។ ឥឡូវនេះប្រាក់ផ្ញើឱ្យនេះមានប្រមាណ ១០% នៃចំណូល បានពីការនាំចេញ ដែលសមមូលប្រហែលនឹងលំហូរប្រចាំឆ្នាំនៃជំនួយអភិវឌ្ឍន៍ក្រៅប្រទេស ឬការវិនិយោគផ្ទាល់ពីបរទេស។[៣] សូម្បីតែសម្រាប់ប្រទេសធំ១ ដូចជា ឥណ្ឌាបានទទួលប្រាក់ផ្ញើត្រឡប់

ប្រអប់ ៥.១

**ការផ្លាស់ទីនៃពលករគ្មានជំនាញនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក**

| | |
|---|---|
| ប្រទេសជាប្រភព | បង់ក្លាដេស កម្ពុជា ចិន ឥណ្ឌូនេស៊ី ឡាវ ភូមា នេប៉ាល់ ហ្វីលីពីន ស្រីលង្កា វៀតណាម |
| ប្រទេសជាគោលដៅ | ប្រ៊ុយណេ ហុងកុង (ចិន) ជប៉ុន សាធារណរដ្ឋកូរ៉េ សឹង្ហបូរី តៃវ៉ាន់ (ចិន) |
| ប្រទេសជាប្រភព និងជាគោលដៅ | ឥណ្ឌា ម៉ាឡេស៊ី ប៉ាគីស្ថាន ថៃ |

**សម្គាល់ ៖ ចំណាត់ថ្នាក់នៅទីនេះ សំដៅលើលំហូរដ៏ច្រើននៃពលករមានជំនាញតិចតួចតែប៉ុណ្ណោះ ប៉ុន្តែពុំរួមបញ្ចូលការឆ្លងទៅមកតាមរង្វង់រវាងប្រជាជននៃប្រទេសជាប់ព្រំដែនគ្នានោះទេ ដែលច្រើនតែជាទម្លាប់នៅក្នុងសេដ្ឋកិច្ចទាំងអស់ដែលធ្លាប់កើតមានឡើងជាច្រើនសតវត្សរ៍មកហើយ។**

**ប្រភព៖ ផ្អែកតាម Wickramasekara ២០០២**

មកផ្ទះវិញនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ ច្រើនជាងលំហូរចូលនៃមូលធនតាមគ្រប់ទម្រង់ផ្សេងទៀត។ ការផ្ញើប្រាក់ត្រឡប់មកវិញនេះ មានបរិមាណច្រើន និងផ្តល់អត្ថប្រយោជន៍បន្ថែមទៀត ដោយសារវាមានលក្ខណៈគួរឱ្យទុកចិត្តបានធៀបនឹងលំហូរដទៃទៀត ហើយប្រាក់ផ្ញើទាំងនោះច្រើនតែបានមកពីអ្នកចំណាកស្រុកដែលធ្វើការនៅក្នុងវិស័យសេវាកម្ម ដែលពុំសូវមានការប្រែប្រួលទៅតាមវដ្តនៃការផ្លាស់ប្តូរខាងផ្នែក




រូបទី ៥.១៖ លំហូរនៃការប្រាក់ផ្ញើមកផ្ទះ នៅក្នុងប្រទេសមួយចំនួននៅអាស៊ី ឆ្នាំ ១៩៨៣-២០០៣ គិតជាពាន់លានដុល្លារ

ប្រភព : ធនាគារពិភពលោក ២០០៥

*ចំណាកស្រុកនាំមកនូវផលប្រយោជន៍ជាច្រើន ទាំងខាងសេដ្ឋកិច្ច និងសង្គម ទាំងសម្រាប់បុគ្គលដែលធ្វើចំណាកស្រុក និងប្រទេសដែលខ្លួនចាកចេញ*

ជំនួញនៅក្នុងប្រទេសជាម្ចាស់ផ្ទះឡើយ ។

អ្នកចំណាកស្រុកម្នាក់ៗ និងគ្រួសាររបស់គាត់ប្រើប្រាស់ប្រាក់ចំណូលនេះសម្រាប់គោលដៅខុសគ្នាជាច្រើន ។ អ្នកខ្លះនឹងចាយប្រាក់ដែលទទួលបាននេះសម្រាប់តម្រូវការជាបន្ទាន់ ដូចជា អាហារ ការអប់រំ ឬការថែទាំសុខភាព ។ អ្នកផ្សេងទៀតអាចទិញផ្ទះឬវិនិយោគលើមុខជំនួញ (ប្រអប់ ៥.២) ។ សម្រាប់សហគមន៍ជាច្រើន ចំណាកស្រុកបានជួយជាមាគ៌ាសម្រាប់ចាកចេញពីភាពក្រីក្រ ។ ប្រាក់ដែលផ្ញើមកផ្ទះក៏ត្រូវបានប្រើប្រាស់ផងដែរសម្រាប់សកម្មភាពសហគមន៍ ដោយសារអ្នកចំណាកស្រុកបានកសាងបណ្តាញឆ្លងប្រទេស និងផ្តល់មូលនិធិដែលផ្តល់ជាប្រយោជន៍សម្រាប់ភូមិ និងតំបន់ដែលជាកន្លែងកំណើតរបស់ខ្លួនផងដែរ ។ ឧទាហរណ៍ អ្នកចំណាកស្រុកពីរដ្ឋគុចារ៉ាតនៃប្រទេសឥណ្ឌាដែលបានក្លាយជាម្ចាស់ហាងលក់ទំនិញ ម្ចាស់សណ្ឋាគារ អ្នកជំនួញនៅចក្រភពអង់គ្លេស និងអាហ្វ្រិកខាងកើត បានជួយកសាងហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាប្រព័ន្ធសេវាសុខភាព និងការអប់រំនៅក្នុងរដ្ឋជាស្រុកកំណើត ។

ប្រអប់ ៥.២

**ការប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះនៅបង់ក្លាដេស**

ការអង្កេតមួយនៅបង់ក្លាដេសបង្ហាញឱ្យឃើញថា កម្មករពីក្រៅប្រទេសចំណាយប្រមាណ ៣០% នៃប្រាក់ចំណូលរបស់ខ្លួន លើការប្រើប្រាស់ផ្ទាល់ខ្លួននៅក្រៅប្រទេស ផ្ញើ ៤៥% មកផ្ទះវិញ និងសន្សំទុក ២៥% ។ ក្នុងចំណោមប្រាក់បញ្ជូនមកផ្ទះ ៥០% ត្រូវបានប្រើប្រាស់សម្រាប់ការរស់នៅ រួមទាំងលើអាហារ ការអប់រំ និងការថែទាំសុខភាព ២៩% យកទៅវិនិយោគលើដីធ្លី និងទ្រព្យសម្បត្តិផ្សេងទៀត និង ២១% សម្រាប់កែលំអផ្ទះ រួមទាំងកែលំអអចលនទ្រព្យដែលមានស្រាប់ ។

ការអង្កេតដដែលក៏រកឃើញផងដែរថាការបញ្ជូនប្រាក់មកផ្ទះ ជាទៀងទាត់សម្រាប់រយៈពេលវែងអាចឱ្យគ្រួសារនានាផ្លាស់ប្តូរពីការរកចំណូលដោយស៊ីឈ្នួលទៅជាការធ្វើការដើម្បីមុខជំនួញខ្លួនឯង និងផ្លាស់ប្តូរពីការដាំដំណាំទៅជាសកម្មភាពច្រើនបែបក្រៅកសិដ្ឋាន ។

**ប្រភពៈ IOM-UNDP ២០០២; Raihan ២០០៤ ។**

ដូចគ្នានេះដែរ កម្មករមកពីរដ្ឋកេរ៉ាឡា បានជួយផ្តល់ហិរញ្ញវត្ថុសម្រាប់កសាងព្រលានយន្តហោះអន្តរជាតិ ដើម្បីសំរួលការធ្វើដំណើររវាងស្រុកកំណើតរបស់ខ្លួន និងប្រទេសដែលខ្លួនធ្វើការ ។[៤]

ជាទូទៅ លំហូរសាច់ប្រាក់ផ្ញើត្រឡប់មកផ្ទះវិញដែលមានបរិមាណច្រើនជាងគេបានមកពីអ្នកចំណាកស្រុករយៈពេលខ្លី សម្រាប់រកចំណូលពីសេដ្ឋកិច្ច ។ ផ្ទុយទៅវិញ អ្នកចំណាកស្រុករយៈពេលវែងពុំទំនងជាផ្ញើប្រាក់មកស្រុកកំណើតទេ ។ ជាធម្មតាកម្មករឯកទេសដែលបានតាំងទីលំនៅក្នុងប្រទេសជឿនលឿនចង់រក្សាទុកប្រាក់ចំណូលរបស់ខ្លួនកាន់តែច្រើន ។ នៅពេលដែលពួកគេផ្ញើប្រាក់មកផ្ទះ ទឹកប្រាក់នោះគឺសម្រាប់ការវិនិយោគដែលពួកគេទាមទារឱ្យសងវិញ ។

*បទពិសោធ និង ជំនាញ* : អ្នកផ្លាស់ទីនាំមកផ្ទះវិញមិនត្រឹមតែប្រាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបទពិសោធការងារដ៏មានតម្លៃផងដែរ ដែលអាចលើកកម្ពស់សកម្មភាពសេដ្ឋកិច្ច ការបង្កើតថ្មី និងការអ្នកដឹកនាំក្នុងសហគ្រាស ។ ដោយបានទទួលបទពិសោធទាំងនេះ អ្នកចំណាកស្រុកអាចប្រើប្រាស់បានប្រសើរជាងមុននូវប្រាក់ដែលខ្លួននាំត្រលប់មកផ្ទះវិញនោះ ។

ការផ្ទេរជំនាញបែបនេះមានសារៈសំខាន់ដោយឡែកសម្រាប់អ្នកជំនាញឯកទេសជាពិសេសនៅក្នុងឧស្សាហកម្មដែលទាក់ទងនឹង IT ។ ឧទាហរណ៍នៅក្នុងដំណើរការស្វែងរកលទ្ធកម្មពីខាងក្រៅ ក្រុមហ៊ុនសេវាកម្មបញ្ជូនទីប្រឹក្សា និងអ្នកឯកទេសសំខាន់ៗទៅឱ្យអតិថិជន ដើម្បីទទួលយកចំណេះដឹង និងផ្ទេរត្រឡប់មកឱ្យក្រុមហ៊ុនវិញនៅអាស៊ីនូវព័ត៌មានអំពីការអនុវត្តបច្ចេកទេស ផលិតផល ដំណើរការ និងបច្ចេកទេសទំនាក់ទំនងទីផ្សារ ។ ដូចគ្នានេះដែរនៅក្នុងផ្នែកសុខភាព វេជ្ជបណ្ឌិត និងអ្នកឯកទេសដែលត្រឡប់មកវិញ អ្នកមានលទ្ធភាពផ្ទេរចំណេះដឹងអំពីបច្ចេកទេសថ្មីៗ ដែលជួយបង្កើន

ស្តង់ដានៃការថែទាំសុខភាព និងជាទូទៅ ធ្វើការកែលំអលើការផ្តល់សេវាសុខភាព។

*ការផ្តល់អំណាចដល់ស្ត្រី* ៖ ការផ្លាស់ទីក៏មានឥទ្ធិពលពិសេសខាងសង្គមផងដែរ ជាពិសេសនៅក្នុងការផ្តល់អំណាចដល់ស្ត្រី។ នៅក្នុងអំឡុងទសវត្សរ៍ថ្មីៗនេះ ស្ត្រីចំណាកស្រុកពីអាស៊ីមានប្រភពពីប្រទេសចំនួនបីជាចម្បងគឺ ឥណ្ឌូណេស៊ី ហ្វីលីពីន និងស្រីលង្កា ដែលពួកគេមានចំនួនពី ៦០-៨០% នៃចំនួនចំណាកស្រុកស្របច្បាប់ទាំងអស់ (រូបទី ៥.២)។ ប្រទេសខ្លះៗក្នុងចំណោម LDCs ដូចជាបង់ក្លាដេស ក៏មានអត្រាទាបនៃអ្នកចំណាកស្រុកដែរ ប៉ុន្តែមានសមាមាត្រស្ត្រីមានអត្រាខ្ពស់។

ភាគច្រើននៃស្ត្រីទាំងនេះត្រូវបានជួលឱ្យធ្វើការក្នុងវិស័យថែទាំសុខភាព និងសេវាក្នុងគ្រួសារ។ ឧទាហរណ៍ ប្រទេសហ្វីលីពីនគឺជាប្រភពធំជាងគេនៃគិលានុប្បដ្ឋាយិកា។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ មានការហូរចេញយ៉ាងច្រើននៃគិលានុប្បដ្ឋានហ្វីលីពីនទៅស.រ.អា។ បន្ទាប់មក រវាងឆ្នាំ ១៩៩៥ និង២០០១ មានការផ្លាស់ទីជាមធ្យម ៥៧.០០០នាក់ ជារៀងរាល់ឆ្នាំ ជាពិសេសទៅចក្រភពអង់គ្លេស និងអារ៉ាប់ប៊ីសាអ៊ូឌីត។ ស្ត្រីពីប្រទេសឥណ្ឌូណេស៊ី និងស្រីលង្កា ច្រើនតែធ្វើដំណើរទៅធ្វើការក្នុងផ្នែកសេវាកម្មតាមផ្ទះ ជាពិសេស ទៅអារ៉ាប៊ីសាអ៊ូឌីត គុយវ៉ែត និងអារ៉ាប់រួម។

## ចំណុចខ្សោយនៃចំណាកស្រុករយៈពេលខ្លី

ទន្ទឹមនឹងផលប្រយោជន៍សម្រាប់សហគមន៍ដែលបញ្ជូនសមាជិកចេញក្រៅចំណាកស្រុកក៏មានទិដ្ឋភាពអវិជ្ជមានផងដែរ។ ជនចំណាកស្រុកអាចប្រទះនឹងលក្ខខណ្ឌការងារដ៏លំបាក ហើយការចេញដំណើររបស់ពួកគេបានបង្កើតឱ្យមានបញ្ហាជាច្រើននៅក្នុងប្រទេសកំណើតរបស់ពួកគេ។

*លក្ខខណ្ឌនៅកន្លែងធ្វើការងារ* ៖ ធៀបនឹងប្រជាជននៅក្នុងមូលដ្ឋាន អ្នកចំណាកស្រុកងាយរងការកេងប្រវ័ញ្ច។ អ្នកចំណាកស្រុកបណ្តោះអាសន្នដែលមានជំនាញតិចតួច ច្រើនតែពុំដឹងអំពីសិទ្ធិរបស់ខ្លួន និងមានកិច្ចការពារខ្លួនតិចតួចតែប៉ុណ្ណោះ ជាពិសេសនៅពេលដែលនិយោជកប្រមូលយកលិខិតឆ្លងដែន




រូបទី ៥.២៖ ចំណាកស្រុកនៃបុរសនិងស្ត្រីពីប្រទេសស្រីលង្កា

ប្រភព ៖ ការិយាល័យការងារនៅបរទេស របស់ស្រីលង្កា២០០១

### ប្រអប់ ៥.៣

### ភាពរើសអើងលើការផ្តល់ទិដ្ឋាការធ្វើការងារ

អាស្រ័យតាមប្រភេទការងារ យូរៗម្តង អ្នកក្រីក្រដែលធ្វើចំណាកស្រុក ជាទូទៅមកពីប្រទេសនៅអាស៊ីខាងត្បូង និងហ្វីលីពីន បានទទួលការកេងប្រវ័ញ្ចនៅក្នុងប្រទេសជាគោលដៅ។ នេះជាករណីដែលកើតឡើងនៅពេលប្រទេសទទួលចំណាកស្រុកដោយទិដ្ឋាការប្រភេទខុសគ្នាសម្រាប់ប្រភេទការងារខុសគ្នា។ ឧទាហរណ៍ ប្រទេសនៅអាស៊ីខាងលិចខ្លះចេញទិដ្ឋាការពីរបែបឱ្យដល់កម្មករជាអ្នកចំណាកស្រុកបណ្តោះអាសន្ន។ ទិដ្ឋាការ "ប្រភេទ B" នឹងចេញឱ្យកម្មករចំណាកស្រុកដែលត្រូវបានជួលដោយក្រុមហ៊ុននៅក្នុងវិស័យផ្លូវការនៃសេដ្ឋកិច្ច។ កម្មករទាំងនេះនឹងទទួលកិច្ចការពារនៅក្រោមច្បាប់ការងារ និងអនុញ្ញាតឱ្យស្នាក់នៅខាងក្រៅបរិវេណនៃកន្លែងធ្វើការ។ ប៉ុន្តែ ទិដ្ឋាការ "ប្រភេទ A" អនុញ្ញាតឱ្យនិយោជករក្សាទុកលិខិតឆ្លងដែនរបស់កម្មករចំណាកស្រុក ដើម្បីប្រមូលផ្តុំកម្មករទាំងនោះនៅក្នុងផ្ទះ និងប្រើអំណាចផ្តាច់ការទៅលើលក្ខខណ្ឌការងារ និងម៉ោងធ្វើការ។ ឧទាហរណ៍ អ្នកបម្រើតាមផ្ទះអាចទទួលបានត្រឹមតែទិដ្ឋាការប្រភេទ A ដែលធ្វើឱ្យពួកគេពឹងផ្អែកតែលើនិយោជកដើម្បីអាចទទួលបានសិទ្ធិអប្បបរមា ហើយកម្មករជាច្រើនបានតវ៉ាអំពីការបង្ខិតបង្ខំឱ្យធ្វើការជាច្រើនម៉ោង ភាពនៅឯកោ និងសុខភាពមិនល្អ ការលំបាកដើម្បីទាក់ទងជាមួយគ្រួសារ និងបៀតបៀនខាងផ្លូវភេទ។

របស់ខ្លួន (ប្រអប់ ៥.៣)។ សូម្បីតែកម្មករឯកទេសក៏អាចប្រឈមនឹងការរើសអើង ដោយទទួលបានប្រាក់កម្រៃទាប និងផលប្រយោជន៍ផ្សេងទៀតតិចតួចផងដែរ ធៀបនឹងបុគ្គលិកជាតិដែលមានសមត្ថភាពប្រហែលគ្នា។ ពួកគេអាចឃើញថា ប្រទេសជាម្ចាស់ផ្ទះពុំទទួលស្គាល់សមត្ថភាពរបស់ពួកគេឡើយ ហើយទាមទារឱ្យធ្វើការប្រឡងជាថ្មី។ ស្ថាបត្យករអាចត្រូវធ្វើការជាអ្នកគូរប្លង់ វិស្វករជាបុគ្គលិកបច្ចេកទេស គិលានុប្បដ្ឋាកជាជំនួយការគិលានុប្បដ្ឋាក និងទន្តបណ្ឌិត ជាជំនួយការទន្តពេទ្យ។

*ឥទ្ធិពលខាងសង្គមទៅលើគ្រួសារ* : សម្រាប់គ្រួសារនានា ចំណាកស្រុកផ្តល់អត្ថប្រយោជន៍ខាងហិរញ្ញវត្ថុ ប៉ុន្តែមានការរំខានខាងសង្គម។ ការបែកគ្នារយៈពេលវែងអាចបង្កឱ្យមានទំនាក់ទំនងមិនស្មោះត្រង់ ហើយសហព័ទ្ធដែលនៅតែឯងឯផ្ទះអាចក្លាយជាអ្នកផឹកស្រា ឬលេងល្បែង។ ជាលទ្ធផលគ្រួសាររបស់អ្នកចំណាកស្រុកច្រើនតែមានអត្រាខ្ពស់នៃការលែងលះគ្នា។ ការផ្លាស់ទីក៏ទំនងជានាំឱ្យមានការពន្យារពេលអាពាហ៍ពិពាហ៍ផងដែរ ហើយជាពិសេសស្ត្រីដែលជាជនចំណាកស្រុក អាចមានការលំបាករកគ្រួសារនៅពេលត្រឡប់មកវិញ។ កុមារក៏អាចរងគ្រោះផងដែរដោយសារអវត្តមានមាតាបិតាជាពិសេសអវត្តមានម្តាយ និងការប្រឈមខាងបញ្ហាចិត្តសាស្ត្រ និងអាកប្បកិរិយាឬរៀនខ្សោយ។

*សម្រាប់គ្រួសារនានា ចំណាកស្រុកផ្តល់ អត្ថប្រយោជន៍ខាង ហិរញ្ញវត្ថុ ប៉ុន្តែមាន ការរំខានខាងសង្គម*

*កំណើនវិសមភាព* : ចំណាកស្រុកអាចបង្កើនយ៉ាងខ្លាំង នូវប្រាក់ចំណូលរបស់គ្រួសារមួយចំនួនតូចដែលធ្វើឱ្យពួកគេមានធនធានច្រើនជាងអ្នកជិតខាងរបស់ខ្លួន ហើយជាទូទៅ នាំឱ្យមានកំណើននៃការគាបសង្កត់ទៅលើទម្រង់នៃប្រាក់ចំណូល និងការចាយវាយ។ ឧទាហរណ៍ នៅប្រទេសហ្វីលីពីន លំហូរចូលនៃប្រាក់ផ្ញើមកផ្ទះបានធ្វើឱ្យមានវិសមភាពប្រាក់ចំណូលនៅមូលដ្ឋាន។[៦]

*ការធ្វើសមាហរណកម្មឡើងវិញ* : ជនចំណាកស្រុកដែលធ្វើមាតុភូមិនិវត្តន៍អាចប្រឈមបញ្ហាខាងសង្គម និងសេដ្ឋកិច្ច នៅពេលត្រឡប់មកដល់ផ្ទះវិញ។ ឧទាហរណ៍ នៅប្រទេសស្រីលង្កា ជាទូទៅទាំងស្ត្រីនិងបុរសដែលធ្វើចំណាកស្រុកបានធ្វើសមាហរណកម្មឡើងវិញដោយងាយស្រួល។ ប៉ុន្តែដោយសារពួកគេមានការអប់រំទាប អ្នកខ្លះអាចរកមិនបានការងារដែលខ្លួនរំពឹងចង់ធ្វើ។ ឧទាហរណ៍ បណ្តាអ្នកដែលធ្វើជាអ្នកបម្រើតាមផ្ទះនៅក្រៅប្រទេស អាចមិនចង់ធ្វើការងារបែបនេះនៅស្រីលង្កា ដែលមានឋានុក្រមទាបនៅក្នុងសង្គម។ បទពិសោធការងាររបស់ពួកគេនៅក្នុងប្រទេសដែលជឿនលឿនជាង អាចផ្តល់ឱ្យពួកគេនូវប្រាក់បៀវត្សរ៍ ដែលពួកគេមិនអាចរំពឹងគិតដល់។

*ការបាត់បង់ធនធានមនុស្ស* : ប្រទេសដែលជាគោលដៅអាចទទួលជំនាញពីជនចំណាកស្រុក ប៉ុន្តែសម្រាប់ប្រទេសជាប្រភពដើមនេះអាចជាការបាត់បង់មួយយ៉ាងច្រើន។ ឧទាហរណ៍នៅហ្វីលីពីនដែលច្រើនជាងមួយភាគបីនៃជនចំណាកស្រុកជាអ្នកឯកទេសនិងកម្មករបច្ចេកទេសការចាកចេញរបស់ពួកគេ ធ្វើឱ្យមានការខ្វះខាតបុគ្គលិកយ៉ាងធ្ងន់ធ្ងរនៅក្នុងវិស័យសុខភាព និងនាំឱ្យមានការទាមទារប្រាក់កម្រៃខ្ពស់។ រវាងឆ្នាំ ១៩៩៥ និង ២000 ចំនួនគិលានុប្បដ្ឋាកដែលមានក្នុងបញ្ជីបានថយចុះពី ២៧.២៧២ មកត្រឹម ៥.៨៧៤នាក់។ វេជ្ជបណ្ឌិតជាច្រើនក៏ផ្លាស់ទីផងដែរ ជាពិសេសទៅ ស.រ.អា និងកាណាដា។

## ចំណាកស្រុក និង ការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍

ការផ្លាស់ទីអាចផ្តល់ឥទ្ធិពលវិជ្ជមាន និង អវិជ្ជមាន។ ប្រការនេះក៏អាចចាត់ទុកថាទាក់ទងនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សន៍ ផងដែរ។

គោលដៅទី 1: ភាពក្រីក្រ: ប្រាក់ចំណូល ខ្ពស់បានពីប្រាក់ផ្ញើមកផ្ទះ មិនត្រឹមតែអាចជួយកាត់បន្ថយភាពក្រីក្រ និង

ភាពអត់ឃ្លានប៉ុណ្ណោះទេ ប៉ុន្តែនៅថែមទាំងគួសបញ្ជាក់ពីវិសមភាព និងនិរន្តរភាពនៃភាពក្រីក្រ ក្នុងចំណោមជនចំណាកស្រុក ដែល គ្មានជំនាញ និងគ្មានអំណាចផងដែរ ។

*គោលដៅទី 2 ការអប់រំ* : ការផ្លាស់ទីអាចជួយមាតាបិតាបង់ថ្លៃសម្រាប់ការអប់រំ ប៉ុន្តែប្រសិនបើវាធ្វើឱ្យគ្រួសារនានាមានភាពខុសគ្នាខ្លាំង វាក៏នឹងធ្វើឱ្យក្មេងខានទៅរៀនផងដែរ ។

*គោលដៅទី 3: សមភាពយេនឌ័រ* : ស្ត្រីអាចទទួលបានអំណាច ប្រសិនបើពួកគេអាចរកចំណូលបានដោយខ្លួនឯង ប៉ុន្តែក៏ងាយរងគ្រោះដោយសារការកេងប្រវ័ញ្ចផងដែរ ។

*គោលដៅ 4: មរណៈភាពកុមារ* : ប្រាក់ចំណូលខ្ពស់ និង ការចេះដឹងកាន់តែច្រើនអំពីសុខភាព គួរតែធ្វើឱ្យកុមារមានសុខភាពល្អជាងមុន ប៉ុន្តែអ្នកខ្លះអាចត្រូវបាត់បង់ទៅវិញប្រសិនបើកុមារទាំងនោះក៏ត្រូវផ្លាស់ទីទៅកាន់កន្លែងដែលមានស្ថានភាពលំបាក ។

*គោលដៅទី 5: សុខភាពមាតា* : ស្ត្រីដែលធ្វើការនៅក្រៅប្រទេស អាចមានកាលានុវត្តភាពច្រើនដើម្បីទទួលបាននូវព័ត៌មានដែលអាចនាំឱ្យ មានអាកប្បកិរិយាស្វែងរកសេវាថែទាំសុខភាព ។ ទោះជាយ៉ាងណាក៏ដោយពួកគេអាចប្រឈមនឹងការដាក់កំហិតលើការធ្វើដំណើរ និង ការកេងប្រវ័ញ្ចផ្សេងទៀតដែលអាចជាឧបសគ្គចំពោះអាកប្បកិរិយា ស្វែងរកការថែទាំសុខភាព ។

*គោលដៅទី 6: ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ និង ជម្ងឺអេដស៍ និងជម្ងឺផ្សេងទៀត* : ប្រាក់ចំណូលបានពីប្រាក់ផ្ញើមកផ្ទះ អាចត្រូវចំណាយដើម្បីប្រឆាំងជម្ងឺឆ្លង ប៉ុន្តែ ជនចំណាកស្រុកខ្លួនឯងក៏អាចជាភ្នាក់ងារចម្លងមេរោគអេដស៍និងជម្ងឺអេដស៍ផងដែរ ។

*គោលដៅទី 7: និរន្តរភាពបរិស្ថាន* : ចំណាកស្រុកពីប្រទេសដែលមានដង់ស៊ីតេប្រជាជនខ្ពស់អាចជួយកាត់បន្ថយសម្ពាធលើដីធ្លី និងធនធានផ្សេងទៀត ។ ទោះជាយ៉ាងណាក៏ដោយ ជនចំណាកស្រុកអាចរស់នៅក្នុងកន្លែងដែលមានប្រជាជនរស់នៅច្រើន និងលក្ខខណ្ឌដែលគ្មានអនាម័យដែលធ្វើឱ្យលក្ខខណ្ឌបរិស្ថាននៅក្នុងប្រទេសជាម្ចាស់ផ្ទះកាន់តែអាក្រក់ ។

*គោលដៅទី 8: ភាពជាដៃគូសកល* : ចំណាកស្រុកអាចនាំឱ្យមានការយល់ដឹងកាន់តែប្រសើរ ឡើងក្នុងចំណោមវប្បធម៌ និងសង្គមមនុស្សជាហេតុនាំឱ្យមានលទ្ធភាពកាន់តែច្រើនឡើងក្នុងការបង្កើតភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍ ។ ប៉ុន្តែចំណាកស្រុកដែលមិនស្ថិតក្រោមការគ្រប់គ្រងក៏អាចនាំឱ្យមានប្រតិកម្មតបប្រឆាំងនឹងជនចំណាកស្រុកក្នុងចំណោមប្រជាពលរដ្ឋនៅមូលដ្ឋានផងដែរ ។

ផ្អែកតាមទស្សនៈនៃ MDGs និងការអភិវឌ្ឍមនុស្សជាទូទៅ ចំណាកស្រុកត្រូវបានបង្ហាញឱ្យឃើញច្បាស់ថា តាមលក្ខណៈធម្មជាតិ វាពុំផ្តល់នូវផលប្រយោជន៍ឬផលអាក្រក់នោះទេ (ប្រអប់ ៥.៤) ។ ភាគច្រើនគឺអាស្រ័យទៅលើកាលៈទេសៈ ។ តើអ្នកកសាងគោលនយោបាយអាចធ្វើអ្វីខ្លះបាន ដើម្បីលើកកម្ពស់ទិដ្ឋភាពវិជ្ជមាន និងកាត់បន្ថយផលអវិជ្ជមាន?

## ទិធានការរបស់ប្រទេសជាប្រភពដើម

ទោះបីទិដ្ឋភាពជាច្រើននៃចំណាកស្រុកទំនងជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសដែលជាគោលដៅក្តី តាមពិត មានកិច្ចការជាច្រើនដែលប្រទេសជាប្រភពដើមអាចធ្វើបានដើម្បីធ្វើឱ្យការផ្លាស់ទីនេះមានប្រយោជន៍ និងទទួលបាននូវបទពិសោធ ជាពិសេសសម្រាប់កម្មករដែលគ្មានជំនាញ និងមានជំនាញតិចតួច និងសម្រាប់ស្ត្រី ។ ឧទាហរណ៍ វៀតណាមបានបង្ហាញឱ្យឃើញពីប្រសិទ្ធិភាពនៃវិធានការបែបនេះ (ប្រអប់ ៥.៥) ។ រដ្ឋាភិបាលនៅក្នុងប្រទេសជាប្រភពដើមគួរកសាង

ប្រអប់ ៥.៤

### លទ្ធផលនៃការអភិវឌ្ឍមនុស្សបណ្តាលពីការចំណាកស្រុក

| ឥទ្ធិពលតាមរយៈ | ប្រភេទនៃឥទ្ធិពល | លទ្ធផលលើការអភិវឌ្ឍមនុស្ស |
|---|---|---|
| *ផលប៉ះពាល់វិជ្ជមាន* | | |
| ការងារនិងប្រាក់ចំណូល | ផ្តល់មុខរបរដល់អ្នកគ្មានការងារ ឬអ្នកមានធ្វើការងារមិនពេញម៉ោង។ ជាទូទៅប្រាក់ចំណូលខ្ពស់ជាងអ្នកដែលនៅក្នុងសេដ្ឋកិច្ចប្រទេសប្រភពដើម នឹងជួយកាត់បន្ថយភាពក្រីក្រ សម្រាប់គ្រួសាររបស់ជនផ្លាស់ទីនោះ។ | អំណាច សមធម៌ ផលិតភាព |
| ឥទ្ធិពលលើស្ត្រី | ផ្តល់ការងារដល់ស្ត្រីជាច្រើនដែលមានលទ្ធភាពតិចតួចដើម្បីរកការងារធ្វើនៅក្នុងប្រទេសដើមរបស់ខ្លួន។ ប្រការនេះនាំឱ្យមានកំណើនការចំណាយប្រចាំគ្រួសារលើសុខភាព និងការអប់រំ និងអត្រានៃការសន្សំបានខ្ពស់ជាងមុន។ | អំណាច សមធម៌ ផលិតភាព |
| ការផ្ទេរជំនាញ និងចំណេះដឹង | អ្នកផ្លាស់ទីជួបជាមួយអ្នកឯកទេស និងសង្គមមនុស្សជាច្រើន និងមានលទ្ធភាពច្រើនក្នុងការប្រើប្រាស់បច្ចេកវិទ្យា និងការអភិវឌ្ឍជំនាញ។ ឧទាហរណ៍ នៅក្នុងវិជ្ជាជីវៈ IT និងសុខភាព អ្នកត្រលប់មកវិញអាចក្រោយមករួមចំណែកចំពោះជំនាញវិជ្ជាជីវៈនិងបច្ចេកទេសនៅក្នុងប្រទេសកំណើតរបស់ខ្លួន។ | ផលិតភាព អំណាច និរន្តរភាព |
| ការបង្កើតធនធាន | ប្រាក់ផ្ញើមកផ្ទះនិងប្រាក់សន្សំច្រើនតែក្លាយជាប្រភពចម្បងនៃរូបិយបណ្ណបរទេស និងបន្ថែមទៅក្នុងស្តុកនៃមូលធនសម្រាប់ការវិនិយោគលើផ្ទះសំបែង ជំនួញតូចតាច និង ហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត។<br>អ្នកចំណាកស្រុកដែលចំណាយប្រាក់ផ្ញើមកផ្ទះនៅក្នុងប្រទេសរបស់ខ្លួននឹងធ្វើឱ្យមានឥទ្ធិពលកើនឡើងទៅលើតម្រូវការ និងប្រាក់ចំណូលក្នុងចំណោមប្រជាជនមូលដ្ឋាន និងជួយបង្កើនធនធានសារពើពន្ធ។ | និរន្តរភាព ផលិតភាព អំណាច សមធម៌ |
| កត្តាខាងក្រៅ និងឥទ្ធិពលបន្ត | អ្នកចំណាកស្រុកមានទស្សនៈសង្គមនិងវប្បធម៌ទូលាយជាងមុន ដោយសារបានរស់នៅក្នុងសង្គមដទៃ និងអាចបង្កើតបណ្តាញឆ្លងប្រទេសដែលមានប្រយោជន៍។ | អំណាច ផលិតភាព សមធម៌ និរន្តរភាព |
| *ផលប៉ះពាល់អវិជ្ជមាន* | | |
| ការងារ និងប្រាក់ចំណូល | ប្រាក់ផ្ញើមកផ្ទះនាំឱ្យមានកំណើនគម្លាតរវាងគ្រួសារនានា និងតំបន់នានា។ | កង្វល់អំពីសមធម៌ |
| ជំនាញនិងចំណេះដឹង | ប្រទេសជាប្រភពដើមអាចបាត់បង់ជំនាញនៃវិជ្ជាជីវៈនានា ដូចជាបុគ្គលិកពេទ្យ។ ជំនាញវិជ្ជាជីវៈទាំងនេះអាចមិនបានប្រើប្រាស់ពេញលេញនៅក្រៅប្រទេស ប្រសិនបើគ្មានការទទួលស្គាល់គុណវុឌ្ឍិរបស់ពួកគាត់។ | កង្វល់អំពីផលិតភាព និរន្តរភាព |
| កត្តាខាងក្រៅ និងឥទ្ធិពលបន្ត | ការបាត់បង់ខាងសង្គមចំពោះគ្រួសារ ជាពិសេសកុមារ។<br>ការបាត់បង់ចំពោះអ្នកចំណាកស្រុក ដូចជា ភាពឯកោ កង្វះខាតការទាក់ទងជាមួយគ្រួសារ។ អាចស្ថិតក្រោមស្ថានភាពនៃការកេងប្រវ័ញ្ចនៅក្នុងប្រទេសដែលទទួលកម្មករធ្វើការ។<br>បញ្ហាសមាហរណកម្មឡើងវិញ ទាំងខាងផ្នែកសេដ្ឋកិច្ច និងសង្គម។ | កង្វល់អំពីសមធម៌ និរន្តរភាព ផលិតភាព រយៈពេលវែង |

យុទ្ធសាស្ត្រជាតិសម្រាប់ចំណាកស្រុក។ វិធានការទាំងនោះអាចរួមបញ្ចូល :

*កំណើនលទ្ធភាពទទួលព័ត៌មាន* : ជនចំណាកស្រុកកាន់តែច្រើនទទួលព័ត៌មានអំពីកាលានុវត្តភាពនៃចំណាកស្រុកពីបណ្ដាញជនចំណាកស្រុក និងអតីតជនចំណាកស្រុក។ ប្រការនេះទំនងជាប្រមូលផ្ដុំផលប្រយោជន៍នៃចំណាកស្រុកនៅក្នុងតំបន់ណាមួយជាក់លាក់ឬភូមិនានា។ រដ្ឋាភិបាលអាចបង្កើតសកម្មភាពជាលក្ខណៈផ្លូវការ ដោយធ្វើឱ្យមាននៅទូទាំងប្រទេស និងសម្រាប់គ្រប់ស្រទាប់មនុស្ស និងក្រុមដែលមានប្រាក់ចំណូលផ្សេងគ្នានូវព័ត៌មានស្ដីពីទីផ្សារដែលពាក់ព័ន្ធ និងកាលានុវត្តភាពការងារ។

*ទីភ្នាក់ងារជ្រើសរើសបុគ្គលិក* : ជនចំណាកស្រុកជាច្រើនបានក្លាយជាជនរងគ្រោះពីការបោកបញ្ឆោតនៃទីភ្នាក់ងារជ្រើសរើសបុគ្គលិក ដែលអាចទារយកកម្រៃខ្ពស់ហួសហេតុ ឬពុំបានផ្ដល់ការងារតាមការសន្យា។ ដូច្នេះ រដ្ឋាភិបាលត្រូវដាក់បញ្ញត្តិ និងតាមដានទីភ្នាក់ងារជ្រើសរើសបុគ្គលិក និងបញ្ឈប់ទីភ្នាក់ងារដែលល្មើសច្បាស់។ ផ្ទុយទៅវិញ រដ្ឋាភិបាលអាចផ្ដល់រង្វាន់ដល់ទីភ្នាក់ងារដែលមានប្រសិទ្ធិភាព ដោយទទួលស្គាល់តួនាទីរបស់ទីភ្នាក់ងារទាំងនោះ និងចាត់ទុកថាជាដៃគូក្នុងដំណើរការអភិវឌ្ឍន៍សង្គម។

*ការបណ្ដុះបណ្ដាលជំនាញ និង ធនធាន* : កម្មករនឹងមានតួនាទីកាន់តែរឹងមាំដើម្បីទាញយកអត្ថប្រយោជន៍ពីកាលានុវត្តភាពនៃចំណាកស្រុក ប្រសិនបើអាចបញ្ជាក់អំពីជំនាញ។ បន្ថែមលើការបង្កើតគ្រឹះស្ថានបណ្ដុះបណ្ដាលកាន់តែច្រើនឡើង រដ្ឋាភិបាលគួរតែធានាថា គ្រឹះស្ថានទាំងនេះ និងទីភ្នាក់ងារដទៃទៀតរបស់រដ្ឋាភិបាល ព្រមទាំងគ្រឹះស្ថានឧត្តមសិក្សា បានការទទួលស្គាល់ជាផ្លូវការនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ ប្រការនេះនឹងផ្ដល់ឱ្យនិយោជកនូវវិធានការធានាគុណភាព ជាពិសេសសម្រាប់កម្មករដែលមានជំនាញខ្ពស់ និងអ្នកមានជំនាញតិចតួច។

*ហិរញ្ញវត្ថុ* : ជនចំណាកស្រុកត្រូវបង់ប្រាក់យ៉ាងច្រើន

---

ប្រអប់ ៥.៥

**ការជម្រុញរបស់រដ្ឋាភិបាលលើចំណាកស្រុកបណ្ដោះអាសន្នពីប្រទេសវៀតណាម**

នៅទសវត្សរ៍ឆ្នាំ ១៩៨០ វៀតណាមបានប្រឈមនឹងការដាក់ទណ្ឌកម្មអន្តរជាតិ និងមានទំនាក់ទំនងតិចតួចជាមួយសេដ្ឋកិច្ចដទៃទៀត។ រដ្ឋាភិបាលបានធានាជាផ្លូវការលើការងារសម្រាប់ជនជាតិវៀតណាមភាគច្រើន ប៉ុន្តែប្រាក់ចំណូល និងស្តង់ដារនៃការរស់នៅរបស់ពួកគេមានកម្រិតទាប ហើយភាពក្រីក្រនិងភាពអត់ឃ្លានបានរាលដាលផងដែរ។ ដើម្បីជួយកាត់បន្ថយបញ្ហានេះ រដ្ឋាភិបាលបានគ្រប់គ្រងដោយប្រុងប្រយ័ត្ននូវចំណាកស្រុកទៅក្រៅប្រទេស នៅក្រោមបទបញ្ជាយ៉ាងតឹងរ៉ឹង។

ដោយត្រូវគោរពតាមបទបញ្ញត្តិរបស់រដ្ឋាភិបាល ទីភ្នាក់ងារជ្រើសរើសកម្មករដែលមានការទទួលស្គាល់ពីរដ្ឋាភិបាល បានទទួលសិទ្ធិស្វយ័តដើម្បីសិក្សាទីផ្សារថ្មីៗសម្រាប់កម្មកររយៈពេលខ្លី បង្កើតទំនាក់ទំនងជាមួយដៃគូបរទេស និងចុះកិច្ចសន្យាពលកម្មដោយផ្ទាល់ជាមួយកម្មករចំណាកស្រុក។ ទីភ្នាក់ងារទាំងនេះបានទទួលការលើកទឹកចិត្តឱ្យធ្វើកិច្ចសហប្រតិបត្តិការថ្មីៗបន្ថែមទៀត ដូចជាម៉ៅការបន្ត កិច្ចសន្យាសាងសង់បម្រើយសម្រាប់គម្រោងសាងសង់ និងរកស៊ីរួមគ្នាជាមួយដៃគូបរទេស។ រដ្ឋាភិបាលក៏លើកទឹកចិត្តដល់អ្នកចំណាកស្រុកផងដែរ ដោយអនុញ្ញាតឱ្យមានភាពបត់បែនលើការប្រើប្រាស់ប្រាក់ចំណូលរបស់ពួកគេ។ ចំណាកស្រុកបានកើនឡើងជាបន្តបន្ទាប់នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ហើយឥឡូវប្រទេសនេះបញ្ជូនកម្មករប្រមាណ ៤០.០០០នាក់ទៅក្រៅប្រទេសជារៀងរាល់ឆ្នាំ (DAFEL ២០០៣)។

ឧទាហរណ៍ នៅខេត្ត ដុងថាប់ មានការលើកទឹកចិត្តចម្រុះ ដើម្បីជម្រុញ និងបំពាក់បរិក្ខារដល់ពលរដ្ឋក្នុងមូលដ្ឋានឱ្យទៅធ្វើការនៅក្រៅប្រទេស។ រដ្ឋាភិបាលបានផ្ដល់ប្រាក់កម្ចីសម្រាប់ការធ្វើដំណើរ តាមរយៈកម្មវិធីហិរញ្ញប្បទានចម្រុះ ៨០% ពីរដ្ឋាភិបាលកណ្ដាល និង ២០% ពីរដ្ឋាភិបាលមូលដ្ឋាន តាមរយៈធនាគារសាធារណៈនៅមូលដ្ឋាន។ ទីភ្នាក់ងារក្នុងមូលដ្ឋានមួយគឺមជ្ឈមណ្ឌលសម្រាប់សេវាការងារ បានផ្ដល់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងថ្នាក់បង្រៀនភាសា ដើម្បីឱ្យប្រជាពលរដ្ឋអាចដាក់ពាក្យធ្វើការនៅម៉ាឡេស៊ី តៃវ៉ាន់ និង ជប៉ុន។ ដោយមានការជួយពីសំណាក់មន្ត្រីក្នុងមូលដ្ឋាន អ្នកចង់ធ្វើចំណាកស្រុកក៏អាចដាក់ពាក្យសុំលិខិតឆ្លងដែនពីលំនៅស្ថានរបស់ខ្លួនដោយពុំចាំបាច់ធ្វើដំណើរមកក្រុងហូជីមិញឡើយ។ កិច្ចផ្ដួចផ្ដើមទាំងនេះជួយបង្កើនអត្រាចំណាកស្រុកចំនួនបីដងពីខេត្តនេះនៅឆ្នាំ ២០០២។

**ប្រភព: Huy et al. ២០០៣។**

*ទីភ្នាក់ងាររបស់រដ្ឋាភិបាលអាចចាត់ការច្រើនបន្ថែមទៀត ដើម្បីផ្ដល់ការប្រឹក្សាដល់អ្នកធ្វើមាតុភូមិនិវត្តន៍ និងជួយពួកគេតាំងទីលំនៅ*

ជាមុន ឧទាហរណ៍ សម្រាប់ការជ្រើសរើស និងសម្រាប់ការធ្វើដំណើរ។ បណ្ដាអ្នកមកពីសហគមន៍ក្រីក្រ ដែលពុំមានលទ្ធភាពខ្ចីប្រាក់ពីគ្រឹះស្ថានផ្លូវការ ត្រូវខ្ចីពីញាតិសណ្ដាន ឬតាមរយៈបណ្ដាញក្រៅផ្លូវការផ្សេងទៀត។ នៅប្រទេសវៀតណាម និងបង់ក្លាដេស ការអង្កេតបានរកឃើញផងដែរថា ជនចំណាកស្រុកច្រើនតែចេញថ្លៃធ្វើដំណើរដោយខ្លួនឯង ដោយលក់ទ្រព្យសម្បត្តិគ្រួសារ។ ដូច្នេះ យុទ្ធសាស្ត្រជាតិសម្រាប់ការចំណាកស្រុក គួរតែដាក់បញ្ចូលមាត្រាអំពីប្រាក់កម្ចីថោកៗពីធនាគារ និងពីគ្រឹះស្ថានផ្សេងទៀត។

*ការបន្សាំចំពោះវប្បធម៌* : ជនចំណាកស្រុកក្រីក្រច្រើនតែមានអារម្មណ៍ថា ខ្លួនមានភាពឯកោនៅក្នុងទីកន្លែងថ្មី។ ដើម្បីធ្វើឱ្យដំណើរការបន្សាំនេះងាយស្រួលជាងមុន រដ្ឋាភិបាលនៅក្នុងប្រទេសជាប្រភពដើម អាចផ្ដល់វគ្គសិក្សាអំពីភាសា និងកម្មវិធីអប់រំដែលណែនាំដល់ជនចំណាកស្រុក អំពីភាពខុសគ្នាខាងវប្បធម៌នៃប្រទេសដែលជាគោលដៅ។

*ការយល់ដឹងអំពីសិទ្ធិ* : ជនចំណាកស្រុកនឹងស្ថិតនៅក្នុងស្ថានភាពដែលត្រូវការការពារខ្លួនឯងពីការកេងប្រវ័ញ្ច ប្រសិនបើពួកគេបានដឹងអំពីសិទ្ធិរបស់ខ្លួន និងដឹងអំពីរបៀបការពារខ្លួនឯង ពីការរើសអើងនិងការបៀតបៀន។ ដូច្នេះ រដ្ឋាភិបាលអាចចាត់ចែងឱ្យមានសិក្ខាសាលាមុនពេលចេញដំណើរ ដើម្បីផ្ដល់ព័ត៌មានចាំបាច់ ដោយនៅក្នុងករណីខ្លះ អាចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលអាចជួយបណ្ដុះបណ្ដាលកម្មករ និងផ្ដល់ការណែនាំ ព្រមទាំងគាំទ្រតាមរយៈមជ្ឈមណ្ឌលផ្ដល់ការប្រឹក្សា។

ការគាំទ្រពីស្ថានទូត ជនចំណាកស្រុកគួរតែអាចពឹងផ្អែកលើកិច្ចការពារពីស្ថានទូតរបស់ខ្លួន។ ដូច្នេះ រដ្ឋាភិបាលគួរពង្រឹងស្ថានទូត នៅក្នុងប្រទេសដែលជួលកម្មករចំណាកស្រុកយ៉ាងច្រើនពីប្រទេសរបស់ខ្លួន ដោយផ្ដល់ការគាំទ្រចាំបាច់តាមរយៈការតែងតាំងមន្ត្រីដែលមានបទពិសោធក្នុងការចាត់ចែងសុខមាលភាពកម្មករ និងបញ្ហាខាងផ្លូវច្បាប់។

*ការបញ្ជូនប្រាក់មកផ្ទះវិញ* : មកទល់ពេលនេះ រដ្ឋាភិបាលក្នុងប្រទេសជាប្រភពដើមបានចាត់ការតិចតួចណាស់ ដើម្បីបញ្ជូនរូបិយបណ្ណបរទេសដែលបានពីប្រាក់បញ្ជូនមកផ្ទះទៅក្នុងគម្រោងអភិវឌ្ឍន៍ជាក់លាក់ ដូចជាកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន ឬកែលំអសេវាសុខភាព និងការអប់រំ។ ដូច្នេះ រដ្ឋាភិបាលគួរលើកទឹកចិត្តវិស័យហិរញ្ញវត្ថុឱ្យបង្កើតបរិធានសមស្រប និងផលិតផលហិរញ្ញវត្ថុ។

*ការធ្វើមាតុភូមិនិវត្តន៍នៃជនចំណាកស្រុក* : ប្រទេសជាប្រភពដើមមួយចំនួនតូចនៅអាស៊ី ផ្ដល់ការគាំទ្រដល់អ្នកធ្វើមាតុភូមិនិវត្ត ដើម្បីជួយពួកគេគ្រប់គ្រងឥទ្ធិពលខាងផ្នែកសង្គម-សេដ្ឋកិច្ច និងចិត្តសាស្ត្រនៃការវិលត្រឡប់ ជួនកាលក្រោយពេលស្នាក់នៅរយៈពេលវែងនៅក្រៅប្រទេស និងក្នុងសង្គមមនុស្សដែលខុសគ្នាយ៉ាងខ្លាំង។ ទីភ្នាក់ងាររបស់រដ្ឋាភិបាលអាចចាត់ការច្រើនបន្ថែមទៀត ដើម្បីផ្ដល់ការប្រឹក្សាដល់អ្នកធ្វើមាតុភូមិនិវត្តន៍ និងជួយពួកគេតាំងទីលំនៅ។ សម្រាប់ជនចំណាកស្រុកដែលបានវិលត្រលប់មកវិញជាមួយមូលនិធិច្រើន រដ្ឋាភិបាលអាចផ្ដល់សិក្ខាសាលាអំពីការចាត់ចែងសហគ្រាស និងកាលានុវត្តភាពផ្សេងទៀត សម្រាប់ធ្វើការដើម្បីខ្លួនឯង។ ចំពោះជនចំណាកស្រុកដែលមានធនធានតិចតួច រដ្ឋាភិបាលអាចផ្ដល់ប្រាក់កម្ចីអនុគ្រោះ និងផ្ដល់កម្មវិធីបណ្ដុះបណ្ដាលជំនាញ ដើម្បីជួយពួកគេបង្កើតមុខជំនួញខ្នាតតូច។

## វិធានការនៃប្រទេសគោលដៅ

ប្រទេសគោលដៅមានការបារម្ភអំពីសន្តិសុខ និងកង្វល់ផ្សេងទៀតអំពីការផ្លាស់ទីលំនៅ។ ដូច្នេះ ប្រទេសទាំងនោះអាចត្រួតត្រាការមកដល់នៃជនចំណាកស្រុកជំពូកខុសៗគ្នា

និងដាក់កំហិតចំពោះសិទ្ធិរបស់អ្នកទាំងនោះ។ ថ្មីៗនេះមានកំណើននៃការចាត់វិធានការការពារបែបនេះ ដែលដាក់កំហិតលើចំនួននៃការមកដល់ ដាក់ឱ្យអនុវត្តវិធានការរដ្ឋបាល និងនីតិវិធី ដើម្បីពិនិត្យមើលសំណើសុំទិដ្ឋាការ និងអាជ្ញាប័ណ្ណធ្វើការងារ និងការបន្តទិដ្ឋាការ ព្រមទាំងធ្វើឱ្យការសុំពន្យារអាជ្ញាយុកាលកាន់តែលំបាក និងត្រូវចំណាយកាន់តែច្រើន។ ប្រទេសទាំងនោះក៏កាន់តែពុំសូវទទួលស្គាល់គុណវុឌ្ឍិ និងបទពិសោធរបស់កម្មករបែបនេះផងដែរ។ ឧទាហរណ៍ នៅក្នុងវិស័យ IT ពុំមាននីតិវិធីជាផ្លូវការ សម្រាប់ការទទួលស្គាល់សមត្ថភាពឡើយ ហើយលទ្ធផលអាចច្រើនតែមិនច្បាស់លាស់ និងអាស្រ័យតាមឆន្ទានុសិទ្ធិ។

ផ្នែកដែលមានការបារម្ភមួយ គឺការតម្រូវឱ្យមាន "ការប្រឡងអំពីលក្ខខណ្ឌសេដ្ឋកិច្ច" សម្រាប់ការមកដល់នៃអ្នកឯកទេសខ្លះៗ។ រដ្ឋាភិបាលខ្លះតម្រូវឱ្យនិយោជកដែលស្នើសុំជួលជនចំណាកស្រុក បង្ហាញថាពួកគេពុំអាចជ្រើសរើសកម្មករក្នុងស្រុកដែលមានសមត្ថភាពប្រហែលគ្នា។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងករណីជាច្រើន ការដែលគ្រាន់តែកំណត់ឱ្យបានច្បាស់លាស់អំពីជំពូកឯកទេសដែលត្រូវការអាចផ្តល់ប្រសិទ្ធិភាពខ្ពស់ជាង ប្រសិនបើអ្នកទាំងនោះនឹងត្រូវបានទទួលសិទ្ធិឱ្យចូលក្នុងប្រទេសនិងស្វែងរកការងារ។

ការផ្លាស់ទីក៏អាចធ្វើឡើងប្រកបដោយប្រសិទ្ធិភាពផងដែរ ប្រសិនបើប្រទេសដែលទទួលយក និងប្រទេសប្រភពដើម មានកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក (MRAs)។ ឧទាហរណ៍ ប្រទេសទាំងនោះអាចចាប់ផ្តើមលើវិស័យដែលពុំសូវមានភាពចម្រូងចម្រាស់ ដូចជា ការទទួលស្គាល់ជាផ្លូវការនូវគ្រឹះស្ថានឧត្តមសិក្សា ដោយគ្រាន់តែបង្កើតសមមូលនៃកម្រិតអប់រំ សញ្ញាប័ត្រ និងគុណភាពនៃអ្នកដែលបានទទួលសញ្ញាប័ត្រ។ បន្ទាប់មកប្រទេស ទាំងនោះអាចបន្តទៅទទួលស្គាល់អាជ្ញាប័ណ្ណ វិញ្ញាបនប័ត្រ ឯកទេស និងបទពិសោធ។ ផ្នែកឯកជន ជាពិសេសសមាគមអ្នកឯកទេស អាចជួយនៅក្នុងផ្នែកនេះ។

ប្រទេសទាំងនេះអាចចរចា MRAs នៅកម្រិតពហុភាគី ប៉ុន្តែដំណើរការនេះអាចមានការលំបាក ចំណាយពេលវែង និងនាំឱ្យធុញទ្រាន់ អាស្រ័យហេតុនេះ កិច្ចព្រមព្រៀងទ្វេភាគី ឬកម្រិតតំបន់ ប្រហែលជាងាយស្រួលជាងសម្រាប់ឯកទេស និងមុខជំនាញជាក់លាក់។ ឧទាហរណ៍ អាស៊ានបានលុបចោលតម្រូវការទិដ្ឋាការសម្រាប់ប្រទេសជាសមាជិក ដើម្បីបង្កើនការធ្វើដំណើររបស់ប្រជាពលរដ្ឋ ដែលនេះជាជំហាននាំមុខមួយដែលអាចនាំទៅរកការអនុវត្តនៅទូទាំងតំបន់។

រដ្ឋាភិបាលនៃប្រទេសគោលដៅក៏អាចកាត់បន្ថយចំនួនជនចំណាកស្រុកបណ្តោះអាសន្ន ដែលស្នាក់នៅហួសកំណត់ទិដ្ឋាការ ដោយធ្វើការឱ្យបានជិតស្និទ្ធជាមួយនិយោជក។ នៅក្រោមប្រព័ន្ធបែបនេះ និយោជកត្រូវសហការជាមួយរដ្ឋាភិបាល ដើម្បីតាមដាននិយោជិតរបស់ខ្លួន និង ទទួលខុសត្រូវលើការវិលត្រឡប់របស់កម្មករ ហើយអាចប្រឈមនឹងការដាក់ទណ្ឌកម្ម ប្រសិនបើរកឃើញថាបានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌដែលមានចែង។ ភស្តុតាងបង្ហាញថា កម្មវិធីថ្មីៗបំផុតអំពីនិរន្តរភាពនៃចំណាកស្រុកបណ្តោះអាសន្ន គឺជាកម្មវិធីដែលមានការអនុវត្តបានត្រឹមត្រូវទៅតាមច្បាប់។ កិច្ចព្រមព្រៀងទ្វេភាគី និងប្រចាំតំបន់អាចដើរតួនាទីសំខាន់ណាស់នៅក្នុងផ្នែកនេះ។

*ការផ្លាស់ទីក៏អាចធ្វើឡើងប្រកបដោយប្រសិទ្ធិភាពផងដែរ ប្រសិនបើប្រទេសដែលទទួលយក និងប្រទេសប្រភពដើមមានកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក*

## វិធានការពហុភាគី

សម្រាប់ចំណាកស្រុក កិច្ចព្រមព្រៀងពាណិជ្ជកម្មដែលសំខាន់ជាងគេបំផុត ដែលដាក់ឱ្យអនុវត្តនៅក្នុងយុគសម័យ WTO គឺកិច្ចព្រមព្រៀងទូទៅឆ្នាំ ១៩៩៥ ស្តីពីពាណិជ្ជកម្មលើសេវាកម្ម (GATS)។ កិច្ចព្រមព្រៀងនេះត្រូវបានបង្កើត

ឡើងដើម្បីអនុញ្ញាតឱ្យប្រទេសកំពុងអភិវឌ្ឍន៍ទទួលបានសេរីភាពកាន់តែច្រើនក្នុងការប្រើប្រាស់ចំណាកស្រុកបណ្ដោះអាសន្ន និងធ្វើឱ្យចំណាកស្រុកបែបនេះប្រកបដោយការធានា និងមាននិរន្តរភាពជាងមុន។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្ដែង វាមិនផ្ដល់ច្រើនតាមរយៈសេរីភាវូបនីយកម្មឡើយ ហើយទំនងជាមានឥទ្ធិពលតិចតួចតែប៉ុណ្ណោះទៅលើទម្រង់នៃចំណាកស្រុកនៅអាស៊ី និងប៉ាស៊ីហ្វិក។

បញ្ហាមួយគឺថាវាមានសភាពចង្អៀតពេក។ ដូចដែលមានការរំពឹងទុក GATS ពុំមានចែងអំពីជនចំណាកស្រុក ដែលធ្វើការនៅក្រៅឧស្សាហកម្មសេវាឡើយ និងមិនទំនងជានិយាយអំពីកម្មករបរទេសដែលផ្ដល់សេវានៅក្នុងស្រុក ទោះបីបញ្ហានេះនៅតែមានចម្រូងចម្រាសនៅឡើយក៏ដោយ។ ដោយសារ GATS ទំនងជាផ្ដល់ការអនុគ្រោះដល់អ្នកដែលមានប្រាក់ចំណូលខ្ពស់ជាង និងដែលមានជំនាញខ្ពស់ គេអាចមើលឃើញថាវាពង្រីកវិសមភាពទាំងក្នុងចំណោម និងនៅក្នុងប្រទេសនានា។ លើសពីនេះ ដោយសារ GATS មិនមែនជាកិច្ចព្រមព្រៀងអំពីចំណាកស្រុក ប៉ុន្តែ ជាកិច្ចព្រមព្រៀងពាណិជ្ជកម្ម វាមិននិយាយអំពីបញ្ហានានា ដូចជា ការយកចិត្តទុកដាក់ចំពោះបុគ្គលដែលធ្វើការនៅក្រៅប្រទេស និងអំពីចំណាកស្រុកដោយបង្ខិតបង្ខំ និងការជួញដូរមនុស្សឡើយ។

ទោះជាយ៉ាងណាក៏ដោយ ប្រទេសប្រភពដើមអាចប្រើប្រាស់ក្របខ័ណ្ឌ GATS ដើម្បីជម្រុញឱ្យមានចំណាកស្រុកសម្រាប់ហេតុផលសេដ្ឋកិច្ចរយៈពេលខ្លីដែលខ្លួនចង់បាន។ មានវិធីមួយចំនួនដែលអាចធ្វើទៅបាន ដូចមានបង្ហាញនៅក្នុងប្រអប់ ៥.៦។

*ការធ្វើលទ្ធកម្មពីខាងក្រៅនាំឱ្យមានការផ្លាស់ប្ដូរមុខនាទីពីសេដ្ឋកិច្ច ដែលទាមទារប្រាក់កម្រៃច្រើនមកសេដ្ឋកិច្ចដែលទាមទារប្រាក់កម្រៃទាប នៅក្នុងកិច្ចប្រឹងប្រែងដើម្បីបង្កើនប្រសិទ្ធិភាព និងកាត់បន្ថយការចំណាយ*

## លទ្ធកម្មដំណើរការជំនួញ

បច្ចុប្បន្ននេះ ក្រុមហ៊ុនកាន់តែច្រើនឡើងបានផ្ទេរការងារខ្លះៗដែលមិនមែនជាការងារស្នូលរបស់ខ្លួនទៅឱ្យអ្នកផ្ដល់សេវាដែលជាភាគីទីបី។ លទ្ធកម្មសេវាដំណើរការពីប្រភពខាងក្រៅបែបនេះកើតមានឡើងទាំងនៅក្នុង និងក្រៅប្រទេស។ ការធ្វើលទ្ធកម្មពីក្រៅប្រទេស គឺជាទម្រង់ថ្មីមួយនៃពាណិជ្ជកម្មសេវាកម្ម ដែលអាចធ្វើទៅបានតាមរយៈបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទង។ ក្រុមហ៊ុននានាប្រើប្រាស់ទម្រង់នៃ "លទ្ធកម្មជាសកល"នេះសម្រាប់ដំណើរការជំនួញ និងមុខងារការិយាល័យគាំទ្រ។ ការធ្វើបែបនេះអាចទាញយកផលចំណេញពីបច្ចេកវិទ្យាទំនើប កាត់បន្ថយការចំណាយលើបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទង ដែលបច្ចុប្បន្ននេះអាចអនុញ្ញាតឱ្យមានការប្រគល់ទំនិញតាមទូរស័ព្ទ ឬអ៊ិនធឺណិតសម្រាប់សេវាជាច្រើនបែបនៅគ្រប់លំដាប់នៃជំនាញ និងភាពសាំញ៉ាំ។[៧]

ការវាយតម្លៃកម្រិតបច្ចុប្បន្ននៃលទ្ធកម្មពីខាងក្រៅមានភាពលំបាកណាស់ ប៉ុន្តែការប៉ាន់ប្រមាណដោយ OECD បង្ហាញថានៅឆ្នាំ ២០០១ ការស្វែងរកប្រភពពីខាងក្រៅសម្រាប់សេវា IT និងសេវាដំណើរការជំនួញមានតម្លៃប្រមាណ ២៦.០០០លានដុល្លារ។[៨] ជាការច្បាស់ណាស់ថា បាតុភូតនេះកំពុងកើនឡើងយ៉ាងឆាប់រហ័ស (ប្រអប់៥.៧)។ ការប៉ាន់ប្រមាណមួយសន្និដ្ឋានថា រវាងឆ្នាំ ២០០២ និង ២០០៦ ការធ្វើលទ្ធកម្មពីខាងក្រៅនូវដំណើរការជំនួញ (BPO) តែឯងអាចបានកើនឡើងពី ៥៧០.០០០ លានដុល្លារ ទៅ ១.២ លានលានដុល្លារ។[៩]

ការធ្វើលទ្ធកម្មពីខាងក្រៅនាំឱ្យមានការផ្លាស់ប្ដូរមុខនាទីពីសេដ្ឋកិច្ចដែលទាមទារប្រាក់កម្រៃច្រើនមកសេដ្ឋកិច្ចដែលទាមទារប្រាក់កម្រៃទាប នៅក្នុងកិច្ចប្រឹងប្រែងដើម្បីបង្កើនប្រសិទ្ធិភាពនិងកាត់បន្ថយការចំណាយ ធ្វើឱ្យក្រុមហ៊ុនផ្ដោតកាន់តែច្រើនឡើងលើការងារស្នូលរបស់ខ្លួន។ ដូច្នេះ ក្រុមហ៊ុននៅ

ស.រ.អា និងអឺរ៉ុប ចាប់ផ្តើមធ្វើលទ្ធកម្មពីក្នុងចំណោមប្រទេសនានា ដូចជា ឥណ្ឌា ចិន អ៊ីស្រាអែល ម៉ាឡេស៊ី ម៉ិកស៊ិកូ ហ្វីលីពីន អាហ្វ្រិកខាងត្បូង និងវៀតណាម។ កាលពីដំបូង ការងារដែលពួកគេបញ្ជូន មានការពាក់ព័ន្ធជាបឋមជាមួយការបញ្ចូល និងថែទាំទិន្នន័យ ការផ្តល់និងគ្រប់គ្រងដំណើរការ IT ។ ចាប់ពីពេលនោះមក ចំនួន និងភាពសាំញ៉ាំនៃសេវាត្រូវបានពង្រីកយ៉ាងឆាប់រហ័ស ហើយធ្វើឱ្យព្រំដែនរវាងវិស័យ និងសកម្មភាពនានាពុំមានភាពច្បាស់លាស់។ ឥឡូវ សេវានានាត្រូវបានផ្តល់ទន្ទឹម

ប្រអប់ ៥.៦

### ជម្រើសនៃចំណាកស្រុកក្នុងកិច្ចព្រមព្រៀងទូទៅលើពាណិជ្ជកម្មខាងសេវាកម្ម

សម្រាប់ចំណាកស្រុក កិច្ចព្រមព្រៀងសំខាន់ជាងគេអំពីពាណិជ្ជកម្មដែល ប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌនៃ WTO គឺកិច្ចព្រមព្រៀងទូទៅឆ្នាំ ១៩៩៥ ស្តីពីពាណិជ្ជកម្មលើសេវាកម្ម (GATS)។ កិច្ចព្រមព្រៀងនេះ កំណត់ការផ្គត់ផ្គង់សេវា "បួនបែប"។ បែបទីមួយ សំដៅលើសេវាឆ្លងដែនដែលអាចអនុវត្តឧទាហរណ៍ តាមអ៊ិនធឺណិត។ បែបទីពីរ សំដៅលើការប្រើប្រាស់នៅក្រៅប្រទេស ដូចជាទេសចរណ៍។ បែបទីបី សំដៅលើការវិនិយោគដោយផ្ទាល់ពីបរទេស នៅពេលដែលក្រុមហ៊ុនសេវាកម្ម ដូចជាធនាគារមួយបើកសាខានៅក្នុងប្រទេសក្រៅ។ ទោះជាយ៉ាងណាក៏ដោយ បែបទីបួន គឺជាគំរូតែមួយដែលចែងពីចំណាកស្រុកនៃអ្វីដែលគេហៅថា "រូបវន្តបុគ្គល" ដែលរួមទាំងការផ្ទេរបុគ្គលិកនៅក្នុងក្រុមហ៊ុន។

*ការផ្តាច់ទំនាក់ទំនងរវាងបែបទីបួន និងទីបី* ៖ យោងតាម GATS ចំណាកស្រុក រយៈពេលខ្លីទាក់ទងយ៉ាងជិតស្និទ្ធជាមួយការវិនិយោគដោយផ្ទាល់ពីបរទេស ដោយសម្រួលចលនានៃបុគ្គលដែលត្រូវផ្ទេរនៅក្នុងក្រុមហ៊ុន។ ការធ្វើបែបនេះ ដើម្បីផ្តល់អត្ថប្រយោជន៍ដល់ប្រទេសជឿនលឿន ដែលជាប្រភពនៃការវិនិយោគបែបនេះភាគច្រើន។ វាផ្តល់នូវអត្ថប្រយោជន៍តិចតួចជាងខ្លាំងណាស់ សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ដែលចង់ឱ្យមានចំណាកស្រុកកាន់តែច្រើនឡើង ថែមទៀតនៃអ្នកឯកទេស និងអ្នកផ្តល់សេវាឯករាជ្យនូវវិវត្តមាននៃសាជីវកម្ម។

*ការពង្រីកបញ្ជីចំណាត់ថ្នាក់* ៖ ចំណាត់ថ្នាក់របស់ WTO នូវអ្នកឯកទេសមានភាពលំអិតពុំទាន់គ្រប់គ្រាន់ទេ ហើយប្រទេសខុសគ្នាបានបកស្រាយខុសៗគ្នា។ ជាជំនួស ចំណាត់ថ្នាក់នេះគួរតែបំបែកលំអិតបន្ថែមទៀត ដើម្បីអាចធ្វើអត្តសញ្ញាណកម្មករឱ្យបានច្បាស់លាស់ ដែលអាចទទួលយកចំណាត់ថ្នាក់ស្តង់ដារអន្តរជាតិនៃមុខរបរ។ ប្រការនេះគួរតែផ្តល់បញ្ជីឯកទេសដោយឡែកៗពីគ្នា ដែលនៅដាច់ដោយឡែកពីក្រុមហ៊ុនវិជ្ជាជីវៈ ឬវិស័យ ដែលនឹងមានប្រយោជន៍បំផុតសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។

*ការផ្តាច់ទំនាក់ទំនងអន្តោប្រវេសន៍ និងគោលនយោបាយការងារ* ៖ ប្រទេសជឿនលឿនមានការរារែកក្នុងការធ្វើឱ្យការប្តេជ្ញានេះ ជាប់ខាងផ្លូវច្បាប់ស្តីពីគំរូទី ៤ ដោយបារម្ភថាប្រការនេះផ្តល់ឱ្យពួកគេនូវការបត់បែនតិចតួចអំពីច្បាប់ និងនីតិវិធីអន្តោប្រវេសន៍។ ដូច្នេះ គួរតែមានយន្តការផ្តាច់ទំនាក់ទំនងរវាងគោលនយោបាយអន្តោប្រវេសន៍ស្របច្បាប់ពីការដាក់កំហិតលើអន្តោប្រវេសន៍សម្រាប់ការងារបណ្តោះអាសន្ន។ រដ្ឋាភិបាលគួរតែបន្ធូរ ឬ លុបចោលរបាំងនានានៃការប្រើប្រាស់ទីផ្សារចំពោះចលនាគំរូទី ៤ ដូចជាកូតា និងការដាក់កំហិតលើបរិមាណ លក្ខខណ្ឌនៃប្រាក់កម្រៃ និងនីតិវិធីរដ្ឋបាល។

*ប្រកាន់យកទិដ្ឋាការ GATS* ៖ សំណើមួយពីប្រទេសឥណ្ឌា គឺការធ្វើឱ្យមាន "ទិដ្ឋាការ GATS" ដែលអាចចេញឱ្យបុគ្គល ឬអ្នកឯកទេសនានា ដែលបានទទួលការអញ្ជើញ ឬជ្រើសរើស ដើម្បីផ្តល់សេវាបណ្តោះអាសន្ននៅក្នុងប្រទេសមួយផ្សេងទៀត។ ដូច្នេះ វាទាក់ទងនឹងពេលវេលា ភាពជាក់លាក់នៃការងារ និងភាពបណ្តោះអាសន្ន។ លើសពីនេះ វាមិនអាចបំលែងទៅជាប្រភេទមួយផ្សេងទៀតនៃទិដ្ឋាការឡើយ ឬប្រើប្រាស់ដើម្បីសុំធ្វើការងារអចិន្ត្រៃយ៍ និងជាអ្នកតាំងទីលំនៅឡើយ។ ប្រការនេះអាចបែងចែកចំណាកស្រុកនៃពលករឱ្យដាច់ពីនីតិវិធីអន្តោប្រវេសន៍ដែលភាគច្រើនសាំញ៉ាំ និងដែលសម្រាប់ការសុំចូលស្នាក់នៅក្នុងប្រទេសជាបណ្តោះអាសន្ន។

*ការពង្រឹងភាពបន្ទាន់ និងកិច្ចការពារ* ៖ ការប្តេជ្ញានៅក្រោម GATS គឺកាតព្វកិច្ចជាអចិន្ត្រៃយ៍ សូម្បីតែនៅពេលប្រទេសជាគោលដៅទទួលយកតម្រូវការឱ្យមានអ្នកចំណាកស្រុកកាន់តែច្រើនឡើងបន្ថែមទៀតក៏ដោយ ពួកគេអាចភ័យព្រួយអំពីការធ្វើឱ្យមានការប្តេជ្ញាជាអចិន្ត្រៃយ៍។ ទោះជាយ៉ាងណាក៏ដោយ កង្វល់ទាំងនេះអាចដោះស្រាយបាន ប្រសិនបើបទបញ្ជារបស់ GATS អាចអនុញ្ញាតឱ្យប្រទេសនានាស្នើសុំចាត់វិធានការការពារក្នុងករណីមានភាពបន្ទាន់ ឬអនុញ្ញាតជាការប្តេជ្ញាដោយកំណត់ពេល។ ប្រទេសនានាអាចនៅតែតម្រូវឱ្យមានការធ្វើតេស្តអំពីតម្រូវការសេដ្ឋកិច្ច ប៉ុន្តែ តាមវិធីដែលមិនតាមទំនើងចិត្តដូចកាលពីមុន។

នឹងខ្សែចង្វាក់នៃតម្លៃ ដោយរាប់ចាប់ពីការបញ្ចូលទិន្នន័យ រហូតដល់កិច្ចការដែលត្រូវការជំនាញខ្ពស់ ដូចជា ម៉ូឌែលវិមាត្របី (ប្រអប់ ៥.៨)។

ជាលទ្ធផល លំហូរនៃលទ្ធកម្មពីខាងក្រៅរវាងប្រទេសនានាមានភាពកាន់តែសាំញ៉ាំ។ ជាក់ស្តែង ក្រុមហ៊ុន IT មួយចំនួននៅឥណ្ឌា និងអ្នកផ្គត់ផ្គង់ BPO ឯករាជ្យ កំពុងធ្វើលទ្ធកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាចិន និង ហ្វីលីពីន ដែលផ្តល់ប្រហាក់ប្រហែលនឹងអតិថិជនពីស.រ.អាដែរ។ ក្រុមហ៊ុនពីសឹង្ហបូរី ដូចជាប្រព័ន្ធកុំព្យូទ័រសឹង្ហបូរីកំពុងបង្កើតបរិក្ខារធ្វើលទ្ធកម្មដោយខ្លួនឯងនៅក្នុងប្រទេសឥណ្ឌា និងចិន។

ប្រអប់ ៥.៧

## ការធ្វើលទ្ធកម្មដំណើរការជំនួញ - ឥទ្ធិពលលើការពង្រីកចំនួនការងារ

ការរួមចំណែកពិសេសពី Narayana Murthy ប្រធានក្រុមហ៊ុនធំជាងគេមួយខាងលទ្ធកម្មនៅក្នុងប្រទេសឥណ្ឌា Infosys។

ឥឡូវនេះ ឧស្សាហកម្មលទ្ធកម្មដំណើរការជំនួញនៅលើពិភពលោក (BPO) ផ្តល់សេវាដែលមានចាប់ពីធនធានមនុស្ស ការស្រាវជ្រាវ និងសកម្មភាពហិរញ្ញវត្ថុ ដើម្បីបង្កើតប្លង់ និងមុខងារវិស្វកម្ម។ នៅទូទាំងពិភពលោក ប្រាក់ចំណូលរបស់ BPO ត្រូវបានរំពឹងថាកើនឡើងដល់ ១១៣.៧០០ លានដុល្លារនៅក្នុងឆ្នាំ ២០០៤។

ឧស្សាហកម្ម BPO នៅអាស៊ី ត្រូវបានប៉ាន់ប្រមាណថាកើនឡើងច្រើនជាង ១៣.៨% ក្នុងមួយឆ្នាំ រហូតដល់ឆ្នាំ២០០៨ ហើយការបង្កើតការងារត្រូវបានរំពឹងថានឹងមានសំទុះកើនឡើង នាំឱ្យមានការងារថ្មីរហូតដល់ ៦ លាននៅឆ្នាំ ២០១៥។ អត្ថប្រយោជន៍នៃលទ្ធកម្មនៅអាស៊ីកើតចេញពីកំណើនចំនួនកម្មករ ដែលមានជំនាញ និងមានប្រាក់កម្រៃថោក។ នៅឥណ្ឌា គ្រឹះស្ថានអប់រំប្រមាណ ៣.០០០ បានបណ្តុះបណ្តាលអ្នកឯកទេសកម្មវិធីកុំព្យូទ័រចំនួន ២០០.០០០នាក់ គឺជាចំនួនស្មើនឹងនិស្សិតបញ្ចប់ការសិក្សា ដែលជាអ្នកនិយាយភាសាអង់គ្លេស និងមិនមែនខាងផ្នែកវិស្វកម្ម។ ចិនបានបណ្តុះបណ្តាលនិស្សិតបញ្ចប់ការសិក្សាចំនួន ៤០០.០០០នាក់ ជារៀងរាល់ឆ្នាំ។ ទន្ទឹមនឹងនេះ ដោយសារមនុស្សមានអាយុចំណាស់ និងអ្នកអត្រាមានកូនតិចនៅក្នុងបស្ចិមប្រទេស និងស.រ.អា មានន័យថា នឹងមានកង្វះចំនួនពលករនៅក្នុងប្រទេសជឿនលឿន។ មានការប៉ាន់ប្រមាណថា តាមអត្រាចំនួនកូនដូចបច្ចុប្បន្ននេះ ស.រ.អាតែឯងនឹងត្រូវការកម្មករចំនួន ១៥.៦ លាននាក់ថែមទៀត នៅឆ្នាំ ២០១៥ ដើម្បីរក្សាស្តង់ដារបច្ចុប្បន្ននៃការរស់នៅ។

ឥណ្ឌាមានច្រើនជាង ៤០% នៃទីផ្សារ BPO នៅទូទាំងពិភពលោក។ ពីឆ្នាំ ២០០០ ដល់ ២០០៤ ប្រទេសនេះបានឃើញកំណើនចំនួនការងារប្រមាណ ២៦០.០០០ ដែលបានបង្កើតឡើងនៅក្នុងវិស័យនេះ។ ឧស្សាហកម្មនេះក៏ឃើញមានការកើនឡើងនៃប្រទេសជាគោលដៅប្រកបដោយភាពប្រកួតប្រជែង និងមានថ្លៃទាបនៅទូទាំងអាស៊ី ដូចជា ហ្វីលីពីន ចិន ម៉ាឡេស៊ី ថៃ និង វៀតណាម។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីទាញយកផលចំណេញពីកាលានុវត្តភាពនេះដែលបានពីលទ្ធកម្ម ប្រទេសនានាត្រូវតែលុបចោលរាល់ឧបសគ្គនានាចំពោះកំណើនដូចដែលមានស្រាប់។

ឧស្សាហកម្មលទ្ធកម្មស្ថិតក្រោមឥទ្ធិពលនៃវត្តមានចំនួនកម្មករជំនាញ និងដោយការចំណាយទាប។ ជាលទ្ធផល ជោគជ័យរយៈពេលវែងរបស់អាស៊ីក្នុងនាមជាគោលដៅនៅក្រៅប្រទេសនឹងអាស្រ័យទៅលើថា តើប្រទេសនានាអាចបង្កើនមូលធនខាងបញ្ញារបស់ខ្លួនបានត្រឹមណា។ បច្ចុប្បន្ន នៅប្រទេសឥណ្ឌាមានកុមារប្រមាណ ៤០% បានឈប់រៀននៅអាយុ ១០ឆ្នាំ។ នៅទូទាំងអាស៊ី កុមារ ៤៦ លាននាក់ស្ថិតនៅក្រៅសាលារៀន។ ជាការច្បាស់ណាស់ថា ប្រទេសនានាត្រូវតែពង្រីកការអប់រំនៅថ្នាក់បឋមសិក្សា។ ការអប់រំត្រូវផ្តោតលើការធ្វើទំនើបកម្មលើកម្មវិធីសិក្សា និងបន្សុំការអប់រំនៅកម្រិតខ្ពស់ជាមួយតម្រូវការនៃឧស្សាហកម្មនេះ។ លើសពីនេះ យើងត្រូវបង្កើតប្រព័ន្ធបែបថ្មីនៃឧស្សាហកម្ម មជ្ឈមណ្ឌលវិទ្យាសាស្ត្រនិងស្រាវជ្រាវ ព្រមទាំងសកលវិទ្យាល័យ ដើម្បីបង្កើតចំណេះដឹង និងបច្ចេកវិទ្យាថ្មី។

មេដឹកនាំកែទម្រង់របស់ចិន តេង ស៊ាវពីង ធ្លាប់បាននិយាយថា "ដើម្បីក្លាយជាអ្នកមាន ជាដំបូងអ្នកត្រូវធ្វើផ្លូវ"។ សុភាសិតនេះនៅតែត្រឹមត្រូវនៅក្នុងសម័យការព័ត៌មានវិទ្យានេះ ក៏ដូចជានៅក្នុងសម័យឧស្សាហកម្មដែរ។ ដើម្បីទទួលស្គាល់បានពេញលេញនូវផលចំណេញពីឧស្សាហកម្មលទ្ធកម្ម ប្រទេសនានាត្រូវតែផ្តោតលើការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនដើម្បីគាំទ្របណ្តុំឧស្សាហកម្ម ដោយធ្វើទំនើបកម្មបរិក្ខារផលិតអគ្គិសនី ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ព្រលានយន្តហោះ ផ្លូវធំៗ និងកំពង់ផែសមុទ្ររបស់ខ្លួន ។ លើសពីនេះ ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិប្រកបដោយប្រសិទ្ធិភាព មានសារៈសំខាន់ណាស់សម្រាប់ដោះស្រាយកង្វល់អំពីសន្តិសុខ និងភាពឯកជនរបស់ក្រុមហ៊ុនលទ្ធកម្ម។

ទម្រង់បែបថ្មីនៃការធ្វើលទ្ធកម្មពីខាងក្រៅបែបនេះ មានការទាក់ទាញដោយសារត្រូវការឱ្យមានផលិតកម្មជាច្រើនបែប ការប្រមូលផ្ដុំហានិភ័យមកជាមួយគ្នា និងទាញយកប្រយោជន៍ពីចំណុចខ្លាំងរបស់ប្រទេសនីមួយៗ។

ប្រទេសមួយចំនួននៅអាស៊ានបានទាញយកកាលានុវត្តភាពនេះ។ យោងតាមការសិក្សាមួយ មួយក្នុងចំណោមគោលដៅនៃការស្វែងរកពីខាងក្រៅគឺនៅអាស៊ី។ ឧទាហរណ៍ នៅឆ្នាំ ២០០១ ភាគចំណែករបស់ចិនមាន ១.១០០ លានដុល្លារ។ ចំណែកនៅអ៊ីស្រាអែល តួលេខនេះគឺ ៣.០០០ លានដុល្លារ នៅម៉ិកស៊ិកូ ៥០០លានដុល្លារ និង នៅអឺរ៉ុបខាងកើត ៤០០លានដុល្លារ។ ប៉ុន្តែប្រទេសជាច្រើនផ្សេងទៀតក៏បានរៀបចំខ្លួនឱ្យទៅជាគោលដៅនៃការផ្ដល់លទ្ធកម្មផងដែរ។[១០]

*បង់ក្លាដេស* គឺជាប្រទេសម្ចាស់ផ្ទះក្នុងការផ្ដល់សេវាកត់ត្រាក្នុងវិស័យពេទ្យ ដូចជា Digital Divide Data។

ប្រអប់ ៥.៨

### សេវាលទ្ធកម្មទៅតាមខ្សែចង្វាក់នៃតម្លៃ

ការធ្វើលទ្ធកម្មសកលនៃសេវាអាចចែកចេញជា ៥ ក្រុមធំៗ ដោយផ្អែក លើការរួមចំណែកទៅក្នុងតម្លៃនិងតម្រូវជំនាញរបស់ពួកគេ :

១. ការបញ្ចូលទិន្នន័យ digitization ការបំលែង និង ការសរសេរនៅចុងខាងទាបបំផុតនៃខ្សែចង្វាក់តម្លៃនិងជំនាញ គឺមុខងារនៃការិយាល័យនៅខាងក្រោយ ដូចជា សេវាស្មៀនជាមូលដ្ឋាន ដែលមិនទាមទារនូវចំណេះដឹងអំពីវិស័យឬជំនាញឯកទេសឡើយ។ សេវាទូទៅបំផុតមួយក្នុងចំណោមសេវាខាងលើគឺសេវាសរសេរដែលពាក្យសំដីរបស់វេជ្ជបណ្ឌិត ឬ របស់មេធាវីត្រូវបានបំលែងទៅជាកំណត់ហេតុខាងពេទ្យ ឬកំណត់ហេតុខាងផ្នែកច្បាប់។

២. ការចាត់ចែងទៅតាមបទបញ្ជា និងសេវាគាំទ្រងាយៗ ចំណុចបន្ទាប់នៅក្នុងខ្សែចង្វាក់តម្លៃគឺ សេវាការងារពីចម្ងាយដែលរួមមានការចាត់ចែងទៅតាមបទបញ្ជា និងផ្ដល់យោបល់ងាយៗ និងសេវាទាក់ទងអតិថិជន តាមប្រព័ន្ធអេឡិចត្រូនិក ផ្អែកទៅតាមបទបញ្ជាដែលកំណត់ដោយអតិថិជន។ បទបញ្ជាទាំងនេះ រួមមាន សេវាស្ថានីយ៍ទទួលការហៅ ការចាត់ចែងអ៊ីម៉ែល ការចាត់ចែងទិន្នន័យ ការចេញវិក័យប័ត្រនិងបង់ប្រាក់ ការបើកគណនី និង ពិនិត្យមើលពាក្យសុំប័ណ្ណឥណទាន ដែលកិច្ចការទាំងនេះផ្ដល់កម្រៃទាបត្រឹម ១០ ដុល្លារ/ម៉ោង។

៣. សកម្មភាពទាក់ទងនឹងការដោះស្រាយបញ្ហា និងការធ្វើសេចក្ដីសម្រេចកម្រិតខ្ពស់ជាងបន្តិចនៅក្នុងចង្វាក់តម្លៃ គឺជាសកម្មភាពដែលទាក់ទងនឹងការដោះស្រាយបញ្ហា និងការធ្វើសេចក្ដីសម្រេច ដូចជា បង្កើតដំណោះស្រាយសម្រាប់កែលំអដំណើរការនានា ឬ សម្រាប់បញ្ហាប្រព័ន្ធនានា។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជា ឥណ្ឌា ប្រាក់កម្រៃសម្រាប់ការងារនេះគឺ ១០-១៥ដុល្លារ/ម៉ោង។

៤. សេវាគាំទ្រសាំញ៉ាំជាច្រើនបែប ចំណុចបន្ទាប់នៅក្នុងខ្សែចង្វាក់តម្លៃគឺសេវាការងារពីចម្ងាយដែលទាក់ទងនឹងអន្តរកម្មដោយផ្ទាល់ជាមួយអតិថិជន ប៉ុន្តែមិនមែនត្រឹមតែផ្ដល់យោបល់ប៉ុណ្ណោះទេ ថែមទាំងផ្ដល់សេវាគាំទ្រចម្រុះតាមវិធីជាច្រើន និងមិនត្រឹមតែការសរសេរកម្មវិធីកុំព្យូទ័រធម្មតានោះឡើយ ថែមទាំងការគ្រប់គ្រងពីចម្ងាយនូវបណ្ដាញសាំញ៉ាំថែមទៀតផង។ កិច្ចការទាំងនេះរួមបញ្ចូលសកម្មភាពដូចជា ការថែទាំវេបសាយ ទំនាក់ទំនងទីផ្សារពីចម្ងាយ ផ្ដល់យោបល់ណែនាំដល់អតិថិជន ការចាត់ចែងបច្ចេកទេសនៅការិយាល័យខាងក្រោយ ការគ្រប់គ្រងទំនាក់ទំនងអតិថិជនពីចម្ងាយ ការបង្កើតប្លង់វេបសាយ ការបង្កើតកម្មវិធីកុំព្យូទ័រសម្រាប់ដំណើរការជំនួញទាំងមូល និងសេវាគាំទ្រខាងផ្នែករឹងនៃកុំព្យូទ័រ។

៥. សេវាឯកទេសដែលទាមទារចំណេះដឹងនិងជំនាញអំពីវិស័យ នៅចុងខាងលើនៃខ្សែចង្វាក់តម្លៃគឺសេវានានាដែលទាក់ទងនឹងបទពិសោធន៍លើវិស័យ និងជំនាញឯកទេស។ សកម្មភាពទាំងនោះរួមបញ្ចូលស្រាវជ្រាវ និងសេវាវិស្វកម្ម ដូចជា ការធ្វើម៉ូឌែលវិមាត្របី បង្កើតឯកសារពន្យល់អំពីផ្នែកលំអិតនៃបច្ចេកទេសសម្រាប់ការដេញថ្លៃវិស្វកម្មរោងចក្រ ការសាកពិសោធន៍គំរូដើម ការសាកល្បងនិងធ្វើឱ្យសមស្រប បង្កើតគំរូឡើងវិញសម្រាប់កែលំអផលធៀបរវាងថ្លៃចំណាយ និងដំណើរការការវិភាគហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ សេវាស្រាវជ្រាវអំពីទុនរួម និងសេវាផ្ដល់យោបល់និងណែនាំ។

*ប្រទេសកម្ពុជា* ផ្តល់សេវាទិន្នន័យឱ្យដល់ក្រុមហ៊ុនជំនួញ និងអតិថិជនជាសាធារណជនទាំងនៅក្នុងនិងក្រៅប្រទេស ហើយបច្ចុប្បន្ននេះកំពុងអនុវត្តកិច្ចការ digitizing របស់បណ្ណសារដ្ឋានពីសកលវិទ្យាល័យ Harvard ។

*ចិន* គឺជាមជ្ឈមណ្ឌលអភិវឌ្ឍន៍ផលិតផលគន្លឹះមួយសម្រាប់ GE, Intel, Microsoft, Phillips និង ក្រុមហ៊ុនអេឡិចត្រូនិកធំៗផ្សេងទៀត សម្រាប់ការបង្កើតបរិក្ខារ និងកម្មវិធីនៃកុំព្យូទ័រ ។

*ឥណ្ឌា* មានក្រុមហ៊ុន IT ដូចជា Infosys, TCS, Wipro nigSatyam ដែលផ្គត់ផ្គង់ IT ផ្នែកជំនួយបច្ចេកទេសគាំទ្រវេបសាយ និងសេវាហេដ្ឋារចនាសម្ព័ន្ធដល់ក្រុមហ៊ុននៅក្រៅប្រទេស ។ ក្រៅពីនេះក៏មានក្រុមហ៊ុនដែលធ្វើការនៅក្នុងការអភិវឌ្ឍផលិតផល បង្កើតប្លង់វិស្វកម្ម ធ្វើការសាកល្បង និងវិភាគបច្ចេកទេសផងដែរ ។

*ហ្វីលីពីន* គឺជាម្ចាស់ផ្ទះនៃការងារលទ្ធកម្ម ដែលធ្វើឡើងដោយក្រុមហ៊ុនបរទេសចំនួនប្រមាណ ៨.០០០ ដែលផ្តល់សេវា ដូចជា បង្កើតក្រាហ្វិក គំនូរប្លង់ស្ថាបត្យកម្ម ទំនាក់ទំនងទីផ្សារតាមទូរគមនាគមន៍ គណនេយ្យ និង សរសេរកូដសម្រាប់កម្មវិធីកុំព្យូទ័រ ។

*សិង្ហបុរី* មានអ្នកផ្តល់សេវា ដែលចូលរួមនៅក្នុងការបំពេញមុខងារទំនើបៗដូចជា ការគ្រប់គ្រងគ្រឿងយន្តពីចម្ងាយ ការថែទាំសុខភាព និងវិភាគរោគសញ្ញាសេនេទិក ។

*វៀតណាម* អនុវត្តការងារបង្កើតកូដងាយៗសម្រាប់ IBM, Cisco, bNþajNortel និង NTT ប៉ុន្តែក៏បង្កើនការចូលរួមនៅក្នុងសកម្មភាពដែលផ្តល់តម្លៃខ្ពស់ផងដែរ ដែលទាក់ទងនឹងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ បង្កើតប្លង់ដោយប្រើកុំព្យូទ័រ ហិរញ្ញវត្ថុ ស្វ័យប្រវត្តិកម្មរោងចក្រ ការថែទាំសុខភាព និងរូបគំនូរជីវចលក្នុងកុំព្យូទ័រ ។

ជាការច្បាស់ណាស់ថា អាចមានកាលានុវត្តភាពសម្រាប់លទ្ធកម្មនៅក្នុងបណ្តារដ្ឋដែលស្ថិតនៅដាច់ស្រយាល ឧទាហរណ៍ប្រទេសដែលមិនជាប់នឹងសមុទ្រ និងរដ្ឋកំពុងអភិវឌ្ឍន៍នៅលើកោះតូចៗ ជាពិសេសនៅក្នុងបណ្តារដ្ឋដូចជា ប៊ូតាណ និងម៉ុងហ្គោលី ដែលមានប្រជាជនជាច្រើនចេះនិយាយភាសាអង់គ្លេស ឬមានមនុស្សដែលមានការអប់រំកម្រិតខ្ពស់បង្គួរ ។

## ហេតុផលនៃលទ្ធកម្មពីខាងក្រៅ

លទ្ធកម្មនៅទូទាំងពិភពលោកកើតឡើង ដោយសារកត្តាខុសៗគ្នាជាច្រើន ។ ក្នុងករណីខ្លះ ក្រុមហ៊ុននឹងធ្វើលទ្ធកម្មទៅក្រុមហ៊ុននៅក្រៅប្រទេសដើម្បីផ្តល់ជំនាញជាក់លាក់ ។ ប៉ុន្តែជាទូទៅ សហគ្រាសនានាប្រឹងប្រែងដើម្បីកាត់បន្ថយការចំណាយលើសកម្មភាពជាមូលដ្ឋាន ដូច្នេះ ពួកគេនឹងពិនិត្យមើលក្នុងប្រទេស និងក្រុមហ៊ុននានាដែលអាចផ្តល់កម្មករដែលយកកម្រៃទាប មានការអប់រំកម្រិតខ្ពស់ដែលអាចផ្តល់ជំនាញជាច្រើនបែប និងអាចធ្វើបែបនេះទៅបានតាមរយៈហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ដែលល្អត្រូវចំណាយតិច និងមានរលកសម្លេងទូលាយ (high-bandwidth) ។ កត្តាផ្សេងទៀត ទាំងនៅក្នុងប្រទេសទិញ និងប្រទេសអ្នកលក់ ដែលមានឥទ្ធិពលទៅលើជម្រើសដៃគូលទ្ធកម្មមានបង្ហាញជូនក្នុងប្រអប់ ៥.៩ ។

ហេតុផលជាគោលការណ៍សម្រាប់លទ្ធកម្ម ជាទូទៅគឺក្នុងបំណងកាត់បន្ថយថ្លៃចំណាយដូច្នេះភាគច្រើននៃលទ្ធកម្ម

គឺឆ្ពោះទៅសេដ្ឋកិច្ចដែលមានកម្រៃទាប។ ឧទាហរណ៍ នៅក្នុងប្រតិបត្តិករទូរស័ព្ទ ស.រ.អា និងអ្នកកត់ត្រាផ្នែកពេទ្យ បានទទួលចំណូលប្រមាណ ១៣ ដុល្លារ/ម៉ោង ចំណែកនៅឥណ្ឌា ពួកគេអាចទទួលតិចជាង ២ ដុល្លារ/ម៉ោង។[១១] ដូចគ្នានេះដែរ នៅស.រ.អា អ្នកវិភាគហិរញ្ញវត្ថុមួយរូបអាចទទួលកម្រៃប្រមាណ ៣៥ ដុល្លារ/ម៉ោង ចំណែកអ្នកមានអាជីពដូចគ្នានៅឥណ្ឌា អាចទទួលបានត្រឹម ៦ ទៅ ១៥ ដុល្លារ/ ម៉ោង។ ការអង្កេតមួយបានសន្និដ្ឋានថា ការចំណាយប្រចាំខែដើម្បីរក្សានិយោជិតមួយរូបខាងផ្នែកបច្ចេកវិទ្យាជាន់ខ្ពស់នៅក្នុងក្រុមហ៊ុន Silicon Valley គឺ ១៥.០០០ ដុល្លារក្នុងម្នាក់ៗ។ ដើម្បីជួលមនុស្សម្នាក់នៅញូដេលីដែលមានជំនាញការ ទទួលខុសត្រូវ និងរបរដូចគ្នា អាចត្រូវចំណាយត្រឹម ២.៥០០ ដុល្លារក្នុងមួយខែ។ នេះអាចជាការសន្សំបាន ១២.៥០០ដុល្លារ/ខែ ឬ ១៥០.០០០ ដុល្លារ/ឆ្នាំ។ ដោយបានធ្វើលទ្ធកម្មការងារចំនួន ១០ ទៅឱ្យប្រទេសឥណ្ឌា ការចាប់ផ្តើមដំបូង នៅស.រ.អា អាចកាត់បន្ថយការចំណាយលើប្រាក់កម្រៃចំនួន ១.៥លានដុល្លារ។ ការចំណាយដំបូងលើការវិនិយោគក៏មានកម្រិតទាបជាងយ៉ាងខ្លាំងផងដែរ។ ឧទាហរណ៍ ដោយបង្កើតមជ្ឈមណ្ឌលទទួលទូរស័ព្ទមួយនៅក្រុងដេលី ការចំណាយមានត្រឹមប្រមាណមួយភាគបីនៃអ្វីដែលអាចត្រូវចំណាយនៅ ស.រ.អា។[១២]

ទោះជាយ៉ាងណាក៏ដោយក្រុមហ៊ុនផ្តល់លទ្ធកម្មជាច្រើនបានដឹងថា ពួកគេអាចសំចៃបានច្រើនជាងនេះទៅទៀតដោយសារកំណើនផលិតភាព ឧទាហរណ៍កំហុសឆ្គងតិចតួចក្នុងការវិភាគទិន្នន័យ និងការខូចខាតតិចតួចនៅក្នុងកម្មវិធីកុំព្យូទ័រ ឬគុណភាពខ្ពស់នៃការសរសេរកម្មវិធី។ ការធ្វើលទ្ធកម្មក៏អាចឱ្យក្រុមហ៊ុនកាត់បន្ថយហានិភ័យផងដែរ ដោយបង្កើនប្រភេទប្រតិបត្តិការនៅក្នុងមជ្ឈមណ្ឌលជាច្រើន។ ទន្ទឹមនឹងនេះ ពួកគេអាចកែប្រែសកម្មភាពរបស់ខ្លួននៅក្នុងប្រទេស ដើម្បីប្រមូលផ្តុំការយកចិត្តទុកដាក់លើសមត្ថភាពស្នូល។

*ក្រុមហ៊ុនផ្តល់លទ្ធកម្មជាច្រើន បានដឹងថា ពួកគេអាចសំចៃបានច្រើនជាងនេះទៅទៀតដោយសារកំណើនផលិតភាព*

ប្រអប់ ៥.៥

### កត្តាមានឥទ្ធិពលលើភាពប្រកួតប្រជែងនៅក្នុងលទ្ធកម្មសកល

នៅក្នុងប្រទេសដែលជាអ្នកផ្តល់សេវា ៖

- វត្តមានពលករនិងជំនាញ គុណភាពនៃកម្លាំងពលករ និងការវិនិយោគលើការ អប់រំដែលពាក់ព័ន្ធ
- ប្រាក់កម្រៃមានភាពប្រកួតប្រជែង
- ភាពខ្លាំងនៃឧស្សាហកម្ម IT ក្នុងស្រុក និងការផ្តោតលើការនាំចេញ
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ការលើកទឹកចិត្តនិងគាំទ្ររបស់រដ្ឋាភិបាល
- បរិយាកាសជំនួញ
- ច្បាប់កម្មសិទ្ធិបញ្ញា
- ស្ថានភាពនៃច្បាប់ក្នុងការគាំទ្រវិស័យ ដូចជា ទូរគមនាគមន៍ និងអ៊ិនធឺណិត

នៅក្នុងប្រទេសដែលជាអ្នកទិញ ៖

- លក្ខខណ្ឌនៃវដ្តជំនួញ
- វត្តមានជំនាញ និងកម្លាំងពលកម្ម
- អត្រាប្រាក់កម្រៃ
- តម្រូវការឱ្យបង្កើនប្រភេទសេវាប្រមូលផ្តុំហានិភ័យ និងកាត់បន្ថយថ្លៃចំណាយ
- ការអភិវឌ្ឍបច្ចេកវិទ្យា និងលទ្ធភាពសម្រាប់ផ្តល់សេវាដោយផ្ទាល់
- ច្បាប់ទាក់ទងនឹងការធ្វើលទ្ធកម្ម
- ការពារទិន្នន័យនិងលក្ខខណ្ឌកម្មសិទ្ធិបញ្ញា
- ច្បាប់ស្តីពីអន្តោប្រវេសន៍
- ការបញ្ជាក់គុណភាពជាអន្តរជាតិ
- អ្នកចំណូលថ្មីនិងអ្នកដទៃទៀត ដែលមានទំនាក់ទំនងនៅក្នុងប្រទេសជាអ្នកផ្គត់ផ្គង់។

## ឧបសគ្គនៅក្នុងការធ្វើលទ្ធកម្មពីក្រៅ

មិនមែនប្រទេសទាំងអស់សុទ្ធតែអាចទាញយកផលចំណេញពីការលានុវត្តភាពលទ្ធកម្មនោះឡើយ ។ឧបសគ្គចម្បងគឺ:

*កង្វះហេដ្ឋារចនាសម្ព័ន្ធ* : ឧទាហរណ៍ ប្រទេសក្រីក្រខ្លះពុំមានប្រព័ន្ធទូរគមនាគមន៍ដែលចាំបាច់ ឬការផ្គត់ផ្គង់ថាមពល ដែលអាចទុកចិត្តបាននោះឡើយ ។

*កង្វះធនធានមនុស្សដែលមានជំនាញ* : មានតែប្រទេសមួយចំនួនតូចតែប៉ុណ្ណោះនៅក្នុងតំបន់នេះ មានមនុស្សដែលបានទទួលការអប់រំគ្រប់គ្រាន់ប្រកបដោយជំនាញត្រឹមត្រូវ រួមទាំងចំណេះដឹងខាងកុំព្យូទ័រ និងភាសាបរទេស ជាពិសេសភាសាអង់គ្លេស ។

*ភាពទន់ខ្សោយនៃក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ* : ក្រុមហ៊ុនផ្តល់លទ្ធកម្ម ត្រូវមានប្រព័ន្ធច្បាប់រឹងមាំសម្រាប់ការពារទិន្នន័យនិងភាពសម្ងាត់ ជាពិសេសនៅក្នុងផ្នែកដូចជាការថែទាំសុខភាព និងសេវាហិរញ្ញវត្ថុ ។ ដូចគ្នានេះដែរ ពួកគេទាមទារឱ្យមានក្របខ័ណ្ឌបទបញ្ញត្តិរឹងមាំ ដើម្បីការពារការបង់ថ្លៃ និងទំនាក់ទំនងតាមប្រព័ន្ធអ៊ិនធឺណិត ។ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើននៅក្នុងតំបន់នេះពុំមានប្រព័ន្ធច្បាប់ដែលអាចត្រូវគ្នានឹងស្តង់ដារអន្តរជាតិនៅក្នុងផ្នែកទាំងនេះទេ ។

សូម្បីតែប្រទេសដែលមានបទពិសោធច្រើនលើការធ្វើលទ្ធកម្មក៏អាចប្រឈមនឹងបញ្ហានានាដែរ ។ ឧទាហរណ៍ នៅឥណ្ឌាឥឡូវមានការលំបាកជ្រើសរើសមនុស្សដែលមានជំនាញគ្រប់គ្រាន់ ។ ការអប់រំដែលមានបច្ចុប្បន្នមិនបានផ្តល់មនុស្សក្មេងៗប្រកបដោយការអប់រំគ្រប់គ្រាន់ អត្រាតម្រូវការមានកម្រិតខ្ពស់ ប្រាក់កម្រៃកំពុងកើនឡើង ឯអ្នកផ្តល់សេវាកំពុងអនុវត្តហួសពីសមត្ថភាពរបស់ខ្លួនឯង ។

លើសពីនេះ មានឧបសគ្គដែលបង្កដោយប្រទេសដែលផ្តល់លទ្ធកម្ម ។ ឧបសគ្គមួយចំនួនមានលក្ខណៈប្រយោល ដូចជា ការដាក់កំហិតយ៉ាងច្រើនលើទិដ្ឋាការការងារបណ្តោះអាសន្នសម្រាប់អ្នកឯកទេសដែលត្រូវចំណាយពេលនៅក្រៅប្រទេស ដើម្បីរៀបចំ និងអនុវត្តកិច្ចសន្យាលទ្ធកម្ម ។ ឧបសគ្គផ្សេងទៀត មានលក្ខណៈផ្ទាល់ ដោយសារកម្មករនៅក្នុងប្រទេសផ្តល់លទ្ធកម្មប្រឆាំងនឹងការបាត់បង់ការងារ ។ នៅស.រ.អាសហជីពកម្មករ ដូចជា កម្មករគមនាគមន៍អាមេរិកកំពុងចរចាប្រឆាំងនឹងការធ្វើលទ្ធកម្មរបស់ ក្រុមហ៊ុនស.រ.អា ឬទាមទារឱ្យមានសមភាពនៃប្រាក់កម្រៃរវាងអ្នកផ្តល់សេវានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសជឿនលឿន ។ ឧទាហរណ៍ នៅខែធ្នូ ឆ្នាំ ២០០២ វិស្វករចំនួន ២២.០០០នាក់ នៅស៊ីអេថិល បានគំរាមថានឹងដើរចេញពីការងារ ដើម្បីប្រឆាំងការសម្រេចរបស់ក្រុមហ៊ុនប៊ូអ៊ីងក្នុងការផ្តល់លទ្ធកម្មការងារទៅឱ្យវិស្វកររុស្ស៊ី ។ ជាលទ្ធផលនៃការប្រឆាំងនេះ ក្រុមហ៊ុនប៊ូអ៊ីងបានកាត់បន្ថយពាក់កណ្តាលនូវចំនួនការងារសម្រាប់កម្មកររុស្ស៊ី ។

ក្នុងការឆ្លើយតបចំពោះសម្ពាធបែបនេះ រដ្ឋមួយចំនួនបានដាក់កំហិតលើការធ្វើលទ្ធកម្មដោយអង្គភាពសាធារណៈ ។ ឧទាហរណ៍ នៅឆ្នាំ ២០០២ រដ្ឋញូជើស៊ី បានអនុម័តច្បាប់មួយដែលហាមឃាត់ការធ្វើលទ្ធកម្មកិច្ចសន្យារបស់រដ្ឋាភិបាលទៅប្រទេសដទៃ ។ ការវាស់ឥទ្ធិពលសុទ្ធនៃសម្ពាធរបស់អ្នកនិយមការពារបែបនេះគឺជាការលំបាក ។ ការហាមឃាត់លើការធ្វើលទ្ធកម្មរបស់រដ្ឋាភិបាល ទំនងជាមានឥទ្ធិពលចម្បង ដោយសារនៅក្នុងប្រទេស ដូចជាឥណ្ឌា គម្រោងបែបនេះផ្សំដោយលទ្ធកម្មត្រឹម ១% ឬតិចជាង ។ ទោះជាយ៉ាងណាក៏ដោយ ការប្រឈមរបស់អ្នកការពារនិយមអាចរីកសាយ ហើយចាប់ផ្តើមមានឥទ្ធិពលទៅតាមកម្រិត និងប្រភេទនៃជំនួញលទ្ធកម្ម ។

*ផលប៉ះពាល់នៃការងារដោយសារលទ្ធកម្មសកល* ៖ ការធ្វើលទ្ធកម្មត្រូវការចំនួនកម្មករតិចតួចនៅចុងខាងនៃខ្សែសង្វាក់តម្លៃនៃផ្សារពលកម្ម ហើយអាចត្រូវបានចាត់ទុកថាមិនទំនងជាមានឥទ្ធិពលទៅលើភាពក្រីក្រដោយផ្ទាល់នោះឡើយ។ ឧទាហរណ៍ ឥណ្ឌា មានមនុស្សត្រឹមតែចំនួនជាងមួយលាននាក់ដែលធ្វើការក្នុងសេវាកម្មវិធីកុំព្យូទ័រ និង IT ប៉ុន្តែចំនួននេះមានត្រឹមមួយភាគបួនភាគរយនៃចំនួនកម្មករទាំងអស់តែប៉ុណ្ណោះ។ ប្រសិនបើវិស័យនេះរីកលូតលាស់បួនដងនៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំខាងមុខ វាអាចនឹងកើនបានត្រឹមចំនួន ១% នៃចំនួនកម្មករសរុប ហើយកាលានុវត្តភាពនេះអាចផ្តល់សម្រាប់តែអ្នកដែលមានចំណេះដឹងជាមូលដ្ឋាន និងមានជំនាញកុំព្យូទ័រ និងដែលប្រើប្រាស់កាលានុវត្តភាពបណ្តុះបណ្តាលតែប៉ុណ្ណោះ។

ទោះជាយ៉ាងណាក៏ដោយ ការងារបែបនេះមានឧត្តមភាពខ្លះៗសម្រាប់ការអភិវឌ្ឍមនុស្ស។ ទីមួយ វាផ្អែកលើទិដ្ឋភាពធំទូលាយខាងសង្គមជាងប្រភេទការងារជាច្រើនផ្សេងទៀត។ ឧទាហរណ៍ ស្ថានីយ៍ទូរស័ព្ទមួយដែលប្រើប្រាស់មនុស្សចំនួន ៥០.០០០នាក់ នៅហ្វីលីពីន និង ១៥០.០០០នាក់ នៅឥណ្ឌា មានគោលនយោបាយការងារទូលំទូលាយ។ នៅក្នុងប្រទេសដែលប្រឈមនឹងការខ្វះខាតពលករដែលមានជំនាញ ក្រុមហ៊ុនរីករាយក្នុងការជួលមនុស្សដែលជាធម្មតាត្រូវស្ថិតនៅក្រៅទីផ្សារពលកម្ម រួមទាំងស្ត្រី និងអ្នកចូលនិវត្តន៍។ ឧទាហរណ៍ នៅឥណ្ឌា ក្រុមហ៊ុន Wipro មាននិយោជិក ៥.០០០នាក់ ក្នុងនោះជិតពាក់កណ្តាល គឺជាស្ត្រី ហើយសម្រាប់ក្រុមហ៊ុន ICICI One Source និង DakshIndia សមាមាត្រនៃនិយោជិត ស្ត្រីមានប្រមាណ ៦០%។

ក្រុមហ៊ុនខ្លះក៏កំពុងធ្វើការពិសោធន៍ជាមួយការដាក់ទីតាំងស្ថានីយ៍ទិន្នន័យ និងស្ថានីយ៍ទូរគមនាគមន៍នៅជិតតំបន់ទីប្រជុំជន ឬអនុញ្ញាតឱ្យប្រជាជនធ្វើការពីផ្ទះរបស់ខ្លួន ដែលធ្វើឱ្យអ្នកធ្វើការពីផ្ទះ និងអ្នកចូលនិវត្តន៍ងាយស្រួលចូលរួមក្នុងការងារនេះ។ អ្នកដទៃបានផ្តោតជាសំខាន់លើការពង្រីកកាលានុវត្តភាពការងារហួសពីក្រុមគោលដៅជាធម្មតានៃអ្នកបញ្ចប់សញ្ញាប័ត្រ និងអ្នកដែលមានស្ថានភាពសេដ្ឋកិច្ចល្អប្រសើរ។ សហគ្រាសដែលផ្តួចផ្តើមដោយអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា ឈ្មោះក្រុមហ៊ុន Digital Data Divide ដែលជាអ្នកផ្តល់សេវាឌីជីថល និងបញ្ចូលទិន្នន័យ ផ្តល់ការងារដល់អ្នកពិការ អ្នកដែលរងគ្រោះដោយសារមីនកប់ក្នុងដី និងអ្នករងគ្រោះ ដោយជម្ងឺ ស្វិតអវៈយវៈ និងកុមារកំព្រា តាមអត្រាប្រចាំខែ (៦៥ដុល្លារ) ដែលខ្ពស់ជាងអ្នកដែលធ្វើការនៅក្នុងកម្មន្តសាល (៤០ដុល្លារ)។ ក្នុងចំណោមបុគ្គលិកសរុបរបស់ក្រុមហ៊ុនចំនួន ៩៣នាក់ មានពាក់កណ្តាលជាស្ត្រី។[១៣] ដូច្នេះលទ្ធកម្មសកលអាចជួយឱ្យក្រុមមនុស្សដែលគេពុំសូវមើលឃើញ និងក្រុមទន់ខ្សោយ ចូលរួមនៅក្នុងទីផ្សារពលកម្ម។ លើសពីនេះអត្រាប្រាក់កម្រៃនៅក្នុងជំនួញបែបនេះទំនងជាខ្ពស់ជាងនៅកន្លែងដទៃទៀត វាអាចផ្តល់ឱ្យអ្នកទាំងនោះ មានការកែលំអយ៉ាងច្រើនលើស្តង់ដារនៃការរស់នៅ។

លទ្ធកម្មក៏អាចជួយពង្រឹងជំនាញនៅកម្រិតអន្តរជាតិផងដែរ។ ប្រការនេះអាចកើតមានឡើងទាំងនៅក្រៅ និងក្នុងប្រទេស។ និយោជិតនៅក្រៅប្រទេសអាចទទួលយកកម្មករដើម្បីសិក្សាអំពីការអនុវត្តផ្នែកបច្ចេកទេស ផលិតផល ដំណើរការ និងបច្ចេកទេសទាក់ទងទីផ្សាររបស់អ្នកទាំងនោះ។ ប៉ុន្តែ សូម្បីតែកម្មករដែលនៅធ្វើការក្នុងផ្ទះនឹងអាចទទួលជំនាញជាច្រើន ក្នុងការគ្រប់គ្រងទំនាក់ទំនងអតិថិជន ដូច្នេះត្រូវរៀនសូត្រដើម្បីផ្តោតលើគុណភាព និងពេលវេលាសមស្រប។ ដូច្នេះ កម្លាំងពលករទទួលបាននូវចំណេះដឹងអំពីវិទ្យាសាស្ត្របន្ថែមទៀត ដែលជាវប្បធម៌នៃការងារប្រកបដោយវិជ្ជាជីវៈច្រើនជាងមុន និងកំណើននៃគណនេយ្យភាព។

*ការធ្វើលទ្ធកម្មត្រូវការចំនួនកម្មករតិចតួចនៅចុងខាងនៃខ្សែសង្វាក់តម្លៃនៃផ្សារពលកម្ម វត្តមាននៃការងារដែលផ្តល់កម្រៃខ្ពស់ក៏ទាំឱ្យបាត់បង់ធនធានមនុស្សផងដែរ*

វត្តមាននៃការងារដែលផ្តល់កម្រៃខ្ពស់ក៏ជួយធ្វើឱ្យបាត់បង់"ធនធានមនុស្ស"ផងដែរ។ ការធ្វើលទ្ធកម្មដោយក្រុមហ៊ុនពហុជាតិ ដូចជា GE និង IBM នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដូចជា ឥណ្ឌា និងចិន បានធ្វើឡើងទន្ទឹមនឹងចលនាឡើងកាន់តែខ្ពស់នៃអត្រាប្រាក់បៀវត្សរ៍ ដែលជាការកាត់បន្ថយការលើកទឹកចិត្តឱ្យអ្នកមានជំនាញចាកចេញពីប្រទេស។ តាមពិត មានភស្តុតាងខ្លះៗអំពីមាតុភូមិនិវត្តន៍មកវិញ។ ក្រុមហ៊ុនមួយចំនួនបញ្ជូនបុគ្គលិកបរទេសទៅធ្វើការនៅក្រៅប្រទេស ហើយអ្នកឯកទេស និងអ្នកគ្រប់គ្រងជាន់ខ្ពស់ក៏វិលត្រលប់ដោយស្ម័គ្រចិត្តមកកាន់ប្រទេសដើមរបស់ខ្លួនវិញ ដោយសារការទាក់ទាញនៃអត្រាប្រាក់បៀវត្សរ៍ដែលប្រហាក់ប្រហែលគ្នា នៅក្នុងក្រុមហ៊ុនអន្តរជាតិ កំណែលំអលក្ខខណ្ឌធ្វើការងារ និងផ្លាស់ប្តូរមុខមាត់នៃប្រទេសរបស់ខ្លួន។

ទោះជាយ៉ាងណាក៏ដោយ មិនមែនគ្រប់ការងារមានឥទ្ធិពលវិជ្ជមាននោះឡើយ ហើយមានភស្តុតាងខ្លះដែលបង្ហាញថាលទ្ធកម្មអាចនាំទៅរកការបាត់បង់ជំនាញ។ នេះដោយសារក្រុមហ៊ុនលទ្ធកម្មអាចទាក់ទាញសូម្បីតែមនុស្សដែលបានទទួលការបណ្តុះបណ្តាលបានច្រើន ធ្វើការនៅកន្លែងដែលទាមទារជំនាញទាប ប៉ុន្តែបានទទួលប្រាក់បៀវត្សរ៍ខ្ពស់។ ឧទាហរណ៍ នៅបង់ក្លាដេស វេជ្ជបណ្ឌិតទទួលយកការងារជាអ្នកសរសេរវេជ្ជបញ្ជា ហើយអ្នកមានសញ្ញាប័ត្រវិស្វកម្មនិងវិទ្យាសាស្ត្រច្រើនតែត្រូវបានជួលឱ្យធ្វើការជាធម្មតា ដូចជា អ្នកបង្កើតកម្មវិធីកុំព្យូទ័រ និងបង្កើត និងថែទាំទំព័រវេបសាយ ។ ក៏ដូចជាការប្រើប្រាស់ជំនាញមិនអស់លទ្ធភាពដែរ នេះក៏ជាហានិភ័យដែលបង្វែរទិសគោលនយោបាយអប់រំជាតិ និងការបណ្តុះបណ្តាល ដើម្បីឆ្លើយតបនឹងតម្រូវការរយៈពេលខ្លីសម្រាប់មនុស្សដែលមានជំនាញតិចតួច និងឆ្ងាយពីការអប់រំដែលផ្តោតលើវិទ្យាសាស្ត្រជាមូលដ្ឋានគ្រឹះ ការស្រាវជ្រាវ និងការអភិវឌ្ឍរយៈពេលវែង ដែលជាតម្រូវការដើម្បីជួយកសាងសមត្ថភាពផលិតនៅក្នុងប្រទេស។

## ឥទ្ធិពលសាយភាយនៃការងារ

ផលប្រយោជន៍នៃលទ្ធកម្ម មិនមែនត្រឹមតែទទួលបានដោយអ្នកដែលចូលធ្វើការនោះផ្ទាល់តែប៉ុណ្ណោះទេ។ កម្មករទាំងនេះនឹងចំណាយប្រាក់កម្រៃរបស់ខ្លួន និងធ្វើឱ្យមានកត្តាខាងក្រៅដ៏សំខាន់និងឥទ្ធិពលសាយភាយ។ ភាគច្រើននៃនិយោជិតលទ្ធកម្ម ទំនងជាមានអាយុក្នុងរង្វង់ពី ២០ ទៅ ៣០ឆ្នាំ គឺជាក្រុមមនុស្សដែលជម្រុញឱ្យមានតម្រូវការលើទំនិញប្រើប្រាស់បានយូរ និងសេវាផ្សេងទៀត។ ខណ្ឌ Gurgaon នៅក្រុងដេលី ដែលជាកន្លែងផ្តល់លទ្ធកម្មចម្បងនៅឥណ្ឌា បានទទួលការរីកចម្រើនយ៉ាងឆាប់រហ័សខាងមជ្ឈមណ្ឌលលក់ទំនិញ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ដែលពាក់ព័ន្ធជាមួយការឆ្លើយតបនឹងតម្រូវការពីនិយោជិតនៅក្នុងឧស្សាហកម្ម BPO ។

កម្មកររបស់ក្រុមហ៊ុនលទ្ធកម្មក៏ជម្រុញឱ្យមានសេវាបន្ទាប់បន្សំជាច្រើនផងដែរ លើផ្នែកគ្រប់គ្រងផ្ទះ សន្តិសុខ សេវាម្ហូបអាហារ ដឹកជញ្ជូន ទ្រព្យសម្បត្តិអចលនវត្ថុ ទូរគមនាគមន៍ និងការផ្តល់និងថែទាំបរិក្ខារកុំព្យូទ័រ។ អ្នកផ្តល់ចំណីអាហារនឹងត្រូវផ្គត់ផ្គង់សម្រាប់វេនផ្តល់សេវាជាច្រើន។ អ្នកសម្អាត អ្នកបោសសម្អាត អ្នកយាមទ្វារ និងបុគ្គលិកបន្ទាប់បន្សំដទៃទៀតក៏ត្រូវការផងដែរ ដើម្បីថែទាំបរិវេណដែលមានលក្ខណៈទំនើប។ ក្នុងករណីពុំមានសេវាដឹកជញ្ជូនដែលអាចទុកចិត្តបាន មានការជួលរថយន្ត និងអ្នកបើកបរជាក្រុម ដើម្បីដឹកជញ្ជូននិយោជិកពីស្ថានីយ៍ទូរស័ព្ទ ពីផ្ទះ និងទៅផ្ទះរបស់អ្នកទាំងនោះវិញ។ ដូច្នេះ ក្នុងពេលដែលវិស័យនេះ អាចផ្តោតទៅរកប្រភេទនិយោជិកបែបណាមួយនោះ វាក៏អាចបង្កើតដោយប្រយោលនូវកាលានុវត្តភាពការងារដោយសមធម៌ដែលមានភាពអព្យាក្រឹត្យ

សម្រាប់មនុស្សទាំងពីរភេទ ប្រភេទជំនួញ និងកម្រិតជំនាញ។

លទ្ធកម្មក៏ជម្រុញឱ្យមានការបង្កើតគ្រឹះស្ថាន និងហេដ្ឋារចនាសម្ព័ន្ធបណ្តុះបណ្តាលថ្មីផងដែរ ដូចជា សាលាបច្ចេកទេសកុំព្យូទ័រ កម្មវិធីយកសញ្ញាប័ត្រ ការបណ្តុះបណ្តាលអំពី IT និងវគ្គបង្រៀនអំពីការកម្មវិធីនានានៃកុំព្យូទ័រនៅតាមវិទ្យាស្ថាន និងសកលវិទ្យាល័យនានា។ អ្នកផ្គត់ផ្គង់លទ្ធកម្មសង្កេតមើលវែងឆ្ងាយបន្ថែមទៀត។ ឥឡូវគ្រឹះស្ថានទាំងនេះកើតឡើងមិនត្រឹមតែនៅក្នុងទីក្រុងធំៗប៉ុណ្ណោះទេ ថែមទាំងរហូតដល់ក្រុងតូចៗ និងទីប្រជុំជននានាផងដែរ ដែលជាការជួយពង្រាយប្រាក់ចំណូល និងផលប្រយោជន៍នៃការងារ។

## ផលប៉ះពាល់ខាងសង្គមនៃលទ្ធកម្ម

ការធ្វើលទ្ធកម្មអាចមានឥទ្ធិពលវិជ្ជមានជាច្រើនខាងសង្គម ដោយផ្តល់ការងារដល់មនុស្សជាច្រើនពាន់នាក់នៅគ្រប់អាយុ និងអព្យាក្រឹត សម្រាប់មនុស្សទាំងពីរភេទ។ ប៉ុន្តែ វាក៏ធ្វើឱ្យខូចបង់ខាងផ្នែកសង្គមផងដែរ។ ការខូចបង់ខ្លះៗទាក់ទងនឹងលក្ខខណ្ឌធ្វើការងារដ៏លំបាក។ ប្រការទាំងនេះ រួមមានដូចជាឥទ្ធិពលអវិជ្ជមានលើសុខភាពដោយសារត្រូវធ្វើការងារសម្រាប់វេនយប់ ការងារដែលតម្រូវឱ្យធ្វើនៅនឹងមួយកន្លែង និងការប្រើប្រាស់កុំព្យូទ័រជាប្រចាំ។ វេនយប់ដែលមានរយៈពេលវែងនៅតាមស្ថានីយ៍ទទួលទូរស័ព្ទក៏អាចរាំងស្ទាត់និយោជិកក្មេងៗពីការចូលរួមនៅក្នុងជីវភាពសង្គម និងអាចធ្វើឱ្យអ្នកទាំងនេះឃ្លាតឆ្ងាយពីសហគមន៍របស់ខ្លួនផងដែរ។

កំណើនយ៉ាងឆាប់រហ័សនៃឧស្សាហកម្មលទ្ធកម្ម ក៏នាំឱ្យមានកំណើនគម្លាតគ្នាផងដែរ។ ឧទាហរណ៍ នៅឥណ្ឌា ការរីកលូតលាស់យ៉ាងឆាប់រហ័សនៅបែងហ្គាឡ័រ បានធ្វើឱ្យមានកំណើនវិសមភាពរវាងទីក្រុងនិងជនបទនិងភូមិតូចៗ។ សូម្បីតែនៅក្នុងទីក្រុង មានសង្កាត់ខ្លះៗបានអភិវឌ្ឍប្រព័ន្ធទូរគមនាគមន៍ចំណែកកន្លែងផ្សេងទៀតត្រូវបានបំភ្លេចចោល។ ទន្ទឹមនឹងនេះដែរ អ្នកក្រនៅទីក្រុងរងគ្រោះដោយសារកំណើនថ្លៃចំណាយ ការខូចខាតខាងភាពជាទីគាប់ចិត្តនៃប្រជាពលរដ្ឋ និងការហូរចូលនៃជនចំណាកស្រុក។ ដូច្នេះ លទ្ធកម្មអាចរួមចំណែកចំពោះទីផ្សារពលកម្ម ឯការបែងចែកព័ត៌មានមិនអាចបម្រើផលប្រយោជន៍ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់រយៈពេលវែងឡើយ។

## ផលប៉ះពាល់ខាងសារពើពន្ធនិងពាណិជ្ជកម្ម

ដោយសារទំហំរបស់វា លទ្ធកម្មអាចជាប្រភពសំខាន់នៃប្រាក់ពន្ធដែលអាចធ្វើឱ្យរដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍អាចចំណាយច្រើនជាងមុនលើសេវាសង្គម។ ទោះជាយ៉ាងណាក៏ដោយ ជាញឹកញាប់ អត្ថប្រយោជន៍ខាងសារពើពន្ធមានកម្រិតទាប។ ដើម្បីលើកទឹកចិត្តសកម្មភាពទាំងនេះ រដ្ឋាភិបាលជាច្រើនបានលើកលែងពន្ធលើសកម្មភាពទាំងនេះ ឬលើកលែងពន្ធលើការនាំចូលបរិក្ខារកុំព្យូទ័រ និងបរិក្ខារទូរគមនាគមន៍។ តាមពិតរដ្ឋាភិបាលអាចត្រូវចំណាយច្រើនលើការកសាងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍សម្រាប់បង្កើតប្រព័ន្ធធ្វើការជាមួយទូរគមនាគមន៍។ ជាលទ្ធផល បើនិយាយពីសារពើពន្ធ ក្រុមហ៊ុនលទ្ធកម្មអាចមិនមែនជាអ្នករួមវិភាគទានសុទ្ធទេ តែគឺជាអ្នកទទួលផលសុទ្ធទៅវិញ។

ដូចគ្នានេះដែរ នៅលើវណសិរ្សពាណិជ្ជកម្ម ទោះបីលទ្ធកម្មរួមវិភាគទានចំពោះប្រាក់ចំណូលពីការនាំចេញក្តី ក៏មានការហូរចេញនូវរូបិយបណ្ណបរទេសច្រើនសន្ធឹកសន្ធាប់ផងដែរពីអ្នកផ្គត់ផ្គង់លទ្ធកម្មដែលទិញ bandwidth ដូចជាពីក្រុមហ៊ុនទូរគមនាគមន៍ ឬក្រុមហ៊ុនដែលទិញបរិក្ខារកុំព្យូទ័រពីសេដ្ឋកិច្ចលទ្ធកម្ម។

*កំណើនយ៉ាងឆាប់រហ័សនៃឧស្សាហកម្មលទ្ធកម្មក៏នាំឱ្យមានកំណើនគម្លាតគ្នាផងដែរ*

## យុទ្ធសាស្ត្រក្នុងប្រទេសធ្វើលទ្ធកម្ម

លទ្ធកម្មអាចមានឥទ្ធិពលជាច្រើន ទាំងវិជ្ជមាន និង អវិជ្ជមានសម្រាប់ការអភិវឌ្ឍមនុស្ស ( ប្រអប់ ៥.១០ ) ។ ដូច្នេះ ការប្រឈមសម្រាប់រដ្ឋាភិបាលគឺ ការបង្កើតបរិយាកាសដែល សមស្របសម្រាប់លទ្ធកម្ម ទន្ទឹមនឹងដាក់បញ្ចូលលទ្ធកម្មទៅ ជាមួយផ្នែកផ្សេងទៀតនៃសេដ្ឋកិច្ច ដើម្បីអាចទាញយកផល ប្រយោជន៍ពីការអភិវឌ្ឍផ្សេងទៀតដែលពាក់ព័ន្ធ។ ប្រការនេះ អាចគ្របដណ្តប់ផ្នែកជាច្រើននៃគោលនយោបាយ ( ប្រអប់ ៥.១១ ) ។

*ធនធានមនុស្ស និង ទីផ្សារពលកម្ម* : ការផ្តោតទៅ លើចុងម្ខាងខ្ពស់នៃទីផ្សារ ទាមទារឱ្យមានការវិនិយោគលើការ បណ្តុះបណ្តាលវិជ្ជាជីវៈ។ ជាក់ស្តែងរដ្ឋាភិបាលចិនកំពុងធ្វើការ

ប្រអប់ ៥.១០

### លទ្ធផលនៃការអភិវឌ្ឍមនុស្សបណ្តាលពីការធ្វើលទ្ធកម្ម

| ឥទ្ធិពលតាមរយៈ | ប្រភេទនៃឥទ្ធិពល | លទ្ធផលនៃការអភិវឌ្ឍមនុស្ស |
|---|---|---|
| បង្កើតការងារ និងប្រាក់ចំណូល - វិជ្ជមាន | បង្កើតការងារដែលផ្តល់កម្រៃខ្ពស់សម្រាប់អ្នកចេះកុំព្យូទ័រ ។<br>បង្កើតការងារដែលផ្តល់កម្រៃខ្ពស់សម្រាប់អ្នកដែលមានជំនាញឯកទេស និងជំនាញអំពីវិស័យនេះ ។<br>ស្រូបយកពលករក្មេងៗដែលចូលប្រឡូកក្នុងកម្លាំងពលកម្ម ។<br>បង្កើតឱកាសសម្រាប់ក្រុមដែលពុំសូវមានលទ្ធភាព ដូចជាជនពិការ និង ស្ត្រី | ការផ្តល់អំណាច<br>សមធម៌<br>ផលិតភាព |
| បង្កើតការងារ និង ប្រាក់ចំណូល - អវិជ្ជមាន | ជួលមិនអស់ និងប្រើប្រាស់មិនអស់សក្តានុពលនៃមូលធនមនុស្ស ។<br>គាបសង្កត់លើជម្រើសមុខការ ។<br>ផ្តល់ចំនួនការងារតិចធៀបនឹងតម្រូវការ ។ | ឥទ្ធិពលអវិជ្ជមាននៃនិរន្តរភាព និង សមធម៌ |
| ការផ្ទេរជំនាញ និង ចំណេះដឹង - វិជ្ជមាន | ជម្រុញឱ្យទទួលបាននិងផ្ទេរជំនាញឯកទេស និងចំណេះដឹងអំពីវិស័យ ។<br>ផ្តល់លទ្ធភាពឱ្យទទួលបានជំនាញទូទៅ និងដែលងាយប្រើប្រាស់ ។<br>កសាងសមត្ថភាពសម្រាប់ផលិតកម្ម និងការបង្កើតថ្មីតាមបែបប្រពៃណី ។ | ផលិតភាព ការផ្តល់អំណាច |
| ការផ្ទេរជំនាញ និង ចំណេះដឹង - អវិជ្ជមាន | បាត់បង់ជំនាញដោយសារប្រើប្រាស់មូលធនមនុស្សមិនចំទិសដៅ ។<br>កំណត់ឡើងវិញនូវអាទិភាពវិនិយោគលើការអប់រំ និងគោលនយោបាយឆ្ងាយពីការអភិវឌ្ឍសមត្ថភាព សម្រាប់រយៈពេលវែង ។<br>ឥទ្ធិពលមានកម្រិតនៃជំនាញបង្កើតបានលើផ្នែកផ្សេងទៀតនៃសេដ្ឋកិច្ច ។ | កង្វល់អំពីផលិតភាព |
| ការបង្កើតធនធាន - វិជ្ជមាន | បង្កើនការវិនិយោគដោយក្រុមហ៊ុនក្នុងស្រុកនិងបរទេស ។<br>លើកទឹកចិត្តសហគ្រាសខ្នាតតូចនិងមធ្យម ។<br>បង្កើតតម្លៃ ។<br>បង្កើនប្រាក់ចំណូលពីការនាំចេញ ។<br>បង្កើនធនធានបានពីសារពើពន្ធ ។ | ផលិតភាព ការផ្តល់អំណាច និងសមធម៌ |

| | | |
|---|---|---|
| ការបង្កើតធនធាន - អវិជ្ជមាន | នាំទៅរកលំហូរចេញនៃរូបិយប័ណ្ណបរទេសតាមរយៈការនាំចូលនិងធ្វើមាតុភូមិនិវត្តន៍នៃប្រាក់ចំណេញ។ សម្បទានសារពើពន្ធ ការលើកទឹកចិត្តផ្សេងទៀត និងការបង្វែរធនធានពីផ្នែកផ្សេងនៃវិស័យសេដ្ឋកិច្ច។ | កង្វល់អំពីសមធម៌ ប្រសិនបើវិស័យនេះមានតែដោយកន្លែង និងជាអ្នកទទួលផលសុទ្ធ។ |
| បង្កើនមូលធនមនុស្ស - វិជ្ជមាន | ជួយរក្សាទុកមនុស្សដែលមានជំនាញ។<br>ជួយទាក់ទាញមនុស្សដែលមានជំនាញមកក្នុងប្រទេស។ | ផលិតភាព |
| បង្កើនមូលធនមនុស្ស-អវិជ្ជមាន | រហូតមកទល់ពេលនេះ ឥទ្ធិពលនៅមានកម្រិត។<br>ការធ្វើមាតុភូមិនិវត្តន៍នាំឱ្យបាត់បង់កាលានុវត្តភាពការងារនិងប្រាក់កម្រៃ។ | ផលិតភាព |
| កត្តាខាងក្រៅ និងឥទ្ធិពលសាយភាយ - វិជ្ជមាន | នាំទៅរកកំណើនឧស្សាហកម្ម និងសកម្មភាពបន្ទាប់បន្សំ និងបង្កើតការងារ និងការវិនិយោគដែលពាក់ព័ន្ធ។<br>អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលពាក់ព័ន្ធ។<br>លើកទឹកចិត្តឱ្យមានការរីកចម្រើននៃការអប់រំ បណ្តុះបណ្តាលចំណេះដឹងអំពីកំព្យូទ័រ និងការជ្រាបចូលនៃអ៊ិនធឺណិត។<br>បង្កើតឱ្យមានតម្រូវការ និងការប្រើប្រាស់ថ្នាក់កណ្តាល។ | ការផ្តល់អំណាច ផលិតភាព សមធម៌ និរន្តរភាព |
| កត្តាខាងក្រៅ និងឥទ្ធិពលសាយភាយ - អវិជ្ជមាន | បង្កើតគម្លាតរវាងទីជនបទនិងទីក្រុង។<br>បង្កើនគម្លាតនៅក្នុងទីក្រុង។<br>បង្កើនគម្លាតនៅទូទាំងតំបន់។<br>នាំទៅរកកំណើនដោយកន្លែង និងវិសមភាពជាមួយវិស័យផ្សេងទៀត។<br>បង្វែរធនធានឱ្យឆ្ងាយពីវិស័យផ្សេងទៀត។ | កង្វល់អំពីសមធម៌ និងនិរន្តរភាព |
| ទិដ្ឋភាពសង្គម វប្បធម៌ មុខរបរ | នាំទៅរកទម្លាប់រស់នៅនិងម៉ោងធ្វើការងារដែលមិនចូលចិត្ត បាត់អត្តសញ្ញាណវប្បធម៌។<br>បង្កើនវិសមភាពសង្គម។<br>បង្កើនភាពដាច់ពីគ្នានៃព័ត៌មាន។ | កង្វល់អំពីសមធម៌ និរន្តរភាព ផលិតភាពរយៈពេលវែង |

វិនិយោគលើកម្មវិធីបណ្តុះបណ្តាលក្រោមភាពជាដៃគូជាមួយ MNCs ហើយក្រុមហ៊ុនឥណ្ឌាកំពុងផ្តល់ការយកចិត្តទុកដាក់កាន់តែច្រើនឡើងលើជំនាញ ដូចជាការបង្កើតកម្មវិធីកុំព្យូទ័រ ដោយមានការបញ្ជាក់គុណភាពសមស្រប។ រដ្ឋាភិបាលវៀតណាមក៏កំពុងលើកទឹកចិត្តឱ្យគ្រឹះស្ថានបណ្តុះបណ្តាលក្រៅប្រទេសមកពីអូស្ត្រាលី និងឥណ្ឌា ផ្តល់ការបណ្តុះបណ្តាលជនជាតិវៀតណាមជាច្រើនពាន់នាក់ នៅក្នុងមជ្ឈមណ្ឌលសម្រាប់គោលបំណងនេះនៅទូទាំងប្រទេសដែរ។

*ស្តង់ដារនិងបទប្បញ្ញត្តិពលកម្ម* : លទ្ធផលអវិជ្ជមានខ្លះៗខាងសង្គម វប្បធម៌ និងវិជ្ជាជីវៈ អាចកាត់បន្ថយបាន ប្រសិនបើរដ្ឋាភិបាលផ្តោតច្រើនជាងមុនទៅលើស្តង់ដារពលកម្ម ទម្លាប់អនុវត្តលើការគ្រប់គ្រងធនធានមនុស្ស និងច្បាប់ការងារនៅក្នុងប្រទេស។ រដ្ឋាភិបាល និងឧស្សាហកម្ម ក៏អាចធ្វើការជាមួយគ្នាផងដែរ ដើម្បីប្រយុទ្ធប្រឆាំងការធ្វើឱ្យរេចរិលដែល

ប្រអប់ ៥.១១

### វិធានការក្នុងស្រុកដើម្បីលើកកម្ពស់ការធ្វើលទ្ធកម្ម

| ផ្នែកដែលត្រូវការគោលនយោបាយ | វិធានការជាក់លាក់ |
|---|---|
| ស៊ីជម្រៅលើទីផ្សារពលកម្ម និងការអភិវឌ្ឍធនធានមនុស្ស | ការវិនិយោគលើការអប់រំ និងបណ្តុះបណ្តាល ដើម្បី :<br>- បង្កើតកម្លាំងត្រៀមបម្រុងសម្រាប់សកម្មភាពនៅចុងខាងក្រោម<br>- បង្កើតកម្មវិធី គ្រឹះស្ថាន ហេដ្ឋារចនាសម្ព័ន្ធសម្រាប់បណ្តុះបណ្តាល ជំនាញឯកទេស<br>- ធានាគុណភាព និងការទទួលស្គាល់សញ្ញាប័ត្រ<br>ច្បាប់ការងារ និងស្តង់ដារសម្រាប់បង្កើត :<br>- ទម្លាប់គ្រប់គ្រងធនធានមនុស្សដោយផ្តោតលើសុខុមាលភាព<br>- យុទ្ធសាស្ត្ររក្សាទុកនិយោជិត និងការអភិវឌ្ឍអាជីព |
| ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | វិនិយោគលើសេវាគមនាគមន៍ ដោយ :<br>- លុបចោលមាត្រាស្តីពីភាពផ្តាច់មុខរបស់រដ្ឋាភិបាល<br>- លើកកម្ពស់ភាពប្រកួតប្រជែងលើសេវាទូរគមនាគមន៍តាមរយៈការលុបចោលបទបញ្ជា ជាពិសេស មាត្រាទាក់ទងនឹងសេវាអ៊ិនធឺណិត និងទូរស័ព្ទរយៈឆ្ងាយ<br>- ការវិនិយោគលើបណ្តាញផ្កាយរណប<br>- ពង្រីកទំហំរលកធាតុអាកាស<br>- ជម្រុញការបង្កើតបណ្តាញការងារពីចម្ងាយដោយបង្កើតស្ថានីយបច្ចេកវិទ្យា និងមណ្ឌលលទ្ធកម្ម<br>- សម្រួលឱ្យមានការទទួលបានអចលនទ្រព្យ ថាមពល បណ្តាញទូរគមនាគមន៍ និងធ្វើលទ្ធកម្មបរិក្ខារ ។ |
| ក្របខ័ណ្ឌច្បាប់ | ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា<br>- អំពីភាពអាថិកំបាំងនៃទិន្នន័យ កិច្ចការពារ និងការលួចចម្លងទិន្នន័យ<br>ច្បាប់ការពារអតិថិជន<br>ច្បាប់ទទួលខុសត្រូវវិសាលគម<br>ច្បាប់ស្តីពីការធ្វើជំនួញអេឡិចត្រូនិក<br>ច្បាប់ទាក់ទងនឹងរដ្ឋាភិបាលអេឡិចត្រូនិក<br>ច្បាប់ស្តីពីការទូទាត់ឆ្លងដែន និងកិច្ចការអ៊ិនធឺណិត<br>ក្របខ័ណ្ឌអាជ្ញាប័ណ្ណបច្ចេកវិទ្យា |
| គោលនយោបាយពន្ធ និងឧបត្ថម្ភធន | ការលើកទឹកចិត្តខាងផ្នែកពន្ធ និងការលុបចោលការយកពន្ធ<br>- ផ្តល់ការលើកទឹកចិត្តខាងសារពើពន្ធនៅក្នុងដំណាក់កាលដំបូង<br>- ដាក់ឧស្សាហកម្មនៅក្រោមបណ្តាញពន្ធនៅពេលដែលបានលូតលាស់ និងមានទំហំធំ<br>- ប្រើប្រាស់ធនធានសារពើពន្ធដើម្បីផ្តោតលើឧស្សាហកម្មជាក់លាក់ និងការវិនិយោគទូទៅលើហេដ្ឋារចនាសម្ព័ន្ធការបណ្តុះបណ្តាល<br>ការលើកទឹកចិត្តឱ្យមានការនាំចេញ<br>- ផ្តល់សម្បទានពន្ធនាំចូលនិងការបញ្ចុះថ្លៃនៅដំណាក់កាលដំបូង ក្រោយមកលុបចោលការអនុគ្រោះនេះ និងចាត់ទុកដូចគ្នាជាមួយវិស័យផ្សេងទៀត<br>- រារាំងការឧបត្ថម្ភធនលើការនាំចេញឱ្យដល់ក្រុមហ៊ុន ឬវិស័យនានាដែលអាចគាបសង្កត់លើពាណិជ្ជកម្ម<br>- ផ្តល់ការឧបត្ថម្ភធនសម្រាប់ហេដ្ឋារចនាសម្ព័ន្ធទូទៅ ដែលមិនគាបសង្កត់លើពាណិជ្ជកម្ម ។ |

មានអត្រាខ្ពស់ តាមរយៈការផ្តល់ការបណ្តុះបណ្តាល និងការអភិវឌ្ឍឱ្យបានច្រើន និងផ្តល់នូវរចនាសម្ព័ន្ធ សម្រាប់ឈោងចាប់យកអាជីពច្បាស់លាស់ទៅអនាគត។

*ទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗទៀត*: ប្រទេសនិងក្រុមហ៊ុនតូចៗចាំបាច់ត្រូវអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន។ ឧទាហរណ៍ពួកគេអាចលុបចោលបទបញ្ញត្តិទូរគមនាគមន៍និងសេវាអ៊ិនធឺណិត និងលុបចោលភាពផ្តាច់មុខសាធារណៈ ដើម្បីកាត់បន្ថយថ្លៃចំណាយ។ ឧទាហរណ៍វៀតណាមកំពុងគ្រោងលុបចោលភាពផ្តាច់មុខរបស់រដ្ឋលើការផ្តល់សេវាអ៊ិនធឺណិត ដើម្បីអនុញ្ញាតឱ្យមានការចូលរួមដាក់ទុនវិនិយោគពីនៅក្នុងវិស័យទូរគមនាគមន៍។ ប្រទេសម៉ាឡេស៊ីបានធ្វើការវិនិយោគយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធ IT (ប្រអប់ ៥.១២)។

*ក្របខ័ណ្ឌច្បាប់* : រដ្ឋាភិបាលអាចត្រូវដាក់ឱ្យអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ដែលស្របគ្នាជាមួយអន្តរជាតិទាក់ទងនឹងកិច្ចការពារសិទ្ធិលើកម្មសិទ្ធិបញ្ញា ជំនួញខាងអ៊ិនធឺណិត ភាពសម្ងាត់នៃទិន្នន័យ កិច្ចការពារអ្នកប្រើប្រាស់រដ្ឋាភិបាលអេឡិចត្រូនិក និងវិសាលគមន៍នៃការទទួលខុសត្រូវ។

*គោលនយោបាយសារពើពន្ធនិងការលើកទឹកចិត្ត* : ទទឹមនឹងភាពចាំបាច់ក្នុងការមិនយកពន្ធ ដើម្បីលើកទឹកចិត្តឱ្យមានកំណើននៅក្នុងដំណាក់កាលដំបូងនៃជំនួញ គោលដៅរយៈពេលវែងគួរតែនាំយកអ្នកផ្តល់លទ្ធកម្មទៅក្នុងបណ្តាញពន្ធដើម្បីឱ្យផ្នែកនៃប្រាក់ចំណេញរបស់អ្នកទាំងនោះ ត្រូវបានវិនិយោគនៅក្នុងសង្គម។

## ការចរចាតាមរយៈ GATS

យុទ្ធសាស្ត្រក្នុងស្រុកត្រូវតែបំពេញបន្ថែមចំពោះវិធានការអន្តរជាតិ។ ការកើនឡើងថ្មីៗនេះជំទាស់នឹងការធ្វើលទ្ធកម្មសកលនៅក្នុងទីផ្សារសំខាន់ៗ ដូចជា ស.រ.អា និងសហភាពអឺរ៉ុប ធ្វើឱ្យប្រការនេះកាន់តែសំខាន់ឡើង ដើម្បីដោះស្រាយបញ្ហានេះតាមរយៈកិច្ចព្រមព្រៀង និងការចរចាពហុភាគីប្រចាំតំបន់និងទ្វេភាគី។ ឥឡូវនេះទីផ្សារសម្រាប់គ្រឿងអេឡិចត្រូនិកច្រើនតែមិនប្រឈមដោយចំហនឹងរបាំងពាណិជ្ជកម្មឡើយហើយសមាជិក WTO បានឯកភាពព្យួរជាបណ្តោះអាសន្ននូវពន្ធគយនិងអាករលើជំនួញគ្រឿងអេឡិចត្រូនិក។ ឥឡូវនេះ ការប្តេជ្ញាទាំងនេះត្រូវតែដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀង ដើម្បីលើកលែងការដាក់របាំងថ្មីចំពោះជំនួញអេឡិចត្រូនិក។

កាលានុវត្តភាពសំខាន់ខ្លះៗសម្រាប់វិធានការពហុភាគីទៅលើការធ្វើលទ្ធកម្មពីក្រៅគួរតែធ្វើឡើងតាមរយៈការចរចាអំពីកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម (GATS)។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងផ្នែកនានា ដូចជា

*កាលានុវត្តភាពសំខាន់ខ្លះៗសម្រាប់វិធានការពហុភាគី ទៅលើការធ្វើលទ្ធកម្មពីក្រៅគួរតែ ធ្វើឡើងតាមរយៈការចរចាអំពីកិច្ចព្រមព្រៀងទូទៅ ស្តីពីពាណិជ្ជកម្មលើសេវាកម្ម (GATS)*

**ប្រអប់ ៥.១២**

**ការបង្កើតឧត្តមភាពសម្រាប់ការធ្វើលទ្ធកម្មនៅម៉ាឡេស៊ី**

ថ្លៃពលកម្មនៅម៉ាឡេស៊ីមានកម្រិតខ្ពស់យ៉ាងខ្លាំងធៀបនឹងចិននិងឥណ្ឌា។ ទោះជាយ៉ាងនេះក៏ដោយ ហេដ្ឋារចនាសម្ព័ន្ធដែលបានអភិវឌ្ឍបានល្អ និងការគាំទ្ររបស់រដ្ឋាភិបាល បានធ្វើឱ្យប្រទេសនេះក្លាយជាគោលដៅប្រកបដោយភាពទាក់ទាញសម្រាប់លទ្ធកម្ម។ ជាផ្នែកមួយនៃគម្រោងច្រកប្រព័ន្ធអ៊ិនធឺណិត (Multi-media Super Corridor) របស់ខ្លួន រដ្ឋាភិបាលបានវិនិយោគប្រមាណ ១០.០០០លានដុល្លារ ដើម្បីតម្លើងទីក្រុង IT ចំនួនពីរគឺ សាយប៊ឺចាយ៉ា និង ពុត្រាចាយ៉ា ប្រកបដោយបច្ចេកវិទ្យាខ្ពស់បណ្តាញសរសៃអុបទិក ផ្លូវថ្នល់ថ្មី និងច្បាប់ ដើម្បីលើកកម្ពស់ការធ្វើជំនួញពីចម្ងាយ។

ម៉ាឡេស៊ីក៏ក្លាយជាមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវ និងសេវាគ្លីនិកនៅក្នុងជីវៈបច្ចេកវិទ្យាផងដែរ។ ផ្អែកលើសមត្ថភាពក្នុងមូលដ្ឋានលើភាសាជាច្រើននៅអាស៊ី ដូចជា ចិនជីគោក ចិនកាតាំង ចិនហុកកៀន បាហាសាម៉ាឡេ បាហាសាឥណ្ឌូណេស៊ី តាមីល ហិណ្ឌីថៃ និងជប៉ុន រដ្ឋាភិបាលកំពុងជម្រុញឱ្យប្រទេសនេះមាននាទីជាមជ្ឈមណ្ឌលទាក់ទងចុងខាងលើសម្រាប់សេវាអតិថិជននៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងមជ្ឈមណ្ឌលអាស៊ីទាំងមូល។ ការធ្វើលទ្ធកម្មត្រូវបានរំពឹងថាផ្តល់ការងារចំនួន ៥០.០០០ ដល់មនុស្សនៅក្នុងទីក្រុង នៅឆ្នាំ ២០១១។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសនេះប្រឈមនឹងកង្វះកម្មករជំនាញ IT និងបច្ចុប្បន្ននេះកំពុងនាំចូលកម្មករ ជំនាញពីប្រទេសឥណ្ឌា និងចិន។

ការចែកចាយ ការផ្សព្វផ្សាយ ស្ថាបត្យកម្ម ការងារ ច្បាប់ គណនេយ្យ កុំព្យូទ័រ និងសេវាពាក់ព័ន្ធតិចជាងពាក់កណ្តាលនៃការប្តេជ្ញានៅក្នុងមាត្រាពាក់ព័ន្ធនៃ GATS ត្រូវបានចែងពេញលេញ ឬមិនមានការដាក់កំហិត។ ជាសំខាន់នេះគឺដោយសារកង្វះខាតការប្តេជ្ញាពីសំណាក់ប្រទេសកំពុងអភិវឌ្ឍន៍។ សេរីភាវូបនីយកម្មបែបនេះគួរតែលើកឡើងតាមរយៈ"បញ្ជីវិជ្ជមាន"មួយ ដើម្បីអនុញ្ញាតឱ្យប្រទេសនានាបង្កើនល្បឿននៃកម្រិតនិងទំហំខាងសេរីភាវូបនីយកម្មអនុលោមតាមតម្រូវការរបស់ប្រទេសទាំងនោះ និង សមត្ថភាពក្នុងការរៀបចំការគាំទ្របទប្បញ្ញត្តិក្នុងស្រុក។

ប្រទេសនានាក៏អាចបន្តទទួលផលពីការធ្វើលទ្ធកម្មពីខាងក្រៅ តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងវិនិយោគប្រចាំតំបន់ និងទ្វេភាគី ដែលអាចរៀបចំជាមូលដ្ឋានគ្រឹះសម្រាប់ក្របខ័ណ្ឌច្បាប់ដែលអាចពង្រីកឱ្យដល់កម្រិតពហុភាគីផងដែរ។

## ភាពជាដៃគូ

រដ្ឋាភិបាលក៏គួរតែអាចពឹងផ្អែកផងដែរទៅលើការគាំទ្រពីអង្គការជំនួយទ្វេភាគី អង្គការជាសមាជិកអង្គការសហប្រជាជាតិ (UN) និង ធនាគារពិភពលោក ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធ ចាត់ចែង ការបណ្តុះបណ្តាល និងផ្តល់ការណែនាំខាងគោលនយោបាយ។ ពួកគេក៏អាចជួយកែលំអស្ថិតិអំពីការធ្វើលទ្ធកម្មនៅក្រៅប្រទេសផងដែរ។

លើសពីនេះ សហគ្រាសឯកជន សមាគមន៍ជាតិ អន្តរជាតិ និងឧស្សាហកម្មរបស់ខ្លួន អាចជួយនៅក្នុងកិច្ចប្រឹងប្រែង ដើម្បីរំដោះទីផ្សារ និងប្រឆាំងនឹងការគំរាមកំហែងពីអ្នកការពារនិយម។ ឧទាហរណ៍ នៅឥណ្ឌា សមាគមន៍ជាតិនៃក្រុមហ៊ុនសេវាកម្មវិធីកុំព្យូទ័រ (NASSCOM) បានជួយគូសបញ្ជាក់អំពីផលប្រយោជន៍ទៅវិញទៅមកពីការធ្វើលទ្ធកម្មនៅខាងក្រៅ និងបដិសេធការយល់ច្រឡំ។ ក្រុមហ៊ុនក្នុងស្រុកដែលចូលរួមនៅក្នុងលទ្ធកម្មខាងក្រៅ ក៏អាចចង់បង្កើតឱ្យមានវត្តមានរបស់ខ្លួននៅក្នុងទីផ្សារនាំចេញរបស់ខ្លួនផងដែរ ដើម្បីខ្លួនអាចបញ្ចុះបញ្ចូលដោយមានប្រសិទ្ធិភាពជាងមុនជាមួយរដ្ឋាភិបាល និងផ្នែកឧស្សាហកម្ម។

## ការបែងចែកការងារអន្តរជាតិថ្មីមួយ

ការធ្វើលទ្ធកម្មសកលតំណាងឱ្យការបែងចែកការងារអន្តរជាតិថ្មីមួយ។ នៅពេលដែលផលិតកម្មកម្មន្តសាលត្រូវបានបែកចេញទៅតាមប្រទេសនានា ដោយផ្អែកលើឧត្តមភាពនៃភាពប្រកួតប្រជែងលើការធ្វើលទ្ធកម្ម ប្រទេសនានានឹងផ្តល់សេវា ដែលរួមគ្នាបង្កើតជាសេវាពិភពលោកទាំងមូល។

សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន នេះអាចជាប្រភពដ៏មានតម្លៃសម្រាប់កំណើននិងសេដ្ឋកិច្ច ព្រមទាំងការអភិវឌ្ឍមនុស្ស ដែលបង្កើតការងារ ប្រាក់ចំណូល និងផ្តល់អំណាចដល់ផ្នែកជាច្រើននៅក្នុងសង្គម ព្រមទាំងលើកកម្ពស់កំណើនជាមួយសមធម៌។ វាក៏អាចផ្ទេរជំនាញថ្មី បច្ចេកវិទ្យា និងដំណើរការនានាផងដែរ។

ទោះជាយ៉ាងណាក្តី ការទទួលស្គាល់អំពីសក្តានុពលនៃលទ្ធកម្មពីក្រៅទាមទារឱ្យរដ្ឋាភិបាលធ្វើការសម្រេច និងចាត់វិធានការដែលផ្តោតចំគោលដៅ ដើម្បីចែកចាយផលប្រយោជន៍ឱ្យបានទូលំទូលាយ និងធានាថាខ្លួនអាចសម្រួលឱ្យមានកំណើនលើវិស័យជាច្រើនដោយរួមបញ្ចូលសកម្មភាពលទ្ធកម្មជាមួយផ្នែកនានាផ្សេងទៀតនៃសេដ្ឋកិច្ច។ ដើម្បីសម្រេចប្រការនេះ រដ្ឋាភិបាលត្រូវធ្វើការវិនិយោគលើមូលធនរូបវន្ត និងមូលធនសង្គម ហើយព្យាយាមធានាថាសហគ្រាសនានាធ្វើដំណើរឈានឡើងជាបន្តបន្ទាប់ទៅតាមចង្វាក់នៃតម្លៃ។ ជារួម មិនត្រូវចាត់ទុកថាលទ្ធកម្មសកលជាគ្រឿងយន្តតែមួយគត់សម្រាប់កំណើន

នោះទេ ប៉ុន្តែថាជាមាគ៌ាមួយផ្សេងទៀតដែលមានសក្តានុពលសម្រាប់លើកកម្ពស់សេដ្ឋកិច្ច និងការអភិវឌ្ឍមនុស្ស។

## ទេសចរណ៍អន្តរជាតិ

បន្ទាប់ពីប្រេងរំអិល និងប្រេងកាត ឧស្សាហកម្មធំជាងគេលើពិភពលោកគឺការធ្វើដំណើរ និងទេសចរណ៍។ នៅឆ្នាំ ២០០៥ ទូទាំងពិភពលោកអាចរំពឹងថា វិស័យនេះរកចំណូលបាន ៦.៤លានលានដុល្លារ នៃសកម្មភាពសេដ្ឋកិច្ចដែលសមាមាត្រទៅនឹង ៣.៨% នៃ GDP សរុប។ ប៉ុន្តែ ប្រសិនបើគិតផងដែរអំពីផ្នែកផ្សេងទៀតនៃសេដ្ឋកិច្ចដែលពឹងផ្អែកលើទេសចរណ៍ ពោលគឺ "សេដ្ឋកិច្ចនៃការធ្វើដំណើរ និងទេសចរណ៍" សមាមាត្រនេះកើនឡើងដល់ ១០.៦%។ វិស័យនេះជួលមនុស្សដោយផ្ទាល់ចំនួន ៧៤លាននាក់ ដែលត្រូវជា ២.៨% នៃចំនួនការងារសរុបនៅលើពិភពលោក។ លើសពីនេះ វិស័យនេះក៏ជួលមនុស្សចំនួន ២២២លាននាក់ ដោយប្រយោលផងដែរដែលត្រូវជា ៨.៣% នៃចំនួនការងារសរុប។

យោងតាមអង្គការទេសចរណ៍សហប្រជាជាតិ ទេសចរម្នាក់គឺជាមនុស្សដែលស្នាក់នៅក្រៅបរិស្ថានធម្មតារបស់ខ្លួនសម្រាប់រយៈពេលមិនលើសពីមួយឆ្នាំជាប់គ្នារហូត ដើម្បីការសម្រាកកាយ ធ្វើជំនួញ ឬគោលបំណងដទៃទៀត។ មនុស្សខ្លះក្នុងចំណោមអ្នកទាំងនេះអាចមិនធ្វើដំណើរឆ្ងាយនោះទេ តែអ្នកផ្សេងទៀតអាចធ្វើដំណើរពាក់កណ្តាលជុំពិភពលោក។ ដោយសាររបាយការណ៍នេះនិយាយពីពាណិជ្ជកម្មអន្តរជាតិ ដូច្នេះ វាមានចំណាប់អារម្មណ៍ ជាពិសេសតែជាមួយទេសចរណ៍ឆ្លងកាត់ព្រំដែនតែប៉ុណ្ណោះ ទោះបីចំណុចជាច្រើនមានភាពស្របគ្នានឹងទេសចរណ៍ក្នុងស្រុកផងដែរក៏ដោយ ដែលច្រើនតែអាចរួមចំណែកយ៉ាងច្រើនចំពោះការអភិវឌ្ឍមនុស្សផងដែរ (ប្រអប់ ៥.១៣)។

នៅឆ្នាំ ២០០៤ មានអ្នកទេសចរអន្តរជាតិ ៧៦៣ លាននាក់ ដែលបានចំណាយប្រមាណ ៦២៣.០០០លានដុល្លារ។ ប៉ុន្តែ នៅឆ្នាំ ២០២០ WTO ព្យាករណ៍ថាចំនួនអ្នកទេសចរនឹងកើនដល់ ១.៦០០ លាននាក់ ដែលនឹងចំណាយសរុបចំនួន ២ លានលានដុល្លារ/ឆ្នាំ។[១៨] ក្នុងចំណោមចំនួនទេសចរទាំងអស់នៅទូទាំងពិភពលោកនៅឆ្នាំ ២០២០ ចំនួន ១.២០០លាននាក់ គឺជាអ្នកធ្វើដំណើរនៅក្នុងតំបន់ និង ៤០០លាននាក់ គឺជាជាអ្នកធ្វើដំណើរដែលសម្រាកកាយរយៈពេលយូរ។

មនុស្សជាច្រើនក្នុងចំណោមអ្នកទាំងនេះនឹងធ្វើដំណើរមកអាស៊ី-ប៉ាស៊ីហ្វិក។ នៅទសវត្សរ៍ឆ្នាំ ១៩៥០ តំបន់នេះរួមចំណែកតិចជាង ១០% នៃចំនួនទេសចរនៅលើពិភពលោកទាំងមូល ប៉ុន្តែនៅទសវត្សរ៍ឆ្នាំ ១៩៧០ វិភាគទានពីតំបន់នេះបានកើនឡើងដល់ ២០% និងនៅឆ្នាំ ២០០៤ ដល់ ៤០%។

ដូចនៅតំបន់ផ្សេងទៀតក្នុងពិភពលោកផងដែរ

*បន្ទាប់ពីប្រេងរំអិល និងប្រេងកាត ឧស្សាហកម្មធំជាងគេលើពិភពលោកគឺ ការធ្វើដំណើរ និង ទេសចរណ៍*

ប្រអប់ ៥.១៣

### សារៈសំខាន់នៃទេសចរណ៍ក្នុងស្រុក

ទន្ទឹមនឹងការថយចុះនៅពេលថ្មីៗនេះនៃការឈប់ធ្វើដំណើរនៅក្រោយថ្ងៃទី ០៩ ខែកញ្ញា ជម្ងឺសារស៍ សង្គ្រាមនៅអ៊ីរ៉ាក់ និងស៊ូណាមី គោលដៅជាច្រើន ពិសេសក្នុងទីក្រុងធំៗ បានពឹងផ្អែកកាន់តែខ្លាំងឡើងលើទីផ្សារក្នុងស្រុក។ ប្រការនេះមានអត្ថប្រយោជន៍យ៉ាងច្រើនប្រសើរជាងទេសចរណ៍អន្តរជាតិ ព្រោះថា ភ្ញៀវក្នុងស្រុកទំនងជាផ្តល់ការគាំទ្រច្រើនជាងដល់សហគ្រាសតូចៗនៅមូលដ្ឋានជួយធ្វើឱ្យមានភាពស្មើគ្នា នៅគ្រប់រដូវ និងជួយរក្សាទុករូបិយប័ណ្ណបរទេស។

ចិនមានទីផ្សារទេសចរក្នុងស្រុកធំជាងគេនៅលើពិភពលោក។ នៅឆ្នាំ ២០០៤ ចំនួនទេសចរក្នុងស្រុក មានដល់ ១.១០០លាននាក់ ហើយប្រាក់ចំណូលពីទេសចរក្នុងស្រុកមាន ៥៧.០០០លាន ដែលត្រូវជា ៦៧% នៃចំណូលដុលពីទេសចរប្រទេសចិន។

ឥណ្ឌាក៏មានទីផ្សារក្នុងស្រុកធំផងដែរ។ ការប៉ាន់ប្រមាណដែលគ្មានការអះអាងបានបង្ហាញថា មានទេសចរក្នុងស្រុកចំនួន ៣៥០លាននាក់ក្នុងនោះប្រហែលមួយភាគបួនជាអ្នកធម្មយាត្រា។ ទោះបីអ្នកទេសចរជាតិចំណាយតិចជាងទេសចរអន្តរជាតិក្តី ពួកគេមានចំនួនច្រើន និងច្រើនតែស្នាក់នៅរយៈពេលវែងជាង ដូច្នេះពួកគេជួយបង្កើតការងារច្រើនជាង (Aibara and Gopalani ២០០៥)។

តារាង ៥.១

## ចំនួនទេសចរមកទស្សនាប្រទេសនានានៅអាស៊ី-ប៉ាស៊ីហ្វិក ឆ្នាំ ២០០៥

| ប្រទេស | ចំនួនប្រជាជន (លាននាក់) | ចំនួនទេសចរ (លាននាក់) | កំណើន (%) | ចំណូលពីទេសចរណ៍ (%នៃGDP) | ប្រទេស | ចំនួនប្រជាជន (លាននាក់) | ចំនួនទេសចរ (លាននាក់) | កំណើន (%) | ចំណូលពីទេសចរណ៍ (%នៃGDP) |
|---|---|---|---|---|---|---|---|---|---|
| *អាស៊ីបូព៌ា* | | | | | អ៊ីរ៉ង់ | ៦៥.៥ | ១.៩ | ៧.១ | ៣.៦ |
| ម៉ុងហ្គោលី | ២.៤ | ០.២ | | ... | ម៉ាល់ឌីវ | ០.៣ | ០.៥ | ៤.១ | ៣២.៣ |
| ចិន | ១.២៨០.៤ | ៤២.៥ | ៧.៥ | ២.៤ | បង់ក្លាដែស | ១៣៥.៧ | ០.២ | ៤.៧ | |
| សាធារណរដ្ឋកូរ៉េ | ៤៧.៦ | ៦.០ | ៥.០ | ១.៦ | ឥណ្ឌា | ១.០៤៨.៦ | ២.៥ | ០.៤ | ២.១ |
| សាធា.ប្រជា.កូរ៉េ | ២២.៥ | | ៤.៧ | ... | នេប៉ាល់ | ២៤.១ | ០.២ | -១៩.៧ | ៤.៤ |
| *អាស៊ីអាគ្នេយ៍* | | | | | ស្រីលង្កា | ១៩.០ | ០.៣ | -៣.៣ | ៣.៨ |
| ឡាវ | ៥.៥ | ០.២ | -២.៩ | ៥.៥ | ប៉ាគីស្ថាន | ១៤៤.៩ | ០.៦ | ៣.៨ | ២.៦ |
| កម្ពុជា | ១២.៥ | ១.០ | | ៧.៣ | ប៊ូតាណ | ០.៩ | ០.០ | -១.៦ | |
| ហ្វីលីពីន | ៧៩.៩ | ១.៧ | -៤.៦ | ២.៧ | *ប៉ាស៊ីហ្វិក* | | | | |
| វៀតណាម | ៨០.៤ | ២.១ | ៩.៣ | ២.២ | វ៉ាណាទូ | ០.២ | ០.០៥១ | -០.៨ | ១៧.២ |
| ឥណ្ឌូណេស៊ី | ២១១.៧ | ៥.៤ | ២.៤ | ៣.១ | គីរីបាទី | ០.១ | ០.០០៤ | -៤.៣ | ៩.៧ |
| ថៃ | ៦១.៦ | ១២.៤ | ៦.៥ | ៥.២ | ហ្វីជី | ០.៨ | ០.៣៦១ | -០.២ | ១២.០ |
| ម៉ាឡេស៊ី | ២៤.៣ | ១៨.១ | ១២.៧ | ៥.៣ | ប៉ាពួញូហ្គីនេ | ៥.៤ | ០.០៤៣ | -៨.៩ | ៥.៨ |
| សឹង្ហបុរី | ៤.២ | ៧៨ | ៤.៣ | ២.៦ | កោះម៉ាហ្សាល់ | ០.១ | ០.០០៥ | ... | |
| ប្រ៊ុយណេ | ០.៤ | ១.០ | ១.០ | ៣.៣ | សាម៉ាវ | ០.២ | ០.០៩៦ | | ២.៧ |
| ភូមា | ៤៨.៨ | ០.២ | ១.៨ | | មីក្រូណេស៊ី | ០.១ | ០.០២១ | ៥.៥ | |
| *អាស៊ីខាងត្បូង* | | | | | ប៉ាឡាវ | ០.០ | ០.០៥៤ | | -២.០ |
| អាហ្វហ្គានីស្ថាន | ២៨.០ | ... | ... | | កោះសូឡូម៉ុង | ០.៤ | ... | ... | ៣.១ |

**សម្គាល់: ទិន្នន័យចំនួនប្រជាជននៅឆ្នាំ ២០០២។ ចំនួនទេសចរ និងកំណើនចំនួនទេសចរ នៅឆ្នាំ ២០០៤ ធៀបនឹងឆ្នាំមុន។ ចំណូលពីទេសចរណ៍គិតជាភាគរយនៃ GDP គឺផ្អែកលើការប៉ាន់ប្រមាណដោយ WTTC សម្រាប់ឆ្នាំ ២០០៥។**

**ប្រភព: Aibara និង Gopalani ២០០២**

ទេសចរណ៍នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក បានរងការរំខានយ៉ាងខ្លាំង ដោយសារឧបទ្ទវហេតុចំនួនបីលើកគឺ ថ្ងៃ ១១ ខែកញ្ញា ឆ្នាំ ២០០១ ការផ្ទុះឡើងនៃជម្ងឺសារស៍ និងសង្គ្រាមនៅអាហ្វហ្គានីស្ថាន ក៏ដូចជានៅអ៊ីរ៉ាក់ផងដែរ។ ការវាយប្រហារថ្ងៃ ១១ ខែ កញ្ញា បានធ្វើការធ្វើដំណើរបានធ្លាក់ចុះនៅទូទាំងពិភពលោក រហូតដល់ ៣០% នៅក្នុងប្រទេសខ្លះ និងបាត់បង់ការងារចំនួន ៦.៥លាន។ នៅឆ្នាំ ២០០៤ មានការងើបឡើងវិញគួរឱ្យចាប់អារម្មណ៍។ នៅពេលដែលវិស័យទេសចរណ៍បានរីកលូតលាស់នៅគ្រប់តំបន់ទូទាំងពិភពលោក ហើយនៅអាស៊ី-ប៉ាស៊ីហ្វិក កំនើនមាន ២៩% ប៉ុន្តែគោលដៅទេសចរមួយចំនួនត្រូវបានរងការប៉ះទង្គិច នៅពេលក្រោយមក ដោយសាររលកយក្សស៊ូណាមិ នៅខែធ្នូ ឆ្នាំ ២០០៤។

របាយនៃចំនួនភ្ញៀវទាំងនេះមានបង្ហាញជូននៅក្នុងតារាងទី ៥.១។ សារៈសំខាន់នៃទេសចរណ៍ចំពោះប្រទេសណាមួយ មានតាមរូបភាពជាច្រើន។ ចំណុចមួយគឺតាមរយៈចំនួននៃការមកដល់សរុបរបស់ភ្ញៀវ។ ចំនួននេះ ទំនងជាច្រើនសម្រាប់ប្រទេសធំៗ ក្នុងនោះគឺប្រទេសចិន ជាអ្នកនាំមុខបន្ទាប់មកគឺប្រទេសម៉ាឡេស៊ី ថៃ និងសិង្ហបូរីដែលនៅក្នុងទសវត្សរ៍កន្លងទៅប្រទេសទាំងនេះបានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេចរណ៍យ៉ាងច្រើន។

វិធានមួយទៀតគឺត្រូវពិចារណាប្រាក់ចំណូលបានពីទេសចរ គិតជាសមាមាត្រនៃ GDP។ នេះជាការបង្ហាញនូវសញ្ញាអំពីកម្រិតដែលប្រទេសមួយពឹងផ្អែកលើទេសចរណ៍សម្រាប់ជាប្រភពនៃសេដ្ឋកិច្ច។ សម្រាប់ប្រទេសដែលមានតួលេខ GDP ប្រទេសម៉ាល់ឌីវស្ថិតនៅជួរខ្ពស់បំផុតនៃតារាងនេះ ដោយចំណូលពីទេសចរមាន ៣២% នៃ GDP បន្ទាប់មកគឺវ៉ាណាទូ និងហ្វីជី។ ប្រសិនបើមានទិន្នន័យ កោះផ្សេងទៀតនៅប៉ាស៊ីហ្វិកក៏ស្ថិតនៅលំដាប់ខ្ពស់ដែរ។

វិធីទីបីសម្រាប់វាយតម្លៃរបាយនេះគឺ ពិចារណាអំពីចំនួនមកដល់នៃទេសចរក្នុងមួយឯកត្តានៃចំនួនប្រជាជនក្នុងប្រទេស (រូបទី ៥.៣)។ តួលេខនេះក៏បង្ហាញកម្រិតនៃការពឹងផ្អែកលើទេសចរណ៍ផងដែរ ប៉ុន្តែថែមទាំងផ្តល់គំនិតអំពីផលប៉ះពាល់សង្គម។ ក្នុងករណីនេះ ប៉ាឡាវ ជាប្រទេសនាំមុខ បន្ទាប់មកគឺ ម៉ាល់ឌីវ ប៉ុន្តែសូម្បីតែសិង្ហបូរី មានចំនួនទេសចរមកដល់ច្រើនជាងចំនួនប្រជាជនទាំងមូលនៅក្នុងប្រទេសនេះទៅទៀត។

ចុងក្រោយបង្អស់គេអាចពិចារណាអំពីការមកដល់ដោយផ្អែកលើទស្សនៈអំពីភាពក្រីក្រ។ គោលដៅដែលមានប្រជាប្រិយភាពជាងគេទំនងជាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលកម្រិតកណ្តាល និងកម្រិតខ្ពស់។ ទោះជាយ៉ាងណា




រូបទី ៥.៣: ចំនួនទេសចរធៀបនឹងចំនួនប្រជាជន ១០០នាក់ ឆ្នាំ ២០០២

ប្រភព : Aibara and Gopalani 2005.

ក៏ដោយប្រទេសខ្លះដែលមានភាពក្រីក្រកម្រិតខ្ពស់ក៏ពឹងផ្អែកលើទេសចរណ៍ដែរ ដោយមានចំណូលច្រើនជាង ៥% នៃ GDP រួមទាំង កម្ពុជា ឡាវ និង វ៉ាណាទូ។

## ឥទ្ធិពលនៃទេសចរណ៍ទៅលើការអភិវឌ្ឍមនុស្ស

ផ្អែកតាមទស្សនៈនៃការអភិវឌ្ឍមនុស្សឥទ្ធិពលសំខាន់បំផុតនៃទេសចរណ៍គឺការបង្កើតការងារ។ ឧស្សាហកម្មទេសចរណ៍ប្រើប្រាស់ពលករដែលមានជំនាញនៅកម្រិតខុសៗគ្នា ចាប់ពីអ្នកមានសញ្ញាប័ត្រ MBA ដល់អ្នកគ្មានជំនាញដែលផ្លាស់ទីពីជនបទ។ ពួកគេអាចមានជំនាញខុសៗគ្នា ដូចជា អ្នកគ្រប់គ្រងសណ្ឋាគារ គ្រូបង្ហាត់នៅបន្ទប់ហាត់កីឡា អ្នកបើកបរ អ្នកម៉ាស្សា អ្នកតែងសម្អាង ចុងភៅ ហើយអ្នកខ្លះពាក់ព័ន្ធដោយផ្ទាល់ អ្នកខ្លះទៀត ដោយប្រយោលនៅក្នុងវិស័យគាំទ្រ ដូចជា អ្នកលក់រាយ ដឹកជញ្ជូន ឬវត្ថុសិល្បៈ និងវត្ថុសិប្បកម្ម។

ទំហំនៃការងារចាប់ពីទេសចរណ៍អន្តរជាតិដល់ក្នុងស្រុក មានបង្ហាញជូនក្នុងតារាង ៥.២។ តួលេខនេះក៏បង្ហាញពីអត្រាប៉ាន់ស្មាននៃផលធៀបរវាងការងារដោយប្រយោលធៀបនឹងដោយផ្ទាល់ ដែលសម្រាប់តំបន់នេះទាំងមូលមាន ធំជាង ២.១ ប៉ុន្តែតួលេខនេះ ប្រែប្រួលទៅតាមតួលេខខ្ពស់របស់

*ផ្អែកតាមទស្សនៈនៃការអភិវឌ្ឍមនុស្ស ឥទ្ធិពលសំខាន់បំផុតនៃទេសចរណ៍គឺការបង្កើតការងារ។ អ្នកក្រអាចជាប់ទាក់ទងដោយផ្ទាល់នឹងឧស្សាហកម្មទេសចរណ៍ មិនត្រឹមតែតាមរយៈការងារប៉ុណ្ណោះទេ ប៉ុន្តែ តាមរយៈកាលានុវត្តភាពជំនួញជាច្រើនផងដែរ*

តារាង ៥.២

ចំនួនការងារក្នុងឧស្សាហកម្មទេសចរណ៍

| ប្រទេស | ឆ្នាំ ២០០៤ (គិតជាលាននាក់) | | | | |
|---|---|---|---|---|---|
| | ផ្ទាល់ | ប្រយោល | សរុប | ផ្ទាល់/ប្រយោល | %នៃពលករក្នុងទេសចរណ៍ |
| *អាស៊ីបូព៌ា* | | | | | |
| ចិន | ១៤.៨ | ៤៧.៥ | ៦២.៣ | ៣.២ | ៨.៣ |
| សាធារណរដ្ឋកូរ៉េ | ០.៥ | ១.៣ | ១.៩ | ២.៦ | ៨.៤ |
| *អាស៊ីអាគ្នេយ៍* | | | | | |
| កម្ពុជា | ០.២ | ០.៤ | ០.៦ | ២.០ | ៨.៣ |
| ឥណ្ឌូណេស៊ី | ៣.២ | ៥.៣ | ៨.៥ | ១.៧ | ៨.៥ |
| ឡាវ | ០.១ | ០.១ | ០.២ | ១.០ | ៧.៣ |
| ម៉ាឡេស៊ី | ០.៥ | ០.៨ | ១.៣ | ១.៦ | ១២.៧ |
| ហ្វីលីពីន | .. | .. | ២.៨ | .. | ៩.៦ |
| សិង្ហបុរី | .. | .. | ០.១ | .. | ៦.០ |
| ថៃ | ១.៥ | ១.៦ | ៣.១ | ១.១ | ៨.៩ |
| វៀតណាម | ០.៦ | ១.៨ | ២.៤ | ៣.០ | ៦.៥ |
| *អាស៊ីខាងត្បូង* | | | | | |
| បង់ក្លាដែស | ០.៩ | ១.៤ | ២.២ | ១.៦ | ៣.០ |
| ឥណ្ឌា | ១១.៤ | ១៣.១ | ២៤.៥ | ១.១ | ៥.៦ |
| ម៉ាល់ឌីវ | ០.០ | ០.០ | ០.១ | .. | ៦៤.៤ |
| នេប៉ាល់ | ០.៣ | ០.៤ | ០.៧ | ១.៣ | ៧.០ |
| ប៉ាគីស្ថាន | ១.០ | ១.២ | ២.២ | ១.២ | ៤.១ |
| ស្រីលង្កា | ០.៣ | ០.៤ | ០.៧ | ១.៣ | ៨.៨ |
| *ប៉ាស៊ីហ្វិក* | | | | | |
| ហ្វីជី | ០.០ | ០.១ | ០.១ | .. | ២៥.៤ |
| គីរីបាទី | .. | .. | .. | .. | ២២.៦ |
| ប៉ាពួញូហ្គីនេ | ០.១ | ០.២ | ០.៣ | ២.០ | ១១.២ |
| កោះសូឡូម៉ុង | ០.០ | ០.០ | ០.០ | .. | ៨.៣ |
| តុងហ្គា | ០.០ | ០.០ | ០.០ | .. | ១២.៣ |
| វ៉ាណាទូ | ០.០ | ០.០ | ០.០ | .. | ៤៧.០ |
| សរុប | ៣៩.៩ | ៧៦.៤ | ១១៥.៣ | ២.១ | ៦.៩ |

**សម្គាល់: ជួរឈរចុងក្រោយបង្ហាញផលធៀបនៃការងារដោយប្រយោល និងការងារដោយផ្ទាល់។**

**ប្រភព: Adhikari និង Yamamoto ២០០៦**

ប្រទេសចិន។ ទិដ្ឋភាពមួយផ្សេងទៀតនៃការងារ មានគូសបញ្ជាក់នៅក្នុងតារាងនេះដែរ ពោលគឺតើចំនួនកម្លាំងពលករសរុបដែលធ្វើការនៅក្នុងវិស័យទេសចរណ៍ មានសមាមាត្រកម្រិតណាដែរ។ ឧទាហរណ៍ នៅម៉ាល់ឌីវ តួលេខនេះខ្ពស់ណាស់ប្រមាណពីរភាគបី។ សម្រាប់តំបន់នេះទាំងមូល តួលេខនេះមានជិត ៧%។ ឥឡូវនេះ ប្រទេសជាច្រើននៅក្នុងតំបន់នេះ កំពុងផ្តោតលើទេសចរណ៍ក្នុងស្រុក ដែលកំពុងបង្ហាញពីការលូតលាស់យ៉ាងឆាប់រហ័ស (ប្រអប់ ៥.១៣)។

ធៀបនឹងវិស័យទំនើបផ្សេងទៀត សមាមាត្រខ្ពស់ជាងនៃផលចំណេញនៅក្នុងឧស្សាហកម្មធ្វើដំណើរ និងទេសចរណ៍បានទៅស្ត្រី អាចតាមរយៈពាណិជ្ជកម្មផ្លូវការឬជំនួញតូចតាច ឬការងារក្រៅផ្លូវការ។ យោងតាម ILO ស្ត្រីមាន ៧០% នៃកម្លាំងពលករសរុបក្នុងវិស័យទេសចរណ៍ ប៉ុន្តែភាគរយនេះប្រែប្រួលយ៉ាងខ្លាំងអាស្រ័យទៅតាមប្រទេស ហើយនៅក្នុងប្រទេសកាន់សាសនាមូស្លីម អាចមានតិចជាង ១០%។

ឧស្សាហកម្មទេសចរណ៍ និងសេវាពាក់ព័ន្ធក៏មានតម្លៃផងដែរ ដោយសារប្រើប្រាស់ពលករច្រើន។ សម្រាប់អ្នកទេសចរម្នាក់ ត្រូវមានអ្នករៀបចំពូកអាហារ និងជូតឥដ្ឋ។ ឧទាហរណ៍នៅឥណ្ឌា មានការគណនាថា ការវិនិយោគមួយដោយតម្លៃ ២៣.០០០ដុល្លារ នឹងបង្កើតការងារចំនួន ៨៩ នៅក្នុងឧស្សាហកម្មសណ្ឋាគារ និងភោជនីយដ្ឋាន ធៀបនឹង ៤៥ នៅក្នុងកសិកម្ម និងត្រឹមតែ ១៣ ក្នុងកម្មន្តសាល។[១៧]

ចំនួនជាច្រើននៃការងារនេះផ្តល់ប្រាក់កម្រៃទាប និងប្រែប្រួលទៅតាមរដូវ ប៉ុន្តែវាផ្តល់ឱ្យកម្មករដែលមានជំនាញតិចតួចនូវកាលានុវត្តភាពក្នុងការឈានទៅរកប្រាក់ចំណូលកាន់តែច្រើនឡើង។ អ្នកក្រីក្រជាច្រើន ដែលបាត់បង់ការងារក្នុងផ្នែកកសិកម្ម ដោយសារទីផ្សារអាហារដែលប្រកបដោយសេរីភាវូបនីយកម្ម និងភាពប្រកួតប្រជែង ត្រូវបានផ្ទេរទៅ

ឧស្សាហកម្មទេសចរណ៍ ឬធ្វើការជាអចិន្ត្រៃយ៍ ឬក្រៅម៉ោង ឬជាកម្មករក្រៅផ្លូវការ នៅរដូវមានភ្ញៀវច្រើន។

អ្នកក្រអាចជាប់ទាក់ទងដោយផ្ទាល់នឹងឧស្សាហកម្មទេសចរណ៍ មិនត្រឹមតែតាមរយៈការងារប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈកាលានុវត្តភាពជំនួញជាច្រើនផងដែរជាពិសេសនៅក្នុងវិស័យក្រៅផ្លូវការ ដែលមានសហគ្រាសទេសចរណ៍ធុនតូចដែលគ្រប់គ្រងដោយមនុស្សនៅក្នុងស្រុក។ អត្ថប្រយោជន៍ទាំងនេះអាចរាយប៉ាយទៅតាមតំបន់ភូមិសាស្ត្រផងដែរ។ ទោះបីទេសចរជាចំនួនច្រើនអាចប្រមូលផ្តុំនៅតាមរម្មណីយដ្ឋានឆ្នេរសមុទ្រ ទីក្រុង ឬទីតាំងល្បីល្បាញក្តី ក៏មានកាលានុវត្តភាពដើម្បីបង្កើតការងារទាក់ទងនឹងទេសចរណ៍នៅទីកន្លែងដាច់ស្រយាលផងដែរ ដែលមានជម្រើសផ្សេងទៀត។

បន្ថែមលើការរួមចំណែកចំពោះការកាត់បន្ថយភាពក្រីក្រ តាមរយៈការងារទេសចរណ៍ក៏ជួយបង្កើនប្រាក់ចំណូលរបស់រដ្ឋាភិបាលផងដែរ តាមរយៈពន្ធ។ ចំណូលនេះអាចរកបានដោយផ្ទាល់ តាមរយៈពន្ធលើទេសចរណ៍ដែលបានបង់ប្រាក់ទៅឱ្យអាជ្ញាធរមូលដ្ឋានឬទៅឱ្យអាជ្ញាធរជាតិ ឬតាមរយៈពន្ធលើប្រាក់ចំណេញពីជំនួញទាក់ទងនឹងទេសចរណ៍។ បន្ទាប់មកចំណូលទាំងនេះអាចយកទៅវិនិយោគក្នុងសេវាសាធារណៈ។ ដោយប្រយោលជាងនេះ តាមរយៈការពង្រឹងចំណូលរូបិយប័ណ្ណបរទេស ទេសចរណ៍ជួយទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។

ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ផងដែរថាភាគច្រើននៃចំណូលពីទេសចរណ៍បានចេញទៅក្រៅប្រទេសតាមរយៈការចំណាយទៅឱ្យម្ចាស់សណ្ឋាគារជាជនបរទេស ការនាំចូលទំនិញសម្រាប់ឧស្សាហកម្មទេសចរណ៍ ឬចំណូលដែលបានទៅក្រុមហ៊ុនដឹកជញ្ជូនតាមយន្តហោះបរទេស។ នៅក្នុងរដ្ឋនៃកោះតូចៗ "ការលេចធ្លាយ"ទាំងនេះ អាចមានបរិមាណច្រើន ទោះបីវាអាចមិនមានចំនួនច្រើនជាងវិស័យផ្សេងទៀត ដូចជាឧស្សាហកម្មក៏ដោយ។

ចំពោះការរួមចំណែកដើម្បីកាត់បន្ថយភាពក្រីក្រទេសចរណ៍អាចត្រូវបានចាត់ទុកជាបីផ្នែក ៖ ការធ្វើដំណើរដើម្បីធុរៈកិច្ច ការធ្វើដំណើរលំហែកាយ និងអេកូទេសចរណ៍ដែលផ្អែកលើធម្មជាតិ។

*ការធ្វើដំណើរដើម្បីធុរៈកិច្ច* ៖ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក អ្នកធ្វើដំណើរដើម្បីមុខការច្រើនតែធ្វើដំណើរទៅទីក្រុងធំៗ ដូចជា បាងកក ហុងកុង ម៉ុមបៃ សៀងហៃ និងសិង្ហបុរី។ ដូចជា អ្នកធ្វើដំណើរដទៃទៀតដែរ នៅទីនេះពួកគេបានបង្កើតឱ្យមានតម្រូវការសេវា ប៉ុន្តែវិសាលភាពដែលការផ្តល់សេវាទាំងនេះ ដោយអ្នកក្រមានភាពខុសគ្នាពីទីក្រុងមួយទៅទីក្រុងមួយផ្សេងទៀត ឧទាហរណ៍ មានចំនួនច្រើននៅទីក្រុងម៉ុមបៃ និង សៀងហៃ ដែលមានប្រជាជនក្រីក្រជាច្រើនលាននាក់រស់នៅក្នុងសង្កាត់ក្រីក្រជាងនៅក្នុងទីក្រុងសិង្ហបុរី ដែលមានធនធានស្តុកស្តម្ភ។ លើសពីនេះ អ្នកធ្វើដំណើរដើម្បីធុរៈកិច្ចទាំងនេះ អាចជួយប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រដោយសារពួកគេបង្កើនការងាររបស់ខ្លួន។ ប្រការនេះអាចកើតមានឡើងនៅក្នុងកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលវែង ដែលប្រសិនបើមានការចែកចាយប្រកបដោយសមធម៌នឹងពង្រីកកាលានុវត្តភាពសម្រាប់ទាំងអស់គ្នា។

*អ្នកធ្វើដំណើរលំហែកាយ*៖ ដូចជាអ្នកធ្វើដំណើរដើម្បីធុរៈកិច្ចដែរ ឥទ្ធិពលពីអ្នកធ្វើដំណើរដើម្បីលំហែកាយអាស្រ័យទៅនឹងជម្រើសជាគោលដៅ។ ទោះជាយ៉ាងណាក៏ដោយ ប្រការសំខាន់គឺរបៀបដែលពួកគេមានអន្តរកម្មជាមួយបរិស្ថានក្នុងមូលដ្ឋាន។ មនុស្សជាច្រើនធ្វើដំណើរកំសាន្តជាក្រុមជាពិសេស អ្នកដែលធ្វើដំណើរទៅទស្សនាតាមកន្លែងអភិវឌ្ឍន៍តូចៗ ឬទី

លំហែកាយទាំងមូល ឬជាអ្នកធ្វើដំណើរតាមនាវាទេសចរណ៍ អាចជួបជាមួយមនុស្សមួយចំនួនតូចនៅក្នុងមូលដ្ឋាន។ ពួកគេប្រាកដជាជួបជាមួយអ្នកបម្រើ ឬអ្នកទទួលភ្ញៀវ ឬមនុស្សផ្សេងទៀត ដែលបម្រើការជាផ្លូវការនៅក្នុងឧស្សាហកម្មទេសចរណ៍ ប៉ុន្តែពួកគេនឹងបង្កើតការងារតិចតួចជាងសម្រាប់មុខជំនួញក្រៅផ្លូវការ។ ម៉្យាងវិញទៀត អ្នកទេសចរសាក់កាដូទោះបីពួកគេចំណាយតិចតួចលើការធ្វើដំណើរទាំងមូលក្តី ប៉ុន្តែអាចបានចំណាយច្រើនលើទំនិញនិងសេវានៅក្នុងមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ សូម្បីតែប្រាក់ចំណូលពីទេសចរណ៍ថ្នាក់លើ ក៏អាចជួយប្រយុទ្ធប្រឆាំងភាពក្រីក្រដែរ ប្រសិនបើប្រាក់ចំណូលត្រូវបានចែកចាយតាមរយៈការចំណាយរបស់រដ្ឋាភិបាល។ ប្រទេសមួយចំនួននៅអាស៊ី ដូចជាប៊ូតាណ និងម៉ាល់ឌីវ បានអនុវត្តវិធីចំនួនទេសចរតិច តែផ្តល់ផលច្រើន (ប្រអប់ ៥.១៤)។

*ទេសចរណ៍ធម្មជាតិនិងអេកូទេសចរណ៍*: ទេសចរណ៍ដែលមានចំនួនភ្ញៀវច្រើន គឺជាកត្តាទាក់ទាញឱ្យមានភ្ញៀវលំហែកាយ ប៉ុន្តែមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ទៅរកទេសចរណ៍មួយបែបដែលមានចំណាប់អារម្មណ៍ពិសេស និងដែលផ្តល់បទពិសោធ។ អ្នកទេសចរណ៍លំហែកាយកាន់តែច្រើនឡើង ចំណាយពេលដើម្បីស្វែងយល់ពីវប្បធម៌ បេតិកភណ្ឌ និងបរិស្ថានធម្មជាតិនៃទីកន្លែងដែលពួកគេទស្សនា ដែលជាទិន្នាការផ្តល់ផលច្រើនសម្រាប់ទីជនបទ និងតំបន់ដាច់ស្រយាលជាច្រើន។ ប្រភេទទេសចរណ៍ ដែលមានការលូតលាស់លឿនជាងគេប្រកបដោយចំណាប់អារម្មណ៍ពិសេសគឺ អេកូទេសចរណ៍ដែលសំដៅលើការធ្វើដំណើរ ទៅកាន់តំបន់ធម្មជាតិតាមវិធីប្រកបដោយការទទួលខុសត្រូវ ដែលអភិរក្សបរិស្ថាន និងរក្សាសុខុមាលភាពរបស់ ប្រជាពលរដ្ឋមូលដ្ឋាន។ ឧទាហរណ៍ ប៊ូតាណ និងនេប៉ាល់ និងតំបន់ពុំសូវមានការលូតលាស់នៅព្រៃសាននៃប្រទេសឥណ្ឌាគឺជាទីកន្លែងសមស្របសម្រាប់អភិវឌ្ឍដោយផ្អែកលើឧត្តមភាពនៃការប្រកួតប្រជែងនៅទីកន្លែងនេះ។ តាមពិតអាស៊ីទាំងមូលមានទីតាំងបេតិកភណ្ឌព្រះពុទ្ធសាសនាចម្បងៗជាច្រើននៃពិភពលោក។ ទេសចរណ៍ផ្អែកលើធម្មជាតិ ផ្តល់នូវអត្ថប្រយោជន៍ជាច្រើនសម្រាប់ការលុបបំបាត់ភាពក្រីក្រ។ វាកើតឡើងនៅទីកន្លែងដាច់ស្រយាល ដែលប្រជាពលរដ្ឋទំនងជាក្រីក្រ។ វាទាក់ទងនឹងសមាមាត្រខ្ពស់នៃអ្នកធ្វើដំណើរតែឯងដែលអាចចំណាយប្រាក់ច្រើននៅតាមមូលដ្ឋាន។ វារួមចំណែកផងដែរចំពោះការអភិរក្សបេតិកភណ្ឌមូលដ្ឋាន និងជីវៈចម្រុះ។ ប៉ុន្តែ វាក៏នាំមកនូវហានិភ័យផងដែរ។ ទេសចរណ៍ធម្មជាតិមិនសុទ្ធតែផ្តល់ផលប៉ះពាល់តិចតួចនោះទេ ជាពិសេសប្រសិនបើវាកើតឡើងនៅក្នុងទីកន្លែងដែលងាយខូចខាត។ វាក៏អាច

**ប្រអប់ ៥.១៤**

**បង្កើនការធ្វើដំណើរកំសាន្តនៅម៉ាល់ឌីវ**

ប្រទេសម៉ាល់ឌីវបានទទួលជោគជ័យក្នុងការអភិវឌ្ឍឧស្សាហកម្មទេសចរណ៍ដែលផ្តល់ចំណូលច្រើនជាង ៧០% នៃ GDP ទាំងដោយផ្ទាល់និងប្រយោល។ វិស័យនេះផ្តល់ការងារចំនួន ២៥.០០០ ប៉ុន្តែ ៦.៨០០ នៃចំនួននេះកាន់កាប់ដោយជនបរទេស។

នៅចុងទសវត្សរ៍ឆ្នាំ១៩៧០ និងដើមទសវត្សរ៍ឆ្នាំ១៩៨០ ម៉ាល់ឌីវគ្មានជម្រើសទេក្រៅពីការពង្រឹងការកំសាន្តដោយទេសចរថ្នាក់កណ្តាល។ មកទល់ពេលនោះ កោះនេះបានទទួលទេសចរយ៉ាងច្រើនដែលទាមទារឱ្យកែលំអប្រព័ន្ធដឹកជញ្ជូនតាមយន្តហោះ និងហេដ្ឋារចនាសម្ព័ន្ធ។ ក្រោយមក ដោយសារប្រទេសមានទំហំតូច និងប្រព័ន្ធអេកូឡូស៊ីងាយខូចខាត រដ្ឋាភិបាលបានចាត់វិធានការយ៉ាងប្រុងប្រយ័ត្នដើម្បីផ្តោតលើទេសចរជាន់ខ្ពស់ និងបានលើកទឹកចិត្តឱ្យមានកំណើននៃហាងទាន់សម័យ ការអភិវឌ្ឍកន្លែងកំសាន្តទំនើប។ វិធីនេះបានជួយបង្កើនជាអតិបរមានូវប្រាក់ចំណូលសម្រាប់រដ្ឋាភិបាល និងអ្នកវិនិយោគឯកជន ទន្ទឹមនឹងការថែរក្សានិរន្តរភាពបរិស្ថាន និងសង្គម។ ម៉ាល់ឌីវ នៅតែអាចផ្តល់គុណភាពចម្រុះសម្រាប់តម្រូវតាមក្រុមខុសៗគ្នា ប៉ុន្តែប្រទេសនេះក៏ជាកន្លែងផ្តល់ការកំសាន្តចំណាត់ថ្នាក់ពិភពលោកផងដែរ។ សេវានេះមានភាពទាក់ទាញយ៉ាងច្បាស់ដោយសារអត្រាទេសចរមកកំសាន្តឡើងវិញគឺ ២០-៣០%។ សេវានេះក៏ផ្តល់ផលចំណេញខ្លាំងណាស់ដែរ ហើយអត្រាចំណូលសម្រាប់គម្រោងភាគច្រើនជាការលើកទឹកចិត្តអ្នកវិនិយោគជាច្រើនហើយសណ្ឋាគារទំនើបជាច្រើនត្រូវបានកសាងឡើង។

**ប្រភព : World Bank, ADB and UN ២០០៥។**

រងគ្រោះដោយសារ "ការលេចធ្លាយ" ច្រើនផងដែរ ប្រសិនបើវាត្រូវការនាំចូលសម្ភារៈសម្រាប់ផ្គត់ផ្គង់ និងអ្នកជំនាញ។

## ផលប៉ះពាល់អវិជ្ជមានដែលអាចកើតពីទេសចរណ៍

ដូចជាផ្នែកដទៃនៃកំណើនសេដ្ឋកិច្ច និង សកលភាវូបនីយកម្មផងដែរ ទេសចរណ៍ក៏អាចផ្តល់ឥទ្ធិពលអវិជ្ជមានខ្លះៗផងដែរ។

*អតិផរណា* : ការវិនិយោគលើគោលដៅទេសចរណ៍អាចធ្វើឱ្យដីធ្លី កន្លែងស្នាក់នៅ និងអាហារឡើងថ្លៃ ហើយអាចរុញច្រានប្រជាជនមូលដ្ឋានចេញពីកន្លែងដើមទៀតផង។

*ទំនាស់ធនធាន* : សហគ្រាសទេសចរក៏អាចបង្កគ្រោះថ្នាក់ចំពោះមុខរបរជាច្រើនផងដែរដោយទាញយកសម្បត្តិធម្មជាតិនានា ដូចជា ដីធ្លី ឬឆ្នេរសមុទ្រ ឬដោយបំពុលផ្លូវទឹក។ ឧទាហរណ៍ ប្រជាពលរដ្ឋនៅក្នុងសហគមន៍មូលដ្ឋាននៅលើកោះជាច្រើននៅប៉ាស៊ីហ្វិកពឹងផ្អែកលើត្រី សម្រាប់ជាប្រភពចម្បងនៃប្រូតេអ៊ីន និងប្រាក់ចំណូល ហើយអាចមើលឃើញថា សន្តិសុខស្បៀង និងការចិញ្ចឹមជីវិតរបស់ខ្លួនខូចខាត ដោយសារការអភិវឌ្ឍទេសចរណ៍។

*បន្ទុកលើសេវា* : ឧទាហរណ៍ សហគ្រាសទេសចរណ៍ថ្មីៗបានបង្កើនសម្ពាធលើការផ្គត់ផ្គង់ទឹក និងលើសេវាគ្រប់គ្រងសំណល់ ជាបន្ទុកដែលច្រើនតែត្រូវផ្ទេរបន្តទៅឱ្យប្រជាជនដទៃទៀតនៅក្នុងមូលដ្ឋាន និងមុខជំនួញនានា។

*ការបំផ្លិចបំផ្លាញបរិស្ថាន* : ជាទូទៅទេសចរណ៍ទ្រង់ទ្រាយធំពាក់ព័ន្ធនឹងការប្រើប្រាស់ទឹក និងថាមពលច្រើន។ សណ្ឋាគារច្រើនតែប្រមូលផ្តុំនៅតែក្នុងកន្លែងតែមួយ ហើយវារួមចំណែកនាំឱ្យមានកំណើនការស្ទះចរាចរ និងការបំពុលទឹក និងខ្យល់។ ក្នុងករណីខ្លះ អ្នកទេសចរដែលមានការទាក់ទាញដោយសារភាពនៅដាច់ស្រយាល ឬសម្រស់នៃទីតាំងនោះ អាចបំផ្លាញអ្វីដែលពួកគេបានមកទស្សនា។ ចំណែកផ្លូវថ្នល់ និងសណ្ឋាគារសង់លយចូលទៅក្នុងទីធម្មជាតិ ឬអ្នកថ្មើរជើងក្នុងព្រៃធ្វើឱ្យហូរច្រោះផ្លូវលំ។ នៅក្នុងតំបន់ឆ្នេរ សកម្មភាពនានា ដូចជា ការហែលដើម្បីទស្សនានៅក្នុងទឹកអាចបង្កគ្រោះថ្នាក់ចំពោះប្រព័ន្ធអេកូឡូស៊ីសមុទ្រ។

*ការរាលដាលនៃជម្ងឺ* : ពុំមានការបង្ហាញឱ្យឃើញច្បាស់ពីទំនាក់ទំនងរវាង AIDS និងទេសចរណ៍ឡើយ ប៉ុន្តែនៅក្នុងប្រទេសជាច្រើន ដូចជា ថៃ អត្រាប្រេវ៉ាឡង់នៃ HIV មានខ្ពស់ជាពិសេសនៅក្នុងមជ្ឈមណ្ឌលទេសចរ ហើយការបន្តកើនឡើងនូវចំនួនទេសចរអាចធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើង។

*បញ្ហាវប្បធម៌* : អ្នកទេសចរជាច្រើន ដែលជាអ្នកមានជាងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន អាចធ្វើឱ្យខូចខាតវប្បធម៌ ដែលមានអាយុចំណាស់មកហើយដោយនាំមកជាមួយនូវតម្លៃរបស់អ្នកប្រើប្រាស់។ របៀបរស់នៅបែបតម្រេកនិយមរបស់អ្នកទេសចរ អាចជាការវាយប្រហារភាពទន់ភ្លន់របស់សហគមន៍បែបអភិរក្សផងដែរ។ លើសពីនេះ ការបន្សាំនៃវប្បធម៌មូលដ្ឋានទៅនឹងទេសចរណ៍ ឧទាហរណ៍ តាមរយៈការសំដែងពិសេសៗអាចធ្វើឱ្យបាត់បង់អត្តសញ្ញាណ និងភាពដើមផងដែរ។

*ការកេងប្រវ័ញ្ចលើស្ត្រី* : ស្ត្រីអាចទទួលបានការងារថ្មីធ្វើនៅក្នុងឧស្សាហកម្មទេសចរណ៍នៅទីនេះ ដូចជានៅក្នុងវិស័យភាគច្រើនដែរ ស្ត្រីច្រើនតែជាអ្នកចាញ់ប្រៀប។ ដោយសារ ពួកគេពុំសូវមានអំណាចត្រួតត្រាដីធ្លី និងទ្រព្យសម្បត្តិផ្សេងទៀត ពួកគេអាចមានការលំបាកដើម្បីទាញយកអត្ថប្រយោជន៍ពេញលេញពីកាលានុវត្តភាពសេដ្ឋកិច្ច។ ដោយសារងាយរងគ្រោះ ស្ត្រីក៏អាចជាមុខព្រួញនៃការកេងប្រវ័ញ្ចខាងផ្លូវភេទផងដែរ។

*សហគ្រាសទេសចរក៏អាចបង្កគ្រោះថ្នាក់ចំពោះមុខរបរជាច្រើនផងដែរ ដោយទាញយកសម្បត្តិធម្មជាតិនានា ដូចជា ដីធ្លី ឬឆ្នេរសមុទ្រ ឬដោយបំពុលផ្លូវទឹក*

*ទន្ទឹមនឹងទេសចរណ៍អាចនាំទៅបង្កើតបញ្ហានៃការអភិវឌ្ឍ ប្រការនេះអាចដោះស្រាយបាន ឬកាត់បន្ថយតាមរយៈការកសាងផែនការ និង គ្រប់គ្រងឱ្យបានត្រឹមត្រូវ*

## ការអភិវឌ្ឍទេសចរណ៍ដែលគាំទ្រជនក្រីក្រ

ទន្ទឹមនឹងទេសចរណ៍អាចនាំទៅបង្កើតបញ្ហានៃការអភិវឌ្ឍ ប្រការនេះអាចដោះស្រាយបាន ឬកាត់បន្ថយ តាមរយៈការកសាងផែនការ និងគ្រប់គ្រងឱ្យបានត្រឹមត្រូវ។ ក្នុងចំណោមអាទិភាព គួររាប់បញ្ចូល :

*កសាងផែនការ និងគាំទ្រ* : រដ្ឋាភិបាលចាំបាច់ត្រូវចូលរួមក្នុងការបង្កើតប៉ារ៉ាម៉ែត្រជាតិ និងតំបន់សម្រាប់ឧស្សាហកម្មនេះ ក៏ដូចជាបង្កើតគ្រឹះស្ថានគាំទ្រផងដែរ ដូចជាក្រុមប្រឹក្សាទេសចរណ៍ និងវិទ្យាស្ថានបណ្តុះបណ្តាល។

*ហេដ្ឋារចនាសម្ព័ន្ធ* : ប្រការនេះមានសារៈសំខាន់ដោយឡែកនៅក្នុងតំបន់ដាច់ស្រយាល ដែលទេសចរណ៍តំណាងឱ្យកាលានុវត្តភាពមួយចំនួនតូចនៃការអភិវឌ្ឍសេដ្ឋកិច្ច ទោះបីនៅក្នុងករណីខ្លះ កង្វះហេដ្ឋារចនាសម្ព័ន្ធអាចផ្តល់ជាប្រយោជន៍ ប្រសិនបើវាជាកត្តារារាំងអ្នកទេសចរកុំឱ្យទៅកាន់គោលដៅបរិស្ថានដែលងាយខូចខាតក្នុងចំនួនច្រើនពេក។

*ភាពសំបូរបែបនៃវប្បធម៌* : រដ្ឋាភិបាលចាំបាច់ត្រូវការពារភាពសំបូរបែបនៃវប្បធម៌ ដោយអនុញ្ញាតឱ្យប្រជាជនមូលដ្ឋានបានចូលរួមនៅក្នុងផលប្រយោជន៍ខាងសេដ្ឋកិច្ចនៃទេសចរណ៍ ទន្ទឹមនឹងការពារបេតិកភណ្ឌវប្បធម៌របស់ខ្លួន។ ឧទាហរណ៍ដែលគួរឱ្យកត់សម្គាល់ជាងគេនៃការអភិវឌ្ឍយ៉ាងឆាប់រហ័សនូវហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍គឺនៅអង្គរក្នុងប្រទេសកម្ពុជា (ប្រអប់ ៥.១៥)។

*ការបណ្តុះបណ្តាល* : ការងារនៅក្នុងឧស្សាហកម្មនេះមិនសុទ្ធតែទាមទារឱ្យមានគុណវុឌ្ឍិខាងការសិក្សាជាន់ខ្ពស់នោះទេ ហើយនៅក្នុងប្រទេសជាច្រើន ក្រុមសណ្ឋាគារធំៗ និងក្រុមហ៊ុនទេសចរណ៍ទំនងជាពឹងផ្អែកលើបរិក្ខារបណ្តុះបណ្តាលនៅក្នុងក្រុមហ៊ុនរបស់ខ្លួនផ្ទាល់។ ប្រការនេះធ្វើឱ្យសហគ្រាសតូចៗចាញ់ប្រៀប។ ដូច្នេះ ទីភ្នាក់ងាររដ្ឋាភិបាលគួរធ្វើការជាមួយវិស័យឯកជនលើការបណ្តុះបណ្តាល ការបង្ហាត់បង្រៀន និងវគ្គអប់រំរយៈពេលខ្លីដែលអាចជួយមនុស្សកាន់តែច្រើនឱ្យទទួលអត្ថប្រយោជន៍។

*ចំណងទាក់ទងសម្រាប់អ្នកក្រ* : ត្រូវពិនិត្យមើល "ការលេចធ្លាយ" សេដ្ឋកិច្ច និងក្នុងករណីអាចធ្វើទៅបាន ត្រូវចាត់វិធានការទប់ទល់ ។ ឧទាហរណ៍ ប្រតិបត្តិករទេសចរណ៍ខ្នាតធំកសាងភាពជាដៃគូជាមួយសហគ្រាសមូលដ្ឋានតូចនិងមធ្យម ដោយទិញវត្ថុធាតុដើមនៅក្នុងមូលដ្ឋាន ធ្វើលទ្ធកម្មការ បោកគក់ និងសេវាផ្សេងៗទៀតបែបនេះ ដាក់តាំងសម្ភារៈ សិប្បកម្ម និងបង្កើតដំណើរកំសាន្តជាកញ្ចប់។ ដូច្នេះ ប្រតិបត្តិករអាចពិចារណាប្រាក់ចំណូលពីមុខជំនួញ ទន្ទឹមនឹងប្រឹងប្រែងធ្វើឱ្យ

### ប្រអប់ ៥.១៥

#### ការអភិវឌ្ឍទេសចរណ៍យ៉ាងឆាប់រហ័សក្នុងតំបន់ដាច់ស្រយាលអង្គរនៅកម្ពុជា

ប្រាសាទអង្គរក្នុងខេត្តសៀមរាបក្នុងប្រទេសកម្ពុជាអាចជា "របកគំហើញ" ខាងផ្នែកទេសចរណ៍ធំជាងគេតែមួយគត់នៅក្នុងទសវត្សរ៍មុន សម្រាប់បេតិកភណ្ឌពុទ្ធសាសនា។ ក្រោយការដួលរលំនៃរបបខ្មែរក្រហម និងការបង្កើតរដ្ឋាភិបាលប្រជាធិបតេយ្យ និងការបើកចំហរ ប្រទេសនេះនៅពេលបន្ទាប់មក ប្រាសាទអង្គរបានទាក់ទាញការយកចិត្តទុកដាក់របស់អ្នកទេសចរវប្បធម៌អន្តរជាតិ។ ចាប់ពីមានទេសចរតិចតួចបំផុតនៅដើមទសវត្សរ៍ ឆ្នាំ ១៩៩០ ចំនួនទេសចរអន្តរជាតិបានកើនឡើងដល់ ៥៦១.000 នាក់នៅឆ្នាំ ២00៤។

ទេសចរណ៍បានផ្លាស់ប្តូរសេដ្ឋកិច្ចនៃតំបន់នេះទាំងមូល។ ទីក្រុងសៀមរាប បានលូតលាស់យ៉ាងឆាប់រហ័សខាងផ្លូវថ្នល់ និងផ្លូវយន្តហោះ។ នៅក្នុងអំឡុងឆ្នាំ ១៩៩៨-២00៣ ចំនួនបន្ទប់សណ្ឋាគារបានកើនឡើង២៩%/ឆ្នាំ។ ទេសចរណ៍បានបង្កើតឧស្សាហកម្មដែលមកទល់ថ្មីៗនេះ ត្រូវបានបំភ្លេចគឺចម្លាក់ថ្មនិងសិប្បកម្ម ហើយបានជម្រុញសហគ្រាសជាច្រើនទៀតក្នុងមូលដ្ឋាន។

ជោគជ័យនេះទាក់ទងទៅនឹងគុណភាពនៃប្រាសាទ និងទីជុំវិញប្រាសាទនេះ ដែលមានដើមឈើខ្ពស់ៗប្រកបដោយស្លឹកត្រឈឹងត្រឈៃ និងកិច្ចប្រឹងប្រែងរួមគ្នារបស់រដ្ឋាភិបាល ផ្នែកឯកជន និង NGOs។ ឥឡូវនេះប្រទេសមួយដែលធ្លាប់នាំចេញពលករទៅប្រទេសផ្សេងទៀតបាននាំចូលពលករមកវិញ។

**ប្រភព : ក្រសួងទេសចរណ៍ ២00៤; Mahajan and Aibara, ២00១។**

ក្រុមទន់ខ្សោយទទួលផលចំណេញសមស្រប។

## ពាណិជ្ជកម្មថ្មីនៅក្នុងសេវាកម្មសេដ្ឋកិច្ច

តំបន់អាស៊ីប៉ាស៊ីហ្វិកស្ថិតនៅជួរមុខនៃពាណិជ្ជកម្មអន្តរជាតិខាងសេវា ជាពិសេស តាមរយៈចំណាកស្រុកជាអន្តរជាតិ លទ្ធកម្មមុខជំនួញ និងទេសចរណ៍។ ប៉ុន្តែនៅក្នុងគ្រប់ផ្នែកទាំងអស់នេះ អ្នកកសាងគោលនយោបាយត្រូវតែចាត់វិធានការតឹងរ៉ឹង និងតាមរូបភាពជាច្រើន ដើម្បីធានាថាវិស័យដែលមានលក្ខណៈឌីណាមិកទាំងនេះបំពេញបាននូវសក្តានុពលរបស់ខ្លួន ដើម្បីលើកកម្ពស់ការអភិវឌ្ឍមនុស្ស។

សម្រាប់ចំណាកស្រុកជាអន្តរជាតិទាំងប្រទេសជាប្រភពដើមនិងប្រទេសជាគោលដៅ អាចចាត់វិធានការបានច្រើនបន្ថែមទៀតដើម្បីធ្វើឱ្យចំណាកស្រុកមានប្រយោជន៍ និងទទួលបានបទពិសោធ។ ប្រទេសជាប្រភពដើមអាចធានាថា ជនចំណាកស្រុកបានទទួលព័ត៌មាន ហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលបានសមស្រប មុនពេលដែលពួកគេចេញដំណើរ ហើយប្រទេសជាគោលដៅអាចធ្វើឱ្យដំណើរការ ចំណាកស្រុកបានងាយស្រួល និងមានតម្លាភាពជាងមុន។

សម្រាប់លទ្ធកម្មដំណើរការជំនួញ រដ្ឋាភិបាលមានជម្រើសគោលនយោបាយជាច្រើន ដើម្បីធានាថា ខ្លួនបានរួមចំណែកយ៉ាងច្រើនទៅក្នុងការអភិវឌ្ឍមនុស្ស រួមទាំងកសាងហេដ្ឋារចនាសម្ព័ន្ធ បណ្តុះបណ្តាលពលករ និងធានាឱ្យមានបរិស្ថានច្បាប់ និងសារពើពន្ធបានប្រសើរបំផុត។

ទាក់ទងនឹងទេសចរណ៍បញ្ហាជាច្រើនអាចដោះស្រាយឬកាត់បន្ថយបានតាមរយៈការកសាងផែនការ និងគ្រប់គ្រងឱ្យបានត្រឹមត្រូវ ឧទាហរណ៍ ដោយកសាងហេដ្ឋារចនាសម្ព័ន្ធសមស្រប ផ្តល់ការបណ្តុះបណ្តាលសម្រាប់អ្នកដែលធ្វើការនៅក្នុងសហគ្រាសតូចៗ និងធានាឱ្យមានទំនាក់ទំនងប្រសើរជាងមុននៃសេដ្ឋកិច្ច រវាងប្រតិបត្តិករទេសចរធំៗ និងសហគមន៍ក្រីក្រ។

# 6



# ៦

# ជំពូក

# កាលានុវត្តភាពពាណិជ្ជកម្មសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច

នៅពេលនិយាយពីការធ្វើសមាហរណកម្មទៅក្នុងពាណិជ្ជកម្មអន្តរជាតិ ប្រទេសដែលមានការអភិវឌ្ឍតិចតួចស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ។ ប្រទេសទាំងនោះមានសេដ្ឋកិច្ចតូច សណ្ឋានដីលំបាក និងស្ថិតនៅឆ្ងាយពីទីផ្សារអន្តរជាតិ ដែលនៅក្នុងនោះពួកគេជាការីតូចតាច និងទន់ខ្សោយ។ ប្រទេសទាំងនេះពុំទទួលផលពីការធ្វើសម្បទានខ្លះៗ ដែលផ្តល់ដោយប្រទេសជឿនលឿននោះឡើយ ប៉ុន្តែពួកគេត្រូវការឱ្យមានការយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវជាងនេះនៅឯ WTO ក៏ដូចជាជំនួយអន្តរជាតិ ប្រសិនបើប្រទេសទាំងនោះត្រូវប្រើប្រាស់ពាណិជ្ជកម្មអន្តរជាតិ ដើម្បីលើកកម្ពស់ការអភិវឌ្ឍមនុស្ស។

ជាគោលការណ៍ប្រទេសទាំងអស់គួរតែអាចប្រើប្រាស់ឧត្តមភាពរបស់ខ្លួនដើម្បីទទួលអត្ថប្រយោជន៍ពីទីផ្សារអន្តរជាតិ និងពាណិជ្ជកម្មសេរី។ ក្នុងស្ថានភាពជាក់ស្តែង ទំហំសេដ្ឋកិច្ចអាចផ្តល់ការអនុគ្រោះយ៉ាងច្រើនដល់ប្រទេសធំ និងជឿនលឿនជាង។ ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស LDCs បានពិនិត្យឃើញថា ខ្លួនមានស្ថានភាពទន់ខ្សោយជាងជាខ្លាំង។

តំបន់អាស៊ីប៉ាស៊ីហ្វិក គឺជាជម្រកនៃប្រជាជន ៣៧% នៃ LDCs នៅលើពិភពលោក ដោយមាន LDCs ចំនួន ១៤ ក្នុងចំណោម ៥០ LDCs។ ប្រទេសទាំងនោះគឺ អាហ្វហ្គានីស្ថាន បង់ក្លាដេស ប៊ូតាណ កម្ពុជា គីរីបាទី ឡាវ ម៉ាល់ឌីវ ភូមា នេប៉ាល់ សាម៉ាវ កោះសូឡូម៉ុង ទីម័រខាងកើត ទូវ៉ាលូ និង វ៉ាណាទូ។ ប្រទេសទាំងនេះត្រូវបានចាត់ជា LDCs ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួនបីគឺ : ចំណូលទាប ភាពទន់ខ្សោយនៃធនធានមនុស្ស និងភាពងាយរងគ្រោះនៃសេដ្ឋកិច្ច។[១] សូម្បីតែ ដូច្នេះប្រទេសទាំងនេះគឺជាក្រុមដែលខុសៗគ្នា។ តាមពិតតំបន់ នេះជាជម្រកនៃ LDCs ដែលមានប្រជាជនរស់នៅកុះករជាងគេ លើពិភពលោក ដូចជា បង់ក្លាដេស និងដង់ស៊ីតេទាបជាងគេគឺទូវ៉ាលូ។ បើផ្អែកតាមស្ថានភាពភូមិសាស្ត្រ ប្រទេសទាំងនេះក៏អាចខុសគ្នាផងដែរ។ ឧទាហរណ៍ បួនជាប្រទេសមិនជាប់សមុទ្រ និងប្រាំពីរជារដ្ឋនៅលើកោះ[២] (តារាងទី ៦.១)។

LDCs ងាយរងគ្រោះដោយសារប្រការជាច្រើនះ

- *សេដ្ឋកិច្ច* : ប្រឈមនឹងការរំជើបរំជួលយ៉ាងខ្លាំងពីខាងក្រៅ ដែលមានឥទ្ធិពលអវិជ្ជមានលើប្រាក់ចំណូល ចំនួនការងារ ផលិតកម្មក្នុងស្រុក ការចែកចាយទីផ្សារ ការប្រើប្រាស់ និងទ្រព្យធន។ LDCs ក៏មានសមត្ថភាពទាបក្នុងការឆ្លើយតបនឹងការរំជើបរំជួលបែបនេះផងដែរ។
- *បរិស្ថាន* : ប្រឈមនឹងគ្រោះថ្នាក់បង្កដោយធម្មជាតិ និងកត្តាមនុស្ស។ ឧទាហរណ៍ រដ្ឋលើកោះតូចៗនៅប៉ាស៊ីហ្វិកច្រើនតែប្រទះនឹងភាពរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ ភ្នំភ្លើង និងរញ្ជួយផែនដី ចំណែកប្រទេសនៅតំបន់ភ្នំនៅអាស៊ីងាយរងគ្រោះដោយសារទឹកជំនន់ពីភ្នំ បន្ទុះភ្នំភ្លើង និងការរញ្ជួយផែនដី។

តារាង ៦.១

ចំនួនការងារក្នុងឧស្សាហកម្មទេសចរណ៍

| ប្រទេស | ស្ថានភាព ភូមិសាស្ត្រ | ចំនួនប្រជាជន ឆ្នាំ ២០០៣ (លាននាក់) | GDP/ម្នាក់ៗ ឆ្នាំ ២០០៣ (ថេរ ២០០០ $) | ជំនួយ/ម្នាក់ៗ ឆ្នាំ ២០០៣ ($) | ស្ថានភាព បំណុល * ឆ្នាំ ២០០៣ | ការនាំចេញនិង នាំចូលគិតជា % នៃ GDP ឆ្នាំ ២០០៣ | សន្ទស្សន៍អភិវឌ្ឍមនុស្ស (HDI) ឆ្នាំ ២០០៣ (តួលេខ HDI ចំណាត់ថ្នាក់ក្នុងចំនួនសរុប ១៧៧) |
|---|---|---|---|---|---|---|---|
| អាហ្វហ្គានីស្ថាន | មិនជាប់សមុទ្រ | ២២.២ | ... | ... | ឥតចាត់ថ្នាក់ | ... | ... |
| បង់ក្លាដេស | ជាប់សមុទ្រ | ១៣៨.១ | ៣៩៥ | ១០.១ | បំណុលតិចតួច | ១៤.២ | មធ្យម (០.៥២០; ១៣៩) |
| ប៊ូតាណ | មិនជាប់សមុទ្រ | ០.៩ | ៦៨០ | ៨៨.១ | បំណុលធ្ងន់ធ្ងរ | ២២.០ | មធ្យម (០.៥៣៦; ១៣៤) |
| កម្ពុជា | ជាប់សមុទ្រ | ១៣.៤ | ៣១៣ | ៣៧.៩ | បំណុលមធ្យម | ៦២.០ | មធ្យម (០.៥៧១; ១៣០) |
| គីរីបាទី | កោះតូច | ០.១ | ៥៦៩ | ១៩០.៦ | ឥតចាត់ថ្នាក់ | ... | ... |
| ឡាវ | មិនជាប់សមុទ្រ | ៥.៧ | ៣៥២ | ៥២.៨ | បំណុលធ្ងន់ធ្ងរ | ២៥.៥ | មធ្យម (០.៥៤៥; ១៣៣) |
| ម៉ាល់ឌីវ | កោះតូច | ០.៣ | ២.៥៤៨ | ៦១.៣ | បំណុលតិចតួច | ៨៥.២ | មធ្យម (០.៧៤៥; ៩៦) |
| ភូមា | ជាប់សមុទ្រ | ៤៩.៤ | ... | ២.៥ | បំណុលធ្ងន់ធ្ងរ | ... | មធ្យម (០.៥៧៨; ១២៩) |
| នេប៉ាល់ | មិនជាប់សមុទ្រ | ២៤.៧ | ២៤១ | ១៨.៩ | បំណុលតិចតួច | ១៦.៧ | មធ្យម (០.៥២៦; ១៣៦) |
| សាម៉ាវ | កោះតូច | ០.២ | ១.៥២២ | ១៨៥.៦ | បំណុលធ្ងន់ធ្ងរ | ... | មធ្យម (០.៧៧៦; ៧៦) |
| កោះសូឡូម៉ុង | កោះតូច | ០.៥ | ៥៩៧ | ១៣១.៩ | បំណុលមធ្យម | ៣១.០ | មធ្យម (០.៥៩៤; ១២៨) |
| ទីម័រខាងកើត | កោះតូច | ០.៩ | ៤២១ | ១៧១.៩ | ឥតចាត់ថ្នាក់ | ... | មធ្យម (០.៥១៣; ១៤០) |
| ទូវ៉ាលូ | កោះតូច | ០.០ | ... | ... | ឥតចាត់ថ្នាក់ | ... | ... |
| វ៉ាណាទូ | កោះតូច | ០.២ | ១.០៩៨ | ១៥៣.៣ | បំណុលតិចតួច | ... | មធ្យម (០.៦៥៩; ១១៨) |
| LDCs នៅអាស៊ីប៉ាស៊ីហ្វិក | | ២៥៦.៣ | ៣៧៥ | ១៣.៦ | ... | ១៨.៨ | ... |
| ប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត នៅអាស៊ីប៉ាស៊ីហ្វិក | | ៣.០១៦.៦ | ៨៥៤ | ២.៧ | ... | ៣៤.៨ | ... |

**សម្គាល់: អត្រាបំណុលកំណត់ដោយធនាគារពិភពលោក។ "បំណុលធ្ងន់ធ្ងរ" មានន័យថា ឬមួយតម្លៃបច្ចុប្បន្ននៃសេវាបំណុលធៀបនឹង GNI មានកម្រិតធ្ងន់ធ្ងរ ពោលគឺ ៨៥% ឬច្រើនជាង ឬមួយតម្លៃបច្ចុប្បន្ននៃសេវាបំណុលមានកម្រិតធ្ងន់ធ្ងរ ពោលគឺ ២២០% ឬច្រើនជាង។ "បំណុលមធ្យម" មានន័យថា ឬមួយផលធៀបចំបងទាំងពីរខ្ពស់ជាង ៦០% ប៉ុន្តែមិនឈានដល់កម្រិតធ្ងន់ធ្ងរ។ សេដ្ឋកិច្ចផ្សេងទៀតត្រូវបានចាត់ទុកថាមានបំណុលតិចតួច។ សូមមើលក្នុង www.worldbank.org/data/countryclass/countryclass.html ។ "..." គ្មានទិន្នន័យ។**

**មានបញ្ហាជាច្រើនទាក់ទងនឹងទិន្នន័យសម្រាប់ LDCs ជាច្រើន។ ប្រភពផ្សេងគ្នាផ្តល់តួលេខប៉ាន់ប្រមាណខុសគ្នាសម្រាប់សូចនាករដូចគ្នា និងទំនងជាមានគម្លាតទិន្នន័យផងដែរ។**

**ប្រភព : UNDP and UNSCAP ២០០៥; World Bank ២០០៥; UNDP ២០០៥; ESCAP ២០០៥។**

- *សង្គម* ៖ ប្រឈមនឹងកត្តានានាដែលធ្វើឱ្យខូចទំនាក់ទំនងសង្គម ជម្ងឺសង្គមដែលនាំចូលពីក្រៅ និងការចុះខ្សោយនៃមូលធនសង្គម។ ដោយសារ LDCs មានសមត្ថភាពតិចតួច ដើម្បីឆ្លើយតប បាតុភូតទាំងនេះទំនងជាកើតឡើងវិញ។
- *ស្ថាប័ន* ៖ សមត្ថភាពមានកម្រិតនៃស្ថាប័នក្នុងស្រុក រួមទាំងរដ្ឋ ដើម្បីឆ្លើយតបនឹងភាពសាំញ៉ាំ និងប្រពលភាពនៃសម្ពាធបណ្តាលពីសកលភាវូបនីយកម្ម។

ជាក្រុមមួយ LDCs ក្នុងតំបន់នេះបានធ្វើឱ្យមានការរីកចម្រើនយ៉ាងច្រើន។ នៅអំឡុងឆ្នាំ១៩៩០-២០០០ ប្រទេសទាំងនេះបានបង្កើន GDP ជាមធ្យមក្នុងមនុស្សម្នាក់ ក្នុងអត្រា ១.៥ដង និងការនាំចេញកើនឡើងបីដង។ សូចនាករសង្គមក៏បានកែលំអផងដែរ។ ក្នុងអំឡុងពេលដូចគ្នានេះ អត្រាចេះអក្សរនៃមនុស្សពេញវ័យបានកើនឡើងពី ៦០% ទៅ ៧១% អាយុកាលកើនឡើងពី ៥៨ ទៅ ៦២ឆ្នាំ និង អត្រាមរណៈភាពនៃកុមារក្នុងចំនួនកើតរស់ ១.០០០ បានថយចុះពី ៧៧ មកត្រឹម ៥៥។

ទោះជាយ៉ាងណាក៏ដោយ ប្រទេសទាំងនេះបានចាប់ផ្តើមពីកម្រិតទាបនិងនៅតែមានអត្រាខ្ពស់នៃភាពក្រីក្រ និងភាពអត់ឃ្លាននៅឡើយ។ នៅឆ្នាំ ២០០៣ GDP ជាមធ្យមក្នុងមនុស្សម្នាក់នៅក្នុង LDCs នៃតំបន់នេះ មានមធ្យមក្នុងមនុស្សម្នាក់នៅក្នុង LDCs នៃតំបន់នេះ មាន ៣៧៥ដុល្លារ តិចជាងពាក់កណ្តាលនៃអត្រាដូចគ្នានៃប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី-ប៉ាស៊ីហ្វិក។ ប្រទេសទាំងនេះ មានសេដ្ឋកិច្ចដែលងាយរងគ្រោះដោយភាគច្រើនស្ថិតនៅឆ្ងាយពីទីផ្សារ ដំណើរការដោយប្រើប្រាស់បច្ចេកវិទ្យាទាប និងពឹងផ្អែកលើការនាំចេញតិចតួចដែលទាំងតម្រូវការនិងថ្លៃអាចងាយប្រែប្រួល។ ប្រទេសទាំងនេះមានធនធានធម្មជាតិតិចតួច និងងាយរងគ្រោះដោយគ្រោះធម្មជាតិ។

## LDCs និង សេរីភាវូបនីយកម្ម

ផ្នែកមួយដែល LDCs ត្រូវប្រឈម គឺពាណិជ្ជកម្មអន្តរជាតិ។ ចំពោះពាណិជ្ជកម្មរបស់ LDCs ជាច្រើន ការនាំចេញបូក និងការនាំចូល គឺជាសមាមាត្រខ្ពស់នៃសកម្មភាពសេដ្ឋកិច្ច។ តាមពិត អត្រាពាណិជ្ជកម្មធៀបនឹង GDP របស់ប្រទេសទាំងនេះច្រើនតែខ្ពស់ជាងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ឬអាចខ្ពស់ជាងប្រទេសជឿនលឿនផង ឧទាហរណ៍ ១២៧% សម្រាប់កម្ពុជានៅឆ្នាំ ២០០២ និង ១៥២% សម្រាប់ម៉ាល់ឌីវ។ ប្រទេសទាំងនោះច្រើនតែមានរបបពាណិជ្ជកម្មបើកចំហ ដែលមានអត្រាពន្ធ ឬរបាំងមិនមែនពន្ធទាប។ យោងតាមសន្ទស្សន៍របស់ IMF និងមានទិន្នន័យសម្រាប់ឆ្នាំ ២០០៤ អំពីការដាក់កំហិតលើពាណិជ្ជកម្ម ក្នុងចំណោម ៤៦ LDCs នៅទូទាំងពិភពលោក មានតែប្រទេសចំនួនបួនដែលមានអត្រាពន្ធជាមធ្យម ២៥%។ លើសពីនេះ សម្រាប់ ២៩ប្រទេស របាំងមិនមែនពន្ធអាចមានកម្រិតទាប ឬតិចតួចតែប៉ុណ្ណោះ។[៣]

ទោះជាយ៉ាងណាក៏ដោយ របបពាណិជ្ជកម្មបើកចំហទាំងនេះមិនមែនកើតឡើងដោយសារការប្តេជ្ញាក្រោមកិច្ចចរចាពហុភាគីនៅក្នុងកិច្ចប្រជុំនៅអ៊ុយរ៉ាហ្គាយ ឬជាមួយ WTO នោះឡើយ។ ជាញឹកញាប់ LDCs បានចាត់វិធានការជាឯកតោភាគីដើម្បីបើកចំហសេដ្ឋកិច្ចរបស់ខ្លួនជាចំណែកមួយនៃកម្មវិធីកំណែទម្រង់ទូលាយនៅក្នុងប្រទេស។ ក្នុងចំណោម ២១% ដែលបានកាត់បន្ថយគិតជាមធ្យមនៃអត្រាពន្ធរបស់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ រវាងឆ្នាំ ១៩៨៣ និង ២០០៣ ពីរភាគបីកើតឡើងដោយសារសេរីភាវូបនីយកម្មស្វយ័ត។

*ពាណិជ្ជកម្មតំណាងឱ្យ សមាមាត្រដ៏ច្រើននៃ សកម្មភាពសេដ្ឋកិច្ច*

## ហេតុអ្វី LDCs មិនបានទទួលប្រយោជន៍គ្រប់គ្រាន់ពីពាណិជ្ជកម្ម?

គតិបណ្ឌិតធម្មតាសន្មតថា កំណើនការនាំចេញតាមបែបណាមួយគួរតែមានប្រយោជន៍ ដែលផ្តល់រូបិយប័ណ្ណដែលជាតម្រូវការបំផុត សម្រាប់វិនិយោគលើការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ម្យ៉ាងវិញទៀត ទោះបី LDCs ច្រើនតែមានវិស័យនាំចេញរស់រវើកក៏ដោយចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ ១៩៨០ ប្រទេសទាំងនេះពុំទាន់បានសម្រេចកំណើនសេដ្ឋកិច្ចសមគួរឬការកាត់បន្ថយភាពក្រីក្រច្រើនឡើយ។

ហេតុអ្វី LDCs មិនអាចប្រើប្រាស់ពាណិជ្ជកម្ម ដើម្បីពង្រឹងកំណើនសេដ្ឋកិច្ច? ឧបសគ្គជាច្រើនមានលក្ខណៈដូចគ្នានឹងប្រទេសជាច្រើនដែលពុំសូវមានការអភិវឌ្ឍជាទូទៅដែរ ពោលគឺកម្រិតទាបនៃជំនាញ និងបច្ចេកវិទ្យាដែលនាំឱ្យមានផលិតភាពទាប ភាពទន់ខ្សោយនៃហេដ្ឋារចនាសម្ព័ន្ធ ទំនាក់ទំនងតិចតួចរវាងវិស័យផលិតកម្ម និងកង្វះវិស័យហិរញ្ញវត្ថុ ដែលអាចផ្តល់មូលធនតាមអត្រាការប្រាក់សមស្រប។

ប្រទេសជាច្រើនក៏ប្រឈមនឹងឧបសគ្គខាងភូមិសាស្ត្រផងដែរ។ ឧទាហរណ៍ អាហ្វហ្គានីស្ថាន ប៊ូតាណ នេប៉ាល់ និងភូមាមានភូមិសាស្ត្រដែលលំបាកចូលដល់។ ដោយសារ ការសាងសង់ផ្លូវត្រូវចំណាយច្រើន ប្រទេសទាំងនេះអាចតភ្ជាប់ទំនាក់ទំនងតំបន់ជាច្រើនរបស់ខ្លួនតែតាមយន្តហោះ ឬតាមផ្លូវវាងកោងដ៏លំបាក ជាការបន្ថែមចំណាយទៅលើការធ្វើជំនួញ។ ការអភិវឌ្ឍសេដ្ឋកិច្ចក៏ប្រព្រឹត្តទៅយឺតផងដែរ បើប្រជាជនរស់នៅដាច់ឆ្ងាយពីគ្នា ទោះបីនៅតាមទីភ្នំ ឬតាមកោះដែលស្ថិតនៅដាច់ពីគ្នាឧទាហរណ៍ នៅម៉ាល់ឌីវ ឬកោះសូឡូម៉ុង។ ប្រការនេះមិនត្រឹមតែធ្វើឱ្យមានការលំបាកក្នុងការផ្តល់សេវាសង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ពន្យឺតការធ្វើសមាហរណកម្មសេដ្ឋកិច្ចផងដែរ។

ស្ថានភាពភូមិសាស្ត្រជាឧបសគ្គមិនត្រឹមតែសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ការធ្វើពាណិជ្ជកម្មអន្តរជាតិផងដែរ។ ប្រទេសជាច្រើនដែលមិននៅជាប់សមុទ្រប្រឈមនឹងថ្លៃខ្ពស់នៃការដឹកជញ្ជូន ដែលកាត់បន្ថយប្រាក់ចំណូលពីការនាំចេញ ដោយបន្ថែមចំណាយលើការនាំចូល។ ប្រទេសទាំងនេះក៏ងាយរងគ្រោះចំពោះការផ្លាស់ប្តូរគោលនយោបាយនៅក្នុងប្រទេសជិតខាងផងដែរ ដែលទំនិញរបស់ខ្លួនត្រូវឆ្លងកាត់ប្រទេសទាំងនោះ។

ប៉ុន្តែស្ថានភាពភូមិសាស្ត្រអាចរាំងស្ទះពាណិជ្ជកម្មសូម្បីតែប្រទេសដែលជាប់នឹងឆ្នេរសមុទ្រ។ ប្រទេសក្រីក្រជាងគេទំនងជាមានតែកំពង់ផែចម្បងៗមួយចំនួនតូច ដូច្នេះ អ្នកនាំចេញដែលស្ថិតនៅឆ្ងាយពីកំពង់ផែទាំងនោះត្រូវបាត់បង់ភាពប្រកួតប្រជែង។ តាមពិត ប្រសិនបើបរិមាណទំនិញត្រូវនាំចេញពុំមានច្រើនគ្រប់គ្រាន់សម្រាប់នាវាចូលផ្ទុក អ្នកនាំចេញអាចត្រូវប្រើប្រាស់កំពង់ផែនៃប្រទេសជិតខាង។[៥]

*LDCs ដែលមាន សេដ្ឋកិច្ចតូចអាចមើលឃើញថា ខ្លួនចាញ់ប្រៀបជាច្រើន*

ដូច្នេះ LDCs ដែលមានសេដ្ឋកិច្ចតូច អាចប្រឈមនឹងការបាត់បង់ភាពប្រកួតប្រជែងដោយសារថ្លៃចំណាយខ្ពស់ជាងជាច្រើនដង។ ការប៉ាន់ស្មានមួយបង្ហាញថា សេវាទូរស័ព្ទ សេវាអគ្គិសនី និងការធ្វើដំណើរនៅក្នុងរដ្ឋតូចៗ ត្រូវចំណាយប្រហែលពីរដងធៀបនឹងអត្រាមធ្យមក្នុងប្រទេសដែលមានទំហំមធ្យម ដែលបង្កជាបន្ទុកចំពោះពាណិជ្ជកម្ម ដោយការចំណាយដឹកទំនិញតាមសមុទ្រអាចមានបីដងខ្ពស់ជាង។[៦]

LDCs ក៏រងគ្រោះផងដែរនៅក្នុងពាណិជ្ជកម្មអន្តរជាតិដោយសារប្រទេសទាំងនោះជាការីតូចតាច។ សម្រាប់មុខទំនិញនីមួយៗ ប្រទេសទាំងនោះអាចរួមចំណែកតិចតួចបំផុតទៅក្នុងទីផ្សារពិភពលោក ដូច្នេះ គេមិនមានឥទ្ធិពលទៅលើថ្លៃជាអន្តរ-ជាតិឡើយ។ នេះមានន័យថាប្រទេសទាំងនោះក្លាយជា "អ្នកទទួលយកថ្លៃ" និងទទួលអ្វីដែលផ្តល់ឱ្យតែប៉ុណ្ណោះ។ ប្រសិនបើ

ផលិតករផ្សេងទៀតបង្កើតផលិតផល ពួកគេអាចរុញច្រានថ្លៃអន្តរជាតិឱ្យចុះទាប ធ្វើឱ្យ LDCs បាត់បង់ប្រាក់ចំណេញ ដែលខ្លួនមានតិចស្រេចហើយនោះ។ ក្នុងរយៈពេលខ្លី ប្រការនេះអាចធ្វើឱ្យមានការប៉ះទង្គិចខាងសេដ្ឋកិច្ចឬសម្រាប់រយៈពេលវែងគឺរុញច្រានប្រទេសទាំងនោះទៅក្នុង "ចំណងនៃភាពក្រីក្រ" ។[៧]

ប្រទេសទាំងនោះក៏ងាយរងគ្រោះផងដែរ ប្រសិនបើពួកគេមានការនាំចេញក្នុងកម្រិតកំណត់។ LDCs ត្រូវតែបង្កើតឯកទេសលើផលិតផលដែលខ្លួនមានឧត្តមភាព ហើយជាលទ្ធផល ប្រទេសជាច្រើននៅតែពឹងផ្អែកលើទំនិញជាកសិផល។ ឧទាហរណ៍ សម្រាប់គីរីបាទី កសិផលមានប្រមាណជិត ៨៩% នៃការនាំចេញសរុប និងសម្រាប់វ៉ាណាទូ ៥៤%។[៨] សូម្បីតែប្រទេសដែលនាំចេញផលិតផលឧស្សាហកម្មច្រើនតែផ្តោតតែលើវិស័យតែមួយ ដូចជាវាយនភណ្ឌ និងសម្លៀកបំពាក់ ដែលនៅក្នុងឆ្នាំ២០០៣ មាន ៤០%នៃការនាំចេញពីប្រទេសនេប៉ាល់ ៧៦% ពីបង់ក្លាដេស និង ៩៥% ពីកម្ពុជា។ ក្នុងចំណោមផលិតផល ៤.១៦២មុខ ដែលនាំចេញដោយ LDCs ទៅដៃគូពាណិជ្ជកម្មចម្បងៗចំនួន៣០ នៅក្នុងឆ្នាំ២០០០ ផលិតផលចំនួន ១២៧មុខ មានប្រមាណ ៩០% នៃពាណិជ្ជកម្មនាំចេញរបស់ប្រទេសទាំងនោះ។[៩] សម្រាប់ LDCs ទាំងអស់ អត្រាប្រមូលផ្តុំនៃការនាំចេញ ដែលជាសមាមាត្រនៃផលិតផលនាំចេញចម្បង១ធៀបនឹងតម្លៃនៃការនាំចេញសរុបនៅតែមានកម្រិតខ្ពស់ និងពុំសូវមានការប្រែប្រួលទេតាំងពីឆ្នាំ១៩៨០ មក។[១០]

សមាហរណកម្មសេដ្ឋកិច្ចក៏មានឥទ្ធិពលតិចតួចប៉ុណ្ណោះទៅលើភាពក្រីក្រ ដោយសារមានការលើកទឹកចិត្តតែលើកំណើននៃ "វិស័យមួយតូច" ។ វិស័យខ្លះបានអនុវត្តល្អជាបង្គួរ ប៉ុន្តែវិស័យដទៃទៀតពុំធ្វើបានល្អដូចគ្នាឡើយ។ សូម្បីតែវិស័យនាំចេញកសិផល ទំនងជាមានទំនាក់ទំនងតិចតួចជាមួយសកម្មភាពកសិកម្មតូចតាចដែលមនុស្សភាគច្រើន ពឹងផ្អែកសម្រាប់ការរស់នៅ។

ក្នុងកាលៈទេសៈបែបនេះអាចមានភាពពុំច្បាស់លាស់ ពីមូលហេតុដែល LDCs អាចចង់ចូលជាសមាជិក WTO និងសេរីភាវូបនីយកម្មទៅអនាគត ដែលទាក់ទងនឹងប្រការខាងលើនេះ។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ប្រទេសភាគច្រើន ជម្រើសផ្សេងមានភាពអាក្រក់ជាងទៅទៀត ដោយសារការដាក់ឱ្យនៅក្រៅសេវៀន ឬការត្រួតត្រាទ្វេភាគីធ្វើឡើងដោយប្រទេសមានអំណាចចម្បងមួយឬពីរប៉ុណ្ណោះ។ អង្គការ WTO ពហុភាគីនៅតែជាជម្រើសប្រសើរជាង ប្រសិនបើវាផ្តល់បទបញ្ញាជាមូលដ្ឋានដែលមានសង្គតិភាព។[១១] ការចូលជាសមាជិក WTO អាចផ្តល់នូវ :

- កាតព្វកិច្ចឱ្យមានគោលនយោបាយមិនផ្លាស់ប្តូរ
- លទ្ធភាពព្យាករណ៍អំពីការប្រើប្រាស់ទីផ្សារ
- ជារបាំងទល់នឹងសម្ពាធឯកតោភាគីពីប្រទេសមានអំណាច
- លទ្ធភាពប្រើប្រាស់យន្តការដ៏មានប្រសិទ្ធិភាពសម្រាប់ដោះស្រាយជម្លោះ
- ការរំពឹងទុកពីតួនាទីក្នុងការកែសម្រួលពាណិជ្ជកម្មពិភពលោកទៅអនាគត។

## បទពិសោធជាមួយសមាហរណកម្មពាណិជ្ជកម្ម

កាលពីអតីតកាល LDCs ភាគច្រើនធ្វើសេរីភាវូបនីយកម្មជាឯកតោភាគី។ ប៉ុន្តែទៅអនាគត ការធ្វើបែបនេះទំនងជានឹងកើតឡើងផ្អែកលើគោលការណ៍ទៅវិញទៅមក ពហុភាគី កម្រិតតំបន់ ឬទ្វេភាគី។ ជម្រើសពហុភាគីចម្បងរបស់ប្រទេសទាំងនោះគឺ WTO ដែលឥឡូវនេះមានសមាជិកចំនួន ១៤៩។ ក្នុងចំណោម LDCs ចំនួន ៥០ប្រទេស ឥឡូវនេះ ៣២

*សមាហរណកម្មសេដ្ឋកិច្ចក៏មានឥទ្ធិពលតិចតួចប៉ុណ្ណោះទៅលើភាពក្រីក្រ ដោយសារមានការលើកទឹកចិត្តតែលើកំណើននៃ "វិស័យមួយតូច"*

បានក្លាយជាសមាជិក WTO ទៅហើយ ចំណែក ៨ ផ្សេងទៀតកំពុងស្នើសុំចូលជាសមាជិក។ LDCs មួយចំនួនតូចនៅអាស៊ីដូចជាបង់ក្លាដេស គឺជាសមាជិកដែលបានចុះហត្ថលេខាបង្កើតអង្គការនេះនៅឆ្នាំ ១៩៩៤ ប៉ុន្តែ ប្រទេសដទៃទៀតបានចូលរួមនៅពេលក្រោយមក។ ក្នុងចំណោម LDCs នៅអាស៊ី-ប៉ាស៊ីហ្វិក បង់ក្លាដេស កម្ពុជា ម៉ាល់ឌីវ ភូមា នេប៉ាល់ កោះសូឡូម៉ុង បានក្លាយជាសមាជិករួចទៅហើយ ចំណែកប៊ូតាណ ឡាវ សាម៉ាវ និងវ៉ាណាទូ កំពុងរៀបចំដើម្បីចូលរួមជាសមាជិក។

LDCs ជាច្រើនជួបការលំបាកដើម្បីចូលជាសមាជិក។ ពួកគេខ្វះអ្នកចេះដឹងដែលចាំបាច់ដើម្បីយល់អំពីផលវិបាកនៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម ទាំងកាតព្វកិច្ចខាងគោលនយោបាយ និងភាពទន់ភ្លន់នៃគោលនយោបាយ។ សូម្បីតែ LDCs មួយចំនួនតូចនៅអាស៊ី-ប៉ាស៊ីហ្វិក ដែលមានស្ថានបេសកកម្មនៅទីក្រុងហ្សឺណែវ អាចផ្តល់តែបុគ្គលិកមួយចំនួនតូចប៉ុណ្ណោះនៅក្នុងការចរចារបស់ WTO។ ជាលទ្ធផល សូម្បីតែតំណាងផ្លូវការអាចពុំមានលទ្ធភាពទាញយកកាលានុវត្តភាពនៅក្នុងពេលចរចាឡើយ ហើយអាចចុះកិច្ចព្រមព្រៀងដែលកាត់បន្ថយផលប្រយោជន៍ជាតិ និង អាទិភាពអភិវឌ្ឍន៍មនុស្ស។

*បទបញ្ជារបស់ WTO មានឥទ្ធិពលទៅលើគោលនយោបាយជាតិ រួមទាំងប្រការជាច្រើន ដែលសំខាន់សម្រាប់ការអភិវឌ្ឍមនុស្ស*

ភាពខ្វះខាតដូចគ្នានេះដែលបានបង្ហាញយ៉ាងច្បាស់នៅក្នុងអង្គការសង្គមស៊ីវិល។ អង្គការទាំងនោះក៏ខ្វះធនធាន និងសមត្ថភាពសម្រាប់ការស្រាវជ្រាវឯកទេស ហើយមានអង្គការមួយចំនួនតូចប៉ុណ្ណោះដែលអាចធ្វើការតស៊ូមតិនៅកម្រិតគោលនយោបាយ។ ជាលទ្ធផល ពួកគេអាចត្រូវបង្កើតយុទ្ធសាស្ត្រសម្រាប់យុទ្ធនាការរបស់ខ្លួនដោយផ្អែកលើការយល់ឃើញរបស់ខ្លួនអំពីថាតើកិច្ចព្រមព្រៀងពាណិជ្ជកម្មដំណើរការបែបណា ដែលអាចមិនស្របនឹងភាពជាក់ស្តែង។ ស្ថានភាពនេះកាន់តែលំបាកសម្រាប់ LDCs ដែលឥឡូវនេះកំពុងព្យាយាមចូលរួមជាសមាជិក។ ដោយសារបទបញ្ជាសម្រាប់ការចូលជាសមាជិក WTO មិនបញ្ជាក់ច្បាស់លាស់ សមាជិកបច្ចុប្បន្នអាចមានលទ្ធភាពដាក់លក្ខខណ្ឌជាបន្ទុកដល់ប្រទេសដែលសុំចូលថ្មី។ ពួកគេព្យាយាមដើម្បីទាញយកសម្បទានអតិបរមាដោយសារហេតុផលចំនួនបីគឺ : ទីមួយ ដោយសារប្រការនេះអាចជួយពួកគេបង្កើតលក្ខខណ្ឌដំបូងសម្រាប់អ្នកសុំលើកក្រោយទៀត។ ទីពីរ ដោយសារវាផ្តល់អត្ថប្រយោជន៍ដល់សមាជិកទាំងនោះដែលខ្លួនពុំចាំបាច់ចាត់វិធានការឆ្លើយតប។ ទីបី ដោយសារពួកគេអាចប្រើប្រាស់លក្ខខណ្ឌទាំងនេះជាឧបករណ៍នៅក្នុងការចរចាពាណិជ្ជកម្មពហុភាគីនៅពេលក្រោយ។

លក្ខខណ្ឌបន្ថែមដែលពួកគេយកមកប្រើវិធានពីរបែប គឺ "WTO-ដក" និង "WTO-បូក"។ លក្ខខណ្ឌ WTO-ដក ជាបណ្តាលក្ខខណ្ឌដែលរាំងស្កាត់អ្នកមកដល់ថ្មីពីការទាញយកអត្ថប្រយោជន៍ពីសិទ្ធិមួយចំនួនដែលមាននៅក្នុងកិច្ចព្រមព្រៀង WTO ដែលសមាជិកបច្ចុប្បន្នកំពុងទទួលបាន។ លក្ខខណ្ឌ WTO -បូក ជាកាតព្វកិច្ចបន្ថែមដែលមិន មែនជាលក្ខខណ្ឌនៃ WTO ឬដែលពុំបានអនុវត្តដោយសមាជិកបច្ចុប្បន្នរបស់ WTO។

លក្ខខណ្ឌទាំងនេះអាចមានឥទ្ធិពលធ្ងន់ធ្ងរ ដោយសារបទបញ្ជារបស់ WTO ដែលមិនដូចលក្ខខណ្ឌរបស់ GATT តែមានឥទ្ធិពលទៅលើគោលនយោបាយជាតិ រួមទាំងប្រការជាច្រើន ដែលសំខាន់សម្រាប់ការអភិវឌ្ឍមនុស្ស។

ឥឡូវនេះ ប្រទេសក្រីក្រដែលចូលជាសមាជិក WTO កាន់តែមានការលំបាកខ្លាំងឡើងដើម្បីទទួលការយកចិត្តទុកដាក់ពិសេស និងខុសគ្នា ដើម្បីពួកគេអាចពន្យាកាតព្វកិច្ចខ្លះ។

ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងខ្លះនៅក្នុង WTO ពិតជាផ្តល់សេរីភាពខាងគោលនយោបាយ។ ឧទាហរណ៍ កិច្ចព្រមព្រៀងទូទៅអំពីពាណិជ្ជកម្មខាងសេវា គោរពសិទ្ធិរបស់សមាជិកក្នុងការអនុវត្តគោលបំណងអភិវឌ្ឍន៍មនុស្សដោយអនុញ្ញាតឱ្យពួកគេរក្សាទុកលក្ខខណ្ឌខ្លះៗ ទាក់ទងនឹងលទ្ធភាព

ប្រើប្រាស់ទីផ្សារនិងការចាត់ចែងរបស់ជាតិ។ សូម្បីតែនៅពេលនៃការសុំចូលជាសមាជិក ប្រទេសខ្លះបានប្រើប្រាស់កាលានុវត្តភាពនេះ ដើម្បីចរចាលក្ខខណ្ឌសមស្របខ្លះៗ ( ប្រអប់ ៦.១) ។

ទោះបីការទាមទារទាំងនេះលើប្រទេសដែលសុំចូលថ្មីគ្របដណ្តប់បញ្ហាជាច្រើនក្តី គេអាចចែកចេញជាពីរក្រុម គឺក្រុមដែលទាក់ទងនឹងសេរីភាពខាងនយោបាយ និងក្រុមដែលទាក់ទងនឹងបញ្ហាជាប្រព័ន្ធ។

## សេរីភាពខាងនយោបាយ

ប្រការនេះសំដៅលើការដាក់កំហិតលើសេរីភាពនៃចំណាត់ការ។ ជាទូទៅ អ្នកបង្កើត និងសមាជិកបច្ចុប្បន្ន បានរក្សាទុកសេរីភាពជាច្រើនក្នុងការចាត់ចែង ទន្ទឹមនឹងការផ្តល់ឱ្យអ្នកចូលថ្មីនូវវិសាលភាពតូចជាង។ ពួកគេប្រើប្រាស់ឧបករណ៍មួយចំនួនដែលគាបសង្កត់សេរីភាពខាងគោលនយោបាយនៃសមាជិកដែលសុំចូលថ្មី រួមទាំង :

- *អត្រាពន្ធ* : បញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗគឺភាពទន់ភ្លន់ក្នុងការផ្លាស់ប្តូរអត្រាពន្ធ។ ប្រសិនបើនៅក្នុង WTO សមាជិកណាមួយមាន "ចំណង" អត្រាពន្ធ ប្រទេសនោះត្រូវមានការប្តេជ្ញាមិនបង្កើនពន្ធនេះហួសអត្រាកំណត់ឡើយ។ សមាជិកភាគច្រើនដែលជាប្រទេសកំពុងអភិវឌ្ឍន៍មានកាតព្វកិច្ចខ្លះ ប៉ុន្តែមិនមែនគ្រប់ខ្ទង់នៃអត្រាពន្ធទាំងអស់ឡើយ និងអាចបង្កើនអត្រាពន្ធនោះយ៉ាងខ្ពស់ ប្រសិនបើកាលៈទេសៈតម្រូវឱ្យធ្វើបែបនោះ។ តាមពិត ប្រទេសខ្លះនៅអាហ្វ្រិកមានចំណងខ្ទង់ខ្លះនៃអត្រាពន្ធ។ ឧទាហរណ៍ ប្រទេសតង់ហ្សានី និងកាមេរូនគឺ 0.9% ម៉ូហ្សំប៊ិក-0.៥% តូហ្គោ 0.៩% និងហ្គាណា ១.២%។[១៦] ម្យ៉ាងវិញទៀត ប្រទេសដែលសុំចូលទាំងអស់ត្រូវបានស្នើឱ្យដាក់ចំណងលើអត្រាពន្ធស្ទើរតែគ្រប់ខ្ទង់ទាំងអស់។

ប្រអប់ ៦.១

### ការប្រុងប្រយ័ត្នរបស់នេប៉ាល់ក្នុងការធ្វើសេរីភាវូបនីយកម្មសេវាកម្ម

នៅពេលសុំចូលជាសមាជិក WTO នេប៉ាល់ធ្វើសេរីភាវូបនីយកម្មវិស័យសេវាចំនួន ១១ និង ៧០ វិស័យរង។ តួលេខនេះដូចជាច្រើន ប៉ុន្តែនេប៉ាល់បានចាត់ចែងដើម្បីចរចាសេរីភាវូបនីយកម្មសម្រាប់តែក្រុមសេវាមួយចំនួនតែប៉ុណ្ណោះ។ ទីមួយ វិស័យដែលផ្នែកឯកជនរបស់នេប៉ាល់អាចនឹងមិនចូលរួមទាល់តែសោះ ដោយសារថ្លៃវិនិយោគខ្ពស់ និងរយៈពេលវែងមុនរកចំណេញបាន ដូចជា ការដឹកជញ្ជូនតាមបំពង់។ ទីពីរ វិស័យដែលផ្នែកឯកជននេប៉ាល់មានភាពប្រកួតប្រជែងរួចទៅហើយ និងដែលអាចប្រជែងអ្នកផ្គត់ផ្គង់សេវាពីបរទេស ដូចជាសេវាធនាគារ។ ទីបី វិស័យដែលមានសក្តានុពលខ្ពស់សម្រាប់ជួលមនុស្សក្នុងស្រុក ដូចជាកុំព្យូទ័រនិងសេវាពាក់ព័ន្ធ។

វិធានការមួយចំនួនផ្សេងទៀតនៃការដាក់កំហិតដែលរដ្ឋាភិបាលនេប៉ាល់បានចរចារួមមាន:

(ក) ដាក់កម្រិតលើការវិនិយោគបរទេសក្នុងវិស័យភាគច្រើនត្រឹម ៥១% ចំណែកក្នុងវិស័យផ្សេងទៀតត្រឹម ៦៦-៦៧% និងមានតែវិស័យចំនួនពីរដែលអត្រានេះឈានដល់ ៨០%។

(ខ) តម្រូវឱ្យភាគច្រើននៃសមាជិកក្រុមប្រឹក្សាអ្នកផ្តល់ទូរគមនាគមន៍ជាមូលដ្ឋាន គឺជាជនជាតិនេប៉ាល់ ហើយក្នុងករណីគ្រឹះស្ថានហិរញ្ញវត្ថុ សមាសភាពនៃក្រុមប្រឹក្សាគួរតែសមាមាត្រទៅនឹងទម្រង់នៃភាគហ៊ុន។

(គ) ធនាគារបរទេសក្នុងក្រុម 'B' ដែលចាត់ថ្នាក់ដោយទីភ្នាក់ងារចាត់ថ្នាក់ឥណទាន ទើបអាចបង្កើតសាខានៅប្រទេសនេប៉ាល់សម្រាប់លក់ដុំតាមធនាគារ តែមិនលក់រាយតាមធនាគារ។

(ឃ) ការលើកទឹកចិត្ត និងការឧបត្ថម្ភធនអាចមានសម្រាប់តែសហគ្រាសដែលជាកម្មសិទ្ធិរបស់ជនជាតិនេប៉ាល់ទាំងស្រុង។

(ង) មិនអនុញ្ញាតឱ្យជនបរទេសទិញ ឬមានកម្មសិទ្ធិដីក្នុងប្រទេសនេប៉ាល់

(ច) ការផ្លាស់ទីរបស់រូបវន្តបុគ្គល ត្រូវបានអនុញ្ញាតត្រឹមតែការផ្ទេរនៅក្នុងសាជីវកម្មថ្នាក់នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬអ្នកឯកទេស ហើយដែលចំនួនអ្នកផ្ទេរបែបនេះ មិនច្រើនជាង ១៥% នៃចំនួននិយោជិតនៅក្នុងក្រុមហ៊ុននោះឡើយ។

**ប្រភព : Adhikari ២00៤។**

- *ពន្ធ ឬកម្រៃផ្សេងទៀត* : ដូចគ្នានេះដែរ សមាជិកជាច្រើនរបស់ WTO នៅតែរក្សា "ពន្ធ ឬកម្រៃផ្សេងទៀត (ODCs)" និងពុំដែលមានការស្នើសុំឱ្យលុបចោលនោះឡើយ ។[១៣] ម្យ៉ាងវិញទៀត ប្រទេសដែលសុំចូល ត្រូវបានស្នើសុំឱ្យដាក់ចំណង ODCs នៅត្រឹមសូន្យ ឬលុបចោលនៅក្នុងរយៈពេលខ្លី ។ តែតាមការពិតប្រទេសដែលសុំចូលនិងដែលត្រូវបានអនុញ្ញាតឱ្យរក្សាទុក ODCs តាមកាលកំណត់ដែលឯកភាពគ្នាមុនពេលលុបចោលទាំងស្រុង គឺ ប៊ុលការី[១៤] និងនេប៉ាល់[១៥] ។ តែប្រទេសផ្សេងទៀតទាំងអស់ត្រូវបានតម្រូវឱ្យមានចំណងពន្ធដល់កម្រិតសូន្យនៅកាលបរិច្ឆេទនៃការចូល ។
- *ការយកចិត្តទុកដាក់ពិសេសនិងខុសគ្នា* : WTO

ប្រអប់ ៦.២

### មាត្រាចែងពីការយកចិត្តទុកដាក់ពិសេសនិងខុសគ្នានៅក្នុង WTO

ប្រទេសកំពុងអភិវឌ្ឍន៍បានទទួលភាពបត់បែនខ្លះៗក្នុងការដាក់ពាក្យសុំជា សមាជិកភាពនៃ WTO តាមរយៈការយកចិត្តទុកដាក់ពិសេសនិងខុសគ្នា (SDT) ។ ការយកចិត្តទុកដាក់នេះ ទាក់ទងនឹងមាត្រាដែលជាប់កាតព្វកិច្ច និងមិនជាប់កាតព្វកិច្ច ។

**មាត្រាជាប់កាតព្វកិច្ច**

ប្រការខ្លះអាចអនុវត្តបានជាឯកតោភាគីដោយពុំចាំបាច់រងចាំការដាក់វិធានការ ដោយប្រទេសដទៃ ។ នៅក្នុងផ្នែកនេះ មាន SDT ពីរបែប :

(ក) អនុញ្ញាតឱ្យប្រទេសកំពុងអភិវឌ្ឍន៍មានកាតព្វកិច្ចតិចជាង ។ ឧទាហរណ៍ ក្នុងកិច្ចព្រមព្រៀងអំពីកសិកម្ម កម្រិតអប្បបរមានៃការគាំទ្រក្នុងស្រុកចំពោះកសិកម្ម គឺ ៥% ប៉ុន្តែសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ មានដល់ ១០% ។ ដូចគ្នានេះដែរ ប្រទេសជឿនលឿនត្រូវកាត់បន្ថយពន្ធ ៣៦% ប៉ុន្តែប្រទេសកំពុងអភិវឌ្ឍន៍ត្រឹម ២៤% ។ ចំពោះការកាត់បន្ថយការឧបត្ថម្ភធន សមាមាត្រនេះគឺ ២០% និង ១៣% ។

(ខ) ផ្តល់រយៈពេលអន្តរកាលដែលខ្ពស់ជាងសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ។ ឧទាហរណ៍ ក្នុង TRIPS ប្រទេសជឿនលឿនមានរយៈពេលអន្តរកាលត្រឹមមួយឆ្នាំ ដើម្បីអនុវត្តការប្តេជ្ញា ចំណែកប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានផ្តល់រហូតដល់ ៥ ឆ្នាំ ហើយ LDCs បានទទួលការអនុគ្រោះបន្ថែមទៀត ។

មាត្រាជាប់កាតព្វកិច្ចផ្សេងទៀតទាមទារចំណាត់ការពីប្រទេសដទៃជាពិសេស ប្រទេសជឿនលឿន ។ ឧទាហរណ៍ មាត្រា ៦៦.២ នៃ TRIPS ទាមទារឱ្យសមាជិកជាប្រទេសជឿនលឿន ផ្តល់ការលើកទឹកចិត្តដល់សហគ្រាស និងគ្រឹះស្ថាននានានៅក្នុងដែនដីរបស់ខ្លួនសំដៅលើកកម្ពស់ និងលើកទឹកចិត្តឱ្យមានការផ្ទេរបច្ចេកវិទ្យាទៅ LDCs ។

**មាត្រាមិនជាប់កាតព្វកិច្ច**

មានប្រការដែលត្រូវបានទទួលស្គាល់ថាជាកិច្ចប្រឹងប្រែងខ្លាំងក្លា ។ សម្រាប់ ប្រការទាំងនេះ សម្បទាន SDTs ត្រូវបានចែកជាបីបែប :

(ក) ទាមទារឱ្យសមាជិក WTO ការពារផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាក្នុងករណីកិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យ (SPS) ដែលទាមទារឱ្យសមាជិកគិតគូរពីតម្រូវការពិសេសរបស់ ប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិក LDCs ។

(ខ) ទាមទារឱ្យប្រទេសជឿនលឿនផ្តល់ជំនួយបច្ចេកទេសដល់ប្រទេសកំពុងអភិវឌ្ឍន៍ និង LDCs ។ ឧទាហរណ៍ កិច្ចព្រមព្រៀង ស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម (TBT) ទាមទារឱ្យសមាជិកនានាផ្តល់ជំនួយបច្ចេកទេសដល់ប្រទេសកំពុងអភិវឌ្ឍន៍ និង LDCs ស្តីពីលក្ខខណ្ឌដែលមានការឯកភាពទៅវិញទៅមក សម្រាប់បង្កើតទីភ្នាក់ងារស្តង់ដារជាតិ ។

(គ) ទាមទារឱ្យប្រទេសជឿនលឿនបង្កើនកាលានុវត្តភាពពាណិជ្ជកម្មរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និង LDCs ។ ឧទាហរណ៍ ត្រូវផ្តល់លទ្ធភាពប្រើប្រាស់ទីផ្សារ ដូចមាត្រា XXXVII នៃ GATT ដែលតម្រូវឱ្យសមាជិកជាប្រទេសជឿនលឿន ផ្តល់អាទិភាព ដើម្បីកាត់បន្ថយ និងលុបបំបាត់របាំងចំពោះផលិតផលបច្ចុប្បន្ន និងសក្តានុពលនៃផលប្រយោជន៍ពីការនាំចេញទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក ។

ទទួលស្គាល់ថាប្រទេសកំពុងអភិវឌ្ឍន៍អាចមានការលំបាកអនុវត្តការប្តេជ្ញា និងកាតព្វកិច្ចជាច្រើន។ ដូច្នេះ អង្គការនេះបានផ្តល់ឱ្យប្រទេសទាំងនោះនូវរយៈពេលអនុគ្រោះវែងមុនពេលដែលត្រូវគោរពតាមកិច្ចព្រមព្រៀង (ប្រអប់ ៦.២)។ សមាជិកបច្ចុប្បន្នរបស់WTO មានសិទ្ធិ "ទទួលការយកចិត្តទុកដាក់ពិសេស និងខុសគ្នា"ដោយស្វ័យប្រវត្តិ ប៉ុន្តែប្រទេសដែលសុំចូលត្រូវចរចាប្រការទាំងនេះតាមករណីនីមួយដាច់ដោយឡែកពីគ្នា ហើយភាគច្រើនបានត្រូវបានបដិសេធសិទ្ធិបែបនេះ។

- *ពន្ធលើការនាំចេញ* : WTO ពុំដាក់កាតព្វកិច្ចលើសមាជិកជាចំណង កាត់បន្ថយ ឬលុបចោលពន្ធលើការនាំចេញឡើយ ហើយសមាជិកទាំងអស់អាចជៀសវាងការទទួលចំណងនេះ។ ទោះជាយ៉ាងណាក៏ដោយប្រទេសខ្លះដែលសុំចូល ត្រូវបានបង្ខំឱ្យលុបចោលពន្ធលើការនាំចេញ ឬចងនៅត្រឹមកម្រិតណាមួយ។
- *សេរីភាវូបនីយកម្មសេវា* : នៅក្នុងវិស័យសេវាកម្មខ្លះៗ ប្រទេសដែលសុំចូលត្រូវបានស្នើសុំឱ្យដាក់ការប្តេជ្ញាយ៉ាងច្រើនជាងប្រទេសជាសមាជិកស្រាប់។
- *កិច្ចការពារកម្មសិទ្ធិបញ្ញា* : ដើម្បីការពារពូជរុក្ខជាតិថ្មីៗ ប្រទេសកំពុងអភិវឌ្ឍន៍ច្រើនតែចង់ប្រើប្រាស់ប្រព័ន្ធរបស់ខ្លួនដែលសមស្របគ្នាជាងធៀបនឹងតម្រូវការខាងសង្គម សេដ្ឋកិច្ច និងបរិស្ថាន។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសជឿនលឿនអះអាងថា ប្រព័ន្ធដែលមានប្រសិទ្ធិភាពតែមួយគត់គឺជាប្រព័ន្ធរបស់សហភាពអន្តរជាតិសម្រាប់ការពារពូជថ្មីនៃរុក្ខជាតិ (UPOV) និងព្យាយាមដាក់ឱ្យប្រើប្រាស់គំរូរបស់ខ្លួនទៅលើគ្រប់ប្រទេសដែលសុំចូល។[១៦] ឧទាហរណ៍ ចិន និងកម្ពុជា ត្រូវបានបញ្ចុះបញ្ចូលឱ្យចុះហត្ថលេខាលើ UPOV ជាចំណែកមួយនៃការចូលជាសមាជិក ប៉ុន្តែនេប៉ាល់ អាចការពារពីសម្ពាធនេះបានដោយសារកិច្ចប្រឹងប្រែងរួមគ្នារបស់រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ ទោះបីវិធានការការពារទិន្នន័យមិនមានចែងដោយ TRIPS ក៏ដោយ សមាជិកថ្មីត្រូវបានតម្រូវឱ្យអនុវត្តមាត្រានេះ ដូចជា ប្រទេសកម្ពុជា (ប្រអប់ ៦.៣)។
- *កិច្ចព្រមព្រៀងច្រើនភាគី* : នេះជាការប្តេជ្ញាដែលមានការឯកភាពដោយសមាជិកតែមួយចំនួនតូចប៉ុណ្ណោះ នៅពេលបង្កើតអង្គការ WTO។ ឥឡូវនេះ សមាជិកខ្លះទាមទារឱ្យប្រទេសចូលថ្មីឯកភាពទទួលកិច្ចព្រមព្រៀងនេះ ឬយ៉ាងហោចណាស់ចូលធ្វើការចរចាដើម្បីទទួលយកកិច្ចព្រមព្រៀងនេះ។ ឧទាហរណ៍ វ៉ាណាទូ ត្រូវឯកភាពទទួលយកការទាមទារនេះ។[១៧]

## បញ្ហាជាលក្ខណៈប្រព័ន្ធ

ការទាមទារដោយ WTO ក៏ទាក់ទងផងដែរជាមួយបញ្ហាជាមូលដ្ឋានគ្រឹះខ្លះៗ ដែលមានឥទ្ធិពលលើការចាត់ចែងសេដ្ឋកិច្ច។ ការទាមទារទាំងនោះរួមមាន :

ប្រអប់ ៦.៣

### TRIPS និងវិបត្តិសុខភាពសាធារណៈនៅក្នុងប្រទេសកម្ពុជា

តាមការប្រមាណ ២.៨% នៃមនុស្សពេញជំទង់ក្នុងប្រទេសកម្ពុជា ឆ្លងជម្ងឺ HIV/AIDS ជាអត្រាមួយខ្ពស់នៅអាស៊ី។ ជនទាំងនេះរាប់ពាន់នាក់បានបាត់បង់ជីវិតរួចទៅហើយ និងក្នុងអំឡុងប្រាំទៅដប់ឆ្នាំខាងមុខ មនុស្ស ២០០.០០០នាក់ រួមទាំងកុមារ អាចឆ្លងជម្ងឺ HIV/AIDS (Ouyahia-McAdams ២០០២)។

ការប្រយុទ្ធប្រឆាំងជម្ងឺ HIV/AIDS ទាមទារឱ្យមានការផ្តល់ថ្នាំប្រឆាំងវីរុស ដើម្បីពន្យារជីវិត។ ប្រទេសកម្ពុជាបានប្រឈមយ៉ាងខ្លាំងចំពោះបញ្ហានេះរួចទៅហើយ ដែលរហូតមកដល់ពេលថ្មីៗនេះ ទីភ្នាក់ងារមនុស្សធម៌ និង NGOs បានផ្តល់ថ្នាំដល់អ្នកជម្ងឺត្រឹម ៧០០នាក់ប៉ុណ្ណោះ (Macan-Marker ២០០៣)។ ប៉ុន្តែ ការចូលជាសមាជិក WTO ធ្វើឱ្យបញ្ហានានាកាន់តែលំបាក។ ក្នុងពេលចរចា ប្រទេសម្ពុជាត្រូវបានបង្ខំតាមលក្ខខណ្ឌរបស់ WTO ឱ្យឯកភាពដើម្បីការពារការសាកល្បងដែលមិនបើកឱ្យដឹង និងទិន្នន័យផ្សេងទៀតអំពីផលិតផលឱសថសម្រាប់រយៈពេល ៥ឆ្នាំ។ នេះគឺជាមហន្តរាយ ចំពោះកិច្ចប្រឹងប្រែងរបស់កម្ពុជា ដើម្បីប្រយុទ្ធនឹង HIV/AIDS សម្រាប់អំឡុងពេលនៃប៉ាតង់ ប្រទេសកម្ពុជា មិនទាំងអាចប្រើប្រាស់ទិន្នន័យសាកល្បងដើម្បីវាយតម្លៃថ្នាំសមមូលគ្នា ដើម្បីត្រៀមសម្រាប់ពេលដែលអស់សុពលភាពនៃប៉ាតង់។ ជាជំនួស ផលិតផលសមមូល ឬក្រុមហ៊ុននាំចូលត្រូវធ្វើការសាកល្បងឡើងវិញ ដែលត្រូវចំណាយច្រើន និងទាមទាមពេលវេលាយូរ បើពុំនោះទេត្រូវរង់ចាំប្រាំឆ្នាំក្រោយ (Charveriat and Kirkbride ២០០៣)។ ដូច្នេះ ថ្នាំប្រឆាំងវីរុសនឹងកាន់តែមិនសំបូរ និងថ្លៃ ធ្វើឱ្យវិបត្តិសុខភាពសាធារណៈដែលធ្ងន់ធ្ងររួចទៅហើយនោះកាន់តែធ្ងន់ធ្ងរឡើង។

**ប្រភព : Adhikari ២០០៤។**

- *ស្ថានភាពសេដ្ឋកិច្ចមិនផ្អែកលើទីផ្សារ* : កិច្ចព្រមព្រៀង WTO មិនទាមទារឱ្យប្រទេសនានាមានសេដ្ឋកិច្ចបែបទីផ្សារនោះឡើយ។ ប៉ុន្តែ សមាជិកស្រាប់បានបង្ខំឱ្យសមាជិកថ្មី រួមទាំងចិន គៀហ្គីស្តង់ និងម៉ុងហ្គោលី ទៅតាមទិសដៅនេះ ហើយទំនងជាអនុវត្តសម្ពាធដូចគ្នាទៅលើប្រទេសវៀតណាម។
- *ឯកជនភាវូបនីយកម្មសហគ្រាសរបស់រដ្ឋ* : អាណត្តិរបស់ WTO មិនទាមទារឱ្យប្រទេសនានាចូលក្នុងគន្លងឯកជនភាវូបនីយកម្មឡើយ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសសុំចូលដូចជាកម្ពុជា និងម៉ុងហ្គោលី ត្រូវបានស្នើឱ្យធ្វើរបាយការណ៍ជាទៀងទាត់ទៅ WTO ពីស្ថានភាពនៃកម្មវិធីឯកជនភាវូបនីយកម្មរបស់ខ្លួន។
- *របបវិនិយោគ* : កិច្ចព្រមព្រៀងស្តីពីវិធានការទាក់ទងនឹងការវិនិយោគ (TRIM) ហាមឃាត់រដ្ឋាភិបាលពីការដាក់ "លក្ខខណ្ឌតុល្យភាពការនាំចេញ" ទៅលើក្រុមហ៊ុន ដែលជាការរារាំងក្រុមហ៊ុនពីការនាំចូលផលិតផលជាបន្ថែម លើកលែងតែពួកគេបានបំពេញគោលដៅនាំចេញ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការចរចាសុំចូលជាសមាជិក សមាជិកWTO ខ្លះបានសុំឱ្យអ្នកដាក់ពាក្យថ្មី ធ្វើការហាមឃាត់លើលក្ខខណ្ឌតម្រូវសម្រាប់ការនាំចេញ សូម្បីតែពុំទាក់ទងជាមួយបរិមាណ និងតម្លៃនៃការនាំចូលក៏ដោយ។[១៨]

## បញ្ហានៃការអនុវត្ត

ប្រទេស LDCs មួយចំនួនមានបញ្ហាក្នុងការអនុវត្តកិច្ចព្រមព្រៀង WTO របស់ខ្លួន។ ពិសេសចំពោះប្រទេសដែលសុំចូលនេះ ដោយសារកិច្ចព្រមព្រៀងទាំងនេះច្រើនតែមិនគួរឱ្យចូលចិត្តនិងមិនសមហេតុផល។ ប៉ុន្តែ LDCs ក៏មានសមត្ថភាពកម្រិតទាបក្នុងការអនុវត្តសូម្បីតែលក្ខខណ្ឌធម្មតា។ កិច្ចព្រមព្រៀងខ្លះងាយស្រួល និងចំណាយតិច ដើម្បីអនុវត្ត ដូចជា អត្រាពន្ធអាចកាត់បន្ថយបានដោយគ្រាន់រដ្ឋមន្ត្រី ឬអ្នកច្បាប់ចុះហត្ថលេខាជាការស្រេច។ ប៉ុន្តែ លក្ខខណ្ឌខ្លះទៀតត្រូវការនូវការវិនិយោគយ៉ាងច្រើន ដើម្បីទិញ និងតម្លើងបរិក្ខារ និងនីតិវិធី ព្រមទាំងបណ្តុះបណ្តាលបុគ្គលិក ដូចជាសម្រាប់ការ

វាយតម្លៃពន្ធគយ និងសិទ្ធិលើកម្មសិទ្ធិបញ្ញា និងស្តង់ដារ។[១៩] លើសពីនេះ LDCs អាចពុំមានសមត្ថភាពខាងរដ្ឋបាល ឬមូលនិធិ ដើម្បីបង្កើតគ្រឹះស្ថានដែលត្រូវការជាចាំបាច់។

## ឥទ្ធិពលនៃសមាហរណកម្មពាណិជ្ជកម្ម ទៅលើការអភិវឌ្ឍមនុស្ស

ការវាយតម្លៃផលប៉ះពាល់នៃសមាហរណកម្មពាណិជ្ជកម្មទៅលើការអភិវឌ្ឍមនុស្សសម្រាប់ LDCs គឺជាការលំបាក។ ការកំណត់ថាតើសមាហរណកម្មនាំឱ្យមានកំណើនពាណិជ្ជកម្មបែបណា មានភាពលំបាកគ្រប់គ្រាន់ទៅហើយ ពុំចាំបាច់គិតដល់ឥទ្ធិពលជាក់លាក់ទៅលើផ្នែកខុសៗគ្នានៃសង្គមឡើយ។[២០] ប៉ុន្តែនៅកម្រិតទូទៅបំផុត មានការបង្ហាញច្បាស់ថា សមាហរណកម្មពាណិជ្ជកម្ម ពិតជាបង្កើតឱ្យមានអ្នកឈ្នះ និងអ្នកចាញ់។ ជាធម្មតា អ្នកឈ្នះគឺជាអ្នកដែលអាចចាត់ចែងខ្លួនឯងបានល្អនៅក្នុងផ្នែកឯកជន ឬជួនកាលនៅក្នុងសហជីពកម្មករដែលអាចដាក់ការគាបសង្កត់ ដើម្បីជាប្រយោជន៍សម្រាប់ខ្លួននៅក្នុងពេលចរចាពាណិជ្ជកម្មហើយ ប្រសិនបើពួកគេគិតថាខ្លួនត្រូវចាញ់ប្រៀប ត្រូវធ្វើការចរចាឱ្យមានការទូទាត់សង។ អ្នកចាញ់មិនសូវមានការចាត់ចែងបានល្អឡើយ ហើយជាទូទៅមានចំនួនច្រើន ឧទាហរណ៍ គ្រួសារកសិករខ្នាតតូច ឬកម្មករនៅក្នុងឧស្សាហកម្មប្រកួតប្រជែងលើការនាំចូល ដែលនឹងបាត់បង់កិច្ចការពារ អត្រាពន្ធខ្ពស់ ដោយនៅពុំទាន់គិតដល់អ្នកបង់ពន្ធ ដែលត្រូវបំពេញគម្លាតនៅក្នុងថវិការដ្ឋាភិបាល ដោយកាត់ចំណូលពន្ធគយនោះនៅឡើយផង។

## ស្ថាប័ន និងអភិបាលកិច្ច

រដ្ឋាភិបាលត្រូវផ្តល់ការគាំទ្រដល់អ្នករងគ្រោះដោយសារសេរីភាវូបនីយកម្មពាណិជ្ជកម្ម។ អាទិភាពមួយគឺគួរកសាងបណ្តាញសុវត្ថិភាពសង្គម ដោយផ្តល់ប្រាក់បំណាច់ឥតការងារធ្វើ និងបរិក្ខារសម្រាប់រក្សាទុក ទន្ទឹមនឹងជួយអ្នកជំនួញនានាឱ្យធ្វើការកែតម្រូវខាងសង្គម។ រដ្ឋាភិបាលខ្លះអនុវត្តបានជោគជ័យលើផ្នែកនេះ និងផ្តល់កិច្ចការពារយ៉ាងច្រើន។ តាមពិតជាញឹកញាប់មានទំនាក់ទំនងជិតស្និទ្ធរវាងការប្រឈមរបស់ប្រទេសមួយទៅនឹងពាណិជ្ជកម្មបរទេស និងទំហំនៃស្ថានភាពសុខុមាលភាពរបស់ប្រទេសនោះ។ ប្រទេសដែលបើកចំហបំផុត ដូចជាស៊ុយអែដ ដាណឺម៉ាក និងហូឡង់ មានការរីកចម្រើនយ៉ាងខ្លាំងខាងការចំណាយទៅលើការផ្ទេរប្រាក់ចំណូល។[២១] គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដែលប្រទេសទាំងនេះក៏បានសម្រេចជោគជ័យបំផុតលើការអភិវឌ្ឍមនុស្ស។

ប៉ុន្តែគោលនយោបាយបើកចំហបែបនេះពុំចាំបាច់មានកម្រិតទេនៅក្នុងប្រទេសអ្នកមាន។ ឧទាហរណ៍ អេក្វាឌ័រដែលជាប្រទេសកំពុងអភិវឌ្ឍន៍មានប្រាក់ចំណូលកណ្តាល បានអនុវត្តកិច្ចប្រឹងប្រែងប្រហាក់ប្រហែលគ្នានេះ។ នៅឆ្នាំ ២០០១ ក្រោយចូលជាសមាជិក WTO និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់មួយចំនួនរួចមក ប្រទេសនេះបានអនុម័តច្បាប់ស្តីពីសន្តិសុខសង្គមថ្មីមួយដែលផ្តល់ប្រាក់បំណាច់គ្មានការងារធ្វើ សម្រាប់អ្នកដែលបាត់បង់ការងារនៅក្នុងផ្នែកឯកជន និងសាធារណៈ។ ដូចគ្នានេះដែរ ក្រោយការចូលជាសមាជិក WTO និងដោយមានការជួយផ្តល់ប្រាក់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី ម៉ុងហ្គោលីបានពង្រឹងកម្មវិធីសន្តិសុខសង្គមរបស់ខ្លួន ដើម្បីអាចជួយអ្នកដែលមិនបានទទួលការងារ និងអ្នកមិនបានធ្វើការតាមសក្តានុពលក្នុងការរកការងារធ្វើ។

## សុខភាពសាធារណៈ

សេរីភាវូបនីយកម្មពាណិជ្ជកម្មអាចមានឥទ្ធិពលលើសុខភាពសាធារណៈតាមវិធីជាច្រើន។ វិធីមួយគឺត្រូវទទួលយករបបកម្មសិទ្ធិបញ្ញា ដែលជះឥទ្ធិពលទៅលើវត្តមាន និងថ្លៃឱសថ។ កាលពីមុន ប្រទេសកំពុងអភិវឌ្ឍន៍ដែលមិនអនុវត្ត

*រដ្ឋាភិបាលត្រូវផ្តល់ការគាំទ្រដល់អ្នករងគ្រោះដោយសារសេរីភាវូប-នីយកម្មពាណិជ្ជកម្ម*

ប្រព័ន្ធប៉ាតង់អាចផលិតគំរូថ្នាំស្រដៀងគ្នាប៉ុន្តែថោកជាងថ្នាំដែលមានយីហោពីនាយ។ ឧទាហរណ៍ ឥណ្ឌាបានកសាងឧស្សាហកម្មឱសថទំនើប និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដើម្បីផលិតឱសថគំរូអាយដែលអាចប្រើប្រាស់ក្នុងប្រទេស និងសម្រាប់នាំចេញ។ ម្យ៉ាងវិញទៀត ប្រទេសប៉ាគីស្ថានដែលនៅជិតខាងដែលមានឧស្សាហកម្មឱសថច្រើនដែរនោះ ប៉ុន្តែដែលគោរពតាមគោលការណ៍ប៉ាតង់ មានឱសថដែលមានថ្លៃជាងពី ៣ ទៅ ១៤ដង។[១២]

ប្រការទាំងអស់នេះបានផ្លាស់ប្តូរចាប់តាំងពីឆ្នាំ ១៩៩៤ ដោយសារកិច្ចព្រមព្រៀងWTOស្តីពីទិដ្ឋភាពទាក់ទងនឹងពាណិជ្ជកម្មនៃសិទ្ធិកម្មសិទ្ធិបញ្ញា (TRIPS)។ ឥឡូវសមាជិកទាំងអស់របស់ WTO ត្រូវតែគោរពយ៉ាងហ្មត់ចត់ទៅតាមមាត្រាចែងពីកម្មសិទ្ធិបញ្ញាដែលគ្របដណ្តប់បញ្ហានានា ដូចជាសិទ្ធិចម្លង និងប៉ាតង់។ ប្រការនេះមានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរ។ ទីមួយមានការចំណាយខាងផ្នែកសេដ្ឋកិច្ច។ ការអនុវត្តតាម TRIPS ត្រូវចំណាយច្រើន ដូចជាកែសម្រួលច្បាប់ បណ្តុះបណ្តាលមន្ត្រីនានា និងអនុវត្តសាកល្បងព្រមទាំងពង្រឹងការអនុវត្តប៉ាតង់ ហើយផលចំណេញខាងសេដ្ឋកិច្ចនៅពុំមានភាពច្បាស់លាស់ទេ។[២៣] ប៉ុន្តែ អាចមានគ្រោះមហន្តរាយទាក់ទងនឹងការចំណាយលើផ្នែកសង្គម។ ដោយដាក់កំហិតទៅលើកាលានុវត្តភាពដើម្បីផលិតថ្នាំពេទ្យតាមគំរូចម្លងដែលអាចជាវបាន TRIPS ត្រូវបានដាក់ឱ្យអនុវត្តដើម្បីបង្កើតឱ្យមានវិបត្តិខាងសង្គមនៅអាស៊ីនិងប៉ាស៊ីហ្វិក។ ផលប៉ះពាល់មួយក្នុងចំណោមផលប៉ះពាល់ធ្ងន់ធ្ងរនោះគឺ HIV/AIDS។ ប្រជាជនច្រើនជាង ៧ លាននាក់នៅក្នុងតំបន់នេះរងគ្រោះដោយសារ HIV/AIDS ហើយជិតកន្លះលាននាក់បានស្លាប់ដោយ សារជម្ងឺនេះជារៀងរាល់ឆ្នាំ។[២៤] ឧទាហរណ៍ប្រទេសកម្ពុជា ដែលថ្មីៗនេះបានចូលជាសមាជិក WTO ឥឡូវនេះមានការលំបាកកាន់តែខ្លាំងឡើងក្នុងការផ្តល់ថ្នាំព្យាបាលប្រឆាំងវីរុស (ប្រអប់ ៦.៣)។

គេនៅពុំទាន់ដឹងអំពីឥទ្ធិពលទាំងស្រុងនៅឡើយទេ ដោយសារមាត្រាជាច្រើននៅក្នុង TRIPS បានរួមបញ្ចូលការរួចពីកាតព្វកិច្ចសម្រាប់រយៈពេលមួយឆ្នាំ ដែលនឹងផុតកំណត់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៤។ LDCs ក៏មានអត្ថប្រយោជន៍ផងដែរពីការដែលស្ថិតនៅក្រៅការប្រតិបត្តិសម្រាប់រយៈពេលវែង។ នៅខែវិច្ឆិកា ឆ្នាំ ២០០១ សេចក្តីថ្លែងការណ៍ទីក្រុងដូហាស្តីពី TRIPS និងសុខភាពសាធារណៈ ដែលបានផ្តល់ឱ្យ LDCs នូវការពន្យាររយៈពេលអន្តរកាលសម្រាប់ផលិតផលឱសថរហូតដល់ឆ្នាំ ២០១៦។ នៅខែមិថុនា ឆ្នាំ ២០០២ ក្រុមប្រឹក្សា TRIPS បានលើកលែងសមាជិក LDCs ទាំងអស់ឱ្យរួចពីការអនុវត្តផ្នែកខ្លះៗនៃកិច្ចព្រមព្រៀង TRIPS ទាក់ទងនឹងឱសថរហូតដល់ឆ្នាំ ២០១៦។

អគ្គក្រុមប្រឹក្សាបានធ្វើឱ្យមានភាពងាយស្រួលជាងមុនបន្តិចសម្រាប់ LDCs ដើម្បីនាំចូលគំរូឱសថចម្លង។ កាលពីមុន ក្រុមហ៊ុននានាដែលធ្វើការផលិតនៅក្រោមអាជ្ញាប័ណ្ណជាកាតព្វកិច្ច ចាំបាច់ត្រូវធ្វើការផលិតភាគច្រើនសម្រាប់ទីផ្សារក្នុងស្រុករបស់ខ្លួន។ ប៉ុន្តែ នៅខែសីហា ឆ្នាំ ២០០៣ ក្រុមហ៊ុនទាំងនោះបានទទួលការឱ្យរួចខ្លួនពីលក្ខខណ្ឌនេះ សម្រាប់ការនាំចេញទៅប្រទេសដែលមានសមត្ថភាពផលិតពុំគ្រប់គ្រាន់ ទោះបីមានឧបសគ្គខ្លះៗខាងនីតិវិធីនៅក្នុងប្រការនេះក៏ដោយ។

ទីបំផុត នៅខែវិច្ឆិកា ឆ្នាំ ២០០៥ សមាជិកជា LDCs ត្រូវបានការពន្យារយៈពេលអន្តរកាលសម្រាប់ TRIPS ទាំងមូលរយៈពេល ៧.៥ ឆ្នាំ ពោលគឺរហូតដល់ខែកក្កដា ឆ្នាំ ២០១៣ ឬរហូតដល់កាលបរិច្ឆេទដែលខ្លួនលែងស្ថិតនៅជា LDCs។ ប៉ុន្តែ សេចក្តីសម្រេចនេះបង្កស្ថានភាពដែលមានស្រាប់ ដោយសារមានការចែងថា រាល់ការកែប្រែនៅក្នុងច្បាប់ បទប្បញ្ញត្តិ និងទម្លាប់អនុវត្ត ដែលធ្វើឡើងនៅក្នុងអន្តរកាលបន្ថែម មិនគួរនាំ

ឱ្យកាត់បន្ថយភាពស៊ីសង្វាក់ ជាមួយកិច្ចព្រមព្រៀង TRIPS ឡើយ។

## កិច្ចការពារបរិស្ថាន

ប្រទេសជឿនលឿនបានអះអាងថា ភាពទន់ខ្សោយនៃស្តង់ដារបរិស្ថាន ផ្តល់ឱ្យប្រទេសកំពុងអភិវឌ្ឍន៍ខ្លះនូវឧត្តមភាពពុំត្រឹមត្រូវ ដោយឡែកសហគ្រាសជាច្រើននៅក្នុងប្រទេសទាំងនោះអាចផលិតទំនិញដោយចំណាយទាបជាងភាគច្រើនដោយសារពួកគេមិនមានការបារម្ភអំពីការបង់ថ្លៃ ឬត្រូវបង់ថ្លៃសម្រាប់ការបំពុលដែលពួកគេបង្កឡើង។ ពួកគេនិយាយថា ប្រការនេះនឹងនាំឱ្យមាន"ការប្រណាំងទៅបាតក្រោម" នៅក្នុងអ្វីដែលត្រូវបានហៅថា "ពិភពនៃការបំពុល"។

ភស្តុតាងពីការពិសោធន៍ពុំគាំទ្រសម្មតិកម្មនេះឡើយ។ ការអង្កេតមួយទៅលើឧស្សាហកម្មចំនួនប្រាំដែលបំពុលនៅក្នុងប្រទេសចំនួន ១១៩ បានរកឃើញថា លើកលែងតែការផលិតដែកថែប និងដែក ពុំមានភស្តុតាងច្បាស់លាស់ថារដ្ឋាភិបាលមានចេតនាកំណត់ស្តង់ដារបរិស្ថាននៅកម្រិតទាបនោះឡើយ ហើយការអង្កេតនោះសន្និដ្ឋានថា ករណីសម្រាប់ការដាក់បញ្ចូលស្តង់ដារបែបនេះទៅក្នុងក្របខ័ណ្ឌ WTO មានភាពទន់ខ្សោយ។ ករណីនេះដូចគ្នានេះក៏សង្កេតឃើញផងដែរទាក់ទងនឹងស្តង់ដារបរិស្ថាននៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មកម្រិតតំបន់ ដូចជា NAFTA និង កិច្ចព្រមព្រៀងទ្វេភាគីរវាង US និងសិង្ហបុរី។[២៧]

សម្រាប់ចំណែករបស់ខ្លួន ប្រទេសកំពុងអភិវឌ្ឍន៍បានឯកភាពថា ការកែលំអកិច្ចការពារបរិស្ថានគឺជាប្រការសំខាន់ ប៉ុន្តែប្រការនេះពុំគួរចាត់ទុកជាផ្នែកមួយនៃការចរចាពាណិជ្ជកម្មឡើយ ដោយសារវាផ្តល់ឱ្យប្រទេសជឿនលឿននូវកាលានុវត្តភាពកាន់តែច្រើនឡើង ដើម្បីបង្កើនរបាំងពាណិជ្ជកម្មតាមតែអំពើចិត្ត និងស្រេចតែខ្លួនឯង។ នៅក្នុងករណីណាមួយ GATT បានអនុញ្ញាតឱ្យមានការដាក់កំហិតរួចទៅហើយ ប្រសិនបើពាណិជ្ជកម្មអាចបង្កគ្រោះថ្នាក់ចំពោះរុក្ខជាតិ សុខភាពសត្វ និងមនុស្ស ឬគ្រោះថ្នាក់ ចំពោះគោលដៅអភិរក្សធនធានធម្មជាតិ។

ជាជំនួស ប្រទេសកំពុងអភិវឌ្ឍន៍ចង់ឱ្យមានការផ្តោតជាងទៅលើសក្តានុពលវិជ្ជមាននៃពាណិជ្ជកម្មដើម្បីផ្ទេរបច្ចេកវិទ្យាដែលផ្តល់កិច្ចការពារបរិស្ថានបានប្រសើរជាង។ ឧទាហរណ៍: សេចក្តីថ្លែងការណ៍ទីក្រុងដូហា បានកំណត់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មលើផលិតផលបរិស្ថាន និងបច្ចេកវិទ្យាដែលមិនបង្កគ្រោះថ្នាក់ចំពោះបរិស្ថាន។

## កិច្ចផ្តួចផ្តើមដោះស្រាយភាពងាយរងគ្រោះនៃប្រទេសដែលមានការអភិវឌ្ឍតិច

ប្រទេសជឿនលឿនទទួលស្គាល់ថា នៅពេលធ្វើសមាហរណកម្មទៅក្នុងពាណិជ្ជកម្មអន្តរជាតិ LDCs ទំនងជាងាយរងគ្រោះ ដូច្នេះពួកគេក៏បានបង្កើតកិច្ចប្រឹងប្រែងខ្លះៗដើម្បីការពារប្រយោជន៍របស់ប្រទេសទាំងនោះ។ ទោះបីនេះជាកិច្ចប្រឹងប្រែងពិតប្រាកដក៏ដោយ ភាគច្រើននៃកិច្ចប្រឹងប្រែងទាំងនោះទទួលបរាជ័យក្នុងការសម្រេចគោលបំណងរបស់ខ្លួន។

## ការយកចិត្តទុកដាក់ពិសេសនិងខុសគ្នា

វិធីមួយគឺការអនុញ្ញាតឱ្យប្រទេសកំពុងអភិវឌ្ឍន៍នូវភាពទន់ភ្លន់ខ្លះនៅក្រោមក្របខ័ណ្ឌនៃ"ការយកចិត្តទុកដាក់ពិសេសនិងខុសគ្នា" (SDT)។ ប្រទេសកំពុងអភិវឌ្ឍន៍បានធ្វើការទទូចជាក្រុមចង់ឱ្យមាន SDT ដោយពោលថាការដាក់ឱ្យអនុវត្តបទបញ្ជាដូចគ្នាចំពោះប្រទេសជាដៃគូពាណិជ្ជកម្មមិនស្មើភាពអាចជាមហន្តរាយមួយ។ ដោយផ្អែកលើពាណិជ្ជកម្ម ការអភិវឌ្ឍ និងតម្រូវការហិរញ្ញវត្ថុរបស់ប្រទេសទាំងនោះ គួរតែមាន SDT

*ប្រទេសកំពុងអភិវឌ្ឍន៍បានធ្វើការទទូចជាក្រុមចង់ឱ្យមាន SDT ដោយពោលថា ការដាក់ឱ្យអនុវត្តបទបញ្ជាដូចគ្នាចំពោះប្រទេសជាដៃគូពាណិជ្ជកម្មមិនស្មើភាពអាចជាមហន្តរាយមួយ*

ដែលបង្កើតបានល្អប្រកបដោយប្រសិទ្ធិភាព ដែលអាចអនុវត្តបាន និងកំណត់ពេលវេលាជាក់លាក់ ទើបអាចជួយប្រទេសកំពុងអភិវឌ្ឍន៍ និង LDCs ធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។[២៦] សារៈសំខាន់ដូចគ្នាផងដែរគឺ SDT ត្រូវផ្តល់វិធីនានាសម្រាប់កែតម្រូវរបបពាណិជ្ជកម្មដោយពិចារណាបានប្រសើរជាងមុនអំពីគោលបំណងនៃការអភិវឌ្ឍមនុស្ស។[២៧]

នៅអាស៊ី ប្រទេសជាច្រើនដែលមានប្រាក់ចំណូលកណ្តាលនិងខ្ពស់ បាននាំចូលតិចតួចពី LDCs នៅក្នុងតំបន់នេះ ដោយសារតម្រូវការនាំចូលរបស់ប្រទេសទាំងនោះ មានភាពខុសគ្នាពីអ្វីដែល LDCs ទាំងនេះអាចផ្គត់ផ្គង់ (ប្រអប់ ៦.៤)។

ប្រអប់ ៦.៤

## ពាណិជ្ជកម្មរវាង LDCs នៅអាស៊ី-ប៉ាស៊ីហ្វិក និងចិន

ពាណិជ្ជកម្មរបស់ចិនជាមួយប្រទេសនៅអាស៊ី-ប៉ាស៊ីហ្វិកកើនឡើងយ៉ាងឆាប់រហ័ស ហើយឥឡូវនេះមានដល់ ៥៣% នៃពាណិជ្ជកម្មរបស់ខ្លួនលើពិភពលោក។ ប៉ុន្តែភាគច្រើននៃពាណិជ្ជកម្មនេះ (ជិត ៧៨%) ធ្វើឡើងជាមួយប្រទេសមានប្រាក់ចំណូលខ្ពស់នៅក្នុងតំបន់ ដូចជា ជប៉ុន សាធារណរដ្ឋកូរ៉េ សឹង្ហបូរី ហុងកុង និងតៃវ៉ាន់។ ក្នុងចំណោមប្រទេសមានចំណូលកណ្តាល ដៃគូពាណិជ្ជកម្មចម្បងគឺ ម៉ាឡេស៊ី ថៃ និងឥណ្ឌូណេស៊ី។

ការនាំចូលរបស់ចិនពីប្រទេស LDCs នៅអាស៊ីមានកម្រិតទាបណាស់ ត្រឹមប្រមាណ ៣០០លានដុល្លារប៉ុណ្ណោះ។ LDCs ទាំងអស់មានឱនភាពពាណិជ្ជកម្មជាមួយចិន។ ឧទាហរណ៍ច្បាស់មួយគឺ ប្រទេសបង់ក្លាដេស ដែលនាំចេញទំនិញដោយតម្លៃ ៥៧លានដុល្លារ និងនាំចូលទំនិញដោយតម្លៃ ១.៩០៦ លានដុល្លារ ពីប្រទេសចិន។

ដោយសារតម្រូវការនាំចូលរបស់ប្រទេសចិន ជាពិសេសបរិក្ខារបច្ចេកវិទ្យាជាន់ខ្ពស់ ដូចជា ម៉ាស៊ីននិងគ្រឿងបន្លាស់ ឥន្ធនៈនិងវត្ថុធាតុដើម គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលភាគច្រើននៃពាណិជ្ជកម្មរបស់ប្រទេសនេះ បានធ្វើឡើងជាមួយប្រទេសមានចំណូលខ្ពស់។ LDCs មានសក្តានុពលទាបសម្រាប់ទទួលអត្ថប្រយោជន៍ពីភាពរីកចម្រើននៃទីផ្សារក្នុងប្រទេសចិន ដែលកើនឡើងច្រើនជាង ១៥%/ឆ្នាំ។ ម៉្យាងវិញទៀត ការនាំចូលរបស់ LDCs ពីប្រទេសចិនមានបរិមាណច្រើន និងមានបរិមាណច្រើនជាង ២០% នៃការនាំចូលសរុបរបស់ប្រទេសទាំងនោះ ដែលមានន័យថាជាកំណើនអតុល្យភាពជញ្ជីងពាណិជ្ជកម្មកាន់តែធំឡើងជាមួយប្រទេសចិន និងលទ្ធភាពដែលផលនាំចូលរបស់ចិន ត្រូវបានដាក់ជំនួសផលិតផលមួយចំនួនដែលផលិតនៅក្នុងប្រទេស។

ជាការច្បាស់ណាស់ថា មានភស្តុតាងច្បាស់ណាស់ថា ប្រទេសចិន ទន្ទឹមនឹងប្រទេសផ្សេងទៀតនៅអាស៊ីប៉ាស៊ីហ្វិកដែលមានចំណូលខ្ពស់ និងកណ្តាល ផ្តល់ការយកចិត្តទុកដាក់ពិសេសនិងខុសៗគ្នាដល់ LDCs តាមរយៈប្រព័ន្ធអនុគ្រោះទូទៅ (GSP) ទាក់ទងនឹងសម្បទានពន្ធ។

**តុល្យភាពជញ្ជីងពាណិជ្ជកម្មនៃប្រទេសនៅអាស៊ី-ប៉ាស៊ីហ្វិក ជាមួយចិន ឆ្នាំ ២០០៤ (លានដុល្លារ)**

| | នាំចេញទៅចិន | នាំចូលពីចិន | តុល្យភាព |
|---|---|---|---|
| LDCs ក្នុងនោះ : | ៣១៤ | ៣.៥៦០ | -៣.២៤៦ |
| បង់ក្លាដេស | ៥៧ | ១.៩០៦ | -១.៨៤៩ |
| កម្ពុជា | ៣០ | ៤៥២ | -៤២២ |
| ឡាវ | ១២ | ១០១ | -៨៩ |
| ភូមា | ២០៧ | ៩៣៨ | -៧៣១ |
| នេប៉ាល់ | ៨ | ១៦៣ | -១៥៥ |
| ប្រទេសចំណូលទាប | ១១.៤៦០ | ១២.៩៤៥ | -១.៤៨៥ |
| ប្រទេសចំណូលកណ្តាល | ៤៦.០១៧ | ២៥.១៤០ | ២០.៨៧៧ |
| ប្រទេសចំណូលខ្ពស់ | ២៤៧.១០៩ | ២២៨.៤១៩ | ១៨.៦៩០ |
| សរុបអាស៊ី-ប៉ាស៊ីហ្វិក | ៣០៤.៩០០ | ២៧០.០៦៤ | ៣៤.៨៣៦ |

**ប្រភព : IMF ២០០៦។**

ជាការឆ្លើយតប កិច្ចព្រមព្រៀងនានារបស់ WTO មានចែងនៅក្នុងមាត្រា ឬវាក្យខណ្ឌខុសៗគ្នាចំនួន ១២៤ ដែលផ្សំដោយប្រការចំនួនប្រមាណ ១៦០ សម្រាប់ SDT ។[២៨] ប្រការទាំងនោះអាចបែងចែកជា "មិនជាប់កាតព្វកិច្ច" និង "ជាប់កាតព្វកិច្ច" ពោលគឺ ដែលអាចអនុវត្តបាន និងដែលមិនអាចអនុវត្តបាន (ប្រអប់ ៦.២)។ ប្រការទាំងនេះកំពុងត្រូវបានពិនិត្យឡើងវិញដោយគណៈកម្មាធិការ WTO ស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ ក្នុងគោលដៅពង្រឹង និងធ្វើឱ្យប្រការទាំងនោះកាន់តែសុក្រឹត មានប្រសិទ្ធិភាព និងអាចអនុវត្តបាន ប៉ុន្តែមកទល់ពេលនេះ មានសញ្ញាអំពីភាពជឿនលឿនត្រឹមតិចតួចតែប៉ុណ្ណោះ ។[២៩]

អ្នកវិភាគខ្លះបានប្រឆាំងជាគោលការណ៍ចំពោះ SDT ដោយអះអាងថាប្រទេសកំពុងអភិវឌ្ឍន៍ពុំគួរទាមទារនូវការយកចិត្តទុកដាក់បែបនេះទេ ព្រោះថាវានឹងធ្វើខ្លួនកាន់តែចាញ់ប្រៀប ។[៣០] ប៉ុន្តែអ្នកផ្សេងទៀតមានទស្សនៈថា SDT គឺជាការចាំបាច់ ប្រសិនបើត្រូវឱ្យប្រទេសក្រីក្រធ្វើសមាហរណកម្មដោយជោគជ័យ ប៉ុន្តែសង្កត់ធ្ងន់ថា នេះមិនមែនជាវិធីគ្រប់គ្រាន់នៅឡើយទេ ។[៣១]

## ការអនុគ្រោះលើការប្រើប្រាស់ទីផ្សារ

ប្រការនេះសំដៅលើសម្បទាននានាដែលអនុញ្ញាតឱ្យមានការប្រើប្រាស់ទីផ្សារដោយឥតពន្ធសម្រាប់ទំនិញខ្លះៗពីប្រទេសកំពុងអភិវឌ្ឍន៍ ។ ការអនុគ្រោះបែបនេះអាចជាផ្នែករងមួយនៃ SDT ប៉ុន្តែ ទម្រង់នៃការយកចិត្តទុកដាក់បែបនេះ មានប្រវត្តិស៊ីជម្រៅជាង ។ នៅឆ្នាំ ១៩៦៥ សមាជិករបស់ GATT បានបន្ថែមមាត្រានានាដើម្បីផ្តល់ការអនុគ្រោះចំពោះទំនិញពីប្រទេសកំពុងអភិវឌ្ឍន៍ ។ បន្ទាប់មក នៅទសវត្សរ៍ឆ្នាំ ១៩៧០ ប្រទេសឈានមុខមួយចំនួនបានដាក់ឱ្យអនុវត្តប្រព័ន្ធអនុគ្រោះទូទៅ (GSP) ដែលផ្តល់ដោយស្ម័គ្រចិត្តជាឯកតោភាគីនូវអត្រាពន្ធអនុគ្រោះលើការនាំចូលពីប្រទេសកំពុងអភិវឌ្ឍន៍ ។ ចាប់ពីឆ្នាំ ១៩៧៩មក ប្រការនេះត្រូវបានចាត់ចែងឱ្យទៅជាទម្រង់អចិន្ត្រៃយ៍នៃប្រព័ន្ធពាណិជ្ជកម្មពហុភាគី ។ បន្ទាប់មក នៅទសវត្សរ៍ឆ្នាំ ១៩៨០ ប្រទេសជឿនលឿនផ្សេងទៀតជាច្រើនបានដាក់អនុវត្តប្រព័ន្ធទ្វេភាគី ។

នៅឆ្នាំ ១៩៧៥ EU បានផ្តល់ប្រព័ន្ធអនុគ្រោះទីពីរលើការប្រើប្រាស់ទីផ្សារនៅក្រោមអនុសញ្ញាឡូមេ ដែលឥឡូវនេះត្រូវបានហៅថា កិច្ចព្រមព្រៀងកុងតូនូ ដែលផ្តល់ឱ្យប្រទេសនៅក្រោមអតីតអាណានិគមរបស់ខ្លួន រួមទាំងប្រទេសនៅប៉ាស៊ីហ្វិកនូវការអនុគ្រោះស៊ីជម្រៅជាងអ្វីដែលមាននៅក្នុងប្រព័ន្ធ GSP ។ បន្ទាប់មក នៅឆ្នាំ ២០០១ សហភាពអឺរ៉ុបបានបង្ហាញកិច្ចព្រមព្រៀងថ្មីមួយដែលមានលក្ខខណ្ឌពិសេសសម្រាប់ LDCs នូវកិច្ចផ្តួចផ្តើម "អ្វីៗទាំងអស់លើកលែងតែសព្វាវុធ" (EBA) ដែលផ្តល់លទ្ធភាពប្រើប្រាស់ទីផ្សាររបស់សហភាពអឺរ៉ុបដោយឥតបង់ពន្ធ និងពុំកំណត់កូតាឡើយ សម្រាប់គ្រប់ផលិតផលក្រៅពីអាវុធ និងគ្រឿងផ្ទុះ ប៉ុន្តែផលិតផលចំនួនបីត្រូវបានលុបចោលនៅពេលក្រោយមកគឺ ចេក នៅឆ្នាំ ២០០៦ ស្រូវនិងស្ករ នៅឆ្នាំ ២០០៩ ។ ដូចគ្នានេះដែរ ប្រទេសផ្សេងទៀតចំនួន ២៧ បានផ្តល់ជាទម្រង់ខ្លះនៃការអនុគ្រោះដល់ LDCs ក្នុងការចូលប្រើប្រាស់ទីផ្សាររបស់ខ្លួនឬកំពុងនៅក្នុងដំណើរការធ្វើបែបនេះ ។[៣២] ប្រទេសទាំងនោះរួមមាន ៖

*កាណាដា* ៖ នៅខែមករា ឆ្នាំ២០០៣ កាណាដាដាក់ឱ្យអនុវត្តប្រព័ន្ធថ្មីនៃ GSP ។ ប្រព័ន្ធមានភាពទូលាយខ្លាំងណាស់ ប៉ុន្តែវាមិនរួមបញ្ចូលផលិតផលទឹកដោះ ស៊ុត និងបក្សីទេ ។ ប្រព័ន្ធនេះក៏មានវិធានប្រកបដោយភាពច្នៃប្រឌិតផងដែរអំពីបទបញ្ញាប្រទេសដើម ដោយប្រើប្រាស់ប្រព័ន្ធបន្ថែមគ្នាដែលអនុញ្ញាតឱ្យនាំចូលផលិតផលដែលរួមបញ្ចូលទាំងធាតុចូល

ពីប្រទេសដែលជាអ្នកទទួលផលទាំងអស់។

*ជប៉ុន* : ប្រទេសជប៉ុនបានពន្យារប្រព័ន្ធ GSP របស់ខ្លួនរហូតដល់ឆ្នាំ២០១៤ ហើយនៅឆ្នាំ២០០៣ ក៏បានកែលំអបន្ថែមនូវប្រព័ន្ធដែលមានស្រាប់ដោយអនុញ្ញាតឱ្យមានការនាំចូលពី LDCs ដោយគ្មានបង់ពន្ធមិនត្រឹមតែសម្រាប់ផលិតផលឧស្សាហកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់កសិផលមួយចំនួនផងដែរ ដូចជា បង្គា និងសាច់ត្រីបង្កកផងដែរ។

*សហរដ្ឋអាមេរិក* : បន្ថែមលើសម្បទានដែលបានផ្តល់តាមរយៈប្រព័ន្ធ GSP ធម្មតារបស់ខ្លួន ស.រ.អាផ្តល់ផងដែរនូវការអនុគ្រោះស៊ីជម្រៅជាងចំពោះប្រទេសមួយចំនួននៅអាហ្វ្រិកតាមរយៈច្បាប់កំណើននិងកាលានុវត្តភាពសម្រាប់អាហ្វ្រិក (AGOA) និងចំពោះប្រទេសនៅតំបន់ការ៉ាអ៊ីប តាមរយៈកិច្ចផ្តួចផ្តើមអាងតំបន់ការ៉ាអ៊ីប។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធ GSP របស់ស.រ.អា ផ្តល់ការអនុគ្រោះដែលមានលក្ខណៈអំណោយផលតិចជាងដល់ប្រទេសនៅអាស៊ី និងប៉ាស៊ីហ្វិក។

***ការទទួលយកភាពអនុគ្រោះនេះ បាននាំឱ្យមានការខកចិត្ត***

ទោះជាយ៉ាងណាក៏ដោយ ការទទួលយកភាពអនុគ្រោះនេះបាននាំឱ្យមានការខកចិត្ត។ ប្រទេសជឿនលឿននៅតែទទួលយកសមាមាត្រតិចតួចបំផុតនៃការនាំចូលរបស់ខ្លួនពី LDCs ពោលគឺ ០.៦% សម្រាប់សហភាពអឺរ៉ុប ០.២% សម្រាប់កាណាដា ០.៤% សម្រាប់ជប៉ុន និង ០.៨% សម្រាប់ស.រ.អា។[៣៣] តួលេខនេះពុំមានការប្រែប្រួលតាំងពី ឆ្នាំ១៩៩២មក ជាក់ស្តែងតួលេខសម្រាប់ជប៉ុនបានធ្លាក់ចុះ។

មានការពន្យល់មួយចំនួនអំពីចំណុចនេះ។ ទីមួយ គឺប្រទេសនាំចេញពុំចង់វិនិយោគលើការកសាងទីផ្សារថ្មីនៅក្នុងប្រទេសទាំងនេះឡើយ ដោយសារការអនុគ្រោះជាចំណាត់ការឯកតោភាគីនិងដោយស្ម័គ្រចិត្ត ហើយអាចលុបចោលវិញនៅពេលណាមួយ។ ពួកគេក៏ចង្អុលបង្ហាញដែរថា ប្រព័ន្ធនេះមិនរាប់បញ្ចូលវិស័យ"ពិបាកដោះស្រាយ"មួយចំនួន ហើយច្រើនតែទាមទារឱ្យអនុវត្តយ៉ាងម៉ឺងម៉ាត់នូវបទបញ្ញាប្រភពដើម ដែលធ្វើឱ្យមានការលំបាកសម្រាប់ផលិតផលឧស្សាហកម្ម ដែលផ្សំដោយវត្ថុធាតុដើមពីប្រទេសផ្សេងទៀតមួយចំនួន។ លើសពីនេះ សហគ្រាសជាច្រើនពុំយល់ច្បាស់អំពីបទបញ្ញានេះ ឬមិនបានដឹងជាទូទៅអំពីវត្តមាននៃភាពអនុគ្រោះទាំងនេះទៀតផង។[៣៤]

បញ្ហាមួយផ្សេងទៀតគឺថាប្រទេសជឿនលឿនកំពុងចាត់វិធានការការពារទីផ្សាររបស់ខ្លួនកាន់តែខ្លាំងឡើងដោយប្រើប្រាស់របាំងមិនមែនពន្ធ។ ឧទាហរណ៍ ស.រ.អា និង សហភាពអឺរ៉ុប បានប្រើប្រាស់កិច្ចព្រមព្រៀងស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ ដើម្បីបដិសេធការនាំចូលខ្លះៗនូវកសិផលសត្វចិញ្ចឹម សាកវប្បកម្ម និងដំណាំផ្កា។ វិធានការទាំងនេះច្រើនតែមិនសមស្របសម្រាប់កាលៈទេសៈរបស់ផលិតករ និងបង្កជាបន្ទុកធ្ងន់ធ្ងរក្នុងកម្រិតវិសមាមាត្រសម្រាប់អ្នកនាំចេញតូចតាច។[៣៥]

"អ្នកមិនជឿលើការអនុគ្រោះ"និយាយថាប្រព័ន្ធនេះមានភាពរើសអើង។ ទោះបីវាផ្តល់អត្ថប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះៗក្តី អត្ថប្រយោជន៍ទាំងនោះកើតឡើងទន្ទឹមនឹងការខូចខាតដល់ប្រទេសដទៃ។[៣៦] ប៉ុន្តែ "អ្នកកែទម្រង់ GSP" មានទស្សនៈវិជ្ជមានដោយអះអាងថា ប្រព័ន្ធនេះមានតួនាទីវិជ្ជមាន។[៣៧] អ្នកផ្សេងទៀតអះអាងថា GSP បានបង្កើនពីរដងនូវអត្រាពាណិជ្ជកម្មរវាងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសជឿនលឿន[៣៨] និងបានរួមចំណែកនៅក្នុង"ជោគជ័យនៅអាស៊ី" ដោយអនុញ្ញាតឱ្យប្រទេសមួយចំនួនជ្រៀតចូលទៅក្នុងទីផ្សារ និងរក្សាទីតាំងរបស់ខ្លួននៅទីនោះ ដើម្បីកសាងឧត្តមភាពរបស់ខ្លួន។[៣៩]

ការគិតគូរថ្មីៗជាច្រើនបានលេចឡើងទាក់ទងនឹងបញ្ហានេះ។ មានការស្នើឡើងថា ប្រទេសជឿនលឿនពុំគួរផ្តល់ការអនុគ្រោះ ប៉ុន្តែផ្ទុយទៅវិញធ្វើសេរីភាវូបនីយកម្មនៅទូទាំងក្រុម"ប្រទេសទទួលការអនុគ្រោះបំផុត" ទន្ទឹមនឹងការផ្តល់ផងដែរនូវការគាំទ្រដល់ LDCs ដើម្បីអនុវត្តកម្មវិធីកែ

ប្រទេសជឿនលឿនទទួលស្គាល់ថា LDCs ជាច្រើននឹងត្រូវការឱ្យមានការគាំទ្រ ប្រសិនបើត្រូវធ្វើសមាហរណកម្មដោយជោគជ័យទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ ដូច្នេះប្រទេសទាំងនោះបានពិចារណាជំនួយពីរបែបដែលទាក់ទងនឹងពាណិជ្ជកម្ម (ប្រអប់ ៦.៥)។

ប្រភេទទីមួយ និងដែលលំបាក ត្រូវបានបង្កើតឡើងដើម្បីជួយប្រទេសជាអ្នកទទួល ដើម្បីធ្វើការប្រកួតប្រជែងប្រកបដោយប្រសិទ្ធិភាពជាងមុនក្នុងសេវៀវនអន្តរជាតិ។ ប្រការបែបនេះទាក់ទងនឹងការជួយលុបបំបាត់ឧបសគ្គខាងសមត្ថភាពទម្រង់របស់ខ្លួន និងដើម្បីពង្រឹងសមត្ថភាពផ្គត់ផ្គង់ និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងនោះតាមរយៈ"ជំនួយសម្រាប់ពាណិជ្ជកម្ម"។ ជាការពិតណាស់ កិច្ចព្រមព្រៀងនានារបស់ WTO បានរួមបញ្ចូលរួចមកហើយនូវប្រការនានាសម្រាប់ជំនួយបច្ចេកទេស ដែលច្រើនតែមិនបានអនុវត្តជាក់ស្តែង។ សូម្បីតែដូច្នេះក៏ដោយ គេគួរតែអាចពង្រឹងជំនួយសម្រាប់វិធានការពាណិជ្ជកម្ម។

## ជំនួយបច្ចេកទេសទាក់ទងនឹងពាណិជ្ជកម្ម

ប្រអប់ ៦.៥

### ជំនួយសម្រាប់ពាណិជ្ជកម្ម : មាគ៌ាទៅមុខ

ប្រសិនបើ LDCs និងប្រទេសមានចំណូលទាបត្រូវទាញយកអត្ថប្រយោជន៍ពេញលេញពីសេដ្ឋកិច្ចពិភពលោកប្រកបដោយសេរីភាវូបនីយកម្មជាងមុន ពួកគេត្រូវការឱ្យមានការគាំទ្របន្ថែមទៀតពីប្រទេសដែលមានច្រើនជាងតាមរយៈ"ជំនួយសម្រាប់ពាណិជ្ជកម្ម"។ ការធ្វើបែបនេះអាចជួយ LDCs ប្រើប្រាស់ពាណិជ្ជកម្មជាឧបករណ៍នៃគោលនយោបាយអភិវឌ្ឍន៍ ឧទាហរណ៍ ជួយប្រទេសទាំងនោះអនុវត្តស្តង់ដារសមស្រប បង្កើនមុខកសិផល ការនាំចេញឧស្សាហកម្ម និងសេវា និងដោះស្រាយបញ្ហាខាងការនាំចេញ គឺ កត្តាមនុស្ស ស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធ។

ជំនួយសម្រាប់ពាណិជ្ជកម្មក្រោមទម្រង់ជាជំនួយឥតសំណង និងបំណុលអនុគ្រោះ ក៏អាចជួយប្រទេសនានាដោះស្រាយការបាត់បង់សារពើពន្ធ និងការខូចខាតស្ថានភាពពាណិជ្ជកម្មផងដែរ ការបាត់បង់ភាពអនុគ្រោះរយៈពេលខ្លី មធ្យម និងវែង និងថ្លៃចំណាយ ដើម្បីអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្ម។

ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះមិនមានយោបល់អំពីកិច្ចផ្តួចផ្តើមនេះទេ។ ពួកគេបារម្ភថា ជំនួយសម្រាប់ពាណិជ្ជកម្មអាចក្លាយជាមូលដ្ឋានសម្រាប់ការបង្កើតលក្ខខណ្ឌថ្មីផ្សេងទៀត ផ្អែកលើគោលជំហរនៃការចរចាពាណិជ្ជកម្មរបស់ប្រទេសនានានៅទីក្រុងដូហា។ ពួកគេក៏បារម្ភផងដែរថា តើនេះពិតជាជំនួយថ្មី ឬបន្ថែម ឬយ៉ាងណា។ ប្រសិនបើពុំមែនទេនោះ ពួកគេចង់ដឹងថាតើពាណិជ្ជកម្មត្រូវបានចាត់ទុកថាសំខាន់ជាងសុខភាព ឬការអប់រំ ឬយ៉ាងណា។ ពួកគេបារម្ភដែរថា តើនេះជាការគាំទ្រពហុភាគីឬទ្វេភាគីនិងថាតើនឹងមានក្រោមភាពជាការគាំទ្រថវិកាឬគម្រោង។

ទោះជាយ៉ាងណាក៏ដោយ ទំនងជាមានការគាំទ្រនយោបាយដល់ទស្សនៈទាននេះ។ ឧទាហរណ៍ រដ្ឋាភិបាលអង់គ្លេសថ្លែងគាំទ្រកិច្ចផ្តួចផ្តើមនេះនៅក្នុងគណៈកម្មការរបស់ខ្លួន សម្រាប់របាយការណ៍អាហ្វ្រិក ហើយរបាយការណ៍គម្រោងសហស្សវត្សរ៍ និងរបាយការណ៍របស់អគ្គលេខាធិការសហប្រជាជាតិសម្រាប់កិច្ចប្រជុំកំពូលឆ្នាំ ២០០៥ បានកំណត់ការពង្រីកជំនួយសម្រាប់ពាណិជ្ជកម្មថាជាអាទិភាព។ ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិបានគាំទ្រផងដែរនូវសំណើសម្រាប់"ការពង្រឹងក្របខ័ណ្ឌចម្រុះ... រួមទាំងការពង្រីកធនធាន និងទំហំរបស់ខ្លួន និងធ្វើឱ្យវាមានប្រសិទ្ធិភាពជាងមុន។"

កិច្ចប្រជុំរដ្ឋមន្ត្រីឆ្នាំ ២០០៥ នៃ WTO បានផ្តល់ការឯកភាពមតិយ៉ាងខ្លាំងក្លាចំពោះក្របខ័ណ្ឌចម្រុះ។ ក្រុមការងារជំនួយសម្រាប់ពាណិជ្ជកម្មថ្មីមួយនឹងផ្តល់អនុសាសន៍ដល់អគ្គក្រុមប្រឹក្សានៃ WTO នៅខែកក្កដា ឆ្នាំ ២០០៦។ សហភាពអឺរ៉ុបក៏ប្រកាសផងដែរថា ពួកគេនឹងបង្កើនការចំណាយលើជំនួយម្រាប់ពាណិជ្ជកម្ម ដោយមិនរាប់បញ្ចូលហេដ្ឋារចនាសម្ព័ន្ធ រហូតដល់ប្រមាណ ២.០០០លានអឺរ៉ូ នៅឆ្នាំ២០១០។ ជប៉ុនបានប្តេជ្ញាផ្តល់ ១០.០០០លានដុល្លារ ហើយស.រ.អា ប្រកាសថាខ្លួននឹងបង្កើនទ្វេដងនូវជំនួយសម្រាប់ពាណិជ្ជកម្ម ឱ្យដល់ ២.៧០០លានដុល្លារ/ឆ្នាំរហូតដល់ឆ្នាំ ២០១០។

ទោះជាយ៉ាងណាក៏ដោយ កញ្ចប់ជំនួយសម្រាប់ពាណិជ្ជកម្មប្រកបដោយមហិច្ឆតាមិនអាច និងពុំគួរត្រូវបានចាត់ទុកថាជាការជំនួសរបៀបវារៈនៃការអភិវឌ្ឍនៅទីក្រុងដូហា ឡើយ។ ប៉ុន្តែ គួរចាត់ទុកថាជាការបំពេញបន្ថែមវិញ។

ឧទាហរណ៍ កសាងហេដ្ឋារចនាសម្ព័ន្ធឱ្យប្រសើរជាងមុនឬកែលំអជំនាញនៅក្នុងកម្លាំងពលករ ។

ប្រភេទទីពីរនៃជំនួយ ផ្តោតជាសំខាន់លើការកែលំអសមត្ថភាពរបស់មន្ត្រីសាធារណៈដើម្បីធ្វើការជាមួយបញ្ហាពាណិជ្ជកម្ម និងដើម្បីធ្វើការប្រកបដោយប្រសិទ្ធិភាពនៅក្នុងការចរចាពាណិជ្ជកម្មនៅក្នុង WTO និងនៅក្នុងការចរចាផ្សេងទៀត។ មកទល់ពេលនេះ ភាគច្រើននៃអ្នកផ្តល់ជំនួយ ឬគ្រឹះស្ថាន ពហុភាគី និងទ្វេភាគី រួមទាំង WTO បានផ្តោតកាន់តែច្រើនឡើងទៅលើប្រភេទទីពីរនៃជំនួយ ។

ដើម្បីព្យាយាមធានាឱ្យមានវិធានទូលំទូលាយ និងប្រកបដោយប្រសិទ្ធិភាពជាងមុន នៅឆ្នាំ ១៩៩៧ គ្រឹះស្ថានពហុភាគីចំនួនប្រាំមួយគឺ IMF, UNDP, ធនាគារពិភពលោក មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ UNCTAD និង WTO បានប្រកាសដាក់ឱ្យប្រើប្រាស់ក្របខ័ណ្ឌសម្រាប់ជំនួយបច្ចេកទេសទាក់ទងនឹងពាណិជ្ជកម្មដល់ LDCs ដែលត្រូវបានឱ្យឈ្មោះផងដែរថាជា "ក្របខ័ណ្ឌចម្រុះ" (IF) ។ IF មានគោលបំណងពីរ ។ ទីមួយ គឺការដាក់បញ្ចូលពាណិជ្ជកម្មទៅក្នុងផែនការអភិវឌ្ឍន៍ជាតិរបស់ LDCs ដូចជា ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។ ទីពីរ ឆ្លើយតបនឹងសេចក្តីត្រូវការដែលបានកំណត់ដោយ LDCs ព្រមជាមួយការប្រគល់ជូនដែលមានការសម្របសម្រួលនូវជំនួយបច្ចេកទេសដែលទាក់ទងនឹងពាណិជ្ជកម្ម ។ ដើម្បីផ្តល់ហិរញ្ញប្បទានសម្រាប់សកម្មភាព IF ម្ចាស់ជំនួយបានបង្កើតមូលនិធិទុកចិត្ត ដែលមាន "មធ្យោបាយ" ពីរ ។ ទីមួយ ដើម្បីផ្តល់ហិរញ្ញប្បទានសម្រាប់ការសិក្សាវិភាគសមាហរណកម្មពាណិជ្ជកម្ម (DTIS) និងទីពីរ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៣ គឺការផ្តល់ហិរញ្ញប្បទានដល់គម្រោងកសាងសមត្ថភាពដែលកំណត់ដោយ DTIS ។[៤០]

IF បានទទួលការគាំទ្រទាំងពីសហគមន៍អភិវឌ្ឍន៍និងសហគមន៍ពាណិជ្ជកម្ម ។ ឧទាហរណ៍ នៅខែកក្កដាឆ្នាំ២០០៣ ប្រធាននៃស្ថាប័ន IF ទាំងប្រាំមួយ និងតំណាងរបស់ខ្លួន បានចេញសេចក្តីប្រកាសរួមមួយ គូសបញ្ជាក់ពីការប្តេជ្ញារបស់ខ្លួនចំពោះគំរូ IF ។ បន្ទាប់មក នៅខែធ្នូ ឆ្នាំ២០០៣ នៅក្រុងដូហា រដ្ឋមន្ត្រី WTO បានគាំទ្រ IF ថាជាគំរូដែលអាចសម្រេចទៅបានសម្រាប់អភិវឌ្ឍន៍ពាណិជ្ជកម្មនៅក្នុង LDCs ។ ទោះបីមានការគាំទ្រនេះក៏ដោយ IF ទំនងជាមានឥទ្ធិពលតិចតួច ហើយហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៃពាណិជ្ជកម្មនៅពុំទាន់បានទទួលមូលនិធិនៅឡើយទេ ។ បញ្ហាខ្លះៗមានលក្ខណៈទូទៅសម្រាប់សហគ្រាសជំនួញពហុភាគីជាច្រើន ។ បញ្ហាមួយគឺកង្វះមូលនិធិ ។ ថវិកាសម្រាប់ប្រទេសនីមួយៗនៅក្រោមមធ្យោបាយទី II គឺ ១លានដុល្លារ ។ DTIS មានឥទ្ធិពលតិចតួចទៅលើការលៃលកមូលនិធិរបស់ម្ចាស់ជំនួយ ។[៤១]

## ការរីកចម្រើននៅពេលថ្មីៗនេះ

ការចរចាបច្ចុប្បន្ននេះអំពីពាណិជ្ជកម្មពោលគឺ របៀបវារៈក្រុងដូហា បានទទួលស្គាល់អំពីតម្រូវការពិសេសរបស់ប្រទេសដែលមានការអភិវឌ្ឍតិចតួច នៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី ។ សេចក្តីថ្លែងការណ៍ថ្នាក់រដ្ឋមន្ត្រីនៅទីក្រុង ដូហាបាននិយាយតែអំពីសារៈសំខាន់នៃភាពបន្ទាន់សម្រាប់ LDCs ដើម្បីចូលជាសមាជិក WTO និងអំពីតម្រូវការឱ្យមានជំនួយបច្ចេកទេស និងការកសាងសមត្ថភាព ។

*មានកិច្ចប្រឹងប្រែងតិចតួចដើម្បីបំលែងការប្តេជ្ញានយោបាយនេះឱ្យទៅជាសកម្មភាពអនុវត្ត*

ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីនោះ មានកិច្ចប្រឹងប្រែងតិចតួចដើម្បីបំលែងការប្តេជ្ញានយោបាយនេះឱ្យទៅជាសកម្មភាពអនុវត្ត ។ នៅឆ្នាំ២០០៤ ក្រោយបរាជ័យនៃសន្និសីទថ្នាក់រដ្ឋមន្ត្រីរបស់ WTO នៅទីក្រុងកាន់គុន ក្រុមដ៏មានឥទ្ធិពលមួយនៃប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសជឿនលឿន ដោយមានការចូលរួមតិចតួចពីLDCsបានសម្រួលឱ្យមាន "ក្របខ័ណ្ឌខែកក្កដា" ។ ប៉ុន្តែ សូម្បីតែក្របខ័ណ្ឌនេះក៏ពុំបានលើកឡើងផងដែរអំពីកង្វល់ភាគច្រើនទាក់ទងនឹងការធ្វើសមាហរណកម្ម LDCs

ទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ ចំណុចដែលថែងមានភាពទន់ខ្សោយលើបញ្ហាមួយចំនួន។ ឧទាហរណ៍ ជំនួសការតម្រូវឱ្យប្រទេសជឿនលឿនផ្តល់ SDT ដល់ប្រទេសកំពុងអភិវឌ្ឍន៍ក្រីក្រ ក្របខ័ណ្ឌនេះបានត្រឹមតែថែងថា "វិន័យលើការគាំទ្រសម្រាប់ការនាំចេញនឹងត្រូវរៀបចំឡើងដោយពិចារណាអំពីផលប៉ះពាល់លើប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាអ្នកនាំចូលសុទ្ធនូវស្បៀង"។ ដូចគ្នានេះដែរ ការថែងនៅទីនេះពុំបង្ហាញពីការប្តេជ្ញាទេ នៅពេលនិយាយពីវិធីសម្រេចឱ្យបាននូវសមាហរណកម្មពេញលេញនៃសេដ្ឋកិច្ចតូចតាច និងដែលងាយរងគ្រោះទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។

កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងហុងកុង នាខែធ្នូ ឆ្នាំ ២០០៥ បានធ្វើឱ្យមានការរីកចម្រើនជាង។ សមាជិកបានឯកភាពថាសមាជិកជាប្រទេសជឿនលឿនត្រូវ និងសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ដែលប្រកាសខ្លួនឯងអំពីគោលជំហរក្នុងការធ្វើបែបនេះ គួរតែផ្តល់លទ្ធភាពប្រើប្រាស់ទីផ្សារដោយឥតយកពន្ធនិងមិនកំណត់កូតា សម្រាប់រយៈពេលវែងសម្រាប់គ្រប់ផលិតផលដែលមានប្រភពពី LDCs ទាំងអស់ រហូតដល់ឆ្នាំ ២០០៨ ឬមិនឱ្យយឺតជាងពេលចាប់ផ្តើមដំណាក់កាលអនុវត្តរបៀបវារៈនៃទីក្រុងដូហា តាមវិធីដែលធានាស្ថិរភាព សន្តិសុខ និងភាពព្យាករណ៍បាន។ ទោះជាយ៉ាងណាក៏ដោយ សមាជិកនានាដែលយល់ថានេះជាការលំបាកអាចត្រូវបានអនុញ្ញាតឱ្យចូលប្រើប្រាស់ទីផ្សារដោយឥតយកពន្ធ និងមិនកំណត់កូតាសម្រាប់តែ ៩៧% នៃលិតផលដែលមានប្រភពពី LDCs។ សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍នឹងត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមកាតព្វកិច្ចរបស់ខ្លួន និងប្រកាន់យកភាពទន់ភ្លន់នៃការអនុវត្តរបស់ខ្លួន។

បន្ទាប់ពីកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងហុងកុង LDCs ក៏ត្រូវបានអនុញ្ញាតឱ្យរក្សាទុកជាបណ្តោះអាសន្ននូវវិធានការដែលមានស្រាប់ដែលខុសពីកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀង TRIMs។[៦២] ប្រទេសទាំងនោះក៏អាចចាត់វិធានការថ្មីថែមទៀតផងដែរ ប្រសិនបើមានការឯកភាពពីក្រុមប្រឹក្សា WTO សម្រាប់ពាណិជ្ជកម្មលើទំនិញ។ ប្រការទាំងនេះអាចបន្តរយៈពេលប្រាំឆ្នាំ និងអាចបន្តឡើងវិញ ប៉ុន្តែត្រូវតែលុបចោលទាំងស្រុងនៅឆ្នាំ ២០២០។

ទីបំផុត មានការអះអាងឡើងវិញថា សមាជិក LDCs ត្រូវអនុវត្តការប្តេជ្ញានិងសម្បទានត្រឹមតែកម្រិតដែលស្របគ្នាជាមួយកម្រិតនៃការអភិវឌ្ឍ តម្រូវការហិរញ្ញវត្ថុ ឬពាណិជ្ជកម្ម ឬសមត្ថភាពខាងរដ្ឋបាល និងស្ថាប័នរបស់ខ្លួនរៀងៗខ្លួនរបស់ប្រទេសនីមួយៗតែប៉ុណ្ណោះ។

## មាគ៌ាទៅមុខ

ប្រទេសដែលមានការអភិវឌ្ឍតិចតួចនៅក្នុងតំបន់នេះ អាចចូលរួមដែលអាចផ្តល់ប្រយោជន៍ច្រើនជាងមុនជាមួយប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ ប៉ុន្តែទាមទារឱ្យមានសកម្មភាពប្រកបដោយការប្តេជ្ញាជាមុន ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ។

## របៀបវារៈជាតិ

- *ចាត់ទុកបញ្ហាពាណិជ្ជកម្មជាអាទិភាពខ្ពស់* : រដ្ឋាភិបាលត្រូវដាក់បញ្ចូលបញ្ហាពាណិជ្ជកម្មទៅក្នុងស្ថាបត្យកម្មអភិវឌ្ឍន៍ទូទៅរបស់ខ្លួន រួមទាំងឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដើម្បីធានាថាមានភាពជាម្ចាស់របស់ជាតិ និងធ្វើឱ្យមានការសម្របសម្រួលប្រសើរជាងមុនក្នុងចំណោមទីភ្នាក់ងារខុសៗគ្នា។ នៅពេលចរចាអំពីការប្តេជ្ញាពាណិជ្ជកម្មអន្តរជាតិ ប្រទេសទាំងនោះត្រូវធានាថា ការប្តេជ្ញាទាំងនោះបានពិចារណាពេញលេញអំពីអាទិភាព

*រដ្ឋាភិបាលត្រូវដាក់បញ្ចូលបញ្ហាពាណិជ្ជកម្មទៅក្នុងស្ថាបត្យកម្មអភិវឌ្ឍន៍ទូទៅរបស់ខ្លួន*

អភិវឌ្ឍន៍មនុស្ស។ ប្រទេសទាំងនេះក៏ត្រូវធ្វើការជិតស្និទ្ធជាមួយផ្នែកឯកជន និងអង្គការសង្គមស៊ីវិល និងសុំយោបល់របស់អង្គការទាំងនោះនៅគ្រប់ដំណាក់កាលនីមួយៗ។

- *បង្កើនផលិតភាពនិងភាពប្រកួតប្រជែង* : នេះមានន័យថា ត្រូវធ្វើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ រួមទាំងផ្លូវថ្នល់ ទូរគមនាគមន៍ឃ្លាំង និងបរិក្ខារកំពង់ផែ។ ទោះបី LDCs គួរតែអាចពឹងផ្អែកលើជំនួយពីខាងក្រៅក៏ដោយ ប្រទេសទាំងនេះក៏ត្រូវតែកៀងគរធនធានខ្លះៗនៅក្នុងប្រទេសផងដែរ។ លើសពីនេះ ពួកគេត្រឹមតែពង្រឹងសមត្ថភាពរបស់សហគ្រាសនៅក្នុងស្រុក ជាពិសេសពង្រឹងសក្តានុពលនៃសេដ្ឋកិច្ចដែលផ្អែកលើមូលដ្ឋាននៃចំណេះដឹង។ ទន្ទឹមនឹងនេះ ប្រទេសទាំងនេះត្រូវពង្រឹងស្ថាប័ន និងប្រព័ន្ធច្បាប់ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងទប់ស្កាត់ការតែបន្លំ ការបោកប្រាស់ និងចរាចរធនធាន។
- *ផ្តល់ការទូទាត់សំណងនិងការពារការអភិវឌ្ឍមនុស្ស* : រដ្ឋាភិបាលគួររិះរកវិធីទូទាត់សំណងដល់អ្នកដែលបង់ចាញ់ដោយសារសមាហរណកម្មពាណិជ្ជកម្ម ឧទាហរណ៍ តាមរយៈការរក្សាទុកបរិក្ខារ ប្រាក់ឧបត្ថម្ភដល់អ្នកបាត់បង់ការងារ និងឥណទានសងជម្ងឺចិត្ត។ រដ្ឋាភិបាលក៏ត្រូវតែការពារវិស័យដែលមានប្រយោជន៍ជាពិសេសសម្រាប់ការអភិវឌ្ឍមនុស្ស ដូចជា សន្តិសុខស្បៀង និងសុខភាពសាធារណៈផងដែរ។
- *បង្កើនមុខទំនិញនាំចេញនិងទីផ្សារ* : ដើម្បីទប់ស្កាត់ការធ្លាក់ចុះនៃពាណិជ្ជកម្ម បណ្តាលពីភាពប្រែប្រួលនៃការនាំចេញមុខទំនិញជាអន្តរជាតិ LDCs មិនត្រឹមតែបង្កើនមុខទំនិញទៅរកវិស័យដែលបន្ថែមតម្លៃឱ្យណាមិកនិងកម្មន្តសាលប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងទៅក្នុងវិស័យសេវាកម្មផងដែរ ដោយផ្តល់កិច្ចប្រឹងប្រែងពិសេសដើម្បីធ្វើអត្តសញ្ញាណ ផលិតផល និងសេវាពិសេសដោយឡែកក៏ដូចជាគោលដៅថ្មីសម្រាប់ការនាំចេញផងដែរ (ប្រអប់ ៦.៦)។

## របៀបវារៈអន្តរជាតិ និងប្រចាំតំបន់

- *កសាងសម្ព័ន្ធភាពដែលទុកចិត្តបាន* : LDCs មិនអាចមានឥទ្ធិពលប្រកបដោយប្រសិទ្ធិភាព

---

ប្រអប់ ៦.៦

### ផលិតផលពិសេសតែមួយ : កាលានុវត្តភាពសម្រាប់ LDCs

ប្រទេសដែលមិនជាប់សមុទ្រនិងប្រទេសតូចៗខ្លះអាចប្រកាន់យកវិធានទីផ្សារសមស្របសម្រាប់នាំចេញផលិតផល។ អត្ថប្រយោជន៍ពិសេសគឺកាលានុវត្តភាពនៅក្នុងទីផ្សារ សម្រាប់ផលិតផល"បៃតង"ដែលផ្អែកលើធម្មជាតិ ដូចជាផ្លែឈើ និងបន្លែសរីរាង្គ និងកម្រាលឡៃន ឬកន្ទេលបង់ក ដែលធ្វើតែពីសសៃធម្មជាតិនិងល័ក្ខពីរុក្ខជាតិ។ ផលិតផលទាំងនេះសមស្របសម្រាប់ផ្គត់ផ្គង់ដល់ផ្នែកដែលកាន់តែរីកចម្រើននៃ"អ្នកប្រើប្រាស់ផលិតផលបៃតង"នៅក្នុងប្រទេសជឿនលឿន។

ផលិតផលពិសេសតែមួយបែបនេះក៏អាចបង្កើតឡើង ដោយផ្អែកលើបេតិកភណ្ឌវប្បធម៌នៃប្រទេសទាំងនេះផងដែរ។ ប្រទេសមួយចំនួននៅប៉ាស៊ីហ្វិក ដូចជា សាម៉ាវ តុងហ្គា និង វ៉ាណាទូ អាចបង្កើតផលិតផលកាវ៉ា សម្រាប់នាំចេញ ដែលជាភេសជ្ជៈជាប្រពៃណី និងរុក្ខជាតិឱសថ។

ដូចគ្នានេះដែរ មានសេវាជាច្រើនដែលពឹងផ្អែកលើទិដ្ឋភាពធម្មជាតិ ដូចជាទេសភាព ដែលពុំទាន់រងការរំខាន ឧទាហរណ៍ ទេសចរណ៍បរិស្ថាននៅប្រទេសនេប៉ាល់ និងប៊ូតាណទេសចរណ៍ ខ្នមតូចៗនៅវ៉ាណាទូ ។ នៅក្នុងវិស័យទេសចរណ៍ ក៏អាចមានលទ្ធភាពសម្រាប់បង្កើតឯកទេសកម្មដទៃទៀតដែរ ដូចជាការជិះទូកក្តោង ឬការនេសាទកីឡានៅក្នុងដែនទឹកឧបទ្វីប ដូចជានៅម៉ាល់ឌីវ។

**ប្រភព : Adapted from UNCTAD ១៩៩៩។**

ទៅលើការចរចាដោយធ្វើសកម្មភាពដាច់ដោយឡែកពីគ្នា ឬជាក្រុមតូចនោះឡើយ ។ ជាជំនួសប្រទេសទាំងនេះត្រូវតែកសាងសម្ព័ន្ធភាពទូលំទូលាយនៅជុំវិញគោលការណ៍ជាក់លាក់ ឬលើបញ្ហានានា ដូចជាភាពងាយរងគ្រោះ និងធ្វើការចរចាជាប្លុក ។

- *សម្រេចលក្ខខណ្ឌប្រសើរនៅពេលចូលជាសមាជិក* : LDCs ត្រូវតែធ្វើការតស៊ូមតិដើម្បីឱ្យមានគោលការណ៍ណែនាំច្បាស់លាស់សម្រាប់ការចូលជាសមាជិក WTO ។ គោលការណ៍ទាំងនោះគួររួមបញ្ចូល ពេលកំណត់សម្រាប់ដំណាក់កាលនីមួយៗនៃការចរចាកម្រិតអតិបរមានៃការប្រើប្រាស់ទីផ្សារ និងលក្ខខណ្ឌ ដើម្បីឱ្យមានការពិចារណាពិតប្រាកដអំពីតម្រូវការខាងពាណិជ្ជកម្ម ការអភិវឌ្ឍ និងហិរញ្ញវត្ថុ ព្រមទាំងសមត្ថភាពខាងស្ថាប័នរបស់ខ្លួន ។ លើសពីនេះ ពួកគេត្រូវភ្ជាប់លក្ខខណ្ឌនៃការអនុវត្តការប្តេជ្ញាជាមួយវត្តមានជំនួយបច្ចេកទេស ។ លក្ខខណ្ឌ WTO-បូក គួរតែត្រូវបញ្ឈប់ ។
- *ជម្រុញឱ្យមានជំនួយបច្ចេកទេស* : អ្នកចូលរួមនៅក្នុងពាណិជ្ជកម្មជាច្រើន រួមទាំងឧស្សាហករ កសិករ និងអ្នកផ្តល់សេវា នឹងទទួលអត្ថប្រយោជន៍ពីកម្មវិធីជំនួយបច្ចេកទេស ដែលផ្តោតគោលដៅបានច្បាស់លាស់ ។ ជំនួយពីក្រៅបែបនេះអាចរំដោះធនធានរបស់រដ្ឋាភិបាលដែលចាំបាច់បំផុតសម្រាប់សម្រេចឱ្យបាននូវគោលបំណងការអភិវឌ្ឍន៍មនុស្ស ។

*ពង្រឹងប្រការអំពី SDT*: SDT គួរតែអាចអនុវត្តទៅបានប្រកបដោយប្រសិទ្ធិភាព និងអាចគោរពបាន ។ នេះមានន័យថា មិនត្រឹមតែដាក់បញ្ចូលប្រការទាំងនេះទៅក្នុងស្ថាបត្យកម្ម WTO ប៉ុណ្ណោះទេ ប៉ុន្តែត្រូវកសាងផងដែរនូវយន្តការដើម្បីតាមដានការអនុវត្តរបស់ពួកគេ ។ ក្នុងន័យនេះគួរតម្រូវឱ្យគណៈកម្មាធិការនានានៅក្នុង WTO ដាក់ជូនរបាយការណ៍ជាទៀងទាត់ ។

- *ផ្តល់ជំនួយសម្រាប់ពាណិជ្ជកម្ម* : លទ្ធភាពនៃការបាត់បង់សមាហរណកម្មពាណិជ្ជកម្មសម្រាប់ LDCs តម្រូវឱ្យមានតួនាទីថ្មីសម្រាប់ជំនួយ ពោលគឺការទូទាត់ជាសំណងសម្រាប់ការខាតបង់ និងការផ្តល់ជំនួយសម្រាប់កំណែទម្រង់ ។ គួរផ្តល់ជំនួយ ដើម្បីអភិវឌ្ឍសមត្ថភាពរបស់អ្នកចរចាជាតំណាងប្រទេស និងកសាងស្ថាប័នឱ្យបានរឹងមាំជាងមុន ។ លើសពីនេះ គួរតែដោះស្រាយបញ្ហាខាងការផ្គត់ផ្គង់ដែលជាឧបសគ្គចំពោះការឆ្លើយតបនឹងតម្រូវការនាំចេញ ។
- *ផ្តោតលើការអភិវឌ្ឍមនុស្ស* : ពាណិជ្ជកម្មមិនមែនជាគោលដៅចុងក្រោយនោះទេ ។ វាជាមធ្យោបាយឆ្ពោះទៅគោលដៅចុងក្រោយ ។ ដូច្នេះ រាល់កិច្ចផ្តួចផ្តើមពាណិជ្ជកម្ម គួរតែផ្អែកលើទស្សនៈវិស័យអំពីការអភិវឌ្ឍមនុស្ស ។ គួរផ្តោតការយកចិត្តទុកដាក់មិនមែនត្រឹមតែលើលទ្ធភាពចូលទៅប្រើប្រាស់ទីផ្សារនោះទេ ប៉ុន្តែលើការសម្រេចឱ្យបានលទ្ធផលអភិវឌ្ឍន៍មនុស្សប្រសើរជាងមុន តាមរយៈបទបញ្ញាពាណិជ្ជកម្ម ដែលអនុញ្ញាតឱ្យមានភាពសំបូរបែបនៃគ្រឹះស្ថានជាតិ និង ស្តង់ដារ ។

*រាល់កិច្ចផ្តួចផ្តើមពាណិជ្ជកម្មគួរតែផ្អែកលើទស្សនៈវិស័យអំពីការអភិវឌ្ឍមនុស្ស*

# 7



៧
ជំពូក

# ពាណិជ្ជកម្មសម្រាប់អភិវឌ្ឍន៍មនុស្ស : របៀបវារៈប្រាំបីចំណុច

តំបន់អាស៊ី-ប៉ាស៊ីហ្វិកច្រើនតែអនុវត្តបានយ៉ាងអស្ចារ្យលើការធ្វើពាណិជ្ជកម្ម និងធ្វើឱ្យមានភាពរីកចម្រើនលើការអភិវឌ្ឍមនុស្ស ។ ប៉ុន្តែទិន្នាការថ្មីៗបំផុត គឺជាការគួរឱ្យព្រួយបារម្ភ ដោយមានការរំខានសម្រាប់បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច និងសូម្បីតែប្រជាពលរដ្ឋក្រីក្រជាងគេនៅក្នុងសេដ្ឋកិច្ចធំជាង និងឌីណាមិក ដែលពាណិជ្ជកម្មបានកើតឡើងទន្ទឹមនឹងការបង្កើតការងារមិនគ្រប់គ្រាន់ និងកំណើនវិសមភាព ។ តើពាណិជ្ជកម្មបម្រើការអភិវឌ្ឍមនុស្សបែបណា? ជំពូកនេះសង្ខេបអំពីអនុសាសន៍គោលនយោបាយចម្បងៗនៃរបាយការណ៍នេះ និងលើកស្នើរបៀបវារៈចំនួនប្រាំបីចំណុច ។

ពិភពលោកបានឃើញតំបន់អាស៊ី-ប៉ាស៊ីហ្វិកជាការីគន្លឹះនៅពេលនិយាយអំពីសកលភាវូបនីយកម្ម ។ ប៉ុន្តែ ប្រទេសផ្សេងៗ ជាពិសេសប្រទេសដែលមានធនធានច្រើនជាងគេ មានទស្សនៈប្រកបដោយមហិច្ឆតាថា នៅក្នុងបរិយាកាសពាណិជ្ជកម្មប្រកបដោយសេរីភាវូបនីយកម្មជាងមុន តំបន់នានានៅលើពិភពលោកប្រឈមការគម្រាមកំហែងពីអាស៊ីនិងប៉ាស៊ីហ្វិក ដែលលេចឡើងជារោងចក្រមួយនៃពិភពលោក និងមានសមត្ថភាពផ្តល់ទំនិញនិងសេវាដោយតម្លៃថោកជាងប្រទេសជឿនលឿន នៅក្នុងផលិតកម្មរបស់គ្រប់យ៉ាង ចាប់ពីសម្លៀកបំពាក់ រហូតដល់ស្បែកជើង និងគ្រឿងអគ្គិសនី ។

រូបភាពដែលមើលឃើញមានភាពខុសគ្នានៅក្នុងតំបន់នេះ ។ តាមទស្សនៈមួយ វាឆ្លុះបញ្ចាំងអំពីពិភពលោក ប៉ុន្តែនៅក្នុងករណីនេះ គឺប្រទេសក្រីក្រជាងគេនៅក្នុងតំបន់នេះ ដែលឈរនៅពីមុខប្រទេសចិនប្រកបដោយការបារម្ភដោយយល់ថាអ្នកជិតខាងដ៏ធំនេះគឺជាអ្នកប្រកួតប្រជែងដ៏ខ្លាំងក្លា ដែលមានសមត្ថភាព ឧទាហរណ៍មិនត្រឹមតែចាប់យកទីផ្សារនាំចេញរបស់ខ្លួនសម្រាប់វាយនភណ្ឌ និងសម្លៀកបំពាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចយកទីកន្លែង សូម្បីតែឧស្សាហកម្មតូចតាចនៅក្នុងស្រុកខ្លះៗផងដែរ ។ ពួកគេក៏មិនអាចមើលឃើញកាលានុវត្តភាពដើម្បីឆ្លើយតបក្នុងការនាំចេញទៅប្រទេសចិនឡើយដែលច្រើនតែត្រូវការវត្ថុធាតុដើម ម៉ាស៊ីន និងបរិក្ខារបច្ចេកវិទ្យាជាន់ខ្ពស់ផងដែរ ។

នៅក្នុងតំបន់នេះ លំហូរពាណិជ្ជកម្មក៏មានភាពសាំញ៉ាំដែរ ហើយតាមទស្សនៈជាច្រើន លំហូរពាណិជ្ជកម្មមានសារៈសំខាន់ណាស់ ដោយសារទម្រង់ថ្មីនៃពាណិជ្ជកម្មមិនត្រឹមតែបញ្ច្រាសទិសនៃលំហូរទំនិញ និងប្រាក់ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងមានឥទ្ធិពលទៅលើការអភិវឌ្ឍជាតិផងដែរ ។ ពលករនៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក ចាប់ពីណេប៉ាល់ ដល់ ណៅរូ រៀនសូត្របានយ៉ាងឆាប់រហ័សអំពីអត្ថន័យនៃពាក្យ WTO ដែលអាចល្អ ឬអាក្រក់ នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។

ចំពោះប្រជាពលរដ្ឋក្រីក្រជាងគេនៅក្នុងប្រទេសដែលក្រីក្រជាងគេ ប្រការទាំងនេះទាក់ទងមិនត្រឹមតែជាមួយយុទ្ធសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែជាមួយការរស់រានមានជីវិតទៀតផង ។ ឧបមាថា កម្មករទទួលទូរស័ព្ទម្នាក់នៅចក្រភពអង់គ្លេស ឬស.រ.អា បានផ្លាស់ទីទៅក្រុងដេលី ឬម៉ានីល គាត់អាចត្រូវបានគេជួលឱ្យធ្វើការដូចគ្នានៅទីកន្លែងផ្សេង ឬអាចប្រើប្រាស់ប្រព័ន្ធ

*ពលករនៅទូទាំងតំបន់អាស៊ី-ប៉ាស៊ីហ្វិក រៀនសូត្របានយ៉ាងឆាប់រហ័សអំពីអត្ថន័យនៃពាក្យ WTO មានន័យថាជាអ្វីៗដែលអាចល្អ ឬអាក្រក់ ក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ*

សន្តិសុខសង្គមដើម្បីស្វែងរកមុខការថ្មីបាន។ ប៉ុន្តែ ស្ត្រីជនជាតិបង់ក្លាដេស ដែលដេរសំពត់សម្រាប់រោងចក្រកាត់ដេរមួយ អាចមានរបស់បន្តិចបន្តួច ឬគ្មានអ្វីសោះ សម្រាប់ជាបង្អែកនៅពេលដែលគេប្រាប់គាត់ថាគេពុំត្រូវការគាត់ទៀតទេ។

នេះជាមូលហេតុដែលរបាយការណ៍នេះបានបង្កប់កង្វល់អំពីការអភិវឌ្ឍមនុស្ស ទៅក្នុងបេះដូងនៃពាណិជ្ជកម្មអន្តរជាតិ។ ទីមួយ របាយការណ៍នេះចង្អុលបង្ហាញពីវិធីជាច្រើនដែលពាណិជ្ជកម្មមានឥទ្ធិពលទៅលើការរស់នៅរបស់ប្រជាជនពោលគឺវាមានឥទ្ធិពលទៅលើរបៀបដែលពួកគេរស់នៅ អ្វីដែលពួកគេធ្វើ និងតើពួកគេអាចក្លាយជាអ្វី។ ទីពីរ របាយការណ៍នេះបង្ហាញអំពីថា តើការអភិវឌ្ឍមនុស្ស និងពាណិជ្ជកម្មអន្តរជាតិមានចំណងទាក់ទងជាមួយគ្នាបែបណា ដែលតាមទស្សនៈខ្លះវាជាផ្លូវមួយដែលមានចរាចរពីរទិស និងតាមទស្សនៈខ្លះទៀតវាជាផ្លូវត្រឡែងកែងដែលមានខ្សែចរាចរជាច្រើនជួរ។

អ្នកខ្លះព្យាយាមជៀសវាងភាពសាំញ៉ាំនេះ ដោយគេចចេញឆ្ងាយពីប្រធានបទនេះ។ នៅចុងម្ខាង មានអ្នកដែលចូលចិត្តបង្កើតរបាំងខ្ពស់សម្រាប់ពាណិជ្ជកម្ម និងចង់ឱ្យមានការពឹងផ្អែកលើខ្លួនឯងរបស់ជាតិ។ ហេតុអ្វីពឹងផ្អែកលើការនាំចូលនៅពេលដែលអ្នកអាចផលិតរបស់ប្រហែលគ្នាដោយខ្លួនឯង? នៅចុងម្ខាងទៀត គឺជាអ្នកលើកស្នើឱ្យមានពាណិជ្ជកម្មសេរីដែលចង់ឱ្យបានជម្រើសគ្មានរបាំងទាល់តែសោះ។ ហេតុអ្វីព្យាយាមកែប្រែលំហូរពាណិជ្ជកម្មនៅពេលដែលលំហូរដោយសេរីនូវទំនិញ ឬមនុស្ស អាចធ្វើឱ្យផលិតកម្មនៅលើពិភពលោកឈានដល់កម្រិតធម្មជាតិរបស់វា ដោយអនុញ្ញាតឱ្យទីផ្សារជាអ្នកបញ្ជាទីតាំងដែលសមស្របបំផុតសម្រាប់សេដ្ឋកិច្ច។

គ្មានចុងខាងណាមួយផ្តល់ការវិនិច្ឆ័យបានល្អនោះទេ។ ការពឹងផ្អែកទាំងស្រុងលើខ្លួនឯងរបស់ប្រទេសនីមួយៗ - អធិបតេយ្យភាពដាច់ខាត - ជាការអំពាវនាវដ៏រំភើប ប៉ុន្តែបន្តិចក្រោយមកក៏ប្រឈមនឹងការលំបាកជាក់ស្តែង។ តើនេះមានន័យថា គ្រប់ប្រទេសតូចៗទាំងអស់គួរតែមានឧស្សាហកម្មឱសថដោយខ្លួនឯងឬយ៉ាងណា ឬមួយព្យាយាមរស់នៅដោយគ្មានថ្នាំបង្ការជម្ងឺកញ្រ្ជិល ឬថ្នាំព្យាបាលជម្ងឺ HIV/AIDS? ប្រជាពលរដ្ឋនៅក្នុងសតវត្សរ៍ទី២១ មានសិទ្ធិខាងសង្គម និងខាងសេដ្ឋកិច្ច អាចបំពេញបានតែតាមរយៈពាណិជ្ជកម្មអន្តរជាតិ។

ប្រការដែលទាក់ចិត្ត និងគួរឱ្យជឿបានគឺ ជម្រើសពាណិជ្ជកម្មសេរី។ ប៉ុន្តែ ជម្រើសនេះក៏នាំឱ្យមានការយល់ច្រឡំផងដែរ ដោយសារវាពាក់ព័ន្ធនឹងពាណិជ្ជកម្មរវាងដៃគូមិនស្មើភាពគ្នា។ ប្រហែលជាវាមានភាពទាក់ទាញ ដោយសារវាបានប្រើប្រាស់ពាក្យគន្លឹះ "សេរី"។ ទោះជាយ៉ាងណាក៏ដោយ បើពិនិត្យឱ្យបានដិតដល់ វាបង្ហាញច្បាស់ថានេះជាសេរីភាពសម្រាប់ទំនិញ និងសម្រាប់ប្រាក់កាស មិនមែនសេរីភាពសម្រាប់មនុស្សឡើយ។ ពុំមានកសិករតូចតាចនៅឥណ្ឌូណេស៊ីត្រូវបានប្រាប់ថាគាត់នឹងទទួលបានប្រាក់តិចជាងមុន ៣០សេន សម្រាប់ផលដំណាំនៅក្នុងឆ្នាំនេះទេ ព្រោះថា ពាណិជ្ជកម្មសេរីបើកឱ្យចូលដោយគ្មានកំណត់នូវបរិមាណផលស្រូវដែលត្រូវបានផលិតក្រោមការឧបត្ថម្ភធនពីស.រ.អា នឹងមានអារម្មណ៍បែបណាអំពីសេរីភាវូបនីយកម្ម។ ប្រហែលជា "ពាណិជ្ជកម្មដែលគ្មានការត្រួតត្រា" អាចជាការអធិប្បាយប្រាកដនិយមជាងអំពីពិភពលោកដែលគ្មានពន្ធ ដែលបង្ហាញថា ដើម្បីមានសុវត្ថិភាពនៅពេលណាមួយការដាក់កំហិតគួរតែបង្កើតឡើងដោយប្រុងប្រយ័ត្ន។

នេះជាមូលហេតុដែលរបាយការណ៍នេះបានគាំទ្រឱ្យមានគោលនយោបាយដែលផ្អែកលើភាពប្រាកដនិយមជាងមុន។ របាយការណ៍នេះទទួលស្គាល់នូវតម្លៃនៃវិស័យឯកជនថាជាក្បាលម៉ាស៊ីនចម្បងសម្រាប់កំណើនសេដ្ឋកិច្ច ប៉ុន្តែបាននិយាយថា ត្រូវតែពង្រឹង ឬតម្រង់ទិសថាមពលខ្លះៗទាំងនេះ

ប្រសិនបើចង់បម្រើគោលដៅនៃការអភិវឌ្ឍមនុស្ស។ ប្រការនេះ គួរតែកើតឡើងដោយគ្មានការភ្ញាក់ផ្អើលនៅក្នុងតំបន់នេះ ដែលនៅផ្នែកខាងក្រោយនៃសតវត្សរ៍ទី២០ គឺការបង្កើតគំរូសម្រាប់កំណើនសេដ្ឋកិច្ចទំនើប ដែលដឹកមុខដោយពាណិជ្ជកម្ម។ នរណាម្នាក់តាមដានអំពីស្នាមដានជើងរបស់ "ខ្លាអាស៊ី" នឹងទទួលស្គាល់ថា ជំហានទាំងនោះប្រកាន់យកជំហរជាយុទ្ធសាស្ត្រ ដោយជ្រើសរើសឧស្សាហកម្មក្មេងខ្ចីណាមួយដើម្បីជួយទ្រទ្រង់ និងនៅពេលណាដើម្បីធ្វើសេរីភាវូបនីយកម្មមុនពេលដាក់ពិភពលោកនៅក្រោមកម្លាំងព្យុះនៃលំហូរទំនិញ។ ពុំចាំបាច់ជ្រើសរើសតែឧទាហរណ៍ពីអាស៊ីនោះទេ។ បើពិនិត្យមើលបកក្រោយវិញ ទៅក្នុងសតវត្សរ៍ទី១៩ អំពីគោលនយោបាយ "ពាណិជ្ជវិស័យ" របស់ប្រទេសដែលបច្ចុប្បន្នជា "ប្រទេសជឿនលឿន" នូវកំណត់ត្រានៃការដាក់កំហិតលើពាណិជ្ជកម្ម រួមទាំងលើការនាំចូលវាយនភណ្ឌពីអាស៊ី ដែលផ្តល់ឱ្យប្រទេសទាំងនេះ នូវដង្ហើមសម្រាប់ដក មុនពេលដែលឧស្សាហកម្មក្មេងខ្ចីរបស់ប្រទេសទាំងនោះពេញវ័យគ្រប់គ្រាន់ ដើម្បីលក់ទំនិញរបស់ខ្លួននៅទូទាំងពិភពលោក។

ពាណិជ្ជកម្មមិនដែលជាកិច្ចការរបស់ឧស្សាហកម្មឯកជនតែម្នាក់ឯងនោះទេ។ វាតែងតែស្ថិតក្រោមអន្តរាគមន៍យ៉ាងសកម្មរបស់រដ្ឋ។ តួនាទីស្នូលរបស់រដ្ឋនេះអាចមិនត្រូវបានមើលឃើញថាជាទស្សនៈវិស័យប្រកបដោយការលើកទឹកចិត្តនោះទេ។ តើអាចជឿទុកចិត្តបានដែរឬទេ? ទោះជាយ៉ាងណាក៏ដោយ បទបញ្ជាពាណិជ្ជកម្មផ្តល់ឱ្យអ្នកនយោបាយ និងមន្ត្រីសាធារណៈនូវអំណាចយ៉ាងច្រើន និងឆន្ទានុសិទ្ធិ។ យ៉ាងហោចណាស់ ប្រការនេះអាចជាការដាក់បន្ទុកធ្ងន់ធ្ងរពេកទៅលើមនុស្សដែលមានសមត្ថភាពទាប ឬពេលវេលាតិចតួចដើម្បីដោះស្រាយបញ្ហាជំនួញដ៏សាំញ៉ាំ ដែលពោរពេញទៅដោយពាក្យបំព្រួញ និងបច្ចេកស័ព្ទដែលមិនអាចយល់បាន។ អាក្រក់បំផុតនោះ វាបើកទ្វារចំហទូលាយជាងមុនសម្រាប់ភាពលំអៀងទៅរកអំពើពុករលួយ និងការប្រព្រឹត្តអំពើពុករលួយ។

ទោះជាយ៉ាងណាក៏ដោយ មានសញ្ញាជាច្រើនដែលគួរឱ្យទុកចិត្ត។ ក្រុមសង្គមស៊ីវិល និងប្រព័ន្ធឃោសនាព័ត៌មានទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ ឥឡូវនេះបានយកចិត្តទុកដាក់កាន់តែខ្លាំងឡើងលើការចរចាពាណិជ្ជកម្ម ដែលកាលពីប៉ុន្មានឆ្នាំមុននេះ បានធ្វើឡើងដោយលាក់កំបាំង។ ពួកគេបានទាមទារយ៉ាងត្រឹមត្រូវឱ្យមានតម្លាភាព សង្គតិភាព និងភាពត្រឹមត្រូវកាន់តែច្រើនឡើង។ ភាពអាថ៌កំបាំងនៅតែមាននៅឡើយ ហើយទ្វារជាច្រើននៅតែបិទនៅឡើយ ប៉ុន្តែ យ៉ាងហោចណាស់ ឥឡូវនេះមន្ត្រីពាណិជ្ជកម្មដែលបានបើកភ្នែកឡើងនៅពេលព្រលឹមបន្ទាប់ពីបានចរចាពេញមួយយប់ បានដឹងថា ជាញឹកញាប់ពួកគេនឹងត្រូវឆ្លើយតបចំពោះមុខកញ្ចក់ម៉ាស៊ីនថតទូរទស្សន៍។

ឥឡូវនេះ មនុស្សជាច្រើនបានសួរសំណួរលំបាកៗអំពីទិសដៅនិងកម្លាំងចលករនៃពាណិជ្ជកម្មអន្តរជាតិ។ ឧទាហរណ៍ ប្រសិនបើប្រទេសជឿនលឿនយកចិត្តទុកដាក់បែបនេះលើពាណិជ្ជកម្ម ហេតុអ្វីសហភាពអឺរ៉ុប និងស.រ.អា មានៈចង់ឱ្យមានការឧបត្ថម្ភធនយ៉ាងច្រើន ដែលកៀបសង្កត់ទៅលើទីផ្សារកសិផល? ហេតុអ្វីពួកគេសាទរអំពីលំហូរដោយសេរីនៃមូលធនទៅក្នុងប្រទេសក្រីក្រ ប៉ុន្តែភ្លាមៗនោះប្តូរគំនិតនៅពេលពិភាក្សាអំពីកាលានុវត្តភាព សម្រាប់លំហូរពលករទៅក្នុងប្រទេសរបស់ពួកគេ? ហេតុអ្វីឥឡូវនេះ ពួកគេមានការអល់អែកក្នុងការអនុញ្ញាតឱ្យប្រទេសនៅអាស៊ីបង្ហាញអំពីសក្តានុពលគួរឱ្យកត់សម្គាល់នៃអ៊ីនធឺណិត ដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋនៅទូទាំងពិភពលោកធ្វើការជាមួយគ្នា ដោយធ្វើលទ្ធកម្មផលិតកម្មកម្មវិធីកុំព្យូទ័រ ឬស្ថានីយ៍ទទួលទូរស័ព្ទ ឬរដ្ឋបាល ដោយការិយាល័យគាំទ្រ?

ក្នុងអំឡុងពេលនេះ របបពាណិជ្ជកម្មពិភពលោកថ្មី

*ពាណិជ្ជកម្មតែងតែស្ថិតក្រោមអន្តរាគមន៍យ៉ាងសកម្មរបស់រដ្ឋ*

កំពុងដាក់កំហិតទៅលើសេរីភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចរបស់ពួកគេ ។ ប្រមាណមួយទសវត្សរ៍មុននេះ នៅក្រោមរបបមុនពោលគឺ GATT ប្រទេសនានាមានសេរីភាពជាងក្នុងការជ្រើសរើសកម្រិតពន្ធ និងកូតាសម្រាប់ការនាំចូល និងដាក់ឱ្យមានការគ្រប់គ្រងរូបិយប័ណ្ណបរទេស ។ ឥឡូវនេះលក្ខខណ្ឌ IMF និងបទបញ្ជាដែល WTO បានបង្រួមជម្រើសនានា ជាពិសេសសម្រាប់អ្នកចូលជាសមាជិកថ្មីនៅក្នុង WTO បានធ្វើឱ្យប្រទេសអភិវឌ្ឍន៍តិចតួចច្រើនតែត្រូវចុះហត្ថលេខានៅលើបញ្ជីបន្ថែមច្រើនជាងបណ្តាសមាជិកចាស់របស់ WTO ។

ប្រការនេះធ្វើឱ្យបញ្ហានេះកាន់តែលំបាកសម្រាប់ប្រទេសជាច្រើនដែលឥឡូវនេះកំពុងតែព្យាយាមពង្រឹងកំណើនដោយផ្អែកលើការនាំចេញ ។ តាមពិត វាបង្កើតឱ្យមានសំណួរថាតើឥឡូវនេះយើងអាចឈានដល់ចុងបញ្ចប់នៃគំរូមួយ ដែលធ្លាប់បានជួយបណ្តាប្រទេសនៅអាស៊ីបានល្អប្រសើរនោះហើយឬយ៉ាងណា ។

តើប្រទេសនៅអាស៊ីនិងប៉ាស៊ីហ្វិកឆ្លើយតបបែបណាទៅនឹងស្ថានភាពថ្មីដែលមានតម្រូវការខ្ពស់បែបនេះ? ជាការច្បាស់ណាស់ថា ប្រហែលជាគ្មានផែនការជាលក្ខណៈស្តង់ដារនោះទេ ជាពិសេសសម្រាប់តំបន់ដែលមានវិសាលភាពធំ និងប្លែកគ្នាបែបនេះ ។ ប្រទេសនីមួយៗមានអាទិភាពរបស់ខ្លួន និងធ្វើតាមរបៀបវារៈរបស់ខ្លួន ។ ដូច្នេះ នៅក្នុងការចរចាអន្តរជាតិប្រទេសនានាអាចមិនត្រឹមតែមានអាទិភាពខុសគ្នាប៉ុណ្ណោះទេ ប៉ុន្តែអាចថែមទាំងមានផលប្រយោជន៍ផ្ទុយគ្នាថែមទៀតផង ។ ឧទាហរណ៍ប្រទេសដែលនាំស្បៀងចេញ អាចមានទស្សនៈខុសគ្នាពីប្រទេសដែលនាំស្បៀងចូល ។ ប្រទេសឥណ្ឌូណេស៊ី នឹងប្រកាន់ជំហរខុសគ្នាពីប្រទេសថៃ និងវៀតណាម ។ ប្រទេសដែលកាន់តែមានការជឿនលឿន នឹងមានអារម្មណ៍ងាយស្រួលជាមួយការប្រកួតប្រជែងពិភពលោក ជាងប្រទេសក្រីក្រ ។

ទោះជាយ៉ាងណាក៏ដោយនៅតែមានវិធីដើម្បីគ្របដណ្តប់ភាពខុសប្លែកគ្នាទាំងនេះផងដែរ ដោយពិនិត្យមើលបញ្ហាពាណិជ្ជកម្មតាមរយៈកញ្ចក់នៃការអភិវឌ្ឍមនុស្ស ។ ធ្វើបែបនេះនឹងជួយផ្តោតការយកចិត្តទុកដាក់លើបញ្ហានានា ដែលមានឥទ្ធិពលចំពោះជនក្រីក្រ ជាពិសេសអ្នកនៅក្នុងប្រទេសអភិវឌ្ឍន៍តិចតួច ។ នៅជំពូកខាងដើម របាយការណ៍នេះបានប្រកាន់យកមនោគមវិជ្ជានេះ ដោយបានធ្វើអត្តសញ្ញាណបញ្ហាលំអិតខ្លះៗនៅក្នុងវិស័យកសិកម្ម កម្មន្តសាល និងសេវា ។ បញ្ហាខ្លះនៅក្នុងចំណោមនេះមានលក្ខណៈទូទៅ ហើយបញ្ហាជាច្រើននឹងក្លាយទៅជាផ្នែកមួយនៃការឯកភាពមតិអំពីការអភិវឌ្ឍមនុស្ស ។ បញ្ហាផ្សេងទៀតអាចពុំសូវមានភាពច្បាស់លាស់ ហើយអាចមានលក្ខណៈបច្ចេកទេសជាង ប៉ុន្តែនៅតែអាចធ្វើឱ្យមានភាពខុសគ្នាចំពោះការរស់នៅរបស់ប្រជាជនក្រីក្រ ។ ជាជាងស្ថិតក្រោមឥទ្ធិពលនៃការចរចាដើម្បីជំនួញ ចំនុចស្នូលនៃការអភិវឌ្ឍមនុស្សគួរតែជាផ្នែកមួយនៃអាទិភាពរបស់ជាតិ ។[1] បញ្ហាចំនួនប្រាំបីដែលមានការប្រើប្រាស់ជាទូទៅខ្លះៗ រួមមាន :

## ១. វិនិយោគដើម្បីភាពប្រកួតប្រជែង

នៅក្នុងពិភពសកលភាវូបនីយកម្ម ការវិនិយោគសាធារណៈត្រូវពិចារណាទាំងកិច្ចការនៅថ្នាក់ជាតិ និងអន្តរជាតិ ។ ជាទូទៅ ប្រភេទនៃការវិនិយោគអាចនៅដដែល ប៉ុន្តែវាអាចត្រូវការឱ្យមានការកែសម្រួល ដោយផ្តោតលើការបង្កើនភាពប្រកួតប្រជែងជាអន្តរជាតិ ។ ដូច្នេះ នៅពេលពិនិត្យមើលហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន រដ្ឋាភិបាលត្រូវធានាថាខ្លួនមានផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ និងប្រព័ន្ធទូរគមនាគមន៍ ដែលស៊ីគ្នាជាមួយតម្រូវការរបស់ជាតិ និងជាមួយតម្រូវការដើម្បីបញ្ជូនទំនិញ និងសេវាទៅកាន់ទីផ្សារអន្តរជាតិឱ្យបានឆាប់រហ័ស និងដោយចំណាយតិច ។

ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ក៏មានសារៈសំខាន់ដូចគ្នានឹងមូលធនមនុស្សផងដែរ។ ប្រទេសដែលធ្វើពាណិជ្ជកម្មបានជោគជ័យជាងគេបានធ្វើការវិនិយោគយ៉ាងច្រើនលើការអភិវឌ្ឍមនុស្សដោយបង្កើតកម្លាំងពលកម្មដែលមានសុខភាពល្អ និងមានការអប់រំខ្ពស់ ដែលមានអំណត់ ជំនាញ និងភាពបត់បែនក្នុងការប្រឈមនឹងភាពប្រែប្រួលនៃបរិយាកាសពាណិជ្ជកម្ម។ ឧទាហរណ៍ នៅក្នុងរយៈពេលដ៏វែងមុនពេលដែលខ្លួនចាប់ផ្តើមបើកចំហប្រទេសសម្រាប់ពិភពលោក នៅចុងទសវត្សរ៍ឆ្នាំ ១៩៧០ ប្រទេសចិនមានសន្ទស្សន៍អភិវឌ្ឍន៍មនុស្សជាមូលដ្ឋានបានល្អរួចទៅហើយ។ ការអប់រំត្រូវតែចាប់ផ្តើមពីការសិក្សាយ៉ាងរឹងមាំ និងជាសកលនៅថ្នាក់បឋមសិក្សា ប៉ុន្តែឥឡូវនេះប្រទេសទាំងអស់ត្រូវតែធានាថាខ្លួនមានមនុស្សគ្រប់គ្រាន់ប្រកបដោយជំនាញបច្ចេកទេស និងគ្រប់គ្រង។ ជោគជ័យរបស់ឥណ្ឌាក្នុងការលក់សេវា IT គឺជារង្វាន់សម្រាប់ការវិនិយោគយ៉ាងច្រើនលើការអប់រំបច្ចេកទេស ដែលការវិនិយោគនោះស្ទើរតែទាំងអស់ទទួលមូលនិធិពីរដ្ឋាភិបាល។ ចំពោះប្រទេសតូចៗ អាចធ្វើបែបនេះបាន ប៉ុន្តែ យ៉ាងហោចណាស់ត្រូវតែមានគោលដៅធ្វើឱ្យមានតុល្យភាពនៃជំនាញ។ ប្រជាជនដែលបានទទួលការអប់រំបានល្អនៅថ្នាក់បឋម និងមធ្យមសិក្សាអាចបានត្រឹមតែប្រើប្រាស់សក្តានុពលរបស់ខ្លួនសម្រាប់ពាណិជ្ជកម្មអន្តរជាតិ ប្រសិនបើពួកគេមានការគាំទ្រពីអ្នកដទៃដែលមានការអប់រំខ្ពស់ជាង ឧទាហរណ៍ ខាងផ្នែកវិស្វកម្ម ទូរគមនាគមន៍ ឬគណនេយ្យ។ បុរសនិងស្ត្រី គួរតែមានកាលានុវត្តភាពស្មើគ្នាដើម្បីប្រើប្រាស់សក្តានុពលរបស់ខ្លួនឱ្យបានពេញលេញ។

ទន្ទឹមនឹងនេះ ប្រទេសជាច្រើនត្រូវវិនិយោគកាន់តែច្រើនឡើងលើ R&D ដែលដោះស្រាយជាពិសេសនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្រីក្រ។ ឧទាហរណ៍ សាធារណរដ្ឋកូរ៉េបានទទួលអត្ថប្រយោជន៍ពីការវិនិយោគយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ហើយនៅឆ្នាំ ២០០៤ មានអត្រាខ្ពស់ជាងគេនៅលើពិភពលោកនៃចំនួននិស្សិតចុះឈ្មោះចូលរៀន។ នៅកម្រិតទូលាយបំផុត R&D អាចរាប់បញ្ចូល "ការសិក្សាអំពីទស្សនៈវិស័យ" ដូចដែលបានកើតឡើងនៅក្នុងប្រទេសថៃ ដើម្បីគ្រោងទុកអំពីតម្រូវការទៅអនាគត និងផ្សារភ្ជាប់វិទ្យាសាស្ត្រជាមួយបច្ចេកវិទ្យា ដើម្បីឆ្លើយតបនឹងតម្រូវការខាងសេដ្ឋកិច្ចនិងសង្គម។ ប៉ុន្តែ ប្រទេសដែលមានភាពប្រកួតប្រជែង ត្រូវតែធ្វើការរុករកជាបន្តបន្ទាប់នូវបច្ចេកវិទ្យាសម័យថ្មីដែលសមស្របបំផុត ដែលអាចទាញយកប្រយោជន៍ពីចំណុចខ្លាំងរបស់ជាតិ។ ប្រការខ្លះៗអាចអនុវត្តទៅបានតាមរយៈភាពជាដៃគូរវាងសាធារណៈនិងឯកជន ដែលអាចរួមបញ្ចូលមូលនិធិបានពីមូលធនវិនិយោគ និងភាគហ៊ុនរបស់រដ្ឋាភិបាល ទោះបីភាគច្រើននៃ R&D ទៅលើកាលានុវត្តភាពដោយឡែកសម្រាប់អ្នកក្រីក្រទំនងជានឹងកើតឡើងនៅក្នុងវិស័យសាធារណៈក៏ដោយ។

## ២. អនុម័តយកគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្ម

នៅក្នុងពិភពលោកដែលមានការីខ្លាំងៗ និងភាពប្រកួតប្រជែងយ៉ាងខ្លាំង ឥឡូវនេះគ្មានប្រទេសកំពុងអភិវឌ្ឍន៍ណាមួយអាចប្រើប្រាស់ទីផ្សារពិភពលោកដោយសុខស្រួល និងសង្ឃឹមថាឈ្នះគេនោះឡើយ។ ផ្ទុយទៅវិញ ដូចដែលរដ្ឋជាសមាជិក OECD និងប្រទេសដែលជាខ្លានៅអាស៊ី បានធ្វើចំពោះប្រទេសកំពុងអភិវឌ្ឍន៍ រដ្ឋនានាត្រូវធ្វើអត្តសញ្ញាណវិស័យ និងឧស្សាហកម្មមួយចំនួនតូចដែលមានសក្តានុពលសម្រាប់រយៈពេលវែងនៅក្នុងទីផ្សារអន្តរជាតិ និងណែនាំសហគ្រាសឆ្ពោះទៅរកសក្តានុពលទាំងនោះ។ សេដ្ឋកិច្ចដ៏អស្ចារ្យនៅអាស៊ី ក៏ដូចជាសេដ្ឋកិច្ចនៅប្រទេស ចិន ឬឥណ្ឌាផងដែរ ដែលឥឡូវនេះ កំពុងតែបានទទួលការសរសើរថាជាបទពិសោធជោគជ័យទើបតែ

បានធ្វើសេរីភាវូបនីយកម្មនៅក្រោយពួកគេបានបង្កើតមូលដ្ឋានសម្រាប់បង្កើនប្រភេទឧស្សាហកម្មនាំចេញតែប៉ុណ្ណោះ។

ឧស្សាហកម្មដែលបានជ្រើសរើសយកនឹងមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ប៉ុន្តែវាអាចរាប់បញ្ចូលឧស្សាហកម្មទំនិញវិស្វកម្មជាមូលដ្ឋាន ដែលមានទំនាក់ទំនងជាមួយសក្តានុពលខ្ពស់បំផុតនៃឧស្សាហកម្មផ្សេងទៀត និងការបណ្តុះបណ្តាលមនុស្សកាន់តែច្រើនឡើងលើជំនាញជាសារវន្ត ហើយការធ្វើដូចនេះនឹងផ្តល់អត្ថប្រយោជន៍ បន្ថែមសម្រាប់វិស័យផ្សេងទៀតនៃសេដ្ឋកិច្ច។

តាមពិត ការជ្រើសយក"អ្នកឈ្នះ" មិនមែនជាកិច្ចការងាយស្រួលនោះទេ និងទាមទារឱ្យមានសមត្ថភាពខ្ពស់ជាងមុននៅក្នុងរដ្ឋាភិបាល។ ប្រការសំខាន់គឺត្រូវជៀសវាងការប៉ះទង្គិចគ្នារវាងមន្ត្រីសាធារណៈ និងប្រធានក្រុមហ៊ុន ដែលបង្កើតកាន់តែច្រើនឡើងនូវ"មូលធននិយមជិតស្និទ្ធ" ដែលមូលដ្ឋានគ្រឹះរបស់ខ្លួនបានដួលរលំនៅអំឡុងពេលនៃវិបត្តិហិរញ្ញវត្ថុនៅអាស៊ី។ ផ្ទុយទៅវិញ គោលដៅគួរតែដើម្បីសម្រេចឱ្យបាននូវគោលនយោបាយតម្លាភាពរវាងរដ្ឋាភិបាល និងផ្នែកឯកជន ដោយប្រើប្រាស់អភិក្រមវិន័យ និងការផ្តល់រង្វាន់។

ការផ្តល់រង្វាន់រាប់បញ្ចូលកាលានុវត្តភាពដើម្បីប្រតិបត្តិការនៅពីក្រោយរបាំងពន្ធ រហូតដល់ពេលដែលក្រុមហ៊ុនមានកម្លាំងរឹងមាំគ្រប់គ្រាន់ ដើម្បីប្រកួតប្រជែងជាអន្តរជាតិ។ ឧទាហរណ៍ មុនពេលចាប់ផ្តើមបើកចំហទៅកាន់ពិភពលោកខាងក្រៅ ប្រទេសចិនមានអត្រាពន្ធជាមធ្យមប្រមាណ ៤០% ។ អត្រាពន្ធគួរតែទាបសម្រាប់ការនាំចូលផលិតផលជាសារវន្ត ដូចជាវត្ថុធាតុដើម និងទំនិញដែលជាមូលធនសម្រាប់បច្ចេកវិទ្យាទំនើប និងអត្រាខ្ពស់ជាងសម្រាប់ទំនិញដែលប្រកួតប្រជែងជាមួយឧស្សាហកម្មជាយុទ្ធសាស្ត្រមួយចំនួន។

អភិក្រមវិន័យគឺថា ឧស្សាហកម្មបែបនេះនឹងត្រូវដាក់ឱ្យនៅក្រោមការអង្កេតដើម្បីមើលឱ្យឃើញថាពួកគេគោរពតាមអ្វីដែលពួកគេបានតថ្លៃ និងអភិវឌ្ឍន៍ជាបណ្តើរៗទៅរកផលិតផលនិងសេវាដែលមានភាពប្រកួតប្រជែងសម្រាប់ការនាំចេញ។ ឧស្សាហកម្មទាំងនោះក៏នឹងត្រូវគោរពតាមគោលនយោបាយប្រកួតប្រជែងនៅក្នុងស្រុក ដែលត្រូវបានបង្កើតឡើង ដើម្បីទប់ស្កាត់ពួកគេពីការរំលោភលើគោលជំហរនៃភាពផ្តាច់មុខផងដែរ។

*តម្រូវការជាសារវន្តដើម្បីចូលរួមនៅក្នុងពាណិជ្ជកម្មអន្តរជាតិស្ថិតនៅត្រង់ថា ដំណើរការនេះគួរតែមានការគ្រោងទុកតាមបែបយុទ្ធសាស្ត្រ និងទៅតាមលំដាប់លំដោយយ៉ាងប្រុងប្រយ័ត្ន*

ទោះជាយ៉ាងណាក៏ដោយ តម្រូវការជាសារវន្តដើម្បីចូលរួមនៅក្នុងពាណិជ្ជកម្មអន្តរជាតិស្ថិតនៅត្រង់ថា ដំណើរការនេះគួរតែមានការគ្រោងទុកតាមបែបយុទ្ធសាស្ត្រ និងទៅតាមលំដាប់លំដោយយ៉ាងប្រុងប្រយ័ត្ន។ ដូច្នេះ អត្រាពន្ធខ្ពស់គួរតែមានកំណត់រយៈពេល។ ដើម្បីជៀសវាងការបង្កើតភាពផ្តាច់មុខយ៉ាងកក់ក្តៅដែលនាំទៅរកការបង្កើតសហគ្រាស ដែលស្ទាហាប់ក្នុងការនាំចេញ អត្រាពន្ធគួរតែត្រូវកាត់បន្ថយជាស្វ័យប្រវត្តិទៅតាមរយៈកាលដែលបានកំណត់ទុកជាមុន។

## ៣. ស្ពានការយកចិត្តទុកដាក់លើកសិកម្ម

ប្រទេសជាច្រើនដែលមានមហិច្ឆិតាក្នុងការបង្កើនវត្តមានរបស់ខ្លួននៅលើទីផ្សារអន្តរជាតិបានផ្តោតភាគច្រើននៃថាមពលរបស់ខ្លួនទៅលើឧស្សាហកម្មនៅទីក្រុង ដោយទុកចោលទីជនបទ ដើម្បីលៃលកដោះស្រាយតាមតែពួកគេអាចធ្វើបាន។ ទោះជាយ៉ាងណាក៏ដោយ យុទ្ធសាស្ត្រពាណិជ្ជកម្មដែលផ្អែកលើការអភិវឌ្ឍមនុស្ស ត្រូវតែមានកសិករជាស្នូលរបស់ខ្លួន។ នេះមិនមែនដោយសារកសិកម្មផ្តល់កាលានុវត្តភាពនាំចេញនោះទេ ប៉ុន្តែដោយសារនៅក្នុងប្រទេសជាច្រើន វប្បកម្មគឺជាប្រភពបឋមនៃប្រាក់ចំណូលសម្រាប់ជនក្រីក្រ។ ដូច្នេះ គ្មានយុទ្ធសាស្ត្រពាណិជ្ជកម្មដែលធ្វើឱ្យខូចការរស់នៅតាមជនបទ អាចអះអាងថាលើកកម្ពស់ការអភិវឌ្ឍមនុស្សឡើយ។

ជាពិសេសសម្រាប់ប្រទេសនាំចូលស្បៀង ការរក្សាទុកពន្ធលើការនាំចូលស្បៀងជាការវាងវៃ ដើម្បីការពារផលិតករ ក្រីក្រ។ ដូច្នេះ នៅក្នុងការចរចា WTO ប្រទេសកំពុងអភិវឌ្ឍន៍គួរតែទាមទារឱ្យមានសិទ្ធិការពារ "ផលិតផលពិសេស" រួមទាំងថែរក្សាយន្តការដែលនឹងក្លាយជាគន្លឹះសម្រាប់ដោះស្រាយនៅពេលការនាំចូលឈានដល់កម្រិតថ្លៃ និងបរិមាណណាមួយជាកំណត់។

ប្រការនេះក៏មានអត្ថប្រយោជន៍ជាយុទ្ធសាស្ត្រផងដែរ ដើម្បីរក្សាសន្តិសុខស្បៀងនៅក្នុងប្រទេស នៅក្នុងពិភពលោកដែលត្រឹមតែប៉ុន្មានឆ្នាំខាងមុខនេះ អាចឈានទៅរកកង្វះស្បៀង ជាក់ស្តែងដោយសារប្រទេសកំពុងអភិវឌ្ឍន៍ធំៗដូចជាចិន បានធ្វើឱ្យកសិកម្មនៅទ្រឹង និងក្លាយជាប្រទេសនាំចូលសុទ្ធនូវកសិផលរួចទៅហើយ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចការពារអត្រាពន្ធឬការពារថ្លៃ ប្រសិនបើចាំបាច់គួរតែបង្កើតឡើងដោយឡែកដើម្បីការពារកសិករ ជាងការគ្រាន់តែបង្កើនផលចំណេញសម្រាប់ពាណិជ្ជកម្ម ឬសម្រាប់ឧស្សាហកម្មស្បៀង។ ហើយប្រសិនបើការធ្វើដូច្នេះនាំឱ្យមានកំណើនថ្លៃដែលបង្កជាការលំបាកសម្រាប់អ្នកប្រើប្រាស់ដែលក្រីក្រជាងគេ រដ្ឋាភិបាលចាំបាច់ត្រូវរៀបចំបណ្តាញសុវត្ថិភាពសង្គម។

ដូចជាកិច្ចការពារដែរ កសិករត្រូវការឱ្យមានការរីកចម្រើន។ នៅក្នុងប្រទេសជាច្រើន ការវិនិយោគលើការអភិវឌ្ឍជនបទបានប្រឈមនឹងការធ្លាក់ចុះយ៉ាងឆាប់រហ័ស។ ចាំបាច់ត្រូវតែធ្វើឱ្យនិន្នាការនេះប្តូរទិសមកវិញ ជាពិសេស តាមរយៈការវិនិយោគ ដូចជាលើប្រព័ន្ធស្រោចស្រព អគ្គិសនីកម្មនៅតាមភូមិ និងផ្លូវថ្នល់ពីកសិដ្ឋានមកទីផ្សារ។

## ៤. ប្រយុទ្ធនឹងកំណើននៃភាពគ្មានការងារធ្វើ

ប្រទេសភាគច្រើនដែលចាប់ផ្តើមឧស្សាហូបនីយកម្ម ជាមួយផលិតកម្មអតិពលកម្មនៅក្នុងឧស្សាហកម្ម ដូចជាកាត់ដេរ វាយនភណ្ឌ និងស្បែកជើង ដោយទាញយកប្រយោជន៍ពីការផ្គត់ផ្គង់គ្រប់គ្រាន់នៃពលកម្មកម្រៃទាប។ ប៉ុន្តែ នៅពេលដែលឧស្សាហូបនីយកម្មបន្តទៅមុខ សម្ពាធនៃភាពប្រកួតប្រជែង មហិច្ឆតាកាន់តែធំឡើង និងការផ្លាស់ប្តូរលក្ខខណ្ឌទីផ្សារចាប់ផ្តើមរុញច្រានការផ្គត់ផ្គង់ឡើងទៅកាន់ចង្វាក់នៃតម្លៃ។ លើសពីនេះសហគ្រាសនានាច្រើនតែនិយមប្រើប្រាស់គ្រឿងយន្ត ប្រសិនបើពួកគេឃើញថា ការប្រើប្រាស់គ្រឿងម៉ាស៊ីនមានភាពងាយស្រួលជាងមនុស្ស។ ជាលទ្ធផល ប្រទេសដែលទទួលជោគជ័យជាងគេក្នុងពាណិជ្ជកម្ម ជាពិសេសនៅអាស៊ីបូព៌ា ឥឡូវនេះកំពុងបង្កើតចំនួនការងារយឺតជាងមុនឆ្ងាយណាស់ ដែលនាំឱ្យមានបាតុភាព"កំណើនភាពគ្មានការងារធ្វើ"។

ដំណើរការនេះ អាចឱ្យយើងយល់បានមួយកម្រិត។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលយើងយល់មិនសូវច្បាស់ គឺថាហេតុអ្វីរដ្ឋាភិបាលធ្វើឱ្យនិន្នាការនេះកាន់តែធ្ងន់ធ្ងរឡើង ដោយរក្សាទុកអត្រាការប្រាក់ជាក់ស្តែងទាប ដែលនាំឱ្យមានការចូលចិត្តប្រើប្រាស់មូលធនជាងពលកម្ម។ នោះទំនងជាយុទ្ធ-សាស្ត្រប្រសើរបំផុតសម្រាប់កំណើនឆាប់រហ័ស ប៉ុន្តែ វាបង្កើតបញ្ហាកាន់តែច្រើនឡើងសម្រាប់អនាគត។ តាមពិត ការធ្វើបែបនេះអនុញ្ញាតឱ្យសហគ្រាសជ្រើសរើសយកជម្រើសផលិតកម្មដែលចំណាយទាបជាងគេបំផុត ប៉ុន្តែ ជម្រើសនេះពុំគួរមានភាពលំអៀងទៅឆ្ងាយពីពលកម្មឡើយ។ ដូច្នេះ អត្រាការប្រាក់គួរតែឆ្លុះបញ្ចាំងអំពីថ្លៃពិតប្រាកដនៃមូលធន មិនមែនអត្រាដែលឧស្សាហករចូលចិត្តនោះទេ។ ដូចគ្នានេះដែរ រដ្ឋនានាគួរតែលុបចោលការលើកទឹកចិត្តខាងសារពើពន្ធដល់សហគ្រាស។ ការលើកទឹកចិត្តបែបនេះអាចទាក់ទាញការវិនិយោគ ប៉ុន្តែមិនសុទ្ធតែជំនួញដែលបង្កើនជាអតិបរមានូវសក្តានុពលអភិវឌ្ឍន៍មនុស្សឡើយ ព្រោះថាការមិនយកពន្ធបង្កើនដោយសប្បនិម្មិតនូវផល

ចំណូលសម្រាប់មូលធនវិញ ហើយលើកទឹកចិត្តឱ្យមានការវិនិយោគដែលប្រើប្រាស់មូលធនច្រើន។

ហេតុផលមួយផ្សេងទៀត ដែលអាចនាំឱ្យសហគ្រាសស្ទាក់ស្ទើរក្នុងការទទួលយកកម្មករថ្មី គឺថាកិច្ចសន្យាការងារអាចមានភាពរឹងឆ្អឹងពេក។ នៅក្នុងទីផ្សារដែលមានការផ្លាស់ប្តូរឆាប់រហ័ស ក្រុមហ៊ុនដែលលំបាកព្យាករណ៍អំពីតម្រូវការទៅអនាគតអាចចូលចិត្តវិនិយោគលើគ្រឿងម៉ាស៊ីនជាងធ្វើការជាមួយកម្លាំងពលកម្មអចិន្ត្រៃយ៍ជាចំនួនច្រើន។ ប្រការនេះបង្កើតឱ្យមានករណីពីរដែលមិនងាយរលុបបាត់គឺ ក្រុម "អ្នកខាងក្នុង" ដែលមានចំនួនតិច និងទទួលបាននូវកិច្ចការពារប្រកបដោយសន្តិសុខខាងការងារ ដែលស្ថិតក្រោមឥទ្ធិពលនៃបទប្បញ្ញត្តិរបស់រដ្ឋាភិបាល និងកម្លាំងពលកម្មជាចំនួនច្រើន និងដែលច្រើនតែត្រូវបានគេងប្រវ័ញ្ច និងដែលធ្វើការទៅតាមបរិមាណផលដែលធ្វើបាន។ ជាជំនួស ចំនួនកម្មករកាន់តែច្រើនឡើងគួរតែអាចស្រូបជាប្រចាំទៅក្នុងការងារផ្លូវការ ប៉ុន្តែតាមរយៈកិច្ចសន្យាដែលអាចបត់បែនបានគ្រប់គ្រាន់ ដែលអាចយកទៅអនុវត្តបានសម្រាប់វិស័យផ្សេងទៀត ឬជាមួយក្រុមហ៊ុននានា នៅពេលដែលលក្ខខណ្ឌពាណិជ្ជកម្មផ្លាស់ប្តូរ។

*រដ្ឋាភិបាលត្រូវមានរបបពន្ធតាមបែបផ្សេង មុនពេលចាប់ផ្តើមសេរីភាវូបនីយកម្ម*

រដ្ឋាភិបាលអាចជួយនៅក្នុងដំណើរការនេះ ដោយផ្តល់ការគាំទ្រខ្លះៗដល់កម្មករ តាមរយៈការធានារ៉ាប់រងលើផ្នែកសុខភាព និងសន្តិសុខសង្គម និងដោយគោលនយោបាយសកម្មអំពីទីផ្សារពលកម្ម ដើម្បីលើកទឹកចិត្តឱ្យមានការរក្សាទុក និងការជួលពលករទាំងនេះឡើងវិញ។

## ៥. រៀបចំរបបពន្ធដារថ្មី

សេរីភាវូបនីយកម្មគឺជាវិធីព្យាបាលទូទៅដើម្បីឱ្យមានជោគជ័យខាងសេដ្ឋកិច្ច ប៉ុន្តែវាមានឥទ្ធិពលបន្ទាប់បន្សំដោយចេតនា ពោលគឺ បំភ្លេចចោលនូវប្រភពចំណូលដែលអាចព្យាករណ៍ទុកបាន និងដែលរដ្ឋាភិបាលងាយប្រមូល។ ប្រទេសក្រីក្រជាងគេជាច្រើនបានពឹងផ្អែកលើពន្ធគយសម្រាប់ជាចំណូលភាគច្រើនពីវិស័យសាធារណៈ ហើយក្នុងករណីខ្លះមានរហូតដល់ ៧០% ។ ប្រសិនបើពួកគេត្រូវបញ្ចុះជាគំហុកនូវអត្រាពន្ធ ពួកគេនឹងបាត់បង់ចំណូលដែលជាអាយុជីវិត។

គេអាចអះអាងថា កំណើនសេដ្ឋកិច្ចអាចដោះស្រាយបញ្ហានេះបាន នៅពេលដែលពន្ធលើប្រាក់ចំណេញ និងលើប្រាក់ចំណូលកើនឡើងជាស្វ័យប្រវត្តិ ដើម្បីបំពេញគម្លាតនៃសារពើពន្ធ។ ប៉ុន្តែ ប្រការនេះមិនទំនងជាកើតឡើងបានទេ ហើយពិតជាមិនអាចកើតឡើងនៅក្នុងរយៈពេលខ្លីឡើយ នៅពេលដែលទាំងសហគ្រាសក្នុងស្រុកនិងបរទេស អាចទទួលការអនុគ្រោះខាងផ្នែកពន្ធជាការលើកទឹកចិត្តសម្រាប់ការវិនិយោគ។ ជាជំនួស រដ្ឋាភិបាលត្រូវមានរបបពន្ធតាមបែបផ្សេង មុនពេលចាប់ផ្តើមសេរីភាវូបនីយកម្ម។

ទោះជាយ៉ាងណាក៏ដោយ ត្រូវមានការប្រុងប្រយ័ត្នដើម្បីធានាថា ពន្ធថ្មីនេះមានអត្រាកំណើនអិចស្ប៉ូណង់ស្យែល និងមិនធ្វើឱ្យខូចខាតដល់ជនក្រីក្រឡើយ។ ឧទាហរណ៍ ពន្ធគយច្រើនតែមានអត្រាកើនអិចស្ប៉ូណង់ស្យែល និងមានអត្រាខ្ពស់បំផុតសម្រាប់ទំនិញប្រណិត ដែលជាទីចាប់អារម្មណ៍របស់អ្នកមាន។ ដូចគ្នានេះដែរ ពន្ធលើប្រាក់ចំណេញក៏អាចកើនឡើងតាមអត្រាអិចស្ប៉ូណង់ស្យែលផងដែរ ទោះបីមនុស្សជាច្រើនអាចជៀសវាងប្រព័ន្ធនេះ ដោយសារមេធាវីរបស់សាជីវកម្មធំៗមានទេពកោសល្យខ្ពស់លើការកសាងផែនការពន្ធ ចំណែកសហគ្រាសភាគច្រើននៅក្នុងវិស័យក្រៅផ្លូវការគ្រាន់តែជៀសវាងអ្នកបង់ពន្ធតែប៉ុណ្ណោះ។ ដូចគ្នានេះដែរ សម្រាប់ពន្ធលើប្រាក់ចំណូល ដែលទំនងជាត្រូវបានបង់យ៉ាងច្រើនដោយកម្មករដែលមានប្រាក់ចំណូលកណ្តាលនៅក្នុងរដ្ឋាភិបាល ឬក្នុងវិស័យផ្លូវការ។

ការប្រមូលប្រាក់ចំណូលកាន់តែច្រើនពីពន្ធលើប្រាក់ចំណេញនិងលើប្រាក់ចំណូល មានន័យថាជាការកែប្រែលើច្បាប់ពន្ធដារ ដើម្បីបំពេញចំណុចខ្វះចន្លោះនិងពិចារណាជម្រើសផ្សេងទៀត ដូចជា "ការហូតពន្ធទុកជាមុន" នៅចំណុចដែលសហគ្រិនក្នុងវិស័យក្រៅផ្លូវការពុំមានជម្រើស ប៉ុន្តែត្រូវផ្តល់ឯកសារ ដូចជា នៅពេលនាំចូលវត្ថុធាតុដើមសម្រាប់មុខជំនួញរបស់ខ្លួន។

រដ្ឋាភិបាលក៏អាចពិចារណាពន្ធលើអចលនទ្រព្យ ឬលើមូលធនចំណេញផងដែរ។ រដ្ឋាភិបាលក៏អាចអនុវត្តពន្ធបន្ថែម (VAT) ដែលអាចរកចំណូលបានកម្រិតខ្ពស់ និងដែលអាចព្យាករណ៍ទុកជាមុនបាន ប៉ុន្តែត្រូវតែអនុវត្តសេដ្ឋកិច្ចដែលចាត់ចែងឯកសារបានល្អ និងត្រូវរៀបចំឡើងប្រកបដោយការយកចិត្តទុកដាក់។ ក្នុងគ្រប់ករណី គួរតែលើកលែងពន្ធលើស្បៀង និងទំនិញផ្សេងទៀតដែលចាំបាច់សម្រាប់អ្នកក្រ។

ចំណុចគន្លឹះស្ថិតនៅត្រង់ថាប្រភពថ្មីនៃប្រាក់ចំណូលទាំងនេះគួរតែត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តមុនការធ្វើសេរីភាវូបនីយកម្ម បើពុំនោះទេ ការធ្លាក់ចុះនៃប្រាក់ចំណូលអាចនាំឱ្យមានការកាត់បន្ថយយ៉ាងធ្ងន់ធ្ងរនូវសេវាសាធារណៈដែលបង្កគ្រោះថ្នាក់ចំពោះការអភិវឌ្ឍមនុស្ស។

## ៦. ធ្វើឱ្យអត្រាប្តូរប្រាក់មានស្ថិរភាព

ប្រការមួយដែលរាំងស្ទះពាណិជ្ជកម្មអន្តរជាតិ និងបំបាក់ទឹកចិត្តការវិនិយោគគឺ ភាពងាយប្រែប្រួលនៃអត្រាប្តូរប្រាក់ ដែលធ្វើឱ្យរដ្ឋ និងសហគ្រាសលំបាកព្យាករណ៍ទុកជាមុន។ ប្រការសំខាន់គឺអត្រានេះត្រូវមានភាពជាក់ស្តែង។ កាលណាអត្រានេះខ្ពស់ពេក វានឹងធ្វើឱ្យបាត់បង់ចំនួនការងារដោយបង្កជាទណ្ឌកម្មដល់អ្នកនាំចេញ ក៏ដូចជាកសិករ និងផលិតករផ្សេងទៀត ដែលត្រូវប្រឈមនឹងភាពប្រកួតប្រជែងកាន់តែខ្លាំងឡើងពីការនាំចូល។ កាលណាអត្រានេះ មានកម្រិតទាបពេក អាចនាំឱ្យមានហានិភ័យដោយសារកំណើនថ្លៃនៅក្នុងស្រុក ដែលបង្កផលប៉ះពាល់អវិជ្ជមានទៅលើការចំណាយសម្រាប់ការរស់នៅរបស់ជនក្រីក្រ។

អត្រាប្តូរប្រាក់ទំនងជានឹងប្រែប្រួល ជាពិសេសនៅក្នុងសេដ្ឋកិច្ចតូចតាច និងបើកចំហដែលពុំមានអំណាចដើម្បីប្រឈមនឹងកំណើន ឬការធ្លាក់ចុះនៃថ្លៃសម្រាប់មុខទំនិញនានា។ ក្នុងលក្ខខណ្ឌដែលអត្រាប្តូរប្រាក់ប្រែប្រួលខ្លាំង សេដ្ឋកិច្ចទាំងនេះក៏ងាយប្រឈមនឹង "ជម្ងឺហូឡង់" ដែលក្នុងនោះ លំហូរចូលនៃមូលធនដោយពុំមានកាលានុវត្តភាពគ្រប់គ្រាន់សម្រាប់ការវិនិយោគដើម្បីស្រូបយកលំហូរចូលនោះ ជាហេតុនាំឱ្យអត្រាប្តូរប្រាក់ឈានទៅកម្រិតដែលពុំមានភាពប្រាកដនិយម។ ប្រការនេះអាចកើតឡើងដោយសារកំណើនថ្លៃទំនិញ ដូចជាកំណើនថ្លៃប្រេងនៅទីម័រខាងកើត។ ប៉ុន្តែ វាក៏អាចកើតឡើងដោយសារការមកដល់នៃមូលនិធិសម្រាប់ជំនួយសង្គ្រោះ ដូចជាករណីព្យុះសមុទ្រ។

ការបញ្ចុះថ្លៃរូបិយប័ណ្ណឥឡូវនេះដែលទំនងជាផ្តល់ឱ្យមានកំណើនសម្រាប់រយៈពេលខ្លី ជាទូទៅវាពុំមានប្រសិទ្ធិភាពទេ។ ឧទាហរណ៍ ធៀបនឹងប្រទេសនៅអាមេរិកឡាទីន ប្រទេសភាគច្រើននៅអាស៊ីដែលមានជោគជ័យក្នុងពាណិជ្ជកម្ម បានទទួលអត្ថប្រយោជន៍ពីស្ថិរភាពរយៈពេលវែងនៃអត្រាប្តូរប្រាក់ដែលផ្អែកលើការគ្រប់គ្រងរូបិយប័ណ្ណសកម្ម។

កាលពីដំបូង ជាជាងអនុញ្ញាតឱ្យមានអត្រាប្តូរប្រាក់ដែលប្រែប្រួលដោយសេរី ប្រទេសនានាដែលបានចូលរួមពាក់ព័ន្ធកាន់តែច្រើននៅក្នុងពាណិជ្ជកម្មអន្តរជាតិ អាចពិចារណាឱ្យមាន "ការប្រែប្រួលក្រោមការគ្រប់គ្រង" ដែលអនុញ្ញាតឱ្យរូបិយប័ណ្ណរបស់ខ្លួនចុះថ្លៃយឺតៗ។ ប្រទេសជាច្រើនមានសេរីភាវូបនីយកម្មពាណិជ្ជកម្មចម្រុះ ដែលមានការធ្លាក់ថ្លៃនៃរូបិយប័ណ្ណបន្តិចម្តងៗហើយទប់ស្កាត់ការកើនឡើងដែលគ្មាន

*ជាការប្រសើរគឺត្រូវទប់ទល់ចំពោះការប៉ុនប៉ងភ្លាមៗឱ្យមានការទទួលយកទ្វេភាគី និងកសាងទំនាក់ទំនងពហុភាគីដោយមានល្បឿនយ៉ាងឃឹតបំផុត ដែលជាទំនាក់ទំនងពហុភាគីដ៏មានប្រយោជន៍*

និរន្តរភាពនៃឱនភាពពាណិជ្ជកម្ម។ ទោះជាយ៉ាងណាក៏ដោយ អាទិភាពរួមគឺត្រូវធានាថាអត្រានេះនៅមានស្ថិរភាពជាបង្គួរ និងមានភាពប្រាកដនិយម។

## ៧. ស៊ូទ្រាំជាមួយពហុភាពនិយម

ល្បឿនយឺតនៃការរីកចម្រើននៅក្នុងការចរចាពាណិជ្ជកម្មពហុភាគីនៅទីក្រុងដូហា បានធ្វើឱ្យខូចទឹកចិត្តដល់ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន។ ប្រទេសទាំងនេះអាចមើលឃើញការរីកចម្រើននៅក្នុងការចរចានេះធ្លាក់ចុះទៅក្នុងឧបសគ្គដែលធ្លាប់មានរួចមកហើយ ជាពិសេស ការរឹងទទឹងពីបណ្តាប្រទេសជឿនលឿនលើគោលនយោបាយឧបត្ថម្ភធនសម្រាប់វិស័យកសិកម្ម។ ប្រការនេះបង្កឱ្យមានទុទិដ្ឋិនិយម ហើយប្រការដែលកាន់តែអាក្រក់នោះបណ្តាលឱ្យមានការធ្លាក់ចុះនៃសេចក្តីរំពឹងដែលអាចធ្វើឱ្យប្រទេសកំពុងអភិវឌ្ឍន៍បោះបង់ចោលពហុភាពនិយមទាំងអស់គ្នាតែម្តង។

ដោយសារតែការអស់សង្ឃឹមនៅក្នុងការចរចានៅឯ WTO ប្រទេសជាច្រើនស្ទុះស្វែងចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយប្រទេសជឿនលឿន។ ប្រទេសខ្លះលើកហេតុផលមកសំអាងថា តាមន័យពាណិជ្ជកម្ម នេះជាការប្រសើរណាស់ ដោយហេតុថាវាផ្តល់ឱ្យមានការចូលរួមជាសមាជិកតាមចំណូលចិត្ត ប៉ុន្តែតាមទស្សនៈនៃការអភិវឌ្ឍមនុស្ស វាអាចបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំង ដោយហេតុថា ជាធម្មតា កិច្ចព្រមព្រៀងទ្វេភាគីតែងពាក់ព័ន្ធដល់ការធ្វើសម្បទានយ៉ាងច្រើនលើតារាងអត្រាពន្ធដោយប្រទេសកំពុងអភិវឌ្ឍន៍ និងធ្វើការទាមទារលើបញ្ហានានា ដូចជា កម្មសិទ្ធិបញ្ញាដែលហួសឆ្ងាយជាងអ្វីដែលសមាជិក WTO កំណត់ចំពោះគ្នាទៅវិញទៅមក និងអាចគម្រាមកំហែងសុខភាព និងជីវភាពរស់នៅរបស់ជនក្រីក្រ។

ប្រទេសជាច្រើននៅក្នុងតំបន់ នឹងមានភាពល្អប្រសើរជាងដើម្បីទប់ទល់ចំពោះការប៉ុនប៉ងភ្លាមៗឱ្យមានការទទួលយកទ្វេភាគី និងកសាងទំនាក់ទំនងពហុភាគីដោយមានល្បឿនយ៉ាងយឺតបំផុត ដែលជាទំនាក់ទំនងពហុភាគីដ៏មានប្រយោជន៍ ដែលអាចបណ្តាលឱ្យលទ្ធផលនៃការអភិវឌ្ឍមនុស្សមាននិរន្តរភាពយូរអង្វែងជាង។

## ៨. ធ្វើសហប្រតិបត្តិការជាមួយប្រទេសជិតខាង

ជាជាងស្វែងរកកិច្ចព្រមព្រៀងទ្វេភាគី ជាការប្រសើររដ្ឋាភិបាលគួរតែស្វែងរកកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងផ្សេងទៀតជាមួយប្រទេសដទៃទៀតនៅក្នុងតំបន់ ឬអនុតំបន់ជាមួយគ្នា។ កិច្ចព្រមព្រៀងទាំងនេះ អាចរាប់បញ្ចូលកតិការសញ្ញាប្រចាំតំបន់ ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ីខាងត្បូង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន ឬកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងប្រទេសនៅលើកោះក្នុងសមុទ្រប៉ាស៊ីហ្វិក។ កិច្ចព្រមព្រៀងទាំងនេះផ្តល់អត្ថប្រយោជន៍សម្រាប់ការចូលចរចាបានឆាប់រហ័សជាងកិច្ចព្រមព្រៀងពហុភាគីទន្ទឹមនឹងការបង្កឱ្យមានហានិភ័យតិចតួចជាងសម្រាប់ការអភិវឌ្ឍមនុស្សធៀបនឹងកិច្ចព្រមព្រៀងទ្វេភាគី។ លើសពីនេះ កិច្ចព្រមព្រៀងទ្វេភាគីមានភាពស៊ីគ្នាបានល្អជាង ដោយសារតំបន់នេះមានប្រព័ន្ធផលិតកម្មអន្តរប្រទេស ដែលមានការធ្វើសមាហរណកម្ម និងដែលនាំទៅរកការបង្កើតពាណិជ្ជកម្ម។

កិច្ចព្រមព្រៀងពាណិជ្ជកម្មប្រចាំតំបន់អាចជាការបំពេញបន្ថែមដោយកិច្ចសហប្រតិបត្តិការតាមបែបផ្សេងទៀតដោយឡែកនៅក្នុងវិស័យហិរញ្ញវត្ថុ។ ប្រទេសជាច្រើននៅក្នុងតំបន់នេះសន្សំទុករូបិយប័ណ្ណបរទេសបានយ៉ាងច្រើនរហូតដល់ចំនួនសរុប ១.៩ លានលានដុល្លារ ដែលពាក់កណ្តាលនៃចំនួននេះនៅក្នុងប្រទេសចិន ដោយមួយផ្នែកសម្រាប់ការពារខ្លួនទល់នឹងវិបត្តិហិរញ្ញវត្ថុមួយផ្សេងទៀតនៅអាស៊ី។ មូលនិធិទាំងនេះ

អាចយកទៅប្រើប្រាស់បានប្រសើរជាង ប្រសិនបើដាក់បញ្ចូលគ្នា ដើម្បីឱ្យប្រទេសដែលប្រឈមវិបត្តិភ្លាមៗនៃជញ្ជីងទូទាត់ ដែលអាចកើតឡើងដោយ ឧទាហរណ៍ ការកើនឡើងយ៉ាងស្រួចស្រាវនៃថ្លៃប្រេង អាចប្រើប្រាស់ធនធានរួមនៃប្រទេសនៅអាស៊ី។ រដ្ឋាភិបាលក៏អាចពិចារណាផងដែរលើការប្រើប្រាស់មូលនិធិបម្រុងនេះ ដើម្បីពង្រីកមូលនិធិអភិវឌ្ឍន៍អាស៊ី ដែលអាចដាក់ធនធានសម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំ និងលើអាទិភាពអភិវឌ្ឍន៍មនុស្ស ដូចជា សុខភាព និងការអប់រំ។

## ទៅដល់ព្រំដែនផ្សេងគ្នា

ទោះមានឬគ្មានកិច្ចព្រមព្រៀងពហុភាគី ការធ្វើសេរីភាវូបនីយកម្មនៅតែបោះជំហានទៅមុខ។ ហើយកម្មករជាច្រើនលាននាក់បន្ថែមទៀតនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិកនឹងក្លាយជាអ្នកផលិតទំនិញសម្រាប់មនុស្សដែលរស់នៅក្នុងតំបន់ផ្សេងទៀតនៃពិភពលោកនេះ ក៏ដូចជាទិញទំនិញដោយថ្លៃថោក ដែលឪពុកម្តាយរបស់ពួកគេបានស្រមើស្រមៃជាយូរមកហើយ។

ប៉ុន្តែគ្រោះថ្នាក់ជាចម្បងគឺថាអ្នកផ្សេងទៀតរាប់លាននាក់នឹងទទួលបរាជ័យនៅតាមផ្លូវ ដោយត្រូវបានបោះបង់ចោលនៅទីជនបទ ដែលសេដ្ឋកិច្ចកសិកម្មត្រូវធ្លាក់ចូលទៅក្នុងភាពអន់ថយ និងទីបំផុតត្រូវទៅប្រកបរបរចិញ្ចឹមជីវិតនៅតាមជាយទីក្រុងធំៗនៃតំបន់អាស៊ីក្នុងស្ថានភាពជាវណ្ណៈថ្នាក់ក្រោម។ សូម្បីតែអ្នកដែលបច្ចុប្បន្ននេះ មានការងារហើយក៏ដោយ ក៏នៅតែពេលក្រោយអាចត្រូវបានបណ្តេញចេញពីប្រព័ន្ធផលិតកម្មទំនើបបំផុត។ ប្រការនេះ មិនគ្រាន់តែបដិសេធមនុស្សមិនឱ្យទទួលបាននូវសិទ្ធិមានការងារថ្លៃថ្នូរ និងជីវភាពរស់នៅសមរម្យប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបង្កឱ្យមានហានិភ័យចំពោះការបះបោរនៅពេលខាងមុខផងដែរ ដូច្នេះការធ្វើសេរីភាវូបនីយកម្មមិនគ្រាន់តែចែកចាយផលិតផលប៉ុណ្ណោះទេ ប៉ុន្តែក៏ប្រកាសផ្សាយផងដែរ អំពីផ្គត់គំនិតថ្មីនិងព័ត៌មានដែលធ្វើឱ្យមានការកែប្រែចំពោះការចង់បានរបស់មនុស្ស។

បណ្តាប្រទេសនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក មានកេរ្តិ៍ឈ្មោះល្បីល្បាញដោយសារល្បឿនដែលប្រទេសទាំងនោះបានអភិវឌ្ឍនៅក្នុងវិស័យសេដ្ឋកិច្ច។ ពេលនេះពួកគេបានទៅដល់ព្រំដែនមួយផ្សេងទៀត ដោយព្យាយាមផ្សារភ្ជាប់កំណើនសេដ្ឋកិច្ចដែលអាស្រ័យលើពាណិជ្ជកម្មដែលមានល្បឿនយ៉ាងលឿន ជាមួយការកាត់បន្ថយភាពក្រីក្រ ដែលមានល្បឿនស្មើគ្នាដែរ ហើយទូលំទូលាយមែនទែននោះ គឺការអភិវឌ្ឍមនុស្ស។ តាមពិតទៅ ប្រការនេះគឺជាការងារមួយដែលស្មុគស្មាញ និងលំបាក ហើយដូចកាលពីមុនដែរ អ្នកទាំងនេះចាំបាច់ត្រូវរិះរកដំណោះស្រាយដោយខ្លួនឯង។ ដំណោះស្រាយមួយចំនួនមានបង្ហាញជូននៅក្នុងរបាយការណ៍នេះ ចំណែកឯមធ្យោបាយផ្សេងទៀតនឹងលេចចេញពីបទពិសោធន៍។ ប្រការដែលមានលក្ខណៈប្រាកដប្រជាមួយ គឺថាតំបន់អាស៊ី និងប៉ាស៊ីហ្វិកនឹងស្ថិតនៅជួរមុខនៃការអភិវឌ្ឍពិភពលោក ហើយនឹងផ្តល់មេរៀនថ្មីៗដល់តំបន់ដទៃទៀតនៃពិភពលោកផងដែរ។

*តំបន់អាស៊ី-ប៉ាស៊ីហ្វិក នឹងផ្តល់មេរៀនថ្មីៗ ដល់តំបន់ដទៃទៀត នៃពិភពលោកផងដែរ*

# កំណត់សម្គាល់

## ជំពូក ១

១. WTO ២០០៥a ។

២. Ranis and Stewart ២០០៥ ។

៣. World Bank ២០០៥ ។

៤. Kelsey ២០០៤ ។

៥. Rodriguez and Rodrik ១៩៩៩ ។

៦. Patnaik and Chandrasekhar ១៩៩៦ ។

៧. ការសិក្សាផ្សេងទៀតក៏អះអាងបែបនេះដែរ ។ ឧទាហរណ៍ សូមអាន Levine and Renelt (១៩៩២) and Wacziarg (២០០១) ។

៨. ភាពខុសគ្នារវាងតួនាទីរបស់លេខាធិការដ្ឋាន WTO ព្រំដែននៃកិច្ចព្រមព្រៀងនេះ និងជំហររឹងត្អឹងរបស់សមាជិកខ្លះនៃ WTO ពុំសុទ្ធតែអាចយល់បានច្បាស់លាស់នោះឡើយ ។

៩. ការបង្ហាញទស្សនាទានមុននេះ និងប្រហាក់ប្រហែលគ្នានេះនៅក្នុងបរិបទពាណិជ្ជកម្ម ក៏អាចសង្កេតឃើញនៅក្នុង Wagle and Gibbs (២០០៣) ដែរ ដែលនៅពេលក្រោយមកត្រូវបានដាក់បញ្ចូលទៅក្នុង Montes and Memis (២០០៥) ។ គំនិតនេះផ្តើមចេញពី Mahbub ul-Haq (១៩៩៥) ។

## ជំពូក ២

១. World Bank ២០០៥ ។

២. World Bank ២០០៥ ។

៣. UNCTAD ១៩៩៩a; ១៩៩៩b ។

៤. Santos-Paulino and Thirlwall ២០០៤ ។

៥. UNCTAD ២០០៤a ។

៦. Dollar and Kraay ២០០១; Rodriguez and Rodrik ១៩៩៩ ។

៧. Hossain ២០០១; Keong et al. ២០០៣ ។

៨. Acharya and Chaudhri ២០០១ ។

៩. World Bank ២០០៥ ។

១០. ភាពរីកចម្រើនយឺតយ៉ាវបែបនេះ បានរួមចំណែកធ្វើឱ្យមានភាពយឺតយ៉ាវនៅកម្រិតអន្តរជាតិ ។ យោងតាម United Nations (២០០៥) នៅឆ្នាំ ២០០២ មានប្រជាពលរដ្ឋអត់ឃ្លានចំនួន ៨១៥លាននាក់នៅលើពិភពលោក ។ ការប៉ាន់ប្រមាណរបស់អង្គការ FAO បង្ហាញថា ចាប់តាំងពីកិច្ចប្រជុំកំពូលស្បៀងពិភពលោកអំពីរយៈពេលគោលដៅ ឆ្នាំ ១៩៩០-៩២ ចំនួនជនអត់ឃ្លាននៅលើពិភពលោក បានថយចុះបានត្រឹមតែ ៩ លានប៉ុណ្ណោះ ។ ចំនួនជនអត់ឃ្លាននៅតែកើនឡើងគួរឱ្យភ្ញាក់ផ្អើលនៅ ក្នុងរយៈពេលប្រាំឆ្នាំថ្មីៗបំផុតនេះ ដែលតួលេខនេះបានកំណត់ឃើញរួចហើយ ។ នៅក្នុងតំបន់បីក្នុងចំណោមតំបន់ទាំងបួននៅលើពិភពលោក ប្រជាជនកាន់តែច្រើនឡើង ដែលមិនបានទទួលអាហារូបត្ថម្ភគ្រប់គ្រាន់នៅក្នុងឆ្នាំ ២០០០-២០០២ បើប្រៀបធៀបនឹងករណីដូចគ្នានេះនៅក្នុងឆ្នាំ ១៩៩៥-៩៧ ។ មានតែអាមេរិកឡាទីន

និងការ៉ាអ៊ីបទេ ដែលបានបង្ហាញថា ចំនួនប្រជាជនអត់ឃ្លានបានថយចុះតិចតួច (FAO ២០០៤a)។

១១. FAO ២០០៤a; ២០០៤b។

១២. នៅក្នុងអំឡុងឆ្នាំ ១៩៩០-៩២ ដល់ ២០០០-០២ សមាមាត្រចំនួនប្រជាជនដែលរស់នៅដោយពុំបានទទួលអាហារគ្រប់គ្រាន់ បានថយចុះពី ២៥ ទៅ២២% នៅអាស៊ីខាងត្បូងពី ១៨ ទៅ ១៣% នៅអាស៊ីអាគ្នេយ៍ និង ១៦ ទៅ ១១% នៅអាស៊ីបូព៌ា។ ជាលទ្ធផល នៅអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ ចំនួនប្រជាជនដែលអត់ឃ្លានបានថយចុះចំនួន ៤៧ និង ១២លាននាក់ ចំណែកនៅអាស៊ីខាងត្បូង ចំនួនប្រជាជនអត់ឃ្លានបានកើន ១៥ លាននាក់ (United Nations ២០០៥)។

១៣. United Nations ២០០៥។

១៤. United Nations ២០០៥។

១៥. United Nations ២០០៥។

១៦. United Nations ២០០៥។

១៧. United Nations ២០០៥។

១៨. Reinert ២០០៥។

១៩. Palanivel ២០០៦។

## ជំពូក ៣

១. FAO ២០០៤b។

២. FAO ២០០៤a។

៣. FAO ២០០៤a។

៤. FAO ២០០៤a។

៥. FAO ២០០៤a។

៦. Einarsson ២០០១។

៧. Aksoy ២០០៥។

៨. OECD ២០០៥។

៩. "ប្រអប់បៃតង" គឺជាពាក្យដែលធ្លាប់ប្រើសម្រាប់សំគាល់គោលនយោបាយគាំទ្រនៅក្នុងស្រុក ដែលមិនត្រូវបានមានការកាត់បន្ថយកម្រិតនៃការប្តេជ្ញាឡើយ នៅក្រោមកិច្ចព្រមព្រៀងស្តីពីកសិកម្ម។ គោលនយោបាយទាំងនេះ ត្រូវបានគេចាត់ទុកថាមានឥទ្ធិពលតិចតួចប៉ុណ្ណោះទៅលើពាណិជ្ជកម្ម និងរួមបញ្ចូលទាំងការគាំទ្រ ដូចជា ការស្រាវជ្រាវ ការផ្សព្វផ្សាយស្តុកសន្តិសុខស្បៀង ការទូទាត់សងថ្លៃខូចខាតដោយគ្រោះមហន្តរាយ និងកម្មវិធីកែទម្រង់រចនាសម្ព័ន្ធ (លុបចោលការទូទាត់ត្រួតគ្នា) ក៏ស្ថិតនៅ ក្រោមប្រអប់បៃតងផងដែរ។

១០. "ប្រអប់ខៀវ" សំដៅលើប្រការនានានៅក្នុងកិច្ចព្រមព្រៀងស្តីពីកសិកម្មដែលរួចផុតពីការប្តេជ្ញាកាត់បន្ថយនូវប្រាក់កម្រៃឱ្យដល់ផលិតករ ដែលបានទទួលនៅក្រោមកម្មវិធីកម្រិតលើផលិតកម្ម ដែលការប្តេជ្ញាទាំងនោះត្រូវបានកំណត់ដោយផ្អែកលើទីកន្លែងដែលមានទំហំកំណត់ ឬចំនួនកំណត់នៃសត្វចិញ្ចឹម ឬវាបានពី ៨៥% ឬ តិចជាងនៃកម្រិតផលិតកម្មគោល។

១១. ថ្លៃចំណាយសរុបនៃការផលិតសណ្តែកសៀង គឺ ៧.៣៤ដុល្លារ/តៅ នៅក្នុងឆ្នាំ២០០២ ប៉ុន្តែផលិតផលនេះត្រូវបាននាំចេញដោយតម្លៃ ៥.៤៨ដុល្លារ/តៅ។ ពោតដែលត្រូវចំណាយ ៣.០៨ដុល្លារ ដើម្បីផលិតបានក្នុងមួយតៅ ត្រូវបាននាំចេញដោយតម្លៃ ២.៦៩ ដុល្លារក្នុង/តៅ និងអង្ករនាំចេញដោយតម្លៃ ១១.៨០ ដុល្លារ ទោះបីគេបានចំណាយ ១៨.២៦ដុល្លារ ដើម្បីផលិតវាបានមួយតៅក៏ដោយ (IATP ២០០៤)។

១២. FAO ២០០៤c ។

១៣. FAO ២០០៤c ។

១៤. Dhar ២០០៤a ។

១៥. Aksoy ២០០៥ ។

១៦. FAO ២០០៤c ។

១៧. FAO ២០០៤a ។

១៨. FAO ២០០៣a ។

១៩. Bhattasali, Li and Martin ២០០៤ ។

២០. Madeley ២០០០; FAO ១៩៩៩a ។

២១. FAO ១៩៩៩a ។

២២. FAO ២០០៤b ។

២៣. ទើបតែនៅពេលថ្មីៗនេះ ឆ្នាំ២០០២ ដែលក្រមច្បាប់ស៊ីវិលរបស់ប្រទេសណេប៉ាល់ ឆ្នាំ១៩៦៣ ត្រូវបានធ្វើវិសោធនកម្ម ដែលផ្ដល់ឱ្យស្ត្រីនូវសិទ្ធិប្រសើរជាងមុនលើទ្រព្យសម្បត្តិ ដូចជាអនុញ្ញាតឱ្យស្ត្រីទទួលមរតកស្មើគ្នាជាមួយបុរសនៅលើចំណែកនៃទ្រព្យរបស់ស្វាមី ដោយពុំចាំបាច់បញ្ជាក់ពីអាយុ ឬរយៈពេលនៃចំណងអាពាហ៍ពិពាហ៍ និងរក្សាសិទ្ធិនៅក្រោយពេលក្លាយជាស្ត្រីមេម៉ាយ ឬរៀបការឡើងវិញ ។

២៤. Anderson ២០០៣ ។

២៥. McCulloch ២០០៤ ។

២៦. Dillon ២០០១ ។

២៧. Conroy, Murray and Rosset ១៩៩៦ ។

| ៦ ម៉ុងហ្គោលី | .. | .. | | .. | ១១.៤ | ១២.៧ | ៩.៥ | ៩.១ | ១៦.៧ | ៩.៧ | ១៥.១ | ១៨.៩ | ២០.២ | ៣១.៣ | ១៨.៥ | |
| ៧ ប៉ាពួញូហ្គីណេ | ១៦.៦ | ១២.៥ | ៨.៥ | ៥.៤ | ២.៨ | ១.៨ | ៥.៧ | ១១.២ | ៧.៤ | ៥.១ | ៥.១ | ៨.១ | ១៣.៣ | ១០.៩ | ១៥.៥ | |
| ៨ ហ្វីលីពីន | ៨.៨ | ២.១ | ៧.១ | ៨.៣ | ៨.៦ | ៩.៤ | ៨.៦ | ១២.១ | ៨.៩ | ១៤.២ | ១៧.៤ | ១៧.២ | ១៨.៧ | ១៧.១ | ១៦.៩ | |
| ៩ ថៃ | ៤.៨ | ១៥.៦ | ១៧.៨ | ១៨.៣ | ១៩.៦ | ២០.៣ | ២១.៤ | ២០.៨ | ១៧.៣ | ២៥.៨ | ២៧.៨ | ២៦.១ | ២៨.០ | ៣០.០ | ២៨.៧ | |
| ១០ វៀតណាម | .. | .. | | .. | .. | | ៦.៤ | ៧.០ | ៧.៤ | ៧.៤ | ១១.៦ | ១១.០ | ១១.២ | ១១.៨ | ១៥.៩ | |
| **សរុបអនុតំបន់** | ៤.៨ | ៩.៤ | ១១.៩ | ៩.២ | ១០.៥ | ១២.៣ | ១២.៤ | ១៤.១ | ១៤.៦ | ១៨.០ | ១៨.៤ | ១៧.៧ | ១៩.៨ | ២៣.១ | ២៧.៥ | |
| **អាស៊ីខាងត្បូង** | | | | | | | | | | | | | | | | |
| ១១ បង់ក្លាដេស | ១.៧ | ២.១ | ៤.១ | ៥.៨ | ៧.៣ | ៩.៣ | ៦.២ | ៤.៥ | ៣.៧ | ៤.៣ | ៣.៥ | ៣.១ | ២.៧ | ៣.៥ | ៥.០ | |
| ១២ ប៉ូតាណ | ៣១.២ | ៤១.៩ | ៣៤.៧ | ៤១.៥ | ៤៤.៣ | ៨២.០ | ៥៧.០ | ៤៧.៩ | ៦៣.៧ | ៦៥.៧ | ៦៥.១ | ៦០.៤ | ៥៨.៨ | ៥២.៦ | | |
| ១៣ ឥណ្ឌា | ៣.៨ | ០.៥ | ១.៤ | ២.៤ | ៣.៧ | ៦.១ | ៥.០ | ៥.២ | ៦.០ | ៦.៦ | ៧.៣ | ៨.៣ | ៩.៦ | ១៣.៣ | ១៦.៥ | |
| ១៤ ម៉ាល់ឌីវ | ២.១ | ១១.៣ | ៩.៦ | ៩.៩ | ៨.១ | ៨.៨ | ១២.០ | ១៦.៩ | ១៩.៣ | ២១.៩ | ២១.៦ | ១៩.៧ | ១៤.៩ | ២០.៨ | ២២.៣ | |
| ១៥ នេប៉ាល់ | ៩.៤ | ៨.១ | ១០.១ | ១៣.៧ | ១៧.៥ | ១៧.១ | ១៣.៣ | ១២.៦ | ១២.៧ | ១៥.៦ | ១៦.៨ | ១៧.២ | ១៨.៦ | ១៨.៣ | ២០.៩ | |
| ១៦ ប៉ាគីស្ថាន | ២.១ | ០.៧ | ១.២ | ១.៧ | ២.៣ | ៥.៦ | ២.៩ | ០.៩ | ១.៩ | ១.៧ | ២.៤ | ២.១ | ៥.១ | ១១.៣ | ១៣.៣ | |
| ១៧ ស្រីលង្កា | ៦.១ | ៥.៣ | ៧.៦ | ៩.៥ | ១៥.៧ | ១៧.៥ | ១៦.០ | ១៤.១ | ១៣.៤ | ១២.៥ | ១០.៤ | ៦.៤ | ៨.២ | ៩.៩ | ១២.៤ | |
| **សរុបអនុតំបន់** | ៣.៦ | ០.៨ | ១.៩ | ២.៩ | ៤.៣ | ៦.៧ | ៥.៣ | ៥.០ | ៥.៧ | ៦.២ | ៦.៧ | ៧.២ | ៨.៦ | ១២.៣ | ១៥.៣ | |
| **សរុបតំបន់** | ៤.៣ | ៦.២ | ៨.៦ | ៧.៤ | ៨.៧ | ១០.៧ | ១០.៥ | ១១.៧ | ១២.២ | ១៤.៥ | ១៥.១ | ១៤.៨ | ១៦.៨ | ២០.២ | ២៤.១ | |

ប្រភព: UNCTAD ២០០៥។ ទិន្នន័យ GDP បានមកពី World Bank ២០០៥

## តារាងទី ៣១: និន្នាការនៃតុល្យភាពគណនីចរន្ត (%GDP)

| អនុតំបន់/ប្រទេស | ១៩៨០ | ១៩៩០ | ១៩៩១ | ១៩៩២ | ១៩៩៣ | ១៩៩៤ | ១៩៩៥ | ១៩៩៦ | ១៩៩៧ | ១៩៩៨ | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **អាស៊ីបូពា៌ និងប៉ាស៊ីហ្វិក** | | | | | | | | | | | | | | | |
| ១ កម្ពុជា | .. | .. | .. | -៤.៧ | -៤.២ | -៥.៧ | -៥.៥ | -៥.៤ | -៦.២ | -៥.៧ | -៥.៤ | -៣.៨ | -២.៣ | -១.៤ | -៣.០ |
| ២ ចិន | | ៣.៤ | ៣.៥ | ១.៥ | -២.៧ | ១.៣ | ០.២ | ០.៩ | ៤.១ | ៣.៣ | ២.១ | ១.៩ | ១.៥ | ២.៨ | ៣.២ |
| ៣ ហ្វីជី | -១.៥ | -៦.៩ | -៤.៨ | -៣.៨ | -៨.៤ | -៦.៥ | -៦.០ | ០.៧ | -១.៧ | -៣.១ | ០.៧ | .. | .. | .. | .. |
| ៤ ឥណ្ឌូណេស៊ី | .. | -២.៦ | -៣.៣ | -២.០ | -១.៣ | -១.៦ | -៣.២ | -៣.៤ | -២.៣ | ៤.៣ | ៤.១ | ៥.៣ | ៤.៨ | ៤.៧ | ៣.៦ |
| ៥ ម៉ាឡេស៊ី | -១.១ | -២.០ | -៨.៥ | -៣.៧ | -៤.៥ | -៦.១ | -៩.៧ | -៤.៤ | -៥.៩ | ១៣.២ | ១៥.៩ | ៩.៤ | ៨.៣ | ៧.៦ | ១២.៩ |
| ៦ ម៉ុងហ្គោលី | .. | .. | .. | .. | ៥.៩ | ៧.២ | ៣.២ | -៣.១ | ៩.៨ | -៧.៧ | -៥.៧ | -៧.៤ | -៦.១ | -៩.៤ | .. |
| ៧ ប៉ាពួញូហ្គីណេ | -១១.៣ | -២.៣ | -៤.០ | ២.២ | ១៣.០ | ១០.៦ | ១៤.៦ | ៦.០ | -២.០ | ១.២ | ៣.០ | ៩.៨ | ៩.០ | .. | .. |
| ៨ ហ្វីលីពីន | -៥.៩ | -៦.១ | -២.៣ | -១.៩ | -៥.៥ | -៤.៦ | -២.៧ | -៤.៨ | -៥.៣ | ២.៤ | ៩.៥ | ៨.២ | ១.៨ | ៥.៦ | ៤.២ |
| ៩ ថៃ | -៦.៤ | -៨.៥ | -៧.៧ | -៥.៧ | -៥.១ | -៥.៦ | -៨.១ | -៨.១ | -២.០ | ១២.៧ | ១០.២ | ៧.៦ | ៥.៤ | ៥.៥ | ៥.៦ |
| ១០ វៀតណាម | .. | .. | .. | .. | .. | .. | .. | -៨.២ | -៥.៧ | -៣.៩ | ៤.១ | ៣.៥ | ២.១ | -១.៧ | .. |
| **អាស៊ីខាងត្បូង** | | | | | | | | | | | | | | | |
| ១១ បង់ក្លាដេស | -៣.៩ | -១.៣ | ០.២ | ០.៦ | ១.១ | ០.៦ | -២.២ | -២.៤ | -០.៧ | -០.១ | -០.៨ | -០.៦ | -១.១ | ១.៦ | ០.៤ |
| ១២ ប៊ូតាណ | .. | -៩.៨ | -៦.៩ | -១០.១ | -២៩.៨ | -១៤.៦ | -១១.០ | ១២.៩ | ៥.៦ | ៤.២ | ៣.០ | -២.៧ | -៧.៥ | -៦.៩ | .. |
| ១៣ ឥណ្ឌា | -១.០ | -២.២ | -១.៦ | -១.៨ | -០.៧ | -០.៥ | -១.៦ | -១.៥ | -០.៧ | -១.៧ | -០.៧ | -១.០ | ០.០ | ០.៧ | ១.៤ |
| ១៤ ម៉ាល់ឌីវ | -៥២.៣ | ៤.៦ | -៣.៧ | -៦.៩ | -១៦.៧ | -៣.១ | -៤.៦ | -១.៧ | -៦.៨ | -៤.០ | -១៣.៤ | -៨.២ | -៩.៤ | -៥.៦ | -៤.៣ |
| ១៥ នេប៉ាល់ | -២.០ | -៨.០ | -៧.៨ | -៥.៣ | -៦.១ | -៨.៧ | -៨.១ | -៧.២ | -៧.៩ | -១.៤ | -១.៦ | -២.៤ | -២.៩ | ៣.៩ | ២.៩ |
| ១៦ ប៉ាគីស្ថាន | -៣.៧ | -៤.២ | -២.៨ | -៣.៩ | -៥.៦ | -៣.៥ | -៥.៥ | -៧.០ | -២.៧ | -៣.៦ | -១.៥ | -០.១ | ២.៦ | ៥.៤ | ៤.៣ |
| ១៧ ស្រីលង្កា | -១៦.៣ | -៣.៧ | -៦.៦ | -៤.៦ | -៣.៧ | -៦.៥ | -៥.៩ | -៤.៩ | -២.៦ | -១.៤ | -៣.៦ | -៦.៤ | -១.៤ | -១.៤ | -០.៧ |

ប្រភព: World Bank ២០០៥។

## តារាងទី ៣២: និន្នាការនៃតុល្យភាពគណនីមូលធន (%GDP)

| អនុតំបន់/ប្រទេស | ១៩៨០ | ១៩៩០ | ១៩៩១ | ១៩៩២ | ១៩៩៣ | ១៩៩៤ | ១៩៩៥ | ១៩៩៦ | ១៩៩៧ | ១៩៩៨ | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក** | | | | | | | | | | | | | | | |
| ១ កម្ពុជា | .. | .. | .. | .. | .. | ៩.១ | ៧.៧ | ៧.៥ | ៧.២ | ៦.៥ | ៧.៤ | ៦.៨ | ៤.៦ | ៦.១ | ៣.៩ |
| ២ ចិន | .. | -0.១ | 0.២ | -៧.0 | ៣.១ | ៤.៤ | ៣.0 | ៣.0 | -0.១ | -២.៦ | -១.៣ | -0.៩ | ២.៥ | ៣.២ | ៥.0 |
| ៣ ហ្វីជី | ៤.១ | ១0.៥ | ៥.៥ | ៦.៦ | ៥.៥ | ៦.៧ | ១0.0 | ៣.២ | -១.៦ | ៤.៥ | ១.៦ | 0.0 | 0.0 | 0.0 | 0.0 |
| ៤ ឥណ្ឌូណេស៊ី | 0.0 | ៤.៤ | ៤.៧ | ២.៩ | ១.៨ | ២.១ | ៤.0 | ៥.៤ | ១.៥ | ២.១ | -១.៥ | -៤.0 | -៥.៧ | -២.៥ | -១.៧ |
| ៥ ម៉ាឡេស៊ី | ៣.0 | ៦.៥ | ១0.៨ | ១៤.៤ | ១៩.៥ | ៣.៦ | ៧.៩ | ៧.៦ | -0.៣ | -៦.៦ | -៩.៦ | -១0.៦ | -៧.២ | -៣.៦ | -៣.0 |
| ៦ ម៉ុងហ្គោលី | .. | .. | .. | .. | ២.៣ | -៣.៩ | -0.៣ | ២.៣ | -៣.៣ | -0.៧ | ១0.៤ | ១១.៩ | ៨.៨ | ២២.៣ | 0.0 |
| ៧ ប៉ាពួញូហ្គីណេ | ៨.២ | ២.៩ | ១.៩ | -៤.១ | -១៤.៩ | -១១.៥ | -១១.0 | 0.២ | -២.៥ | -៥.៧ | -២.៧ | -៧.៥ | -៤.៧ | 0.0 | 0.0 |
| ៨ ហ្វីលីពីន | ៧.៧ | ៥.0 | ៧.៤ | ៤.១ | ៦.0 | ៦.៧ | ៣.២ | ៩.២ | ១.៩ | 0.៦ | -៤.២ | -៨.៥ | -១.៣ | -៦.0 | -៣.៨ |
| ៩ ថៃ | ៥.៥ | ១៣.0 | ១២.0 | ៨.២ | ៨.៤ | ៩.0 | ១២.0 | ៩.0 | -៥.៧ | -១0.៤ | -៥.៩ | -៩.៣ | -៥.១ | -១.0 | -៣.៤ |
| ១0 វៀតណាម | .. | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ៩.៩ | ៦.៦ | ៤.0 | 0.៥ | -៣.៣ | -១.៣ | ៣.0 | 0.0 |
| **អាស៊ីខាងត្បូង** | | | | | | | | | | | | | | | |
| ១១ បង់ក្លាដេស | ៣.៤ | ១.៧ | ១.៩ | ១.២ | 0.៧ | ១.៦ | 0.១ | ១.២ | 0.១ | 0.៨ | 0.១ | 0.៤ | 0.៧ | -0.៧ | ១.៤ |
| ១២ ប៊ូតាណ | 0.0 | ៩.៤ | ១២.១ | ៣.៥ | ៣៥.២ | ២៣.២ | ១៣.៩ | ៥.0 | -៥.៩ | ១២.៧ | ៥.0 | ៧.៩ | ៨.៥ | ១២.២ | 0.0 |
| ១៣ ឥណ្ឌា | 0.៧ | ១.៥ | ២.៤ | ២.៧ | ២.៣ | ៣.៥ | ១.១ | ២.១ | ១.៨ | ២.៣ | ១.៩ | ២.១ | ១.៦ | ៣.៥ | ៣.៨ |
| ១៤ ម៉ាល់ឌីវ | ៥២.៨ | -៤.៨ | ៣.៣ | ៨.៥ | ១៦.0 | ៤.៥ | ៨.៧ | ៧.៩ | ១១.២ | ៧.៨ | ១៤.៩ | ៧.៦ | ៤.៦ | ១១.៨ | ៧.៩ |
| ១៥ នេប៉ាល់ | ៣.២ | ១0.៣ | ១0.៤ | ៧.៤ | ១0.៨ | ១0.0 | ៥.៧ | ៦.៩ | ៩.0 | ៤.១ | ៣.៣ | ៤.២ | ៤.៦ | -៤.២ | 0.៦ |
| ១៦ ប៉ាគីស្ថាន | ៤.៨ | ៣.៦ | ៣.៣ | ៤.៥ | ៦.៣ | ៦.៨ | ៣.៥ | ៥.១ | ៣.៨ | ៣.៣ | ២.២ | 0.១ | 0.៣ | 0.៨ | -0.៩ |
| ១៧ ស្រីលង្កា | ៩.៥ | ៥.៩ | ៩.៥ | ៧.១ | ១0.៥ | ១0.0 | ៦.២ | ៤.0 | ៣.0 | ១.២ | ១.៤ | ២.៧ | ២.៩ | ៣.៥ | ៤.២ |

សម្គាល់ : តុល្យភាពគណនីមូលធន = ការប្រែប្រួលមូលនិធិបម្រុងជារូបិយប័ណ្ណបរទេស - តុល្យភាពគណនីបច្ចុប្បន្ន

ប្រភព: World Bank ២00៥។

## តារាងទី ៣៣: ការវិនិយោគដោយផ្ទាល់ពីបរទេស

| អនុតំបន់/ប្រទេស/តំបន់ | លំហូរចូលសុទ្ធនៃការវិនិយោគដោយផ្ទាល់ពីបរទេស (% នៃ GDP) | | | លំហូរចូលសុទ្ធនៃការវិនិយោគដោយផ្ទាល់ពីបរទេស (% នៃការបង្កើតមូលនិធិដុល) | | |
|---|---|---|---|---|---|---|
| | ១៩៨២ | ១៩៩២ | ២០០០ | ១៩៨២ | ១៩៩២ | ២០០០ |
| **អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក** | | | | | | |
| ១ កម្ពុជា | .. | ១.៧ | ៣.៦ | .. | ១៧.០ | ១៦.៣ |
| ២ ចិន | ០.២ | ២.៧ | ៣.៩ | ០.៦ | ៧.៤ | ៩.៦ |
| ៣ ហ្វីជី | ៣.១ | ៦.៤ | ១.៥ | ១២.០ | ៥០.៣ | .. |
| ៤ ឥណ្ឌូណេស៊ី | ០.២ | ១.៣ | -០.៩ | ០.៩ | ៤.២ | -៩.៦ |
| ៥ ម៉ាឡេស៊ី | ៥.១ | ៨.៨ | ៣.៤ | ១៥.២ | ២៤.៨ | ១៤.២ |
| ៦ ម៉ុងហ្គោលី | .. | .. | ៧.០ | .. | .. | ២១.៦ |
| ៧ ប៉ាពូញូហ្គីណេ | ៣.៦ | ២.៤ | ០.៧ | ១១.៣ | ១០.២ | .. |
| ៨ ហ្វីលីពីន | ០.០ | ០.៤ | ២.៣ | ០.២ | ២.០ | ១១.៩ |
| ៩ ថៃ | ០.៥ | ១.៩ | ០.៨ | ២.០ | ៤.៧ | ៣.២ |
| ១០ វៀតណាម | .. | ៤.៨ | ៤.០ | .. | ២៧.២ | ១២.០ |
| **អាស៊ីខាងត្បូង** | | | | | | |
| ១១ បង់ក្លាដេស | ០.០ | ០.០ | ០.១ | ០.២ | ០.១ | ០.៥ |
| ១២ ប៊ូតាណ | ០.០ | ០.០ | ០.០ | ០.០ | ០.០ | ០.១ |
| ១៣ ឥណ្ឌា | ០.០ | ០.១ | ០.៧ | ០.២ | ០.៥ | ៣.២ |
| ១៤ ម៉ាល់ឌីវ | ០.០ | ២.៣ | ១.៩ | .. | .. | ៧.៦ |
| ១៥ នេប៉ាល់ | ០.០ | ០.០ | -០.១ | ០.០ | ០.០ | -០.៤ |
| ១៦ ប៉ាគីស្ថាន | ០.២ | ០.៧ | ១.២ | ១.១ | ៣.៤ | ៦.៩ |
| ១៧ ស្រីលង្កា | ១.៣ | ១.៣ | ១.២ | ៤.៣ | ៩.២ | ៥.៦ |
| **តំបន់** | | | | | | |
| ១ អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក | ០.៦ | ២.៧ | ៣.១ | ១.៩ | ៧.៧ | ៨.៩ |
| ២ អឺរ៉ុប និងអាស៊ីកណ្ដាល | ០.១ | ០.៤ | ៣.១ | ០.២ | ១.២ | ១៤.១ |
| ៣ អាមេរិកឡាទីន និងការ៉ាអ៊ីប | ០.៩ | ១.២ | ២.៧ | ៤.០ | ៥.៨ | ១៤.០ |
| ៤ មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង | ២.៥ | ០.៧ | .. | ១០.៨ | ៣.០ | .. |
| ៥ អាស៊ីខាងត្បូង | ០.១ | ០.២ | ០.៧ | ០.៤ | ១.០ | ៣.៣ |
| ៦ ក្បែរសាហារ៉ានៃទ្វីបអាហ្វ្រិក | ០.៤ | ០.៥ | ២.៧ | ២.១ | ៣.៥ | ១៤.០ |
| ៧ ប្រទេសអភិវឌ្ឍន៍តិចតួច | ០.៣ | ១.១ | ៣.៤ | ១.៩ | ៧.៤ | ១៥.០ |
| ៨ ពិភពលោក | ០.៥ | ០.៧ | ២.២ | ២.៤ | ៣.១ | ១០.៤ |

ប្រភព: World Bank ២០០៥។

## តារាងទី ៣៤: ជំនួយអភិវឌ្ឍន៍ផ្លូវការ

| អនុតំបន់/ប្រទេស/តំបន់ | ជំនួយក្នុងមនុស្សម្នាក់ (តម្លៃដុល្លារអាមេរិកបច្ចុប្បន្ន) | | | ជំនួយ (% នៃ GDP) | | | ជំនួយ (% នៃការនាំចូលទំនិញ និងសេវា) | | |
|---|---|---|---|---|---|---|---|---|---|
| | ១៩៨២ | ១៩៩២ | ២០០២ | ១៩៨២ | ១៩៩២ | ២០០២ | ១៩៨២ | ១៩៩២ | ២០០២ |
| **អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក** | | | | | | | | | |
| ១ កម្ពុជា | ៦.៤ | ២០.១ | ៣៧.០ | .. | ១០.៤ | ១២.២ | .. | ៣៩.០ | ១៦.៧ |
| ២ ចិន | ០.៥ | ២.៦ | ១.២ | ០.៣ | ០.៧ | ០.១ | ២.៧ | ៣.៨ | ០.៤ |
| ៣ ហ្វីជី | ៥៣.៩ | ៨៤.៨ | ៤១.៤ | ២.៩ | ៤.០ | ២.០ | ៥.៤ | ៦.៩ | .. |
| ៤ ឥណ្ឌូណេស៊ី | ៥.៨ | ១០.៧ | ៦.២ | ១.០ | ១.៤ | ០.៨ | ៣.៤ | ៤.៨ | ២.២ |
| ៥ ម៉ាឡេស៊ី | ៩.៤ | ១០.៧ | ៣.៥ | ០.៥ | ០.៣ | ០.១ | ០.៨ | ០.៤ | ០.១ |
| ៦ ម៉ុងហ្គោលី | ១.៤ | ៥៦.៦ | ៨៥.១ | .. | .. | ១៨.៧ | ០.២ | ២៥.៦ | ២១.៦ |
| ៧ ប៉ាពួញូហ្គីណេ | ៩៥.៦ | ១០៦.៨ | ៣៧.៨ | ១៣.១ | ១០.២ | ៦.៩ | ២០.១ | ១៨.៣ | ១១.៤ |
| ៨ ហ្វីលីពីន | ៦.៦ | ២៦.៩ | ៦.៩ | ០.៩ | ៣.២ | ០.៧ | ២.៨ | ៩.០ | ១.៣ |
| ៩ ថៃ | ៨.០ | ១២.៩ | ៤.៨ | ១.១ | ០.៧ | ០.២ | ៣.៧ | ១.៥ | ០.៤ |
| ១០ វៀតណាម | ៤.៥ | ៨.៣ | ១៥.៩ | .. | ៥.៨ | ៣.៦ | .. | .. | ៥.៧ |
| **អាស៊ីខាងត្បូង** | | | | | | | | | |
| ១១ បង់ក្លាដេស | ១៤.៩ | ១៦.០ | ៦.៧ | ៧.៤ | ៥.៧ | ១.៩ | ៤៧.៦ | ៤២.៣ | ៩.៦ |
| ១២ ប៊ូតាណ | ២២.៣ | ៨៦.៨ | ៨៦.៣ | ៧.០ | ២២.៥ | ១២.២ | ១១.២ | ៥០.១ | ២៨.០ |
| ១៣ ឥណ្ឌា | ២.៣ | ២.៨ | ១.៤ | ០.៨ | ១.០ | ០.៣ | ៩.០ | ៧.២ | ១.៦ |
| ១៤ ម៉ាល់ឌីវ | ៣២.៣ | ១៦២.១ | ៩៥.៨ | ១១.៣ | ១២.៨ | ៤.៣ | ៩.៥ | ១៥.៤ | ៥.៥ |
| ១៥ នេប៉ាល់ | ១៣.២ | ២២.៨ | ១៥.១ | ៨.៤ | ១២.៧ | ៦.៦ | ៤០.៦ | ៤៣.៦ | ២១.១ |
| ១៦ ប៉ាគីស្ថាន | ១០.៥ | ៨.៩ | ១៤.៨ | ៣.០ | ២.១ | ៣.០ | ១២.៦ | ៧.៣ | ១៤.២ |
| ១៧ ស្រីលង្កា | ២៧.៧ | ៣៨.៦ | ១៨.១ | ៨.៧ | ៦.៦ | ២.១ | ១៧.៩ | ១៥.៧ | ៤.៦ |
| **តំបន់** | | | | | | | | | |
| ១ អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក | ២.៦ | ៥.៩ | ៤.០ | ០.៩ | ១.២ | ០.៤ | ៣.៩ | ៣.៩ | ១.១ |
| ២ អឺរ៉ុប និងអាស៊ីកណ្ដាល | ១.៥ | ១៨.០ | ២៣.៨ | .. | ០.៨ | ១.០ | .. | .. | ២.៣ |
| ៣ អាមេរិកឡាទីន និងការ៉ាអ៊ីប | ៦.៩ | ១១.៩ | ៩.៨ | ០.៣ | ០.៤ | ០.៣ | ១.៥ | ២.២ | ១.១ |
| ៤ មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង | ៣០.៦ | ២៧.៧ | ១៩.៨ | ១.៤ | ១.៥ | ០.៩ | ៣.៤ | ៣.៩ | ៣.២ |
| ៥ អាស៊ីខាងត្បូង | ៤.៨ | ៥.៧ | ៤.៧ | ១.៨ | ២.០ | ១.០ | ១៤.៣ | ១១.៥ | ៥.៣ |
| ៦ ក្បែរសាហារ៉ានៃទ្វីបអាហ្វ្រិក | ១៩.៧ | ៣៦.១ | ២៧.៣ | ៣.២ | ៦.៣ | ៥.៦ | ៩.៨ | ២១.៨ | ១៤.៩ |
| ៧ ប្រទេសអភិវឌ្ឍន៍តិចតួច | ១៩.៩ | ៣០.១ | .. | ៧.៤ | ១១.៨ | .. | ៣០.៦ | ៤៤.៨ | .. |
| ៨ ពិភពលោក | ៦.៦ | ១២.៤ | ១០.៨ | ០.៣ | ០.៣ | ០.២ | ១.១ | ១.២ | ០.៧ |

ប្រភព: World Bank ២០០៥។

## តារាងទី ៣៥: ការនាំចេញតាមតំបន់ចំបងៗដែលជាប្រភពដើម និងជាគោលដៅចុងក្រោយ

| អនុតំបន់/ប្រទេស/តំបន់ | ឆ្នាំ | សេដ្ឋកិច្ចជឿនលឿន | EU ២៥ | ស.រ.អ និង កាណាដា | ជប៉ុន | អឺរ៉ុបអាគ្នេយ៍ និង CIS | សេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ | OPEC | សេដ្ឋកិច្ច កំពុងអភិវឌ្ឍន៍: អាហ្វ្រិក | សេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ អាស៊ីខាងលិច | សេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ផ្សេងទៀតនៅអាស៊ី | មិនបានបែងចែក | ពិភពលោក |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក** | | | | | | | | | | | | | |
| ១ កម្ពុជា | ១៩៩០ | ១៥.០ | ៧.១ | .. | ៧.៦ | ០.៧ | ៨៤.៣ | ១.៨ | ០.២ | ០.០ | ៨៣.៣ | ០.០ | ១០០ |
| | ២០០៤ | ៩០.៩ | ២៥.៦ | ៦០.៨ | ៣.៥ | ០.១ | ៩.១ | ០.១ | ០.០ | ០.១ | ៨.៩ | ០.០ | ១០០ |
| ២ ចិន | ១៩៩០ | ៣៥.៧ | ១០.៧ | ៩.២ | ១៤.៧ | ៣.៧ | ៥៩.៦ | ២.៥ | ២.១ | ២.២ | ៥៤.១ | ១.០ | ១០០ |
| | ២០០៤ | ៥៧.៩ | ១៨.២ | ២៤.៩ | ១២.២ | ២.៤ | ៣៩.៦ | ៣.៧ | ២.២ | ៣.១ | ៣១.៦ | ០.០ | ១០០ |
| ៣ ហ្វីជី | ១៩៩០ | ៦៥.២ | ២៣.៣ | ១០.៦ | ៥.៩ | .. | ៥.៤ | .. | .. | .. | ៥.៤ | ២៥.៥ | ១០០ |
| | ២០០៤ | ៦៤.៥ | ១៣.៦ | ២៤.៤ | ៤.១ | ០.០ | ២០.៦ | ០.៤ | ០.០ | ០.០ | ២.៥ | ១៤.៩ | ១០០ |
| ៤ ឥណ្ឌូណេស៊ី | ១៩៩០ | ៧០.៥ | ១២.៣ | ១៣.៦ | ៤២.៥ | ០.៤ | ២៩.០ | ២.៧ | ០.៧ | ២.៧ | ២៥.១ | ០.១ | ១០០ |
| | ២០០៤ | ៥១.៤ | ១៣.៦ | ១៣.៦ | ២០.៣ | ០.៦ | ៤៨.០ | ២.៥ | ១.៩ | ៣.២ | ៤១.៥ | ០.០ | ១០០ |
| ៥ ម៉ាឡេស៊ី | ១៩៩០ | ៥០.៨ | ១៥.៦ | ១៧.៧ | ១៥.៣ | ០.៨ | ៤៨.៤ | ២.៧ | ០.៨ | ២.៤ | ៤៤.៥ | ០.០ | ១០០ |
| | ២០០៤ | ៤៥.៩ | ១២.៦ | ១៩.៤ | ១០.១ | ០.៦ | ៥៣.៥ | ៤.៦ | ១.២ | ៣.០ | ៤៨.១ | ០.០ | ១០០ |
| ៦ ម៉ុងហ្គោលី | ១៩៩០ | ៥៦.០ | ៣៥.៩ | ២.០ | ១៧.៦ | ៨.៨ | ៣៥.២ | ០.១ | ២០.៧ | ០.១ | ១៣.៩ | ០.០ | ១០០ |
| | ២០០៤ | ៤០.៣ | ៧.៤ | ៣១.៨ | ១.០ | ៥.៥ | ៥៤.១ | ០.៣ | ០.០ | ០.៥ | ៥៣.៦ | ០.០ | ១០០ |
| ៧ ប៉ាពួញូហ្គីណេ | ១៩៩០ | ៨២.០ | ២៤.១ | ២.៧ | ២៧.៨ | .. | ១៧.៧ | ០.៣ | ០.២ | ០.០ | ១៧.១ | ០.៣ | ១០០ |
| | ២០០៤ | ៤៥.២ | ១០.៥ | ១.២ | ៥.៦ | ០.០ | ១៤.៨ | ៣.២ | ០.០ | ០.០ | ១៤.៤ | ៤០.០ | ១០០ |
| ៨ ហ្វីលីពីន | ១៩៩០ | ៧៩.៣ | ១៨.៥ | ៣៩.៤ | ១៩.៨ | ០.០ | ២០.០ | ១.៨ | ០.៣ | ១.១ | ១៧.៥ | ០.៦ | ១០០ |
| | ២០០៤ | ៥១.២ | ១៥.៦ | ១៨.៥ | ១៥.៦ | ០.១ | ៤៨.៧ | ១.៤ | ០.៣ | ០.៧ | ៤៧.១ | ០.០ | ១០០ |
| ៩ ថៃ | ១៩៩០ | ៦៨.១ | ២៣.៤ | ២៤.០ | ១៧.២ | ០.៦ | ៣០.៨ | ៥.២ | ២.៥ | ៤.៨ | ២២.០ | ០.៦ | ១០០ |
| | ២០០៤ | ៤៩.៨ | ១៤.៧ | ១៧.០ | ១៣.៩ | ០.៤ | ៤៨.៤ | ៦.៣ | ២.៦ | ៣.២ | ៤១.០ | ១.៣ | ១០០ |
| ១០ វៀតណាម | ១៩៩០ | ២៣.៩ | ៩.៨ | ០.១ | ១៣.៥ | ៣៨.២ | ២៨.៤ | ១.៧ | ០.២ | ០.៩ | ២៦.៨ | ៩.៦ | ១០០ |
| | ២០០៤ | ៦៥.៨ | ២៣.២ | ២១.២ | ១៣.៤ | ០.៦ | ៣២.៨ | ៤.៨ | ១.០ | ៣.២ | ២៧.៧ | ០.៧ | ១០០ |
| **អាស៊ីខាងត្បូង** | | | | | | | | | | | | | |
| ១១ បង់ក្លាដេស | ១៩៩០ | ៧៥.២ | ៣៥.៤ | ៣២.២ | ៣.៩ | ៤.៦ | ១៩.៧ | ៣.៥ | ៤.១ | ៥.០ | ១០.១ | ០.៥ | ១០០ |
| | ២០០៤ | ៧៨.៣ | ៥០.០ | ២៦.៥ | ១.០ | ០.១ | ៨.៧ | ១.២ | ០.៩ | ២.០ | ៥.៤ | ១២.៩ | ១០០ |
| ១២ ប៊ូតាណ | ១៩៩០ | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| | ២០០៤ | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| ១៣ ឥណ្ឌា | ១៩៩០ | ៥៧.៣ | ២៩.១ | ១៦.០ | ៩.៣ | ១៦.៨ | ២១.៥ | ៦.១ | ២.៥ | ៦.៣ | ១២.២ | ៤.៥ | ១០០ |
| | ២០០៤ | ៤៧.៨ | ២២.២ | ១៩.៦ | ២.៩ | ១.៦ | ៥០.២ | ១៤.០ | ៥.៩ | ១៣.៨ | ២៨.៥ | ០.៤ | ១០០ |
| ១៤ ម៉ាល់ឌីវ | ១៩៩០ | ៦១.៥ | ២៦.២ | ២៦.៣ | ៨.៥ | .. | ៣៨.៥ | .. | .. | .. | ៣៨.៥ | ០.០ | ១០០ |
| | ២០០៤ | ៦៣.៤ | ១៤.៨ | ៣៩.៩ | ៨.៦ | ០.០ | ៣៦.៥ | ៦.៨ | ៥.៣ | ០.១ | ៣០.៥ | ០.០ | ១០០ |
| ១៥ នេប៉ាល់ | ១៩៩០ | ៨៥.០ | ៥៣.៨ | ២៤.០ | ០.៨ | ០.០ | ១៥.០ | ០.០ | ០.១ | ០.០ | ១៤.៨ | ០.០ | ១០០ |
| | ២០០៤ | ៤៣.០ | ១៧.៥ | ២៣.៤ | ១.០ | ០.០ | ៥៤.០ | ០.០ | ០.០ | ០.៧ | ៥៣.៣ | ៣.០ | ១០០ |
| ១៦ ប៉ាគីស្ថាន | ១៩៩០ | ៦២.០ | ៣៧.១ | ១៤.១ | ៨.២ | ២.៧ | ៣២.៩ | ៨.៦ | ៤.២ | ១០.១ | ១៨.៤ | ២.៤ | ១០០ |
| | ២០០៤ | ៥៣.០ | ២៨.០ | ២២.១ | ១.១ | ០.៦ | ៤៥.៩ | ១៨.៦ | ៤.៩ | ២០.៦ | ១៨.៨ | ០.៥ | ១០០ |
| ១៧ ស្រីលង្កា | ១៩៩០ | ៦២.៤ | ២៦.៩ | ២៧.៤ | ៥.៤ | ៣.១ | ៣០.៥ | ១១.០ | ៥.៥ | ១៣.៣ | ៩.៦ | ៣.៩ | ១០០ |
| | ២០០៤ | ៦៦.៧ | ២៩.៣ | ៣២.២ | ២.៩ | ៣.៣ | ២២.១ | ៦.២ | ១.៨ | ៧.៥ | ១១.៣ | ៤.៦ | ១០០ |

សម្គាល់ : គ្មានទិន្នន័យសម្រាប់ប្រទេសប៊ូតាណទេ។ ពិភពលោក = សេដ្ឋកិច្ចជឿនលឿន + អឺរ៉ុបអាគ្នេយ៍ + សេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ + សេដ្ឋកិច្ចមិនបានបែងចែក

## តារាងទី ៣៦: ការនាំចូលតាមតំបន់ចម្បងៗដែលជាប្រភពដើម និងជាគោលដៅចុងក្រោយ

| អនុតំបន់/ប្រទេស/តំបន់ | ឆ្នាំ | សេដ្ឋកិច្ចជឿនលឿន | EU ២៥ | ស.រ.អ និងកាណាដា | ជប៉ុន | អឺរ៉ុបអាគ្នេយ៍ និង CIS | សេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ | OPEC | សេដ្ឋកិច្ច កំពុងអភិវឌ្ឍន៍: អាហ្វ្រិក | សេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ អាស៊ីខាងលិច | សេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ផ្សេងទៀតនៅអាស៊ី | មិនបានបែងចែក | ពិភពលោក |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក** | | | | | | | | | | | | | |
| ១ កម្ពុជា | ១៩៩០ | ៤០.០ | ២៨.២ | ០.០ | ៩.០ | ០.០ | ៥៩.៩ | ៣.៩ | ០.១ | ៣.៥ | ៥៥.៨ | ០.០ | ១០០ |
| | ២០០៤ | ៩.៣ | ៤.១ | ១.៩ | ២.៥ | ០.២ | ៩០.៥ | ៣.៣ | ០.០ | ០.១ | ៩០.៤ | ០.០ | ១០០ |
| ២ ចិន | ១៩៩០ | ៥១.៣ | ១៨.២ | ១៥.០ | ១៤.២ | ៤.៨ | ៤២.៩ | ២.២ | ០.៧ | ១.០ | ៣៨.៥ | ១.០ | ១០០ |
| | ២០០៤ | ៣៩.៨ | ១២.២ | ៨.៨ | ១៥.៨ | ៣.០ | ៥០.៧ | ៣.៩ | ២.៣ | ៣.៤ | ៤១.៤ | ៦.៥ | ១០០ |
| ៣ ហ្វីជី | ១៩៩០ | ៧៤.១ | ៥.៦ | ១៣.៤ | ១១.០ | .. | ១៩.៧ | .. | .. | .. | ១៩.៧ | ៦.២ | ១០០ |
| | ២០០៤ | ៥៨.០ | ៤.០ | ២.៥ | ៣.៩ | ០.០ | ៤០.៨ | ១.៧ | ០.៣ | ០.០ | ៣៩.៥ | ១.២ | ១០០ |
| ៤ ឥណ្ឌូណេស៊ី | ១៩៩០ | ៦៦.២ | ២០.៨ | ១៣.៣ | ២៤.៨ | ០.៤ | ៣៣.០ | ៤.៧ | ០.៧ | ៥.១ | ២៤.៨ | ០.៥ | ១០០ |
| | ២០០៤ | ៤២.៥ | ១១.៧ | ៦.៥ | ១៨.៤ | ០.៩ | ៥៥.៩ | ៧.៤ | ៣.៥ | ៥.៦ | ៤៥.០ | ០.៧ | ១០០ |
| ៥ ម៉ាឡេស៊ី | ១៩៩០ | ៦៣.៨ | ១៦.១ | ១៧.៩ | ២៤.២ | ០.៤ | ៣៥.៦ | ២.២ | ០.៥ | ១.២ | ៣២.០ | ០.២ | ១០០ |
| | ២០០៤ | ៤៦.៤ | ១២.១ | ១៥.១ | ១៦.១ | ០.៥ | ៥២.៩ | ៥.៩ | ០.៦ | ២.៤ | ៤៨.៦ | ០.២ | ១០០ |
| ៦ ម៉ុងហ្គោលី | ១៩៩០ | ៦៧.៨ | ៥៤.៣ | .. | ១០.៧ | ៨.៩ | ២៣.២ | ០.០ | ០.៧ | ០.៦ | ២២.៥ | ០.០ | ១០០ |
| | ២០០៤ | ២៦.៣ | ១២.២ | ៤.២ | ៧.៩ | ៣៦.៧ | ៣៧.០ | ០.៤ | ០.០ | ០.៤ | ៣៦.២ | ០.០ | ១០០ |
| ៧ ប៉ាពួញូហ្គីណេ | ១៩៩០ | ៨២.០ | ៦.៧ | ១១.៥ | ១៣.៣ | ០.១ | ១៧.៧ | ១.០ | ០.៣ | ០.០ | ១៦.៨ | ០.៣ | ១០០ |
| | ២០០៤ | ៦០.៧ | ២.៦ | ៣.១ | ៤.៣ | ០.២ | ៣៧.៣ | ៣.១ | ០.២ | ០.១ | ៣៦.៤ | ១.៧ | ១០០ |
| ៨ ហ្វីលីពីន | ១៩៩០ | ៥៦.៥ | ១២.១ | ២១.០ | ១៨.៤ | ០.៤ | ៤៣.០ | ១២.៧ | ០.៧ | ១១.៤ | ២៧.៩ | ០.០ | ១០០ |
| | ២០០៤ | ៤៧.៦ | ៨.៦ | ១៥.៧ | ២០.០ | ១១ | ៥១.៣ | ៧.៧ | ០.២ | ៥.៩ | ៤៣.៧ | ០.០ | ១០០ |
| ៩ ថៃ | ១៩៩០ | ៦៣.៧ | ១៦.៩ | ១១.៩ | ៣០.៤ | ០.៧ | ៣៤.៨ | ៤.០ | ០.៩ | ៣.៨ | ២៨.១ | ០.៨ | ១០០ |
| | ២០០៤ | ៤៥.៧ | ៩.៩ | ៨.២ | ២៣.៦ | ១.៦ | ៥០.៤ | ១០.៣ | ១.៤ | ១១.១ | ៣៦.០ | ២.៣ | ១០០ |
| ១០ វៀតណាម | ១៩៩០ | ២០.០ | ១៣.១ | ០.២ | ៥.៩ | ៧.៧ | ២៩.៩ | ០.៣ | ០.១ | ០.០ | ២៩.៦ | ៤២.៣ | ១០០ |
| | ២០០៤ | ២៦.៨ | ៩.៥ | ៤.២ | ១០.៧ | ៣.០ | ៦៩.៥ | ៣.៣ | ០.៤ | ១.៤ | ៦៦.៧ | ០.៧ | ១០០ |
| **អាស៊ីខាងត្បូង** | | | | | | | | | | | | | |
| ១១ បង់ក្លាដេស | ១៩៩០ | ៤៤.០ | ១៨.៥ | ៨.៣ | ១៣.២ | ១.៣ | ៤១.៣ | ៦.៣ | ០.៣ | ៥.១ | ៣៤.៤ | ១៣.៣ | ១០០ |
| | ២០០៤ | ២០.៨ | ៨.៧ | ៣.២ | ៥.៦ | ២.០ | ៦៦.៣ | ១០.៣ | ០.៩ | ៨.២ | ៥៥.៧ | ១០.៩ | ១០០ |
| ១២ ប៊ូតាណ | ១៩៩០ | .. | .. | .. | .. | .. | | | | | | | |
| | ២០០៤ | .. | .. | .. | .. | .. | | | | | | | |
| ១៣ ឥណ្ឌា | ១៩៩០ | ៥៨.៦ | ៣៤.០ | ១២.៣ | ៧.៥ | ៦.៣ | ៣៤.៦ | ១៦.៧ | ៣.១ | ១៨.០ | ១១.២ | ០.៥ | ១០០ |
| | ២០០៤ | ៤០.៩ | ២១.៧ | ៧.៣ | ៣.៣ | ២.២ | ៣៣.១ | ៦.៥ | ២.៣ | ៤.៦ | ២៤.៥ | ២៣.៨ | ១០០ |
| ១៤ ម៉ាល់ឌីវ | ១៩៩០ | ១៧.៤ | ១៣.០ | ០.៥ | ៣.៣ | ០.០ | ៨២.៦ | ០.៧ | .. | ០.៥ | ៨២.០ | ០.០ | ១០០ |
| | ២០០៤ | ២០.២ | ១២.៣ | ២.២ | ១.២ | ០.០ | ៧៩.៦ | ៩.៦ | ៣.២ | ៧.៦ | ៦៨.៨ | ០.២ | ១០០ |
| ១៥ នេប៉ាល់ | ១៩៩០ | ៤៦.៦ | ១៨.២ | ២.៨ | ១៨.៧ | ០.៨ | ៥២.៦ | ០.០ | ០.២ | ០.០ | ៥១.៩ | ០.០ | ១០០ |
| | ២០០៤ | ៩.៨ | ៥.០ | ២.១ | ១.៤ | ៥.៥ | ៨៦.៨ | ១៦.៩ | ០.៣ | ១៦.៨ | ៦៩.៥ | ២.៩ | ១០០ |
| ១៦ ប៉ាគីស្ថាន | ១៩៩០ | ៥៦.១ | ២៤.៩ | ១៤.១ | ១១.៩ | ១.៥ | ៤១.១ | ១៨.៥ | ២.៦ | ១៩.៥ | ១៧.៩ | ១.៣ | ១០០ |
| | ២០០៤ | ៤០.៣ | ១៨.៥ | ១១.២ | ៦.៧ | ១.៧ | ៥៧.១ | ២៨.០ | ២.២ | ២៧.៤ | ២៦.៩ | ១.០ | ១០០ |
| ១៧ ស្រីលង្កា | ១៩៩០ | ៤០.៩ | ១៦.២ | ៨.៦ | ១២.៣ | ១.០ | ៥៨.០ | ១២.១ | ៤.៤ | ១២.០ | ៤០.៤ | ០.១ | ១០០ |
| | ២០០៤ | ២៩.២ | ១៧.០ | ២.៦ | ៤.៣ | ០.៣ | ៦៥.២ | ១០.៦ | ០.៥ | ៨.៦ | ៥៥.៧ | ២.៥ | ១០០ |

សម្គាល់ : គ្មានទិន្នន័យសម្រាប់ប្រទេសប៊ូតាណទេ។ ពិភពលោក = សេដ្ឋកិច្ចជឿនលឿន + អឺរ៉ុបអាគ្នេយ៍ + សេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ + សេដ្ឋកិច្ចមិនបានបែងចែក

ប្រភព : UNCTAD ២០០៥

## តារាងទី ៣៧: កិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ និងទ្វេភាគី និងសមាជិកភាពអង្គការ WTO

| អនុតំបន់/ប្រទេស/តំបន់ | កិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ (RTAs) | កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី (BTAs) | សមាជិក WTO ឆ្នាំ |
|---|---|---|---|
| **អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក** | | | |
| ១ កម្ពុជា | AFTA (១៩៩៩) | ចិន (២០០២)* | ២០០៤ |
| ២ ចិន | ASEAN (២០០២) កិច្ចព្រមព្រៀងក្រុងបាងកក (២០០១) | ហុងកុង - ចិន (SAR) (២០០៣), ម៉ាកាវ (២០០៣), ប៉ាគីស្ថាន (២០០៥) | ២០០១ |
| ៣ ហ្វីជី | PICTA (២០០១), PACER (២០០១) | គ្មាន | ១៩៩៦ |
| ៤ ឥណ្ឌូណេស៊ី | PICTA (១៩៩២) | ចិន (២០០២)* | ១៩៩៥ |
| ៥ ម៉ាឡេស៊ី | PICTA (១៩៩២), GSTP (១៩៨៩) | ចិន (២០០២)* | ១៩៩៥ |
| ៦ ម៉ុងហ្គោលី | .. | .. | ១៩៩៧ |
| ៧ ប៉ាពួញូហ្គីណេ | PICTA (២០០១), PACER (២០០១) | គ្មាន | ១៩៩៦ |
| ៨ ហ្វីលីពីន | AFT A (១៩៩២), GSTP (១៩៩២) | ចិន (២០០២)* | ១៩៩៥ |
| ៩ ថៃ | AFT A (១៩៩២), BIMSTEC (២០០៤), GSTP (១៩៩០) | អូស្ត្រាលី (២០០៤), បារ៉េន (២០០២), ចិន (២០០២)*, ឥណ្ឌា (២០០៣), នូវ៉ែលហ្សេឡង់ (២០០៥), ប៉េរូ (២០០៣) | ១៩៩៥ |
| ១០ វៀតណាម | AFTA (១៩៩៥), GSTP (១៩៨៩) | ចិន (២០០២)* | អ្នកសង្កេតការ |
| **អាស៊ីខាងត្បូង** | | | |
| ១១ បង់ក្លាដេស | SAFTA (២០០៤), BIMSTEC (២០០៤), កិច្ចព្រមព្រៀងក្រុងបាងកក (១៩៧៥), GSTP (១៩៨៩) | គ្មាន | ១៩៩៥ |
| ១២ ប៊ូតាណ | SAFTA (២០០៤), BIMSTEC (២០០៤) | ឥណ្ឌា (១៩៩៥) | អ្នកសង្កេតការ |
| ១៣ ឥណ្ឌា | SAFTA (២០០៤), BIMSTEC (២០០៤), កិច្ចព្រមព្រៀងក្រុងបាងកក (១៩៧៥), GSTP (១៩៨៩) | អាហ្វកានីស្ថាន (២០០៣), ប៊ូតាណ (១៩៩៥), MERCOSUR (២០០៥), នេប៉ាល់ (១៩៩៦), សឹង្ហបុរី (២០០៥), ស្រីលង្កា (១៩៩៨), ថៃ (២០០៣) | ១៩៩៥ |
| ១៤ ម៉ាល់ឌីវ | SAFTA (២០០៤) | គ្មាន | ១៩៩៥ |
| ១៥ នេប៉ាល់ | SAFTA (២០០៤), BIMSTEC (២០០៤) | ឥណ្ឌា (១៩៩៦) | ២០០៤ |
| ១៦ ប៉ាគីស្ថាន | SAFTA (២០០៤), ECO (២០០៣), GSTP (១៩៨៩) | ចិន (២០០៥), ស្រីលង្កា (២០០៥) | ១៩៩៥ |
| ១៧ ស្រីលង្កា | SAFTA (២០០៤), BIMSTEC (២០០៤), កិច្ចព្រមព្រៀងក្រុងបាងកក (១៩៧៥), GSTP (១៩៨៩) | ឥណ្ឌា (១៩៩៨), ប៉ាគីស្ថាន (២០០៥), អ៊ីរ៉ង់ (២០០៤) | ១៩៩៥ |

ប្រភព : * អាស៊ាន + កិច្ចព្រមព្រៀង; ( ) សំដៅលើឆ្នាំនៃកិច្ចព្រមព្រៀង ។
ប្រភព : វេបសាយ WTO ស្តីពីស្ថិតិពាណិជ្ជកម្មរបស់ WTO និងស្ថិតិពាណិជ្ជកម្មអន្តរជាតិឆ្នាំ ២០០៥
http://www.wto.orglenglish/res_e/statis_e/statis_e.htm
UNDP Policy Paper "The Great Maze: Regional and Bilateral Free Trade Agreements in Asia", UNDP Regional Centre in Colombo, December ២០០៥ ។ Bilateral Agreement Website bilaterals.org

# និយមន័យនៃបច្ចេកស័ព្ទ

**Ad valorem duties (tariffs)** ពន្ធដែលគិតជាភាគរយនៃទំនិញ ត្រូវបានគណនាជាភាគរយនៃតម្លៃមុខទំនិញ ដែលអាចយកពន្ធ។ ផ្ទុយពីអត្រាពន្ធជាក់លាក់។

**Anti-dumping duties** ពន្ធប្រឆាំងការលក់បង្ខូចថ្លៃ ដាក់ឱ្យអនុវត្តប្រសិនបើការនាំចេញដើម្បីលក់ថោកនោះធ្វើឱ្យខូចប្រយោជន៍របស់ផលិតករនៃទំនិញដែលត្រូវប្រកួតប្រជែងនៅក្នុងប្រទេសនាំចូល។ អត្រាពន្ធគួរតែស្មើនឹងផលសងរវាងថ្លៃនាំចេញ និងតម្លៃធម្មតានៃទំនិញដែលត្រូវលក់ថោកនោះ។

**Balance of trade** តុល្យភាពជញ្ជីងពាណិជ្ជកម្ម សំដៅលើភាពខុសគ្នារវាងតម្លៃនៃការនាំចេញនិងការនាំចូល ពោលគឺជាផលដករវាងតម្លៃនៃទំនិញនិងសេវានាំចេញ និងតម្លៃនៃការនាំចូលទំនិញនិងសេវា។

**Balance of payments** ជញ្ជីងទូទាត់កត់ត្រានូវរាល់លំហូរនៃសាច់ប្រាក់ចូល និងចេញពីប្រទេសណាមួយ។ លំហូរនេះអាចកើតឡើងពីការលក់ផលិតផលនាំចេញ (លំហូរចូលឬឥណទាន) ឬពីប្រទេសដែលបានទិញទំនិញពីក្រៅប្រទេស (លំហូរចេញឬឥណពន្ធ)។ លំហូរនេះអាចកើតឡើងពីប្រទេសដទៃដែលបានធ្វើវិនិយោគនៅក្នុងប្រទេសនោះ (ការវិនិយោគចូលក្នុងប្រទេសគឺជាឥណទាន) ឬពីក្រុមហ៊ុនណាមួយនៃប្រទេសមួយដែលធ្វើវិនិយោគនៅបរទេស (ឥណពន្ធ)។ រាល់លំហូរសាច់ប្រាក់ ត្រូវបូកបញ្ចូលគ្នា និងបែងជាក្រុមទៅតាមជំពូក។ បន្ទាប់មកគណនីសរុបត្រូវបានឱ្យឈ្មោះថាជញ្ជីងទូទាត់ ជាគោលការណ៍គឺដោយសារលំហូរចេញសរុបត្រូវតែសមមូលនឹងលំហូរចូលសរុប។ ដូច្នេះ ជញ្ជីងទូទាត់ត្រូវមានសមតុល្យ។

**Blue box** ប្រអប់ខៀវ ផ្សំដោយវិធានការណ៍នានាដែលជាករណីលើកលែងពីបទបញ្ជាទូទៅដែលគ្រប់ការឧបត្ថម្ភធនទាក់ទងទៅនឹងផលិតកម្មត្រូវតែកាត់បន្ថយ ឬ រក្សាទុកនៅក្នុងកម្រិតអប្បរមាដែលបានកំណត់។ ការទូទាត់ជំនួសទាក់ទងដោយផ្ទាល់ទៅនឹងទំហំដីធ្លីឬសត្វចិញ្ចឹម ប្រសិនបើសកម្មភាពដែលកំពុងទទួលការគាំទ្រនោះដាក់កំហិតនៅលើផលិតកម្ម។

**Common external tariffs** អត្រាពន្ធរួមខាងក្រៅ សំដៅលើអត្រាពន្ធប្រើប្រាស់ដោយក្រុមនៃប្រទេសនៅក្នុងតំបន់មួយថាជាឯកត្តារួម។

**Dumping** ការបង្ខូចថ្លៃ កើតឡើងនៅពេលដែលទំនិញត្រូវបាននាំចេញដោយថ្លៃទាបជាងតម្លៃដែលបានកំណត់។ ជាទូទៅមានន័យថាទំនិញទាំងនោះត្រូវបាននាំចេញទៅលក់ដោយថ្លៃទាបជាងថ្លៃដែលលក់នៅទីផ្សារក្នុងស្រុក ឬទីផ្សារក្នុងប្រទេសទីបី ឬដោយថ្លៃទាបជាងថ្លៃផលិត។

**Employment elasticity** ភាពយឺត (អេឡាស្ទិក) នៃការងារ គឺជាការប្រែប្រួលភាគរយចំនួនការងារបណ្តាលពីការផ្លាស់ប្តូរ ១% នៃកំណើនសេដ្ឋកិច្ច។

**EU Common Agricultural Policy** គោលនយោបាយកសិកម្មរួមរបស់សហភាពអឺរ៉ុប សំដៅលើប្រព័ន្ធរបស់សហភាពអឺរ៉ុបស្តីពីការឧបត្ថម្ភធនសម្រាប់កសិផលដែលធានាថ្លៃអប្បរមា

សម្រាប់ផលិតករ និងបង់ថ្លៃឧបត្ថម្ភសម្រាប់ផលដែលដាំបាន។

**An export processing zone (EPZ)** តំបន់កែច្នៃសម្រាប់ការនាំចេញ សម្រួលរបាំងពន្ធនិងពលកម្ម។ គោលបំណងចម្បងគឺបង្កើតប្រាក់ចំណូលពីការនាំចេញនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ជាទូទៅមានភាពដូចគ្នានឹងតំបន់ពាណិជ្ជកម្មសេរី។

**Extreme poverty** ភាពក្រីក្រធ្ងន់ធ្ងរ គឺជាស្ថានភាពធ្ងន់ធ្ងរបំផុតនៃភាពក្រីក្រ ដែលប្រជាជនមានលទ្ធភាពអប្បបរមា ឬតិចតួចបំផុតដើម្បីទទួលបានរបស់ចាំបាច់ជាមូលដ្ឋាន ដូចជា អាហារ សម្លៀកបំពាក់ ជម្រក ការអប់រំ និងការថែទាំសុខភាព។ ធនាគារពិភពលោកបានឱ្យនិយមន័យភាពក្រីក្រធ្ងន់ធ្ងរថាជាការរស់នៅដោយប្រាក់ ១ដុល្លារ ឬ តិចជាងនេះក្នុងមួយថ្ងៃ និងត្រូវបានប្រមាណថា ប្រជាជន ១.១០០ លាននាក់កំពុងរស់នៅក្នុងស្ថានភាពនេះ។ ការបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លានរហូតដល់ឆ្នាំ ២០១៥ គឺជាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

**Financial liberalization** សេរីភាវូបនីយកម្មហិរញ្ញវត្ថុ សំដៅលើការផ្លាស់ប្ដូរជាច្រើនខាងបទបញ្ញត្តិដែលអនុញ្ញាតិឱ្យវិនិយោគិនបរទេសទិញទ្រព្យនៅក្នុងប្រទេស និងបើកឱកាសឱ្យប្រជាពលរដ្ឋធ្វើវិនិយោគលើទ្រព្យបរទេស ដែលធ្វើឱ្យទីផ្សារភាគហ៊ុនក្នុងប្រទេសក្លាយជាផ្នែករួមមួយនៃទីផ្សារពិភពលោក។ ដំណើរការនេះត្រូវបានកំណត់ថាជាការផ្លាស់ប្ដូរបទបញ្ញត្តិ ដែលបើកចំហទីផ្សារមូលធនដល់វិនិយោគិនបរទេសដោយមានការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបញ្ញើមូលនិធិរបស់ប្រទេស ឬលំហូរមូលធននៃភាគទុនទៅក្នុងសេដ្ឋកិច្ចដែលកើតឡើង។ ក្របខ័ណ្ឌ GATT គឺជា កិច្ចព្រមព្រៀងទូទៅខាងផ្នែកពាណិជ្ជកម្មលើសេវា។ កិច្ចព្រមព្រៀងនេះចែងពី "ការផ្គត់ផ្គង់បួនបែប" សម្រាប់ការផ្តល់សេវានៅក្នុងពាណិជ្ជកម្មឆ្លងដែន :

- គំរូទី ១: ពាណិជ្ជកម្មឆ្លងដែន ដែលត្រូវបានឱ្យនិយមន័យថាជាការផ្តល់សេវាពីដែនដីនៃប្រទេសមួយទៅក្នុងដែនដីនៃប្រទេសមួយផ្សេងទៀត។
- គំរូទី ២: ការប្រើប្រាស់នៅក្រៅប្រទេស បានដល់ការផ្គត់ផ្គង់សេវានៃប្រទេសមួយទៅសេវារបស់អ្នកប្រើប្រាស់ប្រទេសណាមួយផ្សេងទៀត។
- គំរូទី ៣: វត្តមានជាលក្ខណៈជំនួញបានដល់សេវានានា ដែលផ្តល់ដោយអ្នកផ្គត់ផ្គង់សេវាពីប្រទេសមួយនៅក្នុងដែនដីនៃប្រទេសណាមួយផ្សេងទៀត។
- គំរូទី ៤: វត្តមាននៃរូបវន្តបុគ្គល បានដល់សេវានានាដែលផ្តល់ដោយអ្នកផ្គត់ផ្គង់សេវានៃប្រទេសមួយតាមរយៈវត្តមាននៃរូបវន្តបុគ្គលនានានៅក្នុងប្រទេសណាមួយផ្សេងទៀត។

"រូបវន្តបុគ្គល"គឺជាមនុស្សដែលខុសពីនីតិបុគ្គល ដូចជា ក្រុមហ៊ុនមួយ ឬអង្គការ។ ប្រទេសនានាអាចសម្រេចដោយសេរីអំពីកន្លែងដើម្បីធ្វើសេរីភាវូបនីយកម្មដោយផ្អែកទៅតាមវិស័យនីមួយៗ រួមទាំងអំពីគំរូជាក់លាក់ណាមួយនៃការផ្គត់ផ្គង់ ដែលពួកគេចង់អនុវត្តសម្រាប់វិស័យនោះ។

**Gross Domestic Product (GDP)** ផលទុនក្នុងស្រុកសរុប គឺជាតម្លៃសរុបដែលបានបូកបញ្ចូលទៅតាមថ្លៃទិញពីសំណាក់ផលិតករនៅក្នុងស្រុកនៃសេដ្ឋកិច្ច បូករួមជាមួយពន្ធនានា និងដកចេញគ្រប់ការឧបត្ថម្ភធន ដែលមិនបានរួមបញ្ចូលទៅក្នុងតម្លៃនៃផលិតផលនោះ។ GDP ត្រូវបានគណនាដោយពុំមានគិតការធ្លាក់ថ្លៃនៃទ្រព្យសម្បត្តិដែលបានបង្កើត ឬការ

បាត់បង់ ឬរេចរិលនៃធនធានធម្មជាតិឡើយ។ តម្លៃបន្ថែមគឺជាផលសម្រេចសុទ្ធនៃឧស្សាហកម្មមួយ ក្រោយពីបូកបញ្ចូលលទ្ធផលទាំងអស់ និងដកផលិតផលពាក់កណ្ដាលសម្រេច។

**Gender** យេនឌ័រ គឺជាសំណង់ខាងសង្គម ទាក់ទងនឹងវប្បធម៌ តួនាទី និងឥរិយាបថ ក៏ដូចជាទំនាក់ទំនងរវាង និងក្នុងចំណោមស្ត្រី និងបុរស កុមារា និងកុមារី។

**Generalized System of Preferences (GSP)** ប្រព័ន្ធអនុគ្រោះទូទៅ មានគោលដៅលើកទឹកចិត្តឱ្យមានការនាំចេញរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយអនុញ្ញាតតាមបែបអនុគ្រោះឱ្យផលិតផលពីប្រទេសទាំងនោះចូលទៅក្នុងទីផ្សារនៃប្រទេសជឿនលឿន។ ទោះបីប្រទេសផ្ដល់ជំនួយពុំមានកាតព្វកិច្ចនៅក្រោមច្បាប់អន្តរជាតិដើម្បីផ្ដល់ការអនុគ្រោះក្ដី ប្រទេសជឿនលឿនស្ទើរតែទាំងអស់បានអនុវត្តប្រព័ន្ធ GSP នេះ។ ប៉ុន្តែប្រព័ន្ធដែលប្រទេសទាំងនោះផ្ដល់ឱ្យមានភាពខុសគ្នាយ៉ាងច្រើន។

**Green Box** ប្រអប់បៃតង ផ្សំដោយការឧបត្ថម្ភចំណូល និងការឧបត្ថម្ភធន ដែលរំពឹងថានឹងបង្កឱ្យមានការរំខានតិចតួច ឬពុំមានការរំខានដល់ពាណិជ្ជកម្ម។ ការឧបត្ថម្ភធន ត្រូវតែទទួលមូលនិធិពីរដ្ឋាភិបាល ប៉ុន្តែមិនត្រូវពាក់ព័ន្ធនឹងការគាំទ្រថ្លៃឡើយ។ ការឧបត្ថម្ភដើម្បីការពារបរិស្ថានត្រូវបានរាប់បញ្ចូល។ ការឧបត្ថម្ភចំណូល ឬការឧបត្ថម្ភធនបែបនេះពុំទាមទារឱ្យមានការដាក់កំហិត ឬកាត់បន្ថយឡើយ។

**Gini coefficient (index)** មេគុណ (សន្ទស្សន៍) Gini សម្រាប់វាស់វិសាលភាពដែលរបាយប្រាក់ចំណូល (ការប្រើប្រាស់) ក្នុងចំណោមបុគ្គល ឬគ្រួសារនៅក្នុងប្រទេសមួយ មានគម្លាតពីរបាយដែលមានសមភាពឥតខ្ចោះ។ មេគុណដែលមានតម្លៃ "សូន្យ" តំណាងឱ្យសមភាពឥតខ្ចោះ រីឯមេគុណដែលមានតម្លៃ "មួយ" តំណាងឱ្យវិសមភាពទាំងស្រុង។

**Globalization** សម្រាប់គោលបំណងនៃរបាយការណ៍នេះ សកលភាវូបនីយកម្មសំដៅលើការពង្រីកជាទូទៅនូវសកម្មភាពសេដ្ឋកិច្ចអន្តរជាតិ ដែលរួមមានកំណើនពាណិជ្ជកម្មអន្តរជាតិ កំណើនការវិនិយោគអន្តរជាតិ (ការវិនិយោគបរទេស) និងចំណាកស្រុកជាអន្តរជាតិ ព្រមទាំងកំណើននៃការសាយភាយនូវបច្ចេកវិទ្យាក្នុងចំណោមប្រទេសនានា។ ដូច្នេះ សកលភាវូប-នីយកម្ម គឺជាកំណើនការធ្វើសមាហរណកម្មនៅទូទាំងពិភពលោក នូវទីផ្សារសម្រាប់ទំនិញ សេវា ពលកម្ម និងមូលធន។

**Headcount ratio** អនុបាតនៃចំនួនមនុស្ស សំដៅលើអាំងស៊ីដង់នៃភាពក្រីក្រ ឬសន្ទស្សន៍ចំនួនមនុស្ស។ នេះជាការវាស់សមាមាត្រធៀបនឹងចំនួនប្រជាជនសរុបនៅក្នុងតំបន់ណាមួយ ដែលការបរិភោគមានកម្រិតទាបជាងខ្សែបន្ទាត់នៃភាពក្រីក្រ។ម្យ៉ាងវិញទៀត នេះជាសមាមាត្រនៃចំនួនប្រជាជនដែលពុំមានលទ្ធភាពទិញទំនិញនិងសេវា ដែលត្រូវការចាំបាច់ជាមូលដ្ឋាន។

**Infant mortality rate** អត្រាមរណៈភាពកុមារ គឺជាភវនីយភាពនៃមរណៈភាពរវាងពេលកើតនិងអាយុមួយឆ្នាំគត់ដែលសំដែងជាមួយភាគពាន់នៃកំណើតរស់។

**Intellectual property rights** សិទ្ធិលើកម្មសិទ្ធិបញ្ញា គឺជាពាក្យទូទៅដែលគ្របដណ្ដប់សិទ្ធិលើទ្រព្យអរូបី រួមទាំងប៉ាតង់ សញ្ញាពាណិជ្ជកម្មនិងសេវា សិទ្ធិចម្លង និមិត្តសញ្ញា ឧស្សាហកម្ម សិទ្ធិលើការបង្កើតប្លង់នៃបន្ទះសៀគ្វីកុងតុចទ័រ និងសិទ្ធិលើការសម្ងាត់ខាងពាណិជ្ជកម្ម។

**Least Developed Countries (LDCs)** ប្រទេសអភិវឌ្ឍន៍តិចតួច ជាបណ្តាប្រទេសដែលអនុលោមតាមអង្គការសហប្រជាជាតិ បង្ហាញពីសូចនាករទាបបំផុតនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ប្រទេសមួយត្រូវបានចាត់ទុកថាមានការអភិវឌ្ឍតិចតួច ប្រសិនបើមានការឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យចំនួនបី ដែលផ្អែកលើ :

- ប្រាក់ចំណូលទាប (GIN ក្នុងមនុស្សម្នាក់ៗតិចជាង ៧៥0 ដុល្លារ)។
- ភាពទន់ខ្សោយនៃធនធានមនុស្ស (ផ្អែកលើសូចនាករនៃអាហារូបត្ថម្ភ សុខភាព ការអប់រំ និងអក្ខរភាពក្នុងចំណោមមនុស្សពេញវ័យ។
- ភាពងាយរងគ្រោះខាងសេដ្ឋកិច្ច (ផ្អែកលើអស្ថិរភាពនៃផលិតកម្មកសិកម្ម អស្ថិរភាពនៃការនាំចេញទំនិញនិងសេវាសារៈសំខាន់ខាងសេដ្ឋកិច្ចនៃសកម្មភាពដែលមិនមែនជាប្រពៃណី ការផ្តោតលើការនាំចេញទំនិញ និង ពិការភាពនៃសេដ្ឋកិច្ចខ្នាតតូច និងភាគរយនៃចំនួនប្រជាជនដែលផ្លាស់ទីដោយសារគ្រោះធម្មជាតិ)។

**Life expectancy at birth** អាយុកាលនៅពេលកើត គឺជាចំនួនឆ្នាំ ដែលទារកទើបកើតអាចរស់បាន ប្រសិនបើទម្រង់ជាទូទៅនៃអត្រាមរណៈភាពជាក់លាក់ទៅតាមអាយុធៀបនឹងពេលកើត ដែលនឹងរស់មានជីវិតនៅក្នុងវ័យកុមារភាព។

**Low- and middle-income developing countries** ប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលទាបនិងកណ្តាល ត្រូវបានឱ្យនិយមន័យដោយផ្អែកលើមូលដ្ឋាននៃផលទុនជាតិសរុបក្នុងម្នាក់ៗ (GNP) ដែលផ្អែកលើវិធានដែលប្រើប្រាស់ដោយធនាគារពិភពលោក។ យោងតាម GNP ក្នុងម្នាក់ៗ សម្រាប់ឆ្នាំ២០០៤ ក្រុមទាំងនេះគឺ ចំណូលទាប ៨២៥ដុល្លារ ឬតិចជាងនេះ ចំណូលទាបថ្នាក់កណ្តាល ៨២៦-៣.២៥៥ដុល្លារ ចំណូលខ្ពស់ថ្នាក់កណ្តាល ៣.២៥៦-១០.០៦៥ដុល្លារ និងចំណូលខ្ពស់ ១០.០៦៦ដុល្លារ ឬច្រើនជាងនេះ។

**Maternal mortality ratio** អត្រាមរណៈភាពមាតា គឺជាចំនួនស្ត្រីដែលបាត់បង់ជីវិតប្រចាំឆ្នាំ ដោយសារបញ្ហាទាក់ទងនឹងភាពមានគភ៌ ក្នុងកំណើតរស់ ១00.000នាក់។

**Multifiber arrangement (MFA)** កិច្ចព្រមព្រៀងពហុសរសៃអំបោះ ក៏ត្រូវបានស្គាល់ថាជាកិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌ និងសម្លៀកបំពាក់ (ATC) ដែលដឹកនាំពាណិជ្ជកម្មពិភពលោកលើផ្នែកវាយនភណ្ឌនិងការកាត់ដេរចាប់ពីឆ្នាំ ១៩៧៤ ដល់ ២០០៤ ដែលកំណត់កូតាលើបរិមាណ ដែលប្រទេសកំពុងអភិវឌ្ឍន៍អាចនាំចេញទៅប្រទេសជឿនលឿន។ កិច្ចព្រមព្រៀងនេះអស់សុពលភាពនៅថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៥។

**Most-favor-nations (MFN)** ប្រទេសទទួលការអនុគ្រោះពាណិជ្ជកម្ម គឺជាការប្តេជ្ញាដែលប្រទេសមួយនឹងពង្រីកទៅដល់ប្រទេសមួយទៀត នូវអត្រាពន្ធទាបបំផុត ដែលប្រទេសនោះអនុវត្តចំពោះប្រទេសណាមួយផ្សេងទៀត។ គ្រប់ប្រទេសជាសមាជិក WTO ព្រមព្រៀងអនុវត្តការអនុគ្រោះបែបនេះចំពោះប្រទេសមួយផ្សេងទៀត ទៅតាមមាត្រា ១ នៃ GATT។ នៅពេលពេលប្រទេសមួយ ព្រមព្រៀងកាត់បន្ថយអត្រាអន្ធលើផលិតផលណាមួយដែលនាំចូលពីប្រទេសមួយផ្សេងទៀត។ ការកាត់បន្ថយអត្រាពន្ធត្រូវអនុវត្តដោយស្វ័យប្រវត្តិចំពោះការនាំចូលផលិតផលនោះពីប្រទេសផ្សេងណាមួយ ដែលមានសិទ្ធិទទួលការអនុគ្រោះ។

**Newly industrializing economies (NIEs)** សេដ្ឋកិច្ចឧស្សាហូបនីយកម្មថ្មីៗ ជាពាក្យដែលមានប្រភពពីអង្គការ

សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ដែលបកស្រាយអំពីសេដ្ឋកិច្ចនៃប្រទេសតតិយលោក ដែលមានកំណើនសេដ្ឋកិច្ចឆាប់រហ័ស និងដែលអាចបកស្រាយថាជាសេដ្ឋកិច្ច "ចំណូលថ្នាក់កណ្ដាល"។ ពីដំបូងពាក្យនេះ សំដៅលើក្រុងហុងកុង សិង្ហបុរី សាធារណរដ្ឋកូរ៉េ និង តៃវ៉ាន់ ប៉ុន្តែច្រើនតែពង្រីកទៅប្រទេសដទៃទៀត។

**Outsourcing of business process** លទ្ធកម្មដំណើរការជំនួញ គឺជាការលើកកម្ពស់បច្ចេកវិទ្យារបស់ភាគីទីបី ឬអ្នកលក់ដំណើរការនៃអ្នកឯកទេស ដើម្បីផ្ដល់និងគ្រប់គ្រងដំណើរការសហគ្រាស និងការអនុវត្តរបស់អង្គការមួយ។ នៅក្នុងកិច្ចសន្យាទាំងនេះ អ្នកផ្គត់ផ្គង់ទទួលខុសត្រូវលើការអនុវត្ត និងគ្រប់គ្រងមុខងារឬដំណើរការជ្រើសរើសនោះក្នុងនាមអតិថិជន។ ជាទូទៅ កិច្ចសន្យាជ្រើសរើសដំណើរការជំនួញគឺអ្នកផ្គត់ផ្គង់ទទួលខុសត្រូវរួមលើដំណើរការនៃជំនួញ និងមិនគ្រាន់តែផ្ដល់កម្មវិធី IT ឬ សេវា ដើម្បីជម្រុញដំណើរការនេះតែប៉ុណ្ណោះទេ។ តាមរយៈលទ្ធកម្មដំណើរការនៃជំនួញ អ្នកលក់ផ្គត់ផ្គង់ និងគ្រប់គ្រងដំណើរការសហគ្រាសសំខាន់ៗ និង/ឬមិនសំខាន់របស់ក្រុមហ៊ុន ។ ឧទាហរណ៍ទូទៅបំផុតអំពីការចាត់ចែងបែបនេះ គឺជាមជ្ឈមណ្ឌលការី ធនធានមនុស្ស គណនេយ្យ និងការជ្រើសរើសគំរូនៃការទូទាត់កម្រៃ។ ការជ្រើសរើសដំណើរការជំនួញអាចទាក់ទងនឹងការប្រើប្រាស់ធនធាននៅក្រៅប្រទេស។

**Plant variety protection(PVP)** កិច្ចការពារពូជដំណាំមានន័យដូចគ្នានឹងសិទ្ធិពូជដំណាំ (PBR)។ នេះជាកិច្ចការពារតាមផ្លូវច្បាប់នៃពូជដំណាំថ្មីៗដែលត្រូវធ្វើឡើងសម្រាប់ពូជឬកូនចៅជំនាន់ក្រោយរបស់ពូជនោះ។ ទាក់ទងនឹង PBR ការចេញលិខិតអនុញ្ញាតគឺជាប្រការចាំបាច់មុនពេលដែលបំណែកនៃពូជរុក្ខជាតិនោះអាចត្រូវយកទៅប្រើប្រាស់សម្រាប់គោលដៅជំនួញ។

**Poverty gap** គម្លាតនៃភាពក្រីក្រ ផ្ដល់ព័ត៌មានអំពីថាតើការបរិភោគរបស់ប្រជាពលរដ្ឋក្រីក្រស្ថិតនៅឆ្ងាយបែបណាពីខ្សែបន្ទាត់នៃភាពក្រីក្រ ពោលគឺ ជម្រៅនៃភាពក្រីក្រ។ បើនិយាយតាមបែបបច្ចេកទេស វិធានការនេះបកស្រាយអំពីឱនភាពនៃការចំណាយ ឬគម្លាត។ តួលេខនេះ អាចគណនាបានដោយបូកបញ្ចូលគ្នានូវរាល់ឱនភាពរបស់ជនក្រីក្រ (ដោយមិនរាប់បញ្ចូលជនមិនមែនក្រីក្រ) ហើយចែកតួលេខសរុបនេះជាមួយចំនួនជនក្រីក្រ។ ដូច្នេះ គម្លាតនៃភាពក្រីក្រជារង្វាស់កង្វះខាងការបរិភោគក្នុងចំណោមប្រជាពលរដ្ឋ ឬធនធានដែលត្រូវការចាំបាច់ដើម្បីសង្គ្រោះជនក្រីក្រទាំងអស់ចេញពីភាពក្រីក្រ តាមរយៈការផ្ទេរសាច់ប្រាក់ដោយផ្ដោតទៅរកគោលដៅបានយ៉ាងត្រឹមត្រូវ។

**Preferential treatment** សិទ្ធិទទួលការអនុគ្រោះ សំដៅលើការអនុគ្រោះខាងផ្នែកពាណិជ្ជកម្ម ដែលជាយូរមកហើយត្រូវបានប្រើប្រាស់ជាបរិធាននៃគោលនយោបាយបរទេស និងជំនួញ ដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើតឱ្យមានទំនាក់ទំនងកាន់តែជិតស្និទ្ធ ទាំងខាងសេដ្ឋកិច្ច និង នយោបាយ រវាងប្រទេសដែលពាក់ព័ន្ធ។ សិទ្ធិទទួលការអនុគ្រោះពីប្រទេសជឿនលឿនលើការនាំចូលពីប្រទេសកំពុងអភិវឌ្ឍន៍បានក្លាយជាធាតុដ៏រឹងមាំនៃគោលនយោបាយដែលផ្ដោតលើការអភិវឌ្ឍ។ របបដែលមានស្រាប់ខុសៗគ្នានៃការអនុគ្រោះខាងពាណិជ្ជកម្មសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍អាចត្រូវបានចែកជាបីក្រុមធំៗគឺ (i) ប្រព័ន្ធអនុគ្រោះទូទៅ (GSP) (ii) របបអនុគ្រោះពិសេសសម្រាប់ក្រុមប្រទេសកំពុងអភិវឌ្ឍន៍ និង (iii) ការចាត់ចែងពាណិជ្ជកម្មសេរីប្រចាំតំបន់រវាងប្រទេសជឿនលឿនណាមួយជាមួយក្រុមណាមួយនៃប្រទេសកំពុងអភិវឌ្ឍន៍។

**Regional integration** សមាហរណកម្មថ្នាក់តំបន់ សំដៅលើព័ត៌មានអំពីចំណងទាក់ទងសេដ្ឋកិច្ចកាន់តែជិតស្និទ្ធក្នុងចំណោមបណ្តាប្រទេសដែលស្ថិតនៅក្នុងភូមិសាស្ត្រជិតគ្នា ជាពិសេសតាមរយៈការបង្កើតកិច្ចព្រមព្រៀងអនុគ្រោះខាងពាណិជ្ជកម្ម។

**Small-island developing states (SIDs)** រដ្ឋកំពុងអភិវឌ្ឍន៍នៅលើកោះតូចៗ រួមមានប្រទេសនៅតំបន់ទំនាបឆ្នេរសមុទ្រ ដែលប្រឈមនឹងការលំបាកដូចគ្នានៃការអភិវឌ្ឍដោយចីរភាព រួមទាំងមានប្រជាជនចំនួនតិច ខ្វះធនធាន ស្ថិតនៅដាច់ស្រយាល ងាយខូចខាតដោយគ្រោះធម្មជាតិ ពឹងផ្អែកខ្លាំងហួសហេតុលើពាណិជ្ជកម្មអន្តរជាតិ និងភាពងាយរងគ្រោះចំពោះការអភិវឌ្ឍសកល។ លើសពីនេះ ប្រទេសទាំងនេះរងគ្រោះដោយសារខ្វះសេដ្ឋកិច្ចទ្រង់ទ្រាយធំ ការចំណាយខ្ពស់លើការដឹកជញ្ជូនគមនាគមន៍ ការចំណាយខ្ពស់លើរដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

**Special and differentil treatment** ការយកចិត្តទុកដាក់ពិសេសនិងខុសគ្នា គឺជាគោលការណ៍នៅក្នុង WTO ដែលប្រទេសកំពុងអភិវឌ្ឍន៍ បានទទួលការអនុគ្រោះពិសេស ឬមួយដោយលើកលែងប្រទេសទាំងនោះពីបទបញ្ញាខ្លះៗរបស់ WTO និងផ្តល់ការអនុគ្រោះពិសេសដល់ប្រទេសទាំងនោះនៅក្នុងការអនុវត្តបទបញ្ញា WTO ។

**Tax-to-GDP ratio** អនុបាតពន្ធ-GDP សំដៅលើពន្ធ និងការរួមវិភាគទានចំពោះសន្តិសុខសង្គម គិតជាភាគរយនៃ GDP ។ សូចនាករនេះត្រូវបានប្រើប្រាស់ទូលំទូលាយ ដើម្បីវាស់បន្ទុកពន្ធទូទៅ។

**Total factor productivity (TFP)** កត្តាផលិតភាពសរុប ច្រើនតែសំដៅទៅលើ "សំណល់តែឯង" (Solo residual) ដែលសំដែងអំពីឥទ្ធិពលណាមួយគិតជាផលសរុបដែលមិនមែនកើតឡើង ដោយសារធាតុចូល ឬផលិតភាព។ មុខងារផលិតកម្មស្តង់ដារ Cobb-Douglas: $Y = AK^{a}L^{1-a}$

ដែល Y តំណាងឱ្យលទ្ធផលសរុបជាអនុគមន៍នៃផលិតភាពនៃកត្តាសរុប (A), មូលធនដែលប្រើប្រាស់ (K), កម្លាំងកម្មករដែលត្រូវប្រើប្រាស់ (L), និងសមាមាត្រនៃផលិតផលដែលត្រូវគ្នានឹងធាតុចូលទាំងពីរនេះ។ កំណើនបច្ចេកវិទ្យា និងប្រសិទ្ធភាពត្រូវបានចាត់ទុកថាជាកត្តាសំខាន់ជាងគេចំនួនពីរដែលមានឥទ្ធិពលទៅលើ TFP ដែលជាតួខាងដើម ផ្សំដោយទិដ្ឋភាពដែលពាក់ព័ន្ធ"ពិសេស" ដូចជា កត្តាវិជ្ជមានពីខាងក្រៅ និងភាពគ្មានការប្រកួតប្រជែង ដែលពង្រឹងស្ថានភាពរបស់ខ្លួនឱ្យទៅជាកម្លាំងជម្រុញកំណើនសេដ្ឋកិច្ច។ TFP ត្រូវបានមើលឃើញថាជាកម្លាំងដឹកនាំជាក់ស្តែងនៃកំណើននៅក្នុងសេដ្ឋកិច្ចមួយ ហើយការសិក្សានានាបង្ហាញថា នៅពេលដែលពលកម្ម និងការវិនិយោគនៅជាវិភាគទានសំខាន់ TFP រួមចំណែករហូតដល់ ៦0% នៃកំណើននៅក្នុងសេដ្ឋកិច្ច។

**Trade diversion** ការបង្វែរពាណិជ្ជកម្ម កើតមានឡើងនៅពេលវិធានការកំណែទម្រង់ពាណិជ្ជកម្មមានការរើសអើងរវាងដៃគូពាណិជ្ជកម្មខុសគ្នា ហើយប្រភពដែលពុំសូវមានប្រសិទ្ធភាព (ការចំណាយខ្ពស់ជាង) បានជំនួសប្រភពដែលមានប្រសិទ្ធភាពជាង (ចំណាយតិចជាង)។ វាអាចកើតមានឡើងនៅពេលអ្នកផ្គត់ផ្គង់ខ្លះដែលទទួលការអនុគ្រោះអាចរួចពីរបាំងនានាចំណែកអ្នកដទៃទៀតពុំអាច។

**Tradable goods** ទំនិញដែលអាចធ្វើពាណិជ្ជកម្មបានជាទំនិញដែលមានសក្តានុពលសម្រាប់ការនាំចេញនិងនាំចូល។ លទ្ធភាពដែលទំនិញទាំងនោះអាចត្រូវបានធ្វើពាណិជ្ជកម្មទៅក្រៅប្រទេស គឺជាផលធៀបរវាងថ្លៃទំនិញទាំងនោះជាមួយ

ថ្លៃទំនិញដែលជាគូប្រកួតនៅក្រៅប្រទេស។

**Trade liberalization** សេរីភាវូបនីយកម្មពាណិជ្ជកម្ម គឺជាការលុបចោលរបាំងចំពោះពាណិជ្ជកម្មសេរី ដូចជា តារាងពន្ធ កូតា អត្រាគោល និងអត្រាជាក់ស្តែងនៃកិច្ចការពារនិងត្រួតត្រាការប្តូរប្រាក់។

**Trade Related Investment Measures (TRIMs)** វិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម គឺជាកិច្ចព្រមព្រៀងមួយបែបដែលមានចែងនៅក្នុងឧបសម្ព័ន្ធ AI នៃកិច្ចព្រមព្រៀង Marrakech ដែលបានចុះហត្ថលេខានៅចុងនៃការចរចានៅប្រទេសអ៊ុរ៉ាហ្គាយ។ កិច្ចព្រមព្រៀងនេះ ចែងពីវិធានការនានានៃការវិនិយោគដែលទាក់ទងនឹងពាណិជ្ជកម្ម និងដែលរំលោភផងដែរទៅលើមាត្រា ៣ (ការយកចិត្តទុកដាក់របស់ជាតិ) ឬមាត្រា ១០ (ការលុបចោលជាទូទៅនៃរបាំងបរិមាណ) នៃកិច្ចព្រមព្រៀងទូទៅស្តីពី តារាងពន្ធ និងពាណិជ្ជកម្ម។

**Trade-Related Aspects of Intellectual Property Rights (TRIPS)** វិធានពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា គឺជាសន្ធិសញ្ញាអន្តរជាតិនៅក្រោម WTO ដែលកំណត់ស្តង់ដារអប្បរមានៃទ្រព្យខាងបញ្ញា សម្រាប់គ្រប់ផលិតផល និងសេវាដែលគ្របដណ្តប់សិទ្ធិថតចម្លង សញ្ញាពាណិជ្ជកម្ម កំណត់សម្គាល់ភូមិសាស្ត្រ គម្រូប្លង់ឧស្សាហកម្ម សៀគ្វីចម្រុះ ប៉ាតង់ និងការសម្ងាត់ខាងពាណិជ្ជកម្ម។

**Trade-to-GDP ratio** អនុបាតពាណិជ្ជកម្មជាមួយ GDP គឺជាផលបូកនៃការនាំចូលនិងការនាំចេញគិតជាសមាមាត្រនៃ GDP ។

**Value added tax** ពន្ធលើតម្លៃបន្ថែម ស្រដៀងគ្នានឹងពន្ធលើការលក់ត្រង់ថាត្រូវបានដាក់ឱ្យអនុវត្តនៅពេលលក់ទំនិញនិងសេវា។ នៅក្នុងប្រទេសខ្លះ រួមទាំងអូស្ត្រាលី កាណាដា នូវែលហ្សេឡង់ និងសិង្ហបូរី ពន្ធត្រូវបានគេស្គាល់ថាជា "ពន្ធលើទំនិញនិងសេវា" ឬ GST ហើយនៅក្នុងប្រទេសជប៉ុនត្រូវបានគេស្គាល់ថាជា "ពន្ធលើការប្រើប្រាស់" ។ VAT គឺជាពន្ធប្រយោល ដោយសារពន្ធនេះត្រូវបានយកពីបុគ្គលនានាផ្សេងពីបុគ្គលដែលត្រូវទទួលរងការចំណាយលើពន្ធ (ពោលគឺអ្នកលក់ជាជាងអតិថិជន)។

**Venture Capital Fund** មូលនិធិវិនិយោគរួម គឺជាមធ្យោបាយនៃការវិនិយោគរួមគ្នា (ច្រើនតែជាដៃគូ) ដែលច្រើនតែវិនិយោគមូលធនហិរញ្ញវត្ថុរបស់វិនិយោគិន ដែលជាភាគីទីបីនៅក្នុងសហគ្រាសដែលមានហានិភ័យខ្ពស់សម្រាប់ទីផ្សារមូលធនស្តង់ដារ ឬកម្ចីពីធនាគារ។

## ដំណឹងពី APRI ផ្នែកអភិវឌ្ឍន៍មនុស្ស RCC

**អាហារូបករណ៍អភិវឌ្ឍន៍មនុស្សរបស់ UNDP ឆ្នាំ ២០០៦**

**ការសិក្សាទ្រឹស្តី**

*គោលបំណង* : លើកទឹកចិត្តនិស្សិតក្មេងៗថ្នាក់បណ្ឌិត ដើម្បីធ្វើការវិភាគបញ្ហាអភិវឌ្ឍន៍ទៅតាមទស្សនៈទាននៃការអភិវឌ្ឍមនុស្ស ដែលរួមវិភាគទានចំពោះការស្រាវជ្រាវទំនើបលើទ្រឹស្តី ការអនុវត្ត និងគោលនយោបាយ ។

*សម្រាប់អ្នកណា* : និស្សិតថ្នាក់បណ្ឌិតពីអាស៊ី-ប៉ាស៊ីហ្វិក នៅដំណាក់កាលសរសេរបរមាធិប្បាយរបស់ខ្លួន ។

**ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន**

*គោលបំណង* : គាំទ្រការតស៊ូមតិអំពីគោលនយោបាយ និងការប្រាស្រ័យទាក់ទងលើការស្រាវជ្រាវ ដើម្បីធ្វើឱ្យមនុស្សក្លាយជាស្នូលនៃកង្វល់អំពីការអភិវឌ្ឍ ។

**ប្រធានបទពីមុននៃ HDRs នៅអាស៊ី-ប៉ាស៊ីហ្វិក**

2005: Promoting ICT for Human Development in Asia 2004: Realizing the Millennium Development Goals
2003: HIV/AIDS and Developmen in South Asia

**Other Publications Relating to MDGs and Human Development**

2006: Pursuing Gender Equality through the MDGs in Asia and the Pacific (with ADB and UNSCAP). Technical paper.
2006: Asia Water Watch 2015: Are Countries in Asia on Track to Meet Taeger 10 of the Millennium Development Goals? (with ADB, UNSCAP and WHO) . Technical Paper.
2005: A Future within Reach: Reshaping Institutions in a Region of Disparities to Meet the Millennium Development Goals in Asia and the Pacific) with ADB and UNSCAP). Regional MDG Report.
2005: Voices of the Least Developed Countries of Asia nad the Pacific: Achieving yhe Millinnium Development Goals Through a Global Partnership (with UNSCAP). Thematic Report and Video.
2004: ICT for Human Development: Towards Building a Composite Index for Asia. Technical Paper.

**Tools**

2005: Cracking the HDI: Humand Development Indexing Exercise
2005: Surviving the Publications Process: Prepkit for Publications
2005: From Development to Humand Development: Tool for Examining Themes from a Humand Development Perspectve
2005: Tool for Credit Rating of Micro Credit Recipients

ចំពោះព័ត៌មានបន្ថែមសូមអានក្នុង http: www.undprcc.lk

UNDP

# របាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សប្រចាំតំបន់ ឆ្នាំ ២០០៦

តំបន់អាស៊ី-ប៉ាស៊ីហ្វិកកំពុងស្ថិតនៅជួរមុខនៃសាកលភាវូបនីយនីយកម្ម ហើយកំពុងតែចរាចរទំនិញប្រទាក់ខ្វាត់ខ្វែងក្នុងតំបន់។ ការរីកចម្រើននេះកើតឡើងមិនត្រឹមតែចំពោះទំនិញប៉ុណ្ណោះទេ រីឯផ្នែកសេវាកម្មក៏បានរីកចម្រើនផងដែរ ពោលគឺចាប់ពីក្រុងបាងកាល័ររហូតដល់ក្រុងម៉ានីលមានបុគ្គលិករាប់សែននាក់កំពុងតែជួយអតិថិជននិងភ្ញៀវនៅអឺរ៉ុប សហរដ្ឋអាមេរិកឬជប៉ុន ហាក់បីដូចជាពួកគេកំពុងអង្គុយក្នុងការិយាល័យមួយនៅជិតអតិថិជនទាំងនោះអញ្ចឹង។ ហើយកាលណាសេវាកម្មមិនអាចបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិកបានបុគ្គលិកផ្តល់សេវាធ្វើដំណើរតាមអាកាសយានឆ្លងកាត់តំបន់ និងមហាសមុទ្រដើម្បីបម្រើការងារជាអ្នកបម្រើតាមគេហដ្ឋាន ឬ គិលានុបដ្ឋាយិកា កម្មករសំណង់ ឬវិស្វករសំណង់។ ដូច្នេះ តំបន់អាស៊ីប៉ាស៊ីហ្វិកមិនត្រឹមតែកំពុងក្លាយទៅជាថ្នាលបណ្តុះធនធានប៉ុណ្ណោះទេប៉ុន្តែថែមទាំងជាសេនាធិការគាំទ្រនៃពិភពលោកទៀតផង។

តើបញ្ហាទាំងនេះមានផលប៉ះពាល់អ្វីលើជីវិតមនុស្ស លើឱកាសការងារ លើប្រាក់ចំណូល លើតម្លៃនៃជីវិតរបស់គេ លើប្រការដែលថាតើពួកគេជាអ្នកណា និងថាតើពួកគេនឹងក្លាយទៅជាអ្វី? និយាយដោយសង្ខេប តើបញ្ហានេះមានន័យដូចម្តេចចំពោះការអភិវឌ្ឍមនុស្ស? ហើយដោយពិនិត្យមើលបញ្ហានេះ តាមទស្សនវិស័យផ្សេង តើការអភិវឌ្ឍមនុស្សតាមស្តង់ដារកម្រិតខ្ពស់អាចរួមវិភាគទានអ្វីខ្លះដល់ការពង្រីកពាណិជ្ជកម្មនិងកំណើនសេដ្ឋកិច្ច?

របាយការណ៍នេះឆ្លើយតបទៅនឹងសំណួរទាំងនេះ ដោយចេញពីផ្នែកក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។ របាយការណ៍នេះបានគូសបញ្ជាក់ថា ពាណិជ្ជកម្មពិតជាអាចលើកកម្ពស់ការអភិវឌ្ឍមនុស្ស ប៉ុន្តែវាក៏អាចរារាំងការអភិវឌ្ឍមនុស្សផងដែរ។ ការខិតខំនាំចេញនិងនាំចូលទំនិញ និងសេវាបន្ថែម ជាទូទៅនាំឱ្យមានដំណើរការដ៏ស្មុគស្មាញ និងប្រកបដោយថាមភាពមួយដែលធ្វើឱ្យមានអ្នកឈ្នះនិងអ្នកចាញ់។ តើរដ្ឋាភិបាលត្រូវឆ្លើយតបដោយវិធីណា? របាយការណ៍នេះបញ្ចប់ដោយដាក់ចេញនូវរបៀបវារៈដ៏ចម្បងចំនួនប្រាំបីចំណុចដើម្បីធានាឱ្យពាណិជ្ជកម្មអន្តរជាតិអាចជួយដល់ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ការអភិវឌ្ឍមនុស្សគ្រប់រូប។

របាយការណ៍នេះត្រូវបានចងក្រងឡើងដោយក្រុមចម្រុះជាតិសាសន៍ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់នៃផ្នែកត្រួតពិនិត្យមើលការអភិវឌ្ឍមនុស្សរបស់ការិយាល័យប្រចាំតំបន់របស់អង្គការយូអិនឌីភី នៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា។ ការិយាល័យប្រចាំតំបន់នៅទីក្រុងកូឡុំបូត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៥ ដើម្បីបម្រើការដល់ប្រទេសនានានៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ហើយដើរតួនាទីជាបណ្តាញថ្នាក់តំបន់សម្រាប់ការអភិវឌ្ឍចំណេះដឹងនិងជំនាញ ដោយផ្តល់នូវការប្រឹក្សាគោលនយោបាយ ការអភិវឌ្ឍសមត្ថភាព និងសេវាកម្មផ្សព្វផ្សាយ ដែលបណ្តុះនូវការច្នៃប្រឌិតដល់ការិយាល័យអង្គការយូអិនឌីភីប្រចាំប្រទេសនានា រដ្ឋាភិបាល និងសង្គមស៊ីវិលនៅក្នុងតំបន់។ ការិយាល័យប្រចាំតំបន់នៅទីក្រុងកូឡុំបូមានឯកទេសលើផ្នែកកាត់បន្ថយភាពក្រីក្រ មេរោគអេដស៍ និងការអភិវឌ្ឍដោយបញ្ចូលបញ្ហាសមភាពយេនឌ័រជាបញ្ហារួម។

ការិយាល័យប្រចាំតំបន់របស់អង្គការយូអិនឌីភីនៅទីក្រុងកូឡុំបូ រុក្ខវិថីឯករាជ្យ ២៣ កូឡុំបូ ៧ ស្រីលង្កា
ទូរស័ព្ទ:+ ៩៤ ១១ ៤៥២៦ ៤០០ ទូរសារ:+ ៩៤ ១១ ៤៥២៦ ៤១០ www.undprcc.ik

ISBN 1403 000000

library.ncdd.gov.kh
014652

MACMILLAN
Macmillan India Ltd.
www.macmillanindia.com